# ព្រះ
# ត្រៃបិដកបាលី
នឹង
## សេចក្ដីប្រែជាភាសាខ្មែរ
## សុត្តន្តបិដក
## ខុទ្ទកនិកាយ ជាតក
## អដ្ឋមភាគ
## ៥៨

សុត្តន្តបិដក
ខុទ្ទកនិកាយ ជាតក
អដ្ឋមភាគ
៥៨

ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

ព.ស. ២៥១៦

សុត្តន្តបិដកេ

ខុទ្ទកនិកាយស្ស ជាតកំ

អដ្ឋមោ ភាគោ

---

## បញ្ចកនិបាតជាតកំ

## មណិកុណ្ឌលវគ្គោ

## មណិកុណ្ឌលជាតកំ

(១) ជិន្នោ រដ្ឋស្សមណិកុណ្ឌលេ ច
បុត្តេ ច ទារេ ច តថេវ ជិន្នោ
សព្វេសុ ភោគេសុ អសេសកេសុ
កស្មា ន សន្តប្បសិ សោកកាលេ ។

(២) បុព្វេវ មច្ចំ វិជហន្តិ ភោគា
មច្ចោ វា តេ បុព្វតរំ ជហាតិ
អសស្សតា ភោគិនោ កាមកាមិ
តស្មា ន សោចាមហំ សោកកាលេ ។

សុត្តន្តបិដក

ខុទ្ទកនិកាយ ជាតក

អដ្ឋមភាគ

---

## បញ្ចកនិបាតជាតក

## មណិកុណ្ឌលវគ្គ

## មណិកុណ្ឌលជាតក

(១) (ព្រះរាជាកោសលពោលថា) ព្រះអង្គសាបសូន្យរាជ្យផង សេះ កែវមណី និងកុណ្ឌល សាបសូន្យរាជបុត្រនិងភរិយា ដូច្នោះដែរ កាលបើភោគៈទាំងអស់ មិនមានសេសសល់ទេ ហេតុអ្វីទើបព្រះអង្គមិនក្តៅក្រហាយ ក្នុងកាលដែលគួរសោកស្តាយ ។

(២) (ព្រះរាជាពោធិសត្វពោលថា) ភោគៈទាំងឡាយលះបង់សត្វមុនក៏មាន សត្វលះបង់ភោគៈទាំងនោះមុនក៏មាន បពិត្រព្រះអង្គទ្រង់ប្រាថ្នាកាម ជនអ្នកមានភោគៈទាំងឡាយ មិនទៀងទេ ព្រោះហេតុនោះ ទើបខ្ញុំមិនសោកស្តាយ ក្នុងកាលដែលគួរសោកស្តាយ ។

(៣) ឧទេតិ បូរេតិ ខិយតិ ចន្ទោ
អត្ថង្គមេត្វាន បលេតិ សូរិយោ
វិទិតា មយា សត្តុក លោកធម្មា
តស្មា ន សោចាមហំ សោកកាលេ ។

(៤) អលសោ គិហី កាមភោគី ន សាធុ
អសញ្ញតោ បព្វជិតោ ន សាធុ
រាជា ន សាធុ អនិសម្មការី
យោ បណ្ឌិតោ កោធនោ តំ ន សាធុ ។

(៥) និសម្ម ខត្តិយោ កយិរា នានិសម្ម ទិសម្បតិ
និសម្មការិនោ រញ្ញោ(១) យសោ កិត្តិ ច វឌ្ឍតីតិ ។

មណិកុណ្ឌលជាតកំ បឋមំ ។

## សុជាតជាតកំ

(៦) កិន្នុ សន្តរមានោវ លាយិត្វា ហរិតំ តិណំ
ខាទ ខាទាតិ លបសិ គតសត្តំ ជរគ្គវំ
នហិ អន្នេន បានេន មតោ គោណោ សមុដ្ឋហេ
ត្វញ្ច តុច្ឆំ វិលបសិ យថាតំ ទុម្មតី តថា ។

១ ម. រញ្ញំ ។



(៣) ព្រះចន្ទ្រតែងតែរះឡើង ពេញវង់ រួចអស់ទៅ ព្រះអាទិត្យក៏អស្តង្គត
ទៅដូចគ្នា បពិត្រស្តេចជាសត្រូវ ពួកលោកធម៌ ខ្ញុំដឹងហើយ ព្រោះ
ហេតុនោះ ទើបខ្ញុំមិនសោកស្តាយ ក្នុងកាលដែលគួរសោកស្តាយ ។

(៤) គ្រហស្ថអ្នកបរិភោគកាម ជាអ្នកខ្ជិលច្រអូស មិនល្អ បព្វជិត
មិនសង្រួម មិនល្អ ព្រះរាជាមិនបានពិចារណាមុន ហើយធ្វើ មិនល្អ
បណ្ឌិតអ្នកច្រើនក្រោធ មិនល្អទេ ។

(៥) បពិត្រព្រះអង្គជាម្ចាស់នៃទិស ក្សត្រិយ៍គប្បីពិចារណា ហើយ
សឹមធ្វើ មិនគប្បីធ្វើទាំងមិនបានពិចារណាទេ យសក្តី កិត្តិ-
គុណក្តី រមែងចំរើនដល់ព្រះរាជា ដែលពិចារណាហើយទើបធ្វើ ។

ចប់ មណិកុណ្ឌលជាតក ទី ១ ។

## សុជាតជាតក

(៦) (បិតារបស់ពោធិសត្វពោលថា) អ្នករលះរលាំងទៅច្រូតស្មៅ
ស្រស់ ហើយនិយាយនឹងគោចាស់ ដែលមានជីវិតបាត់បង់ទៅ
ហើយថា ឯងស៊ីទៅ ឯងស៊ីទៅ ដូចម្តេចកើត គោស្លាប់ហើយ
មិនគប្បីក្រោកឡើងបាន ព្រោះគ្រឿងស៊ីនិងគ្រឿងផឹកទេ អ្នក
រវើរវាយទទេ ដូចជាមនុស្សល្ងង់ខ្លៅ ។

(៧) តថេវ តិដ្ឋតិ សីសំ ហត្ថបាទា ច វាលធិ
សោតា តថេវ តិដ្ឋន្តិ មញ្ញេ គោណោ សមុដ្ឋហេ
នេវយ្យកស្ស សីសំ ច ហត្ថបាទា ច ទិស្សរេ
រុទំ មត្តិកថូបស្មឹ ននុ ត្វញ្ញេវ ទុម្មតិ ។

(៨) អាទិត្តំ វត មំ សន្តំ ឃតសិត្តំវ បាវកំ
វារិនា វិយ ឱសិញ្ចំ សព្វំ និព្វាបយេ ទរំ
អព្វហី វត មេ សល្លំ សោកំ ហទយនិស្សិតំ
យោ មេ សោកបរេតស្ស បិតុសោកំ អបានុទិ ។

(៩) ស្វាហំ អព្វូឡ្ហសល្លោស្មិ វីតសោកោ អនាវិលោ
ន សោចាមិ ន រោទាមិ តវ សុត្វាន មាណវ ។

(១០) ឯវំ ករោន្តិ សប្បញ្ញា យេ ហោន្តិ អនុកម្បកា
វិនិវត្តេន្តិ សោកម្ហា សុជាតោ បិតរំ យថា ។

សុជាតជាតកំ ទុតិយំ ។



(៧) (សុជាតមាណពជាបុត្រពោលថា) ក្បាលក៏តាំងនៅដដែល ដៃជើងកន្ទុយនិងត្រចៀក ក៏តាំងនៅដដែលដែរ ខ្ញុំសំគាល់ថា គោនៅក្រោកឡើងបាន ក្រែងក្បាលដៃជើងរបស់ជីតា មិនប្រាកដទេ ឪពុកយំខ្ទួញជិតស្តូប ដែលធ្វើដោយដីស្អិត មិនមែនជាអ្នកល្ងង់ខ្លៅទេឬ ។

(៨) (បិតាពោលថា) អ្នកបានស្រោចស្រប់ខ្ញុំ ដែលក្តៅនឹងសេចក្តីសោកក្តៅនេះ ឲ្យស្ងប់រម្ងាប់ ញុំាងសេចក្តីក្រវល់ក្រវាយទាំងអស់ឲ្យរលត់ ដូចបុគ្គលស្រោចភ្លើង ដែលគេចាក់ទឹកខ្លាញ់ ដោយទឹក សរ គឺសេចក្តីសោក ដែលអាស្រ័យនូវហឫទ័យរបស់យើង អ្នកដកចេញហើយ អ្នកបានបន្ទោបង់ នូវសេចក្តីសោកគឺបិតា នៃយើង ដែលមានសេចក្តីសោកបៀតបៀនហើយ ។

(៩) ខ្ញុំនោះមានសរដកចេញហើយ ជាអ្នកប្រាសចាកសេចក្តីសោក មានចិត្តមិនល្អក់ ម្នាលមាណព ខ្ញុំលែងសោក លែងយំ ព្រោះបានស្តាប់ពាក្យរបស់អ្នក ។

(១០) ពួកជនណា ប្រកបដោយប្រាជ្ញា ជាអ្នកអនុគ្រោះ (ដោះទុក្ខ) រមែងធ្វើយ៉ាងនេះ រមែងដោះ (បុគ្គលដទៃ) ចេញចាកសេចក្តីសោក ដូចសុជាតមាណពដោះបិតាចាកសេចក្តីទុក្ខសោក ។

ចប់ សុជាតជាតក ទី ២ ។

## ធោនសាខជាតកំ

(១១) នយិទំ និច្ចំ ភវិតព្វំ ព្រហ្មទត្ត
ខេមំ សុភិក្ខំ សុខតា ច កាយេ
អត្ថច្ចយេ មា អហុ សម្បមូឡ្ហោ
ភិន្នប្លវោ សាគរស្សេវ មជ្ឈេ ។

(១២) យានិ ករោតិ បុរិសោ តានិ អត្តនិ បស្សតិ
កល្យាណការី កល្យាណំ បាបការី ច បាបកំ
យាទិសំ វបតេ ពីជំ តាទិសំ ហរតេ ផលំ ។

(១៣) ឥទំ តទាចរិយវចោ បារាសរិយោ(១) យទព្រវិ
មាស្សុ ត្វំ អករិ បាបំ យំ ត្វំ បច្ឆា កតំ តបេ ។

---

១ ម. បោរាណាសិយោ ។





## ធោនសាខជាតក

(១១) (តាំងពីនេះទៅ ពោធិសត្វពោលថា) ម្នាលព្រហ្មទត្តកុមារ សេចក្តីក្សេមក្សាន្តក្តី ភិក្ខាធិសម្បត្តិក្តី សេចក្តីសុខ ក្នុងកាយក្តី នេះ មិនមែនមានជានិច្ចទេ (កាលបើវត្ថុកើតវិនាស) ក្នុងកាលជាទីកន្លងនៃប្រយោជន៍ អ្នកកុំវង្វេងវង្វាន់ ដូចបុគ្គលដែលបែកក្បាន នៅកណ្តាលសាគរ ។

(១២) បុរសធ្វើនូវអំពើទាំងឡាយណា រមែងឃើញ នូវអំពើនោះ ក្នុងខ្លួនវិញ បុរសអ្នកធ្វើល្អ រមែងបានផលល្អ អ្នកធ្វើអាក្រក់ រមែងបានផលអាក្រក់ បុរសអ្នកសាបព្រោះពូជ បែបណា ផលបែបនោះ ក៏រមែងដុះឡើង ។

(១៣) (ស្តេចព្រហ្មទត្តពោលថា) អាចារ្យបារាសរិយគោត្រ បាន ពោលនូវពាក្យណា នេះជាពាក្យ របស់អាចារ្យនោះថា បាប ណា ដែលអ្នកធ្វើហើយ គប្បីក្តៅក្រហាយ ក្នុងកាលជាខាង ក្រោយ អ្នកកុំធ្វើបាបនោះឡើយ ។

(១៤) អយមេវ សោ បិង្គិយោ ធោនសាខោ
យម្ហិ ឃាតយឹ ខត្តិយានំ សហស្សំ
អលង្កតេ ចន្ទនសារលិត្តេ
តមេវ ទុក្ខំ បច្ចាគតំ មមំ ។
(១៥) សាមា ច ខោ ចន្ទនលិត្តគត្តី
លដ្ឋីវ សោភញ្ជនកស្ស ឧគ្គតា
អទិស្វា កាលំ ករិស្សាមិ ឧព្ពរឹ
តំ មេ ឥតោ ទុក្ខតរំ ភវិស្សតិ ។

ធោនសាខជាតកំ តតិយំ ។

## ឧរគជាតកំ

(១៦) ឧរគោវ តចំ ជិណ្ណំ ហិត្វា គច្ឆតិ សន្តនុំ
ឯវំ សរីរេ និព្ភោគេ បេតេ កាលកតេ សតិ
ឌយ្ហមានោ ន ជានាតិ ញាតីនំ បរិទេវិតំ
តស្មា ឯតំ ន សោចាមិ គតោ សោ តស្ស យា គតិ ។



(១៤) ខ្ញុំនឹងបិង្គិយបុរោហិត សម្លាប់ខ្សត្រិយ៍មួយពាន់នាក់ ដែលប្រដាប់ លាប ដោយខ្លឹមចន្ទន៍ ទៀបដើមឈើណា ដើមឈើនេះឯង ជាដើមជ្រៃមានមែកត្រសាយត្រសុំ (មិនអាចជួយអញបាន) សេចក្តីទុក្ខនោះឯងត្រឡប់មកត្រូវខ្ញុំវិញ ។

(១៥) (អគ្គមហេសីរបស់ខ្ញុំ) ឈ្មោះនាងឧព្វរី មានខ្លួនលាបដោយខ្លឹមចន្ទន៍ មានសម្បុរដូចមាស ស្រលូនស្រឡៅ ដូចជាលំពង់ឈើម្រុំ ត្រូវខ្យល់បក់ល្អ ខ្ញុំមិនបានឃើញនាងឧព្វរី នឹងធ្វើមរណកាល ការមិនបានឃើញនាងឧព្វរីនោះ ជាទុក្ខដ៏លើសលុបដល់ខ្ញុំ ជាងទុក្ខព្រោះសេចក្តីស្លាប់នេះទៅទៀត ។

ចប់ ធោនសាខជាតក ទី ៣ ។

## ឧរគជាតក

(១៦) (ព្រាហ្មណ៍ពោធិសត្វពោលថា) កូនរបស់ខ្ញុំ លះបង់នូវសរីរៈ ហើយទៅ ដូចជាពស់ លះបង់នូវសំណកចាស់ កាលបើសរីរៈប្រើប្រាស់មិនបាន ធ្វើកាលកិរិយា ទៅកាន់លោកខាងមុខ យ៉ាងនេះ ក៏កាយ កាលត្រូវគេដុត រមែងមិនដឹងនូវសេចក្តីខ្សឹកខ្សួល នៃញាតិទាំងឡាយ ព្រោះហេតុនោះ ទើបខ្ញុំមិនសោកស្តាយ ចំពោះកូននុ៎ះ គតិណាជារបស់គេ គេក៏ទៅកាន់គតិនោះ ។

(១៧) អនព្ហិតោ តតោ អាគា អននុញ្ញាតោ ឥតោ គតោ
យថា គតោ តថា គតោ តត្ថ កា បរិទេវនា
ឌយ្ហមានោ ន ជានាតិ ញាតីនំ បរិទេវិតំ
តស្មា ឯតំ ន សោចាមិ គតោ សោ តស្ស យា គតិ ។

(១៨) សចេ រោទេ កិសា អស្សំ តស្សា មេ កឹ ផលំ សិយា
ញាតិមិត្តសុហជ្ជានំ ភិយ្យោ នោ អរតី សិយា
ឌយ្ហមានោ ន ជានាតិ ញាតីនំ បរិទេវិតំ
តស្មា ឯតំ ន សោចាមិ គតោ សោ តស្ស យា គតិ ។

(១៩) យថាបិ ទារកោ ចន្ទំ គច្ឆន្តំ អនុរោទតិ
ឯវំ សម្បទមេវេតំ យោ បេតមនុសោចតិ
ឌយ្ហមានោ ន ជានាតិ ញាតីនំ បរិទេវិតំ
តស្មា ឯតំ ន សោចាមិ គតោ សោ តស្ស យា គតិ ។



(១៧) (នាងព្រាហ្មណីពោលថា) កូន (របស់ខ្ញុំ) ដែលមកអំពីបរលោក ខ្ញុំក៏មិនបានអញ្ជើញ គេទៅអំពីលោកនេះ ក៏ខ្ញុំមិនអនុញ្ញាត គេមកយ៉ាងណា គេក៏ទៅយ៉ាងនោះ ខ្សឹកខ្សួលធ្វើអ្វី ព្រោះការដែលគេទៅនោះ កងកាយកាលត្រូវគេដុត រមែងមិនដឹងនូវសេចក្តីខ្សឹកខ្សួលនៃញាតិទាំងឡាយទេ ព្រោះហេតុនោះ ទើបខ្ញុំមិនសោកនឹងកូននុ៎ះ គតិណាជារបស់គេ គេក៏ទៅកាន់គតិនោះ ។

(១៨) (នាងព្រាហ្មណីជាប្អូនពោលថា) បើខ្ញុំយំ ខ្ញុំនឹងស្គាំងស្គម កាលខ្ញុំនោះយំខ្ញុំ នឹងមានផលដូចម្តេច សេចក្តីមិនត្រេកអររបស់ពួកញាតិមិត្រនិងសំឡាញ់របស់យើង នឹងមានដោយក្រៃលែង កងកាយកាលត្រូវគេដុត រមែងមិនដឹងនូវសេចក្តីខ្សឹកខ្សួល នៃញាតិទាំងឡាយទេ ព្រោះហេតុនោះ ទើបខ្ញុំមិនសោកនឹងបងនោះ គតិណាជារបស់គេ គេក៏ទៅកាន់គតិនោះ ។

(១៩) (ភរិយាពោលថា) ទារកយំទារព្រះចន្ទដែលកំពុងរះទៅ យ៉ាងណា បុគ្គលដែលសោករកអ្នកស្លាប់ទៅកាន់លោកខាងមុខ នេះឯងជាគ្រឿងប្រៀបធៀប យ៉ាងនោះដែរ កងកាយកាលត្រូវគេដុតរមែងមិនដឹងនូវសេចក្តីខ្សឹកខ្សួលនៃពួកញាតិទេ ព្រោះហេតុនោះ ទើបខ្ញុំមិនសោកនឹងប្តីនុ៎ះ គតិណាជារបស់គេ គេក៏ទៅកាន់គតិនោះ ។

(៦០) យថាបិ ឧទកកុម្ភោ ភិន្នោ អប្បដិសន្ធិយោ
ឯវំ សម្បទមេវេតិ យោ បេតមនុសោចតិ
ទយ្ហមានោ ន ជានាតិ ញាតីនំ បរិទេវិតំ
តស្មា ឯតំ ន សោចាមិ គតោ សោ តស្ស យា គតី ។

ឧរគជាតកំ ចតុត្ថំ ។

## ឃដជាតកំ

(៦១) អញ្ញេ សោចន្តិ រោទន្តិ អញ្ញេ អស្សុមុខា ជនា
បសន្នមុខវណ្ណោសិ កស្មា ឃដ ន សោចសិ ។

(៦២) នាព្ភតីតហរោ សោកោ នានាគតសុខាវហោ
តស្មា ឃដ ន សោចាមិ នត្ថិ សោកេ ទុតីយតា ។



(៦០) (តាបសពោលថា) ក្អមទឹកដែលបែកធ្លាយ តភ្ជាប់មិនជាប់ យ៉ាងណា បុគ្គលសោកស្តាយនឹងអ្នកស្លាប់ ទៅកាន់លោកខាងមុខ នេះឯង ជារឿងដ៏ទៀប ក៏យ៉ាងនោះដែរ កាលកាយកាលត្រូវគេដុត រមែងមិនដឹងនូវសេចក្តីខ្សឹកខ្សួល នៃញាតិទាំងឡាយទេ ព្រោះហេតុនោះ ទើបខ្ញុំមិនសោកនឹងម្ចាស់ខ្ញុំ គតិណាជារបស់គេ គេក៏ទៅកាន់គតិនោះ ។

ចប់ ឧរគជាតក ទី ៤ ។

## ឃដជាតក

(៦១) (ស្តេចឥន្ទ្រៈសួរព្រាហ្មណ៍ ពោធិសត្វថា) ពួកជនឯទៀត តែងសោកយំខ្សឹកខ្សួល ពួកជនឯទៀត មានមុខជោកជាំដោយទឹកភ្នែក ម្នាលឃដកុមារ អ្នកមានសម្បុរមុខស្រស់បស់ អ្នកមិនសោកសៅ ព្រោះហេតុអ្វី ។

(៦២) (ពោធិសត្វឆ្លើយថា) សេចក្តីសោក នាំមកនូវសេចក្តីសុខ ដែលកន្លងទៅហើយមិនបានទេ នាំមកនូវសេចក្តីសុខ ដែលមិនទាន់មកមិនបានទេ បពិត្រស្តេចឥន្ទ្រៈ ព្រោះហេតុនោះ ទើបខ្ញុំមិនសោក ភាពជាសំឡាញ់ គឺសេចក្តីសោក មិនមានទេ ។

(២៣) សោចំ បណ្ឌុកិសោ ហោតិ ភត្តញ្ចស្ស ន រុច្ចតិ
អមិត្តា សុមនា ហោន្តិ សល្លវិទ្ធស្ស រុប្បតោ ។

(២៤) គាមេ វា យទិ វារញ្ញេ និន្នេ វា យទិ វា ថលេ
ឋិតំ មំ នាគមិស្សតិ(១) ឯវំ ទិដ្ឋបទោ អហំ ។

(២៥) យស្សត្តា នាលមេកោវ សព្វកាមរសាហរោ
សព្វាបិ បថវី តស្ស ន សុខំ អាវហិស្សតីតិ ។

ខន្ធជាតកំ(២) បញ្ចមំ ។

## ការន្ទិយជាតកំ(៣)

(២៦) ឯកោ អរញ្ញេ គិរិកន្ទរាយំ
បគ្គយ្ហ មហន្តសេលំ បវេច្ឆសិ
បុនប្បុនំ សន្តរមានរូបោ
ការន្ទិយ(៤) កោ នុ តវ យិធត្ថោ ។

(២៧) អហញ្ហិមំ សាគរសេវិតន្តំ
សមំ ករិស្សាមិ យថាបិ បាណី
វិកិរិយ សានូនិ ច បព្វតានិ
តស្មា សេលំ កន្ទរាយំ បក្ខិបាមិ ។

១ ម. ឧនន្តំ អាគមិស្សតិ ។ ២ ម. ឃដជាតកំ ។ ៣ ម. ការន្ទិយជាតកំ ។ ៤ ការន្ទិយ ។



(២៣) បុគ្គលកាលសោក រមែងជាអ្នកមានពណ៌លឿង ស្គាំងស្គម ចំណីបាយ រមែងមិនពេញចិត្តដល់បុគ្គលនោះ បុគ្គលដែលត្រូវសរ គឺសេចក្តីសោកមុតហើយ កំពុងព្រួយ ពួកជនជាសត្រូវ រមែងមានចិត្តត្រេកអរ ។

(២៤) សេចក្តីវិនាសនឹងមកកាន់ខ្ញុំ ដែលឋិតនៅក្នុងស្រុក ឬក្នុងព្រៃ ក្នុងទីទាប ឬទីទួល មិនបានទេ (ព្រោះ) ខ្ញុំឃើញច្បាស់នូវធម៌ យ៉ាងនេះហើយ ។

(២៥) បុគ្គលណា មានខ្លួនតែមួយ មិនអាចជាអ្នកនាំយកនូវរស នៃសេចក្តីប្រាថ្នា គឺសុខក្នុងឈានទាំងពួងបាន សូម្បីផែនដីទាំងមូល ក៏មិនអាចនាំមក នូវសេចក្តីសុខ ដល់បុគ្គលនោះបាន ។

ចប់ ខន្ធជាតក ទី ៥ ។

## ការន្ទិយជាតក

(២៦) (អាចារ្យសួរថា) អ្នកតែម្នាក់ឯង លើករលាំងលើកដុំថ្មធំៗ បោះទៅក្នុងជ្រោះភ្នំ ក្នុងព្រៃរឿយៗ ម្នាលការន្ទិយៈ អ្នកមានប្រយោជន៍ដូចម្តេច ក្នុងជ្រោះនេះ ។

(២៧) (ការន្ទិយតបថា) ខ្ញុំនឹងធ្វើនូវផែនដីនេះ ដែលមានសាគរជាទីបំផុត ឲ្យស្មើដូចជាបាតដៃ ព្រោះហេតុនោះ បានជាខ្ញុំកំចាត់បង់ដី និងភ្នំ ហើយបោះថ្មទៅក្នុងជ្រោះ ។

(២៨) ន យិមំ មហឹ អរហតិ បាណិកាប្បំ
សមំ មនុស្សោ ករណាយ មេកោ
មញ្ញាមិមញ្ញេ ត្វំ ន ឥមំ ជិគីសំ
ការណ្ឌិយ ហាយសិ ជីវលោកំ ។

(២៩) សចេ អយំ ភូតធរំ ន សក្កា
សមំ មនុស្សោ ករណាយ មេកោ
ឯវមេវ ត្វំ ព្រហ្មេ ឥមេ មនុស្សេ
នានាទិដ្ឋិកេ នានយិស្សសិ តេ ។

(៣០) សង្ខិត្តរូបេន ភវំ មមត្ថំ
អក្ខាសិ ការណ្ឌិយ ឯវមេតំ
យថា ន សក្កា បឋវី សមាយំ
កាតុំ មនុស្សេន តថា មនុស្សាតិ ។

ការណ្ឌិយជាតកំ ឆដ្ឋំ ។



(២៨) (អាចារ្យពោលថា) មនុស្សម្នាក់ មិនគួរដើម្បីធ្វើផែនដីធំនេះ ឲ្យរាបស្មើដូចបាតដៃបានទេ ម្នាលការណ្ឌិយៈ ខ្ញុំសំគាល់នូវអ្នក ដែលស្វែងរកថ្មនេះឯង (ដើម្បីបំពេញជ្រោះ) អ្នកនឹងលះបង់នូវជីវលោក (ស្លាប់ខ្លួន) ។

(២៩) (ពោធិសត្វពោលថា) បើមនុស្សម្នាក់នេះ មិនអាចដើម្បីធ្វើនូវផែនដីធំនេះ ឲ្យរាបស្មើបានទេ យ៉ាងណា ម្នាលព្រាហ្មណ៍ អ្នកនឹងដឹកនាំពួកមនុស្សទាំងនេះ ដែលមានទិដ្ឋិផ្សេងៗ គ្នា មិនបាន ក៏យ៉ាងនោះដែរ ។

(៣០) (អាចារ្យពោលថា) ម្នាលការណ្ឌិយៈ អ្នកដ៏ចំរើន ពោលនូវពាក្យនេះ ដោយសង្ខេប ជាពាក្យមានប្រយោជន៍ ដល់ខ្ញុំ យ៉ាងនេះ ផែនដីនេះ គេមិនអាចធ្វើឲ្យរាបស្មើ យ៉ាងណា ពួកមនុស្ស ក៏មនុស្សមិនអាចធ្វើបាន យ៉ាងនោះដែរ ។

ចប់ ការណ្ឌិយជាតក ទី ៦ ។

# លដុកិកជាតកំ

(៣១) វន្ទាមិ តំ កុញ្ជរ សដ្ឋិហាយនំ
អារញ្ញកំ យូថបតឹ យសស្សឹ
បក្ខេហិ តំ បញ្ជលិកំ(១) ករោមិ
មា មេ វធិ បុត្តកេ ទុព្ពលាយ ។

(៣២) វន្ទាមិ តំ កុញ្ជរ ឯកចារឹ
អារញ្ញកំ បព្វតសានុគោចរំ
បក្ខេហិ តំ បញ្ជលិកំ ករោមិ
មា មេ វធិ បុត្តកេ ទុព្ពលាយ ។

(៣៣) វធិស្សាមិ តេ លដុកិកេ បុត្តកានិ
កឹ មេ តុវំ កាហសិ ទុព្ពលាសិ
សតសហស្សានិបិ តាទិសីនំ
វាមេន បាទេន បបោថយេយ្យំ(២) ។

---

១ អដ្ឋកថាយំ អញ្ជលិកន្តិ បាឋោ ទិស្សតិ ។ ២ អដ្ឋកថាយំ បោថយេយ្យន្តិ បាឋោ ទិស្សតិ ។



# លដុកិកជាតក

(៣១) (ចាបទៀបកប្បាសពោលនឹងដំរីពោធិសត្វថា) ខ្ញុំសូមថ្វាយបង្គំលោក ជាដំរីមានកំឡាំងខ្សោយ ក្នុងកាលមានអាយុ ៦០ ជាអ្នកនៅក្នុងព្រៃជាម្ចាស់ហ្វូង មានយស ខ្ញុំសូមធ្វើនូវអញ្ជលិកម្ម ចំពោះលោក ដោយស្លាបទាំងឡាយ សូមកុំឲ្យលោកសម្លាប់កូន របស់ខ្ញុំ ជាសត្វមានកំឡាំងខ្សោយ ។

(៣២) (ចាបទៀបកប្បាសពោលនឹងដំរីទៅទៀតថា) ខ្ញុំសូមថ្វាយបង្គំលោក ជាដំរីត្រាច់ទៅតែម្នាក់ឯង ជាអ្នកនៅក្នុងព្រៃ ដើរទៅតាមញកភ្នំ ខ្ញុំសូមធ្វើអញ្ជលិកម្ម ដោយស្លាបទាំងឡាយ សូមលោកកុំសម្លាប់កូនខ្ញុំ ជាសត្វមានកំឡាំងខ្សោយ ។

(៣៣) (ដំរីទៅទៀតពោលថា) នែមេចាបទៀបកប្បាស អញនឹងសម្លាប់នូវកូននាង នាងជាសត្វមានកំឡាំងខ្សោយ នឹងធ្វើអ្វីដល់អញ អញនឹងជាន់នូវចាប សូម្បីមួយសែន ប្រហែលនឹងនាង ដោយជើងឆ្វេង ។

(៣៦) ន ហេវ សព្វត្ថ ពលេន កិច្ចំ
ពលំ ហិ ពាលស្ស វធាយ ហោតិ
ករិស្សាមិ តេ នាគរាជ អនត្ថំ
យោ មេ វធិ បុត្តកេ ទុព្វលាយ ។

(៣៧) កាកញ្ច បស្ស លដុកិកំ មណ្ឌូកំ នីលមក្ខិកំ
ឯតេ នាគំ អឃាតេសុំ បស្ស វេរស្ស វេរិនំ
តស្មា ហិ វេរំ ន កយិរាថ អប្បិយេនបិ កេនចិ ។

លដុកិកជាតកំ សត្តមំ ។

## ចុល្លធម្មបាលជាតកំ

(៣៨) អហមេវ ទូសិយា ភូនហតា រញ្ញោ មហាបតាបស្ស
ឯតំ មុញ្ចតុ ធម្មបាលំ ហត្ថេ មេ ទេវ ឆេទេហិ ។



(៣៦) (ចាបទៀបកប្បាសពោលថា) . កិច្ចដោយកំឡាំងកាយ មិនមែនប្រើបានគ្រប់កន្លែងទេ ព្រោះកំឡាំងកាយ សម្លាប់បានតែអ្នកល្ងង់ទេ នែស្ដេចដំរី អ្នកណា សម្លាប់កូនរបស់ខ្ញុំ ជាសត្វមានកំឡាំងខ្សោយ ខ្ញុំនឹងធ្វើនូវសេចក្ដីវិនាស ដល់អ្នកនោះវិញ ។

(៣៧) (ព្រះសាស្ដាទ្រង់ត្រាស់ថា) អ្នកចូរមើល នូវក្អែក ចាបទៀបកប្បាស កង្កែបនឹងរុយខៀវ សត្វទាំងនុ៎ះ សម្លាប់នូវដំរីបាន អ្នកចូរមើល (នូវគតិ) នៃពៀររបស់ពួកសត្វមានពៀរ ព្រោះហេតុនោះ អ្នកទាំងឡាយ កុំធ្វើនូវពៀរ នឹងជនណាមួយ សូម្បីមិនជាទីស្រឡាញ់ឡើយ ។

ចប់ លដុកិកជាតក ទី ៧ ។

## ចុល្លធម្មបាលជាតក

(៣៨) (ព្រះនាងចន្ទាទេវីពោលថា) ខ្ញុំម្ចាស់ជាស្រីប្រទូស្ត ជាអ្នកបំផ្លាញនូវសេចក្ដីចំរើន ដល់ស្ដេចឈ្មោះ មហាបតាបៈ បពិត្រព្រះសម្មតិទេព សូមលែងនូវធម្មបាល (ជាកូនខ្ញុំ) ចេញ សូមកាត់នូវដៃទាំងឡាយ របស់ខ្ញុំម្ចាស់វិញចុះ ។

(៣៧) អហមេវ ទូសិយា ភូនហតា រញ្ញោ មហាបតាបស្ស

ឯតំ មុញ្ចតុ ធម្មបាលំ ហត្ថេ មេ ទេវ ឆេទយ ។

(៣៨) អហមេវ ទូសិយា ភូនហតា រញ្ញោ មហាបតាបស្ស

ឯតំ មុញ្ចតុ ធម្មបាលំ សីសំ មេ ទេវ ឆេទយ ។

(៣៩) ន ហិ នូនិមស្ស រញ្ញោ មិត្តាមច្ចា ច វិជ្ជរេ

សុហទា យេ ន វទន្តិ មា ឃាតយិ ឱរសំ បុត្តំ ។

(៤០) ន ហិ នូនិមស្ស រញ្ញោ មិត្តា ញាតី ច វិជ្ជរេ

សុហទា យេ ន វទន្តិ មា ឃាតយិ អត្រជំ បុត្តំ ។

(៤១) ចន្ទនសារានុលិត្តា ពាហា ឆិជ្ជន្តិ ធម្មបាលស្ស

ទាយាទស្ស បថព្យា បាណា មេ ទេវ រុជ្ឈន្តិ ។

ចុល្លធម្មបាលជាតកំ អដ្ឋមំ ។



(៣៧) ខ្ញុំម្ចាស់ជាស្រីប្រទូស្ត ជាអ្នកបំផ្លាញខ្សែសេចក្តីចំរើន ដល់ស្តេចឈ្មោះមហាបតាបៈ បពិត្រព្រះសម្មតិទេព សូមព្រះអង្គលែងនូវធម្មបាល នេះចេញ សូមកាត់នូវដៃទាំងពីរ របស់ខ្ញុំ វិញចុះ ។

(៣៨) ខ្ញុំម្ចាស់ជាស្រីប្រទូស្ត ជាអ្នកបំផ្លាញ ខ្សែសេចក្តីចំរើន ដល់ស្តេចឈ្មោះមហាបតាបៈ បពិត្រព្រះសម្មតិទេព សូមព្រះអង្គលែងនូវធម្មបាលនេះចេញ សូមកាត់នូវក្បាល របស់ខ្ញុំម្ចាស់វិញចុះ ។

(៣៩) ពួកមិត្តអាមាត្យ ទាំងអ្នកមានហឫទ័យល្អ របស់ស្តេចនេះ មិនមានទេឬ បានជាមិននិយាយឃាត់ស្តេចថា សូមព្រះអង្គកុំសម្លាប់បុត្តជាឱរសេ ។

(៤០ ពួកមិត្ត ញាតិ ទាំងអ្នកមានហឫទ័យល្អ របស់ស្តេចនេះ មិនមានទេឬ បានជាមិននិយាយឃាត់ស្តេចថា សូមព្រះអង្គកុំសម្លាប់បុត្ត ដែលកើតអំពីខ្លួន ។

(៤១) ដើមដៃទាំងពីរ ដែលលាបដោយខ្លឹមចន្ទន៍ របស់ធម្មបាល អ្នកជាទាយាទផែនដីដាច់ បពិត្រព្រះសម្មតិទេព ជីវិតរបស់ខ្ញុំម្ចាស់នឹងរលត់ ។

ចប់ ចុល្លធម្មបាលជាតក ទី ៨ ។

# សុវណ្ណមិគជាតកំ

(៤២) វិក្កម រេ មហាមិគ    វិក្កម រេ ហរីបទ
ឆិន្ទ វារត្តិកំ បាសំ    នាហំ ឯកា វនេ រមេ ។

(៤៣) វិក្កមាមិ ន បារេមិ    ភូមឹ សុម្ភាមិ វេគសា
ទឡ្ហោ វារត្តិកោ បាសោ    បាទំ មេ បរិកន្តតិ ។

(៤៤) អត្ថរស្សុ បលាសានិ    អសឹ និព្ពាហ លុទ្ទក
បឋមំ មំ វធិត្វាន    ហន បច្ឆា មហាមិគំ ។

(៤៥) ន មេ សុតំ វា ទិដ្ឋំ វា    ភាសន្តឹ មានុសឹ មិគឹ
ត្វញ្ច ភទ្ទេ សុខី ហោហិ    ឯសោ ចាបិ មហាមិគោ ។

(៤៦) ឯវំ លុទ្ទក នន្ទស្សុ    សហ សព្វេហិ ញាតិភិ
យថាហមជ្ជ នន្ទាមិ    មុត្តំ ទិស្វា មហាមិគំ ។

សុវណ្ណមិគជាតកំ នវមំ ។



# សុវណ្ណមិគជាតក

(៤២) (ម្រឹគញីជាប្រពន្ធពោលថា) បពិត្រមហាម្រឹគ អ្នកចូរខំប្រឹង បពិត្រម្រឹគមានជើងដូចមាស អ្នកចូរខំប្រឹង ចូរកាត់ខ្សែអន្ទាក់ដែលធ្វើដោយព្រ័ត្រ ខ្ញុំជាម្រឹគញីម្នាក់ឯង មិនអាចត្រេកអរ ក្នុងព្រៃបានទេ ។

(៤៣) (ម្រឹគពោធិសត្វជាប្តី ពោលថា) អញខំប្រឹង មិនរួចទេ អញជីកកាយផែនដី ដោយកំឡាំង អន្ទាក់ដែលគេធ្វើដោយព្រ័ត្រ ជាប់មាំមួន រឹតកួតជើងរបស់អញ ។

(៤៤) (ម្រឹគញី ពោលថា) បពិត្រនាយព្រាន អ្នកចូរក្រាលស្លឹកឈើ អ្នកចូរហូតដាវ (អំពីស្រោម) អ្នកសម្លាប់ខ្ញុំមុន ហើយសឹមសម្លាប់មហាម្រឹគ ជាខាងក្រោយ ។

(៤៥) (ព្រាន ពោលថា) អញមិនដែលឮ ឬឃើញមេម្រឹគចេះនិយាយភាសាមនុស្សទេ ម្នាលមេម្រឹគដ៏ចំរើន នាងឯងចូរនៅជាសុខចុះ ទាំងមហាម្រឹគនុ៎ះ ក៏សូមឲ្យនៅជាសុខចុះ ។

(៤៦) (ម្រឹគញី ពោលថា) បពិត្រនាយព្រាន ខ្ញុំត្រេកអរ ព្រោះឃើញខ្លួនមហាម្រឹគ ដែលរួច (ចាកអន្ទាក់) ក្នុងថ្ងៃនេះ យ៉ាងណា សូមអ្នកត្រេកអរ ជាមួយនឹងពួកញាតិទាំងអស់ យ៉ាងនោះដែរ ។

ចប់ សុវណ្ណមិគជាតក ទី ៩ ។

## សុសន្ធិជាតកំ(១)

(៤៧) វាតិ គន្ធោ តិមិរានំ   កុសមុទ្ទោ ច ឃោសវា
ទូរេ ឥតោ ហិ សុសន្ធី(២)   តម្ព កាមា តុទន្តិ មំ ។

(៤៨) កថំ សមុទ្ទមតរិ   កថំ អទ្ទក្ខិ សេរុមំ
កថំ តស្សា ច តុយ្ហញ្ច   អហុ អគ្គ សមាគមោ ។

(៤៩) កុរុកច្ឆា បយាតានំ   វាណិជានំ ធនេសិនំ
មករេហិ ភិទា នាវា   ផលកេន ហំ អប្លវឹ(៣) ។

(៥០) សា មំ សណ្ហេន មុទុនា   និច្ចំ ចន្ទនគន្ធិនី
អង្កេន ឧទ្ធរី ភទ្ទា   មាតា បុត្តំវ ឱរសំ ។

១ ម. សុស្សោន្ទិជាតកំ ។ ២ សុស្សោន្ទិ ។ ៣ ផលកេនាហមប្លវឹ ។





## សុសន្ធិជាតក

(៤៧) (អ្នកចំរៀងឈ្មោះ អគ្គៈ ពោលថា) ក្លិននៃផ្កាតិមិរព្រឹក្ស(១) រំភើយផ្សាយទៅ សមុទ្រដែលពេញដោយទឹក មានសំឡេងគឹកកង បពិត្រស្តេចតម្ពៈ ព្រោះថា នាងសុសន្ធី (នៅ) ក្នុងទីឆ្ងាយពីនគរនេះ កាមទាំងឡាយ តែងចាក់ដោតខ្ញុំ ។

(៤៨) (ស្តេចគ្រុឌពោលថា) អ្នកឆ្លងសមុទ្របាន ដោយប្រការដូចម្តេច អ្នកឃើញកោះឈ្មោះសេរុម ដោយប្រការដូចម្តេច ម្នាលអគ្គៈ ការជួបប្រសព្វ នាងសុសន្ធីនឹងអ្នក បានមានមកដោយប្រការដូចម្តេច ។

(៤៩) (អ្នកចំរៀងឈ្មោះអគ្គៈ ពោលថា) នាវារបស់ពួកឈ្មួញអ្នកស្វែងរកទ្រព្យ ចេញទៅអំពីកំពង់កុរុកច្ឆ បែកធ្លាយដោយមង្គរ ខ្ញុំក៏ឆ្លងសមុទ្រដោយផែនក្តារ ។

(៥០) នាងសុសន្ធីនោះ ជាស្ត្រីមានកាយទន់ពីពេរ មានក្លិនដូចខ្លឹមចន្ទន៍ សព្វកាលជានិច្ច ជាស្ត្រីចំរើន ស្រង់ខ្ញុំដោយភ្លៅៈ ដូចមាតាត្រកងនូវបុត្រ ដែលកើតអំពីទ្រូង ។

១ តិមិរព្រឹក្សនេះជាឈ្មោះឈើមួយបែប ក្នុងអដ្ឋកថា ពន្យល់ថា ឈើនេះច្រើនដុះនៅមាត់សមុទ្រ ឈើនេះត្រូវហៅថាស្លុំ ឬឡូស ឬក៏សំបូរមាសទើង ។ គ្នាពិចារ ។

(៥៧) ឥកា ចំ អន្នេន ចារេន វត្ថេន សយនេន ច
អត្តនោ ច មន្ទត្ថី បរិ ភត្តា វិធានយាតិ ៕

សុសន្ធិជាតកំ ទសមំ ៕

មណិកុណ្ឌលវគ្គោ បឋមោ ៕

## តស្សុទ្ទានំ

អថ និចរកេ ហារិតំ តិណរកោ
អថ កិច្ចលិកេ ទុរកោ យមោ
ធរិយោ បុន កុញ្ជរ កូឧហាតា
មិក កុក្កុមសន្តាវេឧ ធស ៕

---



(៥៧) នារីជាស្ត្រីមានកេរ្តិ៍ខ្ពស់ បានផ្តល់ផលធំ ដោយបាយ ទឹក
សំពត់ ទីដំណេក ព្រមទាំងគ្រឿងអប់ បតិព្វតាស្ត្រីឧត្តមៈ សូមព្រះ
អង្គជ្រាបយ៉ាងនេះចុះ ៕

ចប់ សុសន្ធិជាតក ទី ១០ ៕

ចប់ មណិកុណ្ឌលវគ្គ ទី ១ ៕

## ឧទ្ទាននៃជាតកនោះគឺ

និយាយអំពីផែនទីនៃកែវមណី រឺប្រាសាទ ដែលសាបសូន្យ ១ អ្នកប្រាជ្ញស្មោះ យកស្មោះទ្រ (ឲ្យគោស្លាប់) ១ បុគ្គលរំភើបដូចបុគ្គលភ្លាយសំពៅ ១ បុគ្គលលះបង់សារៈ ដូចពស់លះបង់សំណាក ១ ព្រះរាជាឈ្មោះយសកុមារ ១ ព្រៀវភ្លេង ១ កុញ្ជរ ១ មហោស្រ អ្នកបំផ្លាញ ខ្មាសបក្ខពួកម៉េង ១ ម្រឹគ ១ ការត្រេកអរនូវកូន ១ រួមជា ១០ ៕

---

# វណ្ណារោហវគ្គោ

## វណ្ណារោហជាតកំ

(៩២) វណ្ណារោហេន ជាតិយា ពលនិក្ខមនេន ច
សុពាហុ ន មយា សេយ្យោ សុទាឋ ឥតិ ភាសសិ ។

(៩៣) វណ្ណារោហេន ជាតិយា ពលនិក្ខមនេន ច
សុទាឋោ ន មយា សេយ្យោ សុពាហុ ឥតិ ភាសសិ ។

(៩៤) ឯវញ្ចេ មំ វិហរន្តំ សុពាហុ សម្ម ទុព្ភសិ
ន ទានាហំ តយា សទ្ធឹ សំវាសមភិរោចយេ ។

(៩៥) យោ បរេសំ វចនានិ សទ្ទហេថ(១) យថាតថំ
ខិប្បំ ភិជ្ជេថ មិត្តស្មឹ វេរញ្ច បសវេ ពហុំ ។

(៩៦) ន សោ មិត្តោ យោ សទា អប្បមត្តោ
ភេទាសង្កី រន្ធមេវានុបស្សី
យស្មិញ្ច សេតិ ឧរសីវ បុត្តោ
ស វេ មិត្តោ យោ អភេជ្ជោ បរេហិ ។

វណ្ណារោហជាតកំ បឋមំ ។

---

១ ម. សទ្ទហេយ្យ ។

# វណ្ណារោហវគ្គ

## វណ្ណារោហជាតក

(៩២) (ខ្លាឈ្មោះសុពាហុ ពោលថា) អ្នកឈ្មោះសុទាឋៈនិយាយថា ខ្លាឈ្មោះសុពាហុ មិនប្រសើរជាងអញ ដោយទំហំ កំពស់ ជាតិ កំឡាំងកាយ និងសេចក្តីព្យាយាម ដូច្នេះឬទេ ។

(៩៣) (សីហៈឈ្មោះសុទាឋៈ ពោលថា) អ្នកឈ្មោះសុពាហុនិយាយថា សីហៈឈ្មោះសុទាឋៈ មិនប្រសើរជាងអញ ដោយទំហំ កំពស់ ជាតិ កំឡាំងកាយ និងសេចក្តីព្យាយាម ដូច្នេះឬទេ ។

(៩៤) ម្នាលសុពាហុសំឡាញ់ បើអ្នកប្រទូស្តចំពោះអញ ដែលកំពុងនៅយ៉ាងនេះ ឥឡូវនេះ អញមិនពេញចិត្ត ចំពោះការនៅរួមជាមួយអ្នកទេ ។

(៩៥) អ្នកណាជឿ នូវពាក្យនៃជនដទៃ ដ៏ផ្តេសផ្តាស អ្នកនោះ គប្បីបែកធ្លាយចាកមិត្ត ឆាប់រហ័ស ទាំងបាននូវពៀរជាច្រើន ។

(៩៦) មិត្តណា ជាអ្នកប្រយ័ត្ន រង្កៀសគិតការបែកធ្លាយ (ចំពោះមិត្ត) ឃើញតែទោសសព្វកាល អ្នកនោះ មិនឈ្មោះថា មិត្តឡើយ មួយទៀត បុគ្គលណាដែលពួកជនដទៃ បំបែកមិនបាន រមែងដេកនៅរួម ដូចជាកូនដែលកើតអំពីទ្រូង បុគ្គលនោះឯង ទើបឈ្មោះថា មិត្ត ។

ចប់ វណ្ណារោហជាតក ទី ១ ។

# សីលវីមំសជាតកំ

(៥៧) សីលំ សេយ្យោ សុតំ សេយ្យោ ឥតិ មេ សំសយោ
អហុ
សីលមេវ សុតា សេយ្យោ ឥតិ មេ នត្ថិ សំសយោ ។

(៥៨) មោឃា ជាតិ ច វណ្ណោ ច សីលមេវ កិរុត្តមំ
សីលេន អនុបេតស្ស សុតេនត្ថោ ន វិជ្ជតិ ។

(៥៩) ខត្តិយោ ច អធម្មដ្ឋោ វេស្សោ ចាធម្មនិស្សិតោ
តេ បរិច្ចជ្ជុភោ លោកេ ឧបបជ្ជន្តិ ទុគ្គតឹ ។

(៦០) ខត្តិយា ព្រាហ្មណា វេស្សា សុទ្ទា ចណ្ឌាលបុក្កុសា
ឥធ ធម្មំ ចរិត្វាន ភវន្តិ តិទិវេ សមា ។

(៦១) ន វេទា សម្បរាយាយ ន ជាតិ នាបិ ពន្ធវា
សកញ្ច សីលំ សំសុទ្ធំ សម្បរាយសុខាវហន្តិ[១] ។

សីលវីមំសជាតកំ ទុតិយំ ។

---

១ ម. ឧ. សុខាយ ឥតិ ។



# សីលវីមំសជាតក

(៥៧) (ព្រាហ្មណ៍ពោធិសត្វ ពោលថា) ខ្ញុំមានសេចក្ដីសង្ស័យថា សីលជារបស់ប្រសើរ ឬសុតៈជារបស់ប្រសើរ សីល (មារយាទ) ជារបស់ប្រសើរជាងសុតៈ (ការចេះដឹង) ខ្ញុំមិនមានសេចក្ដីសង្ស័យ ដូច្នោះឡើយ ។

(៥៨) ជាតិនិងវណ្ណៈ ឥតផលទេ សីលហ្នឹងឯង ទើបឧត្តម បុគ្គលកាលបើប្រាសចាកសីលហើយ ប្រយោជន៍ដោយសុតៈ មិនមានទេ ។

(៥៩) ក្សត្រិយ៍មិនឋិតនៅក្នុងធម៌ (ច្បាប់) វេស្សៈ មិនអាស្រ័យធម៌ ពួកជនទាំងនោះ រមែងលះបង់លោកទាំងពីរ ទៅកាន់ទុគ្គតិ ។

(៦០) ពួកក្សត្រិយ៍ ព្រាហ្មណ៍ វេស្សៈ សុទ្ទៈ ចណ្ឌាលនិងបុក្កុសជន ប្រព្រឹត្តធម៌ក្នុងលោកនេះ រមែងស្មើគ្នា ក្នុងទេវលោក ។

(៦១) វេទ ក៏មិនមែនឲ្យសុខ ក្នុងបរលោក ជាតិ ក៏មិនមែនឲ្យសុខ ក្នុងបរលោក ផៅពង្ស ក៏មិនមែនឲ្យសុខ ក្នុងបរលោក មានតែសីលដ៏បរិសុទ្ធរបស់ខ្លួន ទើបនាំមកនូវសេចក្ដីសុខ ក្នុងបរលោក ។

ចប់ សីលវីមំសជាតក ទី ២ ។

## ហិរិជាតកំ

(៦២) ហិរឹ តរន្តំ វិជិគុច្ឆមានំ
តវាហមស្មិ ឥតិ ភាសមានំ
សេយ្យានិ កម្មានិ អនាទិយន្តំ
នេសោ មមន្តិ ឥតិ នំ វិជញ្ញា ។

(៦៣) យញ្ហិ កយិរា តញ្ហិ វទេ   យំ ន កយិរា ន តំ វទេ
អករោន្តំ ភាសមានំ   បរិជានន្តិ បណ្ឌិតា ។

(៦៤) ន សោ មិត្តោ យោ សទា អប្បមត្តោ
ភេទាសង្កី រន្ធមេវានុបស្សី
យស្មិញ្ច សេតិ ឧរសីវ បុត្តោ
ស វេ មិត្តោ យោ អភេជ្ជោ បរេហិ ។

(៦៥) បាមោជ្ជករណំ ឋានំ   បសំសាវហនំ សុខំ
ផលានិសំសោ ភាវេតិ   វហន្តោ បោរិសំ ធុរំ ។





## ហិរិជាតក

(៦២) (ពាក្យសេដ្ឋី ពោលថា) បណ្ឌិតគប្បីដឹងច្បាស់ នូវបុគ្គលដែលលះបង់នូវសេចក្តីខ្មាស ខ្ពើមរអើម (ដោយមេត្តាការ) ដែលគ្រាន់តែពោលថា ខ្ញុំ (ជាមិត្ត) របស់អ្នក តែមិនកាន់យកនូវអំពើដ៏ប្រសើរថា អ្នកនុ៎ះ មិនមែនជាមិត្ត របស់អញ ។

(៦៣) ពិតណាស់ បុគ្គលធ្វើនូវអំពើណា គួរនិយាយចំពោះអំពើនោះ បុគ្គលមិនធ្វើនូវអំពើណា មិនគួរនិយាយចំពោះអំពើនោះ ពួកបណ្ឌិតតែងស្គាល់ច្បាស់នូវបុគ្គលដែលមិនធ្វើ គ្រាន់តែនិយាយ ។

(៦៤) បុគ្គលណា ជាអ្នកប្រយ័ត្ន ក្តិតការចាំតែគួរ រង្កៀសក្តីការបែកធ្លាយ (ចំពោះមិត្ត) សំឡឹងរិតតែទោសតែម្យ៉ាង អស់កាលជានិច្ច អ្នកនោះ មិនឈ្មោះថា មិត្តឡើយ ម្យ៉ាងទៀត បុគ្គលណា ដែលពួកជនដទៃ បំបែកមិនបាន រមែងដេកនៅក្បែរ ដូចជាកូនដែលកើតអំពីទ្រូង បុគ្គលនោះ ទើបឈ្មោះថា មិត្តដោយពិត ។

(៦៥) កុលបុត្តអ្នកមានផលានិសង្ស កាលនាំទៅនូវធុរៈ(១) ជារបស់បុរស រមែងចំរើននូវហេតុ ជាគ្រឿងធ្វើនូវបាមោជ្ជៈ ជាគ្រឿងនាំមកនូវសេចក្តីសរសើរ ជាសុខ ។

---

១ ធុរៈរបស់បុរសមាន ៤ យ៉ាង គឺ ទាន ១ សីល ១ ភាវនា មិត្តភាព ១ ។ អដ្ឋកថា ។

(៦៦) បវិវេករសំ បិត្វា រសំ ឧបសមស្ស ច

និទ្ទរោ ហោតិ និប្បាបោ ធម្មប្បីតិរសំ បិវន្តិ ។

ហរិតជាតកំ តតិយំ ។

## ខជ្ជោបនកជាតកំ

(៦៧) កោ នុ សន្តម្ហិ បជ្ជោតេ អគ្គិបរិយេសនំ ចរំ

អទ្ទក្ខិ រត្តិ ខជ្ជោតំ ជាតវេទំ អមញ្ញថ ។

(៦៨) ស្វាស្ស គោមយចុណ្ណានិ អភិមត្ថំ តិណានិ ច

វិបរីតាយ សញ្ញាយ នាសក្ខិ បជ្ជលេតវេ ។

(៦៩) ឯវម្បិ អនុបាយេន អត្ថំ ន លភតេ មគោ

វិសាណតោ គវំ ទោហំ យត្ថ ខីរំ ន វិន្ទតិ ។

(៧០) វិវិធេហិ ឧបាយេហិ អត្ថំ បប្បោន្តិ មាណវា

និគ្គហេន អមិត្តានំ មិត្តានំ បគ្គហេន ច ។

(៧១) សេនាមោក្ខបលាភេន វល្លភានំ នយេន ច

ជគតី ជគតីបាលា អាវសន្តិ វសុន្ធរន្តិ ។

ខជ្ជោបនកជាតកំ ចតុត្ថំ ។



(៦៦) បុគ្គល ផឹកនូវរសនៃវិវេកធម៌ផង នូវរសនៃសេចក្តីស្ងប់រម្ងាប់ផង ផឹកនូវរសនៃធម្មបីតិផង រមែងជាអ្នកមិនមានកង្វល់ មិនមានបាប ។

ចប់ ហរិតជាតក ទី ៣ ។

## ខជ្ជោបនកជាតក

(៦៧) (ទេវតាពោលថា) នែណាហ្ន៎ កាលបើភ្លឺមាន គ្រាប់ទៅស្វែងរកភ្លើង បានឃើញនូវអំពិលអំពែក ក្នុងវេលាយប់ ក៏សំគាល់ថា ភ្លើង ។

(៦៨) បុរសនោះ ក៏ប្រុងបាចល្អិតនូវលាមកនៃគោចមរគោ ផងស្មៅ ដោយសេចក្តីសំគាល់ខុស មិនអាចនឹងបញ្ឆេះភ្លើង ឲ្យឆេះឡើងបានទេ ។

(៦៩) បុគ្គលកាលរកទឹកដោះអំពីគោ អំពីស្នែង រមែងមិនបាននូវទឹកដោះ យ៉ាងណា បុគ្គលអន្ធពាល ក៏មិនបាននូវប្រយោជន៍ ដោយហេតុមិនមែនឧបាយ យ៉ាងនោះដែរ ។

(៧០) ជនទាំងឡាយ តែងបាននូវប្រយោជន៍ ដោយឧបាយទាំងឡាយផ្សេងៗ គឺការផ្ចាញ់ផ្ចាល់សត្រូវទាំងឡាយផង គឺការទំនុកបម្រុង ចំពោះមិត្តទាំងឡាយផង ។

(៧១) ក្សត្រអ្នកគ្រប់គ្រងផែនដី រមែងគ្រប់គ្រងនូវផែនដី ដែលប្រកបដោយទ្រព្យសម្បត្តិ ដោយការបំពេញបំបាន ចំពោះសេនាប្រមុខផង ដោយការណែនាំ របស់អ្នកមន្ត្រី ដែលជាអ្នកស្និទ្ធស្នាលផង ។

ចប់ ខជ្ជោបនកជាតក ទី ៤ ។

# អហិតុណ្ឌិកជាតកំ(១)

(៧២) ធុត្តោម្ហិ សម្ម សុមុខ ជូតេ អក្ខបរាជិតោ
ហរេហិ អម្ពបក្កានិ វីរិយន្តេ ភក្ខយាមសេ ។

(៧៣) អលិកំ វត មំ សម្ម អភូតេន បសំសសិ(២)
កោ តេ សុតោ វា ទិដ្ឋោ វា សុមុខោ នាម មក្កដោ ។

(៧៤) អជ្ជាបិ មេ តំ(៣) មនសិ យំ មំ ត្វំ អហិតុណ្ឌិក
ធញ្ញាបណំ បវិសិត្វា មត្តោ ឆាតំ ហនាសិ មំ ។

(៧៥) តាហំ សរំ ទុក្ខសេយ្យំ អបិ រជ្ជម្បិ ការយេ
នេវាហំ(៤) យាចិតោ ទជ្ជំ តថា ហិ ភយតជ្ជិតោ ។

(៧៦) យញ្ច ជញ្ញា កុលេ ជាតំ គព្ភេ តិត្តំ អមច្ឆរឹ
តេន សខិញ្ច មិត្តញ្ច ធីរោ សន្ធាតុមរហតីតិ ។

អហិតុណ្ឌិកជាតកំ បញ្ចមំ ។

---

១ ឱ. អហិគុណ្ឌិកជាតកំ ។ ២ បសំសយិ ។ ៣ ម. តេ ទំ សរេ ។ ៤ ម.ឱ. នេវតំ ។



# អហិតុណ្ឌិកជាតក

(៧២) (អហិតុណ្ឌិកបុរស ក្នុងកាលនិយាយនឹងស្វាថា) ម្នាលសម្លាញ់មានមុខល្អ ខ្ញុំជាអ្នកលេងល្បែង ចាញ់ហើយ ដោយល្បែងភ្នាល់ អ្នកចូរទំលាក់នូវផ្លែស្វាយទុំ យើងស៊ីដោយសារសេចក្តីព្យាយាមរបស់អ្នក ។

(៧៣) (ស្វានិយាយថា) ម្នាលសម្លាញ់ ពាក្យនេះពេញជាកុហក អ្នកសរសើរខ្ញុំ ដោយពាក្យមិនពិត ស្វាណាឈ្មោះថា មានមុខល្អ ដែលអ្នកធ្លាប់ឮ ឬធ្លាប់ឃើញ ។

(៧៤) ម្នាលអហិតុណ្ឌិកៈ អ្នក (ធ្វើ) នូវអំពើណា ចំពោះខ្ញុំ អំពើនោះ (មាន) ក្នុងចិត្តអញ ក្នុងថ្ងៃនេះឯង អ្នកចូលទៅឯផ្សារលក់ស្រូវ ជាអ្នកស្រវឹង ហើយវាយខ្ញុំ ដែលកំពុងស្រេកឃ្លាន ។

(៧៥) ខ្ញុំកាលនឹកឃើញហេតុនោះ ដេកជាទុក្ខ ទោះបីអ្នកឲ្យខ្ញុំសោយរាជ្យ ហើយអ្នកសុំស្វាយខ្ញុំ ខ្ញុំក៏មិនឲ្យ ព្រោះខ្ញុំត្រូវភ័យគម្រាមហើយ ។

(៧៦) អ្នកប្រាជ្ញ ស្គាល់នូវបុគ្គលណា ដែលកើតក្នុងត្រកូល ជាអ្នកឆ្អែតស្កប់ស្កល់ ក្នុងគភ៌ ជាអ្នកមិនកំណាញ់ គួរចងសម្លាញ់ ចងមិត្តនឹងបុគ្គលនោះ ។

ចប់ អហិតុណ្ឌិកជាតក ទី ៥ ។

## គុម្ពិយជាតកំ

(៧៧)មធុវណ្ណំ មធុរសំ មធុគន្ធំ វិសំ អហុ
គុម្ពិយោ ឃាសមេសានោ អរញ្ញេ ឱទហី វិសំ ។
(៧៨)មធុ ឥតិ មញ្ញមានា យេ តំ វិសមសាយិសុំ(១)
តេសំ តំ កដុកំ អាសិ មរណំ តេនុបាគមុំ ។
(៧៩)យេ ច ខោ បដិសង្ខាយ វិសន្តំ បរិវជ្ជយុំ
តេ អាតុរេសុ សុខិតា ឌយ្ហមានេសុ និព្វុតា ។
(៨០)ឯវមេវ មនុស្សេសុ វិសំ កាមា សមោហិតា
អាមិសំ ពន្ធនញ្ចេតំ មច្ចុវេសោ គុហាសយោ ។
(៨១)ឯវមេវ ឥមេ កាមេ អាតុរា បរិចារិកេ
យេ សទា បរិវជ្ជន្តិ សង្គំ លោកេ ឧបច្ចគុំ ។

គុម្ពិយជាតកំ ឆដ្ឋំ ។

---

១ ម. វិសំ សមាសយិសុំ ។ ឧ. វិសមខាទិសុំ ។



## គុម្ពិយជាតក

(៧៧) (ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា) ថ្នាំពិស មានពណ៌ល្អ មានរសឆ្ងាញ់ មានក្លិនក្រអូប យក្ខឈ្មោះគុម្ពិយៈ ស្វែងរកអាហារ បានដាក់ថ្នាំពិស (ទុកនៅ) ក្នុងព្រៃ ។

(៧៨) ជនទាំងឡាយណា សំគាល់ថ្នាំពិសថាជាទឹកឃ្មុំ ក៏លិទ្ធភក្សនូវថ្នាំពិសនោះ ជនទាំងឡាយនោះ ក៏ដល់នូវសេចក្តីស្លាប់ ព្រោះថ្នាំពិសនោះ ។

(៧៩) ជនទាំងឡាយណា ពិចារណាឃើញច្បាស់ថាជាថ្នាំពិសហើយ វៀរចេញ ជនទាំងឡាយនោះ ដល់នូវសេចក្តីសុខ ក្នុងពួកជនកំពុងក្តៅក្រហាយ ជាអ្នកត្រជាក់ចិត្ត ក្នុងពួកជនកំពុងក្តៅរោលរាល ។

(៨០) ថ្នាំពិស ដែលប្រជុំចុះទៀបផ្លូវ យ៉ាងណាមិញ កាមទាំងឡាយ ដូចជាពិសដែលប្រជុំចុះ ក្នុងពួកមនុស្សក៏យ៉ាងនោះដែរ កាមគុណនេះ ជានុយ ជាចំណង ជាអំណាចនៃមច្ចុ ជាគុហាជាទីអាស្រ័យនៅនៃមច្ចុ ។

(៨១) ជនទាំងឡាយ ជាអ្នកក្តៅក្រហាយ លះវៀរនូវកាមទាំងនេះ ដែលជាគ្រឿងប្រើប្រាស់ អស់កាលទាំងពួង ជនទាំងឡាយនោះ ក៏រមែងកន្លងនូវកិលេស ជាគ្រឿងជាប់ ក្នុងលោកបាន ។

ចប់ គុម្ពិយជាតក ទី ៦ ។

# សាលិយជាតកំ

(៨២) យ្វាយំ សាលិយច្ឆាតោតិ កណ្ហសប្បំ អគាហយិ(●)
តេន សប្បេនយំ ទដ្ឋោ ហតោ បាបានុសាសកោ ។

(៨៣) អហន្តារមហន្តារំ យោ នរោ ហន្តុមិច្ឆតិ
ឯវំ សោ និហតោ សេតិ យថាយំ បុរិសោ ហតោ ។

(៨៤) អហនន្តមឃាតេន្តំ យោ នរោ ហន្តុមិច្ឆតិ
ឯវំ សោ និហតោ សេតិ យថាយំ បុរិសោ ហតោ ។

(៨៥) យថា បំសុមុដ្ឋិំ បុរិសោ បដិវាតំ បដិក្ខិបេ
តមេវ សោ រជោ ហន្តិ យថាយំ បុរិសោ ហតោ ។

(៨៦) យោ អប្បទុដ្ឋស្ស នរស្ស ទុស្សតិ
សុទ្ធស្ស បោសស្ស អនង្គណស្ស
តមេវ ពាលំ បច្ចេតិ បាបំ
សុខុមោ រជោ បដិវាតំវ ខិត្តោ ។

សាលិយជាតកំ សត្តមំ ។

● ម. អគាហយិ ។



# សាលិយជាតក

(៨២) (ពោធិសត្វពោលថា) បុរសណា ឲ្យគេចាប់ ពស់វែក ដោយបញ្ឆោតថា កូនសាលិក បុរសអ្នកប្រៀនប្រដៅអាក្រក់នេះ ត្រូវពស់នោះ ចឹកស្លាប់ហើយ ។

(៨៣) ជនណា ប្រាថ្នា ដើម្បីសម្លាប់នូវបុគ្គល ប៉ុន្តែ មិនបានប្រហារ មិនបានសម្លាប់វិញ ជននោះ ក៏ត្រូវដេកស្លាប់ យ៉ាងនេះ ដូចជាបុរសដែលស្លាប់នេះ ។

(៨៤) ជនណា ប្រាថ្នា ដើម្បីសម្លាប់នូវបុគ្គល អ្នកមិនបានបៀតបៀន មិនបានសម្លាប់វិញ ជននោះ ក៏ត្រូវដេកស្លាប់យ៉ាងនេះ ដូចជាបុរសដែលស្លាប់នេះ ។

(៨៥) បុរសអ្នកក្តាប់នូវកំទេចដី បាចទៅកាន់ទីច្រាសខ្យល់ ធូលីនោះ រមែងវិលមក ប៉ះបុរសនោះវិញ ដូចជាបុរសដែលស្លាប់នេះ ។

(៨៦) បុគ្គលពាលណា ប្រទូស្តចំពោះជន ដែលមិនបានប្រទូស្ត តបវិញ ជាបុគ្គលបរិសុទ្ធ មិនមានទីទួលនៃកិលេស បាបរមែងវិល ត្រឡប់ មកគេបុគ្គលពាលនោះវិញ ដូចជាធូលីដ៏ល្អិត ដែលបុគ្គលបាចទៅ កាន់ទីច្រាសខ្យល់ ។

ចប់ សាលិយជាតក ទី ៧ ។

# តចសារជាតកំ

(៨៧) អមិត្តហត្ថត្តគតា តចសារសមប្បិតា
បសន្នមុខវណ្ណាត្ថ កស្មា តុម្ហេ ន សោចថ ។

(៨៨) ន សោចនាយ បរិទេវនាយ
អត្ថោ ច លព្ភា អបិ អប្បកោបិ
សោចន្តមេនំ ទុខិតំ វិទិត្វា
បច្ចត្ថិកា អត្តមនា ភវន្តិ ។

(៨៩) យតោ ច ខោ បណ្ឌិតោ អាបទាសុ
ន វេធតិ អត្ថវិនិច្ឆយញ្ញូ
បច្ចត្ថិកាស្ស ទុខិតា ភវន្តិ
ទិស្វា មុខំ(*) អវិការំ បុរាណំ ។

(៩០) ជប្បេន មន្តេន សុភាសិតេន
អនុប្បទានេន បវេណិយា វា
យថា យថា យត្ថ លភេថ អត្ថំ
តថា តថា តត្ថ បរក្កមេយ្យ ។

---

● អដ្ឋកថាយំ សុខន្តិ បាឋោ ទិស្សតិ ។



# តចសារជាតក

(៨៧) (ស្តេចព្រហ្មទត្ត សួរថា) អ្នកទាំងឡាយ នៅក្នុងកណ្តាប់ដៃសត្រូវ ជាប់ដោយឃ្នាងឫស្សី តែនៅមានសម្បុរមុខស្រស់បស់ ព្រោះហេតុអ្វី ទើបអ្នកទាំងឡាយ មិនសោយសោក ៗ

(៨៨) ពោធិសត្វ ទូលតបថា សេចក្តីចម្រើន សូម្បីមានប្រមាណតិច គឺគេមិនដែលបាន ព្រោះសេចក្តីសោក ខ្សឹកខ្សួលទេ ផងថា សត្រូវទាំងឡាយ ដឹងច្បាស់នូវបុគ្គលនោះ ដែលកំពុងសោក ដល់នូវទុក្ខហើយ រមែងជាអ្នកមានចិត្តត្រេកអរ ៗ

(៨៩) កាលណា បណ្ឌិតអ្នកឈ្លាស ក្នុងការវិនិច្ឆ័យ នូវប្រយោជន៍ មិនញាប់ញ័រ ក្នុងអន្តរាយទាំងឡាយ កាលនោះ បុគ្គលជាសត្រូវ ជាទុក្ខ ព្រោះឃើញនូវមុខ របស់បណ្ឌិតនោះ មិនប្រែប្រួល នៅដូចពីដើម ៗ

(៩០) បុគ្គលបាននូវប្រយោជន៍ ព្រោះការរាយមន្តក្តី ការប្រឹក្សាក្តី ពោលពាក្យពីរោះក្តី ការឲ្យសំណូកក្តី ប្រវេណីក្តី ក្នុងទីណា យ៉ាងណាៗ ត្រូវប្រឹងប្រែង ក្នុងទីនោះ យ៉ាងនោះៗ ៗ

(៤១) យតោ ច ជាយេយ្យ អលក្ខនេយ្យោ

មយា ក អញ្ញេច ក ឯស អត្តោ

អសោចមានោ អធិកសយេយ្យ

កាម្មំ ធស្សំ កាត្តិ កាកោមិតាធិតិ ។

លោសកជាតកំ អដ្ឋមំ ។

## មិត្តវិន្ទកជាតកំ

(៤២) ក្យាហំ ទេវានមករំ កឹ បាបំ បកតំ មយា

យំ មេ សិរស្មឹ ឩហច្ច ចក្កំ ភមតិ មត្ថកេ ។

(៤៣) អតិក្កម្ម រមណកំ សទាមត្តញ្ច ទូភកំ

ព្រហ្មត្តរញ្ច បាសាទំ កេនត្ថេន ឥធាគតោ ។

(៤៤) ឥតោ ពហុតរា ភោគា អត្រ មញ្ញេ ភវិស្សរេ

ឥតិ ឯតាយ សញ្ញាយ បស្ស មំ ព្យសនំ គតំ ។



(៤១) កាលណា បុគ្គលដឹងថា ប្រយោជន៍នុ៎ះ ទោះបីអញ ឬបុគ្គលដទៃ មិនគប្បីបាន បណ្ឌិតមិនសោកស្តាយ ក្រែងកំណត់ ដោយគិតថា កម្មមានកំឡាំងមាំ វត្ថុនេះ សាត្តអញ ដឹងធ្វើដូចម្តេច ។

ចប់ លោសកជាតក ទី ៨ ។

## មិត្តវិន្ទកជាតក

(៤២) (មិត្តវិន្ទកៈ ពោលថា) ខ្ញុំបានធ្វើអំពើដូចម្តេច ដល់ពួកទេវតា ខ្ញុំបានធ្វើបាប ដូចម្តេច ទើបចក្រសន្លត់លើក្បាល វិលកិនអំបែងក្បាលរបស់ខ្ញុំ ដោយបាបណា (បាបនោះ ដូចម្តេចខ្លះ) ។

(៤៣) (ទេវបុត្រពោធិសត្វ ពោលថា) អ្នកឯងកន្លងផុតនូវប្រាសាទកែវផលិក ប្រាសាទប្រាក់ ប្រាសាទកែវមណី ប្រាសាទមាស ហើយមកក្នុងទីនេះ ដោយហេតុអ្វី ។

(៤៤) (មិត្តវិន្ទកៈ ពោលថា) អ្នកចូរមើលខ្ញុំដល់នូវសេចក្តីវិនាស ដោយសេចក្តីសំគាល់នេះថា ភោគៈទាំងឡាយច្រើន ជាងភោគៈទាំងឡាយ ក្នុងទីនេះ ប្រហែលជានឹងមានក្នុងទីនោះ ។

(៩៥) ចតុព្ភិ អដ្ឋជ្ឈគមា អដ្ឋាហិ ចាបិ សោឡស

សោឡសាហិ ច ពាត្តិំស អត្រិច្ឆំ ចក្កមាសទោ

ឥច្ឆាហតស្ស ពោសស្ស ចក្កំ ភមតិ មត្ថកេ ។

(៩៦) ឧបរិ វិសាលា ទុប្បូរា ឥច្ឆា វិសដគាមិនី

យេ ច តំ អនុគិជ្ឈន្តិ តេ ហោន្តិ ចក្កធារិនោ ។

មិត្តវិន្ទកជាតកំ ចតុត្ថំ ។

## បលាសជាតកំ

(៩៧) ហំសោ បលាសមវច និគ្រោធោ សម្ម ជាយតិ

អង្កស្មឹ តេ និសិន្នោ សោ តេ មម្មានិ ឆេច្ឆតិ ។



(៩៥) (ពោធិសត្វពោលថា អ្នកចេញ) អំពីវេមានិកប្រេត ៤ នាក់ទៅ ក៏បាននូវវេមានិកប្រេត ៨ នាក់ (ចេញ) អំពីវេមានិកប្រេត ៨ នាក់ទៅ ក៏បាននូវវេមានិកប្រេត ១៦ នាក់ (ចេញ) អំពីវេមានិកប្រេត ១៦ នាក់ទៅ ក៏បាននូវវេមានិកប្រេត ៣២ នាក់ អ្នកកាលប្រាថ្នាហួសពេក ទើបមកប្រទះនឹងចក្រ ចំណែកខាងចក្រក៏វិលកិនលើត្បូងក្បាលរបស់សត្វ ដែលត្រូវសេចក្តីប្រាថ្នាបៀតបៀន ។

(៩៦) តណ្ហា ជាធម្មជាតិ ដ៏ទូលាយក្រៃលែងខាងលើ ដែលសត្វបំពេញបានដោយក្រ ជាធម្មជាតិដើររេរកម ដោយអំណាចនៃសេចក្តីប្រាថ្នា ពួកជនណា ជាប់ចំពាក់ ដោយតណ្ហានោះ ពួកជននោះ រមែងទ្រទ្រង់នូវចក្រ ។

ចប់ មិត្តវិន្ទុកជាតកទី ៤ ។

## បលាសជាតក

(៩៧) (ព្រះសម្មាសម្ពុទ្ធសំដែងថា) ស្តេចហង្ស បាននិយាយនឹងបលាស-ទេវតា (ថា) ម្នាលសំឡាញ់ ដើមជ្រៃផុះ ដើមជ្រៃនោះ ដូចស្ត្រីអង្គុយលើភ្លៅរបស់អ្នក នឹងកាត់បង់នូវជីវិតសត្វរបស់អ្នក ។

(៩៨) វឌ្ឍតាមេវ និគ្រោធោ បតិដ្ឋស្ស ភវាមហំ
យថា បិតា ច មាតា ច ឯវមេសោ ភវិស្សតិ ។

(៩៩) យំ ត្វំ អង្កស្មិំ វឌ្ឍេសិ ខីររុក្ខំ ភយានកំ
អាមន្តយោ តំ គច្ឆាម វុឌ្ឍិមស្ស ន រុច្ចតិ ។

(១០០) ឥទានិ ខោ មំ ភាយតិ មហានេរុនិភស្សបិ
ហំសស្ស អនភិញ្ញាយ មហា មេ ភយមាគតំ ។

(១០១) ន តស្ស វុឌ្ឍិ កុសលប្បសត្ថា
យោ វឌ្ឍមានោ ឃសតេ បតិដ្ឋំ
តស្សូបរោធំ បរិសង្កមានោ
បតារយី មូលវធាយ ធីរោ ។

បលាសជាតកំ ទសមំ ។

វណ្ណារោហវគ្គោ ទុតិយោ (១) ។

---

១ ឱម. អស្សុទ្ទានំ តតិយវគ្គាវសានេ សមោហដំ ។



(៩៨) (បលាសទេវតា និយាយថា) ខ្ញុំជាទីពឹង របស់ដើមជ្រៃនុះ ដូចជាមាតាបិតា ដើមជ្រៃនុះនឹងជាទីពឹង (របស់ខ្ញុំ) ក្នុងកាលដែលខ្ញុំចំរើនឡើង យ៉ាងនោះដែរ ។

(៩៩) (ស្តេចហង្ស និយាយថា) អ្នកបណ្តុះនូវឈើមានជ័រ ដូចទឹកដោះ ដែលគួរខ្លាច ដូចសត្វនៅលើភ្លៅ ដោយហេតុណា ហេតុនោះ ទើបយើងប្រាប់អ្នក ហើយនឹងទៅ ការចំរើនឡើង នៃដើមជ្រៃនោះ មិនគាប់ចិត្ត (ខ្ញុំ) ទេ ។

(១០០) (បលាសទេវតា និយាយថា) ឥឡូវនេះ ដើមជ្រៃញាំង អញឱ្យភ័យ ភ័យដ៏ធំមកដល់អញ ព្រោះមិនយល់ពាក្យ នៃស្តេចហង្ស ជាពាក្យដូចជាភ្នំសិនេរុដ៏ធំ ។

(១០១) (ព្រះសម្មាសម្ពុទ្ធសំដែងថា) អ្នកណា កាលចំរើនឡើង រមែងបំផ្លាញនូវទីពឹង សេចក្តីចំរើននៃអ្នកនោះ ជនអ្នកឈ្លាសវៃ មិនសរសើរឡើយ អ្នកប្រាជ្ញកាលរង្កៀសនឹងសេចក្តីវិនាស រមែងព្យាយាម ដើម្បីសម្លាប់នូវមូលហេតុ នៃសេចក្តីអ្នកនោះ ។

ចប់ បលាសជាតក ទី ១០ ។

ចប់ វណ្ណារោហវគ្គ ទី ២ ។

## អដ្ឋវគ្គោ

## ទីឃីតិកោសលជាតកំ

(១០៦) ឯវំ ភូតស្ស តេ រាជ អាគតស្ស វសេ មម
អត្ថិ នុ កោចិ បរិយាយោ យោ តំ ទុក្ខា បមោចយេ ។
(១០៧) ឯវំភូតស្ស មេ តាត អាគតស្ស វសេ តវ
នត្ថិ នោ កោចិ បរិយាយោ យោ មំ ទុក្ខា បមោចយេ ។
(១០៨) នាញ្ញំ សុចរិតំ រាជ នាញ្ញំ រាជ សុភាសិតំ
តាយតេ មរណកាលេ ឯវមេវិតរំ ធនំ ។
(១០៩) អក្កោច្ឆិ មំ អវធិ មំ អជិនិ មំ អហាសិ មេ
យេ ច តំ ឧបនយ្ហន្តិ វេរំ តេសំ ន សម្មតិ
អក្កោច្ឆិ មំ អវធិ មំ អជិនិ មំ អហាសិ មេ
យេ ច តំ នុបនយ្ហន្តិ វេរំ តេសូបសម្មតិ ។

## អដ្ឋវគ្គ

## ទីឃីតិកោសលជាតក

(១០៦) (ទីឃាវុកុមារ ពោលថា) បពិត្រព្រះរាជា ព្រះអង្គធ្លាក់មក ក្នុងអំណាចរបស់ខ្ញុំ យ៉ាងនេះ បរិយាយណា ញុំាងព្រះអង្គឲ្យរួចចាកទុក្ខ បរិយាយណាមួយនោះ មានដែរឬ ។

(១០៧) (ព្រះរាជា ពោលថា) ម្នាលអ្នក ខ្ញុំធ្លាក់មក ក្នុងអំណាចរបស់អ្នក ប្រាកដយ៉ាងនេះ បរិយាយណា ញុំាងខ្ញុំឲ្យរួចចាកទុក្ខ បរិយាយណាមួយនោះ របស់យើងមិនមានទេ ។

(១០៨) (ទីឃាវុកុមារ ពោលថា) បពិត្រព្រះរាជា គុណជាតដទៃ អំពីសុចរិត ទីពឹងមិនបានទេ បពិត្រព្រះរាជា គុណជាតដទៃ អំពីសុភាសិត ទីពឹងមិនបានទេ ទ្រព្យក្រៅពីនេះ ក៏យ៉ាងនោះដែរ ។

(១០៩) បុគ្គលទាំងឡាយណា ចងទុកនូវពៀរនោះ (ដោយគិតថា) អ្នកឯណោះ បានជេរអញ បានវាយអញ បានផ្ចាញ់អញ បានលួចយក (ទ្រព្យ) របស់អញ ពៀររបស់បុគ្គលទាំងឡាយនោះ រមែងមិនរម្ងាប់ទេ លុះតែបុគ្គលទាំងឡាយណា មិនចងទុកនូវពៀរនោះ (ដោយគិតថា) អ្នកឯណោះ បានជេរអញ បានវាយអញ បានផ្ចាញ់អញ បានលួចយក (ទ្រព្យ) របស់អញ ពៀររបស់បុគ្គលទាំងឡាយនោះ ទើបរម្ងាប់បាន ។

(១០៦) ន ហិ វេរេន វេរានិ សម្មន្តីធ កុទាចនំ
អវេរេន ច សម្មន្តិ ឯស ធម្មោ សនន្តនោតិ។

ទីឃិតិកោសលជាតកំ បឋមំ ។

## មិគបោតកជាតកំ

(១០៧) អគារា បច្ចុបេតស្ស អនាគារស្ស តេ សតោ
សមណស្ស ន តំ សាធុ យំ បេតមនុសោចសិ ។

(១០៨) សំវាសេន ហវេ សក្កា មនុស្សស្ស មិគស្ស វា
ហទយេ ជាយតេ បេមំ ន តំ សក្កា អសោចិតុំ។

(១០៩) មតំ មរិស្សំ រោទន្តិ យេ រុទន្តិ លបន្តិ ច
តស្មា ត្វំ ឥសិ មា រោទិ រោទិតំ មោឃមាហុ សន្តោ។



(១០៦) តាំងពីកាលណាមក ពៀរទាំងឡាយ ក្នុងលោកនេះ រមែងមិនរម្ងាប់ ដោយពៀរទេ ពៀរទាំងឡាយ រមែងរម្ងាប់បាន ដោយមិនមានពៀរ នេះជាបុរាណធម៌ ។

ចប់ ទីឃិតិកោសលជាតក ទី ១ ។

## មិគបោតកជាតក

(១០៧) (ព្រះឥន្ទ្រពោលថា) លោកចេញចាកផ្ទះ ជាបុគ្គលមិនមានផ្ទះ ជាសមណៈ លោកសោកស្តាយ ចំពោះសត្វ ដែលទៅកាន់លោកខាងមុខណា សេចក្តីសោកស្តាយនោះ មិនប្រពៃទេ ។

(១០៨) (តាបសតបថា) បពិត្រសក្កៈ សេចក្តីស្រឡាញ់ រមែងកើតឡើង ក្នុងហឫទ័យ ដោយការនៅរួមរបស់មនុស្ស ឬ របស់ម្រឹគ ខ្ញុំមិនអាច មិនសោយសោកនឹងម្រឹគនោះ បានទេ ។

(១០៩) (សក្កទេវរាជពោលថា) ពួកជនណា យំនឹងបុគ្គលដែលស្លាប់ទៅហើយ ឬ នឹងស្លាប់ បុគ្គលនោះរមែងយំ រមែងនិយាយ (ឥតឈប់) បពិត្រឥសី ព្រោះហេតុនោះ លោកកុំយំឡើយ ព្រោះថា ពួកសប្បុរស បានពោលនូវការយំ ថាជាការឥតអំពើ ។

(១១០) កន្ទិតេន ហវេ ព្រហ្មេ មតោ បេតោ សមុដ្ឋហេ
សព្វេ សង្គម្ម រោទាម អញ្ញមញ្ញស្ស ញាតកេ ។
(១១១) អាទិត្តំ វត មំ សន្តំ ឃតសិត្តំវ បាវកំ
វារិនា វិយ ឱសិញ្ចំ សព្វំ និព្វាបយេ ទរំ
អព្វហី វត មេ សល្លំ យមាសិ ហទយស្សិតំ
យោ មេ សោកបរេតស្ស បុត្តសោកំ អបានុទិ
សោហំ អព្វុឡ្ហសល្លោស្មិ វីតសោកោ អនាវិលោ
ន សោចាមិ ន រោទាមិ តវ សុត្វាន ភាសិតំ ។

មិគបោតកជាតកំ ទុតិយំ ។

## មូសិកជាតកំ

(១១២) កុហិំ គតា កត្ថ គតា ឥតិ លាលប្បតី ជនោ
អហមេវេកោ ជានាមិ ឧទបានេ មូសិកា ហតា ។



(១១០) បពិត្រព្រាហ្មណ៍ ប្រសិនបើ បុគ្គលដែលស្លាប់ លះលោកនេះទៅ ហើយ គប្បីក្រោកឡើងបាន ដោយការយំ យើងទាំងអស់ គួរ ប្រជុំគ្នា យំនឹងពួកញាតិ នៃគ្នានឹងគ្នា ។

(១១១) (តាបស ពោលថា) អ្នកបានស្រោចស្រប់ខ្ញុំ ដែលក្តៅនឹង សេចក្តីសោកក្តៅនេះ ឲ្យស្ងប់រម្ងាប់ ញុំាងសេចក្តីក្រវល់ក្រវាយ ទាំងអស់ ឲ្យរលត់ ដូចបុគ្គលស្រោច ទឹកលើភ្លើងដែលឆេះខ្លាញ់ ដោយទឹក សរគឺសេចក្តីសោកណា ដែលអាស្រ័យ ក្នុងហឫទ័យ សរ គឺសេចក្តីសោកនោះ ខ្ញុំបានដកចេញហើយ អ្នកណាបានបន្ទោបង់ សេចក្តីសោក ព្រោះបុត្ត ដល់ខ្ញុំដែលត្រូវសេចក្តីសោកបៀតបៀន ខ្ញុំនោះជាអ្នកមានសរ គឺសេចក្តីសោកដកចេញហើយ ជាអ្នកប្រាស ចាកសេចក្តីសោក មានចិត្តមិនល្អក់ ម្នាលវាសវៈ ខ្ញុំលែងសោក ស្តាយ លែងយំទួញ ព្រោះបានស្តាប់ពាក្យរបស់អ្នក (នោះ) ។

ចប់ មិគបោតកជាតក ទី ២ ។

## មូសិកជាតក

(១១២) (ព្រះរាជាពោលថា) ពួកជននិយាយរវើរវាយថា នាងមូសិ- កា ទៅឯណា ទៅក្នុងទីណា អញតែម្នាក់ឯង ដឹងថា នាងមូសិកា ត្រូវគេសម្លាប់ (ទម្លាក់ទៅ) ក្នុងស្រះ ។

(១១៣) យញ្ចេតំ ឥតិ ចីតិ ច  គទ្រភោវ និវត្តសិ
ឧទបានេ មូសិកំ ហន្ត្វា  យវំ ភក្ខិតុមិច្ឆសិ(១) ។

(១១៤) ទហរោ ចាសិ ទុម្មេធ  បឋមុប្បត្តិកោ សុសុ
ទីឃញ្ចេតំ សមាសជ្ជ  ន តេ ទស្សាមិ ជីវិតំ ។

(១១៥) នាន្តលិក្ខភវនេន  នាង្គបុត្តសិរេន វា
បុត្តេន ហិ បត្ថយិតោ  សិលោកេហិ បមោចិតោ ។

(១១៦) សព្វំ សុតមធីយេថ  ហីនមុក្កដ្ឋមជ្ឈិមំ
សព្វស្ស អត្ថំ ជានេយ្យ  ន ច សព្វំ បយោជយេ
ហោតិ តាទិសកោ កាលោ  យត្ថ អត្ថាវហំ សុតន្តិ ។

មូសិកជាតកំ តតិយំ ។

---

១ ឱ. ភក្ខុតុមិច្ឆសិ ។ ម. ភក្ខេតុមិច្ឆសិ ។





(១១៣) (ព្រះរាជាពោលថា) អ្នកនិតរកនូវកោស នៃការប្រហារដូច្នេះ វិលត្រឡប់ ដូចសត្វលា ព្រោះហេតុណា ហេតុនោះ អ្នកសម្លាប់នូវតាតីមូសិកាតាសី (ទម្លាក់ទៅ) ក្នុងស្រះ ប្រាថ្នា ដើម្បីស៊ីនូវធុយដំណើបឬ ។

(១១៤) (ព្រះរាជា ពោលតទៅទៀតថា) ម្នាលអ្នកឥតប្រាជ្ញា អ្នកជាបុគ្គលនៅក្មេងខ្ចី ទាំងនៅ ក្នុងបឋមវ័យ កាន់យកនូវគ្រឿងប្រហារ មានដងដ៏វែងនេះ យើងមិនឲ្យជីវិតដល់អ្នកទេ ។

(១១៥) (ព្រះរាជាពោលគាថា ដ៏វិសេសថា) អញមិនមែនរួច (អំពីសេចក្តីស្លាប់) ព្រោះនៅមានលើអាកាស ឬ ព្រោះបុត្រ ប្រាកដស្មើដោយអង្គៈ បានទេ ព្រោះថា អញត្រូវកូនប្រាថ្នា (នឹងសម្លាប់) បានរួចខ្លួនព្រោះគាថាទាំងឡាយ ។

(១១៦) បុគ្គលគប្បីសិក្សា នូវសុតៈទាំងពួង ទោះបីជាថោកទាប ខ្ពង់ខ្ពស់ ឬយ៉ាងកណ្តាល គប្បីដឹងនូវប្រយោជន៍នៃសុតៈទាំងអស់ តែមិនគប្បីប្រកបនូវសុតៈទាំងអស់ទេ សុតៈនាំមកនូវប្រយោជន៍ ក្នុងកាលណា កាលប្រាកដដូច្នោះ រមែងមានប្រាកដ ។

ចប់ មូសិកជាតក ទី ៣ ។

# ចុល្លធនុគ្គហជាតកំ

(១៥៧) សព្វំ ភណ្ឌំ សមាទាយ បារំ តិណ្ណោសិ ព្រាហ្មណ
បច្ចាគច្ឆ លហុំ ខិប្បំ មម្បិ តារេហិ ទានិ តោ ។

(១៥៨) អសន្ថុតំ មំ ចិរសន្ថុតេន
និមីនិ ភោតី អទ្ធុវំ ធុវេន
មយាបិ ភោតី និមិនេយ្យ អញ្ញំ
ឥតោ អហំ ទូរតរំ គមិស្សំ ។

(១៥៩) កាយំ ឯឡគលាគុម្ពេ ករោតិ អហុហាសិយំ
នយិធ នច្ចំ វា គីតំ វា តាលំ វា សុសមាហិតំ
អនម្ហិកាលេ សុសោណិ កិន្នុ ជគ្ឃសិ សោភនេ ។

(១៦០) សិង្គាល ពាល ទុម្មេធ អប្បបញ្ញោសិ ជម្ពុក
ជិនោ មច្ឆញ្ច បេសិញ្ច កបណោ វិយ ឈាយសិ ។



# ចុល្លធនុគ្គហជាតក

(១៥៧) (ស្ត្រីនោះនិយាយថា) ម្នាលព្រាហ្មណ៍ អ្នកនាំយកទ្រព្យទាំងអស់ ឆ្លងទៅកាន់ត្រើយនាយ ម្នាលអ្នកដ៏ចំរើន អ្នកចូរត្រឡប់មកវិញ យ៉ាងឆាប់រហ័ស សូមអ្នកចម្លងខ្ញុំ ឥឡូវនេះផង ។

(១៥៨) (ចោរនិយាយថា) នាងផ្លាស់ប្តូរយកអញ អ្នកមិនស្និទ្ធស្នាល ដោយប្តីដែលស្និទ្ធស្នាល អស់កាលយូរ ផ្លាស់ប្តូរយកអញដែលមិនមែនជាប្តីទៀងទាត់ ដោយប្តីទៀងទាត់ នាងនឹងផ្លាស់ប្តូរយកប្រុសឯទៀត នឹងអញមិនខាន អញនឹងទៅកាន់ទីឆ្ងាយជាងទីនេះ ។

(១៥៩) (ចចកនិយាយថា) ស្ត្រីនេះជាអ្វី ទើបធ្វើនូវសំណើចយ៉ាងខ្លាំង ទៀបគុម្ពរំចេក ការរាំក្តី ច្រៀងក្តី ប្រគំក្តី ដែលគេតាំងទុកដោយល្អ ក្នុងទីនេះ មិនមានទេ ម្នាលស្ត្រី មានត្រគាកល្អ មានរូបល្អ ហេតុដូចម្តេច ទើបនាងសើចក្អាកក្អាយ ក្នុងកាលគួរយំ ។

(១៦០) (នាងនោះនិយាយថា) ម្នាលចចក ជម្ពុកៈ ពាលឥតប្រាជ្ញា ឯងជាសត្វគ្មានប្រាជ្ញា ឯងសាបសូន្យចាកត្រីនឹងដុំសាច់ សញ្ជប់សញ្ជឹង ដូចសត្វកំព្រា ។

(១៦១) សុទស្សំ វជ្ជមញ្ញេសំ  អត្តនោ បន ទុទ្ទសំ
ជិន្នា បតិញ្ច ជារញ្ច  មញ្ញេ ត្វញ្ញេវ ឈាយសិ ។

(១៦២) ឯវមេតំ មិគរាជ  យថា ភាសសិ ជម្ពុក
សា នូនាហំ ឥតោ គន្ត្វា  ភត្តុ ហេស្សំ វសានុគា ។

(១៦៣) យោ ហារេ មត្តិកំ ថាលំ  កំសថាលម្បិ សោ ហារេ
កតំយេវ តយា បាបំ  បុនបេវំ ករិស្សសីតិ ។

ចុល្លធនុគ្គហជាតកំ ចតុត្ថំ ។

## កបោតកជាតកំ

(១៦៤) ឥទានិ ខោម្ហិ សុខិតោ អរោគោ
និក្កណ្ឋកោ និប្បតិតោ កបោតោ
កាហាមិ ទានិ ហទយស្ស តុដ្ឋឹ
តថា ហិ មំ មំសសាកំ ពលេតិ ។



(១៦១) (ចចកនិយាយថា) ទោសរបស់ជនទាំងឡាយឯទៀត ឃើញបានដោយងាយ ចំណែកខាងទោសរបស់ខ្លួន ឃើញបានដោយក្រណាស់ នាងឯងជាស្រីសាបសូន្យចាកប្ដី និងសហាយសម្លាញ់ ជាងអញទៅទៀត ។

(១៦២) (នាងនោះនិយាយថា) ម្នាលស្ដេចម្រឹគ ជម្ពុកៈ អ្នកនិយាយយ៉ាងណា ពាក្យនុ៎ះ យ៉ាងហ្នឹងហើយ ខ្ញុំនោះ ទៅអំពីទីនេះ នឹងលុះអំណាចប្ដី ដោយពិត ។

(១៦៣) (សក្កទេវរាជ ពោលថា) អ្នកណា ហ៊ានលួចភាជន៍ដី អ្នកនោះ គង់ហ៊ានលួចភាជន៍សំរឹទ្ធិទៀត បាបដែលនាង បានធ្វើរួចហើយ នាងនឹងធ្វើយ៉ាងនេះទៀត មិនខានឡើយ ។

ចប់ ចុល្លធនុគ្គហជាតក ទី ៤ ។

## កបោតកជាតក

(១៦៤) (ក្អែកនិយាយថា) ឥឡូវនេះ អញបានសុខ មិនមានរោគ មិនមានបន្លា ដូចបក្សី (ព្រោះ) ព្រាបហើរចេញទៅហើយ ឥឡូវនេះ អញនឹងធ្វើនូវសេចក្ដីត្រេកអរ នៃចិត្ត ព្រោះថា សាច់ និងអន្លក់ រមែងញុំាងអញ ឲ្យមានកំឡាំង ។

(១៦៥)កាយំ ពលាកា សិខិនី ចោរី លង្ឃិបិតាមហា
ឱរំ ពលាកេ អាគច្ឆ ចណ្ឌោ មេ វាយសោ សខា ។

(១៦៦)អលញ្ហិ តេ ជគ្ឃិតាយេ មមំ ទិស្វាន ឯទិសំ
វិលូនំ សូទបុត្តេន បិដ្ឋមទ្ទេន មក្ខិតំ ។

(១៦៧)សុន្ហាតោ សុវិលិត្តោសិ អន្នបានេន តប្បិតោ
កណ្ឋេ ច តេ វេឡុរិយោ អកមាសិ កជង្គលំ ។

(១៦៨)មា តេ មិត្តោ អមិត្តោ វា អគមាសិ កជង្គលំ
បិញ្ឆានិ តត្ថ លាយិត្វា កណ្ឋេ ពន្ធន្តិ វដ្ដនំ ។

(១៦៩) បុន បាបជ្ជសី សម្ម សីលំ ហិ តវ តាទិសំ
ន ហិ មានុសកា ភោគា សុភុញ្ជា ហោន្តិ បក្ខិនោតិ ។

កបោតកជាតកំ និដ្ឋិតំ ។

អឌ្ឍវគ្គោ តតិយោ ។



(១៦៥ (ក្រោបនិយាយចំអកថា ) នេះជាកុកញី ជាសត្វមានក់ពោយ ជាចោរ មានពពកជាជីតា នែនាងកុក នាងចូរមកខាងអាយ ក្អែកជាសម្លាញ់របស់ខ្ញុំ កាច ។

(១៦៦) ( ក្អែកនិយាយថា ) អ្នកមិនគួរសើចនឹងខ្ញុំ ព្រោះឃើញខ្ញុំ (ដល់នូវសេចក្តីទុក្ខ) យ៉ាងនេះ ដែលត្រូវកូនអ្នកគ្រួ ដកស្លាប ប្រឡាក់ដោយម្សៅម៉ត់ ។

(១៦៧) ( ក្រោបនិយាយថា ) អ្នកមានខ្លួនងូតស្អាត ស្រលាបដោយល្អ ឆ្អែតស្កប់ស្កល់ ដោយបាយនឹងទឹក អ្នកមានកែវពៃទូរ្យពាក់ក នឹងទៅកាន់នគរកជង្គលៈឬ ។

(១៦៨) (ក្អែកនិយាយថា) សត្វជាមិត្ត ឬ ជាសត្រូវរបស់អ្នក កុំទៅកាន់នគរកជង្គលៈឡើយ ពួកជនក្នុងនគរនោះ បានចាប់បោច ហើយចងប្រឡៅក្រងក ។

(១៦៩) (ក្រោបនិយាយថា) ម្នាលសម្លាញ់ អ្នកនឹងដល់នូវអំពើ យ៉ាងនេះទៀត ព្រោះមារយាទរបស់អ្នក តែយ៉ាងហ្នឹង ភោគៈទាំងឡាយ របស់មនុស្ស មិនមែនសត្វស្លាប បរិភោគបានទេ ។

ចប់ កបោតកជាតក ។

ចប់ អឌ្ឍវគ្គ ទី ៣ ។

## តស្សុទ្ទានំ

អថ វណ្ណ សសីល ហិរិ លតតោ
សុមុខាសិ សសាលិយ ចិត្តវរោ
អថ បក្ខ បលាស សរាជ សរោ
យវ បាល កុរោគក បណ្ណរស ។

## តត្រ វគ្គុទ្ទានំ ភវតិ

ជិនញ្ញ វណ្ណំ អសមំ វគ្គុប្បរំ
សុរេសិតា ជាតកត្ថិ សត្តិ វីសតិ
បរោសតោ ព្រហ្មចរិត្តមុត្ត-
ភវេន គាថា អត្ថវតី សុព្យញ្ជនា ។

បញ្ចកនិបាតំ និដ្ឋិតំ ។

---



## ឧទ្ទាននៃជាតកនោះគឺ

និយាយអំពីវណ្ណារោហជាតក ១ សីលវីមំសជាតក ១ ហិរិជាតក ១ ខជ្ជោបនកជាតក ដែលបុគ្គលបានប្រយោជន៍ ១ ស្វាមានមុខល្អ ១ (គុម្ពិយជាតក ១) សាលិយជាតក ១ មិត្តដ៏ប្រសើរ ១ បក្ខ ១ បលាសជាតក ១ ព្រះរាជកុមារ (ព្រះនាមទីឃាវុ) ១ មិតរបាលក-ជាតក ១ ចុយជំណើប ១ ចចកកាល ១ កាបាលកជាតក ១ រួមជា ១៥ ជាតក ។

## ឧទ្ទានវគ្គ មានក្នុងបញ្ចកនិបាតនោះគឺ

អំពីមណិកុណ្ឌលវគ្គ ( និយាយអំពីបុគ្គលសាបស្បថ ជាតដែនជាដើម ) វណ្ណារោហវគ្គ អំពីវត្ថុនានាទៀត មិនសើត្តា វគ្គទាំងឡាយ ២០ ដែលព្រះសុគត សំដែងទុកល្អហើយ ហៅថា ជាតក ព្រះសត្ថិកាចារ្យ បានសំដែងនូវគាថា នៃព្រហ្មចរិយធម៌ ដ៏ប្រសើរ របស់ព្រះអង្គទាំងឡាយ មានអត្ថព្រមទាំងព្យញ្ជនៈ (បរិបូណ៌) ។

ចប់ បញ្ចកនិបាត ។

# ឆក្កនិបាតជាតកំ

## អាវារិយវគ្គោ

### អាវារិយជាតកំ

(១៣០) មាសុ កុជ្ឈ ភូមិបតិ   មាសុ កុជ្ឈ រថេសភ
កុទ្ធំ អប្បដិកុជ្ឈន្តោ   រាជា រដ្ឋស្ស បូជិតោ
គាមេ វា យទិ វារញ្ញេ   និន្នេ វា យទិ វា ថលេ
សព្វត្ថមនុសាសាមិ   មាសុ កុជ្ឈ រថេសភ ។

(១៣១) អាវារិយបិតា នាម   អហុ គង្គាយ នាវិកោ
បុព្វេ ជនំ តារយិត្វា   បច្ឆា យាចតិ វេតនំ
តេនស្ស ភណ្ឌនំ ហោតិ   ន ច ភោគេហិ វឌ្ឍតិ ។

(១៣២) អតិណ្ណញ្ញេវ យាចស្សុ   អបារំ តាត នាវិក
អញ្ញោ ហិ តិណ្ណស្ស មនោ អញ្ញោ ហោតិ តិរេសិនោ(១) ។

---
១ ម. តរេសិនោ ។ ឱ. តាមេសិនោ ។

# ឆក្កនិបាតជាតក

## អាវារិយវគ្គ

### អាវារិយជាតក

(១៣០) (ព្រះពោធិសត្វទូន្មានថា) បពិត្រម្ចាស់ផែនដី សូមព្រះអង្គ កុំខ្ញាល់ បពិត្រព្រះអង្គ ប្រសើរលើរថ សូមព្រះអង្គ កុំខ្ញាល់ ព្រះរាជា កាលមិនខ្ញាល់តប ចំពោះបុគ្គលដែលខឹង ក្សត្រជាទីបូជា អាត្មា តែងប្រៀនប្រដៅមនុស្ស ក្នុងទីទាំងពួង គឺក្នុងស្រុក ក្នុងព្រៃ ទីទាប ឬទីទួល បពិត្រព្រះអង្គ ប្រសើរលើរថ សូមព្រះអង្គកុំខ្ញាល់ ។

(១៣១) (ព្រះសាស្តាត្រាស់ថា) នាយទូក ក្នុងទន្លេ គង្គា ឈ្មោះ អាវារិយបិតា តែងចម្លងជនទៅដំបូង ហើយទើបសុំយកថ្លៃឈ្នួល ក្នុងកាលខាងក្រោយ ហេតុនោះ ការឈ្លោះប្រកែក ក៏តែងតែមាន ដល់គាត់ គាត់ក៏មិនចម្រើន ដោយភោគសម្បត្តិទាំងឡាយ ។

(១៣២) (ពោធិសត្វទូន្មានថា) ម្នាលនាយទូក ចូរអ្នកសុំយក ថ្លៃ ចំពោះមនុស្ស ដែលមិនទាន់ឆ្លង ទៅកាន់ត្រើយខាងនាយ ឲ្យហើយសិន ព្រោះថា ចិត្តមនុស្សដែលឆ្លងហើយដទៃ ចិត្តរបស់មនុស្ស អ្នកស្វែងរកត្រើយ (ត្រូវការឆ្លង) ដទៃ ។

(១៣៣)គាមេ វា យទិ វារញ្ញេ   និន្នេ វា យទិ វា ថលេ
សព្វត្ថមនុសាសាមិ   មាសុ កុជ្ឈិត្ថ តារិក ។

(១៣៤)យាយេវ អនុសាសនិយា រាជា គាមវរំ អទា
តាយេវ អនុសាសនិយា   នាវិកោ បហរី មុខំ ។

(១៣៥)ភត្តំ ភិន្នំ ហតា ភរិយា   គព្ភោ ច បតិតោ ឆមា
មិគោវ ជាតរូបេន   ន តេនត្ថំ អវឌ្ឍិតុន្តិ(១) ។

អាវារិយជាតកំ បឋមំ ។

## សេតកេតុជាតកំ

(១៣៦) មា តាត កុជ្ឈិ ន ហិ សាធុ កោធោ
ពហុម្បិ តេ អទិដ្ឋំ អស្សុតញ្ច
មាតាបិតា ទិសា(២) តាត សេតកេតុ
អាចរិយមាហុ ទិសតំ បសត្ថា ។

១ ឱ. អវឌ្ឍិតុន្តិ ។ ២ ឱ. ទិសតា សេតកេតុ ។ ៣. ទិសា តា សេតកេតុ ។



(១៣៣) អាត្មា ដែលប្រៀនប្រដៅមនុស្ស ក្នុងទីទាំងពួង គឺក្នុងស្រុក ឬក្នុងព្រៃ ទីទាប ឬទីទួល ម្នាលនាយទូក ចូរអ្នកកុំខឹង ។

(១៣៤) (ព្រះសាស្តាត្រាស់ថា) ព្រះរាជា ទ្រង់ប្រទានស្រុកសួយ ដោយពាក្យប្រៀនប្រដៅណា នាយទូកក៏ទះមាត់ (ឥសី) ដោយពាក្យប្រៀនប្រដៅនោះដែរ ។

(១៣៥) ភាជន៍បាយក៏បែក ភរិយាក៏ត្រូវខ្ញុំប្រហារ គភ៌របស់ភរិយា ក៏ធ្លាក់ចុះទៅលើផែនដី មនុស្សពាល មិនញ៉ាំងប្រយោជន៍ឲ្យចំរើន ដោយទ្រព្យនោះ ដូចជាម្រឹគ មិនចម្រើន ដោយមាសព្រាត់ ។

ចប់ អាវារិយជាតក ទី ១ ។

## សេតកេតុជាតក

(១៣៦) (អាចារ្យទិសាបាមោក្ខ ទូន្មានសេតកេតុព្រាហ្មណ៍ថា) ម្នាលអ្នក ចូរអ្នកកុំខឹង ព្រោះថា ការខឹងជាការមិនល្អទេ អ្នកមិនដែលឃើញ មិនដែលលឮ នូវទិសជាច្រើនទេ ម្នាលអ្នក ឈ្មោះ សេតកេតុ មាតា-បិតា ទុកជាទិស (ខាងដើម អ្នកប្រាជ្ញទាំងឡាយ) ពោលថា អាចារ្យទុកជា (ទិសខាងស្តាំ) ប្រសើរជាងទិសទាំងឡាយ ។

(១៣៧) អគារិនោ អន្នទបានវត្ថទា

អវ្ហាយិកា តម្បិ ទិសំ វទន្តិ

ឯសា ទិសា បរមា សេតកេតុ

យំ បត្វា ទុក្ខី សុខិនោ ភវន្តិ ។

(១៣៨) ខរាជិនា ជដិលា បង្កទន្តា

ទុម្មក្ខរូបា យេមេ ជបន្តិ មន្តេ

កច្ចិ នុ តេ មានុសកេ បយោគេ

ឥទំ វិទូ បរិមុត្តា អបាយា ។

(១៣៩) បាបានិ កម្មានិ ករិត្វា រាជ

ពហុស្សុតោ ចេ ន ចរេយ្យ ធម្មំ

សហស្សវេទោបិ ន តំ បដិច្ច

ទុក្ខា បមុច្ចេ ចរណំ អបត្វា ។



(១៣៧) គ្រូជនជាគ្រហស្ថ ជាអ្នកឲ្យបាយទឹកទីលំពក់ ជាអ្នកហៅរក (ឲ្យអ្នកទទួលទាន) ណា អ្នកប្រាជ្ញទាំងឡាយ មានព្រះពុទ្ធជាដើម ពោលនូវបុគ្គលនោះថា ជាទិស (ខាងលើ) ម្នាលសេតកេតុ បុគ្គលមានទុក្ខ ត្រឡប់ជាបានសេចក្ដីសុខវិញ ព្រោះដល់នូវទិស (និព្វាន) ណា ទិសនុ៎ះ ជាទិសដ៏ប្រសើរ ។

(១៣៨) (ព្រះរាជាសួរបុរោហិតថា) ជដិលទាំងឡាយណា ស្លៀកស្បែកខ្លាឃ្មុំទាំងក្រចក មានធ្មេញប្រកបដោយមន្ទិល មានសភាពដ៏សៅហ្មង តែងស្វាធ្យាយនូវមន្តទាំងឡាយ ជដិលទាំងនោះ (ឋិតនៅ) ក្នុងសេចក្ដីព្យាយាម ជារបស់មនុស្ស ដឹងច្បាស់នូវលោកនេះ បានរួចចាកអបាយឬទេ ។

(១៣៩) (បុរោហិតទូលតបថា) បពិត្រព្រះរាជា បុគ្គលជាពហុស្សូត ធ្វើបាបកម្មទាំងឡាយ មិនប្រព្រឹត្តធម៌ សូម្បីរៀនវេទដ៏ច្រើន ហើយ អាស្រ័យការរៀនវេទនោះ មិនបានដល់នូវការប្រព្រឹត្តិ ក៏រមែងមិនបានរួចចាកទុក្ខឡើយ ។

(១៦០) សហស្សវេទោបិ ន តំ បដិច្ច
ទុក្ខា បមុញ្ចេ ចរណំ អបត្វា
មញ្ញាមិ វេទា អផលា ភវន្តិ
សសំយមំ ចរណញ្ញេវ សច្ចំ ។

(១៦១) ន ហេវ វេទា អផលា ភវន្តិ
សសំយមំ ចរណញ្ញេវ សច្ចំ
កិត្តិញ្ច បប្បោតិ អធិច្ច វេទេ
សន្តឹ បុណេតិ ចរណេន ទន្តោ ។

សេតកេតុជាតកំ ទុតិយំ ។

## ទរីមុខជាតកំ

(១៦២) បង្កោ ច កាមា បលិបោ ច កាមា
ភយញ្ច មេតំ តិមូលំ បវុត្តំ
រជោ ច ធូមោ ច មយា បកាសិតា
ហិត្វា តុវំ បព្វជ ព្រហ្មទត្ត ។



(១៦០) (ព្រះរាជាពោលថា) បុគ្គលអ្នកចេះច្រើន អាស្រ័យនូវការចេះដឹងនោះ តែមិនបានដល់នូវការប្រព្រឹត្តិ គឺវៀរមិនរួចចាកទុក្ខ ខ្ញុំសំគាល់ថា ការចេះដឹង មិនមានផលទេ ការប្រព្រឹត្តិ ព្រមទាំងការសង្រួមទៀងពិត ទើបមានផល ។

(១៦១) (បុរោហិតទូលថា) ការចេះដឹង មិនមែនឥតផលទេ ការប្រព្រឹត្តិ ព្រមទាំងការសង្រួមនោះឯង ក៏មិនទៀងទាត់ដែរ បុគ្គលដល់នូវកិត្តិសព្ទ ព្រោះអាស្រ័យការចេះដឹង បុគ្គលមានខ្លួនទូន្មានបានហើយ ដល់នូវព្រះនិព្វាន ព្រោះការប្រព្រឹត្តិ ។

ចប់ សេតកេតុជាតក ទី ២ ។

## ទរីមុខជាតក

(១៦២) (ព្រះបច្ចេកពុទ្ធទរីមុខ ថ្វាយឱវាទដល់ព្រះរាជាព្រហ្មទត្តថា) កាមទាំងឡាយ ដូចភក់ផង កាមទាំងឡាយដូចគ្រឿងស្អិតផង នេះជាភ័យមានឫសគល់ ៣ យ៉ាង ដែលព្រះសម្ពុទ្ធពោលទុកហើយ កាមទាំងឡាយ ដូចធូលីផង ដូចផ្សែងផង ដែលអាត្មាប្រកាសហើយ បពិត្រព្រះរាជាព្រហ្មទត្ត សូមព្រះអង្គលះបង់ (កាមទាំងនោះ) ហើយបួសចុះ ។

(១៤៣) គធិតោ ច រត្តោ ច អធិមុច្ឆិតោ ច
កាមេស្វាហំ ព្រាហ្មណ ភឹសរូបំ
តំ នុស្សហេ ជីវិកត្ថោ បហាតុំ
កាហាមិ បុញ្ញានិ អនប្បកានិ ។

(១៤៤) យោ អត្ថកាមស្ស ហិតានុកម្បិនោ
ឱវជ្ជមានោ ន ករោតិ សាសនំ
ឥទមេវ សេយ្យោ ឥតិ មញ្ញមានោ
បុនប្បុនំ គព្ភមុបេតិ មន្ទោ ។

(១៤៥) សោ ឃោររូបំ និរយំ ឧបេតិ
សុភាសុភំ មុត្តករីសបូរំ
សត្តា សកាយេ ន ជហន្តិ គិទ្ធា
យេ ហោន្តិ កាមេសុ អវីតរាគា ។

(១៤៦) មីឡ្ហេន លិត្តា រុហិរេន មក្ខិតា
សេម្ហេន លិត្តា ឧបនិក្ខមន្តិ
យំ យំ ហិ កាយេន ផុសន្តិ តាវទេ
សព្វំ អសាតំ ទុក្ខមេវ កេវលំ ។



(១៤៣) (ព្រះរាជាព្រហ្មទត្ត ពោលថា) បពិត្រព្រាហ្មណ៍ ខ្ញុំជាអ្នកជាប់ចំពាក់ ត្រេកអរត្រេកត្រអាលក្នុងកាមទាំងឡាយ ជាអ្នកត្រូវការដោយជីវិត មិនអាចដើម្បីលះនូវកាម មានសភាពគួរខ្លាចនោះបានទេ ខ្ញុំនឹងធ្វើបុណ្យទាំងឡាយច្រើន ។

(១៤៤) (ព្រះបច្ចេកពុទ្ធពោលថា) បុគ្គលណា កាលគេប្រាថ្នាសេចក្តីចំរើន អនុគ្រោះ ដោយប្រយោជន៍ ប្រៀនប្រដៅ តែមិនធ្វើតាមពាក្យប្រៀនប្រដៅ សំគាល់ថា នេះឯងប្រសើរ ជាមនុស្សល្ងង់ខ្លៅ រមែងចូលទៅកាន់គភ៌ញយ ៗ ។

(១៤៥) បុគ្គលល្ងង់ខ្លៅនោះ រមែងចូលទៅកាន់នរក មានសភាពដ៏គគ្រឹក ជាទីមិនស្អាតដល់ពួកកុលបុត្តអ្នកស្អាត ពេញដោយមូត្រនឹងករីស សត្វទាំងឡាយណា ជាអ្នកមិនទាន់ប្រាសចាករាគៈ ជាប់ចំពាក់ក្នុងកាមទាំងឡាយ សត្វទាំងឡាយនោះ រមែងមិនលះបង់នូវសកាយៈ (ការនៅក្នុងគភ៌) ។

(១៤៦) សត្វទាំងឡាយ ប្រសូត (ចាកគភ៌នៃមាតា) រមែងជាប់ ដោយលាមក ប្រឡាក់ដោយឈាម ជាប់ដោយស្លេស្ម ប៉ះពាល់នូវវត្ថុជាទីប្រសូតណា ៗ ដោយកាយ ក្នុងខណៈនោះ វត្ថុទាំងអស់នោះ ជារបស់មិនស្អាត សុទ្ធតែជាទុក្ខទាំងអស់ ។

(១៦៧) និស្វា វនាមិ ន ហិ អញ្ញតោ សវំ
បុត្តេនិកសំ ពហុកំ សកមិ ។
ចិត្រាហិ គាថាហិ សុភាសិតាហិ
ទរីមុខោ និជ្ឈាបយិ សុមេធន្តិ ។

ទរីមុខជាតកំ តតិយំ ។

## នេរុជាតកំ

(១៦៨) កាកោលា កាកសង្ឃា ច មយញ្ច បតតំ វរា
សព្វេវ សទិសា ហោម ឥមំ អាគម្ម បព្វតំ ។
(១៦៩) ឥធ សីហា ច ព្យគ្ឃា ច សកុណា ច មិគាធមា
សព្វេវ សទិសា ហោន្តិ អយំ កោ នាម បព្វតោ ។
(១៧០) ឥមំ នេរុន្តិ ជានន្តិ មនុស្សា បព្វតុត្តមំ
ឥធ វណ្ណេន សម្បន្នា វសន្តិ សព្វបាណិនោ ។



(១៦៧) គាត្ថាឃើញ ទើបពោល មិនមែនស្តាប់ អំពីបុគ្គលដទៃទេ គាត្ថាលើកឃើញ ខ្លួបុត្តនិកសច្រើន ។

(ព្រះសម្មាសម្ពុទ្ធត្រាស់ថា) ព្រះបច្ចេកពុទ្ធ ព្រះនាមទរីមុខៈ ពន្យល់ ស្តេចព្រហ្មទត្ត មានប្រាជ្ញាល្អ ដោយគាថាទាំងឡាយ ដ៏វិចិត្រ ដែលសំដែងហើយដោយល្អ ។

ចប់ ទរីមុខជាតក ទី ៣ ។

## នេរុជាតក

(១៦៨) (សុវណ្ណហង្សជាប្អូន និយាយថា) ពួកក្អែកព្រៃ ក្អែកស្រុក នឹងយើង ជាសត្វប្រសើរ ជាងពួកសត្វស្លាប មកដល់ភ្នំនេះ មាន សម្បុរប្រហែលគ្នាទាំងអស់ ។

(១៦៩) ពួកសីហៈ ខ្លាធំ សត្វស្លាប ម្រឹគថោកទាប ក្នុងទីនេះ មានសម្បុរប្រហែលគ្នាទាំងអស់ តើភ្នំនេះ ឈ្មោះអ្វី ។

(១៧០) (សុវណ្ណហង្សជាបងពោលថា) មនុស្សទាំងឡាយដឹងថា ភ្នំដ៏ឧត្តមនេះឈ្មោះនេរុ សព្វសត្វទាំងឡាយ នៅក្នុងទីនេះ ជា សត្វបរិបូណ៌ដោយពណ៌សម្បុរ ។

(១៨១)អមាននា យត្ថ សិយា  សន្តានំ វា វិមាននា

ហីនសម្មាននា វាបិ  ន តត្ថ វសតឹ វសេ ។

(១៨២)យត្ថាលសោ ច ទក្ខោ ច សូរោ ភីរុ ច បូជិយា

ន តត្ថ សន្តោ វសន្តិ  អវិសេសករេ នរេ[១]។

(១៨៣)នាយំ នេរុ វិភជតិ  ហីនឧក្កដ្ឋមជ្ឈិមេ

អវិសេសករោ នេរុ  ហន្ទ នេរុំ ជហាមសេតិ។

នេរុជាតកំ ចតុត្ថំ ។

## អាសង្កជាតកំ

(១៨៤)អាសាវតី នាម លតា  ជាតា ចិត្តលតាវនេ

តស្សា វស្សសហស្សេន  ឯកំ និព្វត្តតេ ផលំ។

(១៨៥) តំ ទេវា បយិរុបាសន្តិ  តាវ ទូរផលេ សតិ

អាសីសេវ តុវំ រាជ  អាសា ផលវតី សុខា។

១ ម. នរេ ។



(១៨១) (សុវណ្ណហង្សជាប្អូនពោលថា) ការមិនរាប់អាន ឬការមើលងាយ នូវពួកសប្បុរស ឬក៏ការរាប់អានបុគ្គលថោកទាប មានក្នុងទីណា បុគ្គលមិនគប្បីនៅ ក្នុងទីនោះទេ ។

(១៨២) មនុស្សខ្ជិល នឹងមនុស្សឧស្សាហ៍ មនុស្សក្លៀវក្លា នឹងមនុស្សខ្លាច គេបូជាស្មើគ្នា ក្នុងទីណា សប្បុរសទាំងឡាយ រមែងមិននៅក្នុងទីនោះ ជាកន្លែងមិនធ្វើឲ្យប្លែកគ្នា ។

(១៨៣) ភ្នំនេរុនេះ មិនចែកនូវសត្វ ឲ្យថោកទាប ឲ្យខ្ពង់ខ្ពស់ ឲ្យជាកណ្តាល ភ្នំនេរុមិនធ្វើ ឲ្យប្លែកគ្នាបាន បើដូច្នោះ យើងទាំងឡាយ លះបង់នូវភ្នំនេរុចោល ។

ចប់ នេរុជាតក ទី ៤ ។

## អាសង្កជាតក

(១៨៤) (នាងអាសង្កកុមារីពោលថា) វល្លិឈ្មោះអាសាវតី កើតក្នុងឧទ្យានឈ្មោះ ចិត្តលតាវ័ន វល្លិនោះ ក្នុងមួយពាន់ឆ្នាំ ទើបកើតផ្លែ ១ ។

(១៨៥) ទោះបើផ្លែមាននៅ ក្នុងទីឆ្ងាយដល់ម៉្លោះ ពួកទេវតានៅតែចូលទៅរកវល្លិនោះ បពិត្រព្រះរាជា សូមព្រះអង្គប្រាថ្នាចុះ សេចក្តីប្រាថ្នា រមែងមានផល នាំមកនូវសេចក្តីសុខ ។

(១៥៦) អាសីសេថេវ សោ បក្ខី អាសីសេថេវ សោ ទិជោ
តស្សេវាសា សមិជ្ឈន្តិ តាវ ពហុកតា សតា
អាសីសេថ តុវំ ភទ្ទ អាសា ផលវតី សុខា ។

(១៥៧) សមេ្មសិ វាចាយ ន ច សមេ្មសិ កម្មុនា
មាលា សោវេយ្យកស្សេវ វណ្ណវន្តា អគន្ធិកា ។

(១៥៨) អផលំ មធុរំ វាចំ យោ មិត្តេសុ បកុព្វតិ
អទទំ អវិស្សជំ ភោគំ សន្ធិ តេនស្ស ជីរតិ ។

(១៥៩) យំ ហិ កយិរា តំ ហិ វទេ យំ ន កយិរា ន តំ វទេ
អករោន្តំ ភាសមានំ បរិជានន្តិ បណ្ឌិតា ។

(១៦០) ពលញ្ច វត មេ ខីណំ បាថេយ្យញ្ច ន វិជ្ជតិ
សង្កេ បាណុបរោធាយ ហន្ទ ទានិ វជាមហំ ។



(១៥៦) អំបាលសត្វស្លាបនោះ (កុក) នៅប្រាថ្នាបាន អំបាលសត្វមានកំណើតពីរ គង់ប្រាថ្នាបាន ថ្វីបើ ខ្លួនមាននៅក្នុងទីឆ្ងាយ សេចក្តីប្រាថ្នារបស់កុកនោះ គង់សម្រេចមិនខាន បពិត្រព្រះរាជា សូមព្រះអង្គប្រាថ្នាចុះ សេចក្តីប្រាថ្នា រមែងមានផល ជាសុខ ។

(១៥៧) (ព្រះរាជាព្រហ្មទត្តពោលថា) នាងបានញ៉ាំងខ្ញុំ ឲ្យត្រេកអរដោយវាចា មិនឲ្យត្រេកអរដោយការងារ ដូចជាផ្កាកម្រងនៃឈើសោវេយ្យកៈ មានតែពណ៌ មិនមានក្លិន ។

(១៥៨) បុគ្គលណា មិនឲ្យ មិនលះបង់ភោគៈ គ្រាន់តែធ្វើនូវពាក្យពីរោះ ដែលឥតផល ចំពោះមិត្តទាំងឡាយ តំណ (នៃសេចក្តីស្និទ្ធស្នាល) របស់បុគ្គលនោះ រមែងសាបសូន្យទៅ ដោយហេតុនោះឯង ។

(១៥៩) ពិតណាស់ បុគ្គលធ្វើនូវអំពើណា គប្បីនិយាយនូវអំពើនោះ មិនធ្វើនូវអំពើណា មិនគប្បីនិយាយនូវអំពើនោះ បណ្ឌិតទាំងឡាយ រមែងកំណត់ដឹង នូវបុគ្គលអ្នកមិនធ្វើ គ្រាន់តែនិយាយ ។

(១៦០) កម្លាំងរបស់ខ្ញុំអស់ហើយ ចំណីស្បៀងអាហារក៏មិនមាន ខ្ញុំរង្កៀស ចំពោះការបៀតបៀនជីវិត បើដូច្នោះ ខ្ញុំនឹងទៅ ឥឡូវនេះ ។

(១៦១)ឯតទេវ ហិ មេ នាមំ យំ នាមស្មិំ រតេ សត
អាគមេហិ មហារាជ បិតរំ អាមន្តយាមហំ ។

អាសង្កជាតកំ បញ្ចមំ ។

## មិគាលោបជាតកំ

(១៦២)ន មេ រុច្ចតិ មិគាលោប យស្ស តេ តាទិសី គតិ
អតុច្ចំ តាត គច្ឆសិ(១) អភូមឹ តាត សេវសិ ។

(១៦៣)ចតុក្កណ្ណំវ កេទារំ យទា តេ បថវី សិយា
តតោ តាត និវត្តស្សុ មាស្សុ ឯត្តោ បរំ គមិ ។

(១៦៤)សន្តិ អញ្ញេបិ សកុណា បត្តយានា វិហង្គមា
អក្ខិត្តា វាតវេគេន នដ្ឋា តេ សស្សតីសមា ។

(១៦៥)អកត្វា អបរណ្ណស្ស បិតុ វុឌ្ឍស្ស សាសនំ(២)
កាលវាតេ អតិក្កម្ម វេរម្ភានំ វសំ អគា ។

---
១ ម. ឆ. បតសិ ។ ២ ម. គាសនំ ។



(១៦១) (ពានរាសង្កាទូលថា) បពិត្រព្រះអង្គ ទ្រង់ប្រសើរលើផែនដី ពាក្យណាដែលមានក្នុងឈ្មោះ ពាក្យនុ៎ះឯង ជាឈ្មោះ របស់ខ្ញុំព្រះអង្គ បពិត្រមហារាជ សូមព្រះអង្គរង់ចាំចុះ ខ្ញុំព្រះអង្គ នឹងអញ្ជើញបិតាសិន ។

ចប់ អាសង្កជាតក ទី ៥ ។

## មិគលោបជាតក

(១៦២) (ត្បាតពោធិសត្វ និយាយនឹងកូនថា) ម្នាលមិគលោបៈ ដំណើររបស់អ្នកត្បាតដូច្នោះ មិនពេញចិត្តអញទេ ម្នាលកូន ម្យ៉ាង អ្នកហើរទៅខ្ពស់ពេក ម្នាលកូន អ្នកសេពគប់នូវទី មិនមែនផែនដី ។

(១៦៣) វេលាដីប្រាកដដល់អ្នក ដូចជាស្រែមានជ្រុង ៤ ម្នាលកូន ចូរអ្នកត្រឡប់ អំពីទីនោះមកវិញ កុំទៅហួសអំពីទីនេះឡើយ ។

(១៦៤) ពួកសកុណជាតិឯទៀត មានស្លាបជាយាន ទៅកាន់អាកាស ពួកសត្វទាំងនោះ សំគាល់ខ្លួនថា ស្មើដោយផែនដីទៀងទាត់ ត្រូវកំឡាំងខ្យល់បក់បោកវិនាស ។

(១៦៥) (ព្រះសម្មាសម្ពុទ្ធ ទ្រង់សំដែងថា) មិគលោបៈ មិនធ្វើតាមពាក្យប្រដៅរបស់បិតាចាស់ ឈ្មោះអបរណ្ណៈ ហើរកន្លងនូវខ្យល់ ផ្ទុំកាល ធ្លាក់ទៅដល់អំណាចនៃខ្យល់ក្បេរ ។

(១៦៦) តស្ស បុត្តា ច ទារា ច   យេ ចញ្ញេ អនុជីវិនោ
សព្វេ ព្យសនមាបាទុំ   អនោវាទករេ ទិជេ ។
(១៦៧) ឯវម្បិ ឥធ វុឌ្ឍានំ   យោ វាក្យំ នាវពុជ្ឈតិ
អតិសីមំ ចរោ ទិត្តោ   គិជ្ឈោវាតីតសាសនោ
សព្វេ ព្យសនំ បប្បោន្តិ   អកត្វា វុទ្ធសាសនន្តិ ។

មិគាលោបជាតកំ ឆដ្ឋំ ។

## សិរិកាឡកណ្ណិជាតកំ

(១៦៨) កា នុ កាឡេន វណ្ណេន   ន ចាសិ បិយទស្សនា
កា វា ត្វំ កស្ស វា ធីតា   កថំ ជានេមុ តំ មយំ ។
(១៦៩) មហារាជស្សហំ ធីតា   វិរូបក្ខស្ស ចណ្ឌិយា
អហំ កាឡី អលក្ខិកា   កាឡកណ្ណីតិ មំ វិទូ
ឱកាសំ យាចិតោ ទេហិ   វសេមុ តវ សន្តិកេ ។



(១៦៦) កូនក្តី ប្រពន្ធក្តី បួសក្តីដទៃទៀត ជាអ្នកចិញ្ចឹមជីវិត តាមមិគ-
លោបៈនោះ ពួកសត្វស្លាបទាំងអស់ ក៏ដល់នូវសេចក្តីវិនាស
ព្រោះទិជជាតិ (មិគាលោបៈ) មិនធ្វើតាមឱវាទ ។
(១៦៧) បុគ្គលណា មិនយល់នូវពាក្យ របស់បុគ្គលចាស់ទុំ ក្នុងលោកនេះ
បុគ្គលនោះ (ដល់នូវសេចក្តីវិនាស) ដូចជាត្មាតកន្លងពាក្យប្រៀន
ប្រដៅ ជាសត្វក្អើតក្អើនក្រចាប់ទៅ កន្លងហួសដែន ជនទាំងអស់
ដល់នូវសេចក្តីវិនាស ព្រោះមិនធ្វើតាមពាក្យប្រដៅ របស់ព្រះពុទ្ធ ។

ចប់ មិគាលោបជាតក ទី ៦ ។

## សិរិកាឡកណ្ណិជាតក

(១៦៨) (សុចិបរិវារសេដ្ឋីពោធិសត្វ សួរនាងទេវធីតាឈ្មោះកាឡកណ្ណីថា)
នាងជាអ្វី មានវណ្ណៈខ្មៅ ទាំងមិនមានគ្រឿងមើលជាទីស្រឡាញ់
នាងជាអ្វី ឬជាធីតារបស់អ្នកណា យើងស្គាល់នាង ដូចម្តេចបាន ។
(១៦៩) (នាងកាឡកណ្ណី ឆ្លើយថា) ខ្ញុំឈ្មោះចណ្ឌិយា ជាធីតានៃ
មហារាជ ឈ្មោះ វិរូបក្ខៈ ខ្ញុំមានសម្បុរខ្មៅ ជាស្រីឥតបុណ្យ
ពួកទេវតា តែងស្គាល់ខ្ញុំថា ជាកាឡកណ្ណី អ្នកកាលបើខ្ញុំសូមឱកាស
សូមឲ្យ យើងនឹងនៅក្នុងសំណាក់នៃអ្នក ។

(១៧០) កឹសីលេ កឹសមាចារេ   បុរិសេ និវិសេ ធុរំ

បុដ្ឋា មេ កាឡិ អក្ខាហិ   កថំ ជានេមុ តំ មយំ ។

(១៧១) មក្ខី បលាសី សារម្ភី   ឥស្សុកី មច្ឆរី សឋោ

សោ មយ្ហំ បុរិសោ កន្តោ   លទ្ធំ យស្ស វិនស្សតិ ។

(១៧២) កោធនោ ឧបនាហី ច   បិសុណោ ច វិភេទកោ

កណ្ដកាចារោ ផរុសោ   សោ មេ កន្តតរោ តតោ ។

(១៧៣) អជ្ជ សុវេតិ បុរិសោ   សទត្ថំ នាវពុជ្ឈតិ

ឱវជ្ជមានោ កុប្បតិ   សេយ្យសោ អតិមញ្ញតិ ។

(១៧៤) ទវប្បលុទ្ធោ បុរិសោ   សព្វមិត្តេហិ(១) ធំសតិ

សោ មយ្ហំ បុរិសោ កន្តោ   តស្មឹ ហោមិ អនាមយា ។

១ ម. សព្វមិត្តេសុ ។



(១៧០) (សេដ្ឋីពោធិសត្វសួរថា) នាងដាក់ចិត្តចំពោះបុរស មានសីលធម៌ ដូចម្ដេច មានសមាចារ ដូចម្ដេច ម្នាលនាងកាឡី នាងខ្ញុំសួរហើយ ចូរប្រាប់មក យើងនឹងស្គាល់នាង ដូចម្ដេចបាន ។

(១៧១) (នាងកាឡកណ្ណីឆ្លើយប្រាប់ថា) បុរសណា ជាអ្នកលុបគុណ ប្រឡូកកសន ប្រណាំងប្រជែង ច្រណែន កំណាញ់ ជាអ្នកអួតអាង បានទ្រព្យហើយបំផ្លាញទៅវិញ បុរសនោះ ជាទីត្រេក-អររបស់ខ្ញុំ ។

(១៧២) បុរសណា ច្រើនក្រោធ ចងសេចក្ដីក្រោធទុក ញុះញង់បំបែកមិត្ត ពោលពាក្យចាក់ដោត ដូចបន្លា ពោលពាក្យទ្រគោះ បុរសនោះ ជាទីត្រេកអរក្រៃលែង របស់ខ្ញុំជាងនោះ ទៅទៀត ។

(១៧៣) បុរសមិនយល់ប្រយោជន៍ របស់ខ្លួនថា (កិច្ចនេះត្រូវធ្វើ) ក្ដី ថ្ងៃនេះ ឬក្ដីថ្ងៃស្អែក កាលបើគេទូន្មាន ក៏ខឹងគប់ មើលងាយនូវបុគ្គលប្រសើរ ។

(១៧៤) បុរសណា ចាប់ចិត្តក្នុងល្បែង គឺកាមគុណ វង្វេងឃ្លាតចាកមិត្តទាំងពួង បុរសនោះ ជាទីត្រេកអររបស់ខ្ញុំ ទាំងខ្ញុំក៏មិនមានទោសអ្វី ចំពោះបុរសនោះទេ ។

(១៧៥) អបេហិ ឯត្តោ ត្វំ កាឡិ ។ នេតំ អម្ហេសុ យុជ្ជតិ
អញ្ញំ ជនបទំ គច្ឆ និគមេ រាជធានិយោ ។

(១៧៦) អហម្បិ ខោ តំ ជានាមិ នេតំ តុម្ហេសុ យុជ្ជតិ
សន្តិ លោកេ អលក្ខិកា សង្ឃរន្តិ ពហុំ ធនំ
អហំ ទេវោ ច មេ ភាតា ឧភោ នំ វិធមាមសេ ។

(១៧៧) កា នុ ទិព្វេន វណ្ណេន បថព្យា សុបតិដ្ឋិតា
កា ត្វំ កស្ស វា ធីតា កថំ ជានេមុ តំ មយំ ។

(១៧៨) មហារាជស្សហំ ធីតា ធតរដ្ឋសិរីមតោ
អហំ សិរី ច លក្ខី ច ភូរិបញ្ញាតិ មំ វិទូ
ឱកាសំ យាចិតោ ទេហិ វសេមុ តវ សន្តិកេ ។

(១៧៩) កឹសីលេ កឹសមាចារេ បុរិសេ និវិសេ តុវំ
បុដ្ឋា មេ លក្ខិ អក្ខាហិ យថា ជានេមុ តំ មយំ ។



(១៧៥) (ពោធិសត្វ តិះដៀលថា) ម្នាលនាងកាឡី នាងចូរចៀសចេញ អំពីទីនេះទៅ អំពើកាក្រក់នេះ មិនមានក្នុងយើងទាំងឡាយទេ នាងចូរទៅកាន់ជនបទ ឬនិគមរាជធានីដទៃចុះ ។

(១៧៦) (នាងកាឡកណ្ណី ពោលថា) ខ្ញុំក៏បានដឹងហេតុនោះដែរ អំពើនោះ មិនមានក្នុងអ្នកទេ ពួកជនជាអ្នកឥតបុណ្យក្នុងលោក រមែងប្រមូលទ្រព្យច្រើន ខ្ញុំនឹងទេវតាជាបងរបស់ខ្ញុំ ទាំងពីរនាក់ តែងបំផ្លាញទ្រព្យនុ៎ះ ។

(១៧៧) (ពោធិសត្វ សួរថា) នាងជាអ្វី មានវណ្ណៈជាទិព្វ មកឋិតលើផែនដី នាងជាអ្វី ឬជាធីតារបស់នរណា យើងនឹងស្គាល់នាង ដូចម្ដេចបាន ។

(១៧៨) (នាងសិរីទេវធីតា ពោលថា) ខ្ញុំជាធីតានៃមហារាជ ឈ្មោះធតរដ្ឋ ដ៏មានសិរី ខ្ញុំជាស្រីឈ្មោះសិរីផង លក្ខីផង ពួកទេវតា រមែងស្គាល់ខ្ញុំថា ជាស្រីមានប្រាជ្ញា ដូចផែនដី លោក ខ្ញុំសូមឱកាសហើយ សូមឱ្យ យើងនឹងសូមនៅ ក្នុងសំណាក់លោក ។

(១៧៩) (ពោធិសត្វសួរថា) នាងនឹងដល់ចិត្ត ចំពោះបុរស មានសីលធម៌ ដូចម្ដេច មានសមាចារៈ ដូចម្ដេច ម្នាលនាងលក្ខី ខ្ញុំសួរហើយ នាងចូរប្រាប់ យើងស្គាល់នាង ដូចម្ដេច ។

(១៨០) យោ ចាបិ សីតេ អថ វាបិ ឧណ្ហា
វាតាតបេ ឌំសសិរីសបេ ច
ខុទ្ទំ បិបាសំ អភិភុយ្យ សព្វំ
រត្តិន្ទិវំ យោ សតតំ និយុត្តោ
កាលាគតញ្ច ន ហាបេតិ អត្ថំ
សោ មេ មនាបោ និវសេ វតម្ហិ ។

(១៨១) អក្កោធនោ មិត្តវា ចាគវា ច
សីលូបបន្នោ អសឋោជុគតោ
សង្គាហកោ សខិលោ សណ្ហវាចោ
មហគ្គបត្តោបិ និវាតវុត្តិ
តស្មឹហ ហោសេ វិបុលា គភបិ
ទុម្មី សមុទ្ទស្ស យថាបិ វណ្ណំ ។





(១៨០) (មានសិរីទេវធីតា ពោលថា) បុរសណា គ្របសង្កត់ នូវត្រជាក់ក្តី ក្តៅក្តី ខ្យល់និងកំដៅថ្ងៃក្តី របោម ពស់តូច ពស់ធំក្តី ឃ្លានក្តី ស្រេកក្តីទាំងអស់ ហើយប្រកបព្យាយាមរឿយៗ ក្នុងវេលាយប់និងថ្ងៃ រមែងមិនញ៉ាំងប្រយោជន៍ ដែលតាំងនៅក្នុងកាលគួរឲ្យវិនាស បុរសនោះ ជាទីពេញចិត្តរបស់ខ្ញុំ ខ្ញុំគប្បីស៊ប់ចិត្តក្នុងបុរសនោះឯង ។

(១៨១) បុរសណា ជាអ្នកមិនក្រោធ មានកល្យាណមិត្ត មានការបរិច្ចាគ ជាអ្នកបរិបូណ៌ដោយសីល មិនមែនជាអ្នកលេងកោកក្រោស ជាអ្នកត្រង់ ជាអ្នកមានសង្គហធម៌ មានវាចាទន់ភ្លន់ មានវាចាពីរោះ សូម្បីដល់នូវភាពជាអ្នកធំ ក៏ប្រព្រឹត្តទន់ទាប ខ្ញុំជាអ្នកមានចិត្តធំទូលាយ ចំពោះបុរសនោះ ដូចជាលោក (ប្រាកដជារបស់ធំទូលាយ ដល់បុគ្គលដែលសំឡឹងមើល) នូវពណ៌របស់សមុទ្រ ។

(១៨២) យោ ចាបិ មិត្តេ អថវា អមិត្តេ
សេដ្ឋេ សរិក្ខេ អថបិ ហីនេ
អត្ថំ ចរន្តំ អថវា អនត្ថំ
អាវី រហោ សង្គហមេវ វត្តោ
វាចំ ន វជ្ជា ផរុសំ កទាចិ
មតស្ស ធីរស្ស ច តស្ស ហោមិ ។

(១៨៣) ឯសេវ យោ អញ្ញតរំ លភិត្វា
កន្តិំ សិរី មជ្ជតិ អប្បបញ្ញោ
តំ ធិក្ករំ វិសមំ ចរន្តំ
ការីសជាតំ(១) វិវជ្ជយាមិ ។

(១៨៤) អត្តនា កុរុតេ លក្ខី អលក្ខី កុរុតត្តនា
ន ហិ លក្ខី អលក្ខី វា អញ្ញោ អញ្ញស្ស ការកោតិ ។

សិរិកាឡកណ្ណិជាតកំ សត្តមំ ។

## កុក្កុដជាតកំ

(១៨៥) សុចិត្តបត្តច្ឆទន តម្ពចូឡ វិហង្គម
ឱរោហ ទុមសាខាយ មុធា ភរិយា ភវាមិ តេ ។

១ ម. ករីសដ្ឋានំ ។ ឱ. ករីសកំបំ ។



(១៨២) បុគ្គលណា ប្រព្រឹត្តនូវសេចក្តីសង្គ្រោះ ក្នុងចំពោះមុខ កំបាំងមុខ ចំពោះពួកមិត្តក្តី សត្រូវក្តី បុគ្គលប្រសើរក្តី ស្មើគ្នាក្តី ថោកទាបក្តី បុគ្គលអ្នកប្រព្រឹត្តនូវប្រយោជន៍ក្តី មិនមែនជាប្រ-យោជន៍ក្តី មិនពោលពាក្យអាក្រក់ ក្នុងកាលណាមួយ ខ្ញុំជាអ្នកគប់រក ចំពោះបុរសនោះ ទោះបីស្លាប់ក្តី រស់ក្តី ។

(១៨៣) បណ្តាគុណទាំងនុ៎ះ បុរសណាមួយ ជាអ្នកគ្មានបញ្ញា បាននូវសិរី ជាទីត្រេកអរណាមួយ ហើយស្រវឹង ខ្ញុំវៀរនូវបុរសនោះ អ្នកប្រព្រឹត្តមិនស្មើ មានសភាពដីភក់ក្រហាយ ដូចជាបុគ្គលវៀរចេញនូវរណ្តៅលាមក ។

(១៨៤) បុគ្គលធ្វើនូវគុណសម្បត្តិ គឺបុណ្យដោយខ្លួនឯង ធ្វើនូវអំពើមិនមែនជាបុណ្យ គឺដោយខ្លួនឯង ព្រោះថា បុគ្គលដទៃ ធ្វើនូវគុណ-សម្បត្តិ គឺបុណ្យក្តី មិនមែនបុណ្យក្តី ដល់បុគ្គលដទៃទៀតមិនបានទេ ។

ចប់ សិរិកាឡកណ្ណិជាតក ទី ៧ ។

## កុក្កុដជាតក

(១៨៥ (សំពោចញីនិយាយថា) នែអ្នកមានខ្នងបិទបាំង ដោយស្លាបដ៏វិចិត្រល្អ ជាសត្វមានសិរ្សក្រហម ទៅកាន់អាកាសបាន អ្នកចុះអំពីមែកឈើមក ខ្ញុំនឹងជាប្រពន្ធរបស់អ្នក ដោយទទេ ។

(១៨៦) បកុប្បនី តិ កាលញ្ញូណំ ទ្វិបទាហំ មនោរមេ

មំតី បត្តី អសំយុត្តា អញ្ញំ បរិយេស សាមិកំ ។

(១៨៧) កោមារិកា តេ ហេស្សាមិ មញ្ជុកា បិយភាណិនី

វិត្តំ អរិយេន វេទេន កល្យាណី ព្រហ្មចារិនី ។

(១៨៨) កុណាតាតិ(១) លោហិតបេ បោរិ កុក្កុដខោជិតំ

ន តំ អរិយេន វេទេន មមំ គន្តារមិច្ឆសិ ។

(១៨៩) សវេមេ ពាតុក តារី និស្សាន បរំ(២) ធរំ

នេត្តំ សណ្ហាហំ ភវាហំ វិធុរំ វិយ កុក្កុដំ ។

(១៩០) យោ ច ឧប្បតិតំ អត្ថំ ន ខិប្បមនុពុជ្ឈតិ

អមិត្តវសមន្វេតិ បច្ឆា ច អនុតប្បតិ ។

១ ម. សក្កណកាទិនំ ។ ២ ម. សកំ ។





(១៨៦) (មាន់ពោធិសត្វឆ្លើយថា) ម្នាលនាងដ៏ល្អ ជាទីត្រេកអរនៃចិត្ត នាងជាសត្វជើងបួន ខ្ញុំជាសត្វជើងពីរ ពួកយើង និងសត្វបក្សី មិនសមគ្នាទេ នាងចូរស្វែងរកសត្វឯទៀត ធ្វើជាស្វាមីចុះ ។

(១៨៧) (សំពោចញីនិយាយថា) ខ្ញុំនៅជាកុមារី ជាស្ត្រីនិយាយពីរោះ ពោលពាក្យជាទីស្រឡាញ់ នឹងបានជា (ប្រពន្ធ) របស់អ្នក អ្នកចូរបាននូវខ្ញុំ ជាស្ត្រីល្អជាព្រហ្មចារិនី ដោយការបានដ៏ប្រសើរ ។

(១៨៨) (មាន់ពោធិសត្វនិយាយថា) នែនាង ជាសត្វស៊ីខ្មោចសាកសព ផឹកនូវឈាម ជាចោរ បៀតបៀននូវមាន់ នាងឯង មិនមែនបាន បាននូវអញធ្វើជាប្តី ដោយការបានប្រសើរទេ ។

(១៨៩) (ព្រះសម្ពុទ្ធសំដែងថា) នារីទាំងឡាយ ដែលមានការកំណត់ ឃើញនូវបុរសដ៏ប្រសើរហើយ រមែងដឹកនាំ ដោយពាក្យដ៏ពីរោះ យ៉ាងនេះឯង ដូចជាសំពោចញី ប្រលោមនូវមាន់ឈ្មោល (មកធ្វើជាប្តីរបស់ខ្លួន) ។

(១៩០) បុគ្គលណា មិនបានយល់នូវប្រយោជន៍ ដែលកើតឡើង បុគ្គលនោះ រមែងលុះអំណាចនៃសត្រូវផង រមែងក្តៅក្រហាយក្នុងកាលជាខាងក្រោយផង ។

(១៩១) យោ ច ឧប្បតិតំ អត្ថំ ខិប្បមេវ និពោធតិ

មុច្ចតេ សត្តុសម្ពាធា កុក្កុដោវ វិឡារិយាតិ ។

កុក្កុដជាតកំ អដ្ឋមំ ។

## ធម្មទ្ធជជាតកំ

(១៩២) ធម្មំ ចរថ ញាតយោ ធម្មំ ចរថ ភទ្ទ វោ

ធម្មចារី សុខំ សេតិ អស្មិំ លោកេ បរម្ហិ ច ។

(១៩៣) ភទ្ទកោ វតាយំ បក្ខី ទិជោ បរមធម្មិកោ

ឯកបាទេន តិដ្ឋន្តោ ធម្មមេវានុសាសតិ ។

(១៩៤) នាស្ស សីលំ វិជានាថ អនញ្ញាយ បសំសថ

ភុត្វា អណ្ឌញ្ច ពាបេ[1]ច ធម្មោ ធម្មោតិ ភាសតិ ។

---

១ ម. ម. ពោតញ្ច ។



(១៩១) លុះតែបុគ្គលណា ដឹងយល់ច្បាស់ នូវប្រយោជន៍ ដែលកើតឡើង បុគ្គលនោះ រមែងរួចចាកការបៀតបៀន អំពីសត្រូវ ដូចមាន់ឈ្មោល រួចអំពីសំពោចញី ។

ចប់ កុក្កុដជាតក ទី ៨ ។

## ធម្មទ្ធជជាតក

(១៩២) (ក្អែកនិយាយនឹងពួកសត្វស្លាបថា) ម្នាលញាតិទាំងឡាយ អ្នកទាំងឡាយ ចូរប្រព្រឹត្តធម៌ អ្នកទាំងឡាយ ចូរប្រព្រឹត្តធម៌ សេចក្ដីចំរើន (នឹងមាន) ដល់អ្នកទាំងឡាយ អ្នកប្រព្រឹត្តធម៌ រមែងដេកជាសុខ ក្នុងលោកនេះ និងលោកខាងមុខ ។

(១៩៣) (ពួកសត្វស្លាប សរសើរថា) សត្វស្លាបមានកំណើតពីរនេះ ប្រសើរណាស់តើ ជាអ្នកប្រកបដោយធម៌ដ៏ក្រៃលែង ឈរតែជើងម្ខាង ប្រៀនប្រដៅតែធម៌ ។

(១៩៤) (បក្សីពាពិសត្វពោលថា) អ្នកទាំងឡាយ មិនស្គាល់ច្បាស់ នូវមារយាទ នៃក្អែកនោះទេ អ្នកទាំងឡាយសរសើរ ព្រោះមិនដឹង (ចំណែកខាងនៃក្អែកអាក្រក់) ស៊ីទាំងពងទាំងកូន (របស់ពួកយើង) ហើយពោលថា ធម៌ ៗ ដូច្នេះ ។

(១៩៥)អញ្ញំ ភណសិ វាចាយ អញ្ញំ កាយេន កុព្វសិ
វាចាយ នោ ច កាយេន ន តំ ធម្មំ អធិដ្ឋិតោ ។

(១៩៦)វាចាយ សខិលោ ហោតិ មនោវិទុគ្គោ សិយា
បដិច្ឆន្នោ កូបសយោ កណ្ហសប្បោវ ធម្មទ្ធជោ
គាមនិគមាសុ សាធុ សម្មតោ ទុជ្ជានោ អយំ
បុរិសេន ពាលិសេន ។

(១៩៧)ឥមំ តុណ្ឌេហិ បក្ខេហិ បាទា ចិមំ វិហេឋថ
ឆវំ ហិមំ វិនាសេថ នាយំ សំវាសនារហោតិ ។

ធម្មទ្ធជជាតកំ នវមំ ។

## នន្ទិយមិគរាជជាតកំ

(១៩៨)សចេ ព្រាហ្មណ គច្ឆសិ សាកេតេ អញ្ជនំ(១) វនំ
វជ្ជាសិ នន្ទិយំ នាម បុត្តំ អស្មាកមោរសំ
មាតា បិតា ច តេ វុទ្ធា តេ តំ ឥច្ឆន្តិ បស្សិតុំ ។

---

១ ម. សាកេតេ អជ្ជុនំ ។



(១៩៥) បុគ្គលអាក្រក់ និយាយដោយវាចាផ្សេង ធ្វើដោយកាយផ្សេង ក៏ប្រព្រឹត្តធម៌ តែសំដី មិនមែនតាំងកាយផងទេ មិនដំកល់ខ្លួនក្នុងធម៌នោះ ។

(១៩៦) បុគ្គលអ្នកទន់ភ្លន់ ដោយវាចា តែគេស្គាល់ចិត្តបាន ដោយក្រ ដូចជាពស់វែកបិទបាំងខ្លួន អាស្រ័យនៅក្នុងរន្ធ បុគ្គលមានធម៌ជាទង់ជ័យ គេសន្មតថា ល្អ ក្នុងស្រុក និងនិគមទាំងឡាយ បុគ្គលបែបនេះ បុរសអ្នកល្ងង់ខ្លៅ ស្គាល់បានដោយក្រ ។

(១៩៧) អ្នកទាំងឡាយ ចូរបៀតបៀនក្អែកនេះ ដោយចំពុះផង ចូរបៀតបៀនក្អែកនេះ ដោយជើងផង ចូរញាំញីក្អែកលាមកនេះ ឲ្យវិនាសទៅ ក្អែកនេះ មិនគួរឲ្យនៅជាមួយទេ ។

ចប់ ធម្មទ្ធជជាតក ទី ៩ ។

## នន្ទិយមិគរាជជាតក

(១៩៨) (ម្រឹគមាតាបិតានិយាយផ្តាំថា) ម្នាលព្រាហ្មណ៍ បើអ្នកទៅកាន់ចម្ការឈ្មោះ អញ្ជន ក្នុងក្រុងសាកេត និយាយប្រាប់កូនឈ្មោះ នន្ទិយៈ ជាឱរសរបស់ខ្ញុំថា មាតាបិតាទាំងឡាយ របស់អ្នកចាស់ហើយ គាត់ចង់ឃើញអ្នក ។

(៥៩៩)កុក្កា មយា និភតានិ ភជិតោ តាតកោជមំ
តំ ភជបិណ្ឌំ អវកោត្តុំ តាហំ ព្រាហ្មណមុស្សហេ ។
(៦០០)ឥទំ ហិ ស្សាមហំ បស្សំ ទុរប្បញ្ញស្ស ភជិតោ
តជាហំ សុទិតោ មុត្តោ អបិ បស្សេយ្យ មាតរំ ។
(៦០១)មិតកជា មុរេ អាសិ កោសលស្ស ធិតោតវេ
ឆន្ទិយោ ជាម ជាមេន អភិរុតោ ចតុប្បទោ ។
(៦០២) តំ មំ វជិតុមាគច្ឆិ ជាយស្មឹ អញ្ញជាវេន[១]
ជមុំ អារជ្ជិ[២] ពាគ្យាន ទុសុំ សញ្ញាយ[៣] កោសលោ ។
(៦០៣)តស្សាហំ ឥទំ ហិ បស្សំ ទុរប្បញ្ញស្ស ភជិតោ
តជាហំ សុទិតោ មុត្តោ មាតរំ ឆន្ទមាតតោតិ ។

ឆន្ទិយមិគរាជជាតកំ ទសមំ ។

អាភិយវគ្គោ បឋមោ ។

---

១ ម. អញ្ញេន ពៃន ។ ២ ម. ជនុមារទ្ធំ ។ ៣ ម. សន្ធាយ ។



(៥៩៩) (ឆន្ទិយម្រឹគនិយាយថា) បពិត្រព័ន្ធសព្យាយ ទឹកនិងភោជន របស់ព្រះរាជា ខ្ញុំបានបរិភោគហើយ ម្នាលព្រាហ្មណ៍ ខ្ញុំមិនអាចបរិភោគទេ នូវដុំភោជនជាអំណោយ របស់ព្រះរាជានោះទេ ។

(៦០០) ខ្ញុំនឹងបានរួចបំពៀងខ្លួន ដល់ព្រះរាជា មានសេចក្តីថៃ ក្នុងកាលណា ខ្ញុំក៏ដល់នូវសេចក្តីសុខ រួចពាក (មរណៈ) ហើយ ប្រហែលជានឹងបានឃើញនូវមាតា ។

(៦០១) (ព្រះសាស្តាទ្រង់ត្រាស់ថា) កាលពីដើម តថាគត ជាសត្វ ជើង ៤ មានរូបល្អ ជាស្តេចម្រឹគ ឈ្មោះ ឆន្ទិយៈ ដោយឈ្មោះ នៅក្នុងលំនៅ នៃស្តេចកោសល ។

(៦០២) ព្រះរាជាកោសល ផ្ទាប់ព្រួញយកមក ដើម្បីសម្លាប់នូវ តថាគតនោះ ក្នុងទេព្វានឈ្មោះ តញ្ញូន ជាទីដែលពួកជនថ្វាយ ។

(៦០៣) តថាគតក៏បានរួចបំពៀងខ្លួន ដល់ព្រះរាជានោះ ដែលមាន គួនសេចក្តីថៃ ក្នុងកាលណា តថាគត ក៏ដល់នូវសេចក្តីសុខ រួចពាក (មរណៈ) ហើយបានមកឃើញមាតា ។

ចប់ ឆន្ទិយមិគរាជជាតក ទី ១០ ។

ចប់ អាភិយវគ្គ ទី ១ ។

## តស្សុទ្ទានំ

អថ កុណ្ឌលេជសក កោកុរេក
ទរីមុខ សនេរុកា ច បុន
អបនន្ទ សិរី ច សុចិត្តវរោ
អថ ធម្មិកា នន្ទិ មិគេន ទស ។

---





## ឧទ្ទាននៃអាចរិយវគ្គនោះគឺ

(អវារិយជាតក) មានពាក្យថា បពិត្រព្រះគន្ទប្រសើរលើរថ សូមព្រះអង្គកុំខ្វល់ ១ សេតកេតុជាតកដ៏ប្រសើរ ១ ទរីមុខជាតក ១ នេរុជាតក ១ (អាសង្កជាតក) ១ ទៀត ការមិនត្រេកអរ ១ សិរីទៅពីគា ១ មាន់មានស្លាបដ៏ប្រសើរ វិចិត្រ ១ ក្អែកសំដែងធម៌ ១ ម្រឹគឈ្មោះ នន្ទិយៈ ១ ត្រូវជា ១០ ។

---

## ខរបុត្តជាតកំ(១)

(២)

[៦០៤]សច្ចំ កិរេវមាហំសុ ពស្តំ ពាលោតិ បណ្ឌិតា

បស្ស ពាលោ រហោកម្មំ អាវិកុព្វំ ន ពុជ្ឈតិ ។

[៦០៥]ត្វំ នុ ខោ សម្ម ពាលោសិ ខរបុត្ត វិជានហិ

រជ្ជុយា ហិ បរិក្ខិត្តោ វង្កោដ្ឋោ ឱហិតោមុខោ ។

[៦០៦]អបរំបិ សម្ម តេ ពាល្យំ យោ មុត្តោ ន បលាយសិ

សោ ច ពាលតរោ សម្ម យំ ត្វំ វហសិ សេនកំ ។

[៦០៧]យន្នុ សម្ម អហំ ពាលោ អជរាជ វិជានហិ

អថ កេន សេនកោ ពាលោ តំ មេ អក្ខាហិ បុច្ឆិតោ ។

[៦០៨]ឧត្តមត្ថំ លភិត្វាន ភរិយាយ យោ បទស្សតិ(៣)

តេន ជហិស្សតត្តានំ(៤) សា ចេវស្ស ន ហេស្សតិ(៥) ។

១ ម. ខរបុត្តជាតកំ ។ ២ ម. ភស្តំ ។ ម. តំ ។ ៣ ម. ភរិយា ៤ ភរិស្សតិ ។ ៥ ម. បរិស្សតត្តានំ ។ ៥ ម. សា ចេ នស្ស ឆហេស្សតិ ។



## ខរបុត្តជាតក

(៦០៤) (សេះសិន្ធពៈនិយាយថា) ឮថា បណ្ឌិតទាំងឡាយ បានពោល នូវសត្វពពែថាជាសត្វពាលដោយពិត អ្នកចូរមើលចុះ សត្វពាល មិនដឹងនូវអំពើ ដែលខ្លួនធ្វើ ក្នុងទីកំបាំង ទៅធ្វើក្នុងទីចំហ ។

(៦០៥) (ពពែនិយាយថា) ម្នាលសំឡាញ់ អ្នកឯងទេ ជាសត្វពាល ម្នាលខរបុត្រ អ្នកចូរដឹងចុះ អ្នកជាសត្វ ដែលត្រូវគេរួបរឹត ដោយខ្សែ មានបបូរមាត់វៀច មានមុខចុះ ។

(៦០៦) ម្នាលសំឡាញ់ អ្នកណាបានរួចចេញ (អំពីចំណង) មិនគេចទៅ អ្នកនោះ ពេញជាពាលទៅទៀត ម្នាលសំឡាញ់ អ្នកនាំនូវស្តេចសេនកៈណា ស្តេចសេនកៈនោះ ហាក់ជាមនុស្សពាលបំផុត ។

(៦០៧) (សេះសិន្ធពៈ និយាយថា) ម្នាលសំឡាញ់ បើខ្ញុំជាសត្វពាល ដោយហេតុណា ម្នាលអជរាជ អ្នកចូរដឹងនូវហេតុនោះចុះ តែថា ស្តេចសេនកៈ ជាមនុស្សពាល ដោយហេតុដូចម្តេច អ្នកដែលខ្ញុំសួរហើយ ចូរប្រាប់ហេតុនោះ ។

(៦០៨) (ពពែប្រាប់ថា) បុគ្គលណា បាននូវវត្ថុជាប្រយោជន៍ដ៏ឧត្តម ហើយប្រគល់ឲ្យប្រពន្ធ (បុគ្គលនោះ) នឹងលះបង់នូវខ្លួនដោយការ ឲ្យវត្ថុនោះ ទាំងប្រពន្ធនោះ នឹងមិនមានដល់បុគ្គលនោះឡើយ ។

(៦០៩) ន បិយមេទ្ធិ ជនិន្ទ តាទិសោ

អត្តំ និរង្កត្វា បិយានិ សេវតិ

អត្តាវ សេយ្យោ បរមា ច សេយ្យោ

លព្ភា បិយា ឱចិតត្ថេន(១) បច្ឆាតិ ។

ខុរប្បវគ្គោ បឋមោ ។

## សូចិជាតកំ

(៦១០) អកក្កសំ អផរុសំ ខរធោតំ សុបាសិយំ

សុខុមំ តិក្ខិណគ្គញ្ច កោ សូចឹ កេតុមិច្ឆតិ ។

(៦១១) សុមជ្ជញ្ច សុបាសញ្ច អនុបុព្វសុវដ្ដិតំ

ឃនឃាតិមំ បដិត្ថទ្ធំ កោ សូចឹ កេតុមិច្ឆតិ ។

(៦១២) ឥតោ ទានិ បតាយន្តិ សូចិយោ ពលិសានិ ច

កោយំ កម្មារគាមស្មឹ សូចឹ វិក្កេតុមិច្ឆតិ ។

១ ឱ. ម. ឱចិតត្តេន ។



(៦០៩) (តាបសពោលថា) បពិត្រព្រះអង្គជាធំជាងជន បុគ្គលបែបនោះ លះបង់ចោលនូវខ្លួន មិនសេពគប់នូវគុណជាទីស្រឡាញ់ ដោយគិតថា (គុណនេះ) ជាទីស្រឡាញ់របស់អញ ខ្លួនឯង ទើបប្រសើរ ជាងរបស់ដែលប្រសើរទៅទៀត ព្រោះបុរស ដែលមានខ្លួនអប់រំហើយ គប្បីបាននូវផលជាទីស្រឡាញ់ ក្នុងកាលជាខាងក្រោយ ។

ចប់ ខុរប្បវគ្គ ទី ១ ។

## សូចិជាតក

(៦១០) (កុមារបុត្រនាយកម្មករ ពោលថា) នរណា ចង់ទិញម្ជុល(របស់ខ្ញុំ) ជាម្ជុលមិនគ្រោតគ្រាត មិនគគ្រើម ដែលសំលៀងដោយថ្ម មានរង្វះដ៏ល្អ មានចុងដ៏ស្រួចឆ្មារ ។

(៦១១) នរណា ចង់ទិញម្ជុល ជាម្ជុលដែលដុសខាត់ល្អ មានរង្វះល្អ ដែលប្រព្រឹត្តទៅ ដោយល្អតាមលំដាប់ (រៀវត្រង់) ចាក់ទំលុះនូវរបស់ក្រាស់បាន ។

(៦១២) (នាងកុមារី ពោលថា) ម្ជុលនិងសន្ទូច តែងចេញអំពីស្រុកនេះ ក្នុងកាលឥឡូវនេះ បុរសនេះជាអ្វី ចង់លក់ម្ជុល ក្នុងស្រុករបស់ជាង ។

(២១៣) ឥតោ សត្ថានិ គច្ឆន្តិ កម្មន្តា វិវិធា បុថូ

កោយំ កម្មារគាមស្មឹ សូចឹ វិក្កេតុមរហតិ(១) ។

(២១៤) សូចឹ កម្មារគាមស្មឹ វិក្កេតព្វា បជានតា

អាចរិយា បជានន្តិ កម្មំ សុកតទុក្កដំ ។

(២១៥) ឥមញ្ចេ តេ បិតា ភទ្ទេ សូចឹ ជញ្ញា មយា កតំ

តយា ច មំ និមន្តេយ្យ យញ្ចត្ថញ្ញំ ឃរេ ធនន្តិ ។

សូចិជាតកំ ទុតិយំ ។

## តុណ្ឌិលជាតកំ

(២១៦) នវច្ឆន្ទកោ ទានិ(២) ទិយ្យតិ

បុណ្ណាយំ ទោណិ សុវាមិនី ឋិតា

ពហុកោ ជនោ បាសបាណិកោ(៣)

នោ ច ខោ មេ បដិភាតិ ភុញ្ជិតុំ ។

---

១ ម. វិក្កេតុមរហតិ ។ ២ ម. ទោណិ ។ ៣ ឱ. ម. ពហុកេ ជនេ បាសបាណិកេ ។



(២១៣) គ្រឿងសម្រាប់ធ្វើការងារផ្សេងៗ ជាច្រើន កើតចេញទៅអំពី ស្រុកនេះ ចុះបុរសនេះជាអ្វី ក៏មកលក់ម្ជុលក្នុងស្រុកជាងលោហៈ ។

(២១៤) (ពោធិសត្វ ពោលថា) ជនអ្នកចេះដឹង គួរលក់ម្ជុលក្នុង ស្រុកជាងលោហៈ អាចារ្យទាំងឡាយ រមែងដឹងច្បាស់ នូវការងារ ដែលគេធ្វើល្អឬមិនល្អក្រែក ។

(២១៥) ម្នាលនាង បើបិតារបស់នាង ស្គាល់នូវម្ជុល ដែលខ្ញុំធ្វើហើយ នេះ គាត់នឹងអញ្ជើញ (ផ្សំផ្គុំ) ខ្ញុំ ជាមួយនាង ព្រមទាំងទ្រព្យ ដទៃ ដែលមាននៅក្នុងផ្ទះ ។

ចប់ សូចិជាតក ទី ២ ។

## តុណ្ឌិលជាតក

(២១៦) (ចុល្លតុណ្ឌិលសូករៈ ពោលថា) ម្ចាស់យើងធ្លាប់ឲ្យ (បបរ កណ្តក ឬបាយក្តាំង) ឥឡូវនេះ គាត់ឲ្យបាយទឹកស្រស់វិញ ស្នូក នេះ ពេញ (ដោយបាយសម្លក) ស្ត្រីជាម្ចាស់យើង ក៏ ឈរនៅ (ជិតស្នូកនោះដែរ) អ្នកផងដ៏ច្រើនគ្នា មានដៃកាន់ អន្ទាក់ ខ្ញុំមិនចង់ស៊ីទេ ។

(២០៧) តសេសិ កមេសិ លេលាមិជ្ជសិ
អគាណោសិ កុយ៉ា កមិស្សសិ
អបេត្យស្សកោ កុញ្ជ កុណ្ឌិល
មំសត្ថាយ ពោសិហេមកេស(១) ។

(២០៨) ទុកហា រហាធំ អគាទុមំ
សត្តុំ សេធមលំ បភហយ
កណ្ហាហំ ធរំ វិលេបធំ
យស្ស កាហ្វោ ឧ កាធាធំ ធំជួតិ ។

(២០៩) កាកមោ ឧ រហាធោ អកាទុមោ
កាំសុ សេធមលត្តិ វុច្ចតិ
កាកមញ្ចុ ធរំ វិលេបធំ
កស្ស កាហ្វោ ឧ កាធាធំ ធំជួតិ ។

● ម. ពោសិតាឡ្វសេ ។



(៦០៧) (មហាកុណ្ឌល: ពោលថា) អ្នកកក់សក់ ស្ទាំស្ទា ប្រាជ្ញា
កេចចំពីឥត្ថូខ អ្នកផឹកទឹកពីដៃទេ អ្នកទឹនទៅក្នុងទីណា ម្នាល
កុណ្ឌល: អ្នកច្បាមានសេចក្តីទុលំទូលាយ ហ៊ាកានចុះ យើង ដែល
កេចំញ្ចឹម ដើម្បីប្រយោជន៍តែសាច់ (ប៉ុណ្ណោះ) ។

(៦០៨) (បើអ្នកខ្លាចសេចក្តីស្លាប់) អ្នកច្បាចុះទៅកាន់ស្រះ ដែល
មិនមានភក់ អ្នកច្បាជម្រះខ្លួនញើស និងធ្លៃសាច់ផងស់ចេញ ក្នុង
នៃគ្រឿងណាបណា មិនដាច់ ក្នុងកាលណាមួយ អ្នកច្បាកាន់យក
ខ្លួនគ្រឿងណាប ដ៏ជាទោះ ។

(៦០៩) (ចូឡកុណ្ឌល: ស្មោថា) ស្រះមិនមានភក់ តើដូចម្តេច អ្វី
ហ៎្ន ដែលលោកហៅថា ញើសនិងធ្លៃល មួយទៀត គ្រឿងណាប
ដ៏ថ្មី តើដូចម្តេច ចាំងក្នុងរបស់ណា គឺមិនដាច់ក្នុងកាលណាមួយ ។

(៦៦០) ជម្មោ វទតោ អកក្កសោ
តាបំ សេទមលង្តិ វុឌ្ឍិ
សីលញ្ច ឆវំ ភិលបនំ
តស្ស គតោ ន កាលេចិ ឆិជ្ជតិ ។

(៦៦១) ធន្ធន្តិ សរីរឃាតិនោ
ន ច ធន្ធន្តិ សរីរធារិនោ
បុណ្ណាយ បុណ្ណមាសិយា
រមមានាវ ជហន្តិ ជីវិតន្តិ ។

កុណ្ឌលជាតកំ តតិយំ ។

## សុវណ្ណកក្កដកជាតកំ

(៦៦២) សិង្គី មិគោ អាយតចក្ខុនេត្តោ
អដ្ឋិត្តចោ វារិសយោ អលោមោ
តេនាភិភូតោ កបណំ រុទាមិ
មារេ សខា តស្ស ធុ មំ ជហាសិ ។



(៦៦០) (មហាកុណ្ឌលៈ ឆ្លើយថា) ធម៌ ទុកជាស្រះមិនមានភក់ បាប លោកពោលថា ញើសនិងក្អែល សីល ទុកជាគ្រឿងលាបដ៏ថ្មី ចាំង ក្លិនរបស់សីលនោះ មិនដាច់ ក្នុងកាលណាមួយ ។

(៦៦១) ពួកជន អ្នកសម្លាប់ខ្លួនសរីរៈ (នៃសត្វទាំងឡាយ) រមែង ត្រេកអរ ចំណែកខាងពួកសត្វ អ្នកទ្រទ្រង់ខ្លួនសរីរៈ រមែងមិន ត្រេកអរឡើយ ពួកសត្វទាំងឡាយ (ប្រាកដដូចជាយើង) រមែង ត្រេកអរ លះបង់ខ្លួនជីវិត ក្នុងថ្ងៃពេញ មានព្រះចន្ទពេញវង់ ។

ចប់ កុណ្ឌលជាតក ទី ៣ ។

## សុវណ្ណកក្កដកជាតក

(៦៦២) (ព្រាហ្មណ៍ពោលថា) ប្រើតមានពណ៌ដូចមាស (ក្ដាម) មានភ្នែក វែង មានស្បែកដូចឆ្អឹង ការស្រូយនៅក្នុងទឹក ជាសត្វមិនមាន រោម ខ្ញុំត្រូវក្ដាមនោះគ្របសង្កត់ ទើបយំ កំព្រា (តែម្នាក់ឯង) ម្នាលសំឡាញ់អើយ ហេតុអ្វី ទើបអ្នកបោះបង់ខ្ញុំចោល ។

(៦៦៣) សោ អស្សសន្តោ មហតា ជវេន
កុដ្ឋំហោ កណ្ណជកណ្ឌុបត្តោ
សតា សតានិ បរិតាយមានោ(១)
កុដ្ឋំហិ កណ្ណជកោ អគ្គហេសិ ។

(៦៦៤) ន វាយសំ នោ បន សប្បកដិំ(២)
ឃាសត្ថិកោ កណ្ណជកោ អនេយ្យ
បុច្ឆាមិ តំ អាយសក្ខុនេត្ត
អថ កិស្ស ហេតុម្ហ ឧភោ គហិតា ។

(៦៦៥) អយំ បុរិសោ មម អត្ថកាមោ
យោ មំ គហេត្វាន ឧទកាយ នេតិ
តស្មិំ មតេ ទុក្ខមនប្បកំ មេ
អហញ្ច ឯសោ ច ឧភោ ន ហោម ។

(៦៦៦) មមញ្ច ទិស្វាន បវឌ្ឍកាយំ
សព្វោ ជនោ ហិំសិតុមេវមិច្ឆេ
សាទុញ្ច ថូលញ្ច មុទុញ្ច មំសំ
កាកាបិ មំ ទិស្វាន វិហេឋយេយ្យុំ ។

---

១ ម. សតំ សតានិ បរិតាយមានោ ។ ២ ម. កណ្ហសប្បំ ។



(៦៦៣) សេះនោះ កាលដួល (ក្តីនោះ) បើកភ្នែកធំ ល្មមចូល ទៅជិតក្តាម យកកាសាការពារស់ឡូញដ៏ស្អិតស្អាល ក្តាមក៏ចាប់ សេះទៀត ។

(៦៦៤) (សេះពោលថា) ចាំណាកនាក់ ក្តាមជាសត្វក្រៅការ ដោយចំណី មិនគួរចាប់ក្អែក មិនគួរចាប់សេះទេ មាលអ្នក មានភ្នែកលៀន ខ្ញុំសូមសួរអ្នក ហេតុអ្វី ក៏អ្នក មកចាប់យើងទាំងពីរនាក់ ។

(៦៦៥) (ក្តាមនិយាយថា) បុរសនេះ ជាអ្នកប្រាថ្នានូវប្រយោជន៍ ដល់ខ្ញុំ អ្នកណា ចាប់ខ្ញុំនាំទៅកន្លែងទឹក កាលបើអ្នកនោះស្លាប់ ខ្ញុំ (នឹងមាន) សេចក្តីទុក្ខច្រើន (ព្រោះ) ខ្ញុំនិងបុរសនេះទាំងពីរនាក់ នឹងមិនទៅជាមួយគ្នា ។

(៦៦៦) មនុស្សជន ឃើញខ្ញុំមានកាយចំរើន(ធំ) គប្បីប្រាថ្នា ដើម្បី បៀតបៀនតែប៉ុណ្ណោះ សូម្បីពួកក្អែកបានឃើញខ្ញុំ មានសាច់ ឆ្ញាញ់ក្រាស់ ទន់ ក៏គប្បីបៀតបៀនដែរ ។

(៦២៧) សាធ តស្ស ហេតុម្ហា ឧភោ គហីតា
ឧដ្ឋាតុ ហោសោ វិសមាវមាមិ
មមញ្ច កាកញ្ច បមុញ្ច ខិប្បំ
បុរេ វិសំ គាឡ្ហមុបេតិ មច្ចំ ។

(៦២៨) សប្បំ បមោក្ខាមិ ន តាវ កាកំ
បដិពទ្ធកោ ហោតិ ហិ តាវ កាកោ
បុរិសញ្ច ទិស្វាន សុខឹ អរោគំ
កាកំ បមោក្ខាមិ យថេវ សប្បំ ។

(៦២៩) កាកោ តទា ទេវទត្តោ អហោសិ
មារោ បន កណ្ហសប្បោ អហោសិ
អានន្ទភទ្ទោ កក្កដកោ អហោសិ
អហំ តទា ព្រាហ្មណោ ហោមិ សត្ថា ។

សុវណ្ណកក្កដកជាតកំ នវមំ ។

## មយ្ហកសកុណជាតកំ

(៦៣០) សកុណោ មយ្ហកោ នាម គិរិសានុទរីចរោ
បក្កំ បិប្ផលិមារុយ្ហ មយ្ហំ មយ្ហន្តិ កន្ទតិ ។



(៦២៧) (ពស់ពោលថា) បើអ្នកចាប់យើងទាំងពីរនាក់ ព្រោះហេតុតែបុរសនោះ បុរសនោះក្រោកឡើង ខ្ញុំនឹងស្រូបយកពិសចេញ អ្នកចូរលែងខ្ញុំនឹងក្អែកឲ្យឆាប់ ព្រោះកាលពីដើម ពិសដ៏ក្លៀវក្លា ជ្រាបចូលក្នុងសត្វ ។

(៦២៨) (ក្តាមនិយាយថា) អញលែងពស់ តែមិនលែងក្អែកទេ ព្រោះថា ក្អែកទុកជាអ្នកធានាសិន អញលុះឃើញនូវបុរស មានសេចក្តីសុខ មិនមានរោគ ទើបលែងក្អែក ដូចយ៉ាងពស់ដែរ ។

(៦២៩) ក្អែកក្នុងកាលនោះ បានមកជាទេវទត្ត ចំណែកខាងពស់វិញ បានមកជាមារ ក្តាមបានមកជាអានន្ទដ៏ចំរើន ព្រាហ្មណ៍ក្នុងកាលនោះ បានមកជាតថាគត ជាសាស្តា ។

ចប់ សុវណ្ណកក្កដកជាតក ទី ៩ ។

## មយ្ហកសកុណជាតក

(៦៣០) (តាបសពោធិសត្វពោលថា) សត្វស្លាប ឈ្មោះ មយ្ហកៈ (១) ហើរទៅតាមញកនិងជ្រកភ្នំ ទៅទំដើមល្វា ដែលមានផ្លែទុំ យំ កន្ទក់កន្ទេញថា របស់អញ ៗ ដូច្នេះ ។

---

១ ពាក្យថា មយ្ហកៈនេះ ជាឈ្មោះនៃសត្វចាប ១ ពួក ដែលច្រើនតែហៅផ្លែល្វាថា របស់អញ ៗ មិនឲ្យពួកសត្វចាបឯទៀត មកស៊ីផង មយ្ហកៈចាបនេះ ត្រូវហៅថា សត្វពពូល ឬ កំផ្លុក ព្រោះជាសត្វស៊ីផ្លែល្វា ។ អដ្ឋកថាដីកា ។

(២៣១) តស្សេវំ វិលបន្តស្ស ទិជសង្ឃា សមាគតា

ភុត្វាន បិប្ផលឹ យន្តិ វិលបត្វេវ សោ ទិជោ ។

(២៣២) ឯវមេវ ឥធេកច្ចោ សង្ឃរិត្វា ពហុំ ធនំ

នេវត្តនោ ន ញាតីនំ យថោធឹ បដិបជ្ជតិ ។

(២៣៣) ន សោ អច្ឆាទនំ ភត្តំ ន មាលំ ន វិលេបនំ

អនុភោតិ សកឹ កិញ្ចិ ន សង្គណ្ហាតិ ញាតកេ ។

(២៣៤) តស្សេវំ វិលបន្តស្ស មយ្ហំ មយ្ហន្តិ រក្ខតោ

រាជានោ អថវា ចោរា ទាយាទា យេ ច អប្បិយា

ធនមាទាយ គច្ឆន្តិ វិលបត្វេវ សោ នរោ ។

(២៣៥) ធីរោ ភោគេ អធិគម្ម សង្គណ្ហាតិ ច ញាតកេ

តេន សោ កិត្តឹ បប្បោតិ បេច្ច សគ្គេ បមោទតីតិ ។

មយ្ហកសកុណជាតកំ បញ្ចមំ ។



(២៣១) កាលសត្វមយ្ហកៈនោះ ស្រែកយំការពារយ៉ាងនេះ ពួកសត្វដទៃជាតិ ក៏មកប្រជុំគ្នា ស៊ីផ្លែល្វាហើយហើរទៅ សត្វនោះ ក៏នៅតែស្រែកយំការពារ ។

(២៣២) ដូចយ៉ាងដែលពួកខ្លះ ក្នុងលោកនេះ ប្រមូលមក នូវទ្រព្យមានប្រមាណច្រើន ហើយមិនចាត់ចែងនូវទ្រព្យ ឲ្យសមគួរដល់ចំណែក ដើម្បីខ្លួន មិនទំនុកបម្រុង ដល់ញាតិទាំងឡាយ ។

(២៣៣) បុគ្គលនោះ រមែងមិនបានប្រើប្រាស់ នូវគ្រឿងស្លៀកពាក់ទាំងឡាយ មិនបានទ្រទ្រង់នូវកម្រងផ្កា មិនបានលាប នូវគ្រឿងលាប (ដ៏ល្អ) មិនបានប្រើប្រាស់ នូវវត្ថុណាមួយជារបស់ខ្លួន ទាំងមិនបានសង្គ្រោះ នូវញាតិទាំងឡាយឡើយ ។

(២៣៤) កាលបើបុគ្គលនោះ ពោលរៀបរាប់ ហួងហែងថា របស់អញ ៗ យ៉ាងនេះ ស្រាប់តែ ពួកព្រះរាជា ឬពួកចោរ ទាំងពួកជនអ្នកទទួលមត៌ក មិនជាទីស្រឡាញ់ នាំយកទ្រព្យនោះទៅ បុគ្គលនោះ ក៏នៅតែនិយាយរៀបរាប់ ។

(២៣៥) ឯអ្នកប្រាជ្ញបាននូវភោគៈហើយ រមែងសង្គ្រោះញាតិទាំងឡាយ អ្នកប្រាជ្ញនោះ រមែងបាននូវសេចក្ដីសរសើរ ដោយការសង្គ្រោះញាតិនោះ លុះលះលោកនេះទៅហើយ រមែងរីករាយក្នុងឋានសួគ៌ ។

ចប់ មយ្ហកសកុណជាតក ទី ៥ ។

## បព្វជិតវិហេឋកជាតកំ[១]

(២៣៦) ទុព្វណ្ណរូបំ តុវមរិយវណ្ណី
បុរក្ខត្វា បញ្ជលិកោ នមស្សសិ
សេយ្យោ នុ តេ សោ ឧទាហុ សរិក្ខោ
នាមំ បរស្សត្តនោ ចាបិ ព្រូហិ ។

(២៣៧) ន នាមគោត្តំ គណ្ហន្តិ រាជ
សម្មគ្គតានុជ្ជុគតាន ទេវា
អហញ្ច តេ នាមធេយ្យំ វទាមិ
សក្កោហមស្មិ តិទសានមិន្ទោ ។

(២៣៨) យោ ទិស្វា ភិក្ខុំ ចរណូបបន្នំ
បុរក្ខត្វា បញ្ជលិកោ នមស្សតិ
បុច្ឆាមិ តំ ទេវរាជេតមត្ថំ
ឥតោ ចុតោ កិំ លភតេ សុខំ សោ ។

១ ម. វិជ្ជាធរជាតកំ ។ ឧ. តសិវិហេឋកជាតកំ ។



## បព្វជិតវិហេឋកជាតក

(២៣៦) (ព្រះរាជាពារាណសីត្រាស់ថា) អ្នកមានពណ៌ទ្រង់ទ្រាយដ៏ល្អ ផ្គងអញ្ជលីនមស្ការ គម្ពស់នូវបុគ្គលមានរូបអាក្រក់ អំពីខាងមុខ តើបុរសនោះ ប្រសើរជាងអ្នក ឬប្រហែលគ្នា អ្នកចូរប្រាប់នូវឈ្មោះនៃអ្នកឯទៀតផង នៃខ្លួនផង ។

(២៣៧) (ព្រះឥន្ទ្រទូលថា) បពិត្រព្រះរាជា ទេវតាទាំងឡាយ មិនកាន់យកនូវនាមនិងគោត្រ ព្រះខីណាស្រព អ្នកដល់នូវការស្ងប់ ទាំងប្រព្រឹត្តតាមផ្លូវត្រង់ ប៉ុន្តែ ខ្ញុំនឹងសូមប្រាប់ឈ្មោះ (ខ្លួនខ្ញុំ) ដល់ព្រះអង្គ ខ្ញុំជាសក្កៈ ជាធំជាងទេវតាជាន់តាវត្តិង្ស ។

(២៣៨) (ព្រះរាជាសួរថា) បុគ្គលណា ឃើញនូវភិក្ខុអ្នកបរិបូណ៌ដោយចរណៈ ហើយផ្គងអញ្ជលីនមស្ការ គម្ពស់ទុកក្នុងខាងមុខ បពិត្រទេវរាជ ខ្ញុំសូមសួរនូវសេចក្តីនុ៎ះ នឹងព្រះអង្គ បុគ្គលនោះ លុះច្យុតចាកលោកនេះទៅ រមែងបាននូវសេចក្តីសុខ ដូចម្តេច ។

(៦៣៩) យោ ទិស្វា ភិក្ខុំ ចរណូបបន្នំ
បុរក្ខិត្វា បញ្ជលិកោ នមស្សតិ
ទិដ្ឋេវ ធម្មេ លភតេ បសំសំ
សគ្គញ្ច សោ យាតិ សរីរភេទា ។

(៦៤០) លទ្ធី វត មេ ឧទបាទិ អជ្ជ
យំ វាសវំ ភូតបតិទ្ទសាម
ភិក្ខុញ្ច ទិស្វាន តវញ្ច សក្ក
កាហាមិ បុញ្ញានិ អនប្បកានិ ។

(៦៤១) អទ្ធា ហវេ សេវិតព្វា សបញ្ញា
ពហុស្សុតា យេ ពហុឋានចិន្តិនោ
ភិក្ខុញ្ច ទិស្វាន មមញ្ច រាជ
ករោហិ បុញ្ញានិ អនប្បកានិ ។

(៦៤២) អក្កោធនោ និច្ចបសន្នចិត្តោ
សព្វាតិថីយាចយោគោ ភវិត្វា
និហច្ច មានំ អភិវាទយិស្សំ
សុត្វាន ទេវិន្ទ សុភាសិតានិ ។

ភិក្ខាបរម្បរជាតកំ ឆដ្ឋំ ។



(៦៣៩) (ព្រះឥន្ទ្រទ្រង់តបថា) បុគ្គលណា ឃើញនូវភិក្ខុដែលបរិបូណ៌ ដោយចរណៈ ហើយផ្គងអញ្ជលីនមស្ការ តម្កល់ទុកក្នុងខាង មុខ បុគ្គលនោះ រមែងបាននូវសេចក្ដីសរសើរ ក្នុងបច្ចុប្បន្ន លុះ បុគ្គលនោះ បែកធ្លាយសរីរកាយ រមែងទៅកាន់ឋានសួគ៌ ។

(៦៤០) (ព្រះរាជាត្រាស់ថា) ថ្ងៃនេះ សិរីរបស់អញកើតឡើង ក្នុងថ្ងៃនេះ ព្រោះអញបានឃើញនូវវាសវៈ ជាម្ចាស់នៃភូត បពិត្រសក្កៈ ខ្ញុំនឹង ធ្វើនូវបុណ្យជាច្រើន ព្រោះបានឃើញនូវភិក្ខុផង ព្រះអង្គផង ។

(៦៤១) (ព្រះឥន្ទ្រពោលថា) បុគ្គលណា ប្រកបដោយបញ្ញា ជា ពហុស្សូត អាចគិតឃើញនូវហេតុជាច្រើន (ព្រះអង្គ) គប្បីសេព គប់ (បុគ្គលនោះ) ដោយពិត បពិត្រព្រះរាជា ព្រោះព្រះអង្គ បានឃើញភិក្ខុនិងខ្ញុំ សូមធ្វើបុណ្យជាច្រើនចុះ ។

(៦៤២) (ព្រះរាជាត្រាស់ថា) បពិត្រព្រះអង្គជាធំជាងទេវតា ខ្ញុំនឹងជា អ្នកមិនមានសេចក្ដីក្រោធ មានចិត្តជ្រះថ្លាជានិច្ច ជាអ្នកគួរដល់ អ្នកដំណើរ នឹងសូមទាំងអស់ សង្កត់សង្កិននូវមានះ ថ្វាយបង្គំ ព្រោះបានស្ដាប់ នូវសុភាសិត (របស់ព្រះអង្គ) ។

ចប់ ភិក្ខាបរម្បរជាតក ទី ៦ ។

# ឧបសិង្ឃបុប្ផជាតកំ[១]

(៦៦៣) យមេតំ វារិជំ បុប្ផំ អទិន្នំ ឧបសិង្ឃសិ
ឯកង្គមេតំ ថេយ្យានំ គន្ធថេនោសិ មារិស ។
(៦៦៤) ន ហរាមិ ន ភញ្ជាមិ អារា សិង្ឃាមិ វារិជំ
អថ កេន នុ វណ្ណេន គន្ធថេនោតិ វុច្ចតិ ។
(៦៦៥) យោយំ ភិសានិ ខណតិ បុណ្ឌរីកានិ ភញ្ជតិ
ឯវំ អាកិណ្ណកម្មន្តោ កស្មា ឯសោ ន វុច្ចតិ ។
(៦៦៦) អាកិណ្ណលុទ្ទោ បុរិសោ ធាតិចេលំវ មក្ខិតោ
តស្មឹ មេ វចនំ នត្ថិ ត្វញ្ចារហាមិ វត្តវេ ។
(៦៦៧) អនង្គណស្ស បោសស្ស និច្ចំ សុចិគវេសិនោ
វាលគ្គមត្តំ បាបស្ស អព្ភាមត្តំវ ខាយតិ ។

---

១ ម. ភិសបុប្ផជាតកំ ។



# ឧបសិង្ឃបុប្ផជាតក

(៦៦៣) (ទេវតាពោលថា) បពិត្រលោក លោកស្រង់ក្លិនផ្កា កើតអំពីទឹក (ផ្កាឈូក) ដែលគេមិនបានឲ្យ នុះជាចំណែកមួយនៃការលួច លោកជាអ្នកលួចក្លិន ។

(៦៦៤) (តាបសពោលថា) អាត្មាមិនលួចទេ មិនកាច់យកទេ អាត្មាគ្រាន់តែស្រង់ក្លិនផ្កាឈូក អំពីចម្ងាយ កាលបើដូច្នេះ ហេតុអ្វី ទើបអ្នកពោលថា លោកជាអ្នកលួចក្លិន ។

(៦៦៥) បុរសណា ដឹកយកក្រអៅឈូក កាច់យកផ្កាឈូកស បុរសនោះ ដែលមានការងារកាក្រក់យ៉ាងនេះ ព្រោះហេតុអ្វីក៏អ្នកមិនថា ។

(៦៦៦) (ទេវតាពោលថា) ពាក្យសំដីរបស់ខ្ញុំ មិនមានចំពោះបុរស ដែលជាអ្នកល្មោភកាក្រក់ ប្រឡាក់ (ដោយបាបធម៌) ដូចជាសំពត់មេដោះ ខ្ញុំគួរនិយាយតែនឹងលោក ។

(៦៦៧) បាបរបស់បុរស អ្នកមិនមានទីទួល គឺកិលេស អ្នកស្វែងរកនូវតែធម៌ស្អាតជានិច្ច ប្រមាណប៉ុនចុងនៃរោមកន្ទុយសត្វ រមែងប្រាកដ ដូចប៉ុនមេឃ ។

[២៦៨] អទ្ធា មំ យក្ខ ជានាសិ អថោ មំ អនុកម្បសិ
បុនបិ យក្ខ វជ្ជាសិ យទា បស្សសិ ឯទិសំ ។

[២៦៩] នេវ តំ ឧបជីវាមិ នបិ តេ ភតកាម្ហសេ
ត្វមេវ ភិក្ខុ ជានេយ្យ យេន គច្ឆេយ្យ សុគ្គតិន្តិ ។

ភិសបុប្ផជាតកំ សត្តមំ ។

## វិឃាសាទជាតកំ

[២៧០] សុសុខំ វត ជីវន្តិ យេ ជនា វិឃាសាទិនោ
ទិដ្ឋេវ ធម្មេ បាសំសា សម្បរាយេ ច សុគ្គតី ។

[២៧១] សុកស្ស ភាសមានស្ស ន និសាមេថ បណ្ឌិតា
ឥទំ សុណាថ សោទរិយា អម្ហេវាយំ បសំសតិ ។



[២៦៨] (តាបសពោធិសត្វ ពោលថា) ម្នាលយក្ខ អ្នកស្គាល់នូវអាត្មា ដោយពិត មួយទៀតអ្នកឈ្មោះថា អនុគ្រោះនូវអាត្មា ម្នាលយក្ខ បើអ្នកឃើញទោសនេះ ក្នុងកាលណា អ្នកគប្បីប្រាប់ (ដល់អាត្មា) ទៀត ក្នុងកាលនោះ ។

[២៦៩] (នាងទេវតា ពោលថា) ខ្ញុំមិនមែនរស់នៅ ព្រោះអាស្រ័យលោកទេ ទាំងមិនមែនជាអ្នកធ្វើការឈ្នួល របស់លោកទេ បពិត្រភិក្ខុ លោកទៅកាន់សុគតិ ដោយអំពើណា លោកគប្បីដឹង (នូវអំពើនោះចុះ) ។

ចប់ ភិសបុប្ផជាតក ទី ៧ ។

## វិឃាសាទជាតក

[២៧០] (ព្រះឥន្ទ្រក្លែងខ្លួនជាសេក និយាយថា) ពួកជនណាជាអ្នកស៊ីគ្រឿងសល់ផល ជនទាំងនោះរមែងរស់នៅ ជាសុខស្រួល សេចក្តីសរសើរក្នុងបច្ចុប្បន្ន និងសុគតិក្នុងបរលោក រមែងមាន ។

[២៧១] (សេកមួយរូប ពោលថា) អ្នកទាំងឡាយ ជាបណ្ឌិត ចូរកុំផ្ទៀងស្តាប់ (នូវសំដី) របស់សេកនិយាយ ម្នាលអ្នកមានពោះជាមួយគ្នាទាំងឡាយ ពួកអ្នកចូរស្តាប់ពាក្យខ្ញុំនេះវិញ សេកនេះបញ្ជោរនូវពួកយើងទេ ។

(២៩២) នាហំ តុម្ហេ បសំសាមិ កុណបាទា សុណាថ មេ

ឧច្ឆិដ្ឋភោជិនោ តុម្ហេ ន តុម្ហេ វិឃាសាទិនោ ។

(២៩៣) សត្តវស្សា បព្វជិតា[១] មជ្ឈារញ្ញេ[២] សិខណ្ឌិនោ

វិឃាសេនេវ យាបេន្តា មយំ ចេ ភោតោ គារយ្ហា

កេ នុ ភោតោ បសំសិយា ។

(២៩៤) តុម្ហេ សីហានំ ព្យគ្ឃានំ វាឡានញ្ចាវសិដ្ឋកំ

ឧច្ឆិដ្ឋេនេវ យាបេន្តា មញ្ញិត្ថ វិឃាសាទិនោ ។

(២៩៥) យេ ព្រាហ្មណស្ស សមណស្ស អញ្ញស្ស វា វណិព្វិនោ

ទត្វាវសេសំ ភុញ្ជន្តិ តេ ជនា វិឃាសាទិនោតិ ។

វិឃាសាទជាតកំ អដ្ឋមំ ។

១ ម. បព្វជិតា ។ ២ មជ្ឈារញ្ញេ ។



(២៩២) (សេកនិយាយថា) ខ្ញុំមិនបញ្ជោរលោកទាំងឡាយទេ បពិត្រលោកអ្នកបរិភោគនូវសាកសព លោកទាំងឡាយ ចូរស្តាប់ខ្ញុំ លោកទាំងឡាយ ជាអ្នកបរិភោគនូវភោជនសល់ លោកទាំងឡាយ មិនមែនជាអ្នកបរិភោគ នូវតែសល់ដែលទេ ។

(២៩៣) (ពួកឥសីនិយាយថា) យើងទាំងឡាយ បួសបាន ៧ វស្សា ហើយ ជាអ្នកមានកំពូលសក់ នៅក្នុងកណ្តាលព្រៃ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយវត្ថុសល់ប៉ុណ្ណោះ បើពួកយើងត្រូវអ្នកទាំងនេះតិះដៀលហើយ តើពួកជនណា គួរជាទីសរសើរ របស់លោកទាំងនេះ ។

(២៩៤) (សេកពោលតប) លោកទាំងឡាយ បរិភោគនូវភោជនសល់ របស់សត្វសាហាវ គឺសីហៈ ខ្លាខ្លា ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយរបស់សល់ ទើបគេសំគាល់ថា ជាអ្នកបរិភោគរបស់សល់ដែល ។

(២៩៥) ពួកជនណា ឲ្យដល់ព្រាហ្មណ៍ សមណៈ នឹងអ្នកសូមឯទៀត ហើយទើបបរិភោគ នូវភោជនដ៏សេសសល់ ពួកជននោះ ហៅថា ជាអ្នកបរិភោគនូវគ្រឿងសល់ដែល ។

ចប់ វិឃាសាទជាតក ទី ៨ ។

# វដ្ដកជាតកំ

(៦៥៦) បណីតំ ភុញ្ជសេ ភត្តំ   សប្បិតេលញ្ច មាតុល
អថ កេន នុ វណ្ណេន   កិសោ ត្វមសិ វាយស ។

(៦៥៧) អមិត្តមជ្ឈេ វសតោ   តេសុ អាមិសមេសតោ
និច្ចំ ឧព្វិគ្គហទយស្ស   កុតោ កាកស្ស ទឡ្ហិយំ ។

(៦៥៨) និច្ចំ ឧព្វិគ្គិនោ កាកា   ធង្កា(១) បាបេន កម្មុនា
លទ្ធោ បិណ្ឌោ ន បីណេតិ   កិសោ តេនស្មិ វដ្ដក ។

(៦៥៩) លូខានិ តិណពីជានិ   អប្បស្នេហានិ ភុញ្ជសិ
អថ កេន នុ វណ្ណេន   ថូលោ ត្វមសិ វដ្ដក ។

(៦៦០) អប្បិច្ឆា អប្បចិន្តាយ   អទូរគមនេន ច
លទ្ធាលទ្ធេន យាបេន្តោ   ថូលោ តេនស្មិ វាយស ។

---

១ ម. ធង្កា ។



# វដ្ដកជាតក

(៦៥៦) (តាបពោធិសត្វ សួរថា) បពិត្រឪពុកធំ លោកបរិភោគនូវបាយ ទឹកដោះរាវ និងប្រេងដ៏ប្រណីត បពិត្រក្អែក កាលបើដូច្នេះ ហេតុអ្វីបានជា អ្នកស្គាំងស្គមម្ល៉េះ ។

(៦៥៧) (ក្អែកឆ្លើយថា) បណ្ដាពួកក្អែកទាំងនោះ សត្វក្អែកនៅក្នុងកណ្ដាលសត្រូវ ស្វែងរកចំណី មានសេចក្ដីតក់ស្លុតជានិច្ច កើតមានសេចក្ដីមាំមួន អំពីណាកើត ។

(៦៥៨) ពួកក្អែក ជាសត្វមានពុតត្បុត តក់ស្លុតអស់កាលជានិច្ច បានដុំបាយដោយអំពើអាក្រក់ មិនដែលឆ្អែតស្កប់ស្កល់ទេ ម្នាលសត្វតាប ព្រោះហេតុនោះ ទើបខ្ញុំស្គាំងស្គម ។

(៦៥៩) ម្នាលតាប អ្នកបរិភោគនូវពូជស្មៅ ដ៏សៅហ្មង មានខ្លាញ់តិច កាលបើដូច្នេះ ហេតុអ្វី ទើបអ្នកមានសរីរៈធាត់ម្ល៉េះ ។

(៦៦០) (តាបពោធិសត្វ តបថា) ម្នាលក្អែក ខ្ញុំញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយរបស់ដែលខ្ញុំបាន និងមិនបាន ព្រោះខ្ញុំជាអ្នកប្រាថ្នាតិច គិតតិច ចាំងក្រាប់ទៅកាន់ទីមិនឆ្ងាយ ព្រោះហេតុនោះ ទើបខ្ញុំជាអ្នកមានសរីរៈធាត់ ។

(២៦១) អប្បិច្ឆស្ស ហិ បោសស្ស អប្បចិន្តិសុខស្ស ច
សុសង្គហិតប្បមាណស្ស វុត្តី សុសមុទានិយា តិ ។

វគ្គកជាតកំ ឥមំ ។

## មណិជាតកំ[1]

(២៦២) ចិរស្សំ វត បស្សាមិ សហាយំ មណិធារិនំ
សុកតា មស្សុកុត្តិយា សោភតេ វត មេ សខា ។
(២៦៣) បរុឡ្ហកច្ឆនខលោមោ អហំ កម្មេសុ ព្យាវដោ
ចិរស្សំ នហាបិតំ លទ្ធា លោមន្តំ អជ្ជ ហារយិំ ។
(២៦៤) យំ នុ លោមំ អហារេសិ ទុល្លភំ លទ្ធកប្បកំ
អថ កិញ្ចិ ហិ តេ សម្ម កណ្ឋេ កិណិកិណាយតិ[2] ។

---

១ ឱ. កាកជាតកំ ។ ម. ជាកុនជាតកំ ។ ២ ឱ. កិណកិណាយតិ ។ ម. កិណកាយតិ ។



(២៦១) សេចក្តីពិតថា ការប្រព្រឹត្តចិញ្ចឹមជីវិត របស់បុគ្គលអ្នកប្រាថ្នាតិច ផង មានសេចក្តីសុខព្រោះការគិតតិចផង ដឹងប្រមាណក្នុងអាហារ ដែលខ្លួនកាន់យកដោយល្អផង រមែងប្រព្រឹត្តទៅបានដោយស្រួល ។

ចប់ វគ្គជាតក ទី ៨ ។

## មណិជាតក

(២៦២) (ព្រាបពោធិសត្វ និយាយថា) យូរណាស់ហើយតើ ខ្ញុំ ទើបឃើញសំឡាញ់ ពាក់ត្បូងគ្រឿងកែវមណី សម្លាញ់របស់ខ្ញុំល្អ មែន ព្រោះល្អដោយការលៃពុកមាត់ ។

(២៦៣) (ក្អែកនិយាយតបថា) ខ្ញុំមានការខ្វល់ខ្វាយច្រើន ក្នុងការងារ មានក្រចកនិងរោមក្លៀកដុះច្របូកច្របល់ យូរណាស់ហើយ ទើបតែ នឹងបានរោមកាត់ចេញក្នុងថ្ងៃនេះ ព្រោះបានជាងកោរកាត់ ។

(២៦៤) (ព្រាបពោធិសត្វ និយាយថា) អ្នកបានឱ្យជាងកោរកាត់ ដែលគេរកបានដោយក្រ ឱ្យកោរចន្លោះរោមណាមែន ឬ ម្នាលសម្លាញ់ កាលបើដូច្នេះ [illegible]បន្តិចបន្តួច ត្រង់ករបស់អ្នក (នោះ) ទុកនៅ [illegible]ធ្វើអ្វី ។

(២៦៥) មនុស្សសុខុមាលានំ   មណី កណ្ឋេសុ លម្ពតិ

តេសាហំ អនុសិក្ខាមិ   មា ត្វំ មញ្ញិ ឆភ កតំ ។

(២៦៦) សចេបិមំ បិហយសិ   មស្សុកុត្តិំ សុការិតំ

ការយិស្សាមិ តេ សម្ម   មណីចាបិ ទទាមិ តេ ។

(២៦៧) ត្វញ្ញេវ មណិនា ឆន្នោ   សុការិតាយ ច មស្សុយា

អាមន្ត ខោ តំ គច្ឆាមិ   បិយំ មេ តវ ទស្សនន្តិ ។

មណិជាតកំ ទសមំ ។

(១)
ខុរប្បវគ្គោ ទុតិយោ ។

## តស្សុទ្ទានំ

អថ បស្ស សស្វធិ ច កុណ្ឌលិនោ

មិគ មយ្ហកបញ្ចមបក្ខិវរោ

អថ បញ្ចាលិ ភរិជ មជ្ឈ បុន

អថ វត្តក កាកោជវរេន ទស ។

---

១ ម. សេនកវគ្គោ ។ ឧ. សុចិវគ្គោ ។



(២៦៥) (ក្អែកនិយាយតបថា) កែវមណី តែងសំយុងចុះ ត្រង់កនៃមនុស្សសុខុមាលជាតិ ខ្ញុំយកតម្រាប់តាមពួកមនុស្សទាំងនោះ អ្នកកុំសំគាល់ថា (ខ្ញុំ) ធ្វើដោយល្បែងឡើយ ។

(២៦៦) បើអ្នកពេញចិត្តនឹងការលេងពុកមាត់ ដែលឲ្យជាងធ្វើយ៉ាងល្អនេះ ម្នាលសម្លាញ់ ខ្ញុំនឹងឲ្យជាងធ្វើដល់អ្នកផង ឲ្យនូវកែវមណីដល់អ្នកផង ។

(២៦៧) (ព្រាបពោធិសត្វ និយាយថា) អ្នកឯងយកកែវមណីផង យកពុកមាត់ដែលគេធ្វើឲ្យល្អផង មកបិទបាំង ទើបខ្ញុំហៅអ្នកមកហើយនឹងទៅ ការបានជួបប្រទះនឹងអ្នក មែនជាទីពេញចិត្តរបស់ខ្ញុំ ។

ចប់ មណិជាតក ទី ១០ ។

ចប់ ខុរប្បវគ្គ ទី ២ ។

## ឧទ្ទាននៃខុរប្បវគ្គនោះគឺ

និយាយអំពីអ្នកចូលមើលចុះ (ជាដើម) ១ ព្រមទាំងម្ជុល ១ កុណ្ឌលជាតក ១ ម្រឹគក្តាម ១ សត្វស្លាបដ៏ប្រសើរ ឈ្មោះមយ្ហកៈ ជាគំរប់ ៥ ផ្គនិតញ្ចាលី ១ ក្តាឈូក ១ កណ្តាលព្រៃ ១ សត្វតាប ១ ក្រោចដ៏ប្រសើរ ១ រួមជា ១០ ។

## តត្រ វគ្គុទ្ទានំ ភវតិ

អថ វគ្គំ បកាសិស្សំ ឆនិបាតំ វគ្គមេ

អាភរិយា ច សុចិ ច ទ្វេ ច វគ្គា សុព្យញ្ជនា ។

ឆក្កនិបាតំ និដ្ឋិតំ ។





## ឧទ្ទាននៃវគ្គ ក្នុងឆក្កនិបាតនោះគឺ

និទានសំដែងនូវវគ្គ ក្នុងឆក្កនិបាត ដ៏ប្រសើរថ្លៃថ្លា វគ្គទាំងពីរ គឺ អាភរិយវគ្គ និងខុរប្បវគ្គ មានពាក្យថា សុចិជាតក មានលក្ខណៈដ៏ល្អ ដែលព្រះដ៏មានព្រះភាគ សំដែងហើយ ។

ចប់ ឆក្កនិបាត ។

# សត្តកនិបាតជាតកំ

## កុក្កុវគ្គោ

### កុក្កុជាតកំ

[៦៦៨] ទិយឌ្ឍកុក្កូ ឧទយេន កណ្ណិកា
វិទត្ថិយោ អដ្ឋ បរិក្ខិបន្តិ នំ
សា(១) សឹសបា សារមយា អផេគ្គុកា
កុហឹ ឋិតា ឧបរិតោ ន ធំសតិ ។

[៦៦៩] យា តឹសតិ សារមយា អផេគ្គុកា
បរិកិរិយា គោបានសិយោ សមដ្ឋិតា
តាហិ សុសង្គហិតា ពលសា ច បីឡិតា
សមដ្ឋិតា ឧបរិតោ ន ធំសតិ ។

[៦៧០] ឯវម្បិ មិត្តេហិ ទឡ្ហេហិ បណ្ឌិតោ
អភេជ្ជរូបេហិ សុចីហិ មន្តិភិ
សុសង្គហីតោ សិរិយា ន ធំសតិ
គោបានសីភារវហាវ កណ្ណិកា ។

១ ម. សសំសបា ។ ឱ. យាសំសបា ។

# សត្តកនិបាតជាតក

## កុក្កុវគ្គ

### កុក្កុជាតក

[៦៦៨] (ព្រះបាទព្រហ្មទត្ត សួរអាមាត្យពោធិសត្វថា) កំពូល (ដំបូល) មួយហត្ថកន្លះ ផ្ទៃជុំវិញកំពូលនោះ ៨ ចំអាម កំពូលនោះ ជាឈើធ្នង់រឹងសុទ្ធ ឥតមានស្រាយ ឋិតនៅលើអ្វីហ្ន៎ បានជាមិនជ្រុះអំពីខាងលើមក ។

[៦៦៩] (ពោធិសត្វ ពោលតបថា) បន្ទឹងទាំងឡាយណា ចំនួន ៣០ រឹងសុទ្ធ ឥតមានស្រាយ ឋិតនៅកៀបតាជុំវិញ (កំពូលនោះ) បន្ទឹងទាំងឡាយនោះ ទល់ទ្រផង តាបដោយកំឡាំងផង ឋិតនៅស្មើគ្នា ទើបមិនធ្លាក់ចុះ អំពីខាងលើមក ។

[៦៧០] បណ្ឌិត បានពួកមិត្រទាំងមួន មានសភាពមិនបែកចិត្តគ្នា មានប្រាជ្ញាជាទីស្អាត ជួយទល់ទ្រហើយ រមែងមិនសាបសូន្យចាកសិរី ដូចជាកំពូល (ដំបូល) ដែលបន្ទឹងនាំទៅនូវភារៈយ៉ាងនេះឯង ។

(៦៧១) ខរត្តចំ ពេលុវំ យថាបិ សត្ថក
អនាមសន្តោបិ ករោតិ តិត្តកំ
សមាហរំ សាទុ ករោតិ បត្ថវំ[1]
អសាទុ កយិរា តនុពន្ធមុទ្ធរំ ។

(៦៧២) ឯវម្បិ គាមនិគមេសុ បណ្ឌិតោ
អសាហសំ រជ្ជ ធនានិ សង្ឃរំ
ធម្មានុវត្តី បដិបជ្ជមានោ
ផាតី[2] កយិរា អវិហេឋយំ បរំ ។

(៦៧៣) ឱទាតមូលំ សុចិវារិសម្ភវំ
ជាតំ យថា បោក្ខរណីសុ អម្ពុជំ
បទុមំ យថា អគ្គិនិកាសិផាលិមំ[3]
ន កទ្ទមោ ន រជោ ន វារិ លិម្បតិ ។

(៦៧៤) ឯវម្បិ វោហារសុចិំ អសាហសំ
វិសុទ្ធកម្មន្តមបេតបាបកំ
ន លិម្បតិ កម្មកិលេស តាទិសោ
ជាតំ យថា បោក្ខរណីសុ អម្ពុជំ ។

កុក្កុជាតកំ បឋមំ ។

១ ឱ. ម. បត្ថិវំ ។ ២ ឱ. ម. សុផាតិ ។ ៣ ឱ. ម. អគ្គិនិកាសិផាលិមំ ។



(៦៧១) បុគ្គលដែលមានកាំបិតក្នុងដៃ កាលបើមិនចិតផ្លែព្រួចធ្នារ ដែលមានសម្បកគ្រើមចេញទេ រមែងធ្វើ (ផ្លែនេះ) ឲ្យមានរសល្វីង បពិត្រម្ចាស់ផែនដី បុគ្គលកាលនាំយក (សម្បកក្រៅចេញ) រមែងធ្វើឲ្យមានរសឆ្ងាញ់ កាលបើចិតសម្បកសើៗទេ រមែងធ្វើឲ្យមានរសមិនឆ្ងាញ់ មានឧបមាយ៉ាងណាមិញ ។

(៦៧២) ព្រះរាជាជាបណ្ឌិត វៀរ មិនលុះអំណាចកម្មដ៏ក្រៀវក្រា វៀរ (អគតិ) ក្នុងពួកអ្នកស្រុក អ្នកនិគម ប្រមូលមកនូវទ្រព្យទាំងឡាយ ជាអ្នកប្រព្រឹត្ត ប្រតិបត្តិតាមធម៌ មិនបៀតបៀនបុគ្គលដទៃ គប្បីធ្វើឲ្យសំរេចបាន ក៏មានឧបមេយ្យយ៉ាងនោះដែរ ។

(៦៧៣) ផ្កាឈូក ជាអម្ពុជជាតិ មានឫសស កើតក្នុងទឹកដ៏ស្អាត ក្នុងស្រះបោក្ខរណី រីកស្គុះស្គាយដោយសារព្រះអាទិត្យ មិនជាប់ដោយភក់ មិនជាប់ដោយធូលី មិនជាប់ដោយទឹក មានឧបមាយ៉ាងណាមិញ ។

(៦៧៤) កម្មកិលេសប្រាកដដូច្នោះ មិនប្រឡាក់ (ចំពោះស្តេច) ដែលមានវោហារ (សម្រាប់វិនិច្ឆ័យ) ដ៏ស្អាត មិនមានកម្មជាសាហស មានការងារដ៏ស្អាត មានបាបកម្មប្រាសចេញហើយ ដូចជាផ្កាឈូកដែលដុះក្នុងស្រះបោក្ខរណី ក៏មានឧបមេយ្យយ៉ាងនោះដែរ ។

ចប់ កុក្កុជាតក ទី ១ ។

# មនោជជាតកំ

(៤៧៥) យថា ចាបោ និន្នមតិ ជិយា ចាបិ និកូជតិ
ហញ្ញតេ នូន មនោជោ មិគរាជា សខា មម ។
(៤៧៦) ហន្ទទានិ វនន្តានិ បក្កមាមិ យថាសុខំ
នេតាទិសា សខា ហោន្តិ លព្ភា មេ ជីវតោ សខា ។
(៤៧៧) ន បាបជនសំសេវី អច្ចន្តំ សុខមេធតិ
មនោជំ បស្ស សេមានំ គិរិយស្សានុសាសនី(១) ។
(៤៧៨) ន បាបសម្បវង្កេន មាតា បុត្តេន នន្ទតិ
មនោជំ បស្ស សេមានំ អច្ឆន្នំ សម្ហិ លោហិតេ ។

១ ឧ. គិរិយស្សានុសាសនំ ។



# មនោជជាតក

(៤៧៥) (ចចកឮសំឡេងសីហៈនិងសំឡេងបន្ទោរធ្នូ ហើយក៏ពោលគាថាពីរនេះថា) ធ្នូទន់ចុះយ៉ាងណា បន្ទោរលាន់ឮយ៉ាងណា ដោយហេតុណា មិគរាជ ឈ្មោះមនោជៈ ជាសំឡាញ់របស់អញ ត្រូវគេសម្លាប់ដោយពិត (ដោយហេតុនោះ) ។

(៤៧៦) បើដូច្នោះមានតែអញនឹងចៀសចេញទៅ កាន់ព្រៃជាទីពឹង តាមសេចក្ដីសប្បាយ ក្នុងពេលឥឡូវនេះ សត្វស្លាប់បែបនេះ នឹងយកធ្វើជាសំឡាញ់ មិនកើត កាលបើអញរស់នៅ គង់បាន សំឡាញ់ទៀត ។

(៤៧៧) ( មាតាបិតា បរិច្ចេទស្រី ប្រុស ពោលគាថាទាំង ៤ នេះថា ) បុគ្គលដែលសេពគប់ ជាមួយនឹងជនបាប មិនបានសេចក្ដីសុខដ៏ ទៀងទាត់ឡើយ អ្នកចូរមើលសីហៈ ឈ្មោះ មនោជៈ កំពុងដេក (ស្លាប់នេះ ព្រោះតែជឿតាម ) ពាក្យប្រៀនប្រដៅ របស់ចចក ឈ្មោះគិរិយៈ ។

(៤៧៨) មាតាមិនបានរីករាយ ជាមួយនឹងកូន ព្រោះតែគប់គេសំឡាញ់ អាក្រក់ អ្នកចូរមើលសីហៈ ឈ្មោះ មនោជៈ ដេកត្រាំនៅក្នុង ឈាមរបស់ខ្លួន ។

(៦៧៩) ឯវំ ហេ បជ្ជេតោ តោសោ ហាបិយោ ច និគច្ឆតិ

យោ វេ ហិតាន វចនំ ន ករោតិ អត្ថទស្សិនំ ។

(៦៨០) ឯវញ្ច សោ ហោតិ តតោ ហាបិយោ

យោ ឧត្តមោ អធមជនូបសេវី

បស្សុត្តមំ អធមជនូបសេវី(១)

មិគាធិបំ សរវរវេគនិទ្ធុតំ ។

(៦៨១) និហីយតិ បុរិសោ និហីនសេវី

ន ច ហាយេថ កទាចិ តុល្យសេវី

សេដ្ឋមុបគមំ ឧទេតិ ខិប្បំ

តស្មា អត្តនោ ឧត្តរិំ ភជេថាតិ ។

ឥតោនិវគ្គោ ទុតិយំ ។

---

១ ម អធម្មជនូបសេវិតំ ។



(៦៧៩) សត្វណាមិនធ្វើតាមពាក្យនៃជនទាំងឡាយ អ្នកប្រាថ្នានូវសេចក្ដីចំរើន អ្នកឃើញនូវប្រយោជន៍ (ទៅក្នុងអនាគត) សត្វនោះរមែងដល់ (នូវសេចក្ដីទុក្ខ) យ៉ាងនេះផង ដែលឈ្លបព្រះនូវទាសដ៏លាមកក្រៃលែងផង ។

(៦៨០) បុគ្គលដ៏ខ្ពង់ណា សេពគប់នឹងអធម្មជន (ជនដ៏លាមក) បុគ្គលនោះ តាក់តែងក្រៃលែង ជាងអធម្មជននោះទៅទៀត យ៉ាងនេះ អ្នកចូរមើលនូវស្ដេចនៃម្រឹគដ៏ខ្ពង់ ដែលសេពគប់នឹងអធម្មជន ក្រៅកំឡាំងនៃព្រួញ ដ៏ប្រសើរ មុតហើយ ។

(៦៨១) (ព្រះសាស្ដាទ្រង់ត្រាស់ នូវអភិសម្ពុទ្ធគាថា ក្រោយបំផុតថា) បុរសអ្នកគប់គនូវជនថោកទាប រមែងសាបសូន្យ បុគ្គលគប់គនូវជនស្មើ ៗ គ្នា រមែងមិនសាបសូន្យ ក្នុងកាលណាមួយ គប់គនូវជនដែលប្រសើរជាង រមែងចំរើន ឆាប់រហ័ស ព្រោះហេតុនោះ បុគ្គលគួរតែគប់គ នូវបុគ្គល ដែលប្រសើរជាងខ្លួន ។

ចប់ ឥតោនិវគ្គ ទី ២ ។

## សុតនជាតកំ

(២៨២) រាជា តេ ភត្តំ បាហេសិ សុចឹ មំសូបសេចនំ
មខាទេវស្មឹ អធិវត្ថោ ឯហិ និក្ខម្ម ភុញ្ជស្សុ ។

(២៨៣) ឯហិ មាណវ ឱរេហិ(១) ភិក្ខមាទាយ សូបិតំ(២)
ត្វញ្ច មាណវ ភក្ខាសិ ឧភោ ភក្ខា ភវិស្សថ ។

(២៨៤) អប្បកេន តុវំ យក្ខ ថុល្លមត្ថំ ជហិស្សសិ
ភិក្ខន្តេ នាហរិស្សន្តិ ជនា មរណសត្តិនោ(៣) ។

(២៨៥) លទ្ធាយំ យក្ខ តវ និច្ចភិក្ខំ
សុចឹ បណីតំ រសសាទុបេតំ
ភិក្ខញ្ច តេ អាហរិយោ នរោ ឥធ
សុទុល្លភោ ហេហិតិ ខាទិតេ មយិ ។

(២៨៦) មមេវ សុតន អត្ថោ យថា ភាសសិ មាណវ
មយា ត្វំ សមនុញ្ញាតោ សោត្ថឹ បស្សាហិ មាតរំ ។

១ ម. ឯហេ ។ ២ ឱ. ម. សូបិយំ ។ ៣ ឱ. ម. មរណសញ្ញិនោ ។



## សុតនជាតក

(២៨២) (ពោធិសត្វពោលថា) ស្ដេចបានបញ្ជូនភត្ត ដែលលាយដោយសាច់ដ៏ស្អាត មកឲ្យអ្នក ម្នាលទេវតាអ្នកអាស្រ័យនៅ លើដើមជ្រៃក្រើម អ្នកចូរចេញមក បរិភោគចុះ ។

(២៨៣) (យក្សពោលថា) នែមាណព អ្នកចូរមក ចូរអ្នកយកបាយព្រមទាំងសម្លចុះមក ម្នាលមាណព អ្នកនឹងបានជាចំណី (នៃយើង) អ្នកទាំងពីរនឹងបានជាចំណី ។

(២៨៤) (ពោធិសត្វពោលថា) ម្នាលយក្ស អ្នកនឹងលះបង់នូវប្រយោជន៍ធំ ព្រោះតែហេតុបន្តិចបន្តួច ពួកជនអ្នកភ្លៀសនឹងសេចក្ដីស្លាប់ នឹងលែងយកអាហារ មកឲ្យអ្នកទៀតហើយ ។

(២៨៥) ម្នាលយក្ស អ្នកនឹងបាននូវនិច្ចភត្ត ដ៏ស្អាតថ្លៃថ្លា ប្រកបដោយរសដ៏ឧត្តម កាលបើអ្នកទំពាស៊ីយើងហើយ ជនអ្នកនាំយកអាហារ មកឲ្យអ្នក មុខជាមិនងាយនឹងរកបាន ក្នុងទីនេះទៀតឡើយ ។

(២៨៦) (យក្សមានចិត្តជ្រះថ្លាហើយ បានពោលថា) ម្នាលសុតនមាណព អ្នកនិយាយ (បែបនេះ) ជាប្រយោជន៍ដល់ខ្ញុំមែនហើយ ខ្ញុំព្រមបើកលែងអ្នកទៅហើយ ចូរអ្នកជួបនឹងមាតា ដោយសួស្ដីចុះ ។

(២៨៧) ខគ្គំ ឆត្តញ្ច បាតិញ្ច គច្ឆេវាទាយ មាណវ

សោត្ថឹ បស្សតុ តេ មាតា ត្វញ្ច បស្សាហិ មាតរំ ។

(២៨៨) ឯវំ យក្ខ សុខី ហោហិ សហ សព្វេហិ ញាតិភិ

ធនញ្ច មេ អធិគតំ រញ្ញោ ច វចនំ កតន្តិ ។

សុតនជាតកំ តតិយំ ។

## មាតុបោសកគិជ្ឈជាតកំ

(២៨៩) តេ កថន្នុ ករិស្សន្តិ វុឌ្ឍា គិរិទរីសយា

អហំ ពទ្ធោស្មិ បាសេន និលិយស្ស វសំ គតោ ។

(២៩០) កឹ គិជ្ឈ បរិទេវសិ កា នុ តេ បរិទេវនា

ន មេ សុតោ វា ទិដ្ឋោ វា ភាសន្តោ មានុសឹ ទិជោ ។

(២៩១) ភរាមិ មាតាបិតរោ វុឌ្ឍេ គិរិទរីសយេ

តេ កថន្នុ ករិស្សន្តិ អហំ វសំ គតោ តវ ។



(២៨៧) ម្នាលមាណព ចូរអ្នកកាន់យកព្រះខាន់ ឆ័ត្រ និងភាជន៍ ទៅចុះ សូមឲ្យមាតារបស់អ្នក ឃើញអ្នកដោយសួស្តី អ្នកសោតក៏ចូរទៅជួបនឹងមាតាចុះ ។

(២៨៨) (ពោធិសត្វ ពោលថា) ម្នាលយក្ខ កាលបើយ៉ាងនេះ សូមឲ្យអ្នកបានសេចក្តីសុខ ព្រមដោយពួកញាតិទាំងអស់ ទ្រព្យក៏ខ្ញុំបានហើយ ពាក្យព្រះឱង្ការ របស់ព្រះរាជា ខ្ញុំបានធ្វើរួចហើយ ។

ចប់ សុតនជាតក ទី ៣ ។

## មាតុបោសកគិជ្ឈជាតក

(២៨៩) (ត្មាតពោធិសត្វ ពោលថា) មាតាបិតាទាំងនោះចាស់ ជ្រាយ នៅក្នុងជ្រោកភ្នំ នឹងធ្វើដូចម្តេចហ្ន៎ អាត្មាអញជាប់អន្ទាក់ លុះអំណាចនៃនេសាទបុត្ត ឈ្មោះនិលិយៈហើយ ។

(២៩០) (នេសាទបុត្ត ពោលថា) ម្នាលត្មាត ហេតុដូចម្តេច ក៏បានជាអ្នកខ្សឹកខ្សួល ការខ្សឹកខ្សួលរបស់អ្នក ដូចម្តេចហ្ន៎ បក្សីចេះនិយាយសំដីមនុស្ស យើងមិនដែលឮ មិនដែលឃើញសោះឡើយ ។

(២៩១) (ពោធិសត្វ ពោលថា) យើងចិញ្ចឹមមាតាបិតាចាស់ ជ្រាយ នៅក្នុងជ្រោកភ្នំ យើងលុះក្នុងអំណាចអ្នកហើយ មាតាបិតាទាំងនោះ នឹងធ្វើដូចម្តេចហ្ន៎ ។

(៤៨២) យន្នុ គិជ្ឈោ យោជនសតំ កុណបានិ អវេក្ខតិ
កស្មា ជាលញ្ច បាសញ្ច អាសជ្ជាបិ ន ពុជ្ឈសិ ។
(៤៨៣) យទា បរាភវោ ហោតិ បោសោ ជីវិតសង្ខយេ
អថ ជាលញ្ច បាសញ្ច អាសជ្ជាបិ ន ពុជ្ឈតិ ។
(៤៨៤) ភរស្សុ មាតាបិតរោ វុឌ្ឍេ គិរិគព្ភរាសយេ
មយា ត្វំ សមនុញ្ញាតោ សោត្ថឹ បស្សាហិ ញាតកេ ។
(៤៨៥) ឯវំ លុទ្ទក នន្ទស្សុ សហ សព្វេហិ ញាតិភិ
ភរិស្សំ មាតាបិតរោ វុឌ្ឍេ គិរិគព្ភរាសយេតិ ។

មាតុបោសកគិជ្ឈជាតកំ បឋមំ ។

## ទព្ភបុប្ផជាតកំ

(៤៨៦) អនុតីរចារី ភទ្ទន្តេ សហាយមនុធាវ មំ
មហា មេ គហិតោ[១] មច្ឆោ សោ មំ ហរតិ វេគសា ។

---

១ ម. គហិតោ ។





(៤៨២) (នេសាទបុត្ត ពោលថា) ក្រែងត្មាត តែងមើលឃើញសាកសព ចម្ងាយ ១០០ យោជន៍បាន ព្រោះហេតុអ្វី បានជាអ្នកមកជាប់លប់ និងអន្ទាក់ ក៏មិនភ្ញាក់ខ្លួនសោះ ។

(៤៨៣) (ពោធិសត្វ ពោលថា) ពេលណាដែលមានសេចក្តីវិនាស (មកដល់) ពេលនោះ សត្វដែលនឹងអស់ជីវិត បើទុកជាមកជាប់លប់ និងអន្ទាក់ ក៏នឹងមិនអាចភ្ញាក់ខ្លួនបាន ។

(៤៨៤) (នេសាទបុត្ត ពោលថា) អ្នកចូរទៅចិញ្ចឹមមាតាបិតាចាស់ជរា ដែលអាស្រ័យនៅ ក្នុងប្រហោងភ្នំចុះ យើងបានបើកលែងអ្នកហើយ ចូរអ្នកទៅជួបនឹងពួកញាតិសន្តាន ដោយសួស្តីចុះ ។

(៤៨៥) (ពោធិសត្វ ពោលថា) ម្នាលព្រាន អ្នកចូរត្រេកអរជាមួយនឹងពួកញាតិទាំងអស់ យ៉ាងនេះចុះ យើងនឹងចិញ្ចឹមមាតាបិតាចាស់ ដែលអាស្រ័យនៅ ក្នុងប្រហោងភ្នំ ។

ចប់ មាតុបោសកគិជ្ឈជាតក ទី ៤ ។

## ទព្ភបុប្ផជាតក

(៤៨៦) (កៅដែលត្រាច់ទៅក្នុងទឹកជ្រៅ ពោលថា) ម្នាលសំឡាញ់ អ្នកត្រាច់ទៅតាមឆ្នេរទឹកចំរើន សូមអ្នកស្ទុះមកជួយខ្ញុំ ខ្ញុំចាប់បានត្រីធំ វាទាញខ្ញុំទៅ ដោយកំឡាំងដ៏ខ្លាំង ។

(២៩៧) គម្ភីរចារី ភទ្ទន្តេ ទឡ្ហំ គណ្ហាហិ ថាមសា
អហំ តំ ឧទ្ធរិស្សាមិ សុបណ្ណោ ឧរគម្មិវ ។

(២៩៨) វិវាទោ នោ សមុប្បន្នោ ទព្ភបុប្ផ សុណោហិ មេ
សមេហិ មេធគំ សម្ម វិវាទោ វូបសម្មតុ(១) ។

(២៩៩) ធម្មដ្ឋោហំ បុរេ អាសឹ ពហុអដ្ឋំ តីរិតំ(២)
សមេមិ មេធគំ សម្ម វិវាទោ វូបសម្មតុ ។

(៣០០) អនុតីរចារី នង្គុដ្ឋំ សីសំ គម្ភីរចារិនោ
អថាយំ(៣) មជ្ឈិមោ ខណ្ឌោ ធម្មដ្ឋស្ស ភវិស្សតិ ។

(៣០១) ចិរំបិ ភក្ខោ អភវិស្ស សចេ ន វិវទេមសេ
អសីសកំ អនង្គុដ្ឋំ សិគាលោ ហរតិ រោហិតំ ។

១ ឱ. ម. វូបសម្មតំ ។ ២ ម. ពហុអត្ថា មេ តីរិតា ។ ៣ ឱ. អថាយំ ។



(២៩៧) (ភេក្រាប់ទៅតាមឆ្នេរក្រៅនេះ ពោលថា) ម្នាលអ្នកក្រាប់ទៅក្នុងទឹកជ្រៅដ៏ចំរើន អ្នកចូរចាប់ ដោយកំឡាំងយ៉ាងមាំ ខ្ញុំនឹងជួយទាញយកត្រីនោះ ដូចគ្រុឌដែលស្រង់ឡើងនូវពស់ ។

(២៩៨) (ភេទាំងពីរឃើញចចកហើយ ពោលថា) ម្នាលចចកទព្ភបុប្ផៈ ចូរអ្នកស្តាប់ពាក្យយើង វិវាទកើតដល់យើងហើយ ម្នាលសំឡាញ់ អ្នកចូររម្ងាប់នូវជំលោះ ឲ្យវិវាទ (របស់យើង) ស្ងប់រម្ងាប់ទៅ ។

(២៩៩) (ចចកពោលថា) កាលពីដើម យើងជាអ្នកឋិតនៅក្នុងតំណែងជំរះក្តី បានកាត់ក្តី ឲ្យគេជាច្រើនមកហើយ ម្នាលសំឡាញ់ យើងនឹងរម្ងាប់នូវជំលោះ (របស់អ្នកទាំងពីរ) សូមឲ្យវិវាទ (របស់អ្នកទាំងពីរ) ស្ងប់រម្ងាប់ទៅ ។

(៣០០) ម្នាលភេអ្នកក្រាប់ទៅតាមឆ្នេរ (អ្នកត្រូវបាន) កន្ទុយ ភេដែលក្រាប់ទៅក្នុងទឹកជ្រៅ (ត្រូវបាន) ក្បាល ដុំជាកណ្តាលក្រៅអំពីចំណែកពីរនេះ ត្រូវបាន (យើង) អ្នកឋិតនៅក្នុងតំណែងជំរះក្តី ។

(៣០១) (ភេទាំងពីរត្អូញថា) ប្រសិនបើ យើងកុំទាស់គ្នា (ត្រីនេះ) នឹងបានជាអាហារអស់កាលដ៏យូរ ចចកនាំយកត្រីក្តិន ឥតក្បាល ឥតកន្ទុយទៅព្រៃហើយ ។

(៣០២) យថាបិ ភាជនេ ធេយ្យ វដ្ដំ លទ្ធាន ចក្ខុយោ

ឯកំ ហាមជ្ជ ឆន្ទាមិ ទិស្វា បុណ្ណមុខំ បតឹ ។

(៣០៣) កាវន្ត ជលតោ សេដ្ឋោ ឧទកោ មជ្ជំ បកមសិ

បុដ្ឋោ មេ សម្ម អក្ខាហិ កាជំ អធិគតំ តយា ។

(៣០៤) វិភវេន កិសា ហោន្តិ វិភវេន ធនក្ខយោ

ជិតា ឧទ្ធា វិភវេន កុញ្ជមាយាវិភេហិតិ ។

(៣០៥) ឯវមេវ មនុស្សេសុ វិភវោ យត្ថ ជាយតិ

ឧម្មុជ្ជំ បជិនាវុត្តិ សោ ហិ នេសំ វិធាយកោ

ឆាបំ តត្ថ មីយន្តិ កាជកោសោ បវត្តតិ ។

ទុក្ខុប្បត្តិគាថា បញ្ចមំ ។



(៣០២) (មេឃបក គោលជា) ទន្លិយកជ បានខ្សែកជសម្បត្តិហើយកែ-
កយ យ៉ាងណាមិញ ក្នុងថ្ងៃនេះ ខ្ញុំឃើញប្ដីដែលមានមុខកែហើយ
ក៏មានចិត្តកែកយ យ៉ាងនោះដែរ ។

(៣០៣) អ្នកជាសត្វកើតលើគោគេទ ម្ដេចក៏ចាប់ត្រីក្នុងទឹកបាន ខ្ញាល
សំឡាញ់ ខ្ញុំសួរហើយ សូមអ្នកប្រាប់ អ្នកចាប់ (ត្រី) បាន
ដោយហេតុដូចម្ដេច ។

(៣០៤) (បចក គោលជា) សត្វទាំងឡាយស្គាំងស្គម ព្រោះតែការ
ចាស់ទ្រនិត្ត ការអស់ទ្រព្យសម្បត្តិ ក៏ព្រោះតែចាស់ទ្រនិត្តដែរ
គេ (ទាំងពីរ) សាបសូន្យ (ពាក្រើ) ព្រោះតែចាស់ទ្រនិត្ត ថែ
ខាងហេយាវី ខាងដូចបារិកាតខ្លួត្រីខ្ញុំ ។

(៣០៥) (អតិសម្ពុទ្ធគាថា) ក្នុងទីណា វិភវកើតឡើង ក្នុងពួកមនុស្ស
(មនុស្សទាំងឡាយ) រមែងសុះស្ទុះទៅតាមទៅក្រោម អ្នកកាត់ក្ដី
ផ្សេងៗទៅក្រោមនោះ ជាអ្នកដឹកនាំមនុស្សទាំងនោះ មនុស្សទាំងនោះ
រមែងសាបសូន្យពាក្រើ (របស់ខ្លួន) ក្នុងទីនោះ ឃ្លាំង
ព្រះរាជា រមែងចំរើន គឺយ៉ាងនោះដែរ ។

ចប់ ទុក្ខុប្បត្តិគាថា ទី ៥ ។

# ទសណ្ណកជាតកំ[១]

(៣០៦) ទសណ្ណកំ តិខិណធារំ អសឹ សម្បន្នបាយិនំ
បរិសាយំ បុរិសោ គិលតិ តំ ទុក្ករតរំ តតោ
យទញ្ញំ ទុក្ករំ ឋានំ តំ មេ អក្ខាហិ បុច្ឆិតោ ។

(៣០៧) គិជ្ឈេយ្យ បុរិសោ លោភា អសឹ សម្បន្នបាយិនំ
យោ ច វជ្ជា ទទាមីតិ តំ ទុក្ករតរំ តតោ
សព្វញ្ញំ សុករំ ឋានំ ឯវំ ជានាហិ មាគធ[២] ។

(៣០៨) ព្យាកាសិ អាយុរោ បញ្ហំ អត្ថំ ធម្មស្ស កោវិទោ
បុក្កុសំ ទានិ បុច្ឆាមិ កំ ទុក្ករតរំ តតោ
យទញ្ញំ ទុក្ករំ ឋានំ តំ មេ អក្ខាហិ បុច្ឆិតោ ។

១ ម. ទសណ្ណកជាតកំ ។ ២ ម. មគធ ។



# ទសណ្ណកជាតក

(៣០៦) (ព្រះរាជាទ្រង់សួរតាមាត្យ ឈ្មោះអាយុរៈថា) បុរសលេបដាវ មានមុខដ៏មុត ដែលកើតក្នុងដែនឈ្មោះទសណ្ណកៈ ជាដាវផឹកឈាមខ្មាំងហើយ ក្នុងកណ្ដាលបរិស័ទ ចុះអំពើអ្វី ដែលគេធ្វើបានដោយកម្រ ជាងកិរិយាលេបនូវដាវនោះទៅទៀត ខ្ញុំសួរហើយ អ្នកចូរប្រាប់នូវហេតុដទៃ ដែលគេធ្វើបានដោយកម្រនោះ ។

(៣០៧) (អាយុរាមាត្យ ពោលថា) បុរសលេបដាវ ដែលផឹកឈាមខ្មាំងហើយ ព្រោះតែលោភៈ បើបុគ្គលណា ពោលថា យើងនឹងឲ្យ (នូវវត្ថុនោះដល់អ្នក) ដូច្នេះ ពាក្យរបស់បុគ្គលនោះ គឺបានធ្វើក្រៃលែង ជាងការលេបដាវនោះ ទៅទៀត បពិត្រព្រះមាគធរាជ ហេតុដទៃទាំងអស់ (ក្រៅអំពីពាក្យនេះ) គេធ្វើបានដោយងាយ ទូលព្រះអង្គទ្រង់ជ្រាប យ៉ាងនេះចុះ ។

(៣០៨) (ព្រះរាជាទ្រង់ត្រាស់ជាមួយនឹងបុក្កុសាមាត្យថា) អាយុរបណ្ឌិតជាអ្នកឈ្លាសវៃក្នុងធម៌ បានដោះស្រាយនូវសេចក្ដីនៃប្រស្នា ឥឡូវនេះ យើងនឹងសាកសួរ ចំពោះបុក្កុសបណ្ឌិតវិញ តើអំពើអ្វីដែលបុគ្គលធ្វើបានដោយកម្រ ជាងពាក្យនោះទៅទៀត យើងសួរហើយ អ្នកចូរប្រាប់នូវហេតុដទៃ ដែលបុគ្គលធ្វើបានដោយកម្រនោះ (ដល់យើង)។

(៣០៩)ន វាចមុបជីវន្តិ អផលំ គិរមុទីរិតំ
យោ(១)ទត្វា អវាកាយិក តំ ទុក្ករតរំ តតោ
សព្វញ្ញំ សុករំ ឋានំ ឯវំ ជានាហិ មាគធ ។

(៣១០)ព្យាកាសិ បុក្កុសោ បញ្ហំ អត្ថំ ធម្មស្ស កោវិទោ
សេនកំ ទានិ បុច្ឆាមិ កឹ ទុក្ករតរំ តតោ
យទញ្ញំ ទុក្ករំ ឋានំ តំ មេ អក្ខាហិ បុច្ឆិតោ ។

(៣១១)ទទេយ្យ បុរិសោ ទានំ អប្បំ វា យទិ វា ពហុំ
យោ ច ទត្វា នានុតប្បេ តំ ទុក្ករតរំ តតោ
សព្វញ្ញំ សុករំ ឋានំ ឯវំ ជានាហិ មាគធ ។

១ [illegible] ទិស្សតិ ។





(៣០៩) (បុក្កុសបណ្ឌិត ពោលថា) ពួកមនុស្ស រស់នៅ (ព្រោះការអាស្រ័យ)នូវវាចាឥតផល ជាសំដីដែលគេពោល ឥតអន្លើមានឡើយ បុគ្គលណា បានឲ្យ (ពាក្យប្តេជ្ញា) ហើយក៏បានកាត់ផ្តាច់ចោល (នូវលោភៈ) ពាក្យប្តេជ្ញានោះ ជាការធ្វើដោយលំបាក ជាងការលេបថាវិញនឹងជាងពាក្យនោះទៅទៀត បពិត្រព្រះបាទមាគធរាជ ហេតុដទៃទាំងអស់ គេធ្វើបានដោយងាយទេ សូមព្រះអង្គទ្រង់ជ្រាប យ៉ាងនេះចុះ ។

(៣១០) (ព្រះរាជាទ្រង់សួរសេនកបណ្ឌិតថា) បុក្កុសបណ្ឌិត ជាអ្នកឈ្លាសវៃក្នុងធម៌ បានឆ្លើយនូវសេចក្តីនៃប្រស្នារួចហើយ ឥឡូវនេះ យើងនឹងសួរចំពោះសេនកបណ្ឌិត អ្វីនេះ ដែលបុគ្គលធ្វើបានដោយលំបាក ជាងពាក្យប្តេជ្ញានោះទៅទៀត យើងសួរហើយ អ្នកចូរប្រាប់នូវហេតុដទៃ ដែលបុគ្គលធ្វើបានដោយលំបាកនោះ (ដល់យើង) ។

(៣១១) (សេនកបណ្ឌិត ពោលថា) បុរសគួរឲ្យនូវទាន ទោះបីតិចក្តី ច្រើនក្តី បើបុគ្គលណាបានឲ្យហើយ មិនក្តៅក្រហាយស្តាយក្រោយ ដំណើរនោះ ជាការធ្វើបានដោយលំបាក ជាងការលេបថាដើមនោះទៅទៀត បពិត្រព្រះបាទមាគធរាជ ហេតុដទៃទាំងអស់ គេធ្វើបានដោយងាយទេ សូមព្រះអង្គទ្រង់ជ្រាប យ៉ាងនេះចុះ ។

(៣១៦) ព្យាកាសិ អាយុរោ បញ្ហំ អថោ បុក្កុសទោវិសោ
សព្វេ បញ្ហេ អតិគោតិ យថា ភាសតិ សេនកោតិ ។

ទសណ្ណកជាតកំ ឆដ្ឋំ ។

## សេនកជាតកំ

(៣១៧) វិព្ភន្តចិត្តោ កុបិតិន្ទ្រិយោសិ
នេត្តេហិ តេ វារិគណា សវន្តិ
កិំ តេ នដ្ឋំ កិំ បន បត្ថយានោ
ឥធាគមា ព្រាហ្មណ ឥង្ឃ ព្រូហិ ។

(៣១៨) មិយ្យេថ ភរិយា វជតោ មមជ្ជ
អគច្ឆតោ មរណមាហ យក្ខោ
ឯតេន ទុក្ខេន បវេធិតោស្មិ
អក្ខាហិ មេ សេនក ឯតមត្ថំ ។

(៣១៩) ពហូនិ ឋានានិ វិចិន្តយិត្វា
យមេត្ថ វក្ខាមិ តទេវ សច្ចំ
មញ្ញាមិ តេ ព្រាហ្មណ សត្តុភស្តំ
អជានតោ កណ្ហសប្បោ បវិដ្ឋោ ។



(៣១៦) (ព្រះរាជាសរសើរពោធិសត្វ ហើយពោលគាថាទីបំផុតថា) អាយុរបណ្ឌិត បានឆ្លើយប្រស្នារួចហើយ ចំណែកបុក្កុសបុរសក៏ដូចគ្នា សេនកបណ្ឌិត និយាយដោះស្រាយប្រស្នាទាំងអស់តាមសមគួរ ។

ចប់ ទសណ្ណកជាតក ទី ៦ ។

## សេនកជាតក

(៣១៧) (សេនកបណ្ឌិតពោធិសត្វ ពោលថា) អ្នកមានចិត្តក្រេ-ឡុក មានឥន្ទ្រិយកម្រើក ទំណក់ទឹកហូរចេញអំពីភ្នែករបស់អ្នក ម្នាលព្រាហ្មណ៍ អ្នកបាត់របស់អ្វី ឬក៏ អ្នកប្រាថ្នាចង់បានរបស់អ្វី បានជាមក ក្នុងទីនេះ ចូរអ្នកប្រាប់មកមើល ។

(៣១៨) (ព្រាហ្មណ៍ ពោលថា) យក្សពោលថា កាលបើខ្ញុំទៅដល់ (ផ្ទះ) ក្នុងថ្ងៃនេះ ប្រពន្ធ (របស់ខ្ញុំ) នឹងស្លាប់ កាលបើខ្ញុំទៅមិនដល់ (ផ្ទះ) ទេ ខ្ញុំនឹងស្លាប់ ដោយសេចក្តីទុក្ខនេះ បានជាខ្ញុំខ្វល់ចិត្ត បពិត្រសេនកៈ សូមលោកប្រាប់សេចក្តីនេះដល់ខ្ញុំ ។

(៣១៩) (ពោធិសត្វ ពោលថា) យើងរិះគិតនូវហេតុច្រើនយ៉ាង បណ្តាហេតុទាំងនោះ យើងនឹងប្រាប់ហេតុណាមួយ ហេតុនោះឯង ជារបស់ពិត ម្នាលព្រាហ្មណ៍ យើងយល់ថា អ្នកមិនបានដឹងទេ ពស់វែក លួចចូលក្នុងថង់សម្ល ។

(៣១៦) អាទាយ ទណ្ឌំ បរិសុម្ភ ភស្តំ
បស្សេលមូគំ ឧរគំ ទុជិវ្ហំ
ឆិន្ទជ្ជ កង្ខំ វិចិកិច្ឆិតានិ
ភុជង្គមំ បស្ស បមុញ្ច ភស្តំ ។

(៣១៧) សំវិគ្គរូបោ បរិសាយ មជ្ឈេ
សោ ព្រាហ្មណោ សត្តុភស្តំ បមុញ្ចិ
អថ និគ្គមិ ឧរគោ ឧគ្គតេជោ
អាសីវិសោ សប្បោ ផណំ ករិត្វា ។

(៣១៨) សុលទ្ធលាភា ជនកស្ស រញ្ញោ
យោ បស្សតិ សេនកំ សាធុបញ្ញំ
វិវដ្ដច្ឆទោ នុសិ សព្វទស្សី
ញាណំ នុ តេ ព្រាហ្មណ ភឹសរូបំ
ឥមានិ មេ សត្តសតានិ អត្ថិ
គណ្ហាហិ សព្វានិ ទទាមិ តុយ្ហំ
តយា ហិ មេ ជីវិតមជ្ជ លទ្ធំ
អថោបិ ភរិយាយ មកាសិ សោត្ថឹ ។



(៣១៦) (ពោធិសត្វ ពោលថា) អ្នកចូរយកដំបង គោះថង់មើល អ្នកចូរមើលពស់ ដែលមានអណ្តាតពីរ ហៀរទឹកមាត់ ចេញមក អ្នកចូរកាត់បង់នូវសេចក្តីសង្ស័យផង នូវសេចក្តីងឿងឆ្ងល់ផង ក្នុងថ្ងៃនេះ អ្នកចូរមើលពស់ អ្នកចូរទំលាក់ថង់ចោលទៅ ។

(៣១៧) (ព្រះសាស្តាទ្រង់ត្រាស់ថា) ព្រាហ្មណ៍នោះមានសេចក្តីតក់ស្លុត ក្នុងកណ្តាលបរិស័ទ ហើយក៏ដោះថង់នៃសត្តុចោល ទើបពស់ជាសត្វមានពិស លូនទៅដោយទ្រូង មានតេជះក្លា ក៏បើកពពារលូនចេញមក ។

(៣១៨) (ព្រាហ្មណ៍ ពោលថា) ព្រះរាជាជនកៈអង្គណា បានជួបនឹងសេនកបណ្ឌិត អ្នកមានប្រាជ្ញាឆើត ព្រះរាជាជនកៈ (អង្គនោះ) ឈ្មោះថា មានលាភបានហើយ ដោយប្រពៃ (ព្រាហ្មណ៍លុះសរសើរព្រះរាជាហើយ ក៏សរសើរពោធិសត្វថា) បពិត្រព្រាហ្មណ៍ អ្នកមានធម៌កំបាំង (ញេយ្យធម៌) បើកហើយ ជាអ្នកឃើញនូវធម៌ទាំងអស់ឬ បានជាញាណរបស់អ្នក គួរស្ញប់ស្ញែងម៉្លេះ ខ្ញុំមានកហាបណៈប្រាំពីររយនេះ សូមអ្នកយកទាំងអស់ចុះ ខ្ញុំជូនអ្នក ដ្បិតខ្ញុំបានជីវិត ក្នុងថ្ងៃនេះ ដោយសារអ្នក មិនតែប៉ុណ្ណោះសោត ថែមទាំងអ្នកបានធ្វើសួស្តី ដល់ភរិយា (របស់ខ្ញុំ) ទៀតផង ។

(៣១៩) ន បណ្ឌិតា វេតនមាទិយន្តិ
ចិត្រាហិ គាថាហិ សុភាសិតាហិ
ឥតោបិ តេ ព្រាហ្មណា ទេន្តុ វិត្តំ
អាទាយ ត្វំ គច្ឆ សកំ និកេតន្តិ ។

(១)
សេនកជាតកំ សត្តមំ ។

## អដ្ឋិសេនជាតកំ

(៣២០) យេ មេ អហំ ន ជានាមិ អដ្ឋិសេន វនិព្វកេ
តេ មំ សង្គម្ម យាចន្តិ កស្មា មំ ត្វំ ន យាចសិ ។

(៣២១) យាចកោ អប្បិយោ ហោតិ យាចំ អទទមប្បិយោ
តស្មាហំ តំ ន យាចាមិ មា មេ វិទ្ទេស្សនា អហុ ។

(៣២២) យោ វេ យាចនជីវានោ[២] កាលេ យាចំ ន យាចតិ
បរញ្ច បុញ្ញំ ធំសេតិ អត្តនាបិ ន ជីវតិ ។

---

១ ឱ. ម. សត្តុភស្តជាតកំ ។ ២ ម. យាចនជីវិនោ ។



(៣១៩) (សេនកពោធិសត្វ ពោលថា) បណ្ឌិតទាំងឡាយ មិនបានទទួលយករង្វាន់ដោយពោលគាថាទាំងឡាយ ដ៏វិចិត្រទេ ម្នាលព្រាហ្មណ៍ (ជនទាំងឡាយ) ឲ្យទ្រព្យអំពីបាទមូល របស់យើងនេះ ដល់អ្នក អ្នកចូរយក ហើយចូរទៅកាន់លំនៅ របស់ខ្លួនចុះ ។

ចប់ សេនកជាតក ទី ៧ ។

## អដ្ឋិសេនជាតក

(៣២០) (ព្រះបាទពារាណសី សួរពោធិសត្វថា) បពិត្រតាបស ព្រះនាមអដ្ឋិសេនៈ ខ្ញុំមិនដែលស្គាល់ពួកស្មូមណា ពួកស្មូមនោះ ប្រជុំគ្នាមករកខ្ញុំ ហើយសូម(នូវវត្ថុដែលខ្លួនត្រូវការ)ហេតុអ្វីក៏លោកមិនសូមខ្ញុំ ។

(៣២១) (តាបសពោធិសត្វ ពោលថា) បុគ្គលអ្នកសូម រមែងមិនជាទីស្រឡាញ់ (នៃអ្នកឲ្យ) បុគ្គលអ្នកមិនឲ្យនូវរបស់ដែលគេសូម រមែងមិនជាទីស្រឡាញ់ (នៃស្មូម) ព្រោះហេតុនោះ បានជាអាត្មាមិនសូមមហាបពិត្រ កុំឲ្យមហាបពិត្រ ស្អប់អាត្មាឡើយ ។

(៣២២) (ព្រះរាជាត្រាស់ថា) សមណព្រាហ្មណ៍ណារស់នៅដោយការសូម តែមិនសូមវត្ថុដែលខ្លួនត្រូវសូម ក្នុងកាលគួរ (សមណព្រាហ្មណ៍នោះ) ឈ្មោះថា ញ៉ាំងបុគ្គលដទៃ ឲ្យខូចបុណ្យផង ឈ្មោះថា មិនបានរស់ស្រួល ដោយខ្លួនឯងផង ។

(៣៦៣) យោ ច យាចនជីវានោ កាលេ យាចំ ន យាចតិ
បរញ្ច បុញ្ញំ លភេតិ អត្តនាបិ ន ជីវតិ ។

(៣៦៤) ន វេ ទុស្សន្តិ សប្បញ្ញា ទិស្វា យាចកមាគតេ
ព្រហ្មចារី បិយោ មេសិ វទ[១] ភញ្ញមិច្ឆសិ ។

(៣៦៥) ន វេ យាចន្តិ សប្បញ្ញា ធីរោ ច វេទិតុមរហតិ
ឧទ្ទិស្ស អរិយា តិដ្ឋន្តិ ឯសា អរិយាន យាចនា ។

(៣៦៦) ទទាមិ តេ ព្រាហ្មណ រោហិណីនំ
គវំ សហស្សំ សហ បុង្គវេន
អរិយោ ហិ អរិយស្ស កថំ ន ទជ្ជា
សុត្វាន គាថា តវ ធម្មយុត្តា ។

អដ្ឋិសេនជាតកំ និដ្ឋិតំ ។

[១] ម. វទ ត្វំ ភញ្ញមិច្ឆសិ ។



(៣៦៣) សមណព្រាហ្មណ៍ណា រស់នៅដោយការសូម ហើយសូមនូវវត្ថុដែលខ្លួនត្រូវការសូម ក្នុងកាលគួរ (សមណព្រាហ្មណ៍នោះ) ឈ្មោះថា ញុំាងបុគ្គលដទៃឲ្យបានបុណ្យផង ឈ្មោះថា រស់នៅស្រួល ដោយខ្លួនឯងផង ។

(៣៦៤) បុគ្គលមានប្រាជ្ញាទាំងឡាយ ឃើញពួកស្មូម មកដល់ហើយ មិនដែលប្រទូស្ត លោកជាព្រហ្មចារីបុគ្គល ជាទីស្រឡាញ់នៃខ្ញុំ លោកប្រាថ្នារបស់ណា ដែលត្រូវនិយាយសូម លោកចូរសូមចុះ ។

(៣៦៥) (ពោធិសត្វពោលថា) បុគ្គលមានប្រាជ្ញាទាំងឡាយ មិនដែលសូមទេ ស្រេចតែខ្លួន (ឧបដ្ឋាក) អ្នកមានប្រាជ្ញា គួរដឹងខ្លួនឯងចុះ ពួកអរិយៈ គ្រាន់តែឈរទ្រឹងសំងៀម ។ ប៉ុណ្ណោះ នុះជាការសូម របស់ពួកអរិយៈ ។

(៣៦៦) (ព្រះរាជាពោលថា) បពិត្រព្រាហ្មណ៍ ខ្ញុំសូមប្រគេននូវគោមានសម្បុរក្រហម ១ ពាន់ ព្រមទាំងគោឈ្មោលដល់លោកម្ចាស់ ដ្បិតថា បុគ្គលមានអរិយធម៌ប្រសើរ បានស្តាប់គាថារបស់លោក ដែលប្រកបដោយធម៌ហើយ មិនឲ្យដល់បុគ្គល មានអាចារៈដ៏ប្រសើរ (ដូចគ្នា) ដូចម្តេចបាន ។

ចប់ អដ្ឋិសេនជាតក ទី ៨ ។

# កបិជាតកំ

(៣២៧) យត្ថ វេរី និវិសតិ ន វសេ តត្ថ បណ្ឌិតោ
ឯករត្តិំ ទិរត្តិំ វា ទុក្ខំ វសតិ វេរិសុ ។
(៣២៨) ទិសោ វេ លហុចិត្តស្ស បោសស្សានុវិធិយតោ
ឯកស្ស កបិនោ ហេតុ យូថស្ស អនយោ កតោ ។
(៣២៩) ពាលោ ច បណ្ឌិតមានី យូថស្ស បរិហារកោ
សចិត្តស្ស វសំ គន្ត្វា សយេថាយំ យថា កបិ ។
(៣៣០) ន សាធុ ពលវា ពាលោ យូថស្ស បរិហារកោ
អហិតោ ភវតិ ញាតីនំ សកុណានំវ ចេតកោ ។
(៣៣១) ធីរោ ច ពលវា សាធុ យូថស្ស បរិហារកោ
ហិតោ ភវតិ ញាតីនំ តិទសានំវ វាសវោ ។



# កបិជាតក

(៣២៧) (ពោធិសត្វ ពោលថា) បុគ្គលមានពៀរ អាស្រ័យនៅក្នុងទីណា បណ្ឌិតមិនគប្បីនៅក្នុងទីនោះទេ (ព្រោះ) នៅក្នុងពួកបុគ្គលមានពៀរ មួយយប់ក្តី ពីរយប់ក្តី ជាទុក្ខ ។

(៣២៨) បុគ្គលអ្នកមានចិត្តស្រាល គប្បីជាសត្រូវដល់សត្វអ្នកប្រព្រឹត្តតាម សេចក្តីមិនចំរើន ដែលព្រាហ្មណ៍ធ្វើហើយ ដល់ហ្វូងស្វា ព្រោះហេតុតែស្វាមួយ ។

(៣២៩) បុគ្គលល្ងង់ តែប្រកាន់ខ្លួនឯងថាជាបណ្ឌិត ហើយរក្សាពួកក្រុម ជាអ្នកលុះអំណាចចិត្តរបស់ខ្លួន រមែងដេក (ស្លាប់) ដូចស្វានេះឯង ។

(៣៣០) បុគ្គលល្ងង់មានកំឡាំង ជាអ្នករក្សាពួកក្រុម មិនប្រពៃទេ មិនមានសេចក្តីចំរើន ដល់ពួកញាតិ ដូចទាឈ្នាក់ មិនជាប្រយោជន៍ដល់ពួកសត្វស្លាប (ដែលជាញាតិ) ។

(៣៣១) ឯបុគ្គលមានប្រាជ្ញា មានកំឡាំង រក្សាពួកក្រុមវិញ ទើបប្រពៃ រមែងចំរើនដល់ពួកញាតិ ដូចជាក៏សក្កៈទេវរាជ (ជាប្រយោជន៍) ដល់ពួកទេវតា ក្នុងឋានត្រៃត្រឹង្ស ។

[៣៣២] យោ ច សីលញ្ច បញ្ញញ្ច សុតញ្ចត្តនិ បស្សតិ
ឧភិន្នមត្ថំ ចរតិ អត្តនោ ច បរស្ស ច ។
តស្មា តុលេយ្យមត្តានំ សីលំ បញ្ញំ សុតំបិវ
គណំ វា បរិហរេ ធីរោ ឯកោ វាបិ បរិព្វជេតិ ។

កុក្កុវគ្គោ បឋមោ ។

## ពកព្រហ្មជាតកំ

[៣៣៣] ទ្វាសត្តតិ គោតម បុញ្ញកម្មា
វសវត្តិនោ ជាតិជរំ អតីតា
អយមន្តិមា វេទគូ ព្រហ្មុបបត្តិ
អស្មាភិជប្បន្តិ ជនា អនេកា ។

[៣៣៤] អប្បញ្ហិ ឯតំ ន ហិ ទីឃមាយុ
យំ ត្វំ ពក មញ្ញសិ ទីឃមាយុំ
សតំ សហស្សានំ និរព្វុទានំ
អាយុំ បជានាមិ តវាហំ ព្រហ្មេ ។



[៣៣២] បុគ្គលណាមួយ ឃើញថា ខ្លួនឯងមានសីលផង មានបញ្ញាផង មានសុតៈផង (បុគ្គលនោះ) តែងប្រព្រឹត្តប្រយោជន៍ ដើម្បីខ្លួន និងអ្នកដទៃទាំងពីរ ។ ព្រោះហេតុនោះ អ្នកប្រាជ្ញ កាលបើគេ គាប់មើលខ្លួន មានសីល មានបញ្ញា និងសុតៈហើយ គប្បីថែរក្សាពួកក្រុមក៏បាន គប្បីប្រព្រឹត្តទៅតែម្នាក់ឯង ក៏បាន ។

ចប់ កុក្កុវគ្គ ទី ១ ។

## ពកព្រហ្មជាតក

[៣៣៣] (ពកព្រហ្ម ពោលថា) បពិត្រព្រះគោតម ពួកយើង ៧២ រូប មានអំពើជាបុណ្យ ជាអ្នកមានអំណាចប្រព្រឹត្តទៅ កន្លងផុតជាតិនិងជរាបាន នេះជាការកើតខ្ពស់ចុងក្រោយ ជាការកើតដ៏ប្រសើរ មានគុណទីបំផុត (របស់ពួកយើង) ពួកជនច្រើនរូប តែងប្រាថ្នាទីនេះ ។

[៣៣៤] (ព្រះសាស្តាត្រាស់ថា) នែពកៈ អ្នកសំគាល់ថា អាយុណា ជាអាយុវែង អាយុនុ៎ះ ខ្លីទេ មិនមែនវែងទេឡើយ ម្នាលព្រហ្ម តថាគតដឹងនូវអាយុរបស់អ្នក មួយសែននិរព្វុទៈ (ប៉ុណ្ណោះឯង) ។

(៣៣៥) អនន្តទស្សី ភគវាហមស្មិ
ជាតិជ្ជរំ សោកមុបាតិវត្តោ
កឹ មេ បុរាណំ វតសីលវត្តំ
អាចិក្ខ មេតំ យមហំ វិជញ្ញំ ។

(៣៣៦) យំ ត្វំ អបាយេសិ ពហូ មនុស្សេ
បិបាសិតេ ឃម្មនិសម្បរេតេ
តន្តេ បុរាណំ វតសីលវត្តំ
សុត្តប្បពុទ្ធោវ អនុស្សរាមិ ។

(៣៣៧) យំ ឯណិកូលស្មឹ ជនំ[១] គហីតំ
អមោចយី គយ្ហក នីយមានំ
តន្តេ បុរាណំ វតសីលវត្តំ
សុត្តប្បពុទ្ធោវ អនុស្សរាមិ ។

---

១ ម. ឯណិកុលស្មិ ជនំ ។



(៣៣៥) (ពកព្រហ្មថា) បពិត្រព្រះមានព្រះភាគ ព្រះអង្គមានព្រះបន្ទូលថា តថាគតជាអ្នកឃើញមិនមានទីបំផុត កន្លងផុតស្រឡះនូវជាតិនិងជរាផង នូវសេចក្តីសោកផង តើកិរិយាសីលវត្តរបស់ខ្ញុំពីដើម ដូចម្តេចខ្លះ សូមព្រះអង្គប្រាប់នូវកិរិយាសីលវត្ត ដែលខ្ញុំគួរដឹងនោះ ដល់ខ្ញុំ ។

(៣៣៦) (ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា) អ្នកបានញុំាងពួកមនុស្សច្រើន ដែលស្រេកទឹក លំបាកដោយកំដៅថ្ងៃឲ្យផឹកហើយ នោះឯង ជាវតសមាទាន នឹងសីលវត្តរបស់អ្នកពីដើម តថាគតរឭកឃើញ ដូចជាបុគ្គលដេកលក់ ហើយភ្ញាក់ឡើង ។

(៣៣៧) អ្នកបានដោះលែងនូវពួកជនឈ្លើយ ដែលគេចាប់នាំយកទៅទៀបច្រាំងស្ទឹងឈ្មោះ ឯណី នោះឯង ជាវតសមាទាន នឹងសីលវត្តរបស់អ្នកពីដើម តថាគតរឭកឃើញ ដូចជាបុគ្គលដេកលក់ ហើយភ្ញាក់ឡើង ។

(៣៣៨) គង្គាយ សោតស្មឹ គហីតនាវំ
លុទ្ទេន នាគេន មនុស្សកប្បា
អមោចយិ ត្វំ(១) ពលសា បសយ្ហ
តន្តេ បុរាណំ វតសីលវត្តំ
សុត្តប្បពុទ្ធោវ អនុស្សរាមិ ។

(៣៣៩) កប្បោ ច តេ ពទ្ធចរោ អហោសិ
សម្ពុទ្ធិវន្តំ វតឹ តំ អមញ្ញិ
តន្តេ បុរាណំ វតសីលវត្តំ
សុត្តប្បពុទ្ធោវ អនុស្សរាមិ ។

(៣៤០) អទ្ធា បជានាសិ មមេតមាយុំ
អញ្ញម្បិ ជានាសិ តថា ហិ ពុទ្ធោ
តថា ហិ តាយំ ជលិតានុភាវោ
ឱភាសយំ តិដ្ឋតិ ព្រហ្មលោកន្តិ ។

ពកព្រហ្មជាតកំ ទសមំ ។

ពុទ្ធវគ្គោ បឋមោ ។

---

១ ម. អមោចយិត្ថ ។



(៣៣៨) អ្នកបានគំរាមដោយកំឡាំងហើយដោះលែង នូវទូកដែលនាគកាចកាក្រក់ ចាប់នឹងគិតទំលោល ក្នុងខ្សែទឹកស្ទឹង ព្រោះតែចង់ធ្វើមនុស្សឲ្យវិនាស នោះឯង ជាវតសមាទាននិងសីលវត្តរបស់អ្នកពីដើម តថាគតរឭកឃើញ ដូចជាបុគ្គលដេកលក់ហើយភ្ញាក់ឡើង ។

(៣៣៩) តថាគតឈ្មោះកប្បៈ ធ្លាប់ជាកូនសិស្សរបស់អ្នក តថាគតបានសំគាល់ថា អ្នកជាបុគ្គលមានប្រាជ្ញា មានវតប្រតិបត្តិ នោះឯង ជាវតសមាទាននិងសីលវត្ត របស់អ្នកពីដើម តថាគតរឭកឃើញ ដូចជាបុគ្គលដេកលក់ ហើយភ្ញាក់ឡើង ។

(៣៤០) (ពកព្រហ្ម ពោលថា) ព្រះអង្គទ្រង់ជ្រាបច្បាស់នូវអាយុរបស់ខ្ញុំនុះ ដោយពិតមែន ទ្រង់ជ្រាបច្បាស់នូវហេតុដទៃផង ព្រះអង្គជាព្រះពុទ្ធមែន នេះជាអានុភាពដ៏រុងរឿងរបស់ព្រះអង្គ ដែលញុំាងព្រហ្មលោកឲ្យភ្លឺរុងរឿង ។

ចប់ ពកព្រហ្មជាតក ទី ១០ ។

ចប់ ពុទ្ធវគ្គ ទី ១ ។

## តស្សុទ្ទានំ

វរកណ្ណិក ចាបវរោ សុតនោ
អថ គិជ្ឈ សរោហិតមច្ឆវរោ
បុន ទសណ្ណក សេនក យាចនកោ
អថ វេរី សព្រហ្មពកេន ទស ។

---





## ឧទ្ទាននៃជាតក ក្នុងវគ្គនោះគឺ

និយាយអំពីកំពូលដ៏ប្រសើរ ១ បំពង់ព្រួញដ៏ប្រសើរ ១ សុតនជាតក ១ ត្មាត ១ ត្រីឆ្ពិន ១ ដាវកើតក្នុងស្រុកទសណ្ណកៈ ១ សេនកបណ្ឌិត ១ យាចក ១ បុគ្គលមានពៀរ ១ ពកព្រហ្ម ១ រួមត្រូវជា ១០ ។

---

# គន្ធារវគ្គោ

## គន្ធារជាតកំ

(៣៦១) ហិត្វា គាមសហស្សានិ បរិបុណ្ណានិ សោឡស
កោដ្ឋាគារានិ ផីតានិ សន្និធិំ ទានិ កុព្វសិ ។

(៣៦២) ហិត្វា គន្ធារវិសយំ បហូតធនធានិយំ
បសាសនតោ និក្ខន្តោ ឥធ ទានិ បសាសសិ ។

(៣៦៣) ធម្មំ ភណាមិ វេទេហ អធម្មោ មេ ន រុច្ចតិ
ធម្មំ មេ ភណមានស្ស ន បាបមុបលិម្បតិ ។

(៣៦៤) យេន កេនចិ វណ្ណេន បរោ លភតិ រុប្បនំ
មហត្ថិយម្បិ ចេ វាចំ ន តំ ភាសេយ្យ បណ្ឌិតោ ។

(៣៦៥) កាមំ រុប្បតុ វា មា វា ភុសំ វ វិកិរីយតុ
ធម្មំ មេ ភណមានស្ស ន បាបមុបលិម្បតិ ។

# គន្ធារវគ្គ

## គន្ធារជាតក

(៣៦១) (តាបសពោធិសត្វ ពោលថា) អ្នកលះបង់នូវស្រុកចំណុះ ១ ពាន់ នឹងឃ្លាំង ១៦ ដ៏ពេញបរិបូណ៌ (ដោយទ្រព្យ) ធ្វើនូវការសន្សំក្នុងកាលឥឡូវនេះ ។

(៣៦២) (វិទេហតាបស ពោលថា) អ្នកលះបង់នូវដែនគន្ធារៈ ដែលជាដែនសម្បូណ៌ ដោយទ្រព្យនឹងធឹក ហើយចេញផុតអំពីទីជាទីឲ្យនូវពាក្យប្រៀនប្រដៅ (ដូចខ្ញុំដែរ) ឥឡូវនេះ (ហេតុអ្វីក៏មក) ប្រៀនប្រដៅ (យើង) ក្នុងទីព្រៃនេះ ។

(៣៦៣) (ពោធិសត្វ ពោលថា) ម្នាលវិទេហៈ ខ្ញុំនិយាយចំពោះតែធម៌ សភាវៈមិនមែនជាធម៌ មិនគាប់ចិត្តខ្ញុំទេ កាលបើខ្ញុំនិយាយធម៌ បាបឥតប្រឡាក់បានទេ ។

(៣៦៤) (វិទេហតាបស ពោលថា) បុគ្គលដទៃបាននូវសេចក្ដីក្រោធ ព្រោះពាក្យណាមួយ បណ្ឌិត មិនគប្បីពោលនូវពាក្យនោះឡើយ បើទុកជាពាក្យមានប្រយោជន៍ដ៏ធំក៏ដោយ ។

(៣៦៥) (ពោធិសត្វ ពោលថា) បុគ្គលនោះខឹងក៏ដោយ មិនខឹងក៏ដោយ ទោះរាយកាយដូចអង្កាមក៏ដោយ កាលបើខ្ញុំនិយាយធម៌ បាបមិនប្រឡាក់បានទេ ។

(៣៤៦)នោ ចេ អស្ស សកា ពុទ្ធិ វិនយោ វា សុសិក្ខិតោ
វនេ អន្ធមហឹសោវ ចរេយ្យ ពហុកោ ជនោ ។
(៣៤៧)យស្មា ច បនិធេកច្ចេ អាចារម្ហិ សុសិក្ខិតា
តស្មា វិនីតវិនយា (ធីរា) ចរន្តិ សុសមាហិតា ។

ឧត្តរជាតកំ បឋមំ ។

## មហាកបិជាតកំ

(៣៤៨)អត្តានំ សង្កមំ កត្វា យោ សោត្ថឹ សមតារយិ
កឹ ត្វំ តេសំ កឹមេ តុយ្ហំ ហោន្តិ ហេតេ មហាកបិ ។
(៣៤៩) រាជាហំ ឥស្សរោ តេសំ យូថស្ស បរិហារកោ
តេសំ សោកបរេតានំ ភីតានន្តេ អរិន្ទម ។



(៣៤៦) ប្រសិនបើប្រាជ្ញារបស់ខ្លួនក្តី វិន័យដែលសិក្សាល្អក្តី មិនមានទេ ជនច្រើនគ្នានឹងប្រព្រឹត្ត ដូចជាក្របីខ្វាក់ ក្នុងព្រៃ ។

(៣៤៧) មួយទៀត ជនពួកខ្លះ ក្នុងលោកនេះ បានសិក្សាល្អ ក្នុងអាចារប្បញ្ញត្តិ ព្រោះហេតុនោះ (ធីរជន) អ្នកមានវិន័យទូន្មាន ហើយ រមែងមានចិត្តតាំងមាំល្អ ។

ចប់ ឧត្តរជាតក ទី ១ ។

## មហាកបិជាតក

(៣៤៨) (ព្រះរាជាពារាណសី ត្រាស់សួរថា) ម្នាលស្វាដ៏ប្រសើរ អ្នកបានធ្វើខ្លួនឲ្យជាស្ពាន ហើយចម្លង (ពួកស្វាទាំងនេះ) ឲ្យឆ្លងទៅដល់ទីសួស្តី តើអ្នកត្រូវជាអ្វីនឹងពួកស្វាទាំងនោះ ឯស្វាទាំងនោះ ត្រូវជាអ្វីនឹងអ្នក ។

(៣៤៩) (ស្តេចស្វាពោធិសត្វ ទូលតបថា) បពិត្រព្រះបាទអរិន្ទមៈ (អ្នកបង្ក្រាបសត្រូវ) ខ្ញុំជាស្តេច ជាឥស្សរៈ លើស្វាទាំងនោះ ជាអ្នកគ្រប់គ្រងហ្វូងស្វាទាំងនោះ ដែលត្រូវសេចក្តីសោក គ្របសង្កត់ ជាអ្នកខ្លាចព្រះអង្គ ។

(៣៨០) ឧល្លង្ឃយិត្វា(១) អត្តានំ វិស្សដ្ឋធនុនោ សតំ
តតោ អបរបាទេសុ ទឡ្ហំ ពន្ធំ លតាគុណំ ។

(៣៨១) ឆិន្នព្ភមិវ វាតេន នុណ្ណោ រុក្ខមុបាគមឹ
សោហំ អប្បភវំ តត្ថ សាខំ ហត្ថេហិ អគ្គហឹ ។

(៣៨២) តំ មំ វិយាយតំ សន្តំ សាខាយ ច លតាយ ច
សមនុក្កមន្តា បាទេហិ សោត្ថិ សាខាមិគា គតា ។

(៣៨៣) តំ មំ ន តបតី ពន្ធោ វធោ(២) មេ ន តបេស្សតិ
សុខមាហរិតំ តេសំ យេសំ រជ្ជមការយឹ ។

(៣៨៤) ឯសា តេ ឧបមា រាជ តំ សុណោហិ អរិន្ទម
រញ្ញា រដ្ឋស្ស យោគ្គស្ស ពលស្ស និគមស្ស ច
សព្វេសំ សុខមេដ្ឋព្វំ ខត្តិយេន បជានតា ។

មហាកបិជាតកំ ទុតិយំ ។

---

១ ឱ. សលង្ឃយិត្វា ។ ម. សុលង្ឃយិតា ។ ២ ម. មតោ ។



(៣៨០) ខ្ញុំលោតខ្លួនអំពីឈើនេះ ទៅកាន់ទីប្រមាណ ១ រយធ្នូ ដែលគេលើកឡើង ហើយចងវល្លិផ្ដៅ ជាប់ត្រង់សរីរៈ ជាខាងក្រោយនៃជើង (ចង្កេះ) ។

(៣៨១) ខ្ញុំលោតទៅកាន់ដើមឈើ ដោយខ្យល់ ដូចជាពពកដែលខ្យល់ផាត់ហើយ ខ្ញុំនោះទៅមិនដល់ ក៏លូកដៃទៅចាប់មែក (នៃឈើ) ព្រឹក្សប្បទេសនោះ ។

(៣៨២) ពួកស្វាលើកជើងជាន់លើខ្ញុំនោះ ដែលដេកសន្ធឹងដូចខ្សែពាប់ ដោយមែកឈើផង ដោយវល្លិផ្ដៅផង ហើយនាំគ្នាទៅដោយសួស្ដី ។

(៣៨៣) ខ្ញុំនោះមិនក្ដៅក្រហាយនឹងការចង ខ្ញុំនឹងមិនក្ដៅក្រហាយនឹងការស្លាប់ឡើយ (ព្រោះ) ខ្ញុំសោយរាជ្យ (ត្រួតត្រា) លើពួកស្វាណា សេចក្ដីសុខ ខ្ញុំបាននាំមកឲ្យពួកស្វានោះហើយ ។

(៣៨៤) បពិត្រព្រះបាទអរិន្ទមៈ នេះជាសេចក្ដីប្រៀបធៀប ចំពោះព្រះអង្គ សូមព្រះអង្គស្ដាប់នូវឧបមានោះ ខត្តិយរាជមានប្រាជ្ញា គួរផ្ដល់សេចក្ដីសុខ ដល់ពួកជនទាំងអស់ គឺអ្នកដែនផង យាន (វាហនៈ សម្រាប់ទឹម) ផង ពលទ័ពជើងផង អ្នកនិគមផង ។

ចប់ មហាកបិជាតក ទី ២ ។

# កុម្ភការជាតកំ

[៣៨៤] អម្ពាហមទ្ទំ វនមន្តរស្មឹ
នីលោភាសំ ផលិតំ សំវិរូឡ្ហំ
តមទ្ទសំ ផលហេតុ វិភគ្គំ
តំ ទិស្វា ភិក្ខាចរិយំ ចរាមិ ។

[៣៨៥] សេលំ សុមដ្ឋំ នរវីរនិដ្ឋិតំ
នារី យុគំ ធារយិ អប្បសទ្ទំ
ទុតិយញ្ច អាគម្ម អហោសិ សទ្ទោ
តំ ទិស្វា ភិក្ខាចរិយំ ចរាមិ ។

[៣៨៦] ទិជា ទិជំ កុណបមាហរន្តំ
ឯកំ សមានំ ពហុកា សមេច្ច
អាហារហេតុ បរិបាតយឹសុ
តំ ទិស្វា ភិក្ខាចរិយំ ចរាមិ ។



# កុម្ភការជាតក

[៣៨៤] (ព្រះបច្ចេកពុទ្ធ ៤ អង្គ ពោលគាថាមួយ ១ ជា) អាត្មាភាពឃើញដើមស្វាយ ដុះលូតលាស់ ក្នុងកណ្តាលព្រៃ ស្វាយមានពណ៌ខៀវ មានផ្លែ អាត្មាឃើញស្វាយនោះ បាក់ខ្ទេចខ្ទី ព្រោះហេតុតែផ្លែ លុះឃើញស្វាយនោះហើយ ទើបអាត្មាប្រព្រឹត្តនូវភិក្ខាចារ (ទៅបួស) ។

[៣៨៥] នាងនារី (ម្នាក់) ពាក់កងជាវិការៈនៃកែវមណី ១ គូ ដ៏ស្អាតរលោង ដែលជនអ្នកចេះធ្វើឲ្យស្រេចហើយ ឥតឮសូរសំឡេង (ខ្ទិចគ្នាឡើយ) លុះដល់កាលក្រោយ យកមកពាក់ ជាមួយគ្នានឹងកងទី ២ ក៏ (ខ្ទិចគ្នា) ឮសូរសំឡេង អាត្មាភាពឃើញនូវកងនោះហើយ ទើបប្រព្រឹត្តនូវភិក្ខាចារ ។

[៣៨៦] ពួកបក្សីច្រើនចោមរោម ដេញចឹកបក្សី ១ កំពុងពាំដុំសាច់ ព្រោះហេតុតែអាហារ អាត្មាភាពឃើញបក្សីនោះហើយ ទើបប្រព្រឹត្តនូវភិក្ខាចារ ។

(៣៥៨) ឧសភាហមទ្ទក្ខិំ យូថស្ស មជ្ឈេ
ចលក្កកុំ វណ្ណពលូបបន្នំ
តមទ្ទសំ កាមហេតុ វិតុន្នំ
តំ ទិស្វា ភិក្ខាចរិយំ ចរាមិ ។

(៣៥៩) ករណ្ឌកោ កលិង្គានំ គន្ធារានញ្ច នគ្គជិ
និមិរាជា វិទេហានំ បញ្ចាលានញ្ច ទុម្មុខោ
ឯតេ រដ្ឋានិ ហិត្វាន បព្វជឹសុ អកិញ្ចនា ។

(៣៦០) សព្វេបិមេ ទេវសមា សមាគតា
អគ្គី យថា បជ្ជលិតោ តថេវិមេ
អហំបិ ឯកោ ចរិស្សាមិ ភគ្គវិ
ហិត្វាន កាមានិ យថោធិកានិ ។



(៣៥៨) អាត្មាឃើញគោឧសភ (មួយ) កណ្តាលហ្វូង មានបូកច្រញោង បរិបូណ៌ដោយសម្បុរនិងកំឡាំង អាត្មាបានឃើញគោឧសភនោះ ត្រូវគោឧសភដទៃ ចុះមុត (ធ្លាយពោះវៀន) ព្រោះហេតុតែកាម លុះបានឃើញគោឧសភនោះហើយ ទើបប្រព្រឹត្តភិក្ខាចារ ។

(៣៥៩) (ពោធិសត្វ ពោលថា) ព្រះរាជារបស់អ្នកដែនកលិង្គៈ ព្រះនាម ករណ្ឌកៈ ព្រះរាជារបស់អ្នកដែនគន្ធារៈ ព្រះនាម នគ្គជិ ព្រះរាជារបស់អ្នកដែនវិទេហៈ ព្រះនាម និមិរាជ ព្រះរាជារបស់អ្នកដែនបញ្ចាលៈ ព្រះនាម ទុម្មុខៈ ព្រះរាជាទាំង ៤ ព្រះអង្គនុ៎ះ លះបង់នូវដែនទាំងឡាយ ជាអ្នកឥតកង្វល់ បួសហើយ ។

(៣៦០) ព្រះរាជាទាំងអស់អង្គនេះ ប្រហែលគ្នានឹងវិសុទ្ធិទេវតា បានមកជួបគ្នាហើយ ព្រះរាជាទាំងនេះ (រុងរឿង ដោយគុណទាំងឡាយមានសីលគុណជាដើម) ដូចជាភ្លើង ដែលភ្លឺរុងរឿងដូច្នោះ ឯង ម្នាលនាង ភគ្គវី ចំណែកខាងបង ក៏នឹងលះបង់នូវកាមទាំងឡាយ ជាចំណែកដែលខ្ញុំនឿយណាយហើយ ប្រព្រឹត្តតែម្នាក់ឯង ។

(៣៦១) អយមេវ កាលោ ន ហិ អញ្ញោ អត្ថិ
អនុសាសិតោ(១) មេ ន ករេយ្យ បច្ឆា
អហម្បិ ឯកា ចរិស្សាមិ កត្វា
សកុណីវ មុត្តា បុរិសស្ស ហត្ថា ។

(៣៦២) អាមំ បក្កញ្ច ជានន្តិ អថោ លោណំ អលោណកំ
តមហំ ទិស្វាន បព្វជី ចរេវ ត្វំ ចរាមហន្តិ ។

កុម្ភការជាតកំ តតិយំ ។

## ទឡ្ហធម្មជាតកំ

(៣៦៣) អហញ្ចេ ទឡ្ហធម្មស្ស វហន្តី នាភិរាធយឹ
ធុនន្តី(២) ឧរសិ សល្លំ យុទ្ធេ វិក្កន្តចារិនី ។

(៣៦៤) នូន(៣) រាជា ន ជានាតិ មម វិក្កមបោរិសំ
សង្គាមេ សុកតន្តានិ ទូតវិប្បហិតានិ ច ។

---

១ ម. អនុសាសិតា ។ ឧ. អនុសាសិកា នៅ ។ ២. ម. ធជន្តី ។ ៣. ម. ននោ តួន កថា ជាតកំ ។



(៣៦០) (កុមារីនោះ ពោលថា) កាលនេះ ជាកាលគួរ (នឹងបួស ហើយ) ឥតមានកាលដទៃទៀតឡើយ (ព្រោះ) ដល់ទៅពេលក្រោយ បុគ្គលជាអ្នកប្រៀនប្រដៅខ្ញុំ មិនមានទេ បពិត្រអ្នកមានភក្ត្រ ខ្ញុំនឹងប្រព្រឹត្តតែម្នាក់ឯង ដូចជាមេបក្សីដែលរួច អំពីដៃនៃបុរស ។

(៣៦២) (ព្រះមហាសត្វពោលថា ពួកគេទាំងឡាយនោះ) ស្គាល់បាយឆៅ បាយឆ្អិន ទាំងស្គាល់បាយប្រៃ នឹងបាយសាបហើយ លុះយើងឃើញកិរិយារបស់គេនោះហើយ ទើបបួស នាងចូរប្រព្រឹត្តស្វែងរកនូវកិច្ចការចុះ យើងក៏នឹងប្រព្រឹត្តស្វែងរកនូវកិច្ចការដែរ ។

ចប់ កុម្ភការជាតក ទី ៣ ។

## ទឡ្ហធម្មជាតក

(៣៦៣) (មេដំរីឈ្មោះឧដ្ឋិព្យាធិ បានពោល ទីងសាមាក្យពោលថា) ខ្ញុំកាលនាំទៅ (នូវកិច្ច) របស់ព្រះបាទទឡ្ហធម្មៈ នាំទៅនូវសរ (ដែលគេចង) ត្រង់ទ្រូងហើយត្រាច់ទៅ ក្នុងទីចម្បាំង ដោយសេចក្តីប្រឹងប្រែង ក៏គង់ញុំាងព្រះអង្គ ឲ្យសព្វព្រះរាជហឫទ័យ មិនបាន ។

(៣៦៤) ព្រះរាជា មិនជ្រាបនូវសេចក្តីប្រឹងប្រែងរបស់បុរស ដែលខ្ញុំបានធ្វើដោយពិត ទាំងការនាំសំបុត្រចុះឡើង ក្នុងសង្គ្រាម ក៏ខ្ញុំបានធ្វើល្អហើយ ។

(៣៦៤) សា នូនាហំ មរិស្សាមិ អលទ្ធា អបកាយិនី

គតា[1] ហិ កុម្ភការស្ស ធិង្គា គោណបាវិកា ។

(៣៦៦) យថា តាសីសតី ទោសោ តាវ ណេវ បរីណតិ

អត្ថាទាយេ ជហន្តិ ធំ ខុដ្ជីព្យាធីវ ខត្តិយោ ។

(៣៦៧) យោ បុព្វេ កតកល្យាណោ កតត្ថោ នាវពុជ្ឈតិ

អត្ថា តស្ស បលុជ្ជន្តិ យេ ហោន្តិ អភិបត្ថិតា ។

(៣៦៨) យោ បុព្វេ កតកល្យាណោ កតត្ថោ មនុពុជ្ឈតិ

អត្ថា តស្ស បវឌ្ឍន្តិ យេ ហោន្តិ អភិបត្ថិតា ។

១ គតេហិ គតាហំ ។ អដ្ឋកថា ។



(៣៦៤) ខ្ញុំនោះជាអ្នកឥតពៅកន្សែង ឥតទំពក់នាក់ មុខជានឹងស្លាប់ មិន
បាន ព្រោះគំនិតពេលនោះ ព្រោះជាបានទ្រង់ប្រទានខ្ញុំ ឲ្យជាអ្នក
នាំទូកបាបមាស ដល់ស្ដេចផ្ទាំង ។

(៣៦៦) (ពោធិសត្វ ទូលព្រះរាជា) បុរសក្រោញ (ប្រយោជន៍)
ដែលណា រមែងឥតបរេក (ទឹករេ) ដែលនោះ ជនទាំងឡាយ រមែង
លះបង់ពោលគេ គឺពេលដែលគេសាបសូន្យ ចាកសេចក្ដីចំរើន
ដូចជាក្សត្រ (លះបង់ពោល) នូវរោគដ៏ ឈ្មោះខុជ្ជិព្យាធិ នោះ ។

(៣៦៧) បុគ្គលណា មិនដឹងនូវអំពើល្អ ដែលអ្នកដទៃធ្វើហើយ
និងប្រយោជន៍ ដែលអ្នកដទៃធ្វើហើយ (ដល់ខ្លួន) ក្នុងកាលមុន
ប្រយោជន៍ទាំងឡាយ ដែលបុគ្គលនោះប្រាថ្នា រមែងសាបសូន្យ ។

(៣៦៨) បុគ្គលណាដឹងនូវអំពើល្អ ដែលអ្នកដទៃធ្វើហើយ និងប្រ-
យោជន៍ដែលអ្នកដទៃធ្វើហើយ (ដល់ខ្លួន) ក្នុងកាលមុន ប្រយោជន៍
ទាំងឡាយណា ដែលបុគ្គលនោះប្រាថ្នាហើយ រមែងចំរើន ។

(៣៦៩)តំ ភោ វទាមិ ភទ្ទំ ភោ យាវន្តេត្ថ សមាគតា
សព្វេ កាកត្ថាហតា ហោថ ចិរំ សត្តុម្ហិ វស្សថាតិ ។

ធម្មទ្ធជជាតកំ ចតុត្ថំ ។

## សោមទត្តជាតកំ

(៣៧០)យោ មំ បុរេ បច្ចុឌ្ឌេតិ អរញ្ញេ ទូរមាយតោ
សោ ន ទិស្សតិ មាតង្គោ សោមទត្តោ កុហឹ គតោ ។

(៣៧១)អយំ វ សោ មតោ សេតិ អល្លបិដ្ឋំ(១) វច្ឆិតោ
ភូម្យា និបតិតោ សេតិ អមរា វត កុញ្ជរោ ។

(៣៧២)អនគារិយុបេតស្ស វិប្បមុត្តស្ស តេ សតោ
សមណស្ស ន តំ សាធុ យំ បេតមនុសោចសិ ។

១. អល្លបិដ្ឋំ ? វិច្ឆិតោ ។ ២. អល្លសិង្គំ ? វច្ឆិតោ ។



(៣៦៩) ព្រោះហេតុនោះ ខ្ញុំសូមនិយាយ នឹងអ្នកទាំងឡាយ សូមសេចក្ដីចំរើន (កើតមាន) ដល់អ្នកទាំងឡាយ ដែលបានអញ្ជើញមកជួបជុំ ក្នុងទីនេះ ទាំងអម្បាលមាន អ្នកទាំងអស់គ្នា ចូរជាអ្នកដឹងឧបការៈ ដែលអ្នកដទៃបានធ្វើហើយ (ដល់ខ្លួន) អ្នកទាំងឡាយនឹងបានឋិតនៅ ក្នុងឋានសួគ៌ អស់កាលយូរ ។

ចប់ ធម្មទ្ធជជាតក ទី ៤ ។

## សោមទត្តជាតក

(៣៧០) (តាបសយំទួញរកដំរីថា) កាលពីមុន ដំរីណា មកអំពីចម្ងាយ ទទួលអាត្មាអញក្នុងព្រៃ (សព្វថ្ងៃនេះ) ដំរីឈ្មោះ សោមទត្តនោះ ទៅក្នុងទីណា បានជាបាត់ មិនឃើញមក ។

(៣៧១) (តាបសនោះ ឃើញដំរីនោះដួលស្លាប់ ហើយពោលថា) ដំរីដេកស្លាប់នេះ គឺដំរីនេះឯង ដំរីសោមទត្តដួលដេកលើផែនដី ដូចជាត្រួយព្រៃ ដែលបុគ្គលកាច់ហើយ ដំរី (នោះ) មិនខាន់ស្លាប់ទេហ្ន៎ ។

(៣៧២) (ខណៈនោះ សក្កទេវរាជ ពោលថា) លោកសោកស្ដាយដំរីណា ដែលស្លាប់បាត់ទៅហើយ ការសោកស្ដាយដំរីនោះ មិនសមគួរដល់លោក ដែលចូលមកកាន់ផ្នួស ជាសមណៈ មានចិត្តផុតស្រឡះសោះហើយ ។

(៣៧៣) យំកំ សេ ជហវេ សក្កា    មនុស្សស្ស មិគស្ស វា

ហទយេ ជាយតី បេមំ    ឧតិ សក្កា អសោចិតុំ។

(៣៧៦) មតំ មរិស្សំ រោទន្តិ    យេ រុទន្តិ លបន្តិ ច

តស្មា ត្វំ ឥសិ មារោទិ    រោទិតំ មោឃមាហុ សន្តោ។

(៣៧៨) កន្ទិតេន ហវេ ព្រហ្មេ    មតោ បេតោ សមុដ្ឋហេ

សព្វេ សង្គម្ម រោទាម    អញ្ញមញ្ញស្ស ញាតកេ។



(៣៧៣) (កាមស គោលថា) បពិត្រសក្កៈ សេចក្ដីស្រឡាញ់ រមែង កើតក្នុងហឫទ័យ របស់មនុស្សក្ដី ម្រឹគក្ដី ដោយសារភ្ជាប់នៅ ជាមួយគ្នា ក៏ក្ដីមិនអាច មិនសោកស្ដាយចំពោះបាត់ឡើយ ។

(៣៧៦) (សក្ករោហិណ គោលថា) សត្វទាំងឡាយណា យំខ្សឹករៀប រាប់ សត្វទាំងឡាយនោះ តែងយំគេសត្វដែលស្លាប់បាត់ទៅហើយ ឬក៏ សត្វដែលបម្រុងនឹងស្លាប់ នៃឥសី ព្រោះហេតុនោះ លោកកុំ យំឡើយ ពួកសប្បុរសពោលថា ការយំ ជាធម្មជាតឥតអំពើទេ ។

(៣៧៨) បពិត្រព្រាហ្មណ៍ ប្រសិនបើ បុគ្គលដែលស្លាប់ទៅកាន់បរលោក ហើយ គប្បីរស់ឡើងវិញដោយការយំទួញ ពួកយើងទាំងអស់ គឺគប្បីប្រជុំគ្នាយំគេក្នុងក្រុមញាតិ នៃគ្នានឹងគ្នាដែរ ។

(៣៧៦) អាទិត្តំ វត មំ សន្តំ ឃតសិត្តំវ បាវកំ
វារិនា វិយ ឱសិញ្ចំ សព្វំ និព្វាបយេ ទរំ ។
អព្ពូឡ្ហំ វត មេ សល្លំ យមាសិ ហទយស្សិតំ
យោ មេ សោកបរេតស្ស បុត្តសោកំ អបានុទិ ។
សោហំ អព្ពូឡ្ហសល្លោស្មិ វីតសោកោ អនាវិលោ
ន សោចាមិ ន រោទាមិ តវ សុត្វាន ភាសិតំ ។

សោមទត្តជាតកំ បញ្ចមំ ។

## សុសីមជាតកំ

(៣៧៧) កាឡានិ កេសានិ បុរេ អហេសុំ
ជាតានិ សីសម្ហិ យថា បទេសេ
តានជ្ជ សេតានិ សុសីម ទិស្វា
ធម្មំ ចរ ព្រហ្មចរិយស្ស កាលោ ។



(៣៧៦) (តាបស ពោលថា) អ្នកបានស្រោចខ្ញុំ ដែលត្រូវភ្លើងគឺសេចក្តីសោក កំពុងឆេះសព្វ ឲ្យត្រជាក់ត្រជុំ រំលត់នូវក្តៅក្រហល់ក្រហាយទាំងអស់បាន ដូចជាបុគ្គលយកទឹកស្រោចពន្លត់នូវភ្លើង ដែលកំពុងឆេះនូវខ្លាញ់ទឹកញ៉ ។ អ្នកបានបន្ទោបង់សេចក្តីសោក ព្រោះកូនរបស់ខ្ញុំ ដែលត្រូវសេចក្តីសោក កំពុងគ្របសង្កត់ ឈ្មោះថាបានដកចោលនូវសរ គឺសេចក្តីសោក ដែលអាស្រ័យនៅក្នុងហឫទ័យនៃខ្ញុំបាន ។ បពិត្រកំលោះ ខ្ញុំនោះឈ្មោះថា មានសរដកចោលហើយ ប្រាសចាកសេចក្តីសោកហើយ ឥតមានចិត្តល្អក់ ខ្ញុំលែងសោកស្តាយ លែងយំ ព្រោះបានស្តាប់ (នូវពាក្យរបស់អ្នក) ។

ចប់ សោមទត្តជាតក ទី ៥ ។

## សុសីមជាតក

(៣៧៧) (ព្រះពោធិសត្វ ពោលថា) ម្នាលសុសីមៈ កាលពីដើម សក់ទាំងឡាយខ្មៅ ដុះលើក្បាល ជាប្រទេសដ៏សមគួរ ថ្ងៃនេះ អ្នកឃើញសក់ទាំងនោះសហើយ ចូរប្រព្រឹត្តធម៌ចុះ (ព្រោះកាលនេះ) ជាកាលគួរ ដល់ព្រហ្មចរិយធម៌ហើយ ។

(៣៧៨) មមេវ ទេវ បលិតំ ន តុយ្ហំ
មមេវ សីសំ មម ឧត្តមង្គំ
អត្ថំ ករិស្សន្តិ មុសា អភាណឹ(១)
ឯកាបរាធំ ខម រាជសេដ្ឋ ។

(៣៧៩) ទហរោ តុវំ ទស្សនីយោសិ រាជ
បឋមុគ្គតោ ហោសិ យថា កឡីរោ
រជ្ជញ្ច ការេហិ មមញ្ច បស្ស
មា កាលិកំ អនុធាវិ ជនិន្ទ ។

(៣៨០ បស្សាមិ វោហំ ទហរឹ កុមារឹ
សាមដ្ឋបស្សំ សុតនុំ សុមជ្ឈំ
កាលប្បវាឡាវ(២) បវេល្លមានា
បលោភយន្តីវ(៣) នរេសុ គច្ឆតិ ។

១ ម. អភាសឹ ។ ២ ម. កាលាបវាឡាវ ។ ម. កាលប្បវាឡាវ ។ ៣ ម. សា លោភយន្តីវ ។ ម. បលោភយន្តីវ ។



(៣៧៨) (អគ្គមហេសី ពោលថា) បពិត្រព្រះសម្មតិទេព សក់ស្កូវរបស់ខ្ញុំ មិនមែនរបស់ព្រះអង្គទេ ស្កូវក្បាលរបស់ខ្ញុំ ស្កូវត្បូងរបស់ខ្ញុំទេតើ បពិត្រព្រះរាជសេដ្ឋ ខ្ញុំនិយាយកុហកទេ ដោយបំណងថា កាត្ត អញនឹងធ្វើឲ្យសេចក្តីចំរើន (ដល់ខ្លួន) សូមព្រះអង្គទ្រង់ព្រះមេត្តាប្រោស អភ័យទោសកំហុសម្តង (ដល់ខ្ញុំ) ។

(៣៧៩) បពិត្រព្រះរាជា ព្រះអង្គនៅក្មេងបំផុតនៅ គង់បឋមវ័យនៅឡើយ មុខស្អាតគួរឲ្យគយគន់ ពិតពិលរមិលរមើល ដូចជាទំពាំង (ទើបមានសម្បុរជាំស្និទ្ធ ) សូមទ្រង់សោយរាជ្យផង សូមទ្រង់ទតខ្ញុំព្រះអង្គផង បពិត្រព្រះជនិន្ទៈ សូមព្រះអង្គ កុំស្ទុះទៅតាមកាលិកៈឡើយ (១) ។

(៣៨០) (ពោធិសត្វ ពោលថា) យើងឃើញកុមារីក្រមុំ មានសម្បុរស្បែកដ៏ផូរផង់ ក្នុងកាលចំណាស់ មានដងខ្លួនសមរម្យ ត្រង់ពាក់កណ្តាលខ្លួន សណ្ឋិតដោយល្អ (កុមារីនោះ) ធ្វើដំណើរញ៉ឹក ញ៉ង ដូចជាវល្លិប្រេង មានស៊ីគន្ធ (ដែលទន់ល្មន់) ហើយប្រលោមពួកបុរស ។

១ ការប្រព្រឹត្តិព្រហ្មចរិយៈ ឈ្មោះថា កាលិកៈ ព្រោះអាចឲ្យផលក្នុងអត្តភាពទី ២ ឬ ទី ៣ ។ អដ្ឋកថា ។

(៣៨១) ឥមេន បស្សាមិ បរេន ធាតី
អសីតិកំ នាវុតិកញ្ច ជច្ចា
ទណ្ឌំ គហេត្វាន បវេធមានំ
គោបានសីភគ្គសមំ ចរន្តិ(១) ។

(៣៨២) សោហំ តមេវានុវិចិន្តយន្តោ
ឯកោ សយាមិ សយនស្ស មជ្ឈេ
អហម្បិ ឯវំ ឥតិ បេក្ខមានោ
គេហេ ន រមេ ព្រហ្មចរិយស្ស កាលោ ។

(៣៨៣) រជ្ជុវាលម្ពនី ចេសា យា គេហេ វសតោ រតិ
ឯតំបិ ឆេត្វាន វជន្តិ ធីរា
អនបេក្ខិនោ កាមសុខំ បហាយាតិ ។

សុសីមជាតកំ ឆដ្ឋំ ។

## កោដិសិម្ពលិជាតកំ

(៣៨៤) អហំ ទសសតព្យាមំ ឧរគមាទាយ អាគតោ
តញ្ច មញ្ច មហាកាយំ ធារយំ នប្បវេធសិ ។

---

១ ឱ. ម. គោបានសិ ភោគ្គសមំ ចរន្តិ ។



(៣៨១) លុះដល់សម័យខាងក្រោយមក យើងឃើញមេដោះ កើតបាន ៨០ ឆ្នាំ ឬ ៩០ ឆ្នាំ អំពីកំណើត កាន់ឈើច្រត់ញ័រទទ្រើក ត្រាច់ទៅកោងៗ ដូចជាបង្កង់ផ្ទះ ។

(៣៨២) យើងនោះត្រិះរិះឃើញ នូវសេចក្តីកើតយ៉ាងនោះ របស់រូប នោះដេកម្នាក់ឯង ពាក់កណ្តាលនៃដំណេក ក៏ត្រិះរិះឃើញថា អាត្មាអញ មុខជាយ៉ាងនោះដែរ ដូច្នេះហើយ ក៏លែងត្រេកអរក្នុងផ្ទះ (កាលនេះ) ជាកាលនៃព្រហ្មចរិយៈ ។

(៣៨៣) សេចក្តីត្រេកអរ (ក្នុងកាម) របស់បុគ្គលអ្នកនៅក្នុងផ្ទះនុ៎ះ ដូចជាខ្សែសំរក់ពាន (របស់បុរសដែលមានជម្ងឺ) អ្នកប្រាជ្ញទាំងឡាយ កាត់ផ្តាច់នូវខ្សែនុ៎ះហើយ លែងនឹកនា លះបង់ចោលនូវកាមសុខ ទៅបួស ។

ចប់ សុសីមជាតក ទី ៦ ។

## កោដិសិម្ពលិជាតក

(៣៨៤) (ស្តេចគ្រុឌឃើញដើមរការនោះ កំពុងតែក្រើកញាប់ញ័រ ក៏សួររកហេតុថា) យើងចាប់នាគមានប្រវែង ១ ពាន់ព្យាម យកមក (ក្នុងទីនេះ) អ្នកទ្រទ្រង់នូវនាគនោះផង នូវយើងផង សុទ្ធតែមានកាយធំ មិនកម្រើក ។

(៣៨៥) អជិមំ ខុទ្ទកំ បក្ខឹ អប្បមំសតរំ មយា
ជាយំ ព្យធសិ កិំតោ កិមត្ថំ កោដសិម្ពលិ ។

(៣៨៦) មំសភក្ខោ តុវំ រាជ ផលភក្ខោ អយំ ទិជោ
អយំ និគ្រោធពីជានិ បិលក្ខុទុម្ពរានិ ច
អស្សត្ថានិ ច ភក្ខិត្វា ខន្ធេ មេ ឱហទិស្សតិ ។

(៣៨៧) តេ រុក្ខា សំវិរូហន្តិ មម បស្សេ និវាតជា
តេ មំ បរិយោនទ្ធិស្សន្តិ អរុក្ខំ មំ ករិស្សរេ ។

(៣៨៨) សន្តិ អញ្ញេបិ រុក្ខាសេ មូលិនោ ខន្ធិនោ ទុមា
ឥមិនា សកុណជាតេន ពីជមាហរិត្វា ហតា ។

(៣៨៩) អជ្ឈារូហាភិវឌ្ឍន្តិ ព្រហន្តម្បិ វនប្បតឹ
តស្មា រាជ បវេធាមិ សម្បស្សំ អនាគតំ ភយំ ។



(៣៨៥) ម្នាលកោដសិម្ពលិ លុះដល់អ្នកមកច្របក្សីតូចនេះ ដែលមានសាច់តិចជាងយើងទេ ហេតុអ្វី ក៏ភ័យញ័រខ្លាំង ។

(៣៨៦) (ទេវបុត្តពោលថា) បពិត្រព្រះរាជា ព្រះអង្គមានសាច់ជាអាហារ ឯបក្សីនេះមានផ្លែឈើជាអាហារ បក្សីនេះនឹងស៊ីនូវពូជជ្រៃ ពូជល្វៀ ពូជល្វាទាំងពីរយ៉ាង ពូជពោធិ៍ទាំងពីរយ៉ាង ហើយមកជុះដាក់លើដើមឈើរបស់យើង ។

(៣៨៧) ឈើទាំងឡាយនោះ ដុះក្នុងទីពុំមានខ្យល់ ក្បែរខាងនៃយើងលូតលាស់ល្អ ឈើទាំងឡាយនោះ មុខជានឹងរួបរឹតយើង ធ្វើយើងមិនឲ្យនៅជាដើមឈើ ។

(៣៨៨) មានឈើដទៃទៀត ដែលជាឈើប្រកបដោយឫស ប្រកបដោយដើម ត្រូវសកុណជាតិនេះ នាំយកពូជមកបំផ្លាញហើយដែរ ។

(៣៨៩) ព្រោះ (ឈើទាំងឡាយមានជ្រៃជាដើម) រមែងដុះសង្កត់នូវឈើជាធំ ក្តីក្រៃ សូម្បីចំរើន បពិត្រព្រះរាជា ព្រោះហេតុនោះ យើងឃើញភ័យទៅអនាគត បានជាញាប់ញ័រ ។

(៣៩០) សង្កេយ្យ សង្កិតព្វានិ រក្ខេយ្យានាគតំ ភយំ
អនាគតភយា ធីរោ ឧភោ លោកេ អវេក្ខតីតិ ។

កោដសិម្ពលិជាតកំ សត្តមំ ។

## ធូមការិជាតកំ

(៣៩១) រាជា អបុច្ឆិ វិធុរំ ធម្មកាមោ យុធិដ្ឋិលោ
អបិ ព្រាហ្មណ ជានាសិ កោ ឯកោ ពហុ សោចតិ ។

(៣៩២) ព្រាហ្មណោ អជយូថេន ពហុគោធោ(១) វនេ វសិ
ធូមំ អកាសិ វាសេដ្ឋោ រត្តិន្ទិវមតន្ទិតោ ។

(៣៩៣) តស្ស តំ ធូមគន្ធេន សរភា មកសទ្ទិតា(២)
វស្សាវាសំ ឧបគច្ឆុំ ធូមការិស្ស សន្តិកេ ។

១ ម. ឧ. ពហុគោធោ ។ ២ ម. ឧ. មកសន្តិតា ។



(៣៩០) (សុបណ្ណរាជត្រាស់ប្រាប់ទេវតា ហើយពោលថា) អ្នកប្រាជ្ញ គប្បីរង្កៀស ចំពោះហេតុទាំងឡាយដែលគួររង្កៀស គប្បីរក្សា (ប្រយ័ត្ន) នូវភ័យ ជាអនាគត ទើបឈ្មោះថា រមិលមើលនូវលោកទាំងពីរ ព្រោះហេតុនៃភ័យ ជាអនាគត ។

ចប់ កោដសិម្ពលិជាតក ទី ៧ ។

## ធូមការិជាតក

(៣៩១) (ព្រះសាស្តា ទ្រង់ត្រាស់ថា) ព្រះរាជាទ្រង់ព្រះនាមយុធិដ្ឋិលៈ ព្រះអង្គពេញព្រះទ័យនឹងសុចរិតធម៌ បានត្រាស់សួរវិធុរបណ្ឌិតថា ម្នាលព្រាហ្មណ៍ អ្នកដឹង ឬទេ អ្នកណាតែម្នាក់ឯងសោកស្តាយច្រើន ។

(៣៩២) (វិធុរបណ្ឌិតទូលតប ពោលថា) ព្រាហ្មណ៍ជាវាសិដ្ឋគោត្ត មានពពែច្រើន នៅក្នុងព្រៃជាមួយនឹងហ្វូងពពែ ជាអ្នកមិនខ្ជិលច្រអូស ទាំងយប់ទាំងថ្ងៃ បានបង្ហុយផ្សែង (ដើម្បីការពារកុំឲ្យមូសខាំ) ។

(៣៩៣) ពួកម្រឹគឈ្មោះ សរភៈ(១) ត្រូវមូសខាំ ដោយក្លិនផ្សែងនោះ ក៏ចូលទៅនៅ ក្នុងសំណាក់នៃព្រាហ្មណ៍ ជាអ្នកធ្វើផ្សែងនោះ ក្នុងពេលដែលមានភ្លៀងធ្លាក់ជោកជាំ ។

១- ឈ្មោះម្រឹគមានក្រចក ៨ អាចលោតរំលងជ្រោះជ្រៅបាន ។ អដ្ឋកថាធ្យូទីបិកាសូចិ ។

(៣៩៤)សរភេសុ មនំ កត្វា អជា សោ ជាវពុជ្ឈថ

អាគច្ឆន្តិ វជន្តិ ច តស្ស តា វិនស្សុំ អជា ។

(៣៩៥)សរភា សារទេ កាលេ បហីនមកសេ វនេ

បាវិសុ គិរិទុគ្គានិ នទីនំ បភវានិ ច ។

(៣៩៦)សរភេ ច គតេ ទិស្វា អជា ច វិភវំ គតា

កិសោ ច វិវណ្ណោ អាសិ បណ្ឌុរោគី ច ព្រាហ្មណោ ។

(៣៩៧)ឯវំ យោ សន្និរង្កត្វា អាគន្តុំ កុរុតេ បិយំ

សោ ឯកោ ពហុ សោចតិ ធូមការីវ ព្រាហ្មណោតិ ។

ធូមការិជាតកំ អដ្ឋមំ ។



(៣៩៤) ព្រាហ្មណ៍នោះ ចំពាក់ចិត្តនឹងពួកសរភៈ ដែលទើបនឹងដល់ ពួកពពែជា (ពពែប៉ុណ្ណោះ) មកកាន់ក្រោលហើយ ចេញ (ពពែប៉ុណ្ណោះ ចេញអំពីក្រោលទៅព្រៃ) ពួកពពែទាំងនោះ របស់គាត់ ក៏វិនាសអស់ទៅ ។

(៣៩៥) លុះដល់ក្នុងសរទកាល ពួកសរភៈច្រើន ក៏ចូលទៅកាន់ជើងភ្នំផង កាន់ដើមស្ទឹងផង ក្នុងព្រៃដែលគ្មានមូស ។

(៣៩៦) ចំណែកខាងព្រាហ្មណ៍ ក៏កើតរោគលឿង ស្គម មានសម្បុរអាក្រក់ ព្រោះឃើញពួកសរភៈច្រើន ទៅបាត់ផង ឃើញពួកពពែវិនាសផង ។

(៣៩៧) បុគ្គលណា លះបង់អព្ភន្តរិកជន (បុរាណ) របស់ខ្លួនចោលយ៉ាងនេះ ហើយធ្វើសេចក្តីស្រឡាញ់ ចំពោះអាគន្តុកជនវិញ បុគ្គលនោះ តែម្នាក់ឯង តែងសោកស្តាយច្រើន ដូចព្រាហ្មណ៍ជាអ្នកធ្វើផ្សែង ។

ចប់ ធូមការិជាតក ទី ៨ ។

## ជាគរជាតកំ

(៣៩៨) កោធ ជាគរតំ សុត្តោ  កោធ សុត្តេសុ ជាគរោ
កោ មេតំ នុ វិជានាតិ  កោ តំ បដិភណាតិ មេ ។

(៣៩៩) អហំ ជាគរតំ សុត្តោ  អហំ សុត្តេសុ ជាគរោ
អហមេតំ វិជានាមិ  អហំ បដិភណាមិ តេ ។

(៤០០) កថំ ជាគរតំ សុត្តោ  កថំ សុត្តេសុ ជាគរោ
កថំ ឯតំ វិជានាសិ  កថំ បដិភណាសិ មេ ។

(៤០១) យេ ធម្មំ នប្បជានន្តិ  សញ្ញមោតិ ទមោតិ ច
តេសុ សុប្បមានេសុ  អហំ ជគ្គាមិ ទេវតេ ។



## ជាគរជាតក

(៣៩៨) (ទេវតាសួរប្រស្នាថា) កាលសត្វទាំងឡាយ កំពុងភ្ញាក់ អ្នកណាជាអ្នកដេកលក់ ក្នុងលោកនេះ កាលសត្វទាំងឡាយកំពុងដេកលក់ អ្នកណា ជាអ្នកភ្ញាក់ ក្នុងលោកនេះ អ្នកណាហ្ន៎ ដឹងច្បាស់នូវប្រស្នារបស់យើងនុ៎ះបាន អ្នកណានឹងឆ្លើយតបប្រស្នារបស់យើងនោះបាន ។

(៣៩៩) (តាបសពោធិសត្វ ពោលថា) កាលសត្វទាំងឡាយ កំពុងភ្ញាក់ ខ្ញុំជាអ្នកដេកលក់ កាលសត្វទាំងឡាយ កំពុងដេកលក់ ខ្ញុំជាអ្នកភ្ញាក់ ខ្ញុំដឹងច្បាស់ នូវប្រស្នារបស់អ្នកនុ៎ះ ខ្ញុំឆ្លើយតប (ប្រស្នានុ៎ះ) របស់អ្នកបាន ។

(៤០០) (ទេវតានោះ សួរទៀតថា) កាលសត្វទាំងឡាយ កំពុងភ្ញាក់ អ្នកដេកលក់ តើដូចម្តេច កាលសត្វទាំងឡាយ កំពុងដេកលក់ អ្នកភ្ញាក់ តើដូចម្តេច អ្នកដឹងច្បាស់ នូវប្រស្នារបស់ខ្ញុំនុ៎ះ ដូចម្តេច អ្នកឆ្លើយតបខ្ញុំ ដូចម្តេច ។

(៤០១) (ពោធិសត្វ ពោលថា) សត្វទាំងឡាយណា មិនដឹងច្បាស់នូវធម៌ផង មិនដឹងថា (នេះ) ជាសញ្ញមៈផង (នេះ) ជាទមៈផង កាលបើសត្វទាំងឡាយនោះ ដេកលក់ទាំងសេចក្តីប្រមាទហើយ ម្នាលទេវតា ខ្ញុំរមែងភ្ញាក់ ។

(៦០២) យេសំ រាគោ ច ទោសោ ច អវិជ្ជា ច វិរាជិតា
តេសុ ជាគរមានេសុ អហំ សុត្តោស្មិ ទេវតេ។
(៦០៣) អហំ ជាគរេសុ សុត្តោ អហំ សុត្តេសុ ជាគរោ
អហមេតំ វិជានាមិ អហំ បដិភណាមិ តេ ។
(៦០៤) សាធុ ជាគរតំ សុត្តោ សាធុ សុត្តេសុ ជាគរោ
សាធុ មេតំ វិជានាសិ សាធុ បដិភណាសិ មេតិ។

ជាគរជាតកំ នវមំ ។

# កុម្មាសបិណ្ឌជាតកំ

(៦០៥) ន កិរត្ថិ អនោមទស្សីសុ
បារិចរិយា ពុទ្ធេសុ អប្បិកា
សុក្ខាយ អលោណិកាយ ច
បស្ស ផលំ កុម្មាសបិណ្ឌិយា ។
ហត្ថី គវស្សា ចិមេ ពហូ
ធនធញ្ញំ បឋវី ច កេវលា
នារិយោ ចិមា អច្ឆរូបមា
បស្ស ផលំ កុម្មាសបិណ្ឌិយា ។



(៦០២) ពួកសត្វណា លះបង់នូវរាគៈ ទោសៈ និងអវិជ្ជាបាន កាលបើពួកសត្វនោះ កំពុងភ្ញាក់ ម្នាលទេវតា ខ្ញុំជាអ្នកដេកលក់ ។

(៦០៣) កាលបើពួកសត្វ កំពុងភ្ញាក់ ខ្ញុំជាអ្នកដេកលក់យ៉ាងនេះ កាលបើពួកសត្វ កំពុងដេកលក់ ខ្ញុំជាអ្នកភ្ញាក់យ៉ាងនេះ ខ្ញុំដឹងច្បាស់នូវប្រស្នារបស់អ្នកនុ៎ះ យ៉ាងនេះ ខ្ញុំឆ្លើយតបអ្នកយ៉ាងនេះ ។

(៦០៤) (ទេវតាមានចិត្តត្រេកអរ ពោលសរសើរថា) ត្រូវហើយ កាលបើពួកសត្វ កំពុងភ្ញាក់ អ្នកជាបុគ្គលដេកលក់ ត្រូវហើយ កាលបើពួកសត្វ កំពុងដេកលក់ អ្នកជាបុគ្គលភ្ញាក់ ត្រូវហើយ អ្នកដឹងច្បាស់នូវប្រស្នារបស់ខ្ញុំនុ៎ះ អ្នកឆ្លើយតបខ្ញុំ ត្រូវហើយ ។

ចប់ ជាគរជាតក ទី ៩ ។

# កុម្មាសបិណ្ឌជាតក

(៦០៥) (ព្រះរាជាពោធិសត្វ បានពោលថា) បានឮថា ការបំរើព្រះបច្ចេកពុទ្ធទាំងឡាយ ដែលលោកមានពោធិញាណ មិនថោកថយ មិនមែនមានផលតិចតួចឡើយ អ្នកចូរមើលផលនៃដុំនំកុម្មាសៈ ដែលស្ងួតក្រៀម ឥតសៃប្រៃ ។ ដំរី គោ និងសេះ ជាច្រើនទាំងនេះផង ទ្រព្យ ស្រូវ និងផែនដីទាំងអស់ផង នាងនារីទាំងឡាយ ដែលប្រៀបដូចជាស្រីអប្សរទាំងនេះផង សុទ្ធតែជារបស់ខ្ញុំ អ្នកចូរមើលនូវផល នៃដុំនំកុម្មាសៈ ។

(៤០៦) អភិក្ខណំ រាជកុញ្ជរ
គាថា ភាសសិ កោសលាធិប
បុច្ឆាមិ តំ រដ្ឋវឌ្ឍន
ពាឡ្ហំ បីតិមនោ បភាសសិ ។

(៤០៧) ឥមស្មិំយេវ នគរេ កុលេ អញ្ញតរេ អហុំ(១)
បរកម្មករោ អាសឹ ភតកោ សីលសំវុតោ ។
កម្មាយ និក្ខមន្តាហំ ចតុរោ សមណទ្ទសំ
អាចារសីលសម្បន្នេ សីតិភូតេ អនាសវេ ។
តេសុ ចិត្តំ បសាទេត្វា និសីទិត្វា បណ្ណសន្ថតេ
អទំ ពុទ្ធាន កុម្មាសំ បសន្នោ សេហិ បាណិភិ ។
តស្ស កម្មស្ស កុសលស្ស ឥទំ មេ ឯទិសំ ផលំ
អនុភោមិ ឥទំ រជ្ជំ ផីតំ ធរណិមុត្តមំ ។

១ ម. អហុ ។



(៤០៦) (នាងទេវីបានពោលថា) បពិត្រព្រះរាជកុញ្ជរ មានព្រះអធ្យាស្រ័យជាកុសល ទ្រង់ញ៉ាំងផែនដីឲ្យចំរើន ព្រះអង្គត្រាស់គាថាទាំងឡាយរឿយ ៗ ខ្ញុំព្រះអង្គសូមក្រាបបង្គំទូលសួរទ្រង់ ព្រះអង្គមានព្រះទ័យ ប្រកបដោយបីតិក្រៃពេក ហើយទ្រង់ត្រាស់ (គាថាទាំងនុ៎ះ) ។

(៤០៧) (ព្រះមហាសត្វ បានត្រាស់គាថាទាំងនេះថា) យើងបានកើតក្នុងត្រកូលមួយ ក្នុងក្រុងនេះឯង ជាអ្នកស៊ីឈ្នួលធ្វើការងាររបស់បុគ្គលដទៃ ជាអ្នកសង្រួមក្នុងសីល យើងចេញទៅធ្វើការងារ បានជួបនឹងសមណៈ ៤ អង្គ លោកបរិបូណ៌ដោយអាចារៈ និងសីល មានសេចក្តីត្រជាក់ ជាទីផុតចាកអាសវៈហើយ ។ យើងបានញ៉ាំងចិត្តឲ្យជ្រះថ្លា ចំពោះសមណៈទាំងនោះ បាននិមន្តលោកឲ្យគង់លើកម្រាលស្លឹកឈើ លុះយើងមានចិត្តជ្រះថ្លាហើយ បានប្រគេននំកុម្មាសៈ ដល់ព្រះពុទ្ធទាំងឡាយ ដោយដៃរបស់ខ្លួន ។ ផលរបស់យើងបានផល ដូច្នេះ ជាផលរបស់កម្ម ជាកុសលនោះ យើងសោយរាជ្យសម្បត្តិក្នុងស្រុកស្គម្ភ ប្រសើរលើផែនដីនេះ ។

(៦០៨) ទទំ ភុញ្ជ ច(១) មា ច បមាទោ
ចក្កំ វត្តយ កោសលាធិប
មា រាជ អធម្មិកោ អហុ
ធម្មំ បាលយ កោសលាធិប ។

(៦០៩) សោហំ តទេវ(២) បុនប្បុនំ
វដុមំ អាចរិស្សាមិ សោភនេ
អរិយាចរិតំ សុកោសលេ
អរហន្តោ មេ មនាបាវ បស្សិតុំ ។

(៦១០) ទេវី វិយ អច្ឆរូបមា
មជ្ឈេ នារិគណស្ស សោភសិ
កឹ កម្មមកាសិ ភទ្ទកំ
កេនាសិ វណ្ណវតី សុកោសលេ ។

១ ម. ចសទ្ទោ នត្ថិ ។ ២ ម. សោហន្តទេវ ។



(៦០៨) (នាងទេវីពោលថា) បពិត្រព្រះអង្គមានព្រះអធ្យាស្រ័យ ជាកុសល សូមព្រះអង្គទ្រង់ព្រះរាជទាន ហើយសឹមទ្រង់សោយ សូមព្រះអង្គកុំប្រមាទ (ក្នុងបុណ្យទាំងឡាយ) សូមព្រះអង្គញុំាងចក្រធម៌(១) ឲ្យប្រព្រឹត្តទៅ បពិត្រព្រះរាជា មានព្រះអធ្យាស្រ័យ ជាកុសល ព្រះអង្គ កុំជាអ្នកមិនប្រកបដោយធម៌ សូមទ្រង់រក្សានូវអនុធម៌(២) ។

(៦០៩) (ព្រះមហាសត្វ ទ្រង់ត្រាស់ថា) ម្នាលនាងមានលោមល្អ យើងនោះនឹងដើរតាមគន្លង ដែលព្រះអរិយៈធ្លាប់ប្រព្រឹត្តរឿយ ៗ មក នោះឯង ម្នាលនាងដ៏ល្អជាធីតារបស់ព្រះបាទកោសល ការបានជួបប្រទះនូវព្រះអរហន្តទាំងឡាយ ជាទីគាប់ចិត្តរបស់យើងពន់ពេក ។

(៦១០) (ព្រះរាជាទ្រង់សួរនាងទេវីថា) ម្នាលនាងសុកោសលធីតា នាងប្រៀបដូចជាស្រ្តីទេពអប្សរ ជាទេវធីតា (របស់សក្កទេវរាជ) រើករាយ ក្នុងកណ្តាលនៃពួកនាងនារី នាងបានធ្វើនូវកម្មដ៏ចំរើន ដូចម្តេច នាងមានសម្បុរល្អ ដោយហេតុអ្វី ។

១ ចក្រធម៌មាន ៤ យ៉ាងគឺ បដិរូបទេសវាសៈ ១ សប្បុរិសូបស្សយៈ ១ អត្តសម្មាបណិធិ ១ បុព្វេកតបុញ្ញតា ១ ។ ២ រាជធម៌ទាំង ១០ ប្រការ មានទានជាដើម ។ អដ្ឋកថា ។

[៦១១] អម្ពដ្ឋកុលស្ស ខត្តិយ
ទាស្យាហំ បរបេសិយា អហុំ
សញ្ញតា ច ធម្មជីវិនី
សីលវតី ច អបាបទស្សនា ។
ឧទ្ធដភត្តំ អហំ តទា
ចរមានស្ស អទាសិំ ភិក្ខុនោ
វិត្តា សុមនា សយំ អហំ
តស្ស កម្មស្ស ផលំ មមេទិសន្តិ ។

កុម្មាសបិណ្ឌជាតកំ ទសមំ ។

## បរន្តបជាតកំ

[៦១២] អាគមិស្សតិ មេ បាបំ អាគមិស្សតិ មេ ភយំ
តទា ហិ ចលិតា សាខា មនុស្សេន មិគេន វា ។
[៦១៣] ភីរុយា នូន មេ កាមោ អវិទូរេ វសន្តិយា
ករិស្សតិ កិសំ បណ្ឌុំ សាវ សាខា បរន្តបំ ។



[៦១១] (នាងទេវី ឆ្លើយថា) បពិត្រក្សត្រិយ៍ ខ្ញុំម្ចាស់ជាទាសីបម្រើអ្នកដទៃ របស់ត្រកូលអម្ពដ្ឋៈជាស្រីសង្រួម ចិញ្ចឹមជីវិតដោយធម៌ មានសីលធម៌ មានការឃើញមិនអាក្រក់ ។ កាលនោះ ខ្ញុំជាស្រីមានចិត្តត្រេកអរក្រៃលែងខ្លួនឯង បានប្រគេនភត្តដែលគេដួស (ទុកបម្រុងខ្ញុំ) ដល់ភិក្ខុ (ព្រះបច្ចេកពុទ្ធ) ដែលត្រាច់ទៅ (ដើម្បីបិណ្ឌបាត) ផលប្រាកដដូច្នេះនេះ គឺជាផលនៃបុញ្ញកម្មនោះ ។

ចប់ កុម្មាសបិណ្ឌជាតក ទី ១០ ។

## បរន្តបជាតក

[៦១២] (បរន្តបទាសៈ ពោលថា) អំពើលាមកនឹងមកដល់ខ្ញុំ ភ័យនឹងមកដល់ខ្ញុំ ដ្បិតក្នុងកាលនោះ មែកឈើកម្រើក ព្រោះមនុស្សឬម្រឹគ ។

[៦១៣] (បុរោហិត ពោលថា) កាមរបស់ខ្ញុំ (កើតចំពោះនាងព្រាហ្មណី) ជាស្រីខ្លាចច្រើន ដែលនៅក្នុងទីមិនឆ្ងាយ គង់នឹងធ្វើ ខ្ញុំ ឲ្យជាបុគ្គលស្គមស្លេក ដូចជាមែកឈើនោះ (ដែលធ្វើ) តាបសៈឈ្មោះបរន្តបៈ (ឲ្យជាបុគ្គលស្គមស្លេក) ។

(៤០៤) សោចយិស្សតិ មំ កន្តា គាមេ វសំ អនិន្ទិតា
ការិស្សតិ កិសំ បណ្ឌុំ សាវ សាខា បវន្តំ ។
(៤០៥) តយា មំ អសិតាបង្គី មិហិតានិ(១) ភណិតានិ ច
កិសំ បណ្ឌុំ ការិស្សតិ សាវ សាខា បវន្តំ ។
(៤០៦) អគមា នូន សោ សទ្ទោ អសំសិ នូន សោ តវ
អក្ខាតំ នូន តំ តេន យោ តំ សាខមកម្បយិ ។
(៤០៧) ឥទំ ខោ តំ សមាគម្ម មម ពាលស្ស ចិន្តិតំ
គណា ហិ ចលិតា សាខា មនុស្សេន មិគេន វា ។
(៤០៨) តទេវ ត្វំ អវេធសិ អវញ្ចិ បិតរំ មម
ហត្ថា សាខាហិ ធានេន្តោ អាគមិស្សតិ គេហយន្តិ ។

បាទូបជាតកំ ឯកាទសមំ ។

វគ្គោ ទុតិយោ ។

---

១ ម. អសិតាបង្គី សិតានិ ។



(៤០៤) (ថ្ងៃក្រោយ បុរោហិតនោះ ពោលថា) កិរិយាជាទីពេញចិត្ត កាលនៅក្នុងស្រុក ឥតមានអ្នកផង តិះដៀលបាន នឹងធ្វើឲ្យព្រួយសោក នឹងធ្វើឲ្យស្គមលឿង ដូចជាមែកឈើនោះ (ដែលខ្ញុំ) ពាសះ ណោះបោក្ខបះ (ឲ្យជាបុគ្គលស្គមលឿង) ។

(៤០៥) (ថ្ងៃក្រោយទៀត បុរោហិត ពោលថា) នែអ្នក ការញញឹម ញាំញោម ឬសំដី (ពីកាល) ដែលនាង (ឲ្យប្រព្រឹត្តទៅហើយ) នឹងធ្វើឲ្យជាបុគ្គលស្គមលឿង ដូចជាមែកឈើនោះ (ដែលខ្ញុំ) ពាសះ ណោះបោក្ខបះ (ឲ្យជាបុគ្គលស្គមលឿង) ។

(៤០៦) (បាទូបពាសះ ពោលថា) សំឡេង (នៃមែកឈើ)នោះ ប្រព្រឹត្តទៅហើយនោះ ដូចជាប្រាប់អ្នកហើយ សត្វណាញាំងមែកឈើនោះ ឲ្យកំរើក សត្វនោះប្រាប់ហេតុនោះហើយ ។

(៤០៧) គំនិតណាដែលខ្ញុំជាបុគ្គលល្ងង់ គិតថា ក្នុងកាលនោះ មែកឈើកំរើក ព្រោះមនុស្ស ឬម្រឹគ គំនិតនេះឯង មកដល់ខ្ញុំហើយ ។

(៤០៨) (លំដាប់នោះ កជកុមារ ពោលថា) អ្នកបានដឹងពិតដូច្នោះមែន ព្រោះអ្នកបានសម្លាប់ឪពុករបស់ខ្ញុំ បិទបាំងដោយមែកឈើទាំងឡាយ លាក់លៀមដោយគិតថា (ភ័យនឹងមានមកដល់អ្នក) ។

ចប់ បាទូបជាតក ទី ១១ ។

ចប់ វគ្គ ទី ២ ។

## តស្សុទ្ទានំ

វរកាម មហាកបិ កត្តា ច
ឧព្ភជម្ម សកុញ្ញូរ កេសវក
ឱរគោ វិធុរោ បុន ជាគរតំ
អថ កោសលាធិប បរន្តប ច ។

## តត្រ វគ្គុទ្ទានំ ភវតិ

អថ សត្តនិបាតម្ហិ វគ្គំ មេ កណោតោ សុណា
កុក្កុ ច បុន គន្ធារោ ទ្វេ ចវុត្តា មហេសិនា ។

សត្តកនិបាតំ និដ្ឋិតំ ។



## ឧទ្ទាននៃជាតកនោះ គឺ

និយាយអំពីការលះស្រុកដ៏ប្រសើរ ១ ស្វា ១ កត្តរៈសន្តាន ១ ស្តេចព្រះនាម ឧព្ភេម្មៈ ១ ដ៏រ ១ សក់ដ៏ប្រសើរ ១ នាគ ១ វិធុរបណ្ឌិត ១ កាលដេកភ្ញាក់រលឹក ១ ព្រះរាជាមានអធ្យា-ស្រ័យ ជាកុសល ១ បរន្តបតាសៈ ១ ។

ក្នុងសត្តកនិបាតនោះ មានឧទ្ទាននៃវគ្គ (ដូច្នេះ) កាល ខ្ញុំសូមពោលនូវវគ្គ ក្នុងសត្តកនិបាត ចូរអ្នកស្តាប់ វគ្គគឺ គុក្កុវគ្គ ១ គន្ធារវគ្គ ១ ដែលព្រះសម្ពុទ្ធ ព្រះអង្គស្វែងរកនូវគុណដ៏ធំ ទ្រង់ត្រាស់ទុកហើយ ។

ចប់ សត្តកនិបាត ។

# អដ្ឋកនិបាតជាតកំ

## កច្ចានិវគ្គោ

### កច្ចានិជាតកំ

(៦៥៩) ឱទាតវត្ថា សុចិ អល្លកេសា
កច្ចានិ កឹ កុម្ភិមធិស្សយិត្វា
បិដ្ឋា តិលា ធោវសិ តណ្ឌុលានិ
តិលោទនោ ហេហិតិ កិស្ស ហេតុ ។

(៦៦០) ន ខោ អយំ ព្រាហ្មណ ភោជនត្ថំ[១]
តិលោទនោ ហេហិតិ សាធុបក្កោ
ធម្មោ មតោ តស្ស បហុតមជ្ជ
អហំ ករិស្សាមិ សុសានមជ្ឈេ ។

(៦៦១) អនុវិច្ច កច្ចានិ ករោហិ កិច្ចំ
ធម្មោ មតោ កោ នុ តវេតំសំសិ[២]
សហស្សនេត្តោ អតុលានុភាវោ
ន មិយ្យតី ធម្មវរោ កទាចិ ។

១ ម. ភោជនត្ថា ។ ២ ម. តវេតំសំសិ ។


# អដ្ឋកនិបាតជាតក

## កច្ចានិវគ្គ

### កច្ចានិជាតក


(៦៥៩) (ព្រះឥន្ទ្រពោធិសត្វ ពោលថា) ម្នាលនាងកច្ចានី ថ្វីក៏បានជានាងស្លៀកដណ្តប់សំពត់សស្អាត មានសក់ទទឹក ហើយដាំឆ្នាំង លាងម្សៅល្ងនឹងអង្ករ បាយលាយដោយល្ង កើតមានឡើង តើព្រោះហេតុដូចម្តេច ។

(៦៦០) (នាងកច្ចានី ពោលថា) ម្នាលព្រាហ្មណ៍ បាយលាយដោយល្ង ដែលចំអិនដោយប្រពៃនេះ មិនមែនបម្រុងនឹងបរិភោគខ្លួនឯងទេ (ព្រោះថា) ធម៌ស្លាប់បាត់ទៅហើយ ថ្ងៃនេះ ខ្ញុំនឹងធ្វើការបូជាចំពោះធម៌នោះ ក្នុងកណ្តាលព្រៃស្មសាន ។

(៦៦១) (ព្រះឥន្ទ្រពោលថា) ម្នាលនាងកច្ចានី នាងចូរពិចារណាសិន ហើយសឹមធ្វើនូវកិច្ច ដែលត្រូវធ្វើចុះ អ្នកណាប្រាប់នាងថា ធម៌ស្លាប់ទៅហើយ ព្រះសហស្សនេត្រ គឺព្រះឥន្ទ្រមានអានុភាពរកអ្វីថ្លែងផ្ទឹមពុំបាន ជាបុគ្គលមានធម៌ដ៏ប្រសើរ មិនដែលស្លាប់ ក្នុងកាលណាមួយឡើយ ។

(៦៦២) ទឡ្ហប្បមាណំ មម ឯត្ថ ព្រហ្មេ
ធម្មោ មតោ នត្ថិ មមេត្ថ កង្ខា
យេ យេវ ទានិ បាបា ភវន្តិ
តេ តេវ ទានិ សុខិតា ភវន្តិ ។
សុណិសា ហិ មយ្ហំ វញ្ឈា អហោសិ
សា មំ វធិត្វាន វិជាយិ បុត្តំ
សាទានិ សព្វស្ស កុលស្ស ឥស្សរា
អហំ វសាមិ អបវិទ្ធា[១] ឯកិកា ។

(៦៦៣) ជីវាមិ វោហំ ន មតោហមស្មិ
តវេវ អត្ថាយ ឥធាគតោស្មិ
យា តំ វធិត្វាន វិជាយិ បុត្តំ
សហាវ បុត្តេន ករោមិ ភស្មំ ។

(៦៦៤) ឯវញ្ច តេ រុច្ចតិ ទេវរាជ
មមេវ អត្ថាយ ឥធាគតោសិ
អហញ្ច បុត្តោ សុណិសា ច នត្តា
សម្មោទមានា ឃរមាវសេម ។

១ ម. ឧ. អហំ បនម្ហិ អបវិទ្ធា ។



(៦៦២) (នាងកច្ចានី ពោលថា) ម្នាលព្រាហ្មណ៍ ការណ៍ប្រមាណធំមាំ របស់ខ្ញុំក្នុងហេតុនេះ ធម៌ស្លាប់បាត់ទៅហើយ ខ្ញុំមិនមានសង្ស័យ ក្នុងហេតុនេះទេ ឥឡូវនេះ ពួកជនណា ៗ ដែលជាបុគ្គលលាមក ពួកជនោះ ៗ តែងបានសុខ ក្នុងកាលឥឡូវនេះ ។

ម្យ៉ាងកូនប្រសាស្រីខ្ញុំ ជាស្រីអារ កបណ្ដេញខ្ញុំ ហើយសម្រាលកូនប្រុស ឥឡូវនេះ ក៏បានជាធំលើត្រកូលទាំងអស់ ខ្ញុំជាស្ត្រីមិនមានទីពឹង នៅតែម្នាក់ឯង ។

(៦៦៣) (ព្រះឥន្ទ្រ ពោលថា) យើងនៅរស់ យើងមិនទាន់ស្លាប់ទៅទៀយទេ យើងមកក្នុងទីនេះ ក៏ដើម្បីជាប្រយោជន៍ដល់នាងឯង កូនប្រសាស្រីណា ដែលបានបណ្ដេញនាង ហើយបានកូនប្រុស យើងនឹងធ្វើកូនប្រសានោះ ឲ្យខ្ទេចជាផេះ ព្រមទាំងកូនប្រុស មិនខាន ។

(៦៦៤) (នាងកច្ចានី ពោលថា) បពិត្រទេវរាជ លោកគាប់ចិត្តយ៉ាងនេះ លោកអញ្ជើញមក ក្នុងទីនេះ ដើម្បីប្រយោជន៍ ដល់ខ្ញុំ តែសូមឲ្យខ្ញុំ នឹងកូនប្រុស កូនប្រសាស្រី ចៅ ជាបុគ្គលមានសេចក្ដីរីករាយរួមគ្នា ហើយនៅគ្រប់គ្រងផ្ទះវិញ ។

(៦៦៥) ឯវញ្ចេ តេ រុច្ចតិ កាតិយានិ
ហតាបិ សន្តា ន ជហាសិ ធម្មំ
តុវញ្ច បុត្តោ សុណិសា ច នត្តា
សម្មោទមានា ឃរមាវសេថ ។

(៦៦៦) សា កាតិយានី សុណិសាយ សទ្ធិំ
សម្មោទមានា ឃរមាវសិត្ថ
បុត្តោ ច នត្តា ច ឧបដ្ឋហិំសុ
ទេវានមិន្ទេន អធិគ្គហីតា តិ ។

កច្ចានិជាតកំ បឋមំ ។

## អដ្ឋសទ្ទជាតកំ

(៦៦៧) ឥទំ បុរេ និន្នមាហុ ពហុមច្ឆំ មហោទកំ
អាវាសោ ពករាជស្ស បេត្តិកំ ភវនំ មម
(១)
ត្យជ្ជ ភិង្គេន យាបេម ឱកំ ន វិជហាមសេ ។

១ ម. ភេកេន ។



(៦៦៥) (ព្រះឥន្ទ ពោលថា) ម្នាលនាងកាតិយានី បើនាងគាប់ចិត្តយ៉ាងនេះ នាងសូម្បីកូនប្រសាស្រី បៀតបៀនហើយ ក៏នៅតែមិនលះបង់នូវធម៌ឡើយ (ហេតុនេះ) សូមឱ្យនាងនឹងកូនប្រុស កូនប្រសាស្រី ចៅ ចូរជាបុគ្គលមានសេចក្តីរីករាយរកគ្នា ហើយនៅគ្រប់គ្រងផ្ទះចុះ ។

(៦៦៦) (ព្រះសម្ពុទ្ធ ទ្រង់ត្រាស់ថា) នាងកាតិយានី មានសេចក្តីរីករាយរកគ្នា ជាមួយនឹងកូនប្រសាស្រី ហើយនៅគ្រប់គ្រងផ្ទះ ចំណែកកូនប្រុសនឹងចៅ ត្រូវព្រះឥន្ទជាធំជាងពួកទេវតា ជួយអនុគ្រោះហើយ ក៏បាននាំគ្នាបំរើមាតានោះវិញ ។

ចប់ កច្ចានិជាតក ទី ១ ។

## អដ្ឋសទ្ទជាតក

(៦៦៧) (ពកសរពោធិសត្វ ទូលព្រះរាជា អំពីពាក្យកុកថា) ស្រះបោក្ខរណីនេះ ពីដើមជាទីទំនាប មានត្រីច្រើន មានទឹកច្រើន ជាទីលំនៅរបស់ស្តេចកុក ជាកេរ្តិ៍ដំណែលខាងបិតា ជាទីលំនៅរបស់យើង ថ្ងៃនេះ ពួកយើងនោះ ចិញ្ចឹមជីវិតដោយសត្វកង្កែប នៅតែមិនលះបង់ទីលំនៅ ចោលឡើយ ។

(៦២៨) កោ ទុតិយំ អសីលិស្ស ពន្ធុស្សក្ខិ ភេច្ឆតិ
កោ មេ បុត្តេ កុលាវកំ មញ្ច សោត្ថឹ ករិស្សតិ ។

(៦២៩) សព្វា បរិក្ខតា ផេគ្គុ យាវតស្សា គតី អហុ
ខីណភក្ខោ មហារាជ សារេ ន រមតី ឃុណោ ។

(៦៣០) សា នូនាហំ ឥតោ គន្ត្វា រញ្ញោ មុត្តា និវេសនា
អត្តានំ រមយិស្សាមិ ទុមសាខានិកេតិនី ។

(៦៣១) សោ នូនាហំ ឥតោ គន្ត្វា រញ្ញោ មុត្តោ និវេសនា
អគ្គោទកានិ បិវិស្សាមិ យូថស្ស បុរតោ វជំ ។

(៦៣២) តំ មំ កាមេហិ សម្មត្តំ រត្តំ កាមេសុ មុច្ឆិតំ
(●)
អាចយី គរតោ លុទ្ទោ ពាហិកោ ភទ្ទមត្ថុ តេ ។

● ម. វិតតោ ។



(៦២៨) (ទូលអំពីពាក្យក្អែកថា) អ្នកណាហ្ន៎ បំបែកក្អែកជាគំរប់ពីរ របស់ទ្រមឹកអរ ឈ្មោះពន្ធុរៈ ជាបុគ្គលទ្រុស្តសីល អ្នកណាហ្ន៎ នឹងធ្វើនូវកូនទាំងឡាយ នឹងសម្បុករបស់យើង ព្រមទាំងយើង ឲ្យមានសួស្តី ។

(៦២៩) (ទូលអំពីពាក្យដង្កូវដង្កឹថា) ការប្រព្រឹត្តទៅនៃឈើស្រាយនោះ មាននៅត្រឹមណា ឈើស្រាយទាំងអស់ អស់លើងហើយ បពិត្រមហារាជ ដង្កូវដង្កឹអស់អាហារហើយ រីលែងត្រេកអរក្នុងឈើខ្លឹម ។

(៦៣០) (ទូលអំពីពាក្យមេតាវើថា) លុះគ្រាអញនោះ បានទៅផុតអំពីព្រះរាជនិវេសន៍នេះហើយ នឹងកាន់ទីលំនៅ លើមែកឈើ ធ្វើខ្លួនឲ្យរីករាយ ។

(៦៣១) (ទូលអំពីពាក្យម្រឹគថា) លុះគ្រាអញនោះ បានទៅផុតអំពីព្រះរាជនិវេសន៍នេះហើយ នឹងដើរមុខហ្វូង ហើយផឹកនូវទឹកទាំងឡាយ ដ៏ប្រសើរ ។

(៦៣២) (ទូលអំពីពាក្យស្វាថា) ព្រានព្រៃឈ្មោះ ភរតៈ អ្នកនៅក្នុងដែនពាហិកៈ បានចាប់យើងដែលកំពុងស្រវឹង ដោយកាមទាំងឡាយ ត្រេកត្រអាលជាប់នៅក្នុងកាមទាំងឡាយនោះមក សូមសេចក្តីចំរើន ចូរមានដល់អ្នក ។

(៤៣៣) អច្ចការតិ ម៉ឺសភាយំ គុរេដ្ឋ ឧបរិ បព្វតេ
សាមំ សញ្ញោន មុទ្ទុជា មា តាតំ ខណិយស្សុ ឯវ ។

(៤៣៤) អសីសយំ ជាតិខយន្តទស្សី
ន គព្ភសេយ្យំ បុនរាវិសស្សំ
អយមន្តិមា បច្ឆិមគព្ភសេយ្យា
ខីណោ មេ សំសារោ បុនព្ភវាយាតិ ។

អដ្ឋសទ្ទជាតកំ ទុតិយំ ។

## សុលសាជាតកំ

(៤៣៥) ឥទំ សុវណ្ណកាយូរំ មុត្តា វេឡុរិយា ពហូ
សព្វំ ហរស្សុ ភទ្ទន្តេ មញ្ច ទាសីតិ សាវយ ។

(៤៣៦) ឱរោហយស្សុ កល្យាណិ មា ពហុំ បរិទេវសិ
ន ចាហំ(១) អភិជានាមិ អហន្ត្វា(២)ធនមាភតំ ។

១ ម. នេវាហំ ។ ២ ម. អហន្តា ។ ម. បហន្ត្វា ។



(៤៣៣) (ខ្លួនអំពីកាក្សកន្ទេហ) ទាន់លើបកឹតមានថ្ងៃស្រេច ។ មាន ននឹកចុះអព្វ ប្រកនូវរបស់យើងនោះ បានដំបោយនឹងយើង ដោយពាក្យថឹងន់ក៏កេះហ អ្នកប្រយ័ត្ន កុំឲ្យខំពប់ជើងលើថ្ម ។

(៤៣៤) (ខ្លួនអំពីខុពនក្រៃបទ្វេកក្ខុហ) អាត្មាអញ ជាអ្នកឃើញ នូវទីបំផុត គឺព្រះនិព្វាន ជាទីអស់ទៅនៃជាតិ ដោយមិនមាន សង្ស័យ នឹងមិនវិលត្រឡប់មកដេកនៅ ក្នុងគភ៌ទៀត ការដេកនៅ ក្នុងគភ៌នេះ ជាទីក្រោយបំផុត ត្រឹមនេះហើយ ការត្អឹកទៅ ក្នុងភពថ្មីទៀត របស់អាត្មាអញ អស់ហើយ ។

ចប់ អដ្ឋសទ្ទជាតក ទី ២ ។

## សុលសាជាតក

(៤៣៥) (នាងសុលសា ពោលទៅនឹងស្វាមីថា) គ្រឿងប្រដាប់ជាវិការៈ នៃមាសនេះ នឹងកែវមុក្តា កែវពៃទូរ្យទាំងឡាយជាច្រើន បពិត្រអ្នក ដ៏ចំរើន អ្នកចូរនាំយកនូវគ្រឿងទាំងអស់ចុះ មួយទៀត ចូរហៅកន្ទំថាជាទាសីចុះ ។

(៤៣៦) (ចោរឈ្មោះសត្តុកៈជាស្វាមី ពោលនឹងភរិយាថា) នាងចូរ ដោះគ្រឿងប្រដាប់ ដាល់អាចញ្ចៅ កុំយំរៀបរប់ច្រើន ដ្បិតអញ ទើបនឹងយក មិនដែលស្គាល់ទ្រព្យ ដែលនាងនាំមកឡើយ ។

(៦៣៧) យតោ សរាមិ អត្តានំ យតោ បត្តស្មិ វិញ្ញុតំ
នាភិជានាមិ អញ្ញំ បិយតរំ តយា ។

(៦៣៨) ឯហិ តំ ឧបគូហិស្សំ ករិស្សញ្ច បទក្ខិណំ
ន ហិ ទានិ បុន អត្ថិ មម តុយ្ហញ្ច សង្គមោ ។

(៦៣៩) ន ហិ សព្វេសុ ឋានេសុ បុរិសោ ហោតិ បណ្ឌិតោ
ឥត្ថីបិ បណ្ឌិតា ហោតិ តត្ថ តត្ថ វិចក្ខណា ។

(៦៤០) ន ហិ សព្វេសុ ឋានេសុ បុរិសោ ហោតិ បណ្ឌិតោ
ឥត្ថីបិ បណ្ឌិតា ហោតិ លហុមត្ថំ វិចិន្តិកា ។

(៦៤១) លហុញ្ច វត ខិប្បញ្ច និកដ្ឋេ សមចេតយិ
មិគំ បុណ្ណាយតេនេវ សុលសា សត្តុកំ វធិ ។

(៦៤២) យោធ ឧប្បតិតំ អត្ថំ ន ខិប្បមនុពុជ្ឈតិ
សោ ហញ្ញតេ មន្ទមតី ចោរោវ គិរិគព្ភរេ ។



(៦៣៧) (នាងសុលសា ពោលថា) តាំងពីកាលដែលខ្ញុំរលឹកឃើញខ្លួនដរាបមក តាំងពីខ្ញុំបានដល់នូវភាព ជាអ្នកដឹងក្តីដរាបមក ខ្ញុំមិនដែលស្គាល់បុរសដទៃ ដែលជាទីស្រឡាញ់លើសលុបជាងអ្នកទេ ។

(៦៣៨) អ្នកចូរអញ្ជើញមក ខ្ញុំនឹងកៀកឱបនូវអ្នក ហើយនឹងធ្វើប្រទក្សិណ ព្រោះតាំងពីថ្ងៃនេះ ខ្ញុំនឹងអ្នកលែងបានជួបគ្នាទៀតហើយ ។

(៦៣៩) (ទេវតាលើភ្នំ ពោលថា) មិនមែនតែបុរសទេ ដែលជាបណ្ឌិត ក្នុងហេតុទាំងពួង សូម្បីស្ត្រីក៏ជាបណ្ឌិត ឃើញច្បាស់ក្នុងហេតុនោះៗ បានដែរ ។

(៦៤០) មិនមែនតែបុរសទេ ដែលជាបណ្ឌិត ក្នុងហេតុទាំងពួង សូម្បីតែស្ត្រីក៏ជាបណ្ឌិត គន់គិតឃើញសេចក្តីរហ័សបានដែរ ។

(៦៤១) នាងសុលសា បានគិតឃើញឆាប់រហ័ស ក្នុងកាលដែលមានហេតុយ៉ាងកៀកជិត បានសម្លាប់ចោរសត្តុកៈ ដូចជាគេសម្លាប់ម្រឹគនឹងធ្នូ ដែលមានព្រួញដ៏គ្រប់គ្រាន់ ។

(៦៤២) បុគ្គលណា ក្នុងលោកនេះ មិនដឹងឆាប់នូវហេតុដែលកើតឡើង បុគ្គលអ្នកមានប្រាជ្ញាតិចនោះ រមែងត្រូវគេសម្លាប់ ដូចជាចោរ ដែលនាងសុលសា ច្រានទម្លាក់ ក្នុងជ្រោះភ្នំ ។

(៤៤៣) យោ ច ឧប្បតិតំ អត្ថំ ខិប្បមេវ និពោធតិ
មុច្ចតេ សត្តុសម្ពាធា សុលសា សត្តុកាមិវ។

សុលសាជាតកំ តតិយំ ។

## សុមង្គលជាតកំ

(៤៤៤) កុទ្ធស្មិំ កុទ្ធោតិ អវេក្ខិយាន
ន តាវ ទណ្ឌំ បណយេយ្យ ឥស្សរោ
អដ្ឋានសោ អប្បតិរូបមត្តនោ
បរស្ស ទុក្ខានិ ភុសំ ឧទីរយេ ។

(៤៤៥) យតោ ច ជានេយ្យ បសាទមត្តនោ
អត្ថំ និយុញ្ជេយ្យ បរស្ស ទុក្កដំ
តទាយមត្ថោតិ សយំ អវេក្ខិយ
អថស្ស ទណ្ឌំ សទិសំ និវេសយេ ។

(៤៤៦) ន ចាបិ ឈាបេតិ បរំ ន អត្តនំ
អមុច្ឆិតោ យោ នយតេ នយានយំ
យោ ទណ្ឌធារោ ភវតីធ ឥស្សរោ
ស វណ្ណគុត្តោ សិរិយា ន ធំសតិ ។





(៤៤៣) បុគ្គលណា ក្នុងលោកនេះ ដឹងច្បាស់នូវហេតុដែលកើតឡើង បុគ្គលនោះ រមែងរួចចាកការបៀតបៀន របស់សត្រូវ ដូចជានាងសុលសា រួចអំពីកណ្ដាប់ដៃ នៃចោរសត្តុកៈ ។

ចប់ សុលសាជាតក ទី ៣ ។

## សុមង្គលជាតក

(៤៤៤) បុគ្គលជាធំ បើបានដឹងថា កាលអញជាអ្នកក្រោធខ្លាំងដូច្នេះ ហើយ មិនគប្បីដាក់អាជ្ញាតែម្ដង ព្រោះបុគ្គលអ្នកក្រោធ គប្បី (ធ្វើ) ទោស ដែលមិនសមគួរ ដល់ខ្លួនថា (ស្ដេច) ហើយគោល បង្អាប់នូវកម្មជាទុក្ខដ៏ខ្លាំង ដល់បុគ្គលដទៃ ដោយឥតហេតុ ។

(៤៤៥) កាលណា បើបុគ្គលគប្បីដឹង នូវសេចក្ដីជ្រះថ្លារបស់ខ្លួន ហើយ គួរពិចារណានូវសេចក្ដី ដែលជាអំពើអាក្រក់របស់ជនដទៃ មួយទៀត គួរពិចារណាឲ្យឃើញច្បាស់ខ្លួនឯងថា នេះជាសេចក្ដីហើយ សឹមដាក់អាជ្ញាដ៏សមគួរដល់បុគ្គលដទៃនោះ ក្នុងកាលនោះចុះ ។

(៤៤៦) បុគ្គលណាមិនជ្រប់ ដោយកិលេស (អគតិ) ពិចារណានូវហេតុ ដែលជាចំនេញនិងមិនចំនេញ បុគ្គលនោះ រមែងមិនញ៉ាំងខ្លួននិងមិនញ៉ាំងបុគ្គលដទៃ ឲ្យក្ដៅក្រហាយទេ បុគ្គលជាធំណា ក្នុងលោកនេះ ជាអ្នកទ្រទ្រង់នូវអាជ្ញា បុគ្គលនោះ រមែងមានគេគ្រប់គ្រង ដោយការសរសើរគុណ មិនសាបសូន្យ ចាកសិរីឡើយ ។

[៦៦៧] យេ ខត្តិយាសេ អនិសម្មការិនោ
បណេន្តិ ទណ្ឌំ សហសា បមុច្ឆិតា
អវណ្ណសំយុត្តា ជហន្តិ ជីវិតំ
ឥតោ វិមុត្តាបិច យន្តិ ទុគ្គតឹ ។

[៦៦៨] ធម្មេ ច យេ អរិយប្បវេទិតេ រតា
អនុត្តរា តេ វចសា មនសា កម្មុនា ច
តេ ខន្តិសោរច្ចសមាធិសណ្ឋិតា
វជន្តិ លោកំ ឧភយំ តថាវិធា ។

[៦៦៩] បជាហមស្មិ នរបមុខានមិស្សរោ
សចេបិ កុជ្ឈាមិ ឋបេមិ អត្តនំ
និសេធយន្តោ ជនតំ តថាវិធំ
បណេមិ ទណ្ឌំ អនុកម្ប យោនិសោ ។

[៦៧០] សិរី ច លក្ខី ច តវេវ ខត្តិយ
ជនាធិប មា វិជហិ កុទាចនំ
អក្កោធនោ និច្ចបសន្នចិត្តោ
អនីឃោ តុវំ វស្សសតានិ បាលយ ។



(៦៦៧) ពួកក្សត្រណា ជាបុគ្គលមិនពិចារណាសិនហើយធ្វើ ជាអ្នកជ្រប់នៅដោយកិលេស ប្រញាប់ដាក់ទណ្ឌកម្មដល់អ្នកដទៃ ដោយស្រហន់ ពួកក្សត្រនោះ រមែងជាអ្នកប្រកប ដោយពាក្យតិះដៀល លះបង់ជីវិតចេញផុត អំពីលោកនេះទៅ រមែងទៅកាន់ទុគ្គតិ ។

(៦៦៨) បុគ្គលពួកណា ត្រេកអរក្នុងធម៌ ដែលព្រះអរិយៈសំដែងហើយ បុគ្គលពួកនោះ ជាអ្នកប្រសើរដោយកាយកម្ម វចីកម្ម និងមនោកម្ម ពួកបុគ្គលបែបនោះ ជាអ្នកឋិតនៅ ក្នុងខន្តិ សោរច្ចៈនិងសមាធិ រមែងទៅកាន់លោកទាំងពីរ គឺមនុស្សលោកនិងទេវលោក ។

(៦៦៩) ខ្ញុំនេះឯង ជាស្ដេចធំ លើពួកជនប្រុសស្រី បើយើងខឹង យើងទប់ខ្លួន យើងហាមឃាត់នូវប្រជុំជនបែបនោះ ហើយដាក់អាជ្ញាដោយឧបាយប្រាជ្ញា ព្រោះអនុគ្រោះ ។

(៦៧០) (ទេវតាពោល ទូលថា) បពិត្រក្សត្រិយ៍ ជាធំជាងជន សិរី គឺបរិវារសម្បត្តិនិងប្រាជ្ញា កុំលះបង់ព្រះអង្គ ក្នុងកាលណាៗ ឡើយ សូមព្រះអង្គជាបុគ្គលមិនក្រោធ មានចិត្តជ្រះថ្លាជានិច្ច ជាអ្នកមិនមានទុក្ខ ហើយថែរក្សាផែនដី ឲ្យអស់រយឆ្នាំ ។

(៤៨១) គុណេហិ ឯតេហិ ឧបេហិ ខត្តិយ
ឋិតមរិយវត្តិ សុវចោ អកោធនោ
សុខី អនុប្បីឡ បសាស មេទនី
ឥតោ វិមុត្តោបិ វជាហិ សុគ្គតិំ

(៤៨២) ឯវំ សុនីតេន សុភាសិតេន
ធម្មេន ញាយេន ឧបាយសោ នយំ
និព្វាបយេ សង្ខុភិតំ មហាជនំ
មហាវ មេឃោ សលិលេន មេទនិំ ។

សុមង្គលជាតកំ ចតុត្ថំ ។

## គង្គមាលជាតកំ

(៤៨៣) អង្គារជាតា បថវី — កុក្កុឡានុគតា មហី
អថ គាយសិ វត្តានិ — ន តំ តបតិ អាតបោ ។
ឧទ្ធំ តបតិ អាទិច្ចោ — អធោ តបតិ វាលុកា
អថ គាយសិ វត្តានិ — ន តំ តបតិ អាតបោ ។



(៤៨១) បពិត្រក្សត្រិយ៍ សូមព្រះអង្គទ្រង់ប្រកបដោយគុណទាំងឡាយនុ៎ះ សូមឲ្យព្រះអង្គឋិតនៅមាំ ក្នុងការប្រព្រឹត្តដ៏ប្រសើរ ជាបុគ្គលប្រយ័ត្នកាយ មិនមានសេចក្ដីក្រោធ ជាបុគ្គលបានសេចក្ដីសុខ កុំបៀតបៀនសត្វ ហើយគ្រប់គ្រងផែនដី លុះព្រះអង្គចេញផុតអំពីលោកនេះទៅ សូមឲ្យស្ដេចយាងទៅកាន់សុគតិ ។

(៤៨២) ស្ដេចទ្រង់ធម៌ តែងប្រើឧបាយណែនាំពួកជន ដោយពាក្យជាសុភាសិត ជាគ្រឿងណែនាំដ៏ល្អ តាមហេតុដ៏ប្រកបដោយធម៌ ហើយញុំាងមហាជន ដែលរើបរើ ឲ្យត្រជាក់ស្រួល ដូចជាមហាមេឃ ដែលញុំាងផែនដី ឲ្យត្រជាក់ដោយទឹក ។

ចប់ សុមង្គលជាតក ទី ៤ ។

## គង្គមាលជាតក

(៤៨៣) (ស្ដេចទ្រង់ត្រាស់សួរគតិកបុរោហិត) ប្រថពី ជាផែនដីក្ដៅ ដូចរងើកភ្លើង ប្រកបដោយដីខ្សាច់ (ក្ដៅ) ដូចផេះ (ដែលភ្លើងឆេះ) អ្នកច្រៀងនូវចំនុកទាំងឡាយ កំដៅថ្ងៃ មិនដុតកំដៅអ្នកទេឬ ។ ព្រះអាទិត្យក្ដៅខាងលើ ដីខ្សាច់ក្ដៅខាងក្រោម អ្នកច្រៀងនូវចំនុកទាំងឡាយ កំដៅថ្ងៃ មិនដុតកំដៅអ្នកទេឬ ។

(៤៨៤) ន មំ តបតិ អាតបោ  អាតបា តបយន្តិ មំ
អត្ថា ហិ វិវិធា រាជ  តេ តបន្តិ ន អាតបោ ។

(៤៨៥) អទ្ទសំ កាម តេ មូលំ  សង្កប្បា កាម ជាយសិ
ន តំ សង្កប្បយិស្សាមិ  ឯវំ កាម ន ហេហិសិ ។

(៤៨៦) អប្បាបិ កាមា ន អលំ  ពហូហិបិ ន តប្បតិ
អហោ ពាលាន លបតា(១) បដិវិជ្ឈេថ ជគ្គតោ ។

(៤៨៧) អប្បស្ស កម្មស្ស ផលំ មមេទំ
ឧទយោ អជ្ឈគមា មហត្តបត្តំ
សុលទ្ធលាភោ វត មាណវស្ស
យោ បព្វជិ កាមរាគំ បហាយ ។

(៤៨៨) តបសា បជហន្តិ បាបកម្មំ
តបសា ន្ហាបិតកុម្ភការភាវំ(២)
តបសា អភិភុយ្យ គង្គមាល
នាមេនាលបសិជ្ជ ព្រហ្មទត្តំ ។

---

១ ម. អហោ ពាលលបនា ។ ម. អសោតា ពាលលាបនា ។ ២ កុម្ភការត្តំ ។ អន្តរាយិយំ ។



(៤៨៤) (កប្បកបុរស ក្រាបទូលថា) កំដៅថ្ងៃ មិនដុតកំដៅខ្ញុំព្រះអង្គទេ កំដៅគឺកាមទាំងឡាយ ទើបញ៉ាំងខ្ញុំព្រះអង្គឲ្យក្តៅបាន បពិត្រព្រះរាជា ប្រយោជន៍ទាំងឡាយ មានប្រការផ្សេងៗ ប្រយោជន៍ទាំងនោះ តែងដុតកំដៅ ឯកំដៅថ្ងៃ មិនដុតកំដៅទេ ។

(៤៨៥) ម្នាលកាម យើងបានឃើញឫសគល់ របស់អ្នកហើយ ម្នាលកាម អ្នកកើតអំពីសេចក្តីត្រិះរិះ យើងនឹងលែងត្រិះរិះអ្នកទៀតហើយ ម្នាលកាម កាលបើយ៉ាងនេះ អ្នកនឹងមិនកើតបាន (តទៅទៀតទេ)។

(៤៨៦) កាមទាំងឡាយ សូម្បីតិច ក៏នៅតែមិនល្មម សូម្បីច្រើន ក៏នៅតែមិនស្កប់ស្កល់ ។ គួរសើចពេក ឱការបរបារបស់ពួកជនពាល បុគ្គលល្អតែប្រឹងប្រែងបញ្ញាយាម ទើបត្រាស់ដឹងបាន ។

(៤៨៧) (ព្រះរាជាឧទយៈត្រាស់ថា) នេះជាផលកម្ម មានប្រមាណតិច របស់យើង ឧទយៈ បានសម្រេចនូវភាពជាធំ ឱហ្ន៎ មាណពណា បានលះនូវតម្រេក គឺកាមហើយបួស មាណពនោះ ឈ្មោះថា បានល្អហើយ ។

(៤៨៨) (ព្រះរាជមាតា ត្រាស់សួរថា) ពួកសត្វតែងលះបង់នូវបាបកម្ម (របស់ខ្លួន) ដោយតបៈ លះបង់នូវភាពនៃខ្លួនជាត្មាន់ព្រះកេសនិងស្មូនឆ្នាំង ដោយតបៈ តែគង្គមាល ក្នុងថ្ងៃនេះអ្នកហ៊ានហៅលោក ហៅព្រហ្មទត្ត(កូនអញ) ដោយចំឈ្មោះ ព្រោះតែមានតបៈឬ ។

(៦៥៩) សម្ពិដ្ឋិតាមេវ អម្ពំ បស្សថ
ខន្តិសោរច្ចស្ស យោ វិធាតោ
សោ សព្វជនស្ស វន្ទិតោ អហុ
តំ វន្ទាម សកជិកា សមត្ថា ។

(៦៦០) មា កិញ្ចិ អវចុត្ថ គន្ធមាលំ
ឫចិចិ ហោឆបថេសុ សិក្ខមានំ
ឯសោ ហិ អតរិ អណ្ណវំ
យំ តរិត្វា វិចរន្តិ វីតសោកាតិ ។

គន្ធមាលជាតកំ បញ្ចមំ ។

## ចេតិយរាជជាតកំ

(៦៦១) ធម្មោ ហវេ ហតោ ហន្តិ នាហតោ ហន្តិ កិញ្ចិនំ
តស្មា ហិ ធម្មំ ន ហានេ មា តំ ធម្មោ ហតោ ហនិ ។



(៦៥៩) (ព្រះកជាប្រទីត្រាស់ថា) បពិត្រព្រះមាតា សូមទ្រង់ទតនូវផលនៃខន្តិ និងសោរច្ចៈ ដែលកាចឃើញជាក់ច្បាស់ ដោយខ្លួនឯង (ក្នុងបច្ចុប្បន្ន) ព្រះគន្ធមាលបច្ចេកពុទ្ធនោះ ជាបុគ្គលដែលជនទាំងអស់គួរថ្វាយបង្គំ យើងព្រមទាំងស្តេចនិងអាមាត្យ នាំគ្នាថ្វាយបង្គំនូវព្រះបច្ចេកពុទ្ធនោះ ។

(៦៦០) អ្នកទាំងឡាយ កុំនិយាយពាក្យតិចតួច នឹងព្រះបច្ចេកពុទ្ធឈ្មោះគន្ធមាល ដែលជាអ្នកសិក្សាក្នុងគន្លងនៃប្រាជ្ញ របស់ពួកអ្នកប្រាជ្ញឡើយ ព្រោះថា ព្រះបច្ចេកពុទ្ធនេះ បានឆ្លងនូវអន្លង់គឺវដ្ដសង្សារ ដែលពួកបុគ្គលអ្នកប្រាសចាកសោក តែងឆ្លងហើយត្រាច់ទៅ ។

ចប់ គន្ធមាលជាតក ទី ៥ ។

## ចេតិយរាជជាតក

(៦៦១) (តាបសនិយាយថា) (១)ធម៌ដែលបុគ្គលសម្លាប់ហើយ រមែងសម្លាប់វិញដោយពិត ធម៌ដែលបុគ្គលមិនបានសម្លាប់ រមែងមិនសម្លាប់វិញតិចតួចឡើយ ។ ព្រោះហេតុនោះ ព្រះអង្គមិនគួរសម្លាប់ធម៌ ព្រះអង្គកុំឲ្យធម៌ដែលព្រះអង្គសម្លាប់ហើយ ត្រឡប់សម្លាប់ព្រះអង្គវិញបានឡើយ ។

---

(១) ក្នុងទីនេះ សំដៅយកសេចក្ដីពិតឈ្មោះធម៌ា អដ្ឋកថា ។

(៤៦៦) អលិកំ ភាសមានស្ស អបក្កមន្តិ ទេវតា
បូតិកញ្ច មុខំ វាតិ សកដ្ឋានា ច ធំសតិ
យោ ជានំ បុច្ឆិតោ បញ្ហំ អញ្ញថា នំ វិយាករេ
សចេ ហិ សច្ចំ ភណសិ ហោហិ រាជ យថា បុរេ
មុសា ចេ ភាសសេ រាជ ភូមិយំ តិដ្ឋ ចេតិយ ។

(៤៦៧) អកាលេ វស្សតី តស្ស កាលេ តស្ស ន វស្សតិ
យោ ជានំ បុច្ឆិតោ បញ្ហំ អញ្ញថា នំ វិយាករេ
សចេ ហិ សច្ចំ ភណសិ ហោហិ រាជ យថា បុរេ
មុសា ចេ ភាសសេ រាជ ភូមឹ បវិស ចេតិយ ។



(៤៦៦) កាលបើស្តេច ពោលពាក្យកុហក ពួកទេវតា រមែងគេចចេញ (លែងរក្សា) ស្តេចណាជ្រាប កាលគេសួរប្រស្នា ហើយព្យាករប្រស្នានោះ ដោយប្រការដទៃវិញ ព្រះឱស្ឋស្តេចនោះ រមែងមានក្លិនស្អុយ ផ្សាយចេញទៅ តាំងស្តេចនោះទៀត រមែងឃ្លាតចាកកន្លែងរបស់ខ្លួន បពិត្រព្រះរាជា បើប្រសិនជា ព្រះអង្គទ្រង់ពោលពាក្យពិត សូមឱ្យព្រះអង្គឋិតនៅដូចដើម បពិត្រព្រះបាទចេតិយៈ បើព្រះអង្គទ្រង់ពោលពាក្យកុហក សូមឱ្យព្រះអង្គឋិតនៅលើផែនដី ។

(៤៦៧) ស្តេចណាជ្រាប កាលគេសួរប្រស្នាហើយ ក៏ព្យាករប្រស្នានោះ ដោយប្រការដទៃវិញ ភ្លៀងរមែងធ្លាក់ចុះ ក្នុងកាលមិនគួរ (ក្នុងដែន) របស់ស្តេចនោះ ភ្លៀងរមែងមិនធ្លាក់ចុះ ក្នុងកាលគួរ (ក្នុងដែនរបស់ស្តេចនោះ) បពិត្រព្រះរាជា បើព្រះអង្គទ្រង់ពោលនូវពាក្យពិត សូមឱ្យព្រះអង្គទ្រង់ឋិតនៅដូចដើម បពិត្រព្រះបាទចេតិយៈ បើព្រះអង្គទ្រង់ពោលពាក្យកុហក សូមឱ្យព្រះអង្គចូលទៅកាន់ផែនដី (ត្រឹមព្រះជាណុ) ។

(៤៦៤) ជិវ្ហា តស្ស ទ្វិធា ហោតិ   ឧរគស្សេវ ទិសម្បតិ
យោ ជានំ បុច្ឆិតោ បញ្ហំ   អញ្ញថា នំ វិយាករេ
សចេ ហិ សច្ចំ ភណសិ   ហោហិ រាជ យថា បុរេ
មុសា ចេ ភាសសេ រាជ   ភិយ្យោ បវិស ចេតិយ ។

(៤៦៥) ជិវ្ហា តស្ស ន ភវតិ   មច្ឆស្សេវ ទិសម្បតិ
យោ ជានំ បុច្ឆិតោ បញ្ហំ   អញ្ញថា នំ វិយាករេ
សចេ ហិ សច្ចំ ភណសិ   ហោហិ រាជ យថា បុរេ
មុសា ចេ ភាសសេ រាជ   ភិយ្យោ បវិស ចេតិយ ។

(៤៦៦) ធីតរោ តស្ស ជាយន្តិ   ន បុត្តា ជាយរេ កុលេ
យោ ជានំ បុច្ឆិតោ បញ្ហំ   អញ្ញថា នំ វិយាករេ
សចេ ហិ សច្ចំ ភណសិ   ហោហិ រាជ យថា បុរេ
មុសា ចេ ភាសសេ រាជ   ភិយ្យោ បវិស ចេតិយ ។



(៤៦៤) បពិត្រព្រះអង្គជាធំក្នុងទិស ស្ដេចណាជ្រាប កាលគេសួរប្រស្នាហើយ ក៏ព្យាករប្រស្នានោះ ដោយប្រការដទៃវិញ អណ្ដាតរបស់ស្ដេចនោះ រមែងបែកជាពីរ ដូចជាអណ្ដាតនៃពស់ បពិត្រព្រះរាជា បើព្រះអង្គទ្រង់ពោលពាក្យពិត សូមឲ្យព្រះអង្គឋិតនៅដូចដើម បពិត្រព្រះបាទចេតិយៈ បើព្រះអង្គទ្រង់ពោលពាក្យកុហក សូមឲ្យព្រះអង្គចូលទៅកាន់ផែនដីក្រៃលែង (ជាន់នេះ គឺត្រឹមចង្កេះ)។

(៤៦៥) បពិត្រព្រះអង្គជាធំក្នុងទិស ស្ដេចណាជ្រាប កាលគេសួរប្រស្នាហើយ ក៏ព្យាករប្រស្នានោះ ដោយប្រការដទៃវិញ ស្ដេចនោះមិនមានអណ្ដាត ដូចត្រី បពិត្រព្រះរាជា បើព្រះអង្គទ្រង់ពោលពាក្យពិត សូមឲ្យព្រះអង្គទ្រង់ឋិតនៅដូចដើម បពិត្រព្រះបាទចេតិយៈ បើព្រះអង្គទ្រង់ពោលពាក្យកុហក សូមឲ្យព្រះអង្គ ចូលទៅកាន់ផែនដីក្រៃលែង (ជាន់នេះ គឺត្រឹមផ្ចិត) ។

(៤៦៦) ស្ដេចណាជ្រាប កាលគេសួរប្រស្នាហើយ ក៏ព្យាករប្រស្នានោះ ដោយប្រការដទៃវិញ ក្នុងត្រកូលស្ដេចនោះកើតតែកូនស្រី កូនប្រុសមិនកើតទេ បពិត្រព្រះរាជា បើព្រះអង្គទ្រង់ពោលពាក្យពិត សូមឲ្យព្រះអង្គទ្រង់ឋិតនៅដូចដើម បពិត្រព្រះបាទចេតិយៈ បើព្រះអង្គទ្រង់ពោលពាក្យកុហក សូមឲ្យព្រះអង្គ ចូលទៅកាន់ផែនដីក្រៃលែង (ជាន់នេះ គឺត្រឹមដោះ) ។

(៤៦៧) បុត្តា តស្ស ន ភវន្តិ បក្កមន្តិ ទិសោទិសំ
យោ ជានំ បុច្ឆិតោ បញ្ហំ អញ្ញថា នំ វិយាករេ
សចេ ហិ សច្ចំ ភណសិ ហោហិ រាជ យថា បុរេ
មុសា ចេ ភាសសេ រាជ ភិយ្យោ បវិស ចេតិយ ។

(៤៦៨) ស រាជា ឥសិនា(១) សត្តោ អន្តលិក្ខចរោ បុរេ
បាវេក្ខិ បឋវឹ ចេច្ចោ ហីនត្តោ អត្តបរិយាយំ(២)
តស្មា ហិ ឆន្ទាគមនំ នប្បសំសន្តិ បណ្ឌិតា
អទុដ្ឋចិត្តោ ភាសេយ្យ គិរំ សច្ចូបសញ្ហិតន្តិ ។

ចេតិយរាជជាតកំ ឆដ្ឋំ ។

## ឥន្ទ្រិយជាតកំ

(៤៦៩) យោ ឥន្ទ្រិយានំ កាមេន វសំ នារទ គច្ឆតិ
សោ បរិច្ចជ្ជុភោ លោកេ ជីវន្តោវ វិសុស្សតិ ។

---

១ ឱ. ឥសិត ។ ២ ឱ. បត្តបរិយាយំ ។ ម. បត្តបរិយាយំ ។



(៤៦៧) ស្តេចណាត្រាស់ កាលគេសួរប្រស្នាហើយ ក៏ព្យាករប្រស្នានោះ ដោយប្រការដទៃវិញ កូនប្រុសរបស់ស្តេចនោះ រមែងមិនមានឡើយ បើជាមាន រមែងគេចចេញទៅកាន់ទិសតូចទិសធំបាត់អស់ បពិត្រព្រះរាជា បើព្រះអង្គទ្រង់ពោលពាក្យពិត សូមឲ្យព្រះអង្គទ្រង់ឋិតនៅដូចដើម បពិត្រព្រះចេតិយៈ បើព្រះអង្គ ទ្រង់ពោលពាក្យកុហក សូមឲ្យព្រះអង្គ ចូលទៅកាន់ផែនដីក្រៃលែង (ជាងនេះទៅទៀត គឺលិចផុត) ។

(៤៦៨) (អភិសម្ពុទ្ធគាថា) ស្តេចនោះ កាលពីដើមត្រាច់ទៅ ក្នុងអាកាសបាន (ដល់មកខាងក្រោយ) ត្រូវឥសីផ្តាសាហើយ ក៏ប្រែជាមាន សភាពសាបសូន្យ ដល់នូវរបស់ខ្លួន ចូលទៅកាន់ផែនដី ព្រោះហេតុនោះ អ្នកប្រាជ្ញទាំងឡាយ ទើបមិនសរសើរ នូវការលុះក្នុងអំណាចនៃសេចក្តីប្រាថ្នា បុគ្គលគួរជាអ្នកមានចិត្ត មិនប្រទូស្ត ហើយពោលនូវពាក្យ ដ៏ប្រកបដោយសច្ចៈ ។

ចប់ ចេតិយរាជជាតក ទី ៦ ។

## ឥន្ទ្រិយជាតក

(៤៦៩) (ព្រះឈ្មោះសរភង្គ ពោលថា) ម្នាលនារទៈ បុគ្គលណាលុះអំណាចនៃឥន្ទ្រិយទាំងឡាយ ព្រោះកាម បុគ្គលនោះលះបង់នូវលោកទាំងពីរ (ហើយកើតក្នុងនរក) សូម្បីរស់នៅ រមែងរីងស្ងួត ។

(៦៧០) សុខស្សានន្តរំ ទុក្ខំ   ទុក្ខស្សានន្តរំ សុខំ
សោសិ បត្តោ សុខទុក្ខំ   បាដិកង្ខ វរំ សុខំ ។

(៦៧១) កិច្ចកាលេ កិច្ចសហោ   យោ កិច្ចំ នាតិវត្តតិ
ស កិច្ចន្តំ សុខំ ឯធេ   យោគំ សមធិគច្ឆតិ ។

(៦៧២) ន ហេវ កាមានំ កាមា   នានត្ថា នត្ថការណា
ន កតញ្ច និវត្តេតិ   ធម្មា ចវិតុមរហសិ ។

(៦៧៣) ទក្ខំ គហបតិ សាធុ   សំវិភជ្ជញ្ច ភោជនំ
អហាសោ អត្ថលាភេសុ   អត្ថព្យាបត្តិ អព្យថោ ។

(៦៧៤) ឯត្តាវតេតំ បណ្ឌិច្ចំ   អសិតោ ទេវលោ ព្រវិ
ន យិតោ កិញ្ចិ បាបិយោ   ឥន្ទ្រិយានំ វសំ វជេ ។



(៦៧០) ទុក្ខជាលំដាប់នៃសុខ សុខលំដាប់នៃទុក្ខ សូមអ្នកដល់នូវទុក្ខ ព្រោះសាបសូន្យចាកឈានសុខ ក៏ដោយ អ្នកចូរប្រាថ្នានូវសុខដ៏ប្រសើរវិញចុះ ។

(៦៧១) បុគ្គលណា ជាអ្នកអត់ទ្រាំនូវសេចក្តីលំបាក ក្នុងវេលាមានលំបាក មិនប្រព្រឹត្តកន្លងនូវសេចក្តីលំបាក បុគ្គលនោះជាអ្នកប្រាជ្ញ រមែងដល់នូវសេចក្តីសុខ ជាទីបំផុត នៃសេចក្តីលំបាក ដែលកើតអំពីសេចក្តីព្យាយាម ។

(៦៧២) ខ្លួនអ្នក មិនគួរឃ្លៀងឃ្លាតចាកធម៌ ព្រោះការប្រាថ្នាកាម ព្រោះការវិនាស ព្រោះហេតុនៃប្រយោជន៍ ទាំងព្រោះលះបង់ឈាន ដែលខ្លួនធ្វើបានហើយទេ ។

(៦៧៣) (កាលទៅរកតបស ពោលថា) សេចក្តីឈ្លាសវៃ១ ការចែករំលែកភោជន១ មិនរីករាយក្នុងការបាន នូវប្រយោជន៍១ មិនលំបាកចិត្តក្នុងការវិនាសចាកប្រយោជន៍ (នេះ) ជាការប្រពៃរបស់គ្រហស្ថ ។

(៦៧៤) (អកិសមុទ្ទតាថា) អសិតទេវលតាបស បានពោលនូវភាពនៃបុគ្គលជាបណ្ឌិតនុ៎ះ ដោយហេតុមានប្រមាណប៉ុណ្ណេះថា មិនមានបុគ្គលណាមួយ ដែលលាមកជាងបុគ្គល ជាអ្នកលុះអំណាចនៃឥន្ទ្រិយទាំងឡាយនេះឡើយ ។

(៤៧៥)អមិត្តានំ ហត្ថត្ថំ សយំ បប្បោតិ មារិវ
កម្មំ វិជ្ជញ្ច ទក្ខេយ្យំ វិវាហំ សីលមទ្ទវំ
ឯតេ ច យសេ ហាបេត្វា និព្វត្តោ សេហិ កម្មេហិ ។
(៤៧៦)សោហំ សហស្សជីនោវ អពន្ធុ អបរាយណោ
អរិយធម្មា អបក្កន្តោ យថា បេតោ តថេវហំ ។
(៤៧៧)សុខកាមេ ទុក្ខាបេត្វា អាបន្នោស្មិ បទំ ឥមំ
សោ សុខំ នាធិគច្ឆាមិ ឋិតោ ភាណុម(១)តាមិវ ។

ឥន្ទ្រិយជាតកំ សត្តមំ ។

## អាទិត្តជាតកំ

(៤៧៨)អាទិត្តស្មឹ អគារស្មឹ យំ នីហរតិ ភាជនំ
តំ តស្ស ហោតិ អត្ថាយ នោ ច យំ តត្ថ ឌយ្ហតិ ។

១ ឱ. ម. ភាណុមតាមិវ ។



(៤៧៥) (មនុស្សប្រេត និយាយថា) បពិត្រព្រះបាទសិវិ បុគ្គលប្រាកដស្មើនឹងខ្ញុំ រមែងដល់នូវសេចក្តីវិនាស (ដោយអំពើរបស់ខ្លួន) ដូចបុគ្គលដល់នូវសេចក្តីវិនាស ក្នុងកណ្តាប់ដៃ នៃសត្រូវ ខ្ញុំព្រោះតែញុំាងយសទាំងនេះ គឺ កសិកម្ម វិជ្ជា ការជាអ្នកឈ្លាសវៃ វិវាហមង្គល សីល និងការនៃចិត្តទន់ ឲ្យសាបសូន្យ ទើបមកកើត (ជាមនុស្សប្រេត) ដោយអំពើរបស់ខ្លួន ។

(៤៧៦) ខ្ញុំនោះ ជាបុគ្គលមិនមានផៅពង្ស មិនមានទីពឹងទៅ ដូចគេសាបសូន្យ ចាកទ្រព្យរាប់ពាន់ ខ្ញុំ ជាអ្នកប្រាសចាកអរិយធម៌ ដូចប្រេត ។

(៤៧៧) ខ្ញុំ ញុំាងពួកសត្វ ដែលជាអ្នកប្រាថ្នានូវសុខ ឲ្យដល់នូវទុក្ខ ទើបដល់នូវតំណែងនេះ ខ្ញុំនោះ មិនបាននូវសេចក្តីសុខទេឡើយ ឋិតនៅ (ទាំងក្តៅក្រហាយ) ដូចគេកាយ ដោយរងើកភ្លើង ។

ចប់ ឥន្ទ្រិយជាតក ទី ៧ ។

## អាទិត្តជាតក

(៤៧៨) (ព្រះបច្ចេកពុទ្ធជាសង្ឃត្ថេរ សំដែងថា) កាលបើផ្ទះក្តៅភ្លើងឆេះ ហើយ បុគ្គលនាំចេញនូវភាជន៍ណាបាន ភាជន៍នោះ រមែងបានជាប្រយោជន៍ នៃបុគ្គលនោះ ភាជន៍ណា ដែលភ្លើងឆេះក្នុងផ្ទះនោះ ភាជន៍នោះ មិនបានជាប្រយោជន៍ នៃបុគ្គលនោះទេឡើយ ។

(៤៧៩) ឯវមាទិបិតោ លោកោ ជរាយ មរណេន ច
នីហរេថេវ ទានេន ទិន្នំ ហោតិ សុនីហតំ ។

(៤៨០) យោ ធម្មលទ្ធស្ស ទទាតិ ទានំ
ឧដ្ឋានវីរិយាធិគតស្ស ជន្តុ
អតិក្កម្ម សោ វេតរណឹ យមស្ស
ទិព្វានិ ឋានានិ ឧបេតិ មច្ចោ ។

(៤៨១) ទានញ្ច យុទ្ធញ្ច សមានមាហុ
អប្បាបិ សន្តា ពហុកេ ជិនន្តិ
អប្បម្បិ ចេ សទ្ទហានោ ទទាតិ
តេនេវ សោ ហោតិ សុខី បរត្ថ ។

(៤៨២) វិចេយ្យ ទានំ សុគតប្បសត្ថំ
យេ ទក្ខិណេយ្យា ឥធ ជីវលោកេ
ឯតេសុ ទិន្នានិ មហប្ផលានិ
ពីជានិ វុត្តានិ យថា សុខេត្តេ ។





(៤៧៩) សត្វលោក កាលបើត្រូវជរា និងមរណៈឆេះ យ៉ាងនេះហើយ បុគ្គលគួរតែនាំចេញនូវទ្រព្យ ដោយការឲ្យទាន (ព្រោះ) ទ្រព្យដែលបុគ្គលបានឲ្យហើយ ឈ្មោះថា នាំចេញហើយ ដោយប្រពៃ ។

(៤៨០) (ព្រះបរមគ្រូ ទ្រង់សរសើរដែលថា) សត្វណា បានឲ្យទានដល់បុគ្គលអ្នកបានធម៌ បានព្រោះធម៌ ដោយសេចក្តីព្យាយាម គឺការប្រឹងប្រែង សត្វនោះ រមែងប្រព្រឹត្តកន្លងនូវវេតរណី របស់យមៈ (នរក) បាន ហើយចូលទៅកាន់ទីតាំងទិព្វយ៉ាងពិត ។

(៤៨១) អ្នកប្រាជ្ញទាំងឡាយ ពោលថា ទាននិងចម្បាំង ជារបស់ស្មើគ្នា ពួកជនសូម្បីតិចគ្នា តែជាអ្នកស៊ូលះបង់ជីវិត រមែងឈ្នះជនច្រើនបាន បុគ្គលណា កាលបើជឿហើយឲ្យទាន សូម្បីបន្តិចបន្តួច បុគ្គលនោះ រមែងបាននូវសេចក្តីសុខ ក្នុងលោកខាងមុខ ដោយហេតុតែទានប្រមាណតិចនោះ ។

(៤៨២) ការពិចារណាសិនហើយទើបឲ្យ ព្រះសុគតទ្រង់សរសើរហើយ ពួកទក្ខិណេយ្យបុគ្គលណា មាននៅក្នុងជីវលោកនេះ ទានដែលបុគ្គលឲ្យហើយ ដល់ពួកទក្ខិណេយ្យបុគ្គលទាំងនេះ មានផលច្រើន ដូចជាពូជ ដែលគេសាបព្រោះ ក្នុងស្រែដ៏ល្អ ។

(៤៨៣) យោ បាណភូតានិ អហេឋយំ ចរំ
បរូបឃាតា ន ករោតិ បាបំ
ភីរុំ បសំសន្តិ ន តត្ថ សូរំ
ភយា ហិ សន្តោ ន ករោន្តិ បាបំ ។

(៤៨៤) ហីនេន ព្រហ្មចរិយេន ខត្តិយេ ឧបបជ្ជតិ
មជ្ឈិមេន ច ទេវត្តំ ឧត្តមេន វិសុជ្ឈតិ ។

(៤៨៥) អទ្ធា ហិ ទានំ ពហុធា បសត្ថំ
ទានា ច ខោ ធម្មបទំវ សេយ្យោ
បុព្វេវ ហិ បុព្វតរេ ច សន្តោ
និព្វានមេវជ្ឈគមុំ សបញ្ញាតិ ។

អាទិត្តជាតកំ អដ្ឋមំ ។

## អដ្ឋានជាតកំ

(៤៨៦) គង្គា កុមុទិនី សន្តា សង្ខវណ្ណា ច កោកិលា
ជម្ពុ តាលផលំ ទជ្ជា អថ នូន តទា សិយា ។



(៤៨៣) បុគ្គលណា មិនបៀតបៀនសត្វ មិនធ្វើនូវបាប ព្រោះ (ខ្លាច) ការតិះដៀល អំពីអ្នកដទៃ អ្នកប្រាជ្ញទាំងឡាយ តែងសរសើរនូវបុគ្គលអ្នកខ្លាចបាប មិនសរសើរនូវបុគ្គលអ្នកក្លៀវក្លា ក្នុងការធ្វើបាបនោះឡើយ ដ្បិតសប្បុរសទាំងឡាយ តែងមិនធ្វើបាប ព្រោះខ្លាច (ពាក្យតំណោះដំណៀលរបស់គេ) ។

(៤៨៤) បុគ្គលចូលទៅកើត ក្នុងពួកក្សត្រិយ៍ ដោយព្រហ្មចរិយធម៌ដ៏ថោកទាប បុគ្គលចូលទៅកាន់ភាពជាទេវតា ដោយព្រហ្មចរិយធម៌ជាកណ្ដាល បុគ្គលបរិសុទ្ធ ដោយព្រហ្មចរិយធម៌ ដ៏ឧត្តម ។

(៤៨៥) ការឲ្យទាន ពិតជាអ្នកប្រាជ្ញសរសើរ ដោយចំណែកច្រើនក៏មែនហើយ តែថា ចំណែកធម៌ប៉ុណ្ណោះ ប្រសើរជាងទាន ព្រោះពួកសប្បុរសអ្នកមានប្រាជ្ញា ក្នុងកាលមុន និងកាលមុនទៅទៀត បានត្រាស់ដឹង នូវនិព្វានធម៌ ។

ចប់ អាទិត្តជាតក ទី ៨ ។

## អដ្ឋានជាតក

(៤៨៦) (មហាធនកាបស និយាយថា) ក្នុងកាលណា ទន្លេគង្គា ប្រែជាមានផ្កាកុមុទ ទាំងមានទឹកនឹង សត្វតាវ៉ៅ ប្រែជាមានសម្បុរដូចស័ង្ខ ដើមព្រីង ប្រែជាបញ្ចេញផ្លែត្នោត កាលបើហេតុទាំងនេះ ទើប (យើងនិងនាង) បានជួបគ្នា ក្នុងកាលនោះ ដោយពិត ។

(៦៨៧)យទា កច្ឆបលោមានំ    បាវារោ តិវិធោ សិយា

ហេមន្តិកំ បាវុរណំ    អថ នូន តទា សិយា ។

(១)

(៦៨៨)យទា មកសទាឋានំ    អដ្ដាលោ សុកតោ សិយា

ទឡ្ហោ ច អវិកម្បី ច    អថ នូន តទា សិយា ។

(៦៨៩)យទា សសវិសាណានំ    និស្សេណី សុកតា សិយា

សគ្គស្សារោហណត្ថាយ    អថ នូន តទា សិយា ។

(៦៩០)យទា និស្សេណិមារុយ្ហ    ចន្ទំ ខាទេយ្យុំ មូសិកា

(២)

រាហុញ្ច បរិបាតេយ្យុំ    អថ នូន តទា សិយា ។

(៦៩១)យទា សុរាឃដំ បិត្វា    មក្ខិកា គណចារិនី

អង្គារេ វាសំ កប្បេយ្យុំ    អថ នូន តទា សិយា ។

---

១ ម. មកសទាឋានំ ។ ២ ម. ឱ. បវិបាតយេយ្យុំ ។



(៦៨៧) ក្នុងកាលណា សំពត់បាវារៈ ៣ យ៉ាង គឺសំពត់ដែលធ្វើដោយ ផ្កាស្រកាអណ្ដើក ១ សំពត់ដែលធ្វើដោយប៉ុយ ១ សំពត់ដែល ធ្វើដោយលាយគ្នាទាំងពីរមុខ ១ ប្រែជាសំពត់សម្រាប់ដណ្ដប់ ក្នុង រដូវរងាបាន កាលបើយ៉ាងនេះ ទើប (យើងនឹងបាន) បានជួបគ្នា ក្នុងកាលនោះ ដោយពិត ។

(៦៨៨) ក្នុងកាលណា គេយកជើងសត្វមូសទាំងឡាយ មកធ្វើជាប៉ម យ៉ាងល្អខ្ជាប់ មិនឱ្យកក្រើកបាន កាលបើយ៉ាងនេះ ទើប (យើង នឹងបាន) បានជួបគ្នា ក្នុងកាលនោះ ដោយពិត ។

(៦៨៩) ក្នុងកាលណា គេយកស្នែងទន្សាយ មកធ្វើជាជណ្ដើរ សម្រាប់ ឡើងកាន់ឋានសួគ៌បាន កាលបើយ៉ាងនេះ ទើប (យើងនឹងបាន) បានជួបគ្នា ក្នុងកាលនោះ ដោយពិត ។

(៦៩០) ក្នុងកាលណា ពួកកណ្ដុរ ឡើងតាមជណ្ដើរទៅទំពាស៊ី នូវ ដួងព្រះចន្ទ ទាំងដេញរាហូឱ្យធ្លាក់ទៅបាន កាលបើយ៉ាងនេះ ទើប (យើងនឹងបាន) បានជួបគ្នា ក្នុងកាលនោះ ដោយពិត ។

(៦៩១) ក្នុងកាលណា ពួករុយ ហើរទៅជាហ្វូង ក្រេបផឹកនូវស្រាក្នុងក្អម ហើយសម្រេចការនៅ ក្នុងរងើកភ្លើងបាន កាលបើយ៉ាងនេះ ទើប (យើងនឹងបាន) បានជួបគ្នា ក្នុងកាលនោះ ដោយពិត ។

(៤៩២) យទា ពិម្ពោដ្ឋសម្បន្នោ គទ្រភោ សុមុខោ សិយា
កុសលោ នច្ចគីតស្ស អថ នូន តទា សិយា ។

(៤៩៣) យទា កាកា ឧលូកា ច មន្តយេយ្យុំ រហោគតា
អញ្ញមញ្ញំ បិហយេយ្យុំ អថ នូន តទា សិយា ។

(៤៩៤) យទា មុឡាលបត្តានំ ឆត្តំ ថិរតរំ សិយា
វស្សស្ស បដិឃាតាយ អថ នូន តទា សិយា ។

(១)

(៤៩៥) យទា កុលុនកោ សកុណោ បព្វតំ គន្ធមាទនំ
តុណ្ឌេនាទាយ គច្ឆេយ្យ អថ នូន តទា សិយា ។

(៤៩៦) យទា សមុទ្ទិកំ នាវំ សយន្តំ សវដាករំ
ចេដោ អាទាយ គច្ឆេយ្យ អថ នូន តទា សិយាតិ ។

អដ្ឋានជាតកំ នវមំ ។

១ ម. កុលុង្គោ ។



(៤៩២) ក្នុងកាលណា សត្វលា មានបបូរមាត់ជំរាល់ល្អ មានមុខដ៏ល្អ ជាសត្វឈ្លាសវៃ ក្នុងការរាំនឹងការច្រៀងបាន កាលបើយ៉ាងនេះ ទើប (យើងនឹងនាង) បានជួបគ្នា ក្នុងកាលនោះ ដោយពិត ។

(៤៩៣) ក្នុងកាលណា ពួកក្អែកនឹងមៀម នាំគ្នាទៅក្នុងទីស្ងាត់ ហើយតប្បីប្រឹក្សាគ្នា តប្បីស្រឡាញ់គ្នាទៅវិញទៅមកបាន កាលបើយ៉ាងនេះ ទើប (យើងនឹងនាង) បានជួបគ្នា ក្នុងកាលនោះ ដោយពិត ។

(៤៩៤) ក្នុងកាលណា ស្នូកឈូកគង់នឹងឡាយ ប្រែទៅជាឆ័ត្រយ៉ាងមាំ ដើម្បីការពារភ្លៀងបាន កាលបើយ៉ាងនេះ ទើប (យើងនឹងនាង) បានជួបគ្នា ក្នុងកាលនោះ ដោយពិត ។

(៤៩៥) ក្នុងកាលណា សត្វបក្សីតូចឈ្មោះកុលុកៈ នាំភ្នំគន្ធមាទន៍ ដោយចំពុះបាន កាលបើយ៉ាងនេះ ទើប (យើងនឹងនាង) បានជួបគ្នា ក្នុងកាលនោះ ដោយពិត ។

(៤៩៦) ក្នុងកាលណា កូនក្មេងតូច អាចកាន់យកសំពៅ សម្រាប់ដើរសមុទ្រ ព្រមទាំងគ្រឿងយន្ត នឹងចង្កូតទៅបាន កាលបើយ៉ាងនេះ ទើប (យើងនឹងនាង) បានជួបគ្នា ក្នុងកាលនោះ ដោយពិត ។

ចប់ អដ្ឋានជាតក ទី ៩ ។

## ទីបិជាតកំ

(៤៩៧) ខមនីយំ យាបនីយំ   កច្ចិ មាតុល តេ សុខំ
សុខំ តេ អម្មា អវច   សុខកាមា ហិ តេ មយំ ។

(៤៩៨) នង្គុដ្ឋំ មេ អវក្កម្ម   ហេឋយិត្វាន ឯឡកេ
សាជ្ជ មាតុលវាទេន   មុញ្ចិតព្វា នុ មញ្ញសិ ។

(៤៩៩) បុរត្ថាភិមុខោ និសិន្នោសិ   អហំ តេ មុខមាគតា
បច្ឆតោ តុយ្ហំ នង្គុដ្ឋំ   កថំ ខោហំ អវក្កមិំ ។

(៥០០) យាវតា ចតុរោ ទីបា   សសមុទ្ទា សបព្វតា
តាវតា មយ្ហំ នង្គុដ្ឋំ   កថំ ខោ ត្វំ វិវជ្ជសិ ។

(៥០១) បុព្វេវ មេតំ អក្ខិំសុ   មាតា បិតា ច ភាតរោ
ទីឃំ ទុដ្ឋស្ស នង្គុដ្ឋំ   សាម្ហិ វេហាយសាគតា ។





## ទីបិជាតក

(៤៩៧) (មេពពែ និយាយនឹងខ្លាថា) បពិត្រឪពុកធំ លោកល្មមអត់ធន់បាន ល្មមញុំាងអត្តភាពឲ្យប្រព្រឹត្តទៅបានដែរឬ លោកបានសេចក្តីសុខទេឬ ម្តាយខ្ញុំបាននិយាយសួរសេចក្តីសុខ របស់លោក ព្រោះថា យើងទាំងឡាយ ជាអ្នកប្រាថ្នាសេចក្តីសុខ ដល់លោក ។

(៤៩៨) (ខ្លាឆ្លើយតបថា) ម្នាលមេពពែ នាងឯងបានដើរជាន់កន្ទុយរបស់អញ ធ្វើឲ្យអញលំបាក ថ្ងៃនេះ នាងឯងស្មានថា គាត់អញនឹងរួចទោស ដោយសារការហៅអញថា ឪពុកធំ ដូច្នេះឬ ។

(៤៩៩) (មេពពែ និយាយថា) អ្នកអង្គុយបែរមុខទៅទិសខាងកើត ចំណែកខ្ញុំ ក៏បានដើរមកចំមុខរបស់អ្នក កន្ទុយរបស់អ្នកនៅពីខាងក្រោយទេ ចុះខ្ញុំជាន់កន្ទុយរបស់អ្នក ដោយប្រការដូចម្តេចបាន ។

(៥០០) (ខ្លានិយាយថា) ទ្វីប ៤ ព្រមទាំងសមុទ្រនឹងភ្នំ មាននៅត្រឹមណា កន្ទុយរបស់អញ ក៏មាននៅត្រឹមណោះដែរ នាងឯងនឹងវៀរឲ្យផុត (ពីកន្ទុយរបស់អញ) ដូចម្តេចបាន ។

(៥០១) (មេពពែ និយាយថា) អំពីដើមមក មាតាបិតានឹងបងឈ្មោលរបស់ខ្ញុំ ក៏បានប្រាប់ហេតុនុ៎ះហើយថា កន្ទុយសត្វសាហាវវែងណាស់ (ព្រោះហេតុនោះបានជា) ខ្ញុំហោះមកតាមអាកាស ។

[៨០៦] តញ្ច និស្សាយ អាយន្តិ អន្តលិក្ខស្មិំ វណ្ណិកា
មិគសង្ឃា បលាយន្តិ ភក្ខា មេ ជាសិតោ តយា ។
[៨០៧] ឥច្ចេវំ វិលបន្តិយា វណ្ណិកាយ រុហក្ខរសោ
គលកំ អជ្ឈាវមទ្ទិ នត្ថិ ទុជ្ជេ សុភាសិតំ ។
[៨០៨] នេវ ទុជ្ជេ នយោ អត្ថិ ន ធម្មោ ន សុភាសិតំ
និក្កមំ ទុជ្ជេ យុញ្ជេថ សោ ច សព្ភិ ន រញ្ជតីតិ ។

ទីបិជាតកំ ទសមំ ។

កុណាលវគ្គោ ។

# តស្សុទ្ទានំ

បរិសុទ្ធាមជាវិលា វត្ថុជក
ពកករជស្ស កាយុរំ ធណ្ណាវកេ
អថ អន្តោរបេតិយ គេវិលិជា
អថ អាទិត្ត គន្តា ធសេឡ្ហកិជា ។

ចតុក្កនិបាតំ និដ្ឋិតំ ។

---



(៨០៦) (ខ្លាទីនិយាយថា) នែមេពពែ ហ្វូងម្រឹគតែងបាត់អស់ទៅ ព្រោះ
ឃើញនាងឯង ហោះមកក្នុងអាកាស នាងឯងបំបាត់ចំណីរបស់
អញអស់ ។
(៨០៧) (អភិសម្ពុទ្ធគាថា) កាលដែលមេពពែ កំពុងតែនិយាយរៀបរាប់
យ៉ាងនេះ ខ្លាដម្បងដែលជាសត្វស៊ីឈាម ក៏ស្ទុះទៅចាប់កាច់ក
នៃពពែសម្លាប់ទៅ ទុសិតដ៏ល្អមិនមាន ក្នុងបុគ្គលអាក្រក់ឡើយ ។
(៨០៨) ការដឹកនាំ ១ ធម៌ ១ នឹងពាក្យដ៏ល្អ ១ មិនមាន ក្នុងបុគ្គលអាក្រក់ទេ
បុគ្គល គួរនៅវាងនូវបុគ្គលអាក្រក់ ហើយប្រើប្រែមួយបញ្ញាយ៉ាម
ព្រោះពួកបុគ្គលអាក្រក់នោះ មិនត្រេកអរ នឹងពួកសប្បុរសឡើយ ។

ចប់ ទីបិជាតក ទី ១០ ។

ចប់ កុណាលវគ្គ ។

# ឧទ្ទាននៃកុណាលវគ្គនោះគឺ

និយាយអំពីគង្គាទឹកបរិសុទ្ធ មិនមានមន្ទិល ព្រះព្រហ្មទត្ត ១ សាវ័ក
ស្តេចកុក ១ គ្រឿងប្រដាប់មាស ១ ការព្រួញទឹកសាហា ១ ផែន
ដីដុះកើតភ្លើង ១ ស្តេចចេតិយៈ ១ កាលទៀលតាបស ១ ផ្ទះ
ក្រៅភ្លើងនេះ ១ ទន្តគ្គិ ១ មេពពែ ១ រួមត្រូវជា ១០ ។

ចប់ ចតុក្កនិបាត ។

## ឆក្កនិបាតជាតកំ

## គិជ្ឈជាតកំ

(៩០៤)បរិសង្កុបថោ នាម  គិជ្ឈបថោ សនន្តនោ
តត្រាសិ មាតាបិតរោ  គិជ្ឈោ បោសេសិ ជិណ្ណកេ។

(៩០៥)តេសំ អជគរំ មេទំ  អច្ចហាសិ ពហុត្តសោ
បិតា ច បុត្តំ អវច  ជានំ ឧច្ចំ បបាតិនំ
សុបត្តំ បក្ខសម្បន្នំ(១)  តេជស្សឹ ទូរគាមិនំ ។

(៩០៦)បរិប្លវន្តំ បថវឹ  យទា តាត វិជានហិ
សាគរេន បរិក្ខិត្តំ  ចក្កំវ បរិមណ្ឌលំ
តតោ តាត និវត្តស្សុ  មាស្សុ ឯត្តោ បរំ គមិ ។

(៩០៧)ឧទបត្តោសិ វេគេន  ពលី បក្ខី ទិជុត្តមោ
ឱលោកយន្តោ វក្កង្គោ  បព្វតានិ វនានិ ច ។

១ ម. បត្តសម្បន្នំ ។

## ឆក្កនិបាត

## គិជ្ឈជាតក

(៩០៤) (អភិសម្ពុទ្ធគាថា) មានផ្លូវលើគិជ្ឈបព៌ត ឈ្មោះបរិសង្កុបថៈ ជាផ្លូវមានមក តាំងអំពីបុរាណ ត្មាតមួយចិញ្ចឹមមាតាបិតា ដែលចាស់ជរា នៅក្នុងផ្លូវនោះ ។

(៩០៥) ត្មាតនោះ បាននាំយកខ្លាញ់ពស់ថ្លាន់ មកចិញ្ចឹមមាតាបិតាក្នុងទីនោះ ដោយច្រើន ចំណែកត្មាត ជាបិតា កាលបើដឹងថា ត្មាត ឈ្មោះសុបត្តៈជាកូន មានស្លាបបរិបូណ៌ មានតេជៈ ហើរទៅកាន់ទីខ្ពស់ ទាំងហើរទៅកាន់ទីឆ្ងាយបាន ក៏និយាយដាស់តឿន ។

(៩០៦) ខែតា (បើ) អ្នកដឹងនូវផែនដីថា អណ្ដែត (ដូចជាស្លឹកឈូក) មានសាគរព័ទ្ធជុំវិញ មូលដូចកង់ វេលាណាហើយ ខែតា ចូរអ្នកត្រឡប់មក អំពីទីនោះវិញ អ្នកកុំទៅឲ្យហួសទៅឆាយ អំពីទីនេះឡើយ ។

(៩០៧) (ត្មាតឈ្មោះសុបត្តៈ) ជាបក្សីមានកម្លាំង មានកំឡាំងដ៏ប្រសើរ ជាងទិជជាតិ ហើរស្ទុះឡើង ដោយសន្ទុះដ៏ខ្លាំង រមិលមើលនូវភ្នំ និងព្រៃទាំងឡាយ ។

(៨០៩)អទ្ទស បថវឹ គិជ្ឈោ យថាស្សោសិ បិតុស្សុតំ
សាគរេន បរិក្ខិត្តំ ចក្កំវ បរិមណ្ឌលំ ។

(៨១០)តញ្ច សោ សមតិក្កម្ម បរមេវ បវត្តថ
តញ្ច វាតសិខា តិក្ខា អច្ចហាសិ ពលឹ ទិជំ ។

(៨១១)នាសក្ខាតិគតោ បោសោ បុនទេវ និវត្តិតុំ
ទិជោ ព្យសនមាបាទិ វេរម្ភានំ វសំ គតោ ។

(៨១២)តស្ស បុត្តា ច ទារា ច យេ ចញ្ញេ អនុជីវិនោ
សព្វេ ព្យសនមាបាទុំ អនោវាទករេ ទិជេ ។

(៨១៣)ឯវម្បិ ឥធ វុឌ្ឍានំ យោ វាក្យំ នាវពុជ្ឈតិ
អតិសីមចរោ ទិត្តោ គិជ្ឈោវាតីតសាសនោ
សព្វេ ព្យសនំ បប្បោន្តិ អកត្វា វុឌ្ឍសាសនំ ។

គិជ្ឈជាតកំ បឋមំ ។



(៨០៩) ត្មាត (ឈ្មោះសុបត្តៈនោះ) បានឃើញផែនដីមានសាគរព័ទ្ធជុំវិញ មូលដូចជាកង់ សមដូចពាក្យប្រដៅរបស់បិតា ដែលខ្លួនបានឮមកហើយ ។

(៨១០) ត្មាតនោះ ហើរលើសទីនោះ ឆ្ពោះហួសទៅកាន់ទីឆ្ងាយ ស្រាប់តែមានខ្យល់ព្យុះយ៉ាងខ្លាំង បក់ខ្ទប់ត្មាតដ៏មានកំឡាំងនោះ ខ្ទេចខ្ទីអស់ទៅ ។

(៨១១) បក្សីត្មាតនោះ ហើរជ្រុលហួសទៅឆ្ងាយហើយ ក៏មិនអាចហើរត្រឡប់មកវិញបាន លុះក្នុងអំណាចខ្យល់ព្យុះ ក៏ដល់នូវសេចក្តីវិនាសទៅ ។

(៨១២) ពួកកូននឹងប្រពន្ធរបស់ត្មាតនោះក្តី ពួកត្មាតដទៃដែលរស់នៅដោយសារត្មាតនោះ (បរិវារ) ក្តី ក៏ដល់នូវសេចក្តីវិនាសទាំងអស់គ្នា ព្រោះតែត្មាតសុបត្តៈនោះ មិនធ្វើតាមឪពុក ។

(៨១៣) ពួកជនណា ក្នុងលោកនេះ មិនធ្វើតាមពាក្យប្រដៅ របស់បុគ្គលចាស់ព្រឹទ្ធាចារ្យទាំងឡាយ យ៉ាងនេះហើយ ពួកជនទាំងអស់នោះ រមែងដល់នូវសេចក្តីវិនាស ព្រោះតែមិនធ្វើតាមពាក្យប្រដៅ របស់បុគ្គលចាស់ព្រឹទ្ធាចារ្យ ដូចជាត្មាតដ៏មានកំឡាំង ប្រព្រឹត្តល្មើសពាក្យប្រដៅ ហើរហួសទីព្រំប្រទល់ ។

ចប់ គិជ្ឈជាតក ទី ១ ។

# កោសម្ពិយជាតកំ

[៥១៤] ពុថុសទ្ទោ សមជនោ ន ពាលោ កោចិ មញ្ញថ
សង្ឃស្មឹ ភិជ្ជមានស្មឹ នាញ្ញំ ភិយ្យោ អមញ្ញរុំ ។

[៥១៥] បរិមុដ្ឋា បណ្ឌិតាភាសា វាចាគោចរ ភាណិនោ
យាវិច្ឆន្តិ មុខាយាមំ យេន នីតា ន តំ វិទូ ។

[៥១៦] អក្កោច្ឆិ មំ អវធិ មំ អជិនិ មំ អហាសិ មេ
យេ ច តំ ឧបនយ្ហន្តិ វេរំ តេសំ ន សម្មតិ ។

[៥១៧] អក្កោច្ឆិ មំ អវធិ មំ អជិនិ មំ អហាសិ មេ
យេ ច តំ នូបនយ្ហន្តិ វេរំ តេសូបសម្មតិ ។



# កោសម្ពិយជាតក

(៥១៤) (ព្រះសាស្តាត្រាស់ថា) ជនសុទ្ធតែមានសម្លេងខ្លាំង ស្មើគ្នា មិនមានជនណាមួយដឹងថា ខ្លួនឯងជាបុគ្គលពាលឡើយ កាលបើសង្ឃកំពុងបែកគ្នា ក៏មិនមានជនណាមួយ ដឹងនូវហេតុដទៃ ឲ្យក្រៃលែងជាងនេះទៅទៀត ។

(៥១៥) ពួកជនអ្នកភ្លេចស្មារតី មានអាការប្រហៀងនឹងបណ្ឌិត មានពាក្យជាអារម្មណ៍ ចេះតែស្តីនិយាយ តាមតែខ្លួនចង់និយាយឲ្យវែងពេកមាត់ មានគេដឹកនាំ ដោយជំលោះណា ក៏នៅតែមិនស្គាល់នូវជំលោះនោះឡើយ ។

(៥១៦) ពួកជនណា ចងសេចក្តីក្រោធទុក ដោយគិតថា ជនឯណោះ បានជេរអញ បានវាយអញ បានឈ្នះអញ បានលួចយក (ទ្រព្យ) អញដូច្នេះ ពៀររបស់ជនទាំងនោះ រមែងមិនស្ងប់រម្ងាប់បានឡើយ ។

(៥១៧) លុះតែពួកជនណា មិនចងសេចក្តីក្រោធទុក ដោយគិតថា ជនឯណោះ បានជេរអញ បានវាយអញ បានឈ្នះអញ បានលួចយក (ទ្រព្យ) អញដូច្នេះ ទើបពៀររបស់ជននោះ ស្ងប់រម្ងាប់បាន ។

(៨១៨) ន ហិ វេរេន វេរានិ សម្មន្តីធ កុទាចនំ
អវេរេន ច សម្មន្តិ ឯស ធម្មោ សនន្តនោ ។

(៨១៩) បរេ ច ន វិជានន្តិ មយមេត្ថ យមាមសេ
យេ ច តត្ថ វិជានន្តិ តតោ សម្មន្តិ មេធគា ។

(៨២០) អដ្ឋិច្ឆិន្នា បាណហរា គវស្សធនហារិនោ
រដ្ឋំ វិលុម្បមានានំ តេសម្បិ ហោតិ សង្គតិ
កស្មា តុម្ហាក នោ សិយា ។

(៨២១) សចេ លភេថ និបកំ សហាយំ
សទ្ធិំចរំ សាធុវិហារិ ធីរំ
អភិភុយ្យ សព្វានិ បរិស្សយានិ
ចរេយ្យ តេនត្តមនោ សតិមា ។



(៨១៨) ពៀរទាំងឡាយក្នុងលោកនេះ មិនស្ងប់រម្ងាប់ ដោយពៀរ ក្នុងកាលណាមួយឡើយ តែងតែស្ងប់រម្ងាប់ ដោយមិនមានពៀរ នេះជាធម៌មានមកតាំងពីដើម ។

(៨១៩) ពួកជនក្រៅពីបណ្ឌិត មិនដឹងច្បាស់ថា ពួកយើងនឹងដល់នូវសេចក្ដីវិនាស ក្នុងកណ្ដាលសង្ឃនេះ បណ្ដាជនទាំងនោះ លុះតែពួកជនណាដឹងច្បាស់ (យ៉ាងនេះថា ពួកយើងនឹងដល់នូវសេចក្ដីវិនាស) ទើបកលហធម៌ គឺការឈ្លោះប្រកែកទាំងឡាយ ស្ងប់រម្ងាប់អំពីសំណាក់ពួកជននោះទៅបាន ។

(៨២០) កាលពួកជនដែលបានកាត់ឆ្អឹងគ្នា បានសម្លាប់គ្នា បានលួចយកគោ សេះ និងទ្រព្យ ប្លន់យកទាំងដែន គេនៅរួមគ្នាបាន ហេតុអ្វី ក៏ពួកអ្នករួមគ្នា មិនបាន ។

(៨២១) បើបុគ្គលបានសំឡាញ់ ដែលមានប្រាជ្ញា ជាគ្រឿងរក្សាខ្លួន ជាអ្នកប្រាជ្ញត្រាច់ទៅជាមួយ មានវិហារធម៌ប្រពៃ តប្បីគ្របសង្កត់ នូវសេចក្ដីអន្តរាយទាំងឡាយទាំងពួង ហើយមានចិត្តត្រេកអរ មានស្មារតី ត្រាច់ទៅជាមួយ នឹងសំឡាញ់នោះចុះ ។

(៤៦២) នោ ចេ លភេថ និបកំ សហាយំ
សទ្ធិញ្ចរំ សាធុវិហារិ ធីរំ
រាជាវ រដ្ឋំ វិជិតំ បហាយ
ឯកោ ចរេ មាតង្គរញ្ញេវ នាគោ ។

(៤៦៣) ឯកស្ស ចរិតំ សេយ្យោ នត្ថិ ពាលេ សហាយតា
ឯកោ ចរេ ន ច បាបានិ កយិរា
អប្បោស្សុក្កោ មាតង្គរញ្ញេវ នាគោ ។

កោសម្ពិយជាតកំ ទុតិយំ ។

# មហាសុវរាជជាតកំ

(៤៦៤) ទុមោ យទា ហោតិ ផលូបបន្នោ
ភុញ្ជន្តិ នំ វិហង្គមា សម្បតន្តា
ខីណន្តិ ញត្វាន ទុមំ ផលច្ចយេ
ទិសោទិសំ យន្តិ តតោ វិហង្គមា ។



(៤៦២) បើបុគ្គលមិនបាននូវសំឡាញ់ ដែលមានប្រាជ្ញា ជាគ្រឿងរក្សាខ្លួន ជាអ្នកប្រាជ្ញត្រាច់ទៅជាមួយគ្នា មានវិហារធម៌ដ៏ល្អ គប្បីត្រាច់ទៅតែម្នាក់ឯង ដូចជាព្រះរាជាលះបង់ដែន ដែលឈ្នះហើយ (កុំអាឡោះសោក) ដូចដំរីដ៏ប្រសើរ ដែលត្រាច់ទៅតែម្នាក់ឯងក្នុងព្រៃ ។

(៤៦៣) ការត្រាច់ទៅម្នាក់ឯង ប្រសើរជាង (ព្រោះ) សហាយតាគុណ មិនមានក្នុងបុគ្គលពាល ។ បុគ្គលគួរត្រាច់ទៅតែម្នាក់ឯង តែគួរជាអ្នកខ្វល់ខ្វាយតិច កុំធ្វើបាបទាំងឡាយឡើយ ដូចដំរីដ៏ប្រសើរ ដែលត្រាច់ទៅក្នុងព្រៃ ។

ចប់ កោសម្ពិយជាតក ទី ២ ។

# មហាសុវរាជជាតក

(៤៦៤) (ស្តេចឥន្ទ្រ និយាយនឹងស្តេចសេកថា) កាលណា ឈើមានផ្លែបរិបូណ៌ ពួកសត្វស្លាបក៏ហើរសំដៅទៅ បរិភោគផ្លែឈើនោះ លុះពួកសត្វស្លាបបានដឹងថា ឈើអស់ផ្លែហើយ ក៏ហើរចេញអំពីដើមឈើនោះ ទៅកាន់ទិសផ្សេង ៗ ក្នុងវេលាជាទីអស់ទៅនៃផ្លែ ។

(៤៦៥) ចរ ចារិកំ លោហិតតុណ្ឌ មា មរិ
កឹ ត្វំ សុវ សុក្ខទុមម្ហិ ឈាយសិ
តទិង្ឃ ព្រូហិ វសន្តសន្និភ
កស្មា សុវ សុក្ខ ទុមំ ន រិញ្ចសិ ។

(៤៦៦) យេ វេ សខីនំ សខារោ ភវន្តិ
បាណច្ចយេ(១) សុខទុក្ខេសុ ហំស
ខីណំ អខីណន្តិ ន តំ ជហន្តិ
សន្តោ សតំ ធម្មមនុស្សរន្តា ។

(៤៦៧) សោហំ សតំ អញ្ញតរោស្មិ ហំស
ញាតី ច មេ ហោតិ សខា ច រុក្ខោ
តំ នុស្សហេ ជីវិកត្ថោ បហាតុំ
ខីណន្តិ ញត្វាន ន ឯស ធម្មោ ។

(២) (៣)
(៤៦៨) សាធុ សក្ខិ កតំ ហោតិ មេត្តិ សំសតិ សន្ថវោ
សចេតំ ធម្មំ រោចេសិ បាសំសោសិ វិជានតំ ។

១ បាណំ បរេ ។ ២ ឱ. ម. សក្ខិ ។ ៣ ម. ចិត្ត សង្គតិ ។



(៤៦៥) ម្នាលសេកមានចំពុះក្រហម អ្នកចូរត្រាច់ទៅកាន់ចារិក កុំឲ្យខ្លួនអ្នកស្លាប់ឡើយ ម្នាលសេក ម្តេចក៏អ្នក នៅសញ្ជប់សញ្ជឹងលើដើមឈើងាប់ (នេះ) ម្នាលសេកមានសម្បុរខៀវ ស្រដៀងនឹងឈើ ក្នុងវសន្តរដូវ យើងសូមដាស់តឿនអ្នក អ្នកចូរជាមកមើល ព្រោះហេតុអ្វី ក៏បានជាអ្នកមិនលះបង់នូវឈើងាប់នេះ ។

(៤៦៦) (ស្តេចសេកតប) ម្នាលហង្ស ពួកសប្បុរសណា រលឹករឿយ ៗ នូវធម៌របស់ពួកសប្បុរស លោកជាសំឡាញ់ នឹងពួកសំឡាញ់ (ទៅវិញទៅមកហើយ) ពួកសប្បុរសនោះ សូម្បីដល់នូវការអស់ទៅនៃជីវិត ក៏មិនលះបង់សំឡាញ់នោះទេ ដោយគិតថាអស់ ឬមិនអស់ ក្នុងកាលដែលបានសុខនឹងទុក្ខឡើយ ។

(៤៦៧) ម្នាលហង្ស ខ្ញុំជាសប្បុរសដែរ ដើមឈើនេះទុកជាញាតិ ឬជាសំឡាញ់របស់ខ្ញុំក៏បាន ខ្ញុំជាអ្នកត្រូវការដោយជីវិត ក៏មិនអាចនឹងលះបង់ នូវដើមឈើនោះចោលឡើយ (បើខ្ញុំដឹងថា ឈើនោះអស់ហើយ ៗ លះបង់ចោល) នុ៎ះមិនមែនជាធម៌របស់សប្បុរសទេ ។

(៤៦៨) (ស្តេចហង្ស...) ម្នាលបក្សី សេចក្តីមេត្រី សេចក្តីជួបជុំ នឹងសេចក្តីស្និទ្ធស្នាល ដែលអ្នកបានធ្វើហើយ ជាការប្រពៃណាស់ បើអ្នកពេញចិត្តនឹងធម៌នោះ អ្នកនឹងបានជាទីសរសើរ នៃពួកវិញ្ញូជន ។

(៨២៩) សោ តេ ហំ វរំ ទម្មិ បត្តយាន វិហង្គម
វរំ វរស្សុ វក្កង្គ យំ កិញ្ចិ មនសិច្ឆសិ ។

(៨៣០) វរញ្ច មេ ហំស ភវំ ទទេយ្យ
អយញ្ច រុក្ខោ បុនរាយុំ លភេថ
សោ សាខវា ផលិមា សំវិរូឡ្ហោ
មធុត្ថិកោ តិដ្ឋតុ សោភមានោ ។

(៨៣១) តំ បស្ស សម្ម ផលិមំ ឧឡារំ
សហាវ តេ ហោតុ ឧទុម្ពរេន
សោ សាខវា ផលិមា សំវិរូឡ្ហោ
មធុត្ថិកោ តិដ្ឋតុ សោភមានោ ។

(៨៣២) ឯវំ សក្ក សុខី ហោហិ សហ សព្វេហិ ញាតិភិ
យថាហមជ្ជ សុខិតោ ទិស្វាន សផលំ ទុមំ ។

(៨៣៣) សុវស្ស វចនំ[១] សុត្វា កត្វាន សផលំ ទុមំ
បក្កាមិ សហ ភរិយាយ ទេវានំ នន្ទនំ វនំ ។

មហាសុកជាតកំ តតិយំ ។

១ ឱ. ម. សុវស្ស វរំ ទត្វា ។



(៨២៩) ម្នាលសេក អ្នកមានស្លាបជាយាន ហើរទៅក្នុងអាកាស យើងឲ្យពរដល់អ្នក ម្នាលបក្សី បើអ្នកមានចិត្តប្រាថ្នា នូវពរណាមួយ ចូរទទួលយកនូវពរនោះចុះ ។

(៨៣០) (ស្តេចសេក...) ម្នាលហង្ស អ្នកគប្បីឲ្យនូវពរដល់ខ្ញុំ សូមឲ្យដើមឈើនេះត្រឡប់មានអាយុរស់វិញ សូមឲ្យដើមឈើនោះ មានមែក មានផ្លែ លូតលាស់ល្អ មានផ្លែ មានរសផ្អែមល្អ ។

(៨៣១) (ស្តេចហង្ស...) ម្នាលសំឡាញ់ អ្នកចូរមើលដើមឈើ ដែលមានផ្លែធំលើសលុបនេះចុះ ទីលំនៅរបស់អ្នក ចូរកើតជាមួយនឹងដើមល្វា ដើមល្វានោះចូរមានមែក មានផ្លែ លូតលាស់ល្អ មានផ្លែ មានរសផ្អែមល្អ ។

(៨៣២) (ស្តេចសេក...) បពិត្រសក្កៈ កាលបើយ៉ាងនេះ សូមឲ្យព្រះអង្គបានសេចក្តីសុខ ព្រមទាំងពួកញាតិទាំងអស់ ឲ្យដូចខ្ញុំដែលបានសេចក្តីសុខ ព្រោះបានឃើញដើមឈើ ប្រកបដោយផ្លែក្នុងថ្ងៃនេះឯង ។

(៨៣៣) (អភិសម្ពុទ្ធគាថា) ព្រះឥន្ទបានឮពាក្យសេកហើយ ក៏ធ្វើនូវដើមឈើនោះ ឲ្យមានផ្លែ រួចចៀសចេញទៅកាន់នន្ទនឧទ្យាន របស់ពួកទេវតា ជាមួយនឹងប្រពន្ធ ។

ចប់ មហាសុកជាតក ទី ៣ ។

## ចុល្លសុវករាជជាតកំ

(៨៣៤)សន្តិ រុក្ខា ហរិតបត្តា ទុមានេកផលា ពហូ
កស្មា នុ សុក្ខេ កោលាបេ សុវស្ស និរតោ មនោ ។

(៨៣៥)ផលស្ស ឧបភុញ្ជិម្ហា នេកវស្សគណេ ពហូ
អផលម្បិ វិទិត្វាន សាវ មេត្តិ យថា បុរេ ។

(៨៣៦)សុក្ខញ្ច រុក្ខំ កោលាបំ ឱបត្តមផលំ ទុមំ
ឱហាយ សកុណា យន្តិ កឹ ទោសំ មញ្ញសេ[1] ទិជ ។

(៨៣៧)យេ ផលត្ថា សម្ភជន្តិ អផលោតិ ជហន្តិ នំ
អត្តត្ថបញ្ញា ទុម្មេធា តេ ហោន្តិ បក្ខបាតិនោ ។

---

១ ឱ. ម. បស្សសេ ។



## ចុល្លសុវករាជជាតក

(៨៣៤) (ស្តេចឥន្ទ្រ និយាយនឹងស្តេចសេកថា) ដើមឈើទាំងឡាយ ច្រើនណាស់ ដែលមានស្លឹកខៀវ មានផ្លែជាអនេក ព្រោះហេតុអ្វីហ្ន៎ ចុះជាសេកនេះ មានចិត្តរីករាយជានិច្ច នៃដីដង្កត់ឈើពុកស្អុយ ។

(៨៣៥) (ស្តេចសេក និយាយតបវិញថា) យើងបានចូលទៅបរិភោគផ្លែឈើនោះ អស់ជាយូរឆ្នាំច្រើនជាអនេក តែបើយើងដឹងថា ឈើនោះ មិនមានផ្លែហើយ ការមេត្រីនោះ ក៏នៅដូចដើម ។

(៨៣៦) (ស្តេចឥន្ទ្រ និយាយថា) សត្វស្លាបទាំងឡាយ តែងលះបង់នូវដើមឈើដែលពុកស្អុយ ជ្រុះស្លឹកអស់ មិនមានផ្លែ ហើយហើរទៅ ម្នាលអ្នកជាទ្វិជាតិ អ្នកសំគាល់ឃើញទោស (ក្នុងការលះបោលនោះ) ដូចម្តេច ។

(៨៣៧) (ស្តេចសេក និយាយថា) ពួកសត្វណាមានសេចក្តីត្រូវការដោយផ្លែ ហើយគប់រកនូវដើមឈើ លុះដឹងថា មិនមានផ្លែ ក៏លះបោលនូវដើមឈើនោះ ពួកសត្វស្លាបនោះ ឈ្មោះថាមានប្រាជ្ញា គិតតែប្រយោជន៍ផ្ទាល់ខ្លួន មានប្រាជ្ញាមិនល្អ រមែងញុំាងចំណែកនៃសេចក្តីគប់រកឲ្យវិនាស ។

(៨៣៨) សាធុ សក្ខិ កតំ ហោតិ   មិត្តិ សំសតិ សន្ថវោ

សចេ តំ ធម្មំ រោចេសិ   បាសំសោសិ វិជានតំ ។

(៨៣៩) សោ តេ សុត្វាហំ ធម្មំ   បត្តយាន វិហង្គម

វរំ វរស្សុ វក្កង្គ   យំ កិញ្ចិ មនសិច្ឆសិ ។

(៨៤០) អបិ នាម នំ បុន បស្សេ(១) សបត្តំ សផលំ ទុមំ

ទលិទ្ទោវ និធឹ លទ្ធា   នន្ទេយ្យាហំ បុនប្បុនំ ។

(៨៤១) តតោ អមតមាទាយ   អភិសិញ្ចិ មហីរុហំ

តស្ស សាខា វិរូហឹសុ(២)   សីតច្ឆាយា មនោរមា ។

(៨៤២) ឯវំ សក្ក សុខី ហោហិ   សហ សព្វេហិ ញាតិភិ

យថាហមជ្ជ សុខិតោ   ទិស្វាន សផលំ ទុមំ ។

---

១ ម. បស្សេម ។ ម. ឆ. បស្សេយ្យំ ។ ២. ម. វិរូឡ្ហសុ ។



(៨៣៨) (ស្តេចឥន្ទ្រនិយាយថា) ម្នាលបក្សី សេចក្តីមេត្រី សេចក្តីរាប់អាន នឹងសេចក្តីស្និទ្ធស្នាល ដែលអ្នកបានធ្វើហើយ ជាការប្រពៃណាស់ បើអ្នកពេញចិត្តនឹងធម៌នេះ អ្នកនឹងបានជាទីសរសើរនៃពួកវិញ្ញូជន ។

(៨៣៩) ម្នាលសេក អ្នកមានស្លាបជាយាន ហើរទៅតាមអាកាស យើងឲ្យពរដល់អ្នក ម្នាលបក្សី បើអ្នកមានចិត្តប្រាថ្នានូវពរណាមួយ ចូរទទួលយកពរនោះចុះ ។

(៨៤០) (ស្តេចសេក និយាយថា) ខ្ញុំសូមឲ្យបានឃើញ នូវដើមឈើនោះ មានស្លឹកនឹងផ្លែឡើងវិញដូចដើម ខ្ញុំនឹងរីករាយរឿយៗ ដូចមនុស្សកំសត់ បានកំណប់ទ្រព្យ ។

(៨៤១) (អភិសម្ពុទ្ធគាថា) លំដាប់នោះ ព្រះឥន្ទ្របានយកទឹកអម្រឹតមកស្រោច នូវឈើដុះលើផែនដី ដើមឈើនោះ មានមែកល្អ លាស់ត្រសាយត្រសុំ មានម្លប់ដ៏ត្រជាក់ ជាទីគាប់នៃចិត្ត ។

(៨៤២) (ស្តេចសេក និយាយថា) បពិត្រសក្កៈ ការណ៍បើយ៉ាងនេះ សូមឲ្យព្រះអង្គបានសេចក្តីសុខ ព្រមទាំងពួកញាតិទាំងអស់ ឲ្យដូចជាខ្ញុំដែលបានសេចក្តីសុខ ព្រោះឃើញនូវដើមឈើដ៏ប្រកបដោយផ្លែ ក្នុងថ្ងៃនេះ ។

(៨៤៣) សុវស្ស វចនំ សុត្វា កត្វាន សផលំ ទុមំ
បក្កាមិ សហ ភរិយាយ ទេវានំ នន្ទនំ វនន្តិ ។

ចុល្លសុវកជាតកំ ចតុត្ថំ ។

## ហារិតជាតកំ

(៨៤៤) សុតំ មេតំ មហាព្រហ្មេ កាមេ ភុញ្ជតិ ហារិតោ
កច្ចេតំ វចនំ តុច្ឆំ កច្ចិ សុទ្ធោ ឥរីយសិ ។

(៨៤៥) ឯវមេតំ មហារាជ យថា តេ វចនំ សុតំ
កុម្មគ្គេ បដិបន្នោស្មិ មោហនេយ្យេសុ មុច្ឆិតោ ។

(៨៤៦) អទុ(១) បញ្ញា កិមត្ថិយា និបុណា សាធុចិន្តិនី
យាយ ឧប្បតិតំ រាគំ កិំ មនោ ន វិនោទយេ ។

១ ម. សាធុ ។



(៨៤៣) (អភិសម្ពុទ្ធគាថា) ព្រះឥន្ទ្របានឮពាក្យសេកហើយ ក៏ធ្វើឲ្យឈើនោះឲ្យមានផ្លែ រួចក៏ចៀសចេញទៅ កាន់នន្ទនឧទ្យាន នៃទេវតាទាំងឡាយ ជាមួយនឹងភរិយា ។

ចប់ ចុល្លសុវកជាតក ទី ៤ ។

## ហារិតជាតក

(៨៤៤) (ព្រះបាទព្រហ្មទត្ត ទ្រង់ត្រាស់សួរតាបសថា) បពិត្រមហាព្រហ្ម ខ្ញុំបានឮថា ព្រះហារិតតាបសបរិភោគកាម ពាក្យនុ៎ះទទេទេឬ លោកជាបុគ្គលបរិសុទ្ធទេឬ ។

(៨៤៥) (ហារិតតាបសពោធិសត្វតបថា) បពិត្រមហារាជ ពាក្យដែលទ្រង់បានព្រះសណ្ដាប់មកយ៉ាងណា ពាក្យនុ៎ះពិតយ៉ាងនោះហើយ អាត្មាភាពជាបុគ្គលបានដើរ ទៅកាន់ផ្លូវខុស ជ្រប់នៅក្នុងអារម្មណ៍ ដែលជាទីតាំងនៃសេចក្ដីវង្វេង ។

(៨៤៦) (ព្រះរាជា...) បើបុគ្គលមិនអាច ដើម្បីបន្ទោបង់នូវចិត្តមិនល្អ គឺរាគៈ ដែលកើតឡើង ដោយប្រាជ្ញាណាបានទេ ប្រាជ្ញានោះនឹងបានជាមានប្រយោជន៍ ជាគុណជាតិដ៏ល្អិត អាចគិតឃើញនូវរបស់ល្អ ដូចម្ដេចបាន ។

(៤៦៧)ចត្តារោមេ មហារាជ លោកេ អតិពលា ភុសា

កោធោ ទោសោ មទោ មោហោ យត្ថ បញ្ញា ន គាធតិ ៗ

(៤៦៨)អរហា សីលសម្បន្នោ សុទ្ធោ ចរតិ ហារិតោ

មេធាវី បណ្ឌិតោ ចេវ ឥតិ នោ សម្មតោ ភវំ ៗ

(៤៦៩)មេធាវិនម្បិ ហឹសន្តិ ឥសឹ ធម្មគុណេ រតំ

វិតក្កា បាបកា រាជ សុភា រាគូបសញ្ហិតា ៗ

(៤៧០)ឧប្បន្នាយំ សរីរជោ រាគោ វណ្ណវិទូសនោ

តវ តំ បជហ ភទ្ទន្តេ(*) ពហុន្នាសិ មេធាវិ សម្មតោ ៗ

(៤៧១)តេ អន្ធការណេ កាមេ ពហុទុក្ខេ មហាវិសេ

តេសំ មូលំ គវេសិស្សំ ឆេជ្ជំ រាគំ សពន្ធនំ ៗ

---

* ១. ឧសិហ ភទ្ទមត្ថុ តេ ។ ២. ឧសិហមិ ភទ្ទមត្ថុ តេ ។



(៤៦៧) (តាបស...) បពិត្រមហារាជ ធម៌ទាំង ៤ ប្រការនេះ គឺកោធៈ ទោសៈ មទៈ និង មោហៈ ជាកិលេសមានកំឡាំងក្លៀវក្លាបំផុត ក្នុងលោក ប្រាជ្ញាមិនបានទីពឹងពាក់ ព្រោះតែកិលេសទាំងនោះ ៗ

(៤៦៨) (ព្រះរាជា ..) លោកដ៏ចំរើន ពួកយើងសន្មតថា ព្រះហារិត-តាបស ជាព្រះអរហន្តបរិបូណ៌ដោយសីល ជាបុគ្គលបរិសុទ្ធ ជាអ្នកប្រាជ្ញ មានប្រាជ្ញាសម្រាប់ទំលុះទំលាយកិលេស ៗ

(៤៦៩) (តាបស...) បពិត្រព្រះរាជា វិតក្កៈទាំងឡាយដ៏លាមក ប្រកបដោយសុភនិមិត្ត ដ៏ប្រកបដោយរាគៈ តែងបៀតបៀនអ្នកប្រាជ្ញ ដែលជាអ្នកត្រេកអរ ក្នុងគុណធម៌របស់ឥសី ៗ

(៤៧០) (ព្រះរាជា...) រាគៈនេះ ជាសភាពកើតអំពីសរីរៈ តែងកើតឡើង ហើយរមែងប្រទូស្តនូវគុណឲ្យខូច សូមលោកលះរាគៈ របស់លោកនោះចេញ សេចក្តីចំរើន ទើបកើតមានដល់លោក ដ្បិតជនច្រើននាក់ សន្មតលោកថាជាអ្នកប្រាជ្ញ ៗ

(៤៧១) (តាបស...)កាមទាំងឡាយនោះ ជាគ្រឿងធ្វើឲ្យងងឹត ទាំងមានទុក្ខច្រើន មានពិសច្រើន អាត្មាភាពនឹងស្វែងរក នូវឫសនៃកាមទាំងឡាយនោះ នឹងកាត់ផ្តាច់នូវរាគៈ ព្រមទាំងចំណង ៗ

(៨៨២) ឥទំ វត្វាន ហារិតោ ឥសិ សច្ចបរក្កមោ
កាមរាគំ វិរាជេត្វា ព្រហ្មលោកូបគោ អហូតិ។

ហារិតជាតកំ បញ្ចមំ ។

## បទកុសលមាណវជាតកំ

(៨៨៣) ពហុស្សុតំ ចិត្តកថិំ គង្គា វហតិ បាដលិំ
វុយ្ហមានក ភទ្ទន្តេ ឯកំ មេ ទេហិ គាថកំ ។

(៨៨៤) យេន សិញ្ចន្តិ ទុក្ខិតំ យេន សិញ្ចន្តិ អាតុរំ
តស្ស មជ្ឈេ មរិស្សាមិ ជាតំ សរណតោ ភយំ ។

(៨៨៥) យត្ថ វីជានិ រូហន្តិ សត្តា យត្ថ បតិដ្ឋិតា
សា មេ សីសំ និបីឡេតិ ជាតំ សរណតោ ភយំ ។

(៨៨៦) យេន ភត្តានិ បច្ចន្តិ សីតំ យេន វិហញ្ញតិ
សោ មំ ឌហតិ គត្តានិ ជាតំ សរណតោ ភយំ ។



(៨៨២) (អភិសម្ពុទ្ធគាថា) ឥសីឈ្មោះហារិតៈ ជាអ្នកប្រព្រឹត្តព្យាយាម ដោយសច្ចៈ លុះពោលពាក្យនេះរួច ក៏លះបង់កាមរាគ ហើយ បានចូលទៅកើត ក្នុងព្រហ្មលោក ។

ចប់ ហារិតជាតក ទី ៥ ។

## បទកុសលមាណវជាតក

(៨៨៣) (កវិយោ និយាយថា) ទឹកទន្លេគង្គាហូរយកទៅ នូវបុរសឈ្មោះ បាដលិ ជាអ្នកចេះដឹងច្រើន ពោលនូវពាក្យវិចិត្រ នែអ្នកដ៏ចំរើន ដែលទឹកហូរយកទៅ សូមអ្នកឲ្យនូវចំរៀងយ៉ាងតិចមួយដល់ខ្ញុំ ។

(៨៨៤) (ស្វាមីនិយាយតបថា) ពួកជនតែងស្រោចនូវបុគ្គលមានទុក្ខ ដោយទឹកណា តែងស្រោចនូវបុគ្គល ដែលមានសេចក្តីក្រវល់ក្រវាយដោយទឹកណា យើងនឹងស្លាប់ ក្នុងកណ្តាលទឹកនោះ ភ័យ កើតមកអំពីទីពឹងហើយ ។

(៨៨៥) (តាយស្ងួនទាំង និយាយថា) ពូជទាំងឡាយតែងដុះឡើងលើ ផែនដីណា ពួកសត្វឋិតនៅលើផែនដីណា ផែនដីនោះបៀតបៀន នូវក្បាលអញ ភ័យកើតអំពីទីពឹងហើយ ។

(៨៨៦) (បុរសម្នាក់ និយាយថា) ពួកជនតែងចំអិនបាយ ដោយភ្លើងណា តែងកំចាត់បង់នូវត្រជាក់ដោយភ្លើងណា ភ្លើងនោះឆេះនូវកាយរបស់អញ ភ័យកើតអំពីទីពឹងហើយ ។

(៤៤៧) យេន ភត្តេន យាបេន្តិ បុថូ ព្រាហ្មណខត្តិយា
សោ មំ ភត្តោ ព្យាធានិ ជាតំ សរណតោ ភយំ ។

(៤៤៨) គិម្ហានំ បច្ឆិមេ មាសេ ភក្ខមិច្ឆន្តិ បណ្ឌិតា
សោ មំ ភញ្ជតិ ភត្តានំ ជាតំ សរណតោ ភយំ ។

(៤៤៩) យំ និស្សិតា ជគតិរុហំ(វិហង្គមា)ស្វាយំ អគ្គិំ បមុញ្ចតិ
ទិសា ភជថ វក្កង្គា ជាតំ សរណតោ ភយំ ។

(៤៥០) យមានយឹ សោមនស្សំ មាលិនឹ ចន្ទនុស្សទំ
សា មំ ឃរា នីហរតិ(១) ជាតំ សរណតោ ភយំ ។

(៤៥១) យេន ជាតេន នន្ទិស្សំ យស្ស ច ភវមិច្ឆិសំ
សោ មំ ឃរា នីហរតិ ជាតំ សរណតោ ភយំ ។

១ ឱ. ម. និច្ឆុភតិ ។



(៤៤៧) (បុរសម្នាក់ និយាយថា) ពួកព្រាហ្មណ៍និងក្សត្រិយ៍ ជាច្រើន តែងញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយភត្តណា ភត្តនោះ ដែលអាត្មាអញបរិភោគហើយនោះ សម្លាប់នូវអញ ភ័យកើតអំពីវត្ថុជាទីពឹងហើយ ។

(៤៤៨) (បុរសម្នាក់ និយាយថា) ពួកអ្នកប្រាជ្ញ តែងប្រាថ្នាឫស្សី ក្នុងខែជាទីបំផុតនៃគិម្ហរដូវ (ឥឡូវ) ឫស្សីនោះ កាប់បំបាក់ខ្ញុំ ភ័យកើតអំពីវត្ថុជាទីពឹងហើយ ។

(៤៤៩) (បក្សីជាធំ និយាយថា) ពួកបក្សី តែងអាស្រ័យដើមឈើណា ដើមឈើនោះ បញ្ចេញនូវភ្លើង បក្សីទាំងឡាយ ចូរគេចនូវទិសទាំងឡាយផ្សេង ៗ ភ័យកើតអំពីវត្ថុជាទីពឹងហើយ ។

(៤៥០) (មាតានិយាយថា) អញមានចិត្តសោមនស្ស ហើយនាំមកនូវកូនប្រសាស្រីណា ដែលប្រដាប់ដោយកម្រងផ្កា និងប្រស់ព្រំដោយខ្លឹមចន្ទន៍ (ឥឡូវ) កូនប្រសាស្រីនោះ បណ្ដេញអញចេញអំពីផ្ទះ ភ័យកើតអំពីវត្ថុជាទីពឹងហើយ ។

(៤៥១) (បុរសម្នាក់ និយាយថា) អញត្រេកត្រអាលនឹងកូនប្រុសណា ដែលកើតហើយ និងប្រាថ្នាសេចក្ដីចំរើន ដល់កូនប្រុសណា (ឥឡូវ) កូនប្រុសនោះ បណ្ដេញអញចេញអំពីផ្ទះ ភ័យកើតអំពីវត្ថុជាទីពឹងហើយ ។

(៨៦៦)សុណន្តុ មេ ជានបទា នេគមា ច សមាគតា
យតោទកំ តទាទិត្តំ យតោ ខេមំ តតោ ភយំ
រាជា វិលុម្បតេ រដ្ឋំ ព្រាហ្មណោ ច បុរោហិតោ
អត្តគុត្តា វិហរថ ជាតំ សរណតោ ភយន្តិ ។

បទកុសលមាណវជាតកំ ឆដ្ឋំ ។

## លោមសកស្សបជាតកំ

(៨៦៧)អស្ស ឥន្ទសមោ រាជ អច្ចន្តំ អជរាមរោ
សចេ ត្វំ យញ្ញំ យាជេយ្យ ឥសឹ លោមសកស្សបំ ។
(៨៦៨)សសមុទ្ទបរិយាយំ មហឹ សាគរកុណ្ឌលំ
ន ឥច្ឆេ សហ និន្ទាយ ឯវំ សេយ្យ វិជានហិ ។
(៨៦៩)ធិរត្ថុ តំ យសលាភំ ធនលាភញ្ច ព្រាហ្មណ
យា វុត្តិ វិនិបាតេន អធម្មចរណេន វា ។



(៨៦៦) (ពោធិសត្វ ពោលថា) សូមឲ្យពួកអ្នកជនបទ និងអ្នកនិគម ដែលបានមកប្រជុំស្តាប់ខ្ញុំ (ឥឡូវ) ទឹកណាជាទីពឹង ទឹកនោះក្លាយទៅជាភ្លើងហើយ សេចក្តីក្សេម កើតមកអំពីព្រះរាជាណា ភ័យកើតមកអំពីព្រះរាជានោះហើយ ព្រះរាជានិងព្រាហ្មណ៍បុរោហិត ប្លន់ជនអ្នកនៅក្នុងដែន អ្នកទាំងឡាយចូររក្សាខ្លួន ព្រោះភ័យកើតអំពីវត្ថុជាទីពឹងហើយ ។

ចប់ បទកុសលមាណវជាតក ទី ៦ ។

## លោមសកស្សបជាតក

(៨៦៧) (ព្រះឥន្ទ្រនិយាយ នឹងព្រះបាទព្រហ្មទត្តថា) បពិត្រព្រះរាជា បើព្រះអង្គញ៉ាំងឥសី ឈ្មោះលោមសកស្សបៈ ឲ្យបូជាយញ្ញ ព្រះអង្គនឹងបានទៅជាបុគ្គលមិនចាស់មិនស្លាប់ ស្មើនឹងព្រះឥន្ទ្រដោយពិត ។
(៨៦៨) (តាបសពោធិសត្វពោល នឹងអាមាត្យថា) បុគ្គលមិនគួរប្រាថ្នានូវផែនដី ដែលមានសមុទ្រព័ទ្ធជុំវិញ ដូចជាកុណ្ឌលគឺសាគរ ព្រមទាំងពាក្យតិះដៀលនេះ ម្នាលសេយ្យាមាត្យ អ្នកចូរដឹងយ៉ាងនេះចុះ ។
(៨៦៩) ម្នាលព្រាហ្មណ៍ ការប្រព្រឹត្ត (ចិញ្ចឹមជីវិត)ណា ដោយកិរិយាបំផ្លាញជីវិតគេ ឬដោយការប្រព្រឹត្តមិនត្រូវតាមធម៌ មុខគួរឲ្យតិះដៀលនូវការបានយសនិងការបាននូវទ្រព្យ ដោយការប្រព្រឹត្តនោះ ។

(៨៦៦) អបិ ចេ បត្តមាទាយ អនាគារោ បរិព្វជេ
សាយេវ ជីវិកា សេយ្យោ យា ចាធម្មេន ឯសនា ។

(៨៦៧) អបិ ចេ បត្តមាទាយ អនាគារោ បរិព្វជេ
អញ្ញំ អហឹសយំ លោកេ អបិ រជ្ជេន តំ វរំ ។

(៨៦៨) ពលំ ចន្ទោ ពលំ សុរិយោ ពលំ សមណព្រាហ្មណា
ពលំ វេលា សមុទ្ទស្ស ពលាតិពលមិត្ថិយោ ។

(៨៦៩) យថា ឧគ្គតបំ សន្តំ ឥសឹ លោមសកស្សបំ
បិតុ អត្ថាយ ចន្ទវតី វាជបេយ្យំ អយាជយិ ។

(៨៧០) តំ លោភបកតំ កម្មំ កដុកំ កាមហេតុកំ
តស្ស មូលំ គវេសិស្សំ ឆេច្ឆំ រាគំ សពន្ធនំ ។

(៨៧១) ធិរត្ថុ កាមេ សុពហូបិ លោកេ
តបោវ សេយ្យោ កាមគុណេហិ រាជ
តបោ ករិស្សាមិ បហាយ កាមេ
តវេវ រដ្ឋំ ចន្ទវតី ច ហោតូតិ ។

លោមសកស្សបជាតកំ សត្តមំ ។



(៨៦៦) បុគ្គលបួសដើរបិណ្ឌបាត ការចិញ្ចឹមជីវិតនោះ ប្រសើរជាង ការស្វែងរកខុសធម៌ ។

(៨៦៧) បុគ្គលបួសដើរបិណ្ឌបាត មិនបៀតបៀនជនដទៃ ក្នុងលោក ការនោះប្រសើរជាងរាជសម្បត្តិទៅទៀត ។

(៨៦៨) (មហាជន និយាយថា) ព្រះចន្ទមានកំឡាំង ព្រះអាទិត្យមាន កំឡាំង ពួកសមណព្រាហ្មណ៍មានកំឡាំង ច្រាំងសមុទ្រមានកំឡាំង ឯពួកស្ត្រីមានកំឡាំងលើសលុបជាងកំឡាំង (នោះ ៗ ទៅទៀត) ។

(៨៦៩) ដូចជាកញ្ញានាងឈ្មោះចន្ទវតី បាននាំឥសីឈ្មោះលោមសក-ស្សបៈ មានតបៈដ៏ខ្ពង់ខ្ពស់ ឲ្យបូជាយញ្ញការបូជា ឈ្មោះវាជបេយ្យៈ ដ៏បូជាដោយការសម្លាប់សត្វចិញ្ចឹម ដើម្បីប្រយោជន៍ដល់បិតា ។

(៨៧០) (តាបស...) អំពើដែលធ្វើដោយសេចក្តីលោភនោះ ជាអំពើក្តៅក្រហាយ មានកាមជាហេតុ អាត្មានឹងស្វែងរកឫសនៃអំពើនោះ នឹងកាត់នូវរាគៈ ព្រមទាំងចំណង ។

(៨៧១) អាត្មាតិះដៀលនូវកាមទាំងឡាយ ដ៏ច្រើនក្រៃពេក ក្នុងលោក បពិត្រព្រះរាជា ការព្យាយាមដុតកំដៅកិលេស ប្រសើរបំផុត ជាង កាមគុណទាំងឡាយ អាត្មានឹងលះបង់កាម ហើយធ្វើព្យាយាម បំផ្លាញកិលេស ឯដែននឹងនាងចន្ទវតីចូរជារបស់ព្រះអង្គវិញចុះ ។

ចប់ លោមសកស្សបជាតក ទី ៧ ។

# ចក្កវាកជាតកំ

(៨៧២) កាសាយវត្ថេ សកុណេ វទាមិ
ទុវេ ទុវេ នន្ទមនេ ចរន្តេ
កំ អណ្ឌជំ អណ្ឌជមានុសេសុ
ជាតិំ បសំសន្តិ តទិង្ឃ ព្រូថ ។

(៨៧៣) អម្ហេ មនុស្សេសុ មនុស្សហិំស
អនុព្វតេ ចក្កវាកេ វទន្តិ
កល្យាណភាវម្ហេ ទិជេសុ សម្មតា
(អភិរូបា វិចរាម អណ្ណវេ)
ន ឃាសហេតុបិ ករោម បាបំ ។

(៨៧៤) កិំ អណ្ណវេ កានិ ផលានិ ភុញ្ជេ
មំសំ កុតោ ខាទថ ចក្កវាកា
កិំ ភោជនំ ភុញ្ជថ វេ អនោមា
ពលញ្ច វណ្ណោ ច អនប្បរូបា ។



# ចក្កវាកជាតក

(៨៧២) (ក្អែកនិយាយនឹងចាក្រពាកថា) ខ្ញុំសូមសួរនូវពួកសត្វបក្សីមានសម្បុរដូចសំពត់ ដែលស្រលក់ដោយទឹកអម្ចត់ ជាសត្វមានចិត្តរីករាយ ត្រាច់ទៅទាំងគូ ៗ ចុះក្នុងពួកកំណើតជាអណ្ឌជៈទាំងមនុស្សទាំងឡាយ តែងសរសើរនូវកំណើតអណ្ឌជៈណា អ្នកចូរពោលនូវហេតុនោះ មកមើល ។

(៨៧៣) (ចាក្រពាក តបថា) ម្នាលក្អែក ជាសត្វបៀតបៀនមនុស្ស ពួកជនតែងពោលសរសើរយើងថាចាក្រពាកថា ជាសត្វប្រព្រឹត្តសមគួរ ក្នុងចំណោមនៃមនុស្សទាំងឡាយ ទាំងគេបានសន្មតយើងថា ជាសត្វមានគុណល្អ ក្នុងចំណោមនៃសត្វស្លាបទាំងឡាយ (ពួកយើងមានសភាពជាសត្វឥតភ័យ ត្រាច់ទៅផ្សេង ៗ ក្នុងស្រះឈូក) ពួកយើងមិនធ្វើបាប ព្រោះហេតុតែចំណីឡើយ ។

(៨៧៤) (ក្អែក...) ម្នាលចាក្រពាកទាំងឡាយ ជាអ្នកមិនថោកទាប អ្នកទាំងឡាយបរិភោគផ្លែឈើអ្វី ចុះស៊ីសាច់អ្វី បរិភោគភោជនអ្វីក្នុងស្រះ បានជាកម្លាំងនិងសម្បុរ មានសភាពមិនតិច ។

(៤៧៥) ន អណ្ណវេ សន្តិ ផលានិ ធង្ក
មំសំ កុតោ ខាទិតុំ ចក្កវាកេ
សេវាលភក្ខម្ហ អវានភោជនា
(ន ឃាសហេតុបិ ករោម បាបំ)
អភីតរូបា វិចរាម អណ្ណវេ ។

(៤៧៦) ន មេ ឥទំ រុច្ចតិ ចក្កវាក
អស្មិំ ភវេ ភោជនសន្និកាសោ
អហោសិ បុព្វេ តតោ មេ អញ្ញថា
ឥច្ចេវ មេ វិមតិ ឯត្ថ ជាតា ។

(៤៧៧) អហម្បិ មំសានិ ផលានិ ភុញ្ជេ
អន្នានិ ច លោណិកតេលិកានិ
រសំ មនុស្សេសុ លភាមិ ភោត្តុំ
សូរោវ សង្គាមមុខំ វិជេត្វា
ន ច មេ តាទិសោ វណ្ណោ ចក្កវាក យថា តវ ។



(៤៧៥) (ទាក្រពាក...) ម្នាលក្អែក ផ្លែឈើទាំងឡាយ មិនមានក្នុងស្រះទេ ពួកទាក្រពាកបានសាច់បរិភោគអំពីណា ពួកយើងជាអ្នកបរិភោគសារាយ បរិភោគតែទឹកមិនល្អក់ (ពួកយើងមិនធ្វើបាប ព្រោះហេតុតែចំណីឡើយ) ពួកយើងមានសភាពជាអ្នកឥតភ័យ ត្រាច់ទៅផ្សេង ៗ ក្នុងស្រះ ។

(៤៧៦) (ក្អែក...) ម្នាលទាក្រពាក ភោជននេះ មិនគាប់ចិត្តយើងទេ ខ្ញុំអ្នកមានសភាព ប្រហែលនឹងភោជនក្នុងលំនៅនេះ កាលដើមខ្ញុំមានសេចក្តីត្រេកអរ (យ៉ាងនេះ) ខាងក្រោយមក ខ្ញុំមានសេចក្តីត្រេកអរផ្សេង សេចក្តីសង្ស័យរបស់ខ្ញុំ កើតមានក្នុងហេតុនុ៎ះ ដោយប្រការដូច្នេះឯង ។

(៤៧៧) ឯខ្លួនយើង តែងបានបរិភោគសាច់ នឹងផ្លែឈើទាំងឡាយផង នូវចំណីអាហារផងលាយអម្បិល នឹងប្រេងទាំងឡាយផង ខ្លួនយើងតែងបានបរិភោគនូវរស ក្នុងពួកមនុស្សដូចបុគ្គល ក្លៀវក្លាបានឈ្នះ នូវប្រមាណនៃសត្រូវ ម្នាលទាក្រពាក ឯសម្បុររបស់ខ្ញុំ មិនដូចជាសម្បុររបស់អ្នកទេ ។

(៨៧៨) អសុទ្ធកម្មោសិ ខណានុបាតី

កិច្ឆេន តេ លព្ភតិ អន្នបានំ

ន តុស្សសិ រុក្ខផលេហិ ជន្តុ

មំសានិ វា យានិ សុសានមជ្ឈេ ។

(៨៧៩) យោ សាហសេន អធិគម្ម ភោគេ

បរិភុញ្ជតិ ជន្តុ ខណានុបាតី

តតោ ឧបក្កោសតិ នំ សភាវោ

ឧបក្កុដ្ឋោ វណ្ណពលំ ជហាតិ ។

(៨៨០) អប្បម្បិ ចេ និព្វុតិ ភុញ្ជតិ យទិ

អសាហសេន អបរូបឃាតី

ពលញ្ច វណ្ណោ ច តទស្ស ហោតិ

ន ហិ សព្វោ អាហារមយេន វណ្ណោតិ ។

បណ្ណកជាតកំ អដ្ឋមំ ។



(៨៧៨) (ពាក្រោក...) អ្នកជាសត្វមានអាហារមិនស្អាត តែងលបចាក់ក្នុងខណៈ (ដែលគេធ្វេសប្រហែស) អ្នកឯង តែងបាននូវចំណីអាហារនិងទឹកផឹកដោយលំបាក ម្នាលក្អែក អ្នកឯង មិនត្រេកអរដោយផ្លែឈើទាំងឡាយ មួយទៀត សាច់ទាំងឡាយណា ដែលមាននៅ ក្នុងកណ្តាលនៃព្រៃស្មសាន អ្នកមិនត្រេកអរ នឹងសាច់នោះឡើយ ។

(៨៧៩) ម្នាលក្អែក បុគ្គលណាជាអ្នកលបចាក់ក្នុងខណៈ (ដែលគេធ្វេសប្រហែស) បាននូវភោគៈទាំងឡាយ ដោយអំពើដ៏អាក្រក់ហើយ បរិភោគ ដល់មកខាងក្រោយ អ្នកផង នឹងតិះដៀលបុគ្គលនោះ បុគ្គលដែលត្រូវគេតិះដៀលនោះ រមែងសាបសូន្យ ពណ៌សម្បុរ និងកំឡាំង ។

(៨៨០) បុគ្គលបើទុកជា បរិភោគរបស់ត្រជាក់ (ឥតទោស) សូម្បីតិចតួច តែជាអ្នកមិនបៀតបៀនដទៃ ដោយអំពើអាក្រក់ កំឡាំងនិងសម្បុរ រមែងកើតមាន ដល់បុគ្គលនោះ ព្រោះថា សម្បុរទាំងអស់ មិនមែនសុទ្ធតែសម្រេចមក អំពីអាហារទេ ។

ចប់ បណ្ណកជាតក ទី ៨ ។

# ហលិទ្ទិរាគជាតកំ

(៥៨១) សុតិតិក្ខំ អរញ្ញម្ហិ បន្តម្ហិ សយនាសនេ
យេ ច គាមេ តិតិក្ខន្តិ តេ ឧឡារតរា តយា ។

(៥៨២) អរញ្ញា គាមមាគម្ម កឹសីលំ កឹវតំ អហំ
បុរិសំ តាត សេវេយ្យំ តំ មេ អក្ខាហិ បុច្ឆិតោ ។

(៥៨៣) យោ តំ វិស្សាសយេ តាត វិស្សាសញ្ច ខមេយ្យ តេ
សុស្សូសី ច តិតិក្ខី ច តំ ភជេហិ ឥតោ គតោ ។

(៥៨៤) យស្ស កាយេន វាចាយ មនសា នត្ថិ ទុក្កដំ
ឧរសីវ បតិដ្ឋាយ តំ ភជេហិ ឥតោ គតោ ។

(៥៨៥) យោ ច ធម្មេន ចរតិ ចរន្តោបិ ន មញ្ញតិ
វិសុទ្ធការឹ សប្បញ្ញំ តំ ភជេហិ ឥតោ គតោ ។



# ហលិទ្ទិរាគជាតក

(៥៨១) (នាងកុមារិកា និយាយនឹងតាបសកុមារថា) ការដែលលោក អត់ទ្រាំ ក្នុងព្រៃជាសេនាសនៈដ៏ស្ងាត់ ជាការប្រពៃហើយ តែថា ពួកជនណា អត់ទ្រាំនៅក្នុងស្រុក ពួកជនទាំងនោះឈ្មោះថា ប្រសើរលើសលុប ជាងលោកទៅទៀត ។

(៥៨២) (តាបសកុមារ សួរតាបសពោធិសត្វជាបិតាថា) បពិត្របិតា លុះដល់ខ្ញុំចេញអំពីព្រៃមកកាន់ស្រុក តើគួរសេពគប់បុរសមានសីលដូចម្តេច មានវត្តដូចម្តេច ខ្ញុំសួរហើយ សូមបិតាប្រាប់ហេតុនោះ ។

(៥៨៣) (តាបសពោធិសត្វ ..) នែពុក បើបុគ្គលណាស្និទ្ធស្នាលនឹងអ្នក ថែមទាំងគាប់ចិត្តនឹងសេចក្តីស្និទ្ធស្នាលរបស់អ្នក ហើយស្តាប់បង្គាប់ នឹងអត់ទ្រាំ (នូវពាក្យសំដី) អ្នកចេញអំពីព្រៃនេះទៅ គួរសេពគប់បុគ្គលនោះចុះ ។

(៥៨៤) បុគ្គលណាមិនមានអំពើអាក្រក់ ដោយកាយវាចាចិត្ត អ្នកចេញអំពីព្រៃនេះទៅ គួរតាំងខ្លួនដូចជាកូនហើយសេពគប់បុគ្គលនោះចុះ ។

(៥៨៥) មួយទៀត បុគ្គលណាប្រព្រឹត្តតាមធម៌ ទោះបីកំពុងប្រព្រឹត្តក៏មិនប្រកាន់ខ្លួន លុះដល់អ្នកចេញអំពីព្រៃនេះទៅ គួរសេពគប់នូវបុគ្គលដែលជាអ្នកធ្វើអំពើបរិសុទ្ធ ប្រកបដោយប្រាជ្ញានោះចុះ ។

(៤៨៦) ហលិទ្ទរាគំ កបិចិត្តំ បុរិសំ រាគវិរាគិនំ

តាទិសំ តាត មា សេវិ និម្មនុស្សម្បិ ចេ សិយា ។

(៤៨៧) អាសីវិសំវ កុបិតំ មីឡ្ហលិត្តំ មហាបថំ

អារកា បរិវជ្ជេហិ យានីវ វិសមំ បថំ ។

(៤៨៨) អនត្ថា តាត វឌ្ឍន្តិ ពាលំ អច្ចុបសេវតោ

មាស្សុ ពាលេន សង្គច្ឆិ អមិត្តេនេវ សព្វទា ។

(៤៨៩) តំ តាហំ តាត យាចាមិ ករស្សុ វចនំ មម

មាស្សុ ពាលេន សង្គច្ឆិ ទុក្ខោ ពាលេហិ សង្គមោតិ ។

ហលិទ្ទរាគជាតកំ នវមំ ។



(៤៨៦) នែបុត្រ បុគ្គលណា មានចិត្តដូចជាសំពត់ជ្រលក់រមៀត មានចិត្តដូចស្វា ត្រេកអរហើយ បែរជាមិនត្រេកអរវិញ បើទុកជា (គ្រាន់តែមួយរូបនេះ) មិនមានមនុស្សសោះ អ្នកកុំគប់រកបុរសបែបនោះឡើយ ។

(៤៨៧) អ្នកចូរចៀសវាងចេញ (បុគ្គលបែបនោះ) អំពីចម្ងាយ ឲ្យដូចបុគ្គលចៀសវាងនូវអាសិរពិសដែលក្រោធ ឬចៀសវាងនូវផ្លូវធំដែលប្រឡាក់ដោយលាមក ដូចបុគ្គលអ្នកទៅដោយយាន ចៀសវាងនូវផ្លូវមិនស្មើ ។

(៤៨៨) នែបុត្រ អំពើមិនជាប្រយោជន៍ទាំងឡាយ តែងចំរើនដល់បុគ្គលដែលគប់រកបុគ្គលពាល អ្នកកុំគប់រកបុគ្គលពាល ដែលដូចជាសត្រូវសព្វ ៗ កាលឡើយ ។

(៤៨៩) នែបុត្រ ព្រោះហេតុនោះហើយ បានជាយើង សូមអង្វរអ្នក ចូរអ្នកធ្វើតាមពាក្យយើង ចូរអ្នកកុំគប់រកបុគ្គលពាលឡើយ (ព្រោះ) ការគប់រកនូវបុគ្គលពាលទាំងឡាយ តែងនាំមកនូវសេចក្តីទុក្ខ ។

ចប់ ហលិទ្ទរាគជាតក ទី ៩ ។

# សមុគ្គជាតកំ

(៨៤០) កុតោ នុ អាគច្ឆថ ភោ តយោ ជនា
ស្វាគតា ឯថ និសីទថាសនេ
កច្ចិត្ថ ភោន្តោ កុសលំ អនាមយំ
ចិរស្សមព្ភាគមនំ ហិ វោ ឥធ ។

(៨៤១) អហមេវ ឯកោ ឥធមជ្ជ បត្តោ
ន ចាបិ មេ ទុតិយោ កោចិ វិជ្ជតិ
កិមេវ សន្ធាយ តេ ភាសិតំ ឥសេ
កុតោ នុ អាគច្ឆថ ភោ តយោ ជនា ។

(៨៤២) តុវញ្ច ឯកោ ភរិយា ច តេ បិយា
សមុគ្គបក្ខិត្តនិកិណ្ណមន្តរេ
សា រក្ខិតា កុច្ឆិគតា ច តេ សទា
វាយុស្ស បុត្តេន សហា តហឹ រតា ។



# សមុគ្គជាតក

(៨៤០) (តាបសពោធិសត្វ សួរអារក្សទឹកថា) នែអ្នកទាំងឡាយដ៏ចំរើន ពួកអ្នកទាំង ៣ នាក់ មកអំពីទីណា ពួកអ្នកមកស្រួលហើយ ចូរមកអង្គុយលើអាសនៈទៅ នែអ្នកដ៏ចំរើន អ្នកមានសេចក្តីសុខស្រួល មិនមានជម្ងឺផ្តាត់ទេឬ ព្រោះយូរណាស់ហើយ អ្នកទាំងឡាយទើបមកក្នុងទីនេះ ។

(៨៤១) (ទានវៈ(១)តបនឹងតាបសថា) ខ្ញុំមកក្នុងទីនេះតែម្នាក់ឯងទេ ខ្ញុំមិនមានអ្នកណាមួយជាគំរប់ពីរទេ បពិត្រឥសី លោកសំដៅរកហេតុអ្វី បានជាពោលថា នែអ្នកដ៏ចំរើន ពួកអ្នកទាំង ៣ នាក់មកអំពីទីណា ។

(៨៤២) (តាបស...) ខ្លួនអ្នកឯងម្នាក់ផង ភរិយាជាទីស្រឡាញ់របស់អ្នក ដែលអ្នកដាក់ក្នុងស្មុគ ហើយលេបចូលទៅក្នុងពោះផង ភរិយានោះ ដែលអ្នករក្សាហើយនៅក្នុងពោះសព្វកាល ត្រេកអរជាមួយនឹង (វិជ្ជាធរ) ជាវាយុបុត្ត ក្នុងស្មុគនោះផង ។

---

(១) អសុរៈ សាមញ្ញ ។

(៨៩៣) សំវុត្ថរោទា ឥសិជា ព្យាការោ
សោណានហេ តត្ថ សមុក្កមុក្កិលិ
អនត្តំ ករិយំ សុចិមាលធារិនី
ភយុស្ស បុត្តេន សហា តហឹ រតំ ។

(៨៩៤) សុជិដ្ឋបុត្តតាធុវត្តិតា
ហឹឌា ឧក យេ បមុខាវសត្តិតា
យថា ហវេ តាឈារីវេត្ត រត្តិតា
ឧដ្ឋា មយិ អញ្ញមភិប្បមោទតិ ។

(៨៩៥) ធិក ច រត្តា ច មយា ឧបដ្ឋិតា
តបស្សិតា ជោតិរិវ វនេ វសិំ
សា ធម្មមោញ្ញម អធម្មមាចរិ
អគ្គីយវោតា បមុជាហិ សន្តកេ ។

(៨៩៦) សរីមជ្ឈម្ហិ បិតាតិ មញ្ញហំ
មយ្ហំ អយន្តិ អសតិំ អសញ្ញតិំ
សា ធម្មមោញ្ញម អធម្មមាចរិ
អគ្គីយវោតា បមុជាហិ សន្តកេ ។



(៨៩៣) ពានរៈនោះ លុះអស់ព្យាករហើយ ក៏មានសភាពកកក់ស្មុគហើយ ភ្ញាក់ស្មារតីបញ្ញាក្នុងទីនោះ ក៏បានឃើញការយាមានរូបយ៉ាងស្អាត ប្រពន្ធខ្ញុំកប្រមូល ក្រោករជាមួយនឹងវិជ្ជាធរ ជាវេយ្យបុត្តក្នុង ស្រុកនោះ ។

(៨៩៤) ព្រះករុណាដែលជាអ្នកប្រព្រឹត្តតបៈដ៏ខ្ពង់ខ្ពស់ បានឃើញពោត ក្រឹមក្រៀមនេះហើយ ពួកជនណាជាបុគ្គលដោកខាប ពួកជននោះ រមែងលុះអំណាចស្ត្រី ដូចទំនៀលបានកេក្ខពុតខ្លួស្ត្រី ដូចជាដើត ក្នុងទីនេះ ស្ត្រីនោះប្រែខ្លួនទំនង ហើយកែកាយមិនបុសខាងវិញ ។

(៨៩៥) ខ្ញុំបានចំនុកបម្រើស្ត្រីនោះ ទាំងយប់ទាំងថ្ងៃ ដូចជាភ្លើង ដែល លោកមានតបៈនៅ ក្នុងព្រៃបូជាហើយ ស្ត្រីនោះប្រព្រឹត្តកន្លងធម៌ ហើយប្រព្រឹត្តអធម៌វិញ ការសេពគប់ស្មាល ជាមួយនឹងពួកស្ត្រី ជា សភាពមិនគួរធ្វើសោះឡើយ ។

(៨៩៦) ខ្ញុំសំគាល់ស្ត្រី ដែលជាគូសប្បុរស មិនសង្រួមជា (ស្ត្រីនេះ) ប៉ិននៅ ក្នុងកណ្តាលសរីរៈ ស្ត្រីនេះជារបស់អញដូច្នេះ ស្ត្រីនោះ ប្រព្រឹត្តកន្លងធម៌ ហើយប្រព្រឹត្តអធម៌វិញ ការសេពគប់ស្មាល ជាមួយ នឹងពួកស្ត្រី ជាសភាពមិនគួរធ្វើសោះឡើយ ។

(៥៩៧) សុរក្ខិតម្មេតិ កថន្នុ វិស្សសេ
អនេកចិត្តាសុ ន ហេត្ថ រក្ខណា
ឯតា ហិ បាតាលបបាតសន្និភា
ឯត្ថ បមត្តោ ព្យសនំ និគច្ឆតិ ។

(៥៩៨) តស្មា ហិ តេ សុខិនោ វីតសោកា
យេ មាតុគាមេហិ ចរន្តិ និស្សដា
ឯតំ សិវំ ឧត្តមមាភិបត្ថយំ
ន មាតុគាមេហិ ករេយ្យ សន្ថវំ ។

សមុគ្គជាតកំ ទសមំ ។

## បូតិមំសជាតកំ

(៥៩៩) ន ខោ រុច្ចតិ មេ អាឡិ បូតិមំសស្ស បេក្ខណា
ឯតាទិសា សខារស្មា អារកា បរិវជ្ជយេ ។

(៦០០) ឧម្មត្តិកា អយំ វេណី វណ្ណេតិ បតិនោ សខី
បជ្ឈាយិ បដិគច្ឆន្តី អាគតំ មេណ្ឌមាតរំ ។



(៥៩៧) ចុះបុគ្គលគួរទុកចិត្តថា អាត្មាអញបានរក្សាស្រីទុកល្អហើយដូច្នេះ ដោយហេតុដូចម្តេចបាន ព្រោះមិនមានទីរក្សាទុក នូវពួកស្រីដែលមានចិត្តច្រើនយ៉ាងនេះបានទេ ដ្បិតពួកស្រីទាំងនុ៎ះ ប្រហែលនឹងអន្លង់គឺបាតសមុទ្រ បុគ្គលដែលប្រមាទក្នុងពួកស្រីទាំងនោះហើយ រមែងដល់នូវសេចក្តីវិនាស ។

(៥៩៨) ព្រោះហេតុនោះឯង បុគ្គលពួកណា ជាអ្នកប្រព្រឹត្តរលាស់ខ្លួនចេញចាកពួកមាតុគ្រាម បុគ្គលពួកនោះ តែងបានសុខប្រាសចាកសេចក្តីសោក បុគ្គលកាលបើប្រាថ្នាសេចក្តីក្សេម ដ៏ឧត្តមនុ៎ះ មិនគួរធ្វើនូវសេចក្តីស្និទ្ធស្នាល នឹងពួកមាតុគ្រាមឡើយ ។

ចប់ សមុគ្គជាតក ទី ១០ ។

## បូតិមំសជាតក

(៥៩៩) (មេពពែនិយាយ នឹងមេចចកថា) នែសំឡាញ់ ការក្រឡេកមើល នៃចចកឈ្មោះបូតិមំសៈ មិនគាប់ចិត្តយើងទេ បុគ្គលគួរវៀរឲ្យឆ្ងាយអំពីសំឡាញ់បែបនេះ ។

(៦០០) (ចចកឈ្មោះបូតិមំសៈ ពោលតិះដៀលមេចចកជាប្រពន្ធខ្លួនថា) មេចចកឈ្មោះវេណីនេះ ជាសត្វឆ្កួត ពោលសរសើរនូវសំឡាញ់ប្រាប់ដល់អញជាប្តី ហើយបែរជាសោកស្រណោះ នូវមេពពែដែលទើបនឹងមក ហើយត្រឡប់ថយទៅវិញ ។

(៦០១) កិំ នោសិ សម្ម ឧម្មត្តោ ឧម្មត្តោ អវិចក្ខណោ
សោ ត្វំ មតាលយំ កត្វា អកាលេន វិបេក្ខសិ ។

(៦០២) ន អកាលេ វិបេក្ខេយ្យ កាលេ បេក្ខេយ្យ បណ្ឌិតោ
បូតិមំសោវ បជ្ឈាយិ យោ អកាលេ វិបេក្ខតិ ។

(៦០៣) បិយំ ខោ អាគតំ មេ ហោតុ បុណ្ណបត្តំ ទទាហិ មេ
បតិ សញ្ជីវិតោ មយ្ហំ ឯយ្យាសិ បិយបុច្ឆិតា ។

(៦០៤) បិយំ ខោ អាគតំ តេ ហោតុ បុណ្ណបត្តំ ទទាមិ តេ
មហតា បរិហារេន(១) ឯស្សំ កយិរាហិ ភោជនំ ។

(៦០៥) កីទិសោ តុយ្ហំ បរិវារោ យេសំ កាហាមិ ភោជនំ
កឹនាមកា ច តេ សព្វេ តេ មេ អក្ខាហិ បុច្ឆិតា ។

១ ម. ឆ. បរិវារេន ។



(៦០១) (មេចចក និយាយតបថា) នែសំឡាញ់ អ្នកឯងទៅតើជាសត្វឆ្កួតទៀត មិនចេះពិចារណាអ្វីសោះ អ្នកឯងធ្វើពុតជាស្លាប់ ហើយក្រឡេកមើលខុសកាល ។

(៦០២) (អភិសម្ពុទ្ធគាថា) អ្នកប្រាជ្ញមិនគប្បីក្រឡេកមើល ក្នុងកាលមិនគួរ គប្បីក្រឡេកមើលតែក្នុងកាលដ៏គួរ បុគ្គលណា ក្រឡេកមើល ក្នុងកាលមិនគួរ បុគ្គលនោះ រមែងសោកស្រណោះ ដូចចចកឈ្មោះបូតិមំសៈ ។

(៦០៣) (មេចចកនិយាយ នឹងមេពពែថា) ម្នាលសំឡាញ់ សេចក្តីស្រឡាញ់របស់យើង សូមឲ្យមាននៅដដែល សូមនាងឲ្យរង្វាន់ដល់យើង ប្តីរបស់យើងរស់ ដោយខ្លួនឯងវិញហើយ កាលបើខ្ញុំសួរ អំពីសេចក្តីស្រឡាញ់ហើយ (គប្បីមកជាមួយនឹងយើង) ។

(៦០៤) (មេពពែ...) នែសំឡាញ់ របស់ជាទីស្រឡាញ់ ចូរមានដល់នាង ដូចដែលចុះឥឡូវយើងឲ្យរង្វាន់ដល់នាងហើយ (តែថា) យើងនឹងមកជាមួយនឹងបរិវារច្រើន (បើដូច្នោះ) នាងចូររៀបភោជនទុកផង ។

(៦០៥) (មេចចក...) បរិវាររបស់នាង ដូចម្តេចទៅ ខ្ញុំនឹងរៀបភោជន ចាំទទួលភ្ញៀវបរិវាររបស់នាង បរិវារនាងទាំងអស់នោះ តើមានឈ្មោះដូចម្តេច យើងសួរ នាងចូរប្រាប់នូវបរិវារនោះ ។

(២០២)មាលិយោ ចតុរក្ខោ ច  បិង្គិយោ អថ ជម្ពុកោ
ឯតេ សោ មយ្ហំ បរិវារេ  តេសំ កយិរាសិ ភោជនំ ។

(២០៣)និក្ខន្តាយ អគារស្មា  ភណ្ឌកម្បិ វិនស្សតិ(១)
អកេតំ អារោគ្យំ វជ្ជំ  ឥធេវ វស្ស មា គមាតិ ។

ចូឡហំសជាតកំ ឯកាទសមំ ។

## ទូតជាតកំ

(២០៨)យោ តេ បុត្តកេ អក្ខាទិ  និទ្ទុកត្តោ អទូសកេ
តស្មឹ ទាឋំ និបាតេហិ  មា តេ មុញ្ចិត្ថ ជីវតោ ។

(២០៩)អាកិណ្ណលុទ្ទោ បុរិសោ  ធាតិចេលំវ មក្ខិតោ
បទេសំ តំ ន បស្សាមិ  យត្ថ ទាឋំ និបាតយេ ។

(២១០)អកតញ្ញុស្ស បោសស្ស  និច្ចំ វិវរទស្សិនោ
សព្ពញ្ចេ បថវឹ ទជ្ជា  នេវ នំ អភិរាធយេ ។

១ ម. ឧតា ។



(២០២) (មេតាតែ...) (ឆ្កែ ៤ ក្បាល) គឺឆ្កែឈ្មោះមាលិយៈ ១ ឆ្កែឈ្មោះចតុរក្ខៈ ១ ឆ្កែឈ្មោះបិង្គិយៈ ១ ឆ្កែឈ្មោះជម្ពុកៈ ១ ឆ្កែបួននេះ ជាបរិវាររបស់យើង នាងចូររៀបភោជនបម្រើឆ្កែទាំងនោះចុះ ។

(២០៣) (មេបបក...) កាលបើនាងចេញទៅអំពីផ្ទះ ទ្រព្យរបស់ មុខជាវិនាសមិនខាន ចាំយើងប្រាប់សេចក្តីមិនមានរោគដល់សំឡាញ់ នាងចូរនៅក្នុងទីនេះចុះ នាងកុំបាច់ទៅឡើយ ។

ចប់ ចូឡហំសជាតក ទី ១១ ។

## ទូតជាតក

(២០៨) (ក្ងោកពោលនិយាយ នឹងមេខ្សែងថា) បុរសណាដែលនាងបាន ឲ្យអាហារ ហើយស៊ីកូនតូច ៗ ដែលមិនបានប្រទូស្ត (ដល់ខ្លួន) នាងចូរកាំខ្លួនបុរសនោះនឹងចង្កូម កុំឲ្យបុរសនោះរួច (អំពីដៃ) នាង មានជីវិតទៅឡើយ ។

(២០៩) (មេខ្សែងតបនឹងក្ងោកថា) បុរសនេះមានសេចក្តីលោភខ្លាំង ដ៏ប្រឡាក់ប្រឡូស ដូចជាកំណាត់សំពត់ របស់មេដោះ ខ្ញុំមិន ឃើញនូវប្រទេសដំណ ហើយចាំដោយចង្កូមនោះបានឡើយ ។

(២១០) បុគ្គលបើទុកជាឲ្យនូវសម្បត្តិ លើផែនដីទាំងអស់ ដល់បុរស អកតញ្ញូ ដែលសំឡឹងរើញទោសជានិច្ច ក៏នៅតែធ្វើបុរសនោះ ឲ្យត្រេកអរមិនបាន ។

[៦១១] កិន្នុ សុពាហុ តរមានរូបោ
បច្ចាគតោសិ សហ មាណវេន
កឹ កិច្ចមត្ថំ ឥធមត្ថិ តុយ្ហំ
អក្ខាហិ មេ បុច្ឆិតោ ឯតមត្ថំ ។

[៦១២] យោ តេ សខា ទទ្ទរេ សាធុរូបោ
តស្ស វធំ បរិសង្កាមិ អជ្ជ
បុរិសស្ស កម្មាយតនានិ សុត្វា
នាហំ សុខី ទទ្ទរំ អជ្ជ មញ្ញេ ។

[៦១៣] កានិស្ស កម្មាយតនានិ អស្សុ
បុរិសស្ស វុត្តិសមោធានតាយ
កំ វា បដិញ្ញំ បុរិសស្ស សុត្វា
បរិសង្កសិ ទទ្ទរំ មាណវេន ។

[៦១៤] ចិណ្ណា កលិង្គា ចរិតា វណិជ្ជា
វេត្តាចរោ សង្កុបថោបិ ចិណ្ណោ
នដេហិ ចិណ្ណំ សហ វាកុរេហិ
ទណ្ឌេន យុទ្ធម្បិ សមជ្ជមជ្ឈេ ។



(៦១១) (សេនកៈសួរថា) នែអ្នកមានដើមដៃល្អ ចុះដូចម្តេច បានជាអ្នកប្រញាប់ប្រញាល់ត្រឡប់មក ជាមួយនឹងមាណពនេះ អ្នកមានកិច្ចជាប្រយោជន៍ (ដោយមាណពនេះ) ដូចម្តេច ក្នុងទីនេះ ខ្ញុំសួរហើយ អ្នកចូរប្រាប់សេចក្តីនុ៎ះ ។

(៦១២) (ព្រា...) ទទណា ដែលជាសំឡាញ់របស់លោក មានសភាពជាសប្បុរស ខ្ញុំថប់តែបុរសនេះ សម្លាប់ទទណោះ ក្នុងថ្ងៃនេះឯង ខ្ញុំស្តាប់បានឮអំពើរបស់បុរសនេះហើយ ទើបមិនសំគាល់ថា ទទ បានសេចក្តីសុខ ក្នុងថ្ងៃនេះឡើយ ។

(៦១៣) (សេនកៈ...) អ្នកស្តាប់បានឮអំពើសម្រាប់ផ្គុំនូវជីវិត ឲ្យប្រព្រឹត្តទៅរបស់បុរសនេះ ដូចម្តេច មួយទៀត អ្នកស្តាប់បានឮនូវពាក្យប្តេជ្ញារបស់បុរសនេះ ដូចម្តេច បានជាអ្នកថប់ក្រែងតែមាណពនេះ សម្លាប់ទទ ។

(៦១៤) (ព្រា...) បុរសនេះធ្លាប់សញ្ចរ ធ្វើជំនួញក្នុងដែនកលិង្គៈ ធ្លាប់ដើរទៅមក តាមផ្លូវមានផ្តៅសម្រាប់ចរទៅមក តាមខ្សែផ្តៅ ធ្លាប់សញ្ចរជាមួយនឹងពួករាំនឹងដាក់បន្ទាក់ ធ្លាប់លេងគុណដម្បង ក្នុងកណ្តាលមហាស្រព ។

(២១៨) ពទ្ធា កុលិកា មិតមានស្សុពេន
អក្ខា ហិតា សញ្ញមោ អភ្ភតីតោ
អព្យហិតំ បុប្ផកំ អន្យត្តំ
ហត្ថា ធន្ថា បិណ្ឌបដិគ្គហេន ។

(២១៩) គាជិស្ស កម្មាយតនានិ អស្ស
បុរិសស្ស វុត្តិសមោធានតាយ
យថា អយំ ទិស្សតិ លោមបិណ្ឌោ
គាវោ ហតា កិំ បន ទទ្ទរានំ ។

ទទ្ទរជាតកំ ទ្វាទសមំ ។

## តស្សុទ្ទានំ

វរគិជ្ឈ សមជ្ជំ ហំសវរោ
និធិសុហ្វយ ហារិត ពាកលិកោ
អជរាមរ ធន្ត តិតិក្ខ កុរោ
អថ ទ្វាទស បេក្ខុន ទទ្ទរិកេ ។

នវកនិបាតំ និដ្ឋិតំ ។





(២១៨) បុរសនេះច្បាប់ចាក់ក្នុងសត្វបក្សី ច្បាប់ល់ដោយក្បាលកាឡកៈ ច្បាប់ដាក់ទ្រូង (ឱ្យអ្នកលេងស្តា) មានកិរិយាជាអ្នកសង្រួម តែប្រព្រឹត្តកន្លងនូវសីល ច្បាប់ (កស៊ីសម្លាប់អ្នកទោស) ធ្វើមិនឱ្យឈាម ហូរចេញមួយដំណក់ ក្នុងកណ្ដាលកក្រើ មានដៃលោក ដោយការទទួលនូវបិណ្ឌបាតដ៏ក្តៅ (ក្នុងកាលដែលខ្លួនទៅបួស) ។

(២១៩) ខ្ញុំបានឮនូវតែកើតព្រោះចង្កុំដៃក ឱ្យប្រព្រឹត្តទៅរបស់បុរសនេះ (ដែលនេះឯង) នេះដូចជាផ្ទៃរកម (ទេតានៅលើក្សីសក់បុរសនេះ) បុរសនេះសម្លាប់នូវគោតាំងឡាយបានទៅហើយ ណាក៏មិនហាន សម្លាប់នូវសត្វទេ ។

ចប់ ទទ្ទរជាតក ទី ១២ ។

## ឧទ្ទាននៃនវកនិបាតនោះគឺ

និយាយអំពីត្មាតដ៏ប្រសើរ ១ ផនស្នើត ១ ហង្សដ៏ប្រសើរ ១ កំណប់ទ្រព្យ ១ ហារិតកុមារ ១ អ្នកចាំឈ្មោះបុគ្គលិកៈ ១ បុគ្គលមិនចាស់មិនស្លាប់ ១ ក្អែក ១ ការផត់ព្រាំ ១ (អ្នកចាំនី ៣ នាក់មក) ពីណា ១ ការក្រឡេកមើល ១ ទទា ១ រួមត្រូវជា ១២ ។

ចប់ នវកនិបាត ។

## ទសកនិបាតជាតកំ

## ចតុទ្វារជាតកំ

(៦៥៧) ចតុទ្វារមិទំ នគរំ   អាយសំ ទឡ្ហតោរណំ (១)
ឱរុទ្ធបដិរុទ្ធោស្មិ   កឹ បាបំ បកតំ មយា ។
(៦៥៨) សព្វេ អបិហិតា ទ្វារា   ឱរុទ្ធោស្មិ យថា ទិជោ
កិមាធិករណំ យក្ខ   ចក្កាភិនិហតោ អហំ ។
(៦៥៩) លទ្ធា សតសហស្សានិ   អតិរេកានិ វីសតិ
អនុកម្បកានំ ញាតីនំ   វចនំ សម្ម នាការិ ។
(៦៦០) លង្ឃឹ សមុទ្ទំ បក្ខន្ទិ   សាគរំ អប្បសិទ្ធិយំ
ចតុព្ភិ អដ្ឋជ្ឈគមា   អដ្ឋាហិបិ ច សោឡស ។
(៦៦១) សោឡសាហិ ច ពត្តឹស   អត្រិច្ឆំ ចក្កមាសទោ
ឥច្ឆាហតស្ស បោសស្ស   ចក្កំ ភមតិ មត្ថកេ ។

---

១ ម. ឧ. ទឡ្ហតោរណំ ។

## ទសកនិបាតជាតក

## ចតុទ្វារជាតក

(៦៥៧) (មិត្តវិន្ទកៈ សួរទេវតា ថា) ក្រុងនេះមានទ្វារ ៤ ជាវិការៈនៃដែក មានតោរណៈដ៏មាំ ខ្ញុំត្រូវគេឃាត់ឃាំងជាប់ជុំវិញ តើខ្ញុំបានធ្វើបាបអ្វី ។

(៦៥៨) ទ្វារទាំងអស់បិទជិត ខ្ញុំគឺជាប់នៅ ដូចជាសត្វស្លាប (ជាប់នៅក្នុងទ្រុង) បពិត្រយក្ស ហេតុដូចម្តេច ទើបខ្ញុំត្រូវចក្របៀតសង្កិន ។

(៦៥៩) (ទេវតា...) អ្នកបានទ្រព្យជាង ២០ សែន មិនធ្វើតាមពាក្យរបស់ញាតិទាំងឡាយ ដែលជាអ្នកជួយអនុគ្រោះ ដោយល្អ ។

(៦៦០) អ្នកស្ទុះលឿនទៅកាន់ទូក ដែលអណ្តែតទៅកាន់សមុទ្រសាគរ ជាទីសម្រេចប្រយោជន៍តិច បាននាងវេមានិកប្រេត ៤ នាក់ នាងវេមានិកប្រេត ៨ នាក់ លុះចេញអំពីវេមានិកប្រេត ៨ នាក់ ក៏បាននាងវេមានិកប្រេត ១៦ នាក់ ។

(៦៦១) អ្នកចេញអំពីនាងវេមានិកប្រេត ១៦ នាក់ ក៏បាននាងវេមានិកប្រេត ៣២ នាក់ អ្នកជាមនុស្សមានសេចក្តីប្រាថ្នាដ៏លើសលុប បានមកប្រទះនឹងចក្រទាំងចក្រកៀនកិន ខ្ទេចបែកក្បាលនៃបុរសដែលមានសេចក្តីប្រាថ្នាគ្របសង្កត់ ។

(៦៦២) ឧបរិវិសាលា ទុប្បូរា ឥច្ឆា វិសដគាមិនី(១)
យេ ច តំ អនុគិជ្ឈន្តិ តេ ហោន្តិ ចក្កធារិនោ ។

(៦៦៣) ពហុភណ្ឌំ អវហាយ មគ្គំ អប្បដិវេក្ខិយ
យេសំ ចេតំ អសង្ខាតំ តេ ហោន្តិ ចក្កធារិនោ ។

(៦៦៤) កម្មំ សមេក្ខ វិបុលញ្ច ភោគំ
ឥច្ឆំ ន សេវេយ្យ អនត្ថសញ្ហិតំ
ករេយ្យ វាក្យំ អនុកម្បកានំ
តំ តាទិសំ នាតិវត្តេយ្យ ចក្កំ ។

(៦៦៥) កីវចិរំ នុ មេ យក្ខ ចក្កំ សិរសិ ឋស្សតិ
កតិ វស្សសហស្សានិ តំ មេ អក្ខាហិ បុច្ឆិតោ ។

(៦៦៦) អតិសរោ បច្ចសរោ មិត្តវិន្ទ សុណោហិ មេ
ចក្កំ តេ សិរសិ មាវិទ្ធំ ន តំ ជីវំ បមោក្ខសីតិ ។

ចតុទ្វារជាតកំ ចប់ ។

១ ម... តណ្ហា ។



(៦៦២) សេចក្តីប្រាថ្នា ជាធម្មជាតិដ៏ទូលាយលើសលុប ដែលគេបំពេញបានដោយក្រ ជាគ្រឿងដល់នូវសេចក្តីវិបត្តិ ព្រោះសេចក្តីប្រាថ្នា ពួកជនណា ត្រេកអរតាមសេចក្តីប្រាថ្នានោះ ពួកជននោះ រមែងជាអ្នកទ្រទ្រង់នូវចក្រ ។

(៦៦៣) ពួកជនណា មិនពិចារណានូវផ្លូវនេះ ដូចជាអ្នកលះបង់នូវទ្រព្យច្រើន មិនពិចារណានូវផ្លូវ (ដែលខ្លួនត្រូវដើរទៅ) ពួកជននោះ រមែងជាអ្នកទ្រទ្រង់នូវចក្រ ។

(៦៦៤) បុគ្គលគប្បីពិចារណានូវកិច្ចការ ដែលត្រូវធ្វើ និងភោគៈដ៏ច្រើន ហើយមិនគប្បីសេពគប់ នូវសេចក្តីប្រាថ្នា ដែលមិនប្រកបដោយប្រយោជន៍ ធ្វើតាមពាក្យរបស់ពួកជនអ្នកអនុគ្រោះ ចក្រមិនគប្បីវិលសង្កិនបុគ្គលបែបនោះបាន ។

(៦៦៥) (មិត្តវិន្ទកៈ...) បពិត្រយក្ខ ចក្រនឹងឋិតនៅលើក្បាលរបស់ខ្ញុំ អស់កាលយូរប៉ុន្មានហ្ន៎ ប៉ុន្មានពាន់ឆ្នាំ ខ្ញុំសួរហើយ សូមលោកប្រាប់ហេតុនោះ ។

(៦៦៦) (ទេវតា...) ម្នាលមិត្តវិន្ទកៈ អ្នកចូរនឹកលើកឡើងក្រៃលែង នឹកលើកឡើងត្រឡប់ ហើយចូរស្តាប់នូវពាក្យយើង ចក្រ (នេះ) វិលកិនក្បាលរបស់អ្នក អ្នកកាលរស់នៅ រមែងមិនបានរួចទេ ។

ចប់ ចតុទ្វារជាតក ទី ១ ។

## កណ្ហជាតកំ

(៦៦៧) កណ្ហោ វតាយំ បុរិសោ កណ្ហំ ភុញ្ជតិ ភោជនំ
កណ្ហេ ភូមិបទេសស្មឹ ន មយ្ហំ មនសោ បិយោ ។

(៦៦៨) ន វណ្ណេន កណ្ហោ ហោតិ អន្តោសារោ ហិ ព្រាហ្មណោ
យស្មឹ បាបានិ កម្មានិ ស វេ កណ្ហោ សុជម្បតិ ។

(៦៦៩) ឯតស្មឹ តេ សុលបិតេ បដិរូបេ សុភាសិតេ(១)
វរំ ព្រាហ្មណ តេ ទម្មិ យំ កិញ្ចិ មនសិច្ឆសិ ។

(៦៧០) វរញ្ចេ មេ អទោ សក្ក សព្វភូតានមិស្សរ
សុនិក្កោធំ សុនិទ្ទោសំ និល្លោភំ វុត្តិមត្តនោ
និស្នេហមភិកង្ខាមិ ឯតេ មេ ចតុរោ វរេ ។

(៦៧១) កិន្នុ កោធេ វា ទោសេ វា លោភេ ស្នេហេ ច ព្រាហ្មណ
អាទីនវំ សម្បស្សសិ(២) តំ មេ អក្ខាហិ បុច្ឆិតោ ។

១ ម. មនសិច្ឆសិ ។ ២ ឱ. សម្បស្សសិ ។ ម. ត្វំ បស្សសិ ។



## កណ្ហជាតក

(៦៦៧) (សក្កទេវរាជ ពោលថា) ឱហ្ន៎ បុរសនេះ មានសម្បុរខ្មៅ បរិភោគភោជនខ្មៅ នៅក្នុងភូមិប្រទេសក៏ខ្មៅ មិនជាទីពេញចិត្ត របស់យើងឡើយ ។

(៦៦៨) (កណ្ហតាបសពោធិសត្វ ពោលថា) ម្នាលសុជម្បតិ មនុស្សមិនឈ្មោះថា ខ្មៅ ដោយសម្បុរទេ ព្រោះថា មនុស្សមានគុណជាខ្លឹមខាងក្នុង ឈ្មោះថាជាព្រាហ្មណ៍ ឯបាបកម្មមាននៅ ក្នុងមនុស្សណា មនុស្សនោះឯង ឈ្មោះថា ខ្មៅ ។

(៦៦៩) (សក្កទេវរាជ...) ពាក្យនោះ អ្នកពោលល្អហើយ ជាសុភាសិតដ៏គួរ លោកប្រាថ្នាក្នុងចិត្ត ចំពោះពរណាមួយ ខ្ញុំនឹងឲ្យពរ (នោះ) ដល់លោក ។

(៦៧០) (កណ្ហតាបស...) បពិត្រសក្កៈ ជាធំជាងពួកភូតទាំងពួង បើព្រះអង្គនឹងឲ្យពរដល់អាត្មា អាត្មាប្រាថ្នានូវសេចក្តីប្រព្រឹត្តចំពោះខ្លួន គឺការមិនមានក្រោធៈ ១ មិនមានទោសៈ ១ មិនមានលោភៈ ១ មិនមានស្នេហា ១ សូមព្រះអង្គឲ្យនូវពរ ៤ នេះដល់អាត្មា ។

(៦៧១) (សក្កទេវរាជ...) បពិត្រព្រាហ្មណ៍ លោកពិចារណាឃើញច្បាស់នូវទោសដូចម្តេច ក្នុងក្រោធៈ ទោសៈ លោភៈ និងស្នេហា ខ្ញុំសួរហើយ លោកចូរប្រាប់ហេតុនោះ ។

(២៣៦)អប្បោ ហុត្វា ពហុ ហោតិ វឌ្ឍតេ សោ អខន្តិជោ

អាសង្គី ពហុបាយាសោ តស្មា កោធំ ន រោចយេ ។

(២៣៧)ទុដ្ឋស្ស ផរុសា វាចា បរាមាសោ អនន្តរា

តតោ បាណិ តតោ ទណ្ឌោ សត្ថស្ស បរមា គតិ[១]

ទោសោ កោធសមុដ្ឋានោ តស្មា ទោសំ ន រោចយេ ។

(២៣៨)អាលោបសាហសាការា និកតិវញ្ចនានិ ច

ទិស្សន្តិ លោភធម្មេសុ តស្មា លោភំ ន រោចយេ ។

(២៣៩)ស្នេហសង្គថិតា គន្ថា សេន្តិ មនោមយា បុថូ

តេ ភុសំ ឧបតាបេន្តិ តស្មា ស្នេហំ ន រោចយេ ។

១ ម. បរមគតិ ។



(២៣៦) (កណ្ហឥសី...) សេចក្តីក្រោធ មានប្រមាណតិច រមែងទៅជាច្រើន សេចក្តីក្រោធនោះ ដែលកើតអំពីសេចក្តីមិនអត់ធន់ រមែងចំរើន សេចក្តីក្រោធ ជាហេតុឲ្យជាប់ចំពាក់ ឲ្យមានសេចក្តីចង្អៀតចង្អល់ច្រើន ព្រោះហេតុនោះ អាត្មាមិនពេញចិត្ត នឹងសេចក្តីក្រោធឡើយ ។

(២៣៧) វាចារបស់អ្នកប្រកបដោយទោសៈ ជាវាចាអាក្រក់ ការប្រចាប់ (ប្រទាញទៅមក ក៏កើតឡើង) ជាលំដាប់ បន្ទាប់អំពីនោះដៃ បន្ទាប់អំពីដៃ ដំបងមានដំណើរ នៃគ្រឿងសាស្ត្រា ជាទីបំផុត ទោសៈកើតអំពីសេចក្តីក្រោធ ព្រោះហេតុនោះ អាត្មាមិនពេញចិត្ត នឹងទោសៈទេ ។

(២៣៨) ការប្លន់នឹងការកំហែង ការបោកប្រាស់នឹងការបញ្ឆោត រមែងប្រាកដ ក្នុងពួកបុគ្គល អ្នកមានសេចក្តីលោភជាធម្មតា ព្រោះហេតុនោះ អាត្មាមិនពេញចិត្តនឹងលោភៈទេ ។

(២៣៩) កិលេសគ្រឿងចាក់ស្រេះ ដែលសេចក្តីស្នេហាបូរឹត ជាកិលេសក្រាស់ កើតអំពីចិត្ត រមែងដេកនៅ (ក្នុងអារម្មណ៍នោះៗ) កិលេសទាំងនោះ រមែងធ្វើបុគ្គល ឲ្យក្តៅក្រហាយ ដោយក្រៃលែង ព្រោះហេតុនោះ អាត្មាមិនពេញចិត្តនឹងសេចក្តីស្នេហាទេ ។

(៤៣៦) ឯតស្មឹ តេ សុលបិតេ   បដិរូបេ សុភាសិតេ

វរំ ព្រាហ្មណ តេ ទម្មិ   យំ កិញ្ចិ មនសិច្ឆសិ ។

(២៣៧) វរញ្ចេ មេ អទោ សក្ក   សព្វភូតានមិស្សរ

អរញ្ញេ មេ វិហរតោ   និច្ចំ ឯកវិហារិនោ

អាពាធា ន ឧប្បជ្ជេយ្យុំ   អន្តរាយករា ភុសា ។

(២៣៨) ឯតស្មឹ តេ សុលបិតេ   បដិរូបេ សុភាសិតេ

វរំ ព្រាហ្មណ តេ ទម្មិ   យំ កិញ្ចិ មនសិច្ឆសិ ។

(២៣៩) វរញ្ចេ មេ អទោ សក្ក   សព្វភូតានមិស្សរ

ន មនោ វា សរីរំ វា   មំកតេ(១) សក្ក កស្សចិ

កទាចិ ឧបហញ្ញេថ   ឯតំ សក្ក វរំ វរេ ។

កណ្ហជាតកំ ទុតិយំ ។

១ ម. មក្កតេ ។



(២៣៦) (សក្កៈ..) ពាក្យនោះ លោកពោលល្អហើយ ជាសុភាសិតដ៏គួរ ម្នាលព្រាហ្មណ៍ លោកប្រាថ្នាក្នុងចិត្ត ចំពោះពរណាមួយ ខ្ញុំនឹងឲ្យពរ (នោះ) ដល់លោក ។

(២៣៧) (កណ្ហៈ...) បពិត្រសក្កៈ ជាធំជាងពួកភូតទាំងពួង បើព្រះអង្គនឹងឲ្យពរដល់អាត្មា ។ សូមកុំឲ្យអាពាធដ៏ក្លៀវក្លា ធ្វើអន្តរាយកើតឡើងដល់អាត្មា ដែលនៅក្នុងព្រៃ តែម្នាក់ឯងជានិច្ចឡើយ ។

(២៣៨) (សក្កៈ..) ពាក្យនោះ លោកពោលល្អហើយ ជាសុភាសិតដ៏គួរ លោកប្រាថ្នាក្នុងចិត្ត ចំពោះពរណាមួយ ម្នាលព្រាហ្មណ៍ យើងនឹងឲ្យពរ (នោះ) ដល់លោក ។

(២៣៩) (កណ្ហៈ..) បពិត្រសក្កៈ ជាធំជាងពួកភូតទាំងពួង បើព្រះអង្គនឹងឲ្យពរដល់អាត្មា ។ សូមកុំឲ្យចិត្តឬសរីរៈ (របស់អាត្មា) បៀតបៀនចំពោះអ្នកណាមួយ ព្រោះហេតុនៃអាត្មា ក្នុងកាលណាឡើយ បពិត្រសក្កៈ សូមព្រះអង្គឲ្យនូវពរនេះ ។

ចប់ កណ្ហជាតក ទី ២ ។

## ចតុប្បោសថជាតកំ

(៦៤០) យោ កោបនេយ្យេ ករោតិ កោបំ
ន កុជ្ឈតិ សប្បុរិសោ កទាចិ
កុទ្ធោបិ សោ នាវិករោតិ កោបំ
តំ វេ នរំ សមណមាហុ លោកេ ។

(៦៤១) ឩនោទរោ យោ សហតេ ជិឃច្ឆំ
ទន្តោ តបស្សី[១] មិតបានភោជនោ
អាហារហេតុ ន ករោតិ បាបំ
តំ វេ នរំ សមណមាហុ លោកេ ។

(៦៤២) ខិឌ្ឌំ រតី វិប្បជហិត្វាន សព្វំ
ន ចាលិកំ ភាសតិ កិញ្ចិ លោកេ
វិភូសដ្ឋានា វិរតោ មេថុនស្មា
តំ វេ នរំ សមណមាហុ លោកេ ។

១ ម. តបស្សិ ។



## ចតុប្បោសថជាតក

(៦៤០) (ព្រះបាទវរុណនាគរាជ ពោលថា) បុគ្គលណា ជាសប្បុរស មិនធ្វើនូវសេចក្តីក្រោធ ក្នុងបុគ្គលគួរក្រោធ ទាំងមិនក្រោធ ក្នុងកាលណាមួយ បុគ្គលជាសប្បុរសនោះ បើទុកជាក្រោធ ក៏មិនធ្វើសេចក្តីក្រោធឲ្យប្រាកដ បណ្ឌិតទាំងឡាយ ហៅជននោះឯងថា ជាសមណៈ ក្នុងលោក ។

(៦៤១) (ព្រះបាទសុបណ្ណរាជ ពោលថា) ជនណាមានពោះតូច អត់ទ្រាំនូវសេចក្តីស្រេកឃ្លានបាន ទូន្មាននូវឥន្ទ្រិយ ជាអ្នកមានតបៈមានទឹកនិងភោជនល្មមប្រមាណ មិនធ្វើនូវបាប ព្រោះហេតុនៃអាហារឡើយ បណ្ឌិតទាំងឡាយ ហៅជននោះថាជាសមណៈក្នុងលោក ។

(៦៤២) (សក្កទេវរាជ ពោលថា) ជនណា លះបង់នូវល្បែង (ដោយកាយនិងវាចា) និងសេចក្តីត្រេកអរ (ក្នុងកាមគុណ) ទាំងពួង ទាំងមិនពោល នូវពាក្យលេះលោះ តិចតួចក្នុងលោក វៀរចាកហេតុជាទីតាំង នៃការស្អិតស្អាង និងមេថុនធម្ម បណ្ឌិតទាំងឡាយ ហៅជននោះឯង ថាជាសមណៈ ក្នុងលោក ។

(៦៤៣) បរិក្ខហិំ លោកធម្មេ សតិំ
យោ វេ បរិញ្ញាយ បរិព្វជេតិ
ឆន្ទំ ហិតត្តិំ អមមំ និរាសំ
តំ វេ នរំ សមណមាហុ លោកេ ។

(៦៤៤) បុច្ឆាម កត្តារមនោមបញ្ញ
កថាសុ នោ វិគ្គហោ អត្ថិ ជាតោ
ឆិន្នជ្ជ កង្ខំ វិចិកិច្ឆិតានិ
តទជ្ជ កង្ខំ វិតរេមុ សព្វេ ។

(៦៤៥) យេ បណ្ឌិតា អត្ថទសា ភវន្តិ
ភាសន្តិ តេ យោនិសោ តត្ថ កាលេ
កថន្នុ កថានំ អភាសិតានំ
អត្ថំ នយេយ្យុំ កុសលា ជនិន្ទា ។



(៦៤៣) (ព្រះបាទធនញ្ជ័យ ពោលថា) ជនណា កំណត់ដឹង ហើយ លះបង់នូវទ្រព្យសម្បត្តិផង លោភៈទាំងពួងផង បណ្ឌិតទាំងឡាយ ហៅជនដែលមានខ្លួនទូន្មាន មានសភាពខ្ជាប់ខ្ជួន មិនមានសេចក្តីប្រកាន់ថា អញ មិនមានសេចក្តីប្រាថ្នានោះឯង ថាជាសមណៈក្នុងលោក ។

(៦៤៤) (ព្រះរាជាទាំង ៤ ព្រះអង្គនោះ ក្រាបទូលថា) ម្នាលអ្នកមានប្រាជ្ញាមិនថោកថយ យើងទាំងឡាយ សូមសួរចំពោះអ្នក ជាអ្នកធ្វើ (នូវហេតុដែលគួរធ្វើ) ការជជែកចំពោះពាក្យទាំងឡាយ កើតមានដល់យើង សូមអ្នកកាត់នូវសេចក្តីងឿងឆ្ងល់ និងសេចក្តីសង្ស័យចេញ ក្នុងថ្ងៃនេះ យើងទាំងអស់គ្នា គប្បីឆ្លងនូវសេចក្តីសង្ស័យនោះ ក្នុងថ្ងៃនេះ ។

(៦៤៥) (វិធុរបណ្ឌិត ពោធិសត្វ ពោលថា) បណ្ឌិតណា ជាអ្នកយល់សេចក្តី បណ្ឌិតនោះ រមែងពោល ដោយឧបាយនៃប្រាជ្ញា ក្នុងកាលគួរ ក្នុងពាក្យដែលគេនោះ បពិត្រព្រះអង្គជាធំជាងជនទាំងឡាយ ពួកជនអ្នកឈ្លាស គប្បីយល់នូវសេចក្តី នៃពាក្យពោល ដែលគេមិនទាន់និយាយ ដោយប្រការដូចម្តេចបាន ។

(៦៦៦) កថំ ហវេ ភាសតិ នាគរាជា
គរុឡោ បន វេនតេយ្យោ កិមាហ
គន្ធព្វរាជា បន កឹ វទេសិ
កថំ បន កុរូនំ រាជសេដ្ឋោ ។

(៦៦៧) ខន្តិំ ហវេ ភាសតិ នាគរាជា
អប្បាហារំ គរុឡោ វេនតេយ្យោ
គន្ធព្វរាជា រតិវិប្បហានំ
អកិញ្ចនំ កុរូនំ រាជសេដ្ឋោ ។

(៦៦៨) សព្ពានិ ឯតានិ សុភាសិតានិ
ន ហេត្ថ ទុព្ភាសិតមត្ថិ កិញ្ចិ
យស្មិញ្ច ឯតានិ បតិដ្ឋិតានិ
អរាវ នាភ្យា សុសមោហិតានិ
ចតុព្ភិ ធម្មេហិ សមង្គិភូតំ
តំ វេ នរំ សមណមាហុ លោកេ ។



(៦៦៦) ស្តេចនាគ ពោលដូចម្ដេច ស្តេចគ្រុឌ វេនតេយ្យ ពោលដូចម្ដេច ស្តេចគន្ធព្វ (ព្រះឥន្ទ) ពោលដូចម្ដេច ស្តេចដ៏ប្រសើរ របស់អ្នកដែនកុរុ ពោលដូចម្ដេច ។

(៦៦៧) (ព្រះរាជាទាំងឡាយនោះ ឆ្លើយថា) ស្តេចនាគពោលចំពោះ ខន្តិធម៌តែម្យ៉ាង ស្តេចគ្រុឌវេនតេយ្យ ពោលចំពោះអាហារតិច ស្តេចគន្ធព្វ ពោលចំពោះការលះបង់សេចក្ដីត្រេកអរ ស្តេចដ៏ប្រសើរ របស់អ្នកដែនកុរុ ពោលចំពោះការមិនមានកង្វល់ ។

(៦៦៨) (ព្រះពោធិសត្វ ពោលថា) ពាក្យទាំងអស់នេះ ជាសុភាសិត ពាក្យជាទុព្ភាសិត សូម្បីបន្តិចបន្តួច ក៏មិនមាន ក្នុងប្រស្នានេះទេ ម្យ៉ាងទៀត ពាក្យទាំងនេះ តាំងនៅស៊ប់ប្រជុំចុះដោយល្អ ក្នុងបុគ្គលណា ដូចជាកាំរទេះ ដែលគេបញ្ចុះស៊ប់ក្នុងដុំ បណ្ឌិតទាំងឡាយ ហៅបុគ្គលដែលព្រមព្រៀង ដោយធម៌ ៤ យ៉ាងនោះឯង ថាជា សមណៈ ក្នុងលោក ។

(៦៧៩) តុវំ ហិ សេដ្ឋោ ត្វមនុត្តរោសិ
ត្វំ ធម្មគូ ធម្មវិទូ សុមេធោ
បញ្ញាយ បញ្ហំ សមធិគ្គហេត្វា
អច្ឆេច្ឆិ កង្ខំ វិចិកិច្ឆិតានិ
អច្ឆេច្ឆិ កង្ខំ វិចិកិច្ឆិតានិ
ចុន្ទោ[1] យថា នាគទន្តំ ខរេន ។

(៦៨០) និលុប្បលាភំ វិមលំ អនគ្ឃំ
វត្ថំ ឥទំ ធូមសមានវណ្ណំ
បញ្ហស្ស វេយ្យាករណេន តុដ្ឋោ
ទទាមិ តេ ធម្មបូជាយ ធីរ ។

(៦៨១) សុវណ្ណមាលំ សតបត្តផុល្លិតំ
សកេសរំ រត្នសហស្សមណ្ឌិតំ
បញ្ហស្ស វេយ្យាករណេន តុដ្ឋោ
ទទាមិ តេ ធម្មបូជាយ ធីរ ។

---
១ ម. ចុណ្ណោ ។



(៦៧៩) (ព្រះរាជាទាំង ៤ ព្រះអង្គ...) អ្នកជាបុគ្គលប្រសើរ អ្នកជាបុគ្គលមិនមានអ្នកណាវិសេសជាង អ្នកជាបុគ្គលដល់នូវត្រើយនៃធម៌ ចេះដឹងនូវធម៌ មានប្រាជ្ញាល្អ កំណត់ដឹងនូវប្រស្នាដោយប្រាជ្ញា អ្នកជាអ្នកប្រាជ្ញ បានផ្តាច់សេចក្តីសង្ស័យចេញហើយ អ្នកបានកាត់នូវសេចក្តីសង្ស័យ និងសេចក្តីងឿងឆ្ងល់ ដូចជាគេកាត់នូវភ្លុកនៃដំរីដោយរណារ ។

(៦៨០) (សក្កទេវរាជ...) បពិត្រអ្នកប្រាជ្ញ ខ្ញុំត្រេកអរ និងការដោះនូវប្រស្នា ហើយជូនសំពត់នេះមានពន្លឺដូចផ្កាឧប្បលខៀវ មិនមានមន្ទិល ជាសំពត់កាត់ថ្លៃមិនបាន មានពណ៌ស្មើដោយផ្សែង ដើម្បីបូជានូវធម៌របស់អ្នក ។

(៦៨១) (សុបណ្ណរាជ...) បពិត្រអ្នកប្រាជ្ញ ខ្ញុំត្រេកអរ និងការដោះនូវប្រស្នា ហើយជូននូវកម្រងផ្កាមាស ដែលរីកសំពោង ដោយត្របកច្រើនស្រទាប់ ប្រកបដោយលំអង ដ៏ប្រដាប់ដោយកែវដ៏ច្រើន ដើម្បីបូជានូវធម៌របស់អ្នក ។

(២៩២) មណឹ អនគ្ឃំ រុចិរំ បភស្សរំ
កណ្ឋាវសត្តំ មណិភូសិតម្មេ
បញ្ញស្ស វេយ្យាករណេន តុដ្ឋោ
ទទាមិ តេ ធម្មបូជាយ ធីរ ។

(២៩៣) គវំ សហស្សំ ឧសភញ្ច នាគំ
អាជញ្ញយុត្តេ ច រថេ ទស ឥមេ
បញ្ញស្ស វេយ្យាករណេន តុដ្ឋោ
ទទាមិ តេ គាមវរានិ សោឡស ។

(២៩៤) សារីបុត្តោ តទា នាគោ សុបណ្ណោ បន កោលិតោ
គន្ធព្វរាជា អនុរុទ្ធោ រាជា អានន្ទបណ្ឌិតោ
វិធុរោ ពោធិសត្តោ ច ឯវំ ធារេថ ជាតកន្តិ ។

(១)
ចតុប្បោសថិកជាតកំ តតិយំ ។

១ ម. ចតុប្បោសថិយជាតកំ ។



(២៩២) (វរុណនាគរាជ...) បពិត្រអ្នកប្រាជ្ញ ខ្ញុំត្រេកអរ ចំពោះការដោះស្រាយនូវប្រស្នា ហើយជូននូវកែវមណី ដែលកាត់ថ្លៃមិនបាន ជាកែវដ៏រុងរឿង មានពន្លឺផ្លេក ៗ សម្រាប់ពាក់ព្យួរក ដែលស្អិតស្អាងដោយកែវមណី ដើម្បីបូជានូវធម៌របស់អ្នក ។

(២៩៣) (ព្រះរាជា...) ខ្ញុំត្រេកអរ ចំពោះការដោះស្រាយនូវប្រស្នា ហើយជូននូវគោមួយពាន់ ទាំងគោឧសភផង ដំរីផង រថ ១០ ដែលទឹមដោយសេះអាជានេយ្យនេះផង ស្រុកសួយ ១៦ ផង ដល់អ្នក ។

(២៩៤) អ្នកទាំងឡាយ ចូរចាំទុកនូវជាតក យ៉ាងនេះថា ស្តេចនាគក្នុងកាលនោះ បានមកជាព្រះសារីបុត្ត ស្តេចគ្រុឌ បានមកជាកោលិតភិក្ខុ (មោគ្គល្លាន) ស្តេចគន្ធព្វ បានមកព្រះអនុរុទ្ធ ស្តេចបានមកជាអានន្ទបណ្ឌិត វិធុរពោធិសត្វ គឺតថាគត ។

ចប់ ចតុប្បោសថិកជាតក ទី ៣ ។

# សង្ខជាតកំ

(៦៥៥) ពហុស្សុតោ សុតធម្មោសិ សង្ខ
ទិដ្ឋា តយា សមណព្រាហ្មណា ច
អថក្ខណេ ទស្សយសេ វិលាបំ
អញ្ញោ នុ កោ តេ បដិមន្តកោ មយា ។

(៦៥៦) សុព្ភូ សុភា សុប្បដិមុក្កកម្ពូ
បគ្គយ្ហ សោវណ្ណមយាយ បាតិយា
ភុញ្ជស្សុ ភត្តំ ឥតិ មំ វទេតិ
សទ្ធា វិត្តា តមហំ ភោតិ ព្រូហិ ។

(៦៥៧) ឯតាទិសំ ព្រាហ្មណ ទិស្វាន យក្ខំ
បុច្ឆេយ្យ បោសោ សុខមាសិសានោ
ឧដ្ឋេហិ នំ បញ្ជលិកាភិបុច្ឆ
ទេវី នុសិ ត្វំ ឧទ មានុសី នុ ។

(៦៥៨) យំ ត្វំ សុខេនាភិសមេក្ខសេ មំ
ភុញ្ជស្សុ ភត្តំ ឥតិ មំ វទេសិ
បុច្ឆាមិ តំ នារិ មហានុភាវេ
ទេវី នុសិ ត្វំ ឧទ មានុសី នុ ។





# សង្ខជាតក

(៦៥៥) (អ្នកបំរើពោលថា) បពិត្រសង្ខព្រាហ្មណ៍ អ្នកជាពហុស្សូត ធ្លាប់បានស្តាប់ធម៌ ទាំងសមណព្រាហ្មណ៍ អ្នកក៏បានជួបហើយ កាលបើដូច្នេះ (ហេតុអ្វី) ទើបអ្នកសំដែងនូវពាក្យ[illegible] ក្នុងកាលមិនមែនជាខណៈ អ្នកណាទៀតហ្ន៎ ជាអ្នកប្រឹក្សាចំពោះអ្នកក្រៅអំពីខ្ញុំ ។

(៦៥៦) (សង្ខព្រាហ្មណ៍ពោលថា) ទេវតា មានមុខល្អ មានរូបល្អ មានមាសពាក់ដោយល្អ កាន់នូវ (ភត្ត) ដោយភាជន៍មាស មានសទ្ធាមានចិត្តត្រេកអរ និយាយនឹងយើងថា អ្នកចូរបរិភោគនូវភត្តចុះ យើងនិយាយនឹងទេវតានោះថា យើងមិន (បរិភោគ) ទេ ។

(៦៥៧) (លំដាប់នោះ អ្នកបម្រើពោលថា) ម្នាលព្រាហ្មណ៍ ធម្មតាបុរសអ្នកប្រាថ្នាសេចក្តីសុខ កាលបានឃើញយក្ស ប្រាកដដូច្នោះហើយ គួរណាស់តែសួរ (ឡើង) អ្នកចូរក្រោកឡើង ហើយប្រណម្យដៃ សួរយក្ខនោះថា នាងជាទេវតា ឬជាមនុស្ស ។

(៦៥៨) (សង្ខព្រាហ្មណ៍ពោធិសត្វ ពោលថា) នាងបានគយគន់មើលយើងដោយសេចក្តីសុខ និយាយនឹងយើងថា អ្នកចូរបរិភោគនូវភត្តចុះ ម្នាលនាងនារី អ្នកមានអានុភាពធំ យើងសូមសួរនាង តើនាងជាទេវតា ឬជាមនុស្ស ។

(៦៥៩) ទេវី អហំ សង្ខ មហានុភាវា
ឥធាគតា សាគរវារិមជ្ឈេ
អនុកម្បិកា នោ ច បទុដ្ឋចិត្តា
តវេវ អត្ថាយ ឥធាគតាស្មិ ។

(៦៦០) ឥធន្នបានំ សយនាសនញ្ច
យានានិ នានាវិវិធានិ សង្ខ
សព្វស្ស ត្យាហំ បដិបាទយាមិ
យំ កិញ្ចិ តុយ្ហំ មនសាភិបត្ថិតំ ។

(៦៦១) យំ កិញ្ចិ យិដ្ឋញ្ច ហុតញ្ច មយ្ហំ
សព្វស្ស នោ ឥស្សរា ត្វំ សុគត្តេ
សុស្សោណិ សុព្ភុ សុវិលាកមជ្ឈេ
កិស្ស មេ កម្មស្ស អយំ វិបាកោ ។

(៦៦២) ឃម្មេ បថេ ព្រាហ្មណ ឯកភិក្ខុំ
ឧស្សដ្ឋបាទំ(១) តសិតំ កិលន្តំ
បដិបាទយិ សង្ខ ឧបាហនានិ
សា ទក្ខិណា កាមទុហា តវជ្ជ ។

១ ម. ឧគ្ឃដ្ឋបាទំ ។





(៦៥៩) (ទេវតា ពោលថា) បពិត្រសង្ខព្រាហ្មណ៍ ខ្ញុំជាទេវតាមានអានុភាពធំ មកក្នុងកណ្ដាលសាគរនេះ ព្រោះខ្ញុំមានសេចក្ដីអនុគ្រោះ មិនមែនមានចិត្តប្រទូស្តទេ ទើបមកក្នុងទីនេះ ដើម្បីប្រយោជន៍ ចំពោះអ្នកតែម្យ៉ាង ។

(៦៦០) បពិត្រសង្ខព្រាហ្មណ៍ ក្នុងសមុទ្រនេះ មានបាយ ទឹក ទីដេក ទីអង្គុយ និងយានផ្សេងៗ ជាច្រើន អ្នកមានចិត្តប្រាថ្នា ចំពោះរបស់ណាមួយ ខ្ញុំនឹងប្រគល់ឲ្យរបស់ទាំងអស់នោះ ដល់អ្នក ។

(៦៦១) (ព្រាហ្មណ៍សង្ខ ពោលថា) បពិត្រនាងទេវតា មានកាយល្អ មានត្រគាកល្អ មានរោមចិញ្ចើមល្អ មានអវយវៈត្រង់កណ្ដាលខ្លួនល្អ ការបូជាធំក្ដី បូជាតូចក្ដី ណាមួយរបស់ខ្ញុំ នាងជាឥស្សរៈ នៃបុញ្ញកម្ម របស់យើងនោះទាំងអស់ នេះជាផលនៃកម្ម របស់ខ្ញុំដូចម្ដេច ។

(៦៦២) (នាងទេវតា ពោលថា) បពិត្រសង្ខព្រាហ្មណ៍ អ្នកបានប្រគេនស្បែកជើងចំពោះភិក្ខុ ១ អង្គ (ព្រះបច្ចេកពុទ្ធ) ដែលមានជើងក៏រលាក ស្រេកឃ្លាន លំបាក ក្នុងផ្លូវដ៏ក្ដៅ ទក្ខិណាទាននោះ ឲ្យនូវសេចក្ដីប្រាថ្នាដល់អ្នក ក្នុងថ្ងៃនេះ ។

(៦៦៣) សា ហោតុ នាវា ផលកូបបន្នា
អនវស្សុតា ឯរកវាតយុត្តា
អញ្ញស្ស យានស្ស ន ហេត្ថ ភូមិ
អជ្ជេវ មំ មោលិនិ តាយស្សុ ។

(៦៦៤) សា គុជ្ជចិត្តា សុមនា បតីតា
នាវំ សុចិត្តំ អភិនិម្មិនិត្វា
អាទាយ សង្ខំ បុរិសេន សទ្ធឹ
ឧបានយី នគរំ សាធុរម្មំ ។

សង្ខជាតកំ ចតុត្ថំ ។

## ចុល្លពោធិជាតកំ

(៦៦៥) យោ តេ ឥមំ វិសាលក្ខឹ បិយំ សម្មិល្លហាសិនឹ[១]
អាទាយ ពលា គច្ឆេយ្យ កឹ នុ កយិរាសិ ព្រាហ្មណ ។

(៦៦៦) ឧប្បជ្ជេ មេ ន មុច្ចេយ្យ ន មេ មុច្ចេយ្យ ជីវតោ
រជំវ វិបុលា វុដ្ឋិ ខិប្បមេវ និវារយេ ។

១ ម. សម្មិល្លភាសិនឹ ។ ឱ. សម្មិលហាសិនឹ ។



(៦៦៣) (ព្រះពោធិសត្វ ពោលថា) សូមឲ្យកើតសំពៅ ដែលពាស ដោយផែនក្តារ ជាសំពៅមិនលិចទឹក ប្រកបដោយក្តោងនឹងខ្យល់ ព្រោះថា ត្រង់សមុទ្រនេះ មិនមែនជាភូមិនៃយានដទៃឡើយ សូមនាងចម្លងខ្ញុំ ឲ្យដល់នូវក្រុងមោលិនី ក្នុងថ្ងៃនេះ ។

(៦៦៤) (អភិសម្ពុទ្ធគាថា) ទេវតានោះ មានចិត្តត្រេកអរ រីករាយ សប្បាយ និម្មិតសំពៅដ៏វិចិត្រល្អ ហើយនាំសង្ខព្រាហ្មណ៍ ព្រមទាំងបុរសបដ្ឋាក ចូលទៅកាន់ក្រុង ជាទីសុខសាន្ត ។

ចប់ សង្ខជាតក ទី ៤ ។

## ចុល្លពោធិជាតក

(៦៦៥) (ព្រះរាជាពារាណសី ពោលថា) បើបុគ្គលណា ចាប់យកនាង បរិព្វាជិកា មានភ្នែកធំទូលាយ ជាទីស្រឡាញ់ មានមុខញញឹម នេះរបស់អ្នក ទៅដោយការកំហែង ម្នាលព្រាហ្មណ៍ តើអ្នកនឹងធ្វើអ្វី (ដល់បុគ្គលនោះ) ។

(៦៦៦) (ព្រះពោធិសត្វ ពោលថា) សេចក្តីក្រោធកើតដល់អាត្មា ក៏ចេញមកមិនបាន អាត្មាកាលរស់នៅ ចេញមកមិនបានទេ អាត្មាឃាត់ឆាប់រហ័សឲ្យស្ងប់ដូចជាភ្លៀងដ៏ធំឃាត់នូវធូលី ។

(៦៦៧) យន្នុ បុព្វេ វិកត្ថិតោ ពលម្ហិវ អបស្សិតោ
ស្វាជ្ជ តុណ្ហិកតោ ទានិ សង្ឃាដឹ សិព្វមច្ឆសិ ។

(៦៦៨) ឧប្បជ្ជិ មេ ន មុញ្ចិត្ថ ន មេ មុញ្ចិត្ថ ជីវតោ
រជំ វិបុលា វុដ្ឋិ ខិប្បមេវ និវារយិ ។

(៦៦៩) កិន្តេ ឧប្បជ្ជិ នោ មុញ្ចិ កិន្តេ ន មុញ្ចិ ជីវតោ
រជំ វិបុលា វុដ្ឋិ កតមំ តំ និវារយិ(១) ។

(៦៧០) យម្ហិ ជាតេ ន បស្សតិ អជាតេ សាធុ បស្សតិ
សោ មេ ឧប្បជ្ជិ នោ មុញ្ចិ កោធោ ទុម្មេធគោចរោ ។

(៦៧១) យេន ជាតេន នន្ទន្តិ អមិត្តា ទុក្ខមេសិនោ
សោ មេ ឧប្បជ្ជិ នោ មុញ្ចិ កោធោ ទុម្មេធគោចរោ ។

(៦៧២) យស្មិញ្ច ជាយមានស្មឹ សទត្ថំ នាវពុជ្ឈតិ
សោ មេ ឧប្បជ្ជិ នោ មុញ្ចិ កោធោ ទុម្មេធគោចរោ ។

១ ម. កតមំ តំ និវារយិ ។



(៦៦៧) (ព្រះរាជា...) ក្នុងកាលពីដើម លោកពោលយ៉ាងអួត ក្នុងកម្លាំង ថ្ងៃនេះ លោកនោះស្ងប់ការនឹកឃើញ នៅស្ងៀមសម្ងំដេរសង្ឃាដីវិញ ។

(៦៦៨) (ព្រះមហាសត្វ...) សេចក្តីក្រោធកើតដល់អាត្មា ក៏ចេញមកមិនបាន អាត្មាកាលរស់នៅ ចេញមកមិនបានទេ អាត្មាឃាត់ទប់ហើយ ឲ្យស្ងប់ដូចភ្លៀងធំឃាត់ធូលី ។

(៦៦៩) (ព្រះរាជា...) អ្វីកើតឡើងដល់លោក ចេញមកមិនបាន លោកកាលរស់នៅអ្វីចេញមកបាន លោកឃាត់អ្វី ដូចភ្លៀងធំឃាត់ធូលី ។

(៦៧០) (ព្រះពោធិសត្វពោលថា) កាលសភាវៈណាកើតឡើង បុគ្គលមើលមិនឃើញ កាលមិនកើតឡើង ទើបឃើញងាយ សភាវៈនោះ គឺសេចក្តីក្រោធជាអារម្មណ៍ របស់បុគ្គលល្ងង់ កើតឡើងដល់អាត្មា ចេញមកមិនបានទេ ។

(៦៧១) បុគ្គលទាំងឡាយ ជាសត្រូវ អ្នកស្វែងរកនូវសេចក្តីទុក្ខ រមែងត្រេកអរ ដោយសភាវៈណា ដែលកើតហើយ សភាវៈនោះ គឺសេចក្តីក្រោធ ជាអារម្មណ៍របស់បុគ្គលល្ងង់ កើតឡើងដល់អាត្មា ចេញមកមិនបានទេ ។

(៦៧២) កាលសភាវៈណាកើតឡើង បុគ្គលរមែងមិនយល់ នូវប្រយោជន៍របស់ខ្លួន សភាវៈនោះគឺសេចក្តីក្រោធ ជាអារម្មណ៍របស់បុគ្គលល្ងង់ កើតឡើងដល់អាត្មាមិនបានទេ ។

(២៧៣) យេនាភិភូតោ កុសលំ ជហាតិ
បរក្ការេ វិបុលញ្ចាបិ អត្ថំ
ស ភីមសេនោ ពលវា បមទ្ទិ
សោ កោធោ មហារាជ ន មេ អមុច្ចថ ។

(២៧៤) កដ្ឋស្មឹ មត្ថមានស្មឹ    បាវកោ នាម ជាយតិ
តមេវ កដ្ឋំ ទហតិ    យស្មា សោ ជាយតេ គិនិ ។

(២៧៥) ឯវំ មន្ទស្ស បោសស្ស    ពាលស្ស អវិជានតោ
សារម្ភា ជាយតេ កោធោ    សោបិ តេនេវ ឌយ្ហតិ ។

(២៧៦) អគ្គីវ តិណកដ្ឋស្មឹ    កោធោ យស្ស បវឌ្ឍតិ
និហីយតិ តស្ស យសោ    កាឡបក្ខេវ ចន្ទិមា ។

(២៧៧) អនេធោ ធូមកេតូវ    កោធោ យស្សូបសម្មតិ
អាបូរតិ តស្ស យសោ    សុក្កបក្ខេវ ចន្ទិមា ។

ពុណ្យកោដិជាតកំ បញ្ចមំ ។



(២៧៣) បពិត្រមហារាជ បុគ្គលត្រូវសេចក្ដីក្រោធណា គ្របសង្កត់ហើយ រមែងលះបង់នូវកុសលផង ធ្វើប្រយោជន៍ដ៏ធំទូលាយឲ្យសាបសូន្យផង សេចក្ដីក្រោធនោះ មានសេនា គឺកិលេសដែលគួរខ្លាច មានកំឡាំងកាចញាំញីសត្វបាន សេចក្ដីក្រោធចេញពីអាត្មាមិនបានទេ ។

(២៧៤) ឧបមាភ្លើង រមែងកើតត្រង់ឈើដែលគូត ភ្លើងនោះកើតអំពីឈើណា តែងឆេះនូវឈើនោះវិញ ។

(២៧៥) កាលបុរសល្ងង់ខ្លៅ អប់អួរក្រញាញ់ មិនចេះដឹងហេតុនេះ សេចក្ដីក្រោធ រមែងកើតអំពីការប្រណាំងប្រជែង បុរសនោះ រមែងត្រូវភ្លើងគឺសេចក្ដីក្រោធនោះឆាបឆេះ ។

(២៧៦) សេចក្ដីក្រោធ របស់បុគ្គលណា ចម្រើនឡើង ដូចភ្លើងកាលចម្រើនឡើង ក្នុងគំនរស្មៅនិងឈើ យសរបស់បុគ្គលនោះ រមែងសាបសូន្យ ដូចព្រះចន្ទ្រ ក្នុងកាឡបក្ខ ។

(២៧៧) សេចក្ដីក្រោធ របស់បុគ្គលណា ស្ងប់រម្ងាប់ ដូចភ្លើងមិនមានកំញួម យសរបស់បុគ្គលនោះ រមែងបរិបូណ៌ ដូចព្រះចន្ទ្រ ក្នុងសុក្កបក្ខ ។

ចប់ ពុណ្យកោដិជាតក ទី ៥ ។

# មណ្ឌព្យជាតកំ[១]

(៦៧៨) សត្តាហមេវាហំ បសន្នចិត្តោ
បុញ្ញត្ថិកោ អាចរិំ ព្រហ្មចរិយំ
អថាបរំ យំ ចរិតំ មមយិទំ
វស្សានិ បញ្ញាស សមាធិកានិ
អកាមកោ វាហិ អហំ ចរាមិ
ឯតេន សច្ចេន សុវត្ថិ ហោតុ
ហតំ វិសំ ជីវតុ យញ្ញទត្តោ ។

(៦៧៩) យស្មា ទានំ នាភិនន្ទឹ កទាចិ
ទិស្វានហំ អតិថឹ វាសកាលេ
ន ចាបិ មេ អប្បិយតំ អវេទុំ
ពហុស្សុតា សមណព្រាហ្មណា ច
អកាមកោ វាហិ អហំ ទទាមិ
ឯតេន សច្ចេន សុវត្ថិ ហោតុ
ហតំ វិសំ ជីវតុ យញ្ញទត្តោ ។

១. កណ្ហទីបាយនជាតកំ ។



# មណ្ឌព្យជាតក

(៦៧៨) (កណ្ហទីបាយនតាបស ធ្វើសច្ចកិរិយាថា) យើងមានចិត្តជ្រះថ្លា ត្រូវការដោយបុណ្យ បានប្រព្រឹត្តព្រហ្មចរិយៈអស់ ៧ ថ្ងៃគត់ មួយទៀត ព្រហ្មចរិយៈណា លើសទៅទៀត ដែលយើងបានប្រព្រឹត្តហើយ ព្រហ្មចរិយៈនេះជារបស់នៃយើង យើងជាអ្នកមិនត្រេកអរ (ចំពោះបព្វជ្ជា) អស់ជាង ៥០ ឆ្នាំ មកហើយ តែឥឡូវនេះ យើងនៅប្រព្រឹត្តព្រហ្មចរិយៈ ដោយពាក្យសច្ចៈនេះ សូមសួស្តីកើតមាន (ដល់យញ្ញទត្តកុមារ) ពិសចូរសាបរលាបបាត់ទៅ យញ្ញទត្តកុមារ ចូររស់ឡើង ។

(៦៧៩) (បិតាយញ្ញទត្តកុមារ ធ្វើសច្ចកិរិយាថា) កូនសំលាញ់ ខ្ញុំឃើញភ្ញៀវដែលមកដល់លំនៅ ក៏មិនត្រេកអរនឹងឲ្យទានទេ តែខ្ញុំមិនឲ្យពួកសមណព្រាហ្មណ៍ ទោះជាពហុស្សូត បានដឹងថា ខ្ញុំមិនស្រឡាញ់ទេ មួយទៀតខ្ញុំ ទោះបីមិនត្រេកអរ (ក្តីតាម) ក៏នៅតែឲ្យ ដោយពាក្យសច្ចៈនេះ សូមសួស្តីកើតមាន (ដល់យញ្ញទត្តកុមារ) ពិសចូរសាបរលាបបាត់ទៅ សូមយញ្ញទត្តកុមាររស់ឡើង ។

[៦៨០] អាសីវិសោ តាត បហូតតេជោ
យោ តំ អទំសី ពិឡារា ឧទ្ទិច្ច(១)
តស្មិញ្ច មេ អប្បដិការមត្ថិ
បិតរិ ច តេ នត្ថិ កោចិ វិសេសោ
ឯតេន សច្ចេន សុវត្ថិ ហោតុ
ហតំ វិសំ ជីវតុ យញ្ញទត្តោ ។

[៦៨១] សន្តា ទន្តា យេ ច បរិព្វជន្តិ
អញ្ញត្រ កណ្ហា អនកាមរូបា(២)
ទីបាយន ការិស្ស ជិគុច្ឆមានោ
អកាមកោ ចរសិ ព្រហ្មចរិយំ ។

---

១ ឱ. យោ តំ អទ្ទសិ បតា ឧទ្ទិច្ច ។ ម. យោ តំ អទសី សបរា ឧទ្ទិច្ច ។
២ ឱ. កណ្ហ នកាមរូបា ។



[៦៨០] (មាតាយញ្ញទត្តកុមារ ពោលថា) ម្នាលកូន អាសិរពិសណា មានតេជះច្រើន បានលូនចេញពីរន្ធមកចឹកអ្នក ក្នុងថ្ងៃនេះ ខ្ញុំនឹងបិតាអ្នក មិនមានសេចក្តីប្លែកគ្នាណាមួយ ក្នុងអាសិរពិសនោះទេ (ព្រោះជាអ្នកមិនស្រឡាញ់អាសិរពិស (ដូចគ្នា)) ដោយពាក្យសច្ចៈនេះ សូមសួស្តីកើតមាន ពិសចូរសាបរលាបបាត់ទៅ សូមយញ្ញទត្តកុមារ រស់ឡើង ។

[៦៨១] (តាបសមណ្ឌព្យៈជាសំឡាញ់សួរថា) ពួកជនណាបួស ជាអ្នកស្ងប់រម្ងាប់ ទូន្មានឥន្ទ្រិយ ពួកជននោះ ប្រាកដជាអ្នកប្រាជ្ញ (ទើបបួស) វៀរលែងតែកណ្ហទីបាយនតាបសចេញ បពិត្រទីបាយនតាបស លោកស្អប់ខ្ពើមអ្វី បានជាមិនចង់បួស ហើយក៏ប្រព្រឹត្តព្រហ្មចារ្យទៅវិញ ។

(៦៤៦) សទ្ធាយ និក្ខម្ម បុន និវត្តោ
សោ ឯឡមូគោ ចបលោ វតាយំ
ឯតស្ស វាទស្ស ជិគុច្ឆមានោ
អកាមកោ ចរាមិ ព្រហ្មចរិយំ
វិញ្ញូបសត្ថញ្ច សតញ្ច ឋានំ
ឯវម្បហំ បុញ្ញករោ ភវាមិ ។

(៦៤៧) សមណេ តុវំ ព្រាហ្មណេ អទ្ធិកេ ច
សន្តប្បយាសិ អន្នបានេន ភិក្ខំ
ឱបានភូតំ ឃរំ តវយិទំ
អន្នេន បានេន ឧបេតរូបំ
អថ កិស្ស វាទស្ស ជិគុច្ឆមានោ
អកាមកោ ទានមិមំ ទទាសិ ។



(៦៤៦) (ទីបាយនតាបស ពោលថា) បុគ្គលណាចេញ (ចាកផ្ទះបួស) ដោយសទ្ធា ហើយត្រឡប់មក (កាន់ផ្ទះ) វិញ បុគ្គលនោះឯង ឈ្មោះថាជាមនុស្សល្ងីល្ងើ មិនចេះខ្លួន យើងស្អប់ខ្ពើមពាក្យនេះ (ស្មើ) ជាអ្នកមិនប្រាថ្នា (បួស) ក៏ត្រាំប្រព្រឹត្តព្រហ្មចារ្យ ដែលវិញ្ញូជនសរសើរផង ជាឋានៈរបស់ពួកសប្បុរសផង យើងជាអ្នកធ្វើនូវបុណ្យយ៉ាងនេះ ។

(៦៤៧) ចំណែកអ្នកបានញុំាងពួកសមណព្រាហ្មណ៍ និងអ្នកដំណើរ ឲ្យឆ្អែតស្កប់ស្កល់ ដោយបាយទឹកនិងភិក្ខាហារ ផ្ទះរបស់អ្នកនេះ មានភិក្ខាហារ (ដ៏សម្បូណ៌) ដូចជាស្រះសំរាប់ផងទឹក កាលបើដូច្នេះ ចុះអ្នកស្អប់ខ្ពើមពាក្យអ្វី បានជាអ្នកមិនប្រាថ្នានឹងឲ្យទាន តែនៅតែឲ្យនូវទាននេះវិញ ។

(៦៨៦) បិតរោ ច មេ អាសុំ បិតាមហា ច

សទ្ធា អហុ ទានបតី វទញ្ញូ

តំ កុលវត្តំ អនុវត្តមានោ

មាហំ កុលេ អន្តិមគន្ធិនោ អហុំ

ឯតស្ស វាទស្ស ជិគុច្ឆមានោ

អកាមកោ ទានមិមំ ទទាមិ ។

(៦៨៧) ទហរី កុមារី អសមត្ថបញ្ញា

យន្តានយី ញាតិកុលា សុគត្តេ

ន ចាបិ មេ អប្បិយតំ អវេទិ

អញ្ញត្រ កាមា បរិចារយន្តា

អថ កេន វណ្ណេន មយា ហិ ភោតិ

សំវាសធម្មោ អហុ ឯវរូបោ ។



(៦៨៦) (មណ្ឌាក្យៈ..) មាតាបិតានឹងជីដូនជីតារបស់ខ្ញុំ ជាអ្នកមានសទ្ធា ជាម្ចាស់នៃទាន ជាអ្នកដឹងនូវពាក្យសូម ខ្ញុំប្រព្រឹត្តតាមវត្តរបស់ត្រកូលនោះ ដោយគំនិតថា អាត្មាអញកុំជាអ្នកមានគន្ធទីបំផុត គឺជាអ្នកកាត់នូវវង្សត្រកូល ក្នុងត្រកូលឡើយ អាត្មាអញស្អប់ខ្ពើម ចំពោះពាក្យនោះ (គេថា) ជាអ្នកមិនមានប្រាជ្ញានឹងឲ្យទាន ក៏នៅតែឲ្យនូវទាននេះ ។

(៦៨៧) ម្នាលនាងមានសរីរកាយដ៏ល្អ យើងបាននាំនាងមកអំពីត្រកូលនៃញាតិ តាំងពីកាលនាងនៅជាកុមារីក្មេង មានប្រាជ្ញាមិនទាន់គង់អាចម្ល៉េះ នាងបំរើអញទាំងមិនចង់ តែមិនឲ្យដឹងថា មិនស្រឡាញ់អញ ម្នាលនាង កាលបើដូច្នេះ ការនៅរួមជាមួយយើង មានសភាពយ៉ាងនេះ តើដោយហេតុដូចម្តេច ។

(៦៨៦) អារា ទូរេ នយិធ កទាចិ អត្ថិ
បរម្បរា នាម កុលេ ឥមស្មឹ
តំ កុលវត្តំ អនុវត្តមានា
នាហំ កុលេ អន្តិមគន្ធិនី អហុំ
ឯតស្ស ភវស្ស ជិគុច្ឆមានា
អកាមិកា បទ្ធចរម្ហិ(១) តុយ្ហំ ។

(៦៨៧) មណ្ឌព្យ ភាសិស្សំ អភាសនេយ្យំ(២)
តំ ខមតំ បុត្តហេតុ មមជ្ជ
បុត្តបេមា នយិធ បរត្ថិ កិញ្ចិ
សោ នោ អយំ ជីវតិ យញ្ញទត្តោ ។

មណ្ឌព្យជាតកំ ឆដ្ឋំ ។

## និគ្រោធជាតកំ

(៦៨៨) ន វាហមេតំ ជានាមិ   កោ វាយំ កស្ស វាតិ វា
យថា សាខោ វទី ឯវំ   និគ្រោធ កិន្តិ មញ្ញសិ ។

(៦៨៩) តតោ គលវិនីតេន   បុរិសា នីហរឹសុ មំ(៣)
ទត្វា មុខបហារានិ   សាខស្ស វចនំករា ។

---

១ ឧ. ពទ្ធចរម្ហិ ។ ម. បទ្ធចរាមិ ។ ២ ម. មណ្ឌព្យ ភាសឹ យមភាសនេយ្យំ ។
៣ ឧ. បុរិសា និក្ខាមយឹសុ មំ ។ ម. បុរិសា និក្ខាមយឹសុ ។



(៦៨៦) (ភរិយា...) យូរណាស់មកហើយ ក្នុងកាលណាក៏ដោយ ការផ្លាស់ប្តូរប្តី មិនមានក្នុងត្រកូលនេះទេ ខ្ញុំប្រព្រឹត្តតាមវត្តរបស់ត្រកូលនោះ ដោយគំនិតថា អាត្មាអញ កុំជាអ្នកមានក្លិនចុងបំផុត នឹងជាអ្នកកាត់ខ្សែត្រកូល ក្នុងត្រកូលឡើយ ខ្ញុំស្អប់ខ្ពើមពាក្យនេះ ព្រោះប្តី ជាអ្នកមិនមានប្រាជ្ញានឹងបំរើ ក៏ប្រព្រឹត្តបំរើមិនជាប់ចំពោះអ្នក ។

(៦៨៧) បពិត្រមណ្ឌព្យៈ ខ្ញុំនិយាយនូវពាក្យ ដែលមិនគួរនិយាយ សូមអ្នកអត់ទោសចំពោះពាក្យនោះ ដល់ខ្ញុំ ក្នុងថ្ងៃនេះ ព្រោះហេតុនៃកូន ព្រោះរបស់ណាមួយដទៃទៀត ក្នុងលោកនេះ រមែងមិនមានជាទីសេចក្តីស្រឡាញ់ ក្នុងកូនឡើយ យញ្ញទត្តកុមាររបស់យើងនេះរស់វិញ ។

ចប់ មណ្ឌព្យជាតក ទី ៦ ។

## និគ្រោធជាតក

(៦៨៨) (ទុគ្គតបុរស ពោលថា) បពិត្រនិគ្រោធ សាខសេនាបតីបាននិយាយថា អញមិនស្គាល់អ្នកនុះទេ អ្នកនេះជាអ្វី ឬជាអ្នកបម្រើ របស់អ្នកណា (ដូច្នេះ) យ៉ាងណា តើព្រះអង្គទ្រង់យល់យ៉ាងនោះ ដែរឬ ។

(៦៨៩) កាលនោះ ពួកបុរសអ្នកធ្វើតាមពាក្យសាខបុរស ក៏ចាប់ក ទាត់បណ្តេញខ្ញុំក្រៅផ្ទះ ដោយការគុស-គរញ ។

(៦៤០) ឋិតា ធិសំ ទុម្មតិកា   អកាតញ្ញេន ទុត្តិកា
ការតំ អនរិយំ សាខេន   សខិនា តេ ជនាធិប ។

(៦៤១) ន ហិ មេតំ វិជានាមិ   ន ច មេ កោចិ សំសតិ
យំ មេ ត្វំ សម្ម អក្ខាសិ   សាខេន កលុំ(១) កតំ ។

(៦៤២) សខីនំ សាជីវកោ   មម សាខស្ស ចូភយំ
ត្វំ នោសិស្សរិយំ ទាតា   មនុស្សេសុ មហន្តតំ(២)
តយម្ហា លទ្ធិកា(៣) ឥទ្ធិ   ឯត្ថ មេ នត្ថិ សំសយោ ។

(៦៤៣) យថាបិ វីជំ អគ្គិម្ហិ   ឌយ្ហតិ ន វិរូហតិ
ឯវំ កតំ អសប្បុរិសេ   នស្សតិ ន វិរូហតិ ។

(៦៤៤) កតញ្ញុម្ហិ ច បោសម្ហិ   សីលវន្តេ អរិយវុត្តិនេ
សុខេត្តេ វិយ វីជានិ   កតំ តម្ហិ ន នស្សតិ ។

១ ឱ. កលុំ ។ ម. ឧណ្ណំ ។ ២ ឱ. ម. មហន្តនំ ។ ៣ ម. តយា មាលទ្ធិកា ។



(៦៤០) បពិត្រព្រះអង្គជាធំជាងជន អំពើមិនប្រសើរ ព្រោះតែដូច្នេះ សាខៈ ជាសំឡាញ់របស់ព្រះអង្គ ជាមនុស្សមានគំនិតអាក្រក់ ជាអកតញ្ញូ ប្រទូស្តមិត្រ បានធ្វើហើយ ។

(៦៤១) (ព្រះបាទខិត្រោធ ..) ម្នាលសំឡាញ់ អ្នកប្រាប់ខ្ញុំការទទឹងទាញណា ដែលសាខៈធ្វើហើយដល់ខ្ញុំ ខ្ញុំមិនដឹងខ្ញុំដំណើរនុ៎ះទេ ទាំងអ្នកណាមួយ ក៏មិនបានប្រាប់ដល់ខ្ញុំដែរ ។

(៦៤២) អ្នកបានធ្វើខ្ញុំការចិញ្ចឹមជីវិតហើយ ដល់សំឡាញ់ទាំង ២ នាក់ គឺខ្ញុំ នឹងសាខៈ ជាអ្នកឲ្យឥស្សរិយយស គឺភាពជាធំ ក្នុងមនុស្ស ដល់យើង យើងបានសេចក្តីសុខ ក៏ព្រោះអ្នក សេចក្តីសង្ស័យ ក្នុងហេតុនុ៎ះ មិនមានដល់ខ្ញុំទេ ។

(៦៤៣) ពូជ (ដែលដាក់) ក្នុងភ្លើង រមែងឆេះ មិនដុះឡើងណាមិញ ឧបការគុណដែលបុគ្គលធ្វើហើយ ក្នុងអសប្បុរស រមែងវិនាស មិនលូតលាស់ យ៉ាងនោះដែរ ។

(៦៤៤) ឧបការគុណដែលបុគ្គលធ្វើហើយ ក្នុងបុរសជាកតញ្ញូ មានសីលធម៌ មានសេចក្តីប្រព្រឹត្តប្រសើរនោះ រមែងមិនវិនាសទេ ដូចពូជ (ដែលព្រោះ) ក្នុងស្រែល្អ ។

(៦៩៥) ឥមញ្ច ជម្មំ នេកតិកំ អសប្បុរិសចិន្តកំ
ហនន្តុ សាខំ សត្តីហិ នាស្ស(១) ឥច្ឆាមិ ជីវិតំ ។
(៦៩៦) ខមតស្ស មហារាជ បាណា ន បដិអានយា
ខម ទេវ អសប្បុរិសស្ស នាស្ស ឥច្ឆាមហំ វធំ ។
(៦៩៧) និគ្រោធមេវ សេវេយ្យ ន សាខមុបសំវសេ
និគ្រោធស្មឹ មតំ សេយ្យោ យញ្ចេ សាខស្មិ ជីវិតន្តិ ។

និគ្រោធជាតកំ សត្តមំ ។

## តក្កលជាតកំ

(៦៩៨) ន តក្កលា សន្តិ ន អាលុបានិ
ន ពិឡាលិយោ ន កឡម្ពានិ តាត
ឯកោ អរញ្ញម្ហិ សុសានមជ្ឈេ
កិមត្ថិកោ តាត ខណាសិ កាសុំ ។

១ ម. នាហំ ។



(៦៩៥) ពួកបុរសទាំងឡាយ ចូរយកលំពែងសម្លាប់នូវសាខៈនេះ ជាមនុស្សលាមក បញ្ឆោតបុគ្គល មានគំនិតជាអសប្បុរសចុះ យើងមិនប្រាថ្នាឲ្យរស់នៅទេ ។

(៦៩៦) (ពោធិសត្វ..) បពិត្រមហារាជ សូមព្រះអង្គអត់ទោស ចំពោះបុរសនេះ (ព្រោះថា) ជីវិត (របស់សត្វដែលស្លាប់ហើយ) មិនអាចនាំត្រឡប់មកវិញបានទេ បពិត្រព្រះសម្មតិទេព សូមព្រះអង្គអត់ទោសដល់អសប្បុរស ខ្ញុំព្រះអង្គ មិនប្រាថ្នាការសម្លាប់បុរសនេះទេ ។

(៦៩៧) បុគ្គលគប្បីសេពគប់ នូវស្តេចនិគ្រោធប៉ុណ្ណោះ កុំនៅជាមួយសាខៈឡើយ សេចក្តីស្លាប់ ក្នុងសំណាក់ស្តេចនិគ្រោធប្រសើរជាងឯការរស់នៅ ក្នុងសំណាក់សាខៈ កុំប្រសើរឡើយ ។

ចប់ និគ្រោធជាតក ទី ៧ ។

## តក្កលជាតក

(៦៩៨) (កុមារពោធិសត្វ ពោលថា) បពិត្របិតា ដំឡូងឈាមទាន់ មិនមាន ដំឡូងជ្វា មិនមាន ដំឡូងដៃខ្លា មិនមាន ដំឡូងក្តាម មិនមាន (ក្នុងទីនេះទេ) បិតាមានប្រយោជន៍អ្វី ទើបមកជីករណ្តៅ ក្នុងកណ្តាលស្មសាន ក្នុងព្រៃ តែម្នាក់ឯង ។

(៦៩៩) បិតាមហោ តាត សុទុព្វលោ តេ
អនេកព្យាធីហិ ទុខេហិ ផុដ្ឋោ
តមជ្ជហំ និក្ខណិស្សាមិ សោព្ភេ
ន ហិស្ស តំ ជីវិតំ រោចយាមិ ។

(៧០០) សព្វម្បេតំ បដិលទ្ធបាបកំ
អច្ចាហិតំ កម្មំ ករោសិ លុទ្ទំ
មយាបិ តាត បដិលច្ឆសេ តុវំ
ឯតាទិសំ កម្មំ ជរូបនីតោ
តំ កុលវត្តំ អនុវត្តមានោ
អហម្បិ តំ និក្ខណិស្សាមិ សោព្ភេ ។

(៧០១) ផរុសាហិ វាចាហិ បកុព្វមានោ
អាសជ្ជ មំ ត្វំ វទសេ កុមារ
បុត្តោ មមំ ឱរសកោ សមានោ
អហិតានុកម្បី មេ ត្វំសិ បុត្ត ។



(៦៩៩) (បិតាពោលថា) ម្នាលកូន ជីតារបស់អ្នក មានកំឡាំងថយ ថយណាស់ហើយ ត្រូវព្យាធិទុក្ខច្រើនយ៉ាងប៉ះពាល់ ថ្ងៃនេះ អញនឹងកប់គាត់ចោលក្នុងរណ្តៅ ព្រោះមិនចង់ឲ្យគាត់រស់នៅទេ ។

(៧០០) (កុមារ...) សេចក្តីត្រិះរិះនោះ ជាអំពើលាមក ដែលបិតាបានហើយ បិតាធ្វើនូវកម្ម មិនជាប្រយោជន៍ក្រៃពេក ជាអំពើអាក្រក់ បពិត្របិតា អ្នកកាលបើជរាចូលគ្របសង្កត់ រមែងបាននូវកម្មប្រាកដដូច្នេះ អំពីខ្ញុំវិញ សូម្បីខ្ញុំកាលប្រព្រឹត្តតាមវត្តរបស់ត្រកូលនោះ នឹងកប់បិតា ក្នុងរណ្តៅវិញ ។

(៧០១) (បិតា...) ម្នាលកុមារ អ្នកគ្របសង្កត់ និយាយ[illegible]អញដោយសំដីអាក្រក់ ឱកូន អ្នកជាកូនកើតអំពីទ្រូងនៃអញ អនុគ្រោះដោយអំពើ មិនមែនជាប្រយោជន៍ដល់អញ ។

(៧០២) ន ខ្វាហំ តាត អហិតានុកម្បី
ហិតានុកម្បី តេ អហញ្ហិ តាត
តាបញ្ច តំ កម្ម បកុព្វមានំ
អរហាមិ តោ វារយិតុំ ឥតោ ហិ ។

(៧០៣) យោ មាតរំ វា បិតរំ សវិដ្ឋ
អទូសកេ ហឹសតិ បាបធម្មោ
កាយស្ស ភេទា អភិសម្បរាយំ
អសំសយំ សោ និរយំ ឧបេតិ ។

(៧០៤) យោ មាតរំ វា បិតរំ សវិដ្ឋ
អន្នេន បានេន ឧបដ្ឋហាតិ
កាយស្ស ភេទា អភិសម្បរាយំ
អសំសយំ សោ សុគតឹ ឧបេតិ ។

(៧០៥) ន មេ ត្វំ បុត្ត អហិតានុកម្បី
ហិតានុកម្បី មេ ត្វំសិ បុត្ត
អហញ្ច តេ មាតរា វុច្ចមានោ
ឯតាទិសំ កម្ម ករោមិ លុទ្ទំ ។



(៧០២) (កុមារ..) បពិត្របិតា ខ្ញុំមិនមែនអនុគ្រោះលោក ដោយឥតប្រយោជន៍ទេ បពិត្របិតា ពិតណាស់ ខ្ញុំអនុគ្រោះដោយប្រយោជន៍ដល់លោក ដោយពិត ប៉ុន្តែ ខ្ញុំមិនគួរ ដើម្បីនឹងឃាត់លោក ដែលកំពុងធ្វើកម្មអាក្រក់ ដោយហេតុនោះទេ ។

(៧០៣) បពិត្រសេដ្ឋី៖ បុគ្គលណា មានធម៌ដ៏លាមក បៀតបៀននូវមាតាបិតា ដែលជាអ្នកមិនប្រទូស្ត បុគ្គលនោះ លុះបែកធ្លាយនៃកាយទៅក្នុងភពខាងមុខ រមែងកើតក្នុងនរក ឥតសង្ស័យ ។

(៧០៤) បពិត្រសេដ្ឋី៖ បុគ្គលណា ទំនុកបំរុងមាតាបិតា ដោយបាយនឹងទឹក បុគ្គលនោះ លុះបែកធ្លាយនៃកាយ ទៅក្នុងភពខាងមុខ រមែងកើត ក្នុងសុគតិ ឥតសង្ស័យ ។

(៧០៥) (បិតា...) ម្នាលកូន អ្នកមិនមែនអនុគ្រោះ ដោយឥតប្រយោជន៍ដល់យើងទេ ម្នាលកូន អ្នកអនុគ្រោះ ដោយប្រយោជន៍ដល់យើងពិត ចំណែកខាងយើង ត្រូវមាតារបស់អ្នកប្រើ ទើបមកធ្វើ នូវកម្មអាក្រក់ ព្រោតដូច្នេះ ។

(៧០៦) យា តេ សា ភរិយា អនរិយរូបា
មាតា មមេសា សកិយា(១) ជនេត្តិ
និទ្ធាបយេ តញ្ច សកា អគារា
អញ្ញម្បិ តេ សា ទុខមាវហេយ្យ ។

(៧០៧) យា តេ សា ភរិយា អនរិយរូបា
មាតា មមេសា សកិយា ជនេត្តិ
ទន្តា ករេណូវ វសូបនីតា
សា បាបធម្មា បុនរាវជាតុ ។

តក្កលជាតកំ អដ្ឋមំ ។

## មហាធម្មបាលជាតកំ

(៧០៨) កិន្តេ វតំ កិំ បន ព្រហ្មចរិយំ
កិស្ស សុចិណ្ណស្ស អយំ វិបាកោ
អក្ខាហិ មេ ព្រាហ្មណ ឯតមត្ថំ
កស្មា នុ តុម្ហំ ទហរា ន មិយ្យរេ ។

១ ម. ជនិយា ។



(៧០៦) (កុមារ...) ស្ត្រីណា ជាភរិយារបស់បិតា មានសភាពមិនប្រសើរ ស្ត្រីនោះ ជាមាតាបង្កើតរបស់ខ្ញុំ បិតាគប្បីបណ្តេញមាតានោះ ចេញចាកផ្ទះរបស់ខ្លួន ព្រោះថា មាតានោះ គង់នឹងនាំទុក្ខឯទៀត មកឲ្យបិតា មិនខាន ។

(៧០៧) ស្ត្រីណា ជាភរិយារបស់បិតា មានសភាពមិនប្រសើរ ស្ត្រីនោះ ជាមាតាបង្កើតរបស់ខ្ញុំ មាតាមានធម៌លាមកនោះ ចុះខ្លួនខ្លួន ចុះអំណាច ដូចជាមេដំរី ចូលត្រឡប់មក (កាន់ផ្ទះ) វិញ ។

ចប់ តក្កលជាតក ទី ៨ ។

## មហាធម្មបាលជាតក

(៧០៨) (អាចារ្យសួរថា) អ្វីជាវត្តរបស់អ្នក អ្វីជាព្រហ្មចរិយៈរបស់អ្នក នេះជាផលសុចរិតធម៌ ដូចម្តេច ដែលអ្នកសន្សំល្អហើយ ម្នាលព្រាហ្មណ៍ អ្នកចូរប្រាប់សេចក្តីនុ៎ះដល់ខ្ញុំ ព្រោះហេតុអ្វី ទើបពួកជននៅក្មេង (ក្នុងត្រកូល) របស់អ្នក មិនស្លាប់ ។

(៧០៩) ធម្មំ ចរាម ន មុសា ភណាម
បាបានិ កម្មានិ វិវជ្ជយាម
អនរិយំ បរិវជ្ជេម(១) សព្វំ
តស្មា ហិ អម្ហំ ទហរា ន មិយ្យរេ(២) ។

(៧១០) សុណោម ធម្មំ អសតំ សតញ្ច
ន ចាបិ ធម្មំ អសតំ រោចយាម
ហិត្វា អសន្តេ ន ជហាម សន្តេ
តស្មា ហិ អម្ហំ ទហរា ន មិយ្យរេ ។

(៧១១) បុព្វេវ ទានា សុមនា ភវាម
ទទម្បិ វេ(៣) អត្តមនា ភវាម
ទត្វាបិ វេ(៤) នានុតបាម បច្ឆា
តស្មា ហិ អម្ហំ ទហរា ន មិយ្យរេ ។

(៧១២) សមណេ មយំ ព្រាហ្មណេ អទ្ធិកេ ច
វណិព្វកេ យាចនកេ ទលិទ្ទេ
អន្នេន បានេន អភិតប្បយាម
តស្មា ហិ អម្ហំ ទហរា ន មិយ្យរេ ។

១ ឱ. ម. បរិវជ្ជេម ។ ២ ឱ. តស្មា ហិ អម្ហំ ទហរា ន មីយរេ ។ ៣–៤ ឱ. ម. វេ ។



(៧០៩) (បិតារបស់ធម្មបាល តបថា) ពួកយើងប្រព្រឹត្តធម៌ មិននិយាយកុហក វៀរខ្លួនអំពើដ៏លាមក វៀរខ្លួនអំពើមិនប្រសើរគ្រប់យ៉ាង ព្រោះហេតុនោះឯង ទើបពួកជននៅក្មេង (ក្នុងត្រកូល) របស់ពួកយើង មិនស្លាប់ ។

(៧១០) ពួកយើងស្តាប់ធម៌ របស់អសប្បុរសផង សប្បុរសផង ប៉ុន្តែពួកយើង មិនពេញចិត្ត នឹងធម៌របស់ពួកអសប្បុរសទេ ពួកយើងលះបង់អសប្បុរស មិនលះបង់សប្បុរសទេ ព្រោះហេតុនោះឯង ទើបពួកជននៅក្មេង (ក្នុងត្រកូល) របស់ពួកយើង មិនស្លាប់ ។

(៧១១) ពួកយើង មានចិត្តល្អ ក្នុងកាលមុនឲ្យ កាលកំពុងឲ្យក៏មានចិត្តត្រេកអរ លុះឲ្យហើយ មិនក្តៅក្រហាយក្រោយ ព្រោះហេតុនោះឯង ទើបពួកជននៅក្មេង (ក្នុងត្រកូល) របស់ពួកយើង មិនស្លាប់ ។

(៧១២) ពួកយើង បានញុំាងពួកសមណព្រាហ្មណ៍ អ្នកដំណើរ ស្មូម យាចក នឹងអ្នកកំសត់ ឲ្យឆ្អែតស្កប់ស្កល់ ដោយបាយនឹងទឹក ព្រោះហេតុនោះឯង ទើបពួកជននៅក្មេង (ក្នុងត្រកូល) របស់យើង មិនស្លាប់ ។

(៧១៣) មយញ្ច ភរិយំ នាតិក្កមាម
ភរិយាបិ អម្ហេ នាតិក្កមន្តិ
អញ្ញត្រ តាហិ ព្រហ្មចរិយំ ចរាម
តស្មា ហិ អម្ហំ ទហរា ន មិយ្យរេ ។

(៧១៤) បាណាតិបាតា វិរមាម សព្វេ
លោកេ អទិន្នំ បរិវជ្ជយាម
អមជ្ជបា នោបិ មុសា ភណាម
តស្មា ហិ អម្ហំ ទហរា ន មិយ្យរេ ។

(៧១៥) ឯតាសុ វេ ជាយរេ សុត្តមាសុ
មេធាវិនោ ហោន្តិ ពហុតបញ្ញា
ពហុស្សុតា វេទគុនោ ច ហោន្តិ
តស្មា ហិ អម្ហំ ទហរា ន មិយ្យរេ ។

(៧១៦) មាតា បិតរោ ភគិនី ភាតរោ ច
បុត្តា ច ទារា ច មយញ្ច សព្វេ
ធម្មំ ចរាម បរលោកហេតុ
តស្មា ហិ អម្ហំ ទហរា ន មិយ្យរេ ។



(៧១៣) ពួកយើង មិនប្រព្រឹត្តកន្លងចិត្តភរិយាទេ ទាំងពួកភរិយា ក៏មិនប្រព្រឹត្តកន្លងចិត្តយើង ពួកយើងប្រព្រឹត្តនូវព្រហ្មចរិយធម៌ លើកលែងតែភរិយាទាំងនោះចេញ ព្រោះហេតុនោះឯង ទើបពួកជននៅក្មេង (ក្នុងត្រកូល) របស់ពួកយើង មិនស្លាប់ ។

(៧១៤) យើងទាំងអស់គ្នា វៀរចាកបាណាតិបាត វៀរចាកអទិន្នាទានក្នុងលោក មិនផឹកទឹកស្រវឹង មិននិយាយពាក្យកុហក ព្រោះហេតុនោះឯង ទើបពួកជននៅក្មេង (ក្នុងត្រកូល) របស់ពួកយើង មិនស្លាប់ ។

(៧១៥) កូនទាំងឡាយ (របស់យើង) កើតក្នុងពួកស្ត្រីដ៏ឧត្តម រមែងជាអ្នកប្រាជ្ញ មានប្រាជ្ញាច្រើន ជាពហុស្សូត ដល់នូវវេទ ព្រោះហេតុនោះឯង ទើបពួកជននៅក្មេង (ក្នុងត្រកូល) របស់យើង មិនស្លាប់ ។

(៧១៦) មាតាបិតា បងប្អូនស្រី បងប្អូនប្រុស កូន ប្រពន្ធ និងយើងគ្រប់គ្នា ប្រព្រឹត្តធម៌ ដើម្បីជាប្រយោជន៍ ក្នុងលោកខាងមុខ ព្រោះហេតុនោះឯង ទើបពួកជននៅក្មេង (ក្នុងត្រកូល) របស់ពួកយើង មិនស្លាប់ ។

(៧៥៧) ទាសា ច ទាសី អនុជីវិនោ ច
បរិចារិកា កម្មករា ច សព្វេ
ធម្មំ ចរន្តិ បរលោកហេតុ
តស្មា ហិ អម្ហំ ទហរា ន មិយ្យរេ ។

(៧៥៨) ធម្មោ ហវេ រក្ខតិ ធម្មចារឹ
ធម្មោ សុចិណ្ណោ សុខមាវហាតិ
ឯសានិសំសោ ធម្មេ សុចិណ្ណេ
ន ទុគ្គតឹ គច្ឆតិ ធម្មចារី ។

(៧៥៩) ធម្មោ ហវេ រក្ខតិ ធម្មចារឹ
ឆត្តំ មហន្តំ វិយ វស្សកាលេ
ធម្មេន គុត្តោ មម ធម្មបាលោ
អញ្ញស្ស អដ្ឋីនិ សុខី កុមារោ ។

មហាធម្មបាលជាតកំ នវមំ ។

## កុក្កុដជាតកំ

(៧៦០) នាស្មសេ កតបាបម្ហិ នាស្មសេ អលិកវាទិនេ
នាស្មសេ អត្តត្ថបញ្ញម្ហិ អតិសន្តេបិ នាស្មសេ ។



(៧៥៧) ពួកខ្ញុំប្រុស ពួកខ្ញុំស្រី អ្នកចិញ្ចឹមជីវិតដោយសារ អ្នកបម្រើ និងអ្នកធ្វើខ្ញុំការទាំងអស់ ប្រព្រឹត្តធម៌ ដើម្បីប្រយោជន៍ ក្នុងលោកខាងមុខ ព្រោះហេតុនោះឯង ទើបពួកជននៅក្មេង (ក្នុងត្រកូល) របស់យើង មិនស្លាប់ ។

(៧៥៨) ធម៌ រមែងរក្សាអ្នកប្រព្រឹត្តធម៌ ដោយពិត ធម៌ដែលសន្សំល្អហើយ រមែងនាំសុខមកឲ្យ នេះជាអានិសង្ស ក្នុងធម៌ដែលសន្សំល្អហើយ បុគ្គលអ្នកប្រព្រឹត្តធម៌ រមែងមិនទៅកាន់ទុគ្គតិ ។

(៧៥៩) ធម៌ រមែងរក្សាអ្នកប្រព្រឹត្តធម៌ ដោយពិត ដូចឆ័ត្រធំ (ការពារ) ក្នុងកាលដែលភ្លៀង ធម្មបាលជាបុត្ររបស់យើង ធម៌គ្រប់គ្រងហើយ ឆ្អឹង (ដែលអ្នកនាំមកនេះ) ជាឆ្អឹងសត្វដទៃ កុមារ (ជាបុត្ររបស់យើង) មានសេចក្ដីសុខនៅឡើយ ។

ចប់ មហាធម្មបាលជាតក ទី ៩ ។

## កុក្កុដជាតក

(៧៦០) (មាន់ពោធិសត្វពោលថា) បុគ្គលមិនគប្បីស្និទ្ធស្នាល នឹងបុគ្គលដែលធ្វើបាបកម្មហើយ មិនគប្បីស្និទ្ធស្នាល នឹងបុគ្គលដែលពោលពាក្យលេសលោះ មិនគប្បីស្និទ្ធស្នាល នឹងបុគ្គលដែលមានប្រាជ្ញាគិតតែប្រយោជន៍ខ្លួន មិនគប្បីស្និទ្ធស្នាលនឹងបុគ្គល (មានពុតត្បុត) ដែលធ្វើហាក់ដូចជាស្ងប់ស្ងាត់ ក្រៃលែង ។

(៧២១) កល្លិ ហោតេ បុរិសា     គោបិតាសិកជាតិកា

ឃសន្តិ មញ្ញេ មិត្តានិ     វាចាយ ន ច កម្មុនា ។

(៧២២) សុខញ្ជលី បគ្គហិតា     វាចាយ បលិគុណ្ឋិតា

មនុស្សផេគ្គុ នាសីទេ     យស្មិំ នត្ថិ កតញ្ញុតា ។

(៧២៣) នហិ អញ្ញញ្ញចិត្តានំ(១)     ឥត្ថីនំ បុរិសាន ច

នានាវិកត្វា សំសគ្គំ     តាទិសម្បិ ន សេវិយេ(២) ។

(៧២៤) អនរិយកម្មុក្កន្តំ     អត្ថេតំ សព្វឃាតិនំ

និសិតំវ បដិច្ឆន្នំ     តាទិសម្បិ ន សេវិយេ ។

(៧២៥) មិត្តរូបេនិធេកច្ចេ(៣) សាខល្យេន(៤) អចេតសា

វិវិធេហិ ឧបាយន្តិ     តាទិសម្បិ ន សេវិយេ ។

---

១ ឱ. អញ្ញសចិត្តានំ ។ ម អញ្ញញ្ញចិត្តានំ ។ ២ ឱ. សេវយេ ។ ម.ឧ សេវយេ ។
៣ ឱ. ម. មិត្តរូបេនិធេកច្ចេ ។ ៤ ឱ. សាខល្លេន ។



(៧២១) បុរសពួកខ្លះ ប្រកបដោយជាតិ ហាក់ដូចជាគោស្រែកទឹក ស៊ីនូវមិត្ត ដោយពាក្យ តែម្តង (សាស្ត្រះដោយការងារ) ។

(៧២២) បុរសពួកខ្លះ ផ្គងអញ្ជលីទទេៗ ហើយបិទបាំង ដោយពាក្យ ជាមនុស្សស្រាយ កតញ្ញុតាធម៌ មិនមានក្នុងបុគ្គលណា សប្បុរស មិនគប្បីចូលទៅជិត នូវបុគ្គលនោះទេ ។

(៧២៣) បុគ្គលមិនគប្បីសេពគប់ស្ត្រី ឬបុរស ដែលមានចិត្តប្រែប្រួល (អ្នកណា) ធ្វើនូវសេចក្តីសេពគប់ ឲ្យច្បាស់ដោយអំពើផ្សេងៗ (ហើយធ្វើនូវសេចក្តីអន្តរាយ ក្នុងកាលខាងក្រោយ) បុគ្គល មិនគប្បីសេពគប់ នឹងបុគ្គលបែបនោះទេ ។

(៧២៤) អ្នកដែលល្មោភនឹងអំពើមិនប្រសើរ មានពាក្យមិនខ្ជាប់ខ្ជួន បៀតបៀននូវជនទាំងពួង ដូចជាដាវដែលសំលៀង ហើយបិទបាំងទុក បុគ្គលមិនគប្បីសេពគប់ នឹងបុគ្គលបែបនោះទេ ។

(៧២៥) បុគ្គលពួកខ្លះ ក្នុងលោកនេះ ចូលទៅជិតដោយឧបាយផ្សេងៗ នឹងដោយសំណាប ធ្វើហាក់ដូចជាមិត្ត (ដ៏ស្និទ្ធ) មានពាក្យដ៏ស្អាតផូរផង់ តែមិនមានចិត្ត (ស្អាតល្អ) បុគ្គលមិនគប្បីសេពគប់ នឹងបុគ្គលបែបនោះទេ ។

[៧៦៦] អាមិសំ វា ធនំ វាបិ  យត្ថ បស្សតិ តាទិសោ
ទុព្ភិំ ករោតិ ទុម្មេធោ  តញ្ច ហន្ត្វាន គច្ឆតិ ។

[៧៦៧] មិត្តរូបេន ពហវោ  ឆន្នា សេវន្តិ សត្តវោ
ជហេ កាបុរិសេ ហេតេ  កុក្កុដោ វិយ សេនកំ ។

[៧៦៨] យោ ច ឧប្បតិតំ អត្ថំ  ខិប្បមេវ ន ពុជ្ឈតិ
អមិត្តវសមន្វេតិ  បច្ឆា អនុតប្បតិ ។

[៧៦៩] យោ ច ឧប្បតិតំ អត្ថំ  ខិប្បមេវ និពោធតិ
មុច្ចតេ សត្តុសម្ពាធា  កុក្កុដោ វិយ សេនកា ។

[៧៧០] តំ តាទិសំ កូដមិវោឌ្ឌិតំ វនេ
អធម្មិកំ និច្ចវិធំសការិនំ
អារា វិវជ្ជេយ្យ នរោ វិចក្ខណោ
សេនំ យថា កុក្កុដោ វំសកាននេតិ ។

កុក្កុដជាតកំ ទសមំ ។



(៧៦៦) ជនឥតប្រាជ្ញបែបនោះ ឃើញនូវអាមិសៈ ឬទ្រព្យ ក្នុងផ្ទះសម្លាញ់ណា រមែងធ្វើនូវសេចក្តីប្រទុស្ត បៀតបៀន នូវជននោះ ហើយចៀសចេញទៅ ។

(៧៦៧) (អភិសម្ពុទ្ធគាថា) សត្រូវច្រើនបិទបាំង ដោយសភាពហាក់ដូចជាមិត្តមកសេពគប់ បុគ្គលគប្បីលះបង់ នូវបុរសអាក្រក់នោះចោលចេញ ដូចមាន់លះបង់ខ្លែង ។

(៧៦៨) បុគ្គលណា មិនឆាប់យល់នូវហេតុ ដែលកើតឡើង បុគ្គលនោះ រមែងលុះអំណាចសត្រូវ រមែងក្តៅក្រហាយរឿយ ៗ ក្នុងកាលជាខាងក្រោយ ។

(៧៦៩) បុគ្គលណា យល់ឆាប់នូវហេតុដែលកើតឡើង បុគ្គលនោះរមែងរួចផុតចាកការបៀតបៀន របស់សត្រូវ ដូចជាមាន់រួចអំពីខ្លែង ។

(៧៧០) ជនមានប្រាជ្ញាវាងវៃ គប្បីវៀរអំពីចម្ងាយនូវបុគ្គលមិនប្រកបដោយធម៌ ជាអ្នកកំចាត់នូវគុណរបស់បុគ្គលដទៃជានិច្ច ប្រាកដដូចជាអន្ទាក់បញ្ឆោត ដែលគេដាក់ក្នុងព្រៃ ដូចជាមាន់វៀរខ្លែង ក្នុងព្រៃឫស្សី ។

ចប់ កុក្កុដជាតក ទី ១០ ។

# មដ្ឋកុណ្ឌលិជាតកំ(១)

(៧៣១) អលង្កតោ មដ្ឋកុណ្ឌលី
មាលធារី ហរិចន្ទនុស្សទោ
ពាហា បគ្គយ្ហ កន្ទសិ
វនមជ្ឈេ កឹ ទុក្ខិតោ តុវំ ។

(៧៣២) សោវណ្ណមយោ បភស្សរោ
ឧប្បន្នោ រថបញ្ជរោ មម
តស្ស ចក្កយុគំ ន វិន្ទាមិ
តេន ទុក្ខេន ជហាមិ ជីវិតំ ។

(៧៣៣) សោវណ្ណមយំ មណីមយំ
លោហមយំ អថ រូបិយមយំ
ពាវទ រថំ ករិស្សាមិ តេ
ចក្កយុគំ បដិលាភយាមិ(២) តំ ។

---

១. មដ្ឋកុណ្ឌលីជាតកំ ។ ២. ម. ឆ. បដិបាទយាមិ ។



# មដ្ឋកុណ្ឌលិជាតក

(៧៣១) (ព្រាហ្មណ៍ សួរថា) អ្នកស្អិតស្អាង ដោយគ្រឿងប្រដាប់ មានកុណ្ឌលដ៏រលីង ទ្រទ្រង់នូវកម្រងផ្កា ប្រស់ព្រំដោយខ្លឹមចន្ទន៍ក្រហម ផ្គងដៃកន្ទក់កន្ទេញ ក្នុងកណ្តាលនៃព្រៃស្មសាន តើអ្នកដល់នូវសេចក្តីទុក្ខ ដូចម្តេច ។

(៧៣២) (មាណព ឆ្លើយថា) គ្រោងនៃរថ ធ្វើដោយមាស មានរស្មីភ្លឺផ្លេក កើតឡើងហើយ ដើម្បីខ្ញុំ (តែ) ខ្ញុំមិនបាននូវនឹមនៃកង់របស់រថនោះទេ ខ្ញុំនឹងលះបង់ជីវិត ព្រោះសេចក្តីទុក្ខនោះ ។

(៧៣៣) (ព្រាហ្មណ៍...) អ្នកចូរប្រាប់នូវរថ ដែលធ្វើដោយមាស ធ្វើដោយកែវមណី ធ្វើដោយទង់ដែង ឬធ្វើដោយប្រាក់ចុះ ខ្ញុំនឹងធ្វើរថ (នោះ) ឲ្យដល់អ្នក ខ្ញុំនឹងញ៉ាំងអ្នក ឲ្យបាននូវនឹមនៃកង់ (នោះ) ។

(៧៣៤) អថ មាណវោ(១) តស្ស ភាសតិ
ចន្ទិមសុរិយា ឧភយត្ថ ភាតរោ
សោវណ្ណមយោ រថោ មម
តេន ចក្កយុគេន សោភតិ ។

(៧៣៥) ពាលោ ខោ ត្វំសិ មាណវ
យោ ត្វំ បត្ថយសិ អបត្ថិយំ
មញ្ញាមិ តុវំ មរិស្សសិ
ន ហិ ត្វំ លច្ឆសិ ចន្ទសុរិយេ ។

(៧៣៦) គមនាគមនម្បិ ទិស្សតិ
វណ្ណធាតុ ឧភយេត្ថ វីថិយោ
បេតោ បន នេវ ទិស្សតិ
កោ នុ ខោ កន្ទតំ ពាល្យតរោ ។

(៧៣៧) សច្ចំ ខោ វទេសិ មាណវ
អហមេវ កន្ទតំ ពាល្យតរោ
ចន្ទំ វិយ ទារកោ រុទំ
បេតំ កាលកតាភិបត្ថយេ ។

---

១ [illegible] មាណវោ ។



(៧៣៤) លំដាប់នោះ មាណពក្រាបទូលព្រាហ្មណ៍នោះថា ព្រះចន្ទនិងព្រះអាទិត្យ ទ្រង់រៀនក្នុងវិថីទាំងពីរ ជារបស់ខ្ញុំ ដែលធ្វើអំពីមាស ហើយសមអោយគួរនឹងកង់ គឺព្រះចន្ទ និងព្រះអាទិត្យនោះ ។

(៧៣៥) (ព្រាហ្មណ៍...) ម្នាលមាណព អ្នកណា ប្រាថ្នារបស់ដែលមិនគួរប្រាថ្នា អ្នកនោះឈ្មោះថាល្ងង់មែន ខ្ញុំសំគាល់ថា អ្នកនឹងស្លាប់ អ្នកពិតជាមិនបាននូវព្រះចន្ទ និងព្រះអាទិត្យឡើយ ។

(៧៣៦) (មាណព...) ការទៅនិងការមក (នៃព្រះចន្ទ និងព្រះអាទិត្យទាំងពីរ) ក៏ប្រាកដ វណ្ណធាតុ (ស្មើ) ក៏ប្រាកដ វិថីទាំងពីរឃើញការសន្ធឹះ ក៏ប្រាកដ ចំណែកខាងជនធ្វើមរណកាល ទៅកាន់លោកខាងមុខហើយ មិនប្រាកដទេ បណ្តាយើងទាំងពីរនាក់ ដែលកំពុងកន្ទក់កន្ទេញ តើអ្នកណា ល្ងង់ជាង ។

(៧៣៧) (ព្រាហ្មណ៍...) ម្នាលមាណព អ្នកនិយាយត្រូវមែន បណ្តាយើងទាំងពីរនាក់ កំពុងកន្ទក់កន្ទេញ ខ្ញុំនេះឯង ជាបុគ្គលល្ងង់ជាង ខ្ញុំប្រាថ្នានូវកូនដែលធ្វើមរណកាល ទៅកាន់លោកខាងមុខ ដូចជាទារកយំទារនូវព្រះចន្ទ ។

[៧៣៨] អាទិត្តំ វត មំ សន្តំ ឃតសិត្តំវ បាវកំ
វារិនា វិយ ឱសិញ្ចំ សព្វំ និព្វាបយេ ទរំ ។

[៧៣៩] អព្ពុហី(១) វត មេ សល្លំ យមាសិ ហទយស្សិតំ
យោ មេ សោកបរេតស្ស បុត្តសោកំ អបានុទិ ។

[៧៤០] សោហំ អព្ពូឡ្ហសល្លោស្មិ វីតសោកោ អនាវិលោ
ន សោចាមិ ន រោទាមិ តវ សុត្វាន មាណវាតិ ។

មដ្ឋកុណ្ឌលិជាតកំ ឯកាទសមំ ។

## ពិឡារ(២)កោសិយជាតកំ

[៧៤១] អបចន្តាបិ ទិច្ឆន្តិ សន្តោ លទ្ធាន ភោជនំ
កិមេវ ត្វំ បចមានោ យំ ន ទជ្ជា ន តំ សមំ ។

[៧៤២] មច្ឆេរា ច បមាទា ច ឯវំ(៣) ទានំ ន ទិយ្យតិ
បុញ្ញំ អាកង្ខមានេន ទេយ្យំ ហោតិ វិជានតា ។

១ ម. អព្ពហី ។ ឱ. អព្ពុឡ្ហំ ។ ២ ម. ពិឡារិ... ។ ៣ ម. ឯតំ ។



[៧៣៨] អ្នកបានស្រោចស្រប់ខ្ញុំ ដែលក្ដៅភ្លើងគឺសេចក្ដីសោកកំពុងឆេះ ឲ្យស្ងប់រម្ងាប់ ញុំាងសេចក្ដីក្រវល់ក្រវាយទាំងអស់ឲ្យរលត់ ដូចបុគ្គលយកទឹកស្រោចទៅភ្លើង ដែលឆេះខ្ទាំងខ្លាញ់ ។

[៧៣៩] សរគឺសេចក្ដីសោកណា ដែលអាស្រ័យក្នុងហឫទ័យ សរគឺសេចក្ដីសោកនោះ ខ្ញុំបានដកចេញហើយ ខ្ញុំកាលត្រូវសេចក្ដីសោកគ្របសង្កត់ អ្នកបានបន្ទោបង់សេចក្ដីសោក ព្រោះបុត្រនោះហើយ ។

[៧៤០] ម្នាលមាណព ខ្ញុំនោះជាអ្នកមានសរគឺសេចក្ដីសោកដកចេញហើយ ជាអ្នកប្រាសចាកសេចក្ដីសោក មានចិត្តមិនល្អក់ ម្នាលមាណព ខ្ញុំលែងសោកស្ដាយ លែងយំទួញ ព្រោះបានស្ដាប់ពាក្យរបស់អ្នក ។

ចប់ មដ្ឋកុណ្ឌលីជាតក ទី ១១ ។

## ពិឡារកោសិយជាតក

[៧៤១] (ឥន្ទ្រព្រាហ្មណ៍ពោលថា) សប្បុរសទាំងឡាយ ទោះបីមិនបានចំអិន តែបើបានភោជនហើយ ក៏ប្រាថ្នានឹងឲ្យដែរ អ្នកកាលចំអិន មិនឲ្យភោជនណា ការមិនឲ្យភោជននោះ មិនសមគួរទេ ។

[៧៤២] បុគ្គលមិនឲ្យទាន (ដោយហេតុ ២ យ៉ាងគឺ) សេចក្ដីកំណាញ់ ១ សេចក្ដីប្រមាទ ១ បុគ្គលអ្នកចេះដឹង កាលប្រាថ្នា នូវបុណ្យ រមែងឲ្យទាន ។

(៧៤៣)យស្សេវ ភីតោ ន ទទាតិ(មច្ឆរី)តទេវាទទតោ ភយំ

ជិឃច្ឆា ច បិបាសា ច យស្ស ភាយតិ មច្ឆរី

តមេវ ពាលំ ផុសតិ អស្មឹ លោកេ បរម្ហិ ច ។

(៧៤៤)តស្មា វិនេយ្យ មច្ឆេរំ ទជ្ជា ទានំ មលាភិភូ

បុញ្ញំ ហិ បរលោកស្មឹ បតិដ្ឋា ហោតិ បាណិនំ ។

(៧៤៥)ទុទ្ទទំ ទទមានានំ ទុក្ករំ កម្ម កុព្វតំ

អសន្តោ នានុកុព្វន្តិ សតំ ធម្មោ ទុរន្នយោ ។

(៧៤៦)តស្មា សតញ្ច អសតញ្ច នានា ហោតិ ឥតោ គតិ

អសន្តោ និរយំ យន្តិ សន្តោ សគ្គបរាយណា ។



(៧៤៣) (ចន្ទព្រាហ្មណ៍ ពោលថា) បុគ្គលកំណាញ់ ខ្លាចចំពោះសេចក្ដីឃ្លាន និងការស្រេកណាហើយ តែងមិនឲ្យទានមិនកើតនេ សេចក្ដីឃ្លាន និងការស្រេកនោះ ជាភ័យរបស់បុគ្គលអ្នកមិនឲ្យ បុគ្គលកំណាញ់ តែងខ្លាចចំពោះសេចក្ដីឃ្លាន និងការស្រេកណា សេចក្ដីឃ្លាន និងការស្រេកនោះ តែងប៉ះពាល់នូវបុគ្គលពាលនោះ ឯង ក្នុងលោកនេះផង ក្នុងលោកខាងមុខផង ។

(៧៤៤) ព្រោះហេតុនោះ បុគ្គលគប្បីបន្ទោបង់ នូវសេចក្ដីកំណាញ់ចេញ គប្បីគ្របសង្កត់នូវមន្ទិល គឺសេចក្ដីកំណាញ់ ហើយឲ្យនូវទាន ព្រោះថា បុណ្យ តែងជាទីពឹង របស់សត្វទាំងឡាយ ក្នុងលោកខាងមុខ ។

(៧៤៥) (សុរិយព្រាហ្មណ៍ ពោលថា) ពួកជនជាសប្បុរស ឲ្យនូវវត្ថុដែលគេឲ្យ បានដោយក្រ ធ្វើនូវអំពើដែលគេធ្វើ បានដោយក្រ ឯពួកអសប្បុរស តែងមិនធ្វើតាមឡើយ ធម៌របស់សប្បុរស គឺអសប្បុរសយល់បានដោយក្រ ។

(៧៤៦) ព្រោះហេតុនោះ គតិ របស់ពួកសប្បុរស និងអសប្បុរស តែងបែកផ្សេងគ្នាអំពីលោកនេះ ពួកអសប្បុរស តែងទៅកាន់នរក ពួកសប្បុរស តែងមានឋានសួគ៌ប្រព្រឹត្តទៅក្នុងខាងមុខ ។

(៧៦៧) អប្បស្មេកេ(១) បវេច្ឆន្តិ ពហុនេកេ(២) ន ឥច្ឆរេ

អប្បស្មា ទក្ខិណា ទិន្នា សហស្សេន សមំ មិតា ។

(៧៦៨) ធម្មញ្ចរេ យោបិ សមុញ្ឆកំ ចរេ

ទារញ្ច(៣) បោសំ ទទមប្បកស្មឹ

សតសហស្សានំ សហស្សយាគិនំ

កលម្បិ នាគ្ឃន្តិ តថាវិធស្ស តេ ។

(៧៦៩) កេនេស យញ្ញោ វិបុលោ មហគ្គតោ

សមេន ទិន្នស្ស អនគ្ឃមេតិ

កថំ សតសហស្សានំ សហស្សយាគិនំ

កលម្បិ នាគ្ឃន្តិ តថាវិធស្ស តេ ។

១ ម. អប្បស្មេកេ ។ ឱ. អប្បមេកេ ។ ២ ម. ពហុនា នេកេ ។ ឱ. ពហុនេ-កេ ។ ៣ ឱ. បុត្តទារំ ។



(៧៦៧) (មាតលិព្រាហ្មណ៍ពោលថា) បណ្ឌិតបុរសពួកខ្លះ សូម្បីមានទេយ្យធម៌បន្តិចបន្តួច ក៏រមែងនៅតែឲ្យបាន តែបុរសពួកខ្លះ (សូម្បីបរិបូណ៌) ដោយទេយ្យធម៌ដ៏ច្រើន ក៏ឲ្យមិនបាន ទក្ខិណាទាន ដែលបុគ្គល (រំលែក) អំពីវត្ថុមានប្រមាណតិចហើយឲ្យ រាប់ស្មើដោយទានមានប្រមាណច្រើន ។

(៧៦៨) (បញ្ចសិខព្រាហ្មណ៍ពោលថា) បុគ្គលណា ប្រព្រឹត្តស្វែងរកអាហារមកចិញ្ចឹមនូវកូននិងប្រពន្ធផង ឲ្យទានសូម្បីបន្តិចបន្តួចផង បុគ្គលនោះឈ្មោះថា ប្រព្រឹត្តធម៌ បុគ្គលជាឥស្សរៈតាំងសែននាក់ ជាអ្នកបូជាតាំងពាន់នោះ មិនដល់នូវចំណិតរបស់អ្នកកំសត់ ដែលឲ្យទានដោយធម៌ មានឧបការៈដូច្នោះឡើយ ។

(៧៦៩) (ពិលារកោសិយសេដ្ឋីសួរថា) យញ្ញៈគឺការបូជាធំ ជាបូជាដ៏ទូលាយ មានផលច្រើន ហេតុអ្វី ទើបមិនដល់នូវថ្លៃនៃទាន ដែលបុគ្គលឲ្យហើយ តាមធម៌ត្រឹមត្រូវ ហេតុអ្វី បុគ្គលជាឥស្សរៈតាំងសែននាក់ ជាអ្នកបូជាតាំងពាន់នោះ មិនដល់នូវចំណិតរបស់អ្នកកំសត់ ដែលឲ្យទានដោយធម៌ មានឧបការៈដូច្នោះ ។

(៧៨០) ទទន្តិ ហេកេ វិសមេ និវិដ្ឋា
ឃត្វា[១] វធិត្វា អថ សោចយិត្វា
សា ទក្ខិណា អស្សុមុខា សទណ្ឌា
សមេន ទិន្នស្ស ន អគ្ឃមេតិ
ឯវំ សហស្សានំ សហស្សយាគិនំ
កលម្បិ នាគ្ឃន្តិ តថាវិធស្ស តេតិ ។

ពិលារកោសិយជាតកំ ទ្វាទសមំ ។

## ចក្កវាកជាតកំ

(៧៨១) វណ្ណវា អភិរូបោសិ ឃនោ សញ្ជាតរោហិតោ
ចក្កវាក សុរូបោសិ វិប្បសន្នមុខិន្ទ្រិយោ ។
(៧៨២) បាឋីនំ បាវុសំ មច្ឆំ ពលជំ មុញ្ជរោហិតំ
គង្គាតីរេ និសិន្នោសិ ឯវំ ភុញ្ជសិ ភោជនំ ។
(៧៨៣) ន វាហមេតំ ភុញ្ជាមិ ជង្គលានុទកានិ វា[២]
អញ្ញត្រ សេវាលបណកា អញ្ញំ មេ សម្ម ភោជនំ ។

---
១ ម. ឆេត្វា ។ ២ ម. ម. សំ. ។





(៧៨០) (បញ្ចសិខៈ...) ព្រោះថា បុគ្គលពួកខ្លះ តាំងនៅក្នុងកាយ-កម្មជាដើម មិនស្មើគ្នា បៀតបៀន សម្លាប់ ឬក៏ធ្វើគេឲ្យសោកសៅ ហើយទើបឲ្យ (នូវទក្ខិណាទាន) ទក្ខិណាទាននោះ ឈ្មោះថា មានមុខជោកជោយទឹកភ្នែក ប្រកបដោយអាជ្ញា រមែងមិនដល់នូវតម្លៃនៃទាន ដែលបុគ្គលឲ្យ ដោយធម៌ស្មើ ព្រោះទេ បុគ្គលជាអ្នកស្រុះតាំងសែននាក់ ជាអ្នកបូជាតាំងពាន់នោះ មិនដល់នូវចំណិតរបស់អ្នកកំសត់ ដែលឲ្យទានដោយធម៌ មានឧបការៈដូច្នោះ ។

ចប់ ពិលារកោសិយជាតក ទី ១២ ។

## ចក្កវាកជាតក

(៧៨១) (ក្អែក សួរថា) ម្នាលចាក្រពាក អ្នកមានសរីរៈដ៏មាំមួន មានសម្បុរនិងរូបដ៏ល្អ មានសម្បុរក្រហមតាំងពីកំណើត មានរូបដ៏សមរម្យ មានឥន្ទ្រិយនិងមុខ ថ្លាផូរផង់ ។
(៧៨២) អ្នកចាំនៅក្បែរឆ្នេរស្ទឹងគង្គា ប្រហែលជាស៊ីនូវភោជន គឺត្រីក្អែក ត្រីសណ្តាយ ត្រីឃ្លោក ត្រីក្រពុ និងត្រីក្តិន យ៉ាងនេះឬ ។
(៧៨៣) (ចាក្រពាក ឆ្លើយថា) ម្នាលសម្លាញ់ ខ្ញុំមិនបរិភោគនូវសាច់របស់សត្វគោក និងសត្វទឹក វៀរលែងតែសារាយនិងចកពេញ ទេ ថែម (គ្រឿងគឺសាច់) ជាភោជន របស់ខ្ញុំ ។

(៧៥៤) ន វាហមេតំ សទ្ទហាមិ ចក្កវាកស្ស ភោជនំ
អហម្បិ សម្ម ភុញ្ជាមិ គាមេ លោណិកតេលិកំ ។

(៧៥៥) មនុស្សេសុ កតំ ភត្តំ សុចិំ មំសូបសេចនំ
ន ច មេ តាទិសោ វណ្ណោ ចក្កវាក យថា តុវំ ។

(៧៥៦) សម្បស្សំ អត្តនិ វេរំ ហឹសាយ មានុសឹ បជំ
ឧត្រស្តោ ឃសសី ភីតោ តេន វណ្ណោ តវាទិសោ ។

(៧៥៧) សព្វលោកវិរុទ្ធោសិ ធង្ក បាបេន កម្មុនា
លទ្ធោ បិណ្ឌោ ន បីណេតិ តេន វណ្ណោ តវាទិសោ ។

(៧៥៨) អហម្បិ សម្ម ភុញ្ជាមិ អហឹសំ សព្វបាណិនំ
អប្បោស្សុក្កោ និរាសង្កី អសោកោ អកុតោភយោ ។

(៧៥៩) សោ ករស្សុ អានុភាវំ វីតិវត្តស្សុ សីលិយំ
អហឹសាយ ចរ លោកេ បិយោ ហោហិសិ មម្មិវ ។



(៧៥៤) (ក្អែក...) ម្នាលសម្លាញ់ ខ្ញុំមិនជឿថា សារាយខ្ចីនឹងចកនោះ ជាភោជន របស់ចាក្រពាកទេ ចំណែកខាងខ្ញុំ បរិភោគអាហារ ភោជន ដែលលាយដោយអំបិល នឹងប្រេងក្នុងស្រុក ។

(៧៥៥) (ខ្ញុំបរិភោគ) នូវបាយលាយដោយសាច់ដ៏ស្អាត ដែលគេធ្វើ ក្នុងពួកមនុស្ស ម្នាលចាក្រពាក អ្នកមានសម្បុរយ៉ាងណា ខ្ញុំមិន មានសម្បុរប្រាកដដូច្នោះទេ ។

(៧៥៦) (ចាក្រពាក...) អ្នកបៀតបៀននូវពួកមនុស្ស សត្វ ឃើញ នូវពៀរក្នុងខ្លួន ស៊ីចំណីតក់ស្លុត ភិតភ័យ ព្រោះហេតុនោះ ទើប ពណ៌សម្បុរ របស់អ្នកប្រាកដដូច្នោះ ។

(៧៥៧) ម្នាលក្អែក អ្នកត្រូវសត្វលោកទាំងពួងទិទៀន បិណ្ឌាហារដែល អ្នកបានមក ដោយអំពើដ៏អាក្រក់ បានជាមិនស្កប់ស្កល់ (ដល់អ្នក) ព្រោះហេតុនោះ ពណ៌សម្បុរ របស់អ្នក ប្រាកដដូច្នោះ ។

(៧៥៨) ម្នាលសម្លាញ់ ខ្លួនខ្ញុំមិនបៀតបៀនពួកសត្វទាំងពួង មកស៊ីទេ ខ្ញុំមានសេចក្តីខ្វល់ខ្វាយតិច ប្រាសចាកសេចក្តីរង្កៀស មិនមាន សេចក្តីសោកភ័យ អំពីទីណាទេ ។

(៧៥៩) អ្នកនោះ ចូរធ្វើនូវអានុភាព គឺសេចក្តីព្យាយាម ចូរផ្លាស់មារ-យាទចេញ កាលបើអ្នកប្រព្រឹត្ត នូវការមិនបៀតបៀនគេ នឹងបាន ជាទីស្រឡាញ់ (របស់សត្វលោក) ដូចជាខ្ញុំដែរ ។

(៧៦០) យោ ន ហន្តិ ន ឃាតេតិ ន ជិនាតិ ន ជាបយេ
មេត្តំសោ សព្វភូតេសុ វេរំ តស្ស ន កេនចីតិ ។

ចក្កវាកជាតកំ តេរសមំ ។

## ភូរិបញ្ញាជាតកំ

(៧៦១) សច្ចំ កិរ ត្វម្បិ ភូរិបញ្ញ
យា តាទិសី សិរី ធិតិ មតិ ច
ន តាយតេ ភាវវសូបនីតំ
យោ យវកំ ភុញ្ជសិ អប្បសូបំ ។

(៧៦២) សុខំ ទុក្ខេន បរិបាចយន្តោ
កាលាកាលំ វិចិនំ ឆន្ទច្ឆន្នោ
អត្ថស្ស ទ្វារានិ អវាបុរន្តោ
តេនាហំ តុស្សាមិ យវោទនេន ។



(៧៦០) អ្នកណា មិនបៀតបៀនគេ ដោយខ្លួនឯង មិនប្រើគេឲ្យបៀតបៀន មិនបំផ្លាញគេ ដោយខ្លួនឯង មិនប្រើគេឲ្យបំផ្លាញ ជាបុគ្គលមានចំណែកនៃមេត្រីចិត្ត ក្នុងពួកសត្វទាំងពួង ពៀរបស់អ្នកនោះ នឹងមិនមាន មួយអន្លើដោយសត្វណានីមួយឡើយ ។

ចប់ ចក្កវាកជាតក ទី ១៣ ។

## ភូរិបញ្ញជាតក

(៧៦១) (អាមាត្យពួកមានអាចារ្យសេនកៈ សួរថា) បពិត្រអ្នកមានបញ្ញាក្រាស់ ដូចផែនដី សិរី សេចក្តីព្យាយាម នឹងប្រាជ្ញាប្រាកដដូច្នេះ រមែងមិនរក្សានូវអ្នក ដែលជាមនុស្សធ្លាក់ចុះ ទៅកាន់អំណាចនៃសេចក្តីមិនចំរើន ព្រោះហេតុតែអ្នកបរិភោគ នូវបាយដំណើប មានសម្លតិច ហេតុការណ៍នោះពិតមែនឬ ។

(៧៦២) (ព្រះមហាសត្វពោធិសត្វ ពោលថា) ខ្ញុំញ៉ាំងសេចក្តីសុខ (ពាស់របស់ខ្លួន) ឲ្យចំរើនដោយសេចក្តីទុក្ខ ពិនិត្យមើលនូវកាលគួរនឹងកាលមិនគួរ ហើយបិទបាំង តាមសេចក្តីពេញចិត្ត (របស់ខ្លួន) បើកនូវទ្វារនៃប្រយោជន៍ ព្រោះហេតុនោះ ទើបត្រេកអរដោយបាយដំណើប ។

(៧៦៣) កាលញ្ញូ ញត្វា អភិជ្ឈិតាយ
មន្តេហិ អត្ថំ បរិបាចយិត្វា
វិជម្ភិសំ សីហវិជម្ភិតានិ
តាយិទ្ធិយា នត្តសិំ មំ មុញ្ចាមិ ។

(៧៦៤) សុទីបំ យោគោ ន កាកេហិ ទាបិ
អវណ្ណសំសគ្គភយា បុនេកោ
ពហុសមាគោ វិបុលត្ថចិន្តី
កិំការណា មេ ន កាកេសិ ទុក្ខំ ។

(៧៦៥) ន បណ្ឌិតា អត្តសុខស្ស ហេតុ
បាបានិ កម្មានិ សមាចរន្តិ
ទុក្ខេន ផុដ្ឋា ខលិតាបិ សន្តា
ឆន្ទា ច ទោសា ន ជហន្តិ ធម្មំ ។

(៧៦៦) យេនកេនចិ វណ្ណេន មុទុនា ទារុណេន វា
ឧទ្ធរេ ទីនមត្តានំ បច្ឆា ធម្មំ សមាចរេ ។



(៧៦៣) មួយទៀត ខ្ញុំដឹងនូវកាលគួរ ហើយញុំាងប្រយោជន៍ ឲ្យចំរើន ដោយប្រាជ្ញា (របស់ខ្លួន) ព្រោះសេចក្តីព្យាយាមដ៏ក្លៀវក្លា ដូចសត្វសីហៈ ធ្វើសេចក្តីព្យាយាមដ៏ទេរឹមជុំន អ្នកគង់នឹងឃើញខ្ញុំ ម្តងទៀត ដោយឫទ្ធិនោះ មិនបាន ។

(៧៦៤) (ព្រះរាជា ត្រាស់សួរថា) ជនពួកខ្លះ ជាអ្នកមានសេចក្តីសុខ ទើបមិនធ្វើបាប ជនពួកខ្លះទៀត (មិនធ្វើបាប) ព្រោះខ្លាចអំពីការ ជាប់ចំពាក់ ដោយការតិះដៀល អ្នកជាបុគ្គលអាចមានគំនិត គិតនូវប្រយោជន៍ដ៏ទូលាយបាន ហេតុអ្វី ក៏មិនធ្វើសេចក្តីលំបាក ដល់យើង ។

(៧៦៥) (ព្រះពោធិសត្វ...) បណ្ឌិតទាំងឡាយ រមែងមិនប្រព្រឹត្តនូវអំពើដ៏លាមក ព្រោះហេតុនៃសេចក្តីសុខ ផ្ទាល់ខ្លួនទេ ពោះបើត្រូវសេចក្តីទុក្ខបំពាល់ ឬឃ្លាតចាក (សម្បត្តិ) ក៏រមែងមិនលះបង់នូវធម៌ ព្រោះសេចក្តីស្រឡាញ់ និងសេចក្តីស្អប់ឡើយ ។

(៧៦៦) (ព្រះរាជា...) បុគ្គលគប្បីលើកតំកើងនូវខ្លួន ដ៏ក្រក្សត់ (ឲ្យតាំងនៅក្នុងសម្បត្តិ) ដោយពាក្យសរសើរ ឬដោយពាក្យដ៏ទន់ ឬក៏ដោយពាក្យទ្រគោះណាមួយ ហើយសឹមប្រព្រឹត្តធម៌ ដោយប្រពៃ ក្នុងកាលជាខាងក្រោយ ។

(៧៦៧)យស្ស រុក្ខស្ស ឆាយាយ និសីទេយ្យ សយេយ្យ វា
ន តស្ស សាខំ ភញ្ជេយ្យ មិត្តទុព្ភោ ហិ បាបកោ ។

(៧៦៨) យស្សាបិ ធម្មំ បុរិសោ វិជញ្ញា
យេ ចស្ស កង្ខំ វិនយន្តិ សន្តោ
តំ ហិស្ស ទីបញ្ច បរាយនញ្ច
ន តេន មេត្តឹ ជិរយេថ បញ្ញោ ។

(៧៦៩) អលសោ គិហី កាមភោគី ន សាធុ
អសញ្ញតោ បព្វជិតោ ន សាធុ
រាជា ន សាធុ អនិសម្មការី
យោ បណ្ឌិតោ កោធនោ តំ ន សាធុ ។

(៧៧០)និសម្ម ខត្តិយោ កយិរា នានិសម្ម ទិសម្បតិ
និសម្មការិនោ រាជ យសោ កិត្តិ ច វឌ្ឍតីតិ ។

ភូរិបញ្ញជាតកំ ចុទ្ទសមំ ។



(៧៦៧) (ពោធិសត្វ...) បុគ្គលអង្គុយ ឬដេក ក្នុងម្លប់នៃឈើណា មិនត្រូវកាច់មែកនៃឈើនោះទេ ព្រោះបុគ្គលអ្នកប្រទូស្តមិត្ត ជាមនុស្សអាក្រក់ ។

(៧៦៨) បុរសដឹងច្បាស់នូវធម៌ (អំពីសំណាក់) នៃអាចារ្យណា មួយទៀត សប្បុរសទាំងឡាយណា បន្ទោបង់នូវសេចក្ដីសង្ស័យ របស់អ្នកនោះ ការដឹងនឹងការបន្ទោបង់នោះ ឈ្មោះថាជាទីពឹង ជាទីប្រព្រឹត្តទៅរបស់បុរសនោះ បុគ្គលអ្នកមានប្រាជ្ញា មិនត្រូវញ៉ាំងមេត្រីចិត្តឲ្យសាបសូន្យ អំពីអាចារ្យនោះទេ ។

(៧៦៩) គ្រហស្ថអ្នកបរិភោគកាមខ្ជិលច្រអូស មិនល្អ បព្វជិតមិនសង្រួម មិនល្អ ព្រះរាជាធ្វើការមិនពិចារណា មិនល្អ នរណាជាបណ្ឌិត ច្រើនក្រោធ សេចក្ដីក្រោធនោះ មិនល្អ ។

(៧៧០) បពិត្រព្រះអង្គជាធំក្នុងទិស ក្សត្រិយ៍គប្បីពិចារណា ហើយសឹមធ្វើ មិនគប្បីមិនបានពិចារណាហើយធ្វើទេ បពិត្រព្រះរាជា យសបរិវារក្ដី កេរ្តិ៍ឈ្មោះក្ដី រមែងចំរើនដល់ព្រះរាជាអ្នកពិចារណាហើយធ្វើ ។

ចប់ ភូរិបញ្ញជាតក ទី ១៤ ។

# មហាមង្គលជាតកំ

(៧៧១) កឹសុ នរោ ជប្បមធិច្ច កាលេ
កំ វា វិជ្ជំ កតមំ វា សុតានំ
សោ មច្ចោ អស្មឹ ច(១) បរម្ហិ លោកេ
កថំករោ សោត្ថានេន គុត្តោ ។

(៧៧២) យស្ស ទេវា បិតរោ ច សព្វេ
សរីសបា សព្វភូតានិ ចាបិ
មេត្តាយ និច្ចំ អបចិតានិ ហោន្តិ
ភូតេសុ វេ សោត្ថានំ តទាហុ ។

(៧៧៣) យោ សព្វលោកស្ស និវាតវុត្តិ
ឥត្ថីបុមានំ សហទារកានំ
ខន្តា ទុរុត្តានំ អប្បដិកូលវាទី
អធិវាសនំ សោត្ថានំ តទាហុ ។

---
១ ម. ឥ ។



# មហាមង្គលជាតក

(៧៧១) (តាបស ជាសិស្សច្បង របស់ពោធិសត្វសួរថា) ក្នុងកាល (ជាទីប្រាថ្នានូវមង្គល) នរជនសែកមន្តដូចម្តេច ការស្រឹយនូវវិជ្ជាដូចម្តេច ឬ (នូវបរិយត្តិ) នៃសុត្រទាំងឡាយ ដូចម្តេច ជននោះទើបឈ្មោះថា គ្រប់គ្រងខ្លួនដោយសួស្តី ក្នុងលោកនេះនិងលោកខាងមុខ ។

(៧៧២) (ពោធិសត្វ ពោលថា) ពួកទេវតាក្តី ពួកបិតា (ព្រហ្ម) ទាំងអស់ក្តី ពួកទីឃជាតិក្តី ពួកសត្វទាំងអស់ក្តី ដែលបុគ្គលណា កោតក្រែងដោយមេត្តាចិត្ត អស់កាលជានិច្ច បណ្ឌិតទាំងឡាយ ពោលនូវមេត្តាចិត្ត ក្នុងពួកសត្វនោះ ថាជាសួស្តីរបស់បុគ្គលនោះ ដោយពិត ។

(៧៧៣) បុគ្គលណា ប្រព្រឹត្តទន់ទាប ចំពោះសត្វលោកទាំងអស់ ជាអ្នកអត់ទ្រាំនូវពាក្យ នៃស្រីប្រុសនិងក្មេងទាំងឡាយ ដែលពោលអាក្រក់ ជាអ្នកពោលពាក្យមិនជាទីខ្ពើម បណ្ឌិតទាំងឡាយ ពោលនូវការអត់ទ្រាំនោះ ថាជាសួស្តី (របស់បុគ្គលនោះ) ។

(៧៧៤) យោ នាវជានាតិ សហាយមិត្តេ
សិប្បេន កុល្យាហិ (១) ធនេន ជច្ចា
រុចិបញ្ញោ អត្ថកាលេ មតីមា
សហាយេសុ វេ សោត្ថានំ តមាហុ ។

(៧៧៥) មិត្តានិ វេ យស្ស ភវន្តិ សន្តោ
សំវិស្សត្ថា អវិសំវាទកស្ស
ន មិត្តទុព្ភី សំវិភាគី ធនេន
មិត្តេសុ វេ សោត្ថានំ តមាហុ ។

(៧៧៦) យស្ស ភរិយា តុល្យវយា សមគ្គា
អនុព្វតា ធម្មកាមា បជាតា
កោលិនិយា សីលវតី បតិព្វតា
ទារេសុ វេ សោត្ថានំ តមាហុ ។

(៧៧៧) យស្ស រាជា ភូតបតី យសស្សី
ជានាតិ សោចេយ្យំ បរក្កមញ្ច
អទ្វេជ្ឈតា សុហទយំ មមន្តិ
រាជូសុ វេ សោត្ថានំ តមាហុ ។

១ ម. កុល្យាភិ ។



(៧៧៤) បុគ្គលណា មានប្រាជ្ញាដ៏ភ្លឺថ្លា មានបញ្ញាវាងវៃ ក្នុងកាលដែលកើតឡើងនៃហេតុ មិនមើលងាយនូវសម្លាញ់និងមិត្ត ដោយសិល្បវិជ្ជា ដោយកុលសម្បត្តិ ដោយទ្រព្យ ដោយជាតិ បណ្ឌិតទាំងឡាយ បានពោលនូវការមិនមើលងាយ ក្នុងពួកសម្លាញ់នោះ ថាជាសួស្តី (របស់បុគ្គលនោះ) ។

(៧៧៥) ពួកជនណា ជាអ្នកមិនពោលបង្វែរ ជាសប្បុរស ជាមិត្តស្និទ្ធស្នាល ជាអ្នកមិនប្រទូស្តមិត្ត ចែករំលែកដោយទ្រព្យ បណ្ឌិតទាំងឡាយ បានពោលនូវការស្និទ្ធស្នាល ក្នុងមិត្តទាំងឡាយនោះ ថាជាសួស្តី (របស់ជននោះ) ។

(៧៧៦) បុគ្គលណា មានភរិយាមានវ័យប្រហែលគ្នា មានសេចក្តីព្រមព្រៀងគ្នា ជាអ្នកប្រព្រឹត្តតាម ប្រាថ្នាធម៌ ជាស្រីមានកូន មានសីលធម៌ដោយគួរ ដល់ត្រកូល មានវត្តដល់ប្តី ពួកបណ្ឌិត បានពោលនូវបរិយាយនៃភរិយាទាំងឡាយនោះ ថាជាសួស្តី (របស់ស្វាមីនោះ) ។

(៧៧៧) ព្រះរាជាជាម្ចាស់របស់សត្វ មានយស ទ្រង់ជ្រាបនូវសេចក្តីស្អាត និងសេចក្តីព្យាយាម របស់រាជសេវកាមាត្យណាថា (សេវកាមាត្យនោះ) មិនបែកចិត្ត (អំពីអញ) ជាអ្នកមានចិត្តល្អចំពោះអញ បណ្ឌិតទាំងឡាយ បានពោលនូវសេចក្តីល្អ ក្នុងព្រះរាជាទាំងឡាយនោះ ថាជាសួស្តី (របស់រាជសេវកាមាត្យ) ។

(៧៧៨) អន្នញ្ច បានញ្ច ទទាតិ សទ្ធោ
មាលញ្ច គន្ធញ្ច វិលេបនញ្ច
បសន្នចិត្តោ អនុមោទមានោ
សគ្គេសុ វេ សោត្ថានំ តមាហុ ។

(៧៧៩) យមរិយធម្មេន បុនន្តិ វុទ្ធា
អារាធិតា សមចរិយាយ សន្តោ(១)
ពហុស្សុតា ឥសយោ សីលវន្តោ
អរហន្តមជ្ឈេ សោត្ថានំ តមាហុ ។

(៧៨០) ឯតានិ ខោ សោត្ថានានិ លោកេ
វិញ្ញុប្បសត្ថានិ សុខុទ្រយានិ
តានីធ សេវេថ នរោ សបញ្ញោ
ន ហិ មង្គលេ កិញ្ចនមត្ថិ សច្ចំ ។

មហាមង្គលជាតកំ បញ្ចមំ ។

១ ម. វុទ្ធា ។



(៧៧៨) បុគ្គលណា មានសទ្ធា មានចិត្តជ្រះថ្លា ត្រេកអរ ឲ្យបាយ ទឹក ផ្កាកម្រង គ្រឿងក្រអូប និងគ្រឿងលាប បណ្ឌិតទាំងឡាយ បានពោលនូវសេចក្ដីល្អនោះ ថាជាសួស្ដី ក្នុងឋានសួគ៌ទាំងឡាយ (របស់បុគ្គលនោះ) ។

(៧៧៩) ពួកបុគ្គលណា ដ៏ចំណាស់ដោយញាណ រមែងញ៉ាំងបុគ្គលណាឲ្យស្អាត ដោយអរិយធម៌ ជាអ្នកត្រេកអរក្នុងការប្រព្រឹត្តល្អ ជាអ្នករៀនសូត្រច្រើន ជាអ្នកស្វែងរកគុណ ជាអ្នកមានសីល បណ្ឌិតទាំងឡាយ បានពោលនូវសេចក្ដីល្អ ក្នុងកណ្ដាលនៃព្រះអរហន្តនោះ ថាជាសួស្ដី (របស់បុគ្គលនោះ) ។

(៧៨០) សួស្ដីមង្គលទាំងឡាយនេះឯង វិញ្ញូជនតែងសរសើរ មានសេចក្ដីសុខជាកម្រៃ ក្នុងលោក នរជនអ្នកប្រកបដោយប្រាជ្ញា ក្នុងលោកនេះ គប្បីសេពគប់នូវសួស្ដីមង្គលទាំងឡាយនោះ វត្ថុណាមួយ ក្នុងមង្គល (មានទិដ្ឋមង្គលជាដើម) មិនឈ្មោះថាជាសច្ចៈទេ ។

ចប់ មហាមង្គលជាតក ទី ៥ ។

## ឃដបណ្ឌិតជាតកំ(១)

(៧៨១) ឧដ្ឋេហិ កណ្ហ កឹ សេសិ កោ អត្ថោ សុបនេន តេ

យោបិ តុយ្ហំ សកោ ភាតា ហទយំ ចក្ខុ ច ទក្ខិណំ

តស្ស វាតា ពលីយន្តិ ឃដោ ជប្បតិ កេសវ ។

(៧៨២) តស្ស តំ វចនំ សុត្វា រោហិណេយ្យស្ស កេសវោ

តរមានរូបោ វុដ្ឋាសិ ភាតុ សោកេន អដ្ដិតោ ។

(៧៨៣) កិន្នុ ឧម្មត្តរូបោវ កេវលំ ទ្វារកំ(២) ឥមំ

សសោ សសោតិ លបសិ កោ នុ តេ សសមាហរិ ។

---

● ១ ឃដជាតកំ ។ ២ [illegible] ។



## ឃដបណ្ឌិតជាតក

(៧៨១) (អាមាត្យឈ្មោះរោហិណេយ្យ ពោលថា) បពិត្រព្រះអង្គជាកណ្ហាយនគោត្រ សូមព្រះអង្គក្រោកឡើង ព្រះអង្គនៅផ្ទំធ្វើអ្វី ប្រយោជន៍អ្វីរបស់ព្រះអង្គ ដោយការផ្ទំ ក្សត្រិយ៍ណា ជាព្រះកនិដ្ឋាភាតារបស់ព្រះអង្គ (ស្មើដោយ) ហឫទ័យ និងព្រះនេត្រខាងស្តាំ ខ្យល់ចាប់ផ្តើមគ្របហឫទ័យរបស់ក្សត្រិយ៍ ជាព្រះកនិដ្ឋាភាតានោះ បពិត្រព្រះកេសវៈ ឃដបណ្ឌិត រមែងនិយាយនាំថា (អ្នកទាំងឡាយ ចូរឲ្យទន្សាយដល់យើង) ។

(៧៨២) (ព្រះសាស្តាត្រាស់ថា) ព្រះបាទកេសវៈ ទ្រង់ព្រះសណ្តាប់ពាក្យរបស់អាមាត្យឈ្មោះរោហិណេយ្យនោះហើយ ក៏ទ្រង់ក្រោកឡើង រលះរលាំង ត្រូវសេចក្តីសោកគឺព្រះកនិដ្ឋាភាតាគ្របសង្កត់ ។

(៧៨៣) (ព្រះបាទកេសវៈ សួរថា) អ្នកហេតុអ្វី ក៏មានសភាព ហាក់ដូចជាឆ្កួត (ត្រាច់ទៅ) កាន់នគរទ្វារវតីទាំងមូលនេះ និយាយរឿយៗថា ទន្សាយ ៗ អ្នកណាលួចយកទន្សាយ របស់អ្នកទៅឬ ។

(៧៨៤) សោវណ្ណមយំ មណិមយំ (លោហមយំ) អថ រូបិយមយំ

សង្ខសិលាបវាឡមយំ ការយិស្សាមិ តេ សសំ ។

សន្តិ អញ្ញេបិ សសកា អរញ្ញវនគោចរា

តេបិ តេ អានយិស្សាមិ កីទិសំ សសមិច្ឆសិ ។

(៧៨៥) ន ចាហមេតេ ឥច្ឆាមិ យេ សសា បឋវិស្សិតា

ចន្ទតោ សសមិច្ឆាមិ តម្មេ ឱហរ កេសវ ។

(៧៨៦) សោ នូន មធុរំ ញាតិ ជីវិតំ វិជហិស្សសិ

អបត្ថិយំ យោ បត្ថយសិ ចន្ទតោ សសមិច្ឆសិ ។



(៧៨៤) អ្នកប្រាថ្នា នូវទន្សាយមាស កែវមណី (លោហៈ) ឬប្រាក់ ឬក៏ទន្សាយធ្វើដោយស័ង្ខ ដោយសិលា ដោយកែវប្រពាឡ យើងនឹងឲ្យគេធ្វើទន្សាយនោះដល់អ្នក ។ (បើអ្នកមិនពេញចិត្តទន្សាយនោះទេ) ទន្សាយឯទៀតក្នុងព្រៃ គេស៊ីក្នុងព្រៃ យើងនឹងឲ្យគេនាំទន្សាយទាំងនោះមកឲ្យអ្នក អ្នកត្រូវការទន្សាយបែបណា (ចូរប្រាប់យើងក្នុងកាលឥឡូវនេះ) ។

(៧៨៥) (ឃដបណ្ឌិតឆ្លើយថា) ពួកទន្សាយណា ដែលអាស្រ័យនៅលើផែនដី ខ្ញុំមិនចង់បានទន្សាយនោះទេ ខ្ញុំចង់បានទន្សាយអំពីដួងព្រះចន្ទ្រ បពិត្រព្រះកេសវៈ សូមព្រះអង្គញ៉ាំងទន្សាយនោះឲ្យចុះមក ដើម្បីខ្ញុំ ។

(៧៨៦) (ព្រះបាទកេសវៈ...) អ្នកណាប្រាថ្នានូវរបស់ ដែលមិនគួរប្រាថ្នា (ដូចជា) អ្នកប្រាថ្នានូវទន្សាយ អំពីដួងព្រះចន្ទ្រ ម្នាលអ្នកជាញាតិ អ្នកនោះនឹងលះបង់ជីវិត ជាទីស្រឡាញ់ ដោយពិត (តែមិនបានទន្សាយនោះទេ) ។

[៧៨៧] ឯវញ្ចេ កណ្ហ ជានាសិ យថញ្ញមនុសាសសិ
កស្មា បុរេ មតំ បុត្តំ អជ្ជាបិ អនុសោចសិ ។

[៧៨៨] យំ ន លព្ភា មនុស្សេន អមនុស្សេន វា បុន
ជាតោ មេ មា មរី បុត្តោ កុតោ លព្ភា អលព្ភិយំ ។

ន មន្តា មូលភេសជ្ជា ឱសធេហិ ធនេន វា
សក្កា អានយិតុំ កណ្ហ យំ បេតមនុសោចសិ ។



(៧៨៧) (ឃដបណ្ឌិត...) បពិត្រព្រះកណ្ហាយនគោត្រ បើព្រះអង្គទ្រង់ជ្រាប យ៉ាងនោះ ព្រះអង្គទ្រង់ប្រៀនប្រដៅបុគ្គលដទៃ ហេតុអ្វី ព្រះអង្គសោកស្តាយ នឹងបុត្រដែលទទួលមរណភាព ក្នុងកាលមុន រហូតមក ក្នុងថ្ងៃនេះ ។

(៧៨៨) របស់ណា ដែលមនុស្ស ឬអមនុស្ស មិនគប្បីបានវិញ ដោយប្រាថ្នាថា (ព្រះអង្គប្រាថ្នានូវរបស់នោះថា) បុត្ររបស់អញ កើតហើយកុំស្លាប់ឡើយ ដូច្នេះ ព្រះអង្គនឹងគប្បីបានរបស់ ដែលមិនគប្បីបាន អំពីទីណាកើត ។ បពិត្រព្រះកណ្ហាយនគោត្រ ព្រះអង្គសោកស្តាយនឹងបុត្រណា ដែលទៅកាន់បរលោកហើយ ព្រះអង្គអាចនាំបុត្រនោះមកវិញ ដោយមន្ត ដោយថ្នាំដែលធ្វើដោយឫសឈើ ដោយឱសថ ឬក៏ដោយទ្រព្យ មិនបានឡើយ ។

(៧៨៩)យស្ស ឯតាទិសា អស្សុ អមច្ចា បុរិសបណ្ឌិតា
យថា និជ្ឈាបយេ អជ្ជ ឃដោ បុរិសបណ្ឌិតោ ។
អាទិត្តំ វត មំ សន្តំ ឃតសិត្តំវ បាវកំ
វារិនា វិយ ឱសិញ្ចំ សព្វំ និព្វាបយេ ទរំ ។
អព្វហិ វត មេ សល្លំ យមាសិ ហទយស្សិតំ
យោ មេ សោកបរេតស្ស បុត្តសោកំ អបានុទិ ។
សោហំ អព្វូឡ្ហសល្លោស្មិ វីតសោកោ អនាវិលោ
ន សោចាមិ ន រោទាមិ តវ សុត្វាន មាណវ ។
(៧៩០)ឯវំ ករោន្តិ សប្បញ្ញា យេ ហោន្តិ អនុកម្បកា
និវត្តយន្តិ សោកម្ហា ឃដោ ជេដ្ឋំវ ភាតរំ ។

ឃដបណ្ឌិតជាតកំ សោឡសមំ ។



(៧៨៩) (ព្រះបាទវាសុទេវៈ សរសើរថា) ពួកបុរសជាបណ្ឌិតប្រាកដដូច្នេះ ជាអាមាត្យរបស់ព្រះរាជាណា ដូចយ៉ាងអ្នក ជាបណ្ឌិត-បុរស ឈ្មោះឃដៈ បានពន្យល់ (ខ្ញុំ) ក្នុងថ្ងៃនេះ (សោករបស់ព្រះរាជានោះ ចិនមានមកពីណា) ។ អ្នកបានស្រោចស្រពនូវយើង ដែលភ្លើងគឺសេចក្តីសោកកំពុងឆេះ ឲ្យស្ងប់រម្ងាប់ ញុំាងសេចក្តីក្រ-វល់ក្រវាយទាំងអស់ឲ្យរលត់ ដូចបុគ្គលយកទឹកស្រោច នូវភ្លើងកំពុងឆេះឆៅនឹងខ្លាញ់ ។ សរគឺសេចក្តីសោកណា ដែលអាស្រ័យក្នុងហឫទ័យ សរ គឺសេចក្តីសោកនោះ យើងបានដកចេញហើយ អ្នកឈ្មោះឃដ បានបន្ទោបង់នូវសេចក្តីសោកព្រោះបុត្ត របស់យើង ដែលត្រូវសេចក្តីសោកគ្របសង្កត់ ។ ម្នាលមាណព យើងនោះ ជាអ្នកមានសរ គឺសេចក្តីសោក ដកចេញហើយ ជាអ្នកប្រាសចាកសេចក្តីសោក ម្នាលមាណព យើងលែងសោកស្តាយ លែងយំទួញ ព្រោះបានស្តាប់នូវពាក្យ របស់អ្នក ។

(៧៩០) (ព្រះសម្ពុទ្ធត្រាស់ថា) ពួកជនណា ប្រកបដោយប្រាជ្ញា ជាអ្នកអនុគ្រោះ រមែងធ្វើយ៉ាងនេះ រមែងញុំាងជនឲ្យឃ្លាតចាកសេចក្តីសោក ដូចឃដបណ្ឌិត ញុំាងព្រះជេដ្ឋា (ឲ្យរួចចាកសេចក្តីសោក)។

ចប់ ឃដបណ្ឌិតជាតក ទី ១៦ ។

## តស្សុទ្ទានំ

ទឡ្ហ កណ្ហ ធនញ្ជយ សង្ខវរោ

រាជា សត្តាហ សសាម តក្កលិកា

ធម្ម កុក្កុដ កុណ្ឌលិ ភោជនា

ចក្កវាក សុភូរិ សមង្គលិ ឃដោ ។

ទសកនិបាតំ និដ្ឋិតំ ។

---



## ឧទ្ទាននៃជាតកនោះគឺ

និយាយអំពីកំពែងនៃនគរដើមមុន ១ កណ្ហតាបស ១ ស្តេចធនញ្ជ័យ ១ សង្ខព្រាហ្មណ៍ ១ ព្រះរាជាកាកណស ១ តាបសជ្រះថ្លា ចាំពោះព្រហ្មចរិយធម៌ អស់៧ថ្ងៃ ១ សាមកុមារ ១ តក្កលជាតក ១ មហាធម្មបាលជាតក ១ កុក្កុដជាតក ១ មដ្ឋកុណ្ឌលិជាតក ១ អ្នកឲ្យខ្ញុំភោជន ១ ចក្កវាកជាតក ១ ភូរិបញ្ហាជាតក ១ ប្រកបដោយសេចក្តីសួស្តី ១ ឃដបណ្ឌិតជាតក ១ ។

ចប់ ទសកនិបាត ។

---

# ឯកាទសកនិបាតជាតកំ

## មាតុបោសកជាតកំ(១)

(៧៩១) តស្ស នាគស្ស វិប្បវាសេន
វិរូឡ្ហា សល្លកិយោ ច កុដជា
កុរុវិន្ទករវីរា ភិសសាមា ច
និវាតេ បុប្ផិតា ច កណ្ណិការា ។

(៧៩២) កោចិទេវ សុវណ្ណកាយុរា
នាគរាជំ ភរន្តិ បិណ្ឌេន
យត្ថ រាជា រាជកុមារោ វា
កវចមភិហេស្សតិ អសម្ភិតោ ។

(៧៩៣) គណ្ហាហិ នាគ កពឡំ មា នាគ កិសកោ អហុ
ពហូនិ រាជកិច្ចានិ តានិ នាគ ករិស្សសិ ។

(៧៩៤) សា នូន សា កបណិកា អន្ធា អបរិណាយិកា
ខាណុំ បាទេន ឃដ្ដេតិ គិរឹ ចណ្ឌោរណំ បតិ ។

១ ឱ. មាតិបោសកជាតកំ ។

# ឯកាទសកនិបាតជាតក

## មាតុបោសកជាតក

(៧៩១) (ដំរីជាមាតារបស់ព្រះពោធិសត្វ ពោលថា) ដើមពោធស្លាធំ
ដើមខ្ទឹងនិងដើម ដើមខ្ទឹមនិងស្មៅដំណេក ឈ្មោះករវីរៈធំ ក្រអៅឈូក
និងស្រងែធំ ដុះត្រួយត្រួសហើយ ទាំងដើមកណ្ណិការដែលដុះក្នុង
ទីបញ្ចាំងខ្យល់ ក៏រីកបញ្ចេញផ្កាដែរ ព្រោះតែដំរីនោះមិននៅ ។

(៧៩២) ពួកស្រុក ឬពួកក្រុងណាមួយ ព្រះរាជា ឬព្រះរាជកុមារណាមួយ
មានគ្រឿងអាភរណៈជាវិការៈនៃមាស រមែងចិញ្ចឹមស្តេចដំរី ដោយ
ដុំនៃភោជន ផ្សិតដំរីដែលព្រះរាជា ឬព្រះរាជកុមារ (គង់ហើយ)
មិនតក់ស្លុត (ក្នុងសង្គ្រាម) អាចនឹងទំលុះទំលាយនូវក្រោះ (នៃ
ពួកបច្ចាមិត្រផង) ។

(៧៩៣) (ព្រះរាជា...) ម្នាលដំរី អ្នកចូរទទួលដុំនូវភោជនចុះ ម្នាល
ដំរី អ្នកកុំស្គមឡើយ ម្នាលដំរី រាជកិច្ចទាំងឡាយ មានច្រើន អ្នក
នឹងធ្វើនូវរាជកិច្ចទាំងនោះ ។

(៧៩៤) (ព្រះពោធិសត្វ...) មេដំរីនោះជាសត្វកំព្រា ខ្វាក់ភ្នែក មិន
មានអ្នកដឹកនាំ ទង្គិចជើងនឹងគល់ឈើ ហើយបែរមុខទៅរកភ្នំ
ចណ្ឌោរណៈ ដួលទៅ ។

(៧៩៤)កានុ តេ សា មហានាគ អន្ធា អបរិណាយិកា
ខាណុំ បាទេន ឃដ្ដេតិ គិរិំ ចណ្ឌោរណំ បតិ ។
(៧៩៥)មាតា មេ សា មហារាជ អន្ធា អបរិណាយិកា
ខាណុំ បាទេន ឃដ្ដេតិ គិរិំ ចណ្ឌោរណំ បតិ ។
(៧៩៦)មុញ្ចេថេតំ មហានាគំ យោយំ ភរតិ មាតរំ
សមេតុ មាតរា នាគោ សហ សព្វេហិ ញាតិភិ ។
(៧៩៧)មុត្តោវ ពន្ធនា នាគោ កាសិករាជេន បេសិតោ(១)
មុហុត្តំ អស្សសិត្វាន(២) អគមា យេន បព្វតោ
តតោ សោ នឡិនឹ(៣) គន្ត្វា សីតំ កុញ្ជរសេវិតំ
សោណ្ឌាយ ឧទកមាហិត្វា មាតរំ អភិសិញ្ចថ ។
(៧៩៨)កោយំ អនរិយោ ទេវោ អកាលេន បវស្សតិ
គតោ មេ អត្រជោ បុត្តោ យោ មយ្ហំ បរិចារកោ ។

១ ឱ. មុត្តោ ទាមតោ កុញ្ជរោ ។ ម. ឧត្តមនាគ កុញ្ជរោ ។ ២ ម. អស្សាសយិត្វា ។
៣ ឱ. ម. នឡិនឹ ។



(៧៩៤) (ព្រះរាជា..) ម្នាលដំរីដ៏ប្រសើរ មេដំរី ខ្វាក់ភ្នែក មិនមាន
អ្នកដឹកនាំ ទន្គិចជើងនឹងគល់ឈើ ដែលមុខទៅរកភ្នំចណ្ឌោរណៈ
ដួលនៅនោះ តើត្រូវជាអ្វីនឹងអ្នកឯង ។
(៧៩៥) (ព្រះពោធិសត្វ...) បពិត្រមហារាជ មេដំរីខ្វាក់ភ្នែក មិនមាន
អ្នកដឹកនាំ ទន្គិចជើងនឹងគល់ឈើ ដែលមុខទៅរកភ្នំចណ្ឌោរណៈ
ដួលនៅនោះ ត្រូវជាមាតារបស់ខ្ញុំព្រះបង្គំជាខ្ញុំ ។
(៧៩៦) (ព្រះរាជា...) អ្នកទាំងឡាយចូរលែង នូវដំរីដ៏ប្រសើរនុ៎ះ ជា
សត្វចិញ្ចឹមនូវមាតា ចូរឲ្យដំរីបានជួបជុំនឹងមាតា ព្រមទាំងញាតិ
ទាំងពួងចុះ ។
(៧៩៧) (អភិសម្ពុទ្ធគាថា) ដំរីត្រូវគេដោះលែងចាកចំណង ដែលព្រះរាជា
កាសីបានបញ្ជូនទៅ សម្រាកខ្លួនតែមួយរំពេច ក៏ដើរសំដៅទៅ
រកភ្នំ ដំរីនោះចេញទៅអំពីភ្នំនោះ ដើរទៅកាន់ស្រះជាទីពួនសម្ងំ
ដ៏ត្រជាក់ ដែលដំរីធ្លាប់សេព (នៅ) ហើយដងទឹកដោយប្រមោយ
យកមកស្រោចស្រពមាតា ។
(៧៩៨) (មាតាពោធិសត្វ..) ភ្លៀងអ្វីហ្នឹងធ្លាក់សព្វទិសចុះ ក៏ខុស
កាលសោះ កូនប្រុសរបស់អញ ដែលជាអ្នកបម្រើអញទៅបាត់
ហើយតើ ។

(៨០០) ឧដ្ឋេហិ អម្ម កិំ សេសិ អាគតោ ត្យាហមត្រជោ
មុត្តោម្ហិ កាសិរាជេន វេទេហេន យសស្សិនា ។
(៨០១) ចិរំ ជីវតុ សោ រាជា កាសីនំ រដ្ឋវឌ្ឍនោ
យោ មេ បុត្តំ បមោចេសិ សទា វុឌ្ឍាបចាយិកំ ។

មាតុបោសកជាតកំ ចប់ ។

## ជុណ្ហជាតកំ

(៨០២) សុណោហិ មយ្ហំ វចនំ ជនិន្ទ
អត្ថេន ជុណ្ហម្ហិ ឥធានុបត្តោ
ន ព្រាហ្មណេ អទ្ធិកេ តិដ្ឋមានេ
គន្តព្វមាហុ ទ្វិបទិន្ទ សេដ្ឋ[១] ។

១ ឱ. ទិបទានសេដ្ឋ ។ ម. ទ្វិបទិន្ទ សេដ្ឋ ។



(៨០០) (ពោធិសត្វ...) បពិត្រម្តាយ សូមម្តាយក្រោកឡើង សម្រាន្តអ្វី ខ្ញុំជាកូនបង្កើតរបស់ម្តាយ ដែលព្រះរាជាកាសី ទ្រង់ប្រកបដោយប្រាជ្ញា មានយស បានលែងមកវិញហើយ ។
(៨០១) (មាតាពោធិសត្វ...) ព្រះរាជាណា បានលែងកូន របស់ខ្ញុំ ជាអ្នកកោតក្រែង ចំពោះបុគ្គលចាស់សព្វ ៗ កាល សូមព្រះរាជានោះ ញុំាងដែនរបស់ពួកអ្នកកាសីឲ្យចំរើន គង់ព្រះជន្មនៅអស់កាលយូរអង្វែងចុះ ។

ចប់ មាតុបោសកជាតក ទី ១ ។

## ជុណ្ហជាតក

(៨០២) (ព្រាហ្មណ៍បានពោលថា) បពិត្រព្រះអង្គជាធំជាងជន សូមព្រះអង្គស្តាប់ពាក្យរបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គមកក្នុងទីនេះ ដោយសេចក្តីត្រូវការចំពោះព្រះអង្គ ទ្រង់ព្រះនាមជុណ្ហៈ បពិត្រព្រះអង្គប្រសើរបំផុត ជាងពួកសត្វជើងពីរ បណ្ឌិតទាំងឡាយពោលថា កាលព្រាហ្មណ៍ ជាអ្នកដំណើរ កំពុងឈរ (សូម) បុគ្គលមិនត្រូវដើរ (ហួស)ទេ ។

(៨០៣) សុណោមិ តិដ្ឋាមិ វទេហិ ព្រហ្មេ
យេនាបិ អត្ថេន ឥធានុបត្តោ
កំ វា ត្វមត្ថំ មយិ បត្ថយានោ
ឥធាគមា ព្រហ្មេ តទិង្ឃ ព្រូហិ ។

(៨០៤) ទទាហិ មេ គាមវរានិ បញ្ច
ទាសីសតំ សត្ត គវំសតានិ
បរោសហស្សញ្ច សុវណ្ណនិក្ខេ
ភរិយា ច មេ សាទិសី ទ្វេ ទទាហិ ។

(៨០៥) តបោ នុ តេ ព្រាហ្មណ កិំសរូបោ
មន្តា នុ តេ ព្រាហ្មណ ចិត្តរូបា
យក្ខា នុ តេ អស្សវា សន្តិ កេចិ
អត្ថំ វា មេ អភិជានាសិ កត្តំ ។

(៨០៦) ន មេ តបោ អត្ថិ ន ចាបិ មន្តា
យក្ខាបិ មេ អស្សវា នត្ថិ កេចិ
អត្ថម្បិ តេ នាភិជានាមិ កត្តំ
បុព្វេ ច ខោ សង្គតិមត្តមាសិ ។



(៨០៣) (ព្រះរាជាទ្រង់ត្រាស់ថា) ម្នាលព្រាហ្មណ៍ យើងឮ យើងឈប់នៅ អ្នកចូរនិយាយចុះ អ្នកមកក្នុងទីនេះ ដោយប្រយោជន៍ណា ឬប្រាថ្នានូវប្រយោជន៍អ្វី ចំពោះយើង ទើបមកក្នុងទីនេះ ម្នាលព្រាហ្មណ៍ អ្នកចូរប្រាប់នូវប្រយោជន៍នោះចុះ ។

(៨០៤) (ព្រាហ្មណ៍...) សូមព្រះអង្គប្រទានស្រុកសួយ ៥ ទាសី ១០០ គោ ៧០០ និងមាសនិក្ខជាង ១០០ ដល់ខ្ញុំព្រះបង្គំ សូមប្រទានភរិយា ២ នាក់មានរូបសណ្ឋានដូចគ្នា ដល់ខ្ញុំព្រះបង្គំផង ។

(៨០៥) (ព្រះរាជា...) ម្នាលព្រាហ្មណ៍ តើអ្នកមានតបៈដ៏ខ្លាំងដែរឬ ម្នាលព្រាហ្មណ៍ តើអ្នកមានមន្តទាំងឡាយ មានសភាពដ៏វិចិត្រដែរឬ តើអ្នកមានពួកយក្ស ជាអ្នកស្ដាប់ដែរឬ ម្យ៉ាងទៀត អ្នកដឹងច្បាស់នូវប្រយោជន៍ ដែលអ្នកធ្វើហើយ ចំពោះយើងឬ ។

(៨០៦) (ព្រាហ្មណ៍...) ខ្ញុំព្រះបង្គំ មិនមានតបៈ មិនមានមន្តទេ ខ្ញុំព្រះបង្គំ មិនមានពួកយក្ស ជាអ្នកស្ដាប់ទេ ខ្ញុំព្រះបង្គំ មិនដឹងច្បាស់នូវប្រយោជន៍ ដែលខ្ញុំព្រះបង្គំធ្វើហើយ ចំពោះព្រះអង្គទេ ក្នុងកាលមុន (ខ្ញុំព្រះបង្គំនិងព្រះអង្គ) គ្រាន់តែបានជួបគ្នាប៉ុណ្ណោះ ។

(៨០៧) បឋមំ ឥទំ ទស្សនំ ជានតោ មេ
ន តាភិជានាមិ ឥតោ បុរត្ថា
អក្ខាហិ មេ បុច្ឆិតោ ឯតមត្ថំ
កទា កុហឹ វា អហុ សង្គមោ នោ ។

(៨០៨) គន្ធាររាជស្ស បុរម្ហិ រម្មេ
អវសិម្ហសេ តក្កសិលាយ ទេវ
តត្ថន្ធការម្ហិ តិមិស្សកាយំ
អំសេន អំសំ សមឃដ្ដយិម្ហា
តេ តត្ថ ឋត្វាន ឧភោ ជនិន្ទ
សាខល្យំ វីតិសារម្ហ តត្ថ
សាយេវ នោ សង្គតិមត្តមាសិ
តតោ ន បច្ឆា ន បុរេ អហោសិ(១) ។

(៨០៩) យទា កទាចិ មនុជេសុ ព្រហ្មេ
សមាគមោ សប្បុរិសេន ហោតិ
ន បណ្ឌិតា សង្គតិសន្ថវានិ
បុព្វេ កតំ វាបិ វិនាសយន្តិ ។

១ ម. អហោសិ ។



(៨០៧) (ព្រះរាជា ..) តាមទំនង នេះជាការឃើញដំបូង យើងមិនស្គាល់អ្នកមុន អំពីកាលនេះទេ យើងសួរហើយ អ្នកចូរប្រាប់សេចក្តីនុ៎ះ យើងបានចួបគ្នា ក្នុងកាលណា ឬក្នុងទីណា ។

(៨០៨) (ព្រាហ្មណ៍...) បពិត្រព្រះសម្មតិទេព ពួកយើងនៅក្នុងក្រុងតក្កសិលា ជាបុរីគួរឲ្យត្រេកអរ របស់ស្តេចគន្ធារៈ ក្នុងទីនោះ ពួកយើងទាំង ២ បានបង្អឹតស្មានឹងស្មា ក្នុងទីងងឹត ក្នុងព្រៃមានអន្ធការក្រាស បពិត្រព្រះអង្គជាធំជាងជន យើងទាំងពីរនាក់នោះ ឈរក្នុងទីនោះ បានបញ្ចប់ពាក្យគួរឲ្យរឭក ក្នុងទីនោះ នោះឯងឈ្មោះថា ការចួបគ្នានៃយើងទាំង ២ (ឯការចួបគ្នា) ខាងក្រោយ ទាំងខាងមុខ អំពីកាលនោះ មិនមានឡើយ ។

(៨០៩) (ព្រះរាជា...) ម្នាលព្រាហ្មណ៍ ការចួបនឹងសប្បុរស ក្នុងពួកមនុស្ស ក្នុងកាលណា ពួកបណ្ឌិត មិនដែលបំបាត់ការចួបនឹងសេចក្តីស្និទ្ធស្នាល ឬគុណដែលគេធ្វើហើយ ក្នុងកាលមុនទេ ។

(៨១០) ពាលា ច ខោ សង្គតិសន្ថវានិ
បុព្វេ កតំ ភវិ វិនាសយន្តិ
ពហុំបិ ពាលេសុ កតំ វិនស្សតិ
តថា ហិ ពាលា អកតញ្ញុរូបា ។

(៨១១) ធីរា ច ខោ សង្គតិសន្ថវានិ
បុព្វេ កតំ ភវិ ន នាសយន្តិ
អប្បំបិ ធីរេសុ កតំ ន នស្សតិ
តថា ហិ ធីរា សុកតញ្ញុរូបា
ទទាមិ តេ គាមវរានិ បញ្ច
ទាសីសតំ សត្ត គវំសតានិ
បរោសហស្សញ្ច សុវណ្ណនិក្ខេ
ភរិយា ច តេ សាទិសី ទ្វេ ទទាមិ ។

(៨១២) ឯវំ សតំ ហោតិ សមេច្ច រាជ
នក្ខត្តរាជារិវ តារកានំ
អាបូរតិ កាសិបតី យថា អហំ
តយា ហិ មេ សង្គមោ អជ្ជ លទ្ធោតិ ។

ជុណ្ហជាតកំ ទុតិយំ ។



(៨១០) ចំណែកខាងពួកពាល តែងបំផ្លាញការជួបនឹងសេចក្តីស្និទ្ធស្នាល ឬគុណដែលគេធ្វើហើយក្នុងកាលមុន គុណសូម្បីច្រើន ដែលគេធ្វើហើយ ចំពោះពួកពាល រមែងបាត់ទៅ ពិតដូច្នោះមែន ពួកពាលមានសភាព ជាមនុស្សអកតញ្ញូ ។

(៨១១) ចំណែកខាងពួកបណ្ឌិត មិនបំផ្លាញការជួបនឹងសេចក្តីស្និទ្ធស្នាល ឬគុណដែលគេធ្វើហើយ ក្នុងកាលមុនទេ គុណសូម្បីតិចដែលគេធ្វើហើយ ចំពោះពួកបណ្ឌិត រមែងមិនបាត់ ពិតដូច្នោះមែន ពួកបណ្ឌិតមានសភាព ជាមនុស្សកតញ្ញូ យើងនឹងឲ្យស្រុកសួយ ៥ ទាសី ១០០ នាក់ គោ ៧០០ មាសក្តោរជាង ១០០០ ដល់អ្នក ម្យ៉ាង-ទៀត យើងនឹងឲ្យភរិយាពីរដែលមានរូបសណ្ឋានដូចគ្នា ដល់អ្នក ។

(៨១២) (ព្រាហ្មណ៍...) បពិត្រព្រះរាជា ការជួបជុំសប្បុរស តែងមានយ៉ាងនេះ បពិត្រព្រះអង្គជាម្ចាស់នៃដែនកាសី ដូចយ៉ាង (ព្រះចន្ទ្រ ឋិតនៅក្នុងកណ្តាល) នៃពួកផ្កាយ រមែងពេញឡើងយ៉ាងណាមិញ ខ្ញុំព្រះបង្គំជាខ្ញុំ (ពេញព្រៀបដោយស្រុកសួយជាដើម ដែលព្រះអង្គប្រទានក្នុងថ្ងៃនេះ ក៏យ៉ាងនោះដែរ) ព្រោះការជួបនឹងព្រះអង្គខ្ញុំបានហើយក្នុងថ្ងៃនេះ ។

ចប់ ជុណ្ហជាតក ទី ២ ។

# ធម្មទេវបុត្តជាតកំ (១)

(៨១៣) យសោករោ បុញ្ញករោហមស្មិ
សទត្ថុតោ សមណព្រាហ្មណានំ
មគ្គារហោ ទេវមនុស្សបូជិតោ
ធម្មោ អហំ ទេហិ អធម្ម មគ្គំ ។

(៨១៤) អធម្មយានំ ទឡ្ហមារុហិត្វា
អសន្តសន្តោ ពលវាហមស្មិ
ស កិស្ស ហេតុម្ហិ តវជ្ជ ទជ្ជំ
មគ្គំ អហំ ធម្ម អទិន្នបុព្វំ ។

(៨១៥) ធម្មោ ហវេ បាតុរហោសិ បុព្វេ
បច្ឆា អធម្មោ ឧទបាទិ លោកេ
ជេដ្ឋោ ច សេដ្ឋោ ច សនន្តនោ ច
ឧយ្យាហិ ជេដ្ឋស្ស កនិដ្ឋ មគ្គា ។

---

១ ម. ធម្មជាតកំ ។



# ធម្មទេវបុត្តជាតក

(៨១៣) (ធម្មទេវបុត្រ ពោលថា) ម្នាលអធម្មទេវបុត្រ ខ្ញុំឈ្មោះធម្មៈ ជាអ្នកធ្វើយស ធ្វើបុណ្យ ខ្ញុំដែលពួកសមណព្រាហ្មណ៍ សរសើរជានិច្ច ដែលទេវតានិងមនុស្សបូជាហើយ គួរបានផ្លូវ អ្នកចូរឲ្យផ្លូវ ។

(៨១៤) (អធម្មទេវបុត្រ ពោលថា) ម្នាលធម្មៈ ខ្ញុំជិះរថ ឈ្មោះអធម្មយានដ៏មាំ ជាអ្នកមិនតក់ស្លុត មានកម្លាំង ខ្ញុំនោះនឹងឲ្យផ្លូវដល់អ្នក ដែលមិនធ្លាប់ឲ្យហើយ ក្នុងថ្ងៃនេះ ព្រោះហេតុអ្វី ។

(៨១៥) (ធម្មទេវបុត្រ...) ធម៌បានកើតមុន អធម៌កើតក្រោយក្នុងលោក ខ្ញុំជាច្បងផង ប្រសើរជាងផង មានតាំងពីព្រេងនាយផង ម្នាលប្អូន អ្នកចូរចៀសចេញ អំពីផ្លូវរបស់បង ។

(៨១៦) ន យាចនាយ នបិ បាតិរូបា
ន អរហតា តេហំ ទទេយ្យ មគ្គំ
យុទ្ធញ្ច នោ ហោតុ ឧភិន្នមជ្ជ
យុទ្ធស្មិំ យោ ជិស្សតិ តស្ស មគ្គោ ។

(៨១៧) សព្វា ទិសា អនុវិស្សុតោហមស្មិ
មហព្វលោ អមិតយសោ អតុល្យោ
គុណេហិ សព្វេហិ ឧបេតរូបោ
ធម្មោ អធម្ម ត្វំ កថំ វិជេស្សសិ ។

(៨១៨) លោហេន វេ ហញ្ញតិ ជាតរូបំ
ន ជាតរូបេន ហនន្តិ លោហំ
សចេ អធម្មោ ហញ្ញតិ ធម្មមជ្ជ
អយោ សុវណ្ណំ វិយ ទស្សនេយ្យំ ។

(៨១៩) សចេ តុវំ យុទ្ធពលោ អធម្ម
ន តុយ្ហ វុឌ្ឍា ច គរូ ច អត្ថិ
មគ្គញ្ច តេ ទម្មិ បិយាប្បិយេន
វាចាទុរុត្តានិបិ តេ ខមាមិ ។



(៨១៦) (អធម្មទេវបុត្រ...) ខ្ញុំមិនត្រូវឲ្យផ្លូវដល់អ្នក ដោយសេចក្តីអង្វរ មិនត្រូវឲ្យ ដោយពាក្យសមគួរ មិនត្រូវឲ្យ ព្រោះខ្ញុំគួរបានផ្លូវ យើងទាំងពីរនាក់ ចូរច្បាំងគ្នា ក្នុងថ្ងៃនេះ អ្នកណាឈ្នះក្នុងចម្បាំង ផ្លូវជារបស់អ្នកនោះ ។

(៨១៧) (ធម្មទេវបុត្រ...) ម្នាលអធម្មៈ ខ្ញុំឈ្មោះធម្មៈ ជាអ្នកល្បីល្បាញសព្វទិស មានកំឡាំងច្រើន មានយសរាប់មិនអស់ មិនមានអ្នកណាផ្ទឹមបាន មានសភាពជាអ្នកប្រកប ដោយគុណគ្រប់យ៉ាង អ្នកចំនឹងឈ្នះ (ខ្ញុំ) ដូចម្តេចបាន ។

(៨១៨) (អធម្មទេវបុត្រ...) គេតែងដំមាសដោយដែក គេមិនដែលដំ-ដែកដោយមាសទេ បើអធម្មៈ ដំ ធម្មៈ ក្នុងថ្ងៃនេះ ដូចជាដែកដំមាស បុគ្គលគួរមើលផង ។

(៨១៩) (ធម្មទេវបុត្រ...) ម្នាលអធម្មៈ បើអ្នកមានកំឡាំងនឹងច្បាំង បុគ្គលចាស់នឹងបុគ្គលជាគ្រូ មិនមានដល់អ្នក ខ្ញុំនឹងឲ្យផ្លូវដល់អ្នក ដោយពាក្យជាទីស្រឡាញ់ និងមិនជាទីស្រឡាញ់ផង ខ្ញុំនឹងអត់ទ្រាំនូវពាក្យទ្រគោះបោះបោក របស់អ្នកផង ។

(៨២០) ឥទញ្ច សុត្វា វចនំ អធម្មោ
អវំសិរោ បតិតោ ឧទ្ធបាទោ
យុទ្ធត្ថិកោ ចេ ន លភាមិ យុទ្ធំ
ឯត្តាវតា ហោតិ ហតោ អធម្មោ ។

(៨២១) ខន្តីពលោ យុទ្ធពលំ វិជេត្វា
ហន្ត្វា អធម្មំ និហនិត្វា ភូម្យា
បាយាសិ វិត្តោ អភិរុយ្ហ សន្ទនំ
មគ្គេនេវ អតិពលោ សច្ចនិក្កមោ ។

(៨២២) មាតា បិតា សមណព្រាហ្មណា ច
អសម្មានិតា យស្ស សកេ អគារេ
ឥធេវ និក្ខិប្ប សរីរទេហំ
កាយស្ស ភេទា និរយំ វជន្តិ តេ
យថា អធម្មោ បតិតោ អវំសិរោ ។



(៨២០) (ព្រះភគវា ទ្រង់ត្រាស់ថា) អធម្មទេវបុត្រ ឮពាក្យនេះហើយ មានក្បាលសំយុងចុះ មានជើងឡើងលើ ក៏ធ្លាក់ចុះ ពោលពាក្យថា អញត្រូវការដោយចម្បាំង តែមិនបាននូវការច្បាំងឡើយ អធម្មទេវបុត្រ ក៏ស្លាប់ ដោយហេតុត្រឹមប៉ុណ្ណោះឯង ។

(៨២១) ធម្មទេវបុត្រ មានខន្តិពលជាកំឡាំង មានចិត្តមានកំឡាំងក្រៃពេក មានព្យាយាមដ៏ទៀងទាត់ បានផ្ចាញ់ បានសម្លាប់នូវអធម្មទេវបុត្រ ដែលមានចម្បាំងជាកំឡាំង ទំលាក់ទៅ លើផែនដី ហើយឡើងកាន់រថ (របស់ខ្លួន) បរទៅតាមផ្លូវដែល ។

(៨២២) បុគ្គលណា មិនបានធ្វើសក្ការៈ ដល់មាតាបិតា និងសមណព្រាហ្មណ៍ ក្នុងផ្ទះរបស់ខ្លួន បុគ្គលនោះ លុះដាក់ចុះនូវកងកាយគឺសរីរៈ បែកធ្លាយកងកាយ ក្នុងលោកនេះ រមែងទៅកាន់នរក ដូចជាអធម្មទេវបុត្រ ដែលសំយុងក្បាលធ្លាក់ចុះ ។

(៤៦៣) មាតា បិតា សមណព្រាហ្មណា ច
សុសម្មានិតា យស្ស សកេ អគារេ
ឥធេវ និក្ខិប្ប សរីរទេហំ
កាយស្ស ភេទា សុគតឹ វជន្តិ តេ
យថាបិ ធម្មោ អភិរុយ្ហ សន្ទនន្តិ ។

ធម្មទេវបុត្តជាតកំ តតិយំ ។

## ឧទយជាតកំ

(៤៦៤) ឯកា និសិន្នា សុចិ សញ្ញតូរូ
បាសាទមារុយ្ហ អនិន្ទិតង្គី
យាចាមិ តំ កិន្នរនេត្តចក្ខុ
ឯកមេករត្តឹ ឧភយោ វសេម ។

(៤៦៥) ឱកិណ្ណន្តរបរិខំ ទឡ្ហមដ្ដាលកោដ្ឋកំ
រក្ខិតំ ខគ្គហត្ថេហិ ទុប្បវេសមិទំ បុរំ ។
ទហរស្ស យុវិតោ(១) នាបិ អាគមោ ច ន វិជ្ជតិ
អថ កេន នុ វណ្ណេន សង្គមំ ឥច្ឆសេ មយា ។

១ ម. យុវិនោ ។



(៤៦៣) បុគ្គលណា បានធ្វើសក្ការៈដល់មាតាបិតានិងសមណព្រាហ្មណ៍ ក្នុងផ្ទះរបស់ខ្លួន បុគ្គលនោះ លុះដាក់ចុះ នូវកាយ គឺសរីរៈ បែកធ្លាយកាយ ក្នុងលោកនេះ រមែងទៅកាន់សុគតិ ដូចជា ធម្មទេវបុត្រ ឡើងកាន់រថរបស់ខ្លួនដូច្នោះ ។

ចប់ ធម្មទេវបុត្តជាតក ទី ៣ ។

## ឧទយជាតក

(៤៦៤) (សក្កទេវរាជត្រាស់សួរ ពោលថា) ម្នាលនាងមានចក្ខុប្រា-កដស្មើ ដោយភ្នែកនៃកិន្នរ នាងស្លៀកសំពត់ដ៏ស្អាត មានភ្លៅរៀបស្រួលបួល មានអវយវៈតិះដៀលមិនបាន ឡើងកាន់ប្រា-សាទ អង្គុយតែម្នាក់ឯង បងសូមអង្វរនាង សូមយើងទាំងពីរនាក់នៅ (ជាមួយគ្នា) អស់មួយយប់នេះ ។

(៤៦៥) (ព្រះរាជធីតា ពោលថា) បុរីនេះមានគូទឹក ជាសង្កាត់ ៗ មានប៉មនិងក្លោងទ្វារយ៉ាងមាំ (មានពលបាល ១០០០០ នាក់) កាន់ព្រះខាន់ត្រៀបរក្សាហើយ ចូលបានដោយក្រ ។ មិនមានប្រុសជំទង់ ឬប្រុសកម្លោះមក (ក្នុងទីនេះតាំងពីវេលាណាមក) ហើយអ្នកនេះ កើតហេតុអ្វី បានជាអ្នកចង់មកជួបនឹងខ្ញុំ (តាំងពីវេលាណា) ។

[៨៦៦] យក្ខោហមស្មិ កល្យាណិ អាគតោស្មិ តវន្តិកេ
ត្វំ មំ នន្ទស្សុ ភទ្ទន្តេ បុណ្ណកំសំ ទទាមិ តេ ។

[៨៦៧] ទេវំ វ យក្ខំ អថ វា មនុស្សំ
ន បត្ថយេ ឧទយមតិច្ច អញ្ញំ
គច្ឆេវ ត្វំ យក្ខ មហានុភាវ
មា ចស្សុ គន្ត្វា បុនរាវជិត្ថ ។

[៨៦៨] យា សា រតី ឧត្តមា កាមភោគិនំ
យំ ហេតុ សត្តា វិសមំ ចរន្តិ
មា តំ រតិំ ជីយិ តុវំ សុចិម្ហិតេ
ទទាមិ តេ រូបិយកំសបូរំ ។

[៨៦៩] នារី នរំ និជ្ឈបយំ ធនេន
ឧក្កំសតី យត្ថ ករោតិ ឆន្ទំ(១)
វិបច្ចនីកោ តវ ទេវធម្មោ
បច្ចក្ខតោ ថោកតរេន ឯសិ ។

---
(១) ម. ឆន្ទំ ។



(៨៦៦) (សក្កទេវរាជ...) ម្នាលនាងកល្យាណី យើងជាយក្ខ មកក្នុងសំណាក់នាង ម្នាលនាងដ៏ចំរើន នាងចូរត្រេកអរ ចំណែកយើង យើងនឹងឲ្យភាជន៍មាស ដ៏ពេញដោយមាស ដល់នាង ។

(៨៦៧) (ព្រះរាជធីតា...) ម្នាលទេវបុត្រ ខ្ញុំមិនប្រាថ្នាបុគ្គលដទៃ ទោះបីជាទេវតា យក្ស ឬ មនុស្សលើសជាងព្រះបាទឧទយៈទេ អ្នកចូរទៅចុះ លុះអ្នកទៅហើយ កុំត្រឡប់មកវិញឡើយ ។

(៨៦៨) (សក្កទេវរាជ...) សេចក្តីត្រេកត្រអាលណា ដ៏ឧត្តមរបស់ពួកសត្វអ្នកបរិភោគកាម ពួកសត្វប្រព្រឹត្តមិនស្មើ ព្រោះហេតុនៃសេចក្តីត្រេកត្រអាលណា នាងកុំផ្ចាញ់សេចក្តីត្រេកត្រអាលនោះ ក្នុងធម្មជាតិស្អាតរបស់នាង យើងនឹងឲ្យភាជន៍ប្រាក់ ដ៏ពេញដោយមាស ដល់នាង ។

(៨៦៩) (ព្រះរាជធីតា...) បុរសកាលលួងលោមស្ត្រី ដោយទ្រព្យ ធ្វើឲ្យសេចក្តីពេញចិត្ត ក្នុងស្ត្រីណា គឺលើកតម្កើងស្ត្រីនោះ ទេវធម៌របស់អ្នកខុសនឹងគេ (ព្រោះថា) អ្នកមកដោយខ្លួន តែតែងដោយតិចប្រាកដ ។

(៨១០) អាយុ ច វណ្ណោ ច មនុស្សលោកេ
និហីយតិ មនុជានំ សុគត្តេ
តេនេវ វណ្ណេន ធនំបិ តុយ្ហំ
និហីយតិ ជិណ្ណតរាសិ អជ្ជ ។
ឯវំ មេ បេក្ខមានស្ស រាជបុត្តិ យសស្សិនិ
ហាយតេវ តវ វណ្ណោ អហោរត្តានមច្ចយេ
ឥមិនាវ ត្វំ វយសា រាជបុត្តិ សុមេធសេ
ព្រហ្មចរិយំ ចរេយ្យាសិ ភិយ្យោ វណ្ណវតី សិយា ។

(៨១១) ទេវា ន ជីរន្តិ យថា មនុស្សា
គត្តេសុ តេសំ វលិយោ ន ហោន្តិ
បុច្ឆាមិ តំ យក្ខ មហានុភាវ
កថន្នុ ទេវាន សរីរទេហោ ។

(៨១២) ទេវា ន ជីរន្តិ យថា មនុស្សា
គត្តេសុ តេសំ វលិយោ ន ហោន្តិ
សុវេ សុវេ ភិយ្យតរោវ តេសំ
ទិព្វោ ច វណ្ណោ វិបុលា ច ភោគា ។



(៨១០) (សក្កទេវរាជ...) ម្នាលនាងមានខ្លួនល្អ អាយុនឹងវណ្ណៈ របស់ពួកមនុស្ស ក្នុងមនុស្សលោក រមែងសាបសូន្យទៅ ព្រោះហេតុនោះឯង ធនជាទ្រព្យរបស់នាងក៏សាបសូន្យដែរ នាងនឹងតែចាស់ទៅក្នុងថ្ងៃនេះ ។ ម្នាលរាជបុត្រី មានយស កាលយើងរមិលមើលយ៉ាងនេះ ពណ៌សម្បុររបស់នាងក៏សាបសូន្យទៅ ក្នុងកាលកន្លងទៅ នៃថ្ងៃនិងយប់ទាំងឡាយ ម្នាលរាជបុត្រី មានប្រាជ្ញាល្អ នាងគប្បីប្រព្រឹត្ត ព្រហ្មចរិយដោយវ័យនេះ នាងមុខជានឹងមានពណ៌សម្បុរដ៏ក្រៃលែង ។

(៨១១) (ព្រះរាជធីតា...) ទេវតាទាំងឡាយមិនចាស់ដូចពួកមនុស្សទេ ការជ្រួញជ្រីវក្នុងខ្លួនរបស់ទេវតាទាំងនោះ មិនមានទេឬ បពិត្រយក្ខ ខ្ញុំសូមសួរលោក ដែលមានអានុភាពច្រើន កងកាយនិងសរីរៈរបស់ទេវតាទាំងឡាយ (មិនចាស់) តើដោយហេតុអ្វី ។

(៨១២) (សក្កទេវរាជ...) ទេវតាទាំងឡាយមិនចាស់ ដូចពួកមនុស្សទេ ការជ្រួញជ្រីវក្នុងខ្លួនរបស់ទេវតាទាំងនោះ មិនមានឡើយ ពណ៌សម្បុរជាទិព្វ និងភោគៈដ៏ច្រើន របស់ទេវតាទាំងឡាយនោះ រឹតតែចំរើនឡើងរាល់ៗថ្ងៃ ។

(៨៣៣) កឹសូធ ភីតា ជនតា អនេកា
មគ្គោ ច នេកាយតនប្បវុត្តោ
បុច្ឆាមិ តំ យក្ខ មហានុភាវ
កត្ថ ឋិតោ បរលោកំ ន ភាយេ ។
(៨៣៤) វាចំ មនញ្ច បណិធាយ សម្មា
កាយេន បាបានិ អកុព្វមានោ
ពហុន្នបានំ ឃរមាវសន្តោ
សទ្ធោ មុទូ សំវិភាគី វទញ្ញូ
សង្គាហកោ សខិលោ សណ្ហវាចោ
ឯត្ថ ឋិតោ បរលោកំ ន ភាយេ ។
(៨៣៥) អនុសាសសិ មំ យក្ខ យថា មាតា យថា បិតា
ឧឡារវណ្ណ បុច្ឆាមិ កោ នុ ត្វមសិ សុព្រហា ។
(៨៣៦) ឧទយោហមស្មិ កល្យាណិ សង្គរត្តា ឥធាគតោ
អាមន្ត ខោ តំ គច្ឆាមិ មុត្តោស្មិ តវ សង្គរា ។



(៨៣៣) (ព្រះរាជធីតា...) ប្រជុំជនដ៏ច្រើនក្នុងលោកនេះខ្លាចអ្វី (ទើបមិនទៅកាន់ទេវលោក) មួយទៀត ផ្លូវ (ទៅទេវលោក) បណ្ឌិតសំដែងដោយអណ្ដូងទីតាំងច្រើន (ផ្លូវណា ជាផ្លូវទៅទេវលោក) បពិត្រយក្ខ មានអានុភាពច្រើន ខ្ញុំសូមសួរលោក បុគ្គល (កាលទៅ) កាន់បរលោក គេឋិតនៅក្នុងផ្លូវណា ទើបមិនខ្លាច ។

(៨៣៤) (សក្កទេវរាជ...) បុគ្គលបានតាំងវាចា និងចិត្តដោយប្រពៃ មិនធ្វើបាបទាំងឡាយ ដោយកាយ នៅគ្រប់គ្រងផ្ទះដែលមានបាយ និងទឹកដ៏ច្រើន ជាអ្នកមានសទ្ធា មានចិត្តទន់ បានចែករំលែក ឲ្យទាន ជាអ្នកដឹងនូវពាក្យស្នើ ជាអ្នកសង្គ្រោះគេ មានវាចាផ្អែម មានវាចាល្អិតល្អ បានឋិតនៅក្នុងគំនរនៃគុណនេះហើយ (កាលនឹងទៅ) កាន់បរលោក មិនខ្លាចឡើយ ។

(៨៣៥) (ព្រះរាជធីតា...) បពិត្រទេវបុត្រ លោកប្រៀនប្រដៅខ្ញុំ ដូចជាមាតា ដូចជាបិតា បពិត្រលោកមានសម្បុរដ៏លើសលុប ខ្ញុំសូមសួរលោក មានសរីរៈសមរម្យល្អ លោកជាអ្វី ។

(៨៣៦) (ព្រះពោធិសត្វ...) ម្នាលនាងកល្យាណី យើងឈ្មោះឧទយៈ បានមកក្នុងទីនេះ ដើម្បីដោះពាក្យប្តេជ្ញា យើងប្រាប់នាងហើយទៅ យើងរួចចាកពាក្យប្តេជ្ញា របស់នាងហើយ ។

(៨៣៧) សចេ ខោ ត្វំ ឧទយោសិ សង្ករត្តាយមាគតោ

អនុសាស មំ រាជបុត្ត យថស្ស(១) បុន សង្គមោ ។

(៨៣៨) អតិបតតិ វយោ ខណោ តថេវ

ឋានំ នត្ថិ ធុវំ ចវន្តិ សត្តា

បរិជីយតិ អទ្ធុវំ សរីរំ

ឧទយេ មា បមាទ ចរស្សុ ធម្មំ ។

កសិណា បថវី ធនស្ស បូរា

ឯកស្សេវ សិយា អនញ្ញសេយ្យា

តំ ចាបិ ជហាតិ អវីតរាគោ

ឧទយេ មា បមាទ ចរស្សុ ធម្មំ ។

មាតា បិតា ច ភាតរោ ច ញាតិយោ

ភរិយា សាមិកោ សធនេន ហោតិ(២)

តេ ចាបិ ជហន្តិ អញ្ញមញ្ញំ

ឧទយេ មា បមាទ ចរស្សុ ធម្មំ ។

---

១ ឱ. យថស្ស ។ ម. យថស្សុ ។ ២ ឱ. ម មាតា ច បិតា ច ភាតរោ ច ភរិយា យាបិ ធនេន ហោតិ កីតា ។ ម. មាតា ច បិតា ច ភាតរោ ច ភរិយាបិ ធនេន ហោតិ កីតា ។



(៨៣៧) (ព្រះរាជធីតា...) បពិត្រព្រះរាជបុត្រ ប្រសិនបើ ព្រះអង្គព្រះនាមឧទយៈបានមកក្នុងទីនេះ ដើម្បីប្រយោជន៍ដល់ពាក្យប្តេជ្ញា សូមព្រះអង្គប្រៀនប្រដៅខ្ញុំ ឲ្យបានជួបគ្នាទៀត ។

(៨៣៨) (ព្រះមហាសត្វ...) វ័យកន្លងទៅតាម ខណៈចិត្ត ក៏កន្លងទៅតាមដូចគ្នា ការតាំងនៅ (នៃសត្វទាំងឡាយ) មិនមាន ពួកសត្វតែងច្យុតទៅដោយពិត សរីរៈមិនទៀង តែងទ្រុឌទ្រោមទៅ ម្នាលនាងឧទយភទ្ទា នាងកុំប្រមាទ ចូរប្រព្រឹត្តធម៌ចុះ ។ ផែនដីទាំងមូលរបស់ស្តេចតែមួយព្រះអង្គ ដ៏ពេញដោយទ្រព្យ ជាផែនដីដែលអ្នកដទៃគ្រប់គ្រងមិនបាន បុគ្គលដែលមិនទាន់ប្រាសចាករាគៈ រមែងលះបង់ទ្រព្យនោះ ម្នាលនាងឧទយភទ្ទា នាងកុំប្រមាទ ចូរប្រព្រឹត្តធម៌ចុះ ។

មាតា បិតា បងប្អូនប្រុស បងប្អូនស្រី និងប្រពន្ធក្តី ប្តីក្តី ព្រមទាំងទ្រព្យ ឯជនទាំងនោះ រមែងលះបង់នូវគ្នានឹងគ្នា ម្នាលនាងឧទយភទ្ទា នាងកុំប្រមាទ ចូរប្រព្រឹត្តធម៌ចុះ ។

កាយោ បរភោជនន្តិ វិទិត្វា(១)
សំសារេ សុគតឹ ច ទុគ្គតឹ ច(២)
ឥត្តរវាសោតិ ជានិត្វា
ធនយេ មា បមាទ ចរស្សុ ធម្មំ ។

(៨៣៩) សាធុ ភាសតិយំ យក្ខោ អប្បំ មច្ចាន ជីវិតំ
កសិរញ្ច បរិត្តញ្ច តញ្ច ទុក្ខេន សំយុតំ
សាហំ ឯកា បព្វជិស្សាមិ ហិត្វា កាសី សុរុន្ធនន្តិ ។

ឧទយជាតកំ ចតុត្ថំ ។

## បានីយជាតកំ

(៨៤០) មិត្តោ មិត្តស្ស បានីយំ អទិន្នំ បរិភុញ្ជិសំ
តេន បច្ឆា វិជិគុច្ឆឹ តំ បាបំ បកតំ មយា
មា បុន អករំ បាបំ តស្មា បព្វជិតោ អហំ ។

(៨៤១) បរទារញ្ច ទិស្វាន ឆន្ទោ មេ ឧបបជ្ជថ
តេន បច្ឆា វិជិគុច្ឆឹ តំ បាបំ បកតំ មយា
មា បុន អករំ បាបំ តស្មា បព្វជិតោ អហំ ។

---

១ ម. ញាត្វា ។ ២ ម. សុគតិំ ទុគ្គតិញ្ច ។



ម្នាលនាងឧទយភទ្ទា នាងដឹងថា កាយជាចំណីនៃពួកសត្វដទៃ ដឹងថា សុគតិនិងទុគ្គតិក្នុងសង្សារ ជាលំនៅរបស់សត្វជាកាលបន្តិចប៉ុណ្ណោះហើយ កុំប្រមាទ ចូរប្រព្រឹត្តធម៌ចុះ ។

(៨៣៩) (ព្រះនាងតបថា...) យក្សនេះ ពោលពីរោះណាស់ ជីវិតរបស់ពួកសត្វ លំបាកផង តិចផង ព្រោះជីវិតនោះ ប្រកបដោយទុក្ខ ខ្ញុំនោះនឹងលះដែនកាសី នឹងក្រុងសុរុន្ធនៈ បួសតែម្នាក់ឯង ។

ចប់ ឧទយជាតក ទី ៤ ។

## បានីយជាតក

(៨៤០) (ព្រះបច្ចេកពុទ្ធ ទី ១ ពោលសំដែងថា) អាត្មាភាពជាមិត្រ (នៃមិត្រម្នាក់) បានប្រើប្រាស់ទឹក ដែលមិត្រនោះមិនឲ្យហើយ ហេតុនោះ អាត្មាភាព ខ្ពើមរអើម ក្នុងកាលជាខាងក្រោយ អាត្មាភាព បានធ្វើបាបនោះហើយ អាត្មាភាព លែងធ្វើបាបទៀតហើយ ព្រោះហេតុនោះ បានជាអាត្មាភាពបួស ។

(៨៤១) (ព្រះបច្ចេកពុទ្ធ ទី ២...) សេចក្តីប្រាថ្នា (ក្នុងកាម) កើតឡើងដល់អាត្មាភាព ព្រោះឃើញនូវប្រពន្ធរបស់បុគ្គលដទៃ ព្រោះហេតុនោះ អាត្មាភាពខ្ពើមរអើម ក្នុងកាលជាខាងក្រោយ អាត្មាភាពបានធ្វើបាបនោះហើយ អាត្មាភាព លែងធ្វើបាបទៀតហើយ ព្រោះហេតុនោះ បានជាអាត្មាភាពបួស ។

(៨៦២) បិតរំ មេ មហារាជ   ចោរា អគណ្ហុ(*) កាននេ
តេសាហំ បុច្ឆិតោ ជានំ   អញ្ញថា នំ វិយាករឹ
តេន បច្ឆា វិជិគុច្ឆឹ   តំ បាបំ បកតំ មយា
មា បុន អករំ បាបំ   តស្មា បព្វជិតោ អហំ ។

(៨៦៣) បាណាតិបាតមករុំ   សោមយាគេ ឧបដ្ឋិតេ
តេសាហំ សមនុញ្ញាសឹ
តេន បច្ឆា វិជិគុច្ឆឹ   តំ បាបំ បកតំ មយា
មា បុន អករំ បាបំ   តស្មា បព្វជិតោ អហំ ។

(៨៦៤) សុរាមេរយមធុកា   យេ ជនា បឋមាសុ នោ
ពហុន្នំ តេ អនត្ថាយ   មជ្ជបានមកប្បយុំ
តេសាហំ សមនុញ្ញាសឹ
តេន បច្ឆា វិជិគុច្ឆឹ   តំ បាបំ បកតំ មយា
មា បុន អករំ បាបំ   តស្មា បព្វជិតោ អហំ ។

---

១ ម. អគ្គណ្ហុំ ។ ឱ. អគណ្ហុំ ។



(៨៦២) (ព្រះបច្ចេកពុទ្ធ ទី ៣...) បពិត្រមហារាជ ពួកចោរបានចាប់បិតារបស់អាត្មាភាពក្នុងព្រៃ អាត្មាភាព ដែលពួកចោរនោះសួរហើយ ទុកជាដឹង ក៏ប្រាប់ហេតុនោះ ដោយចំណែកដទៃវិញ ព្រោះហេតុនោះ អាត្មាភាព ខ្ពើមរអើម ក្នុងកាលជាខាងក្រោយ អាត្មាភាព បានធ្វើបាបនោះហើយ អាត្មាភាព លែងធ្វើបាបទៀតហើយ ព្រោះហេតុនោះ បានជាអាត្មាភាពបួស ។

(៨៦៣) (ព្រះបច្ចេកពុទ្ធ ទី៤...) កាលសែនព្រេន ឈ្មោះសោមយាគតាំងឡើងហើយ ពួកមនុស្សបានធ្វើបាណាតិបាត អាត្មាភាពក៏អនុញ្ញាតឲ្យពួកមនុស្សនោះ ព្រោះហេតុនោះ អាត្មាភាព ខ្ពើមរអើម ក្នុងកាលជាខាងក្រោយ អាត្មាភាពបានធ្វើបាបនោះហើយ អាត្មាភាព លែងធ្វើបាបទៀតហើយ ព្រោះហេតុនោះ បានជាអាត្មាភាពបួស ។

(៨៦៤) (ព្រះបច្ចេកពុទ្ធ ទី ៥...) ពួកជនណា (ក្នុងស្រុក) របស់យើង ដែលសំគាល់សុរា និងមេរ័យថា ដូចទឹកឃ្មុំ ជាដំបូង (មានសភាពយ៉ាងនេះ) ជាដំបូង ពួកជននោះ បានចាត់ចែងទឹកស្រវឹង ដើម្បីសេចក្តីវិនាសដល់ពួកជនច្រើន អាត្មាភាព បានអនុញ្ញាតឲ្យពួកជននោះ ព្រោះហេតុនោះ អាត្មាភាព ខ្ពើមរអើម ក្នុងកាលជាខាងក្រោយ អាត្មាភាព បានធ្វើបាបនោះហើយ អាត្មាភាព លែងធ្វើបាបទៀតហើយ ព្រោះហេតុនោះ បានជាអាត្មាភាពបួស ។

(៨៦៥) ជិរត្តស្សុ ពហុកាមេ ទុក្ខេ ពហុកណ្ដកេ
យេ អហំ បដិសេវន្តោ នាលភឹ តាទិសំ សុខំ ។

(៨៦៦) មហស្សាទា សុខា កាមា នត្ថិ កាមា បរំ សុខំ
យេ កាមេ បដិសេវន្តិ សគ្គន្តេ ឧបបជ្ជរេ ។

(៨៦៧) អប្បស្សាទា ទុខា កាមា នត្ថិ កាមា បរំ ទុក្ខំ[1]
យេ កាមេ បដិសេវន្តិ និរយន្តេ ឧបបជ្ជរេ ។

(៨៦៨) អសិ យថា សុនិសិតោ នេត្តិំសោវ សុបាយិកោ
សត្តីវ ឧរសិ ខិត្តា កាមា ទុក្ខតរា តតោ ។

(៨៦៩) អង្គារានំ ជលិតានំ កាសុំ សាធិកពោរិសំ
ផាលំ ទិវសន្តត្តំ កាមា ទុក្ខតរា តតោ ។

(៨៧០) វិសំ យថា ហលាហលំ តេលំ[2] បក្កុដ្ឋិតំ[3] យថា
តម្ពលោហំ វិលីនំវ កាមា ទុក្ខតរា តតោតិ ។

កាមជាតកំ បញ្ចមំ ។

---

១ ឱ. កាមា បរំ សុខំ ។ ម. កាម បរំ សុខំ ។ ២ ម. តេលំ ។ ៣ ម. ឧក្កុដ្ឋិតំ ។



(៨៦៥) (ព្រះរាជា...) ខ្ញុំឲ្យគេរៀបកាមដ៏ច្រើន ដែលមានទុក្ខ អាក្រក់ មានបន្លាច្រើន ព្រោះថា អាត្មាអញបានសេពហើយ ក៏មិនបានសេចក្ដីសុខ (ក្នុងឈាន) ប្រាកដដូច្នោះ ។

(៨៦៦) (អគ្គមហេសី...) កាមទាំងឡាយ មានសេចក្ដីត្រេកអរច្រើន ជាសុខ សេចក្ដីសុខក្រៅអំពីកាម មិនមានទេ ពួកជនណា បានសេពកាមទាំងឡាយ ពួកជននោះ តែងកើតក្នុងឋានសួគ៌ ។

(៨៦៧) (ព្រះរាជា...) កាមទាំងឡាយ មានសេចក្ដីត្រេកអរតិច ជាទុក្ខ សេចក្ដីទុក្ខក្រៅអំពីកាម មិនមានទេ ពួកជនណា សេពកាមទាំងឡាយ ពួកជននោះ តែងកើតក្នុងនរក ។

(៨៦៨) កាមទាំងឡាយ មានសេចក្ដីទុក្ខ លើសជាងដាវដែលសំលៀងហើយ ជាងព្រះខាន់ដែលលាបដោយថ្នាំពិស ទាំងជាងលំពែង ដែលពួយត្រង់ទ្រូង ។

(៨៦៩) កាមទាំងឡាយ មានសេចក្ដីទុក្ខ លើសជាងរងើកភ្លើងដ៏ច្រាលក្ដៅ ជាងរណ្ដៅរងើកភ្លើង មានជម្រៅមួយខ្លួន ឬអណ្ដាតភ្លើង ដែលក្ដៅពេញមួយថ្ងៃ ។

(៨៧០) កាមទាំងឡាយមានសេចក្ដីទុក្ខ លើសជាងថ្នាំពុលដ៏ក្លៀវក្លា ឬប្រេងកំពុងពុះ ឬក៏ទង់ដែងរលាយ ។

ចប់ កាមជាតក ទី ៥ ។

## យុធញ្ជយជាតកំ

(៨៨១) មិត្តាមច្ចបរិព្យូឡ្ហំ  អហំ វន្ទេ រថេសភ
បព្វជិស្សាមហំ រាជ(១)  តំ ទេវោ អនុមញ្ញតុ ។

(៨៨២) សចេ តេ ឩនំ កាមេហិ  អហំ បរិបូរយាមិ តេ
យោ តំ ហឹសតិ វារេមិ  មា បព្វជ យុធញ្ជយ(២) ។

(៨៨៣) ន មត្ថិ ឩនំ កាមេហិ  ហឹសិតា មេ ន វិជ្ជតិ
ទីបញ្ច កាតុមិច្ឆាមិ  យំ ជរា នាភិកីរតិ ។

(៨៨៤) បុត្តោ វា បិតរំ យាចេ  បិតា វា បុត្តមោរសំ
នេគមោ យាចតេ(៣) តាត  មា បព្វជ យុធញ្ជយ ។

(៨៨៥) មា មំ ទេវ(៤) និវារេហិ  បព្វជន្តំ រថេសភ
មាហំ កាមេហិ សម្មត្តោ(៥)  ជរាយ វសមន្វគូ ។

---

១ ឱ. បព្វជិស្សំ មហារាជ ។ ២ ឱ. មាបព្វជិ យុវញ្ជយ ។ ៣ ឱ. និគមោ តំ យាចេ ។ ៤ ម. ឱ. ទេវ ។ ៥ ឱ សម្បត្តោ ។



## យុធញ្ជយជាតក

(៨៨១) (ព្រះរាជកុមារពោធិសត្វ ពោលថា) បពិត្រព្រះរាជា ជាធំក្នុងរថ ខ្ញុំព្រះអង្គសូមថ្វាយបង្គំ (ព្រះអង្គ) ដែលមិត្រនិងអាមាត្យចោមរោម ហើយ ខ្ញុំព្រះអង្គនឹងបួស សូមព្រះសម្មតិទេព អនុញ្ញាតផ្នួសនោះ (ដល់ខ្ញុំព្រះអង្គ) ។

(៨៨២) (ព្រះរាជា ទ្រង់ត្រាស់ថា) បើកូនឯងខ្វះកាមទាំងឡាយ ឪពុកនឹងបំពេញ ឲ្យគ្រប់គ្រាន់ដល់អ្នក បុគ្គលណាបៀតបៀនអ្នក ឪពុកនឹងឃាត់ (បុគ្គលនោះ) ម្នាលយុធញ្ជ័យ អ្នកកុំបួសឡើយ ។

(៨៨៣) (ព្រះរាជកុមារ...) ខ្ញុំព្រះអង្គមិនមានសេចក្តីខ្វះកាមទាំងឡាយទេ បុគ្គលណាមួយ បៀតបៀនខ្ញុំព្រះអង្គ ក៏មិនមានដែរ តែថា ខ្ញុំព្រះអង្គប្រាថ្នានឹងធ្វើនូវទីពឹង(ដល់ខ្លួន) ដែលជរាកាត់បង់មិនបាន ។

(៨៨៤) (ព្រះសាស្តា...) បុត្រអង្វរនូវបិតា បិតាក៏អង្វរនូវបុត្រឱរសដែរ ព្រះរាជាទ្រង់ត្រាស់ថា ម្នាលកូន ជនអ្នកនៅក្នុងនិគម អង្វរអ្នក ម្នាលយុធញ្ជ័យ អ្នកកុំបួសឡើយ ។

(៨៨៥) (ព្រះរាជកុមារ...) បពិត្រព្រះបិតាជាធំក្នុងរថ សូមព្រះអង្គកុំឃាត់ផ្នួសខ្ញុំព្រះអង្គនោះ កុំឲ្យខ្ញុំព្រះអង្គពោរពេញ ដោយកាមទាំងឡាយ ឲ្យលុះក្នុងអំណាចជរាឡើយ ។

[៨៥៦] អហំ តំ តាត យាចាមិ អហំ បុត្ត និវារយេ

ចិរំ តំ ទដ្ឋុមិច្ឆាមិ មា បព្វជ យុធញ្ជយ ។

[៨៥៧] ឧស្សាវោវ តិណគ្គម្ហិ សុរិយស្សុគ្គមនំ បតិ

ឯវមាយុ មនុស្សានំ មា មំ អម្ម និវារយ ។

[៨៥៨] តរមានោ ឥមំ យានំ អារោបេតុ រថេសភ

មា មេ មាតា តរន្តស្ស អន្តរាយករា អហុ ។

[៨៥៩] អភិធាវថ ភទ្ទន្តេ សុញ្ញំ ហេស្សតិ រម្មកំ(១)

យុធញ្ជយោ អនុញ្ញាតោ សព្វទត្តេន រាជិនា ។

[៨៦០] យោហុ សេដ្ឋោ មនុស្សានំ យុវា កញ្ចនសន្និភោ

សោយំ កុមារោ បព្វជិតោ កាសាយវសនោ ពលី ។

---

១ ម. សុញ្ញោ ហេស្សតិ រម្មកោ ។



[៨៥៦] (ព្រះមាតា...) ម្នាលកូន យើងសូមអង្វរអ្នក ម្នាលកូន យើងសូមឃាត់អ្នក យើងចង់ឃើញអ្នកអស់កាលយូរ ម្នាលយុធញ្ជ័យ ចូរអ្នកកុំបួសឡើយ ។

[៨៥៧] (ព្រះរាជកុមារ...) ទឹកសន្សើមលើចុងស្មៅ តែងធ្លាក់ចុះ (លើផែនដី) ក្នុងកាលព្រះអាទិត្យរះឡើង យ៉ាងណាមិញ អាយុរបស់មនុស្សទាំងឡាយ ក៏យ៉ាងនោះដែរ បពិត្រព្រះមាតា សូមព្រះមាតា កុំឃាត់ខ្ញុំឡើយ ។

[៨៥៨] បពិត្រព្រះបិតា ជាធំក្នុងរថ សូមឲ្យ (បុរស) បម្រើព្រះមាតា (របស់ខ្ញុំព្រះអង្គ) ឲ្យឡើងកាន់ព្រះរាជយាននេះ កុំឲ្យព្រះមាតាធ្វើនូវសេចក្តីអន្តរាយ ដល់ខ្ញុំព្រះអង្គ ដែលកំពុងឆ្លង ។

[៨៥៩] (ព្រះមាតា...) នាងទាំងឡាយចូរស្ទុះទៅ សេចក្តីចំរើន (ចូរមាន) ដល់នាង នគររម្មកៈមុខជានឹងសូន្យ (ព្រោះថា) យុធញ្ជយកុមារ ព្រះរាជាសព្វទត្ត អនុញ្ញាត (ឲ្យបួសហើយ) ។

[៨៦០] ព្រះរាជកុមារណានៅក្មេង មានសម្បុរដូចនឹងមាស ប្រសើរបំផុតជាងព្រះរាជបុត្រ ១០០០ ព្រះរាជកុមារនោះ ជាអ្នកមានកំឡាំង ស្លៀកសំពត់កាសាយៈបួសហើយ ។

(៤៦១) ឧភោ កុមារា បព្វជិតា យុវញ្ជយោ យុធិដ្ឋិលោ
បហាយ មាតាបិតរោ សង្គំ ឆេត្វាន មច្ចុនោតិ ។

(១) យុវញ្ជយជាតកំ ឆដ្ឋំ ។

## ទសរថជាតកំ

(៤៦២) ឯថ លក្ខណសីតា ច ឧភោ ឱតរថោទកំ
ឯវាយំ ភរតោ អាហ រាជា ទសរថោ មតោ ។

(៤៦៣) កេន រាម បភាវេន[២] សោចិតព្វំ ន សោចសិ
បិតរំ កាលកតំ សុត្វា ន តំ បសហតេ ទុខំ ។

(៤៦៤) យំ ន សក្កា និបាលេតុំ បោសេន លបតំ[៣] ពហុំ
ស កិស្ស វិញ្ញូ មេធាវី អត្តានមុបតាបយេ ។

(៤៦៥) ទហរា ច ហិ យេ វុឌ្ឍា យេ ពាលា យេ ច បណ្ឌិតា
អឌ្ឍា ចេវ ទលិទ្ទា ច សព្វេ មច្ចុបរាយណា ។

១ ឱ. យុវញ្ជយជាតកំ ។ ២ ម. សភាវេន ។ ៣ ឱ. ម. បោសេន លបតំ ។



(៤៦១) (ព្រះសាស្តា...) កុមារទាំងពីរអង្គ គឺយុវញ្ជ័យ ១ យុធិដ្ឋិលៈ ១ លះបង់នូវព្រះមាតានិងព្រះបិតា ផ្តាច់បង់នូវគ្រឿងជាប់ចំពាក់របស់មច្ចុមារ បួសហើយ ។

ចប់ យុវញ្ជ័យជាតក ទី ៦ ។

## ទសរថជាតក

(៤៦២) (រាមបណ្ឌិតកុមារ បានពោលថា) ម្នាលលក្ខណៈនិងនាងសីតា អ្នកទាំងពីរចូរមក អ្នកទាំង ២ នាក់ចូរចុះទឹក ភរតកុមារ បាននិយាយយ៉ាងនេះថា ព្រះបាទទសរថទ្រង់ទិវង្គតហើយ ។

(៤៦៣) (ភរតកុមារ...) បពិត្រព្រះរាមៈដោយអានុភាពអ្វី ទើបទ្រង់បានឮថា ព្រះបិតាទិវង្គតហើយ មិនសោកស្តាយរបស់ដែលគួរសោកស្តាយ សេចក្តីទុក្ខមិនគ្របសង្កត់ទ្រង់ ។

(៤៦៤) (រាមបណ្ឌិតកុមារ...) ជីវិតណា (របស់ពួកសត្វ) បណ្តាពួកបុរសដែលការពារ បុរស (សូម្បីតែម្នាក់) ក៏មិនអាចដើម្បីរក្សាជីវិតនោះបានទេ វិញ្ញូជន ជាមេធាវីនោះ ធ្វើខ្លួនឲ្យក្តៅក្រហាយ ដើម្បីអ្វី ។

(៤៦៥) សេចក្តីពិតថា ជនទាំងឡាយណា ទាំងក្មេង ទាំងចាស់ ទាំងល្ងង់ ទាំងប្រាជ្ញ ទាំងអ្នកមាន ទាំងអ្នកក្រ ជនទាំងអស់នោះ សុទ្ធតែមានសេចក្តីស្លាប់នៅខាងមុខ ។

(៨៦៦)ផលានមិវ បក្កានំ  និច្ចំ បតនតោ ភយំ
ឯវំ ជាតាន មច្ចានំ  និច្ចំ មរណតោ ភយំ ។

(៨៦៧)សាយមេកេ ន ទិស្សន្តិ  បាតោ ទិដ្ឋា ពហុជ្ជនា
បាតោ ឯកេ ន ទិស្សន្តិ  សាយំ ទិដ្ឋា ពហុជ្ជនា ។

(៨៦៨)បរិទេវយមានោ ចេ  កិញ្ចិទត្ថំ ឧទព្វហេ
សម្មូឡ្ហោ ហឹសមត្តានំ  កយិរា តំ វិចក្ខណោ ។

(៨៦៩)កិសោ វិវណ្ណោ ភវតិ  ហឹសមត្តានមត្តនោ
ន តេន បេតា បាលេន្តិ  និរត្ថា បរិទេវនា ។

(៨៧០)យថា សរណមាទិត្តំ  វារិនា បរិនិព្វយេ
ឯវម្បិ ធីរោ សុតវា  មេធាវី បណ្ឌិតោ នរោ
ខិប្បមុប្បតិតំ សោកំ  វាតោ តូលំវ ធំសយេ[១]។

---

១ ម. តូលំ ចធំសយេ ។



(៨៦៦) ផ្លែឈើទុំទាំងឡាយ មានសេចក្តីភ័យ អំពីកិរិយាជ្រុះជានិច្ច យ៉ាងណាមិញ ពួកសត្វកើតហើយ ក៏មានសេចក្តីភ័យ អំពីសេចក្តីស្លាប់ជានិច្ច យ៉ាងនោះដែរ ។

(៨៦៧) ជនទាំងឡាយច្រើន ពួកខ្លះ គេឃើញក្នុងវេលាព្រឹក វេលាល្ងាចមិនឃើញ ជនទាំងឡាយច្រើន ពួកខ្លះ គេឃើញក្នុងវេលាល្ងាច វេលាព្រឹកមិនឃើញ ។

(៨៦៨) បើបុគ្គលអ្នកល្ងង់ កាលខ្សឹកខ្សួល បៀតបៀនខ្លួន ហើយគប្បីនាំមកនូវប្រយោជន៍បន្តិចបន្តួចបាន អ្នកប្រាជ្ញក៏គប្បីធ្វើសេចក្តីខ្សឹកខ្សួលនោះដែរ ។

(៨៦៩) (បុគ្គលខ្សឹកខ្សួល) បៀតបៀនខ្លួនរបស់ខ្លួន ជាអ្នកស្គម មិនមានពណ៌សម្បុរ ពួកសត្វដែលទៅកាន់បរលោក មិនមែនញុំាងគត្ត-កាលឲ្យប្រព្រឹត្តទៅ ដោយសេចក្តីខ្សឹកខ្សួលនោះឡើយ ព្រោះថា សេចក្តីខ្សឹកខ្សួល មិនមានប្រយោជន៍ទេ ។

(៨៧០) (បណ្ឌិតបុរស) គប្បីញុំាងផ្ទះដែលភ្លើងឆេះឲ្យរលត់ ដោយទឹកបាន យ៉ាងណាមិញ ធីរជន ជាមេធាវី បណ្ឌិត បានស្តាប់ហើយ គប្បីញុំាងសេចក្តីសោក ដែលកើតហើយឲ្យរលត់ឆាប់ ដូចខ្យល់បក់ផាត់នូវប៉ុយ យ៉ាងនោះដែរ ។

(៨៩១)ឯកោវ មច្ចោ អច្ចេតិ ឯកោវ ជាយតេ កុលេ
សំយោគបរមាត្វេវ សម្ភោគា សព្វបាណិនំ។

(៨៩២) តស្មា ហិ ធីរស្ស ពហុស្សុតស្ស
សម្បស្សតោ លោកមិមំ បរញ្ច
អញ្ញាយ ធម្មំ ហទយំ មនញ្ច
សោកា មហន្តាបិ ន តាបយន្តិ ។

(៨៩៣)សោហំ យសញ្ច ភោគញ្ច ភរិយាបិ ច ញាតកេ
សេសំ សម្បាលយិស្សាមិ កិច្ចមេតំ វិជានតោ។

(៨៩៤)ទសវស្សសហស្សានិ សដ្ឋីវស្សសតានិ ច
កម្ពុគីវោ មហាពាហុ រាមោ រជ្ជមការយីតិ។

ទសរថជាតកំ សត្តមំ ។

## សំវរជាតកំ

(៨៩៥)ជានន្តោ នោ មហារាជ តវ សីលំ ជនាធិបោ
ឥមេ កុមារា បូជេន្តិ ន តំ កេនចិ មញ្ញរ ។



(៨៩១) សត្វមែនតែទៅកាន់បរលោកតែម្នាក់ឯង កើតក្នុងត្រកូលក៏តែម្នាក់ឯង ការសេពគប់នៃពួកសត្វទាំងអស់ គឺមានការជួបជុំ ជាការប្រសើរបំផុត ។

(៨៩២) ព្រោះហេតុនោះ សេចក្តីសោកទាំងឡាយ សូម្បីធំ ក៏មិនដុតកំ-ដៅនូវហទយវត្ថុ និងចិត្តរបស់អ្នកប្រាជ្ញ ជាពហុស្សូត ដែលឃើញច្បាស់នូវលោកនេះ និងលោកខាងមុខ ព្រោះដឹងច្បាស់នូវធម៌ ។

(៨៩៣) យើងនោះនឹងរក្សានូវយសផង ភោគៈផង ភរិយាទាំងឡាយផង ញាតិទាំងឡាយផង នឹងជនដ៏សេសផង នេះជាកិច្ចរបស់អ្នកប្រាជ្ញ។

(៨៩៤) ព្រះសាស្តាទ្រង់ត្រាស់ថា ព្រះរាមៈមានព្រះសូរគ្គីវដូចជារូប សំណាកមាស មានព្រះពាហាធំ បានសោយរាជ្យអស់ ១៦០០០ ឆ្នាំ ។

ចប់ ទសរថជាតក ទី ៧ ។

## សំវរជាតក

(៨៩៥) (ពោធិសត្វកុមារ បានពោលថា) បពិត្រមហារាជ ព្រះជនាធិបៈ (ជាព្រះបិតា) ទ្រង់ជ្រាប នូវសីលរបស់ព្រះអង្គហើយ បានជាព្រះអង្គបូជានូវព្រះរាជកុមារទាំងនេះ (ដោយជនបទនោះៗ) មិនសំគាល់នូវព្រះអង្គ ដោយជនបទណាមួយឡើយ ។

(៨៧៦) តិដ្ឋន្តេ នោ មហារាជ អាទូ ទេវេ ទិវង្គតេ
ញាតី តំ សមនុមញ្ញឹសុ សម្បស្សំ អត្ថមត្តនោ ។
(៨៧៧) កេន សីលេន វត្តេន សញ្ជាតេ អភិតិដ្ឋសិ
កេន តំ នាតិវត្តន្តិ ញាតិសង្ឃា សមាគតា ។
(៨៧៨) ន រាជបុត្ត ឧស្សុយ្យាមិ សមណានំ មហេសិនំ
សក្កច្ចន្តេ នមស្សាមិ បាទេ វន្ទាមិ តាទិនំ ។
(៨៧៩) តេ មំ ធម្មគុណេ យុត្តា សុស្សូសមនុសូយកំ(១)
សមណា សមនុសាសន្តិ ឥសិធម្មគុណេ រតា ។
(៨៨០) តេសាហំ វចនំ សុត្វា សមណានំ មហេសិនំ
ន កិញ្ចិ អតិមញ្ញាមិ ធម្មេ មេ និរតោ មនោ ។
(៨៨១) ហត្ថារោហា អនីកដ្ឋា រថិកា បត្តិការកា
តេសំ(២) នប្បដិពាហាមិ និវិដ្ឋំ(៣) ភត្តវេតនំ ។

---

១ ម. សុស្សូសមនុស្សុយ្យកំ ។ ២ ឱ. តេសុ ។ ៣ ឱ. និវិដ្ឋំ ។





(៨៧៦) កាលដែលមហារាជ គង់ព្រះជន្មនៅ ឬកាលដែលព្រះអង្គ (ជាបិតារបស់ពួកយើង) ទិវង្គតហើយ ពួកញាតិ កាលឃើញសេចក្តីចំរើនរបស់ខ្លួន បានយល់ព្រមឲ្យព្រះអង្គ (សោយរាជ្យ) ។
(៨៧៧) បពិត្រព្រះបាទសីវៈ ព្រះអង្គទ្រង់គ្របសង្កត់ (ខ្ញុំបង ៩៩ ព្រះអង្គ) ដែលកើតជាមួយ ដោយវត្តដូចម្តេច ឯពួកញាតិដែលមកប្រជុំគ្នាហើយ ក៏មិនគ្របសង្កត់នូវព្រះអង្គ ដោយវត្តដូចម្តេច ។
(៨៧៨) (ព្រះបាទសីវៈ...) បពិត្ររាជបុត្រ ខ្ញុំមិនច្រណែន ខ្ញុំថ្វាយបង្គំព្រះបាទទាំងឡាយ របស់ពួកសមណៈ ជាតាទិបុគ្គល បាននមស្ការពួកសមណៈទាំងនោះ ដោយគោរព ។
(៨៧៩) សមណៈទាំងនោះ ជាអ្នកត្រេកអរ ក្នុងធម្មគុណ របស់ឥសី បានប្រៀនប្រដៅខ្ញុំ ឲ្យប្រកបក្នុងធម្មគុណ ឲ្យជាអ្នកក្រងក្រាប់ មិនច្រណែន ។
(៨៨០) ខ្ញុំបានស្តាប់ពាក្យរបស់ពួកសមណៈ អ្នកស្វែងរកនូវគុណនោះហើយ មិនមើលងាយបន្តិចបន្តួចសោះ ចិត្តរបស់ខ្ញុំក៏ត្រេកអរ ក្នុងធម៌ជានិច្ច ។
(៨៨១) ពួកទាហានដំរី ពួកទាហានដែលឋិតនៅក្នុងទ័ព ពួកទាហានរថ ពួកពលថ្មើរជើង ខ្ញុំមិនបង្អាក់នូវបាយ និងថ្លៃឈ្នួល ដែលពួកទាហានទាំងនោះធ្លាប់បានហើយ ។

(៨៨២)មហាមត្តា ច មេ អត្ថិ មន្តិនោ បរិចារិកា
ពារាណសឹ វោហារន្តិ ពហុមំសំ សុរោទនំ ។

(៨៨៣)អថោបិ វណិជា ផីតា នានារដ្ឋេហិ អាគតា
តេសុ មេ វិហិតា រក្ខា យំ ជានាហុបោសថ ។

(៨៨៤)ធម្មេន កិរ ញាតីនំ រជ្ជំ ការេហិ សំវរ
មេធាវី បណ្ឌិតោ ចាសិ អថោបិ ញាតីនំ ហិតោ ។

(៨៨៥)តំ តំ ញាតិបរិព្យូឡ្ហំ នានារតនមោចិតំ
អមិត្តា នប្បសហន្តិ ឥន្ទំវ អសុរាធិបោតិ ។

សំវរជាតកំ អដ្ឋមំ ។

## សុប្បារកជាតកំ

(៨៨៦) ឧម្មុជ្ជន្តិ និមុជ្ជន្តិ មនុស្សា ខុរនាសិកា
សុប្បារកំ តំ បុច្ឆាម សមុទ្ទោ កតមោ អយំ ។



(៨៨២) ពួកមហាមាត្យ ពួកមន្ត្រី ពួកអ្នកបម្រើ របស់ខ្ញុំមាន ពួកនេះបាននាំតែងនូវសាច់ នឹងទឹកស្រវឹងច្រើន ក្នុងក្រុងពារាណសី ។

(៨៨៣) មួយទៀត សូម្បីពួកពាណិជ ដែលមកអំពីដែនផ្សេង ៗ ក៏សម្បូណ៌ ខ្ញុំបាននាំតែងការរក្សា ចំពោះពួកពាណិជទាំងនោះ បពិត្រឧបោសថជាបង សូមព្រះបងជ្រាបយ៉ាងនេះចុះ ។

(៨៨៤) (ឧបោសថកុមារ...) បពិត្រព្រះបាទសំវរៈ ឮថាព្រះអង្គ (គ្រប់សក្តិកានុភាព) របស់ពួកញាតិ (បង ៩៩ ព្រះអង្គ) ដោយធម៌ សូមព្រះអង្គសោយរាជ្យចុះ ព្រះអង្គជាអ្នកមានប្រាជ្ញាផង ជាបណ្ឌិតផង ទាំងជាប្រយោជន៍ដល់ពួកញាតិផង ។

(៨៨៥) ពួកសត្រូវ មិនអាចគ្របសង្កត់ព្រះអង្គ ដែលពួកញាតិចោមរោមហើយ ជាអ្នកកុះករដោយរតនៈផ្សេង ៗ ដូចជាស្តេចអសុរ មិនអាចគ្របសង្កត់ព្រះឥន្ទ្រ ដូច្នោះដែរ ។

ចប់ សំវរជាតក ទី ៨ ។

## សុប្បារកជាតក

(៨៨៦) (ពួកពាណិជ បានពោលថា) មនុស្សទាំងឡាយ មានច្រមុះដូចកាំបិតកោរ ងើប មុជ (ក្នុងសមុទ្រនេះ) ពួកយើង សូមសួរលោកឈ្មោះសុប្បារកៈ សមុទ្រនេះ តើឈ្មោះអ្វី ។

(៨៨៧) ករុកច្ឆា[១] បយាតានំ ភណិជានំ ធនេសិនំ
នាវាយ វិប្បនដ្ឋាយ ខុរមាលីតិ វុច្ចតិ ។

(៨៨៨) យថា អគ្គិ សុរិយោ ច សមុទ្ទោ បដិទិស្សតិ
សុប្បារកំ តំ បុច្ឆាម សមុទ្ទោ កតមោ អយំ ។

(៨៨៩) ករុកច្ឆា បយាតានំ ភណិជានំ ធនេសិនំ
នាវាយ វិប្បនដ្ឋាយ អគ្គិមាលីតិ វុច្ចតិ ។

(៨៩០) យថា ទធិ ច ខីរញ្ច សមុទ្ទោ បដិទិស្សតិ
សុប្បារកំ តំ បុច្ឆាម សមុទ្ទោ កតមោ អយំ ។

(៨៩១) ករុកច្ឆា បយាតានំ ភណិជានំ ធនេសិនំ
នាវាយ វិប្បនដ្ឋាយ ទធិមាលីតិ[២] វុច្ចតិ ។

(៨៩២) យថា កុសោ ច សស្សោ ច សមុទ្ទោ បដិទិស្សតិ
សុប្បារកំ តំ បុច្ឆាម សមុទ្ទោ កតមោ អយំ ។

---

១ ម. ភរុកច្ឆា ។ ២ ម. ខីរមាលីតិ ។



(៨៨៧) (ព្រះមហាសត្វ បានពោលថា) កាលសំពៅរបស់ពួកពាណិជ អ្នកស្វែងរកទ្រព្យ ចេញទៅអំពីកំពង់ករុកច្ឆៈ លឿនទៅកាន់ប្រទេសផ្សេង សមុទ្រនេះហៅថា ខុរមាលី ។

(៨៨៨) (ពួកពាណិជ បានពោលថា) សមុទ្រដែលប្រាកដ ចំពោះមុខហាក់ដូចជាភ្លើងនឹងព្រះអាទិត្យ ពួកយើង សូមសួរលោកសុប្បារកៈ សមុទ្រនេះ តើឈ្មោះអ្វី ។

(៨៨៩) (ព្រះមហាសត្វ...) កាលសំពៅរបស់ពួកពាណិជ អ្នកស្វែងរកទ្រព្យ ចេញទៅអំពីកំពង់ករុកច្ឆៈ លឿនទៅកាន់ប្រទេសផ្សេង សមុទ្រនេះហៅថា អគ្គិមាលី ។

(៨៩០) (ពួកពាណិជ...) សមុទ្រដែលប្រាកដ ចំពោះមុខហាក់ដូចជាទឹកដោះជូរនឹងទឹកដោះស្រស់ ពួកយើង សូមសួរលោកសុប្បារកៈ សមុទ្រនេះ តើឈ្មោះអ្វី ។

(៨៩១) (ព្រះមហាសត្វ...) កាលសំពៅរបស់ពួកពាណិជ អ្នកស្វែងរកទ្រព្យ ចេញទៅអំពីកំពង់ករុកច្ឆៈ លឿនទៅកាន់ប្រទេសផ្សេង សមុទ្រនេះហៅថា ទធិមាលី ។

(៨៩២) (ពួកពាណិជ...) សមុទ្រដែលប្រាកដ ចំពោះមុខ ហាក់ដូចជាស្បូវភ្លាំងនឹងសំទូង ពួកយើង សូមសួរលោកសុប្បារកៈ សមុទ្រនេះតើឈ្មោះអ្វី ។

(៨៩៣) ភរុកច្ឆា បយាតានំ ភណិជានំ ធនេសិនំ

នាវាយ វិប្បនដ្ឋាយ កុសមាលីតិ វុច្ចតិ ។

(៨៩៤) យថា នឡោ ច វេឡុ ច សមុទ្ទោ បដិទិស្សតិ

សុប្បារកំ បុច្ឆាម សមុទ្ទោ កតមោ អយំ ។

(៨៩៥) ភរុកច្ឆា បយាតានំ ភណិជានំ ធនេសិនំ

នាវាយ វិប្បនដ្ឋាយ នឡមាលីតិ វុច្ចតិ ។

(៨៩៦) មហព្ភយោ ភឹសនកោ សទ្ទោ សុយ្យតិ មានុសោ

យថា សោព្ភោ បបាតោ ច សមុទ្ទោ បដិទិស្សតិ

សុប្បារកំ បុច្ឆាម សមុទ្ទោ កតមោ អយំ ។

(៨៩៧) ភរុកច្ឆា បយាតានំ ភណិជានំ ធនេសិនំ

នាវាយ វិប្បនដ្ឋាយ ពលភាមុខីតិ វុច្ចតិ ។



(៨៩៣) (ព្រះមហាសត្វ...) កាលសំពៅពួកពាណិជ អ្នកស្វែងរកទ្រព្យ ចេញទៅអំពីកំពង់ភរុកច្ឆៈ លឿនទៅកាន់ប្រទេសផ្សេង សមុទ្រនេះហៅថា កុសមាលី ។

(៨៩៤) (ពួកពាណិជ...) សមុទ្រដែលប្រាកដ ចំពោះមុខ ហាក់ដូចជាបបុសនិងបុស្ស៊ី ពួកយើង សូមសួរលោកសុប្បារកៈ សមុទ្រនេះ តើឈ្មោះអ្វី ។

(៨៩៥) (ព្រះមហាសត្វ..) កាលសំពៅពួកពាណិជ អ្នកស្វែងរកទ្រព្យ ចេញទៅអំពីកំពង់ភរុកច្ឆៈ លឿនទៅកាន់ប្រទេសផ្សេង សមុទ្រនេះហៅថា នឡមាលី ។

(៨៩៦) (ពួកពាណិជ...) សំឡេងរបស់អមនុស្ស គួរឲ្យភ័យខ្លាំង គួរឲ្យស្ញើម ដែលពួកយើងបានឮជាក់ សមុទ្រដែលប្រាកដ ចំពោះមុខ ហាក់ដូចជារណ្ដៅនិងជ្រោះ ពួកយើង សូមសួរលោកសុប្បារកៈ សមុទ្រនេះ តើឈ្មោះអ្វី ។

(៨៩៧) (ព្រះមហាសត្វ...) កាលសំពៅពួកពាណិជ អ្នកស្វែងរកទ្រព្យ ចេញទៅអំពីកំពង់ភរុកច្ឆៈ លឿនទៅកាន់ប្រទេសផ្សេង សមុទ្រនេះហៅថា ពលភាមុខី ។

(៨៩៨) យតោ សរាមិ អត្តានំ យតោ បត្តោស្មិ វិញ្ញុតំ
នាភិជានាមិ សញ្ចិច្ច ឯកបាណម្បិ ហឹសិតំ
ឯតេន សច្ចវជ្ជេន សោត្ថឹ នាវា និវត្តតុ ។

សុប្បារកជាតកំ នវមំ ។

## តស្សុទ្ទានំ

សិរិ មាតុបោសកធម្មវរោ
បុន ជុណ្ហក ធម្មុទយវរោ
អថ បាណិយ យុធញ្ជយកោ
ទសរថ សំវរ បារគេន ទស ។

ឯកាទសកនិបាតំ និដ្ឋិតំ ។

---



(៨៩៨) (ព្រះមហាសត្វ ធ្វើសច្ចកិរិយាថា) តាំងពីកាលដែលខ្ញុំរលឹក ឃើញខ្លួនខ្ញុំ តាំងពីកាលដែលខ្ញុំដល់នូវភាពជាអ្នកដឹងក្តី ខ្ញុំមិនបៀតបៀនសត្វ សូម្បីតែមួយឡើយ សូមឲ្យសំពៅត្រឡប់ទៅកាន់ទីមានសួស្តី ដោយការពោលពាក្យសច្ចៈនេះចុះ ។

ចប់ សុប្បារកជាតក ទី ៩ ។

## ឧទ្ទាននៃជាតកនោះគឺ

និយាយអំពីវត្ថុប្រសើរ ចិញ្ចឹមមាតា ១ ព្រះរាជាព្រះនាមជុណ្ហៈ ១ ធម្មទេវបុត្ត ១ ព្រះរាជាព្រះនាមឧទយៈ ១ ទឹកផឹក ១ ព្រះរាជាព្រះនាមយុធញ្ជ័យ ១ ព្រះរាជាព្រះនាមទសរថ ១ ព្រះរាជាព្រះនាមសំវរៈ ១ សំពៅត្រឡប់មកក្រោយ ១ ត្រូវជា ៩ ជាតក ។

ចប់ ឯកាទសកនិបាត ។

---

# ទ្វាទសនិបាតជាតកំ

## ចុល្លកុណាលជាតកំ

(៨៩៩) ខុទ្ទានំ(១) លហុចិត្តានំ អកតញ្ញូន ទុព្ភិនំ
នាទេវសត្តោ បុរិសោ ថីនំ សទ្ធាតុមរហតិ ។

(៩០០) ន តា បជានន្តិ កតំ ន កិច្ចំ
ន មាតរំ បិតរំ ភាតរំ វា
អនរិយា សមតិក្កន្តធម្មា
សស្សេវ ចិត្តស្ស វសំ វជន្តិ ។

(៩០១) ចិរានុវុដ្ឋម្បិ បិយំ មនាបំ
អនុកម្បកំ បាណសមម្បិ សន្តំ
អាវាសុ កិច្ចេសុ ច នំ ជហន្តិ
តស្មាហំ ឥត្ថីនំ ន វិស្សសាមិ ។

(៩០២) ថីនញ្ហិ ចិត្តំ យថា វានរស្ស
កន្នប្បកន្នំ យថា រុក្ខច្ឆាយា
ចលាចលំ ហទយំ ឥត្ថិយានំ
ចក្កស្ស នេមិ វិយ បរិវត្តតិ ។

---

១ ម. លុទ្ធានំ ។

# ទ្វាទសនិបាតជាតក

## ចុល្លកុណាលជាតក

(៨៩៩) (សកុណពោល ជាគាថាថា) បុរសដែលមិនជាប់ចំពាក់ដោយទេវតា (ខ្មោចមិនចូល) មិនគួរជឿ (នូវសីលធម៌) របស់ពួកស្រ្តីជាអ្នកល្មោភខាន មានចិត្តរហ័ស មិនដឹងនូវឧបការគុណ ដែលគេធ្វើហើយ ជាអ្នកប្រទូស្តមិត្រទេ ។

(៩០០) ស្រ្តីទាំងនោះ មិនដឹងនូវឧបការគុណ ដែលគេធ្វើហើយដល់ខ្លួន មិនដឹងច្បាស់នូវកិច្ច (ដែលខ្លួនត្រូវធ្វើ) មិនដឹងច្បាស់នូវមាតាបិតាឬបងប្អូន មិនអៀនខ្មាស តែងប្រព្រឹត្តកន្លងច្បាប់ ជាធម្មតា លុះក្នុងអំណាច នៃចិត្តរបស់ខ្លួន ។

(៩០១) ស្រ្តីទាំងនោះ តែងលះបង់នូវបុរសនោះ ដែលជាទីស្រឡាញ់ ជាទីគាប់ចិត្ត សូម្បីនៅជាមួយគ្នាអស់កាលយូរ ជាអ្នកអនុគ្រោះ សូម្បីស្មើដោយជីវិត ក្នុងគ្រោះថ្នាក់ទាំងឡាយផង ក្នុងកិច្ចការទាំងឡាយផង ព្រោះហេតុនោះ ខ្ញុំមិនស្និទ្ធស្នាលនឹងស្រ្តីទាំងឡាយឡើយ ។

(៩០២) ព្រោះថា ចិត្តរបស់ពួកស្រ្តីប្រែប្រួល ដូចជាសត្វស្វា ឬដូចជាម្លប់ឈើ ចិត្តរបស់ពួកស្រ្តី ព្រាល់ព្រាល វិលវង់ ដូចជាខ្នងកង់រាល វិលទៅដូច្នោះ ។

(៤០៣) យទា តា បស្សន្តិ សមេក្ខមានា
អាទេយ្យរូបំ បុរិសស្ស វិត្តំ
សណ្ហាហិ វាចាហិ នយន្តិ មេនំ
កម្ពោជកា ជលជេនេវ អស្សំ ។

(៤០៤) យទា ន បស្សន្តិ សមេក្ខមានា
អាទេយ្យរូបំ បុរិសស្ស វិត្តំ
សមន្តតោ នំ បរិវជ្ជយន្តិ
តិណ្ណោ នទីបារគតោវ កុល្លំ ។

(៤០៥) សិលេសូបមា សិខីរិវ សព្វភក្ខា
តិក្ខមាយា(១) នទីរិវ សីឃសោតា
សេវន្តិ ហេតា បិយមប្បិយញ្ច
នាវា យថា ឱរកុលំ បរញ្ច ។

(៤០៦) ន តា ឯកស្ស ន ទ្វិន្នំ អាបណោវ(២) បសារិតោ
យោ តា មយ្ហន្តិ មញ្ញេយ្យ វាតំ ជាលេន ពន្ធយេ ។

---

១ ម. តិក្ខមាតា ។ ២ ម. អាបណោ សោ ។



(៤០៣) ក្នុងកាលដែលស្ត្រីទាំងនោះ សំឡឹងឃើញទ្រព្យ របស់បុរស មានសភាពគួរយកបាន ក៏នាំបុរសនុ៎ះទៅ (កាន់អំណាចខ្លួន) ដោយសំដីដ៏ផ្អែមល្ហែមទាំងឡាយ ដូចជាពួកជនអ្នកនៅក្នុងដែនកម្ពោជៈ កាលនាំសេះទៅកាន់អំណាចខ្លួន ដោយស្លែដូច្នោះ ។

(៤០៤) ក្នុងកាលដែលស្ត្រីទាំងនោះ សំឡឹងមើលមិនឃើញទ្រព្យរបស់បុរស មានសភាពគួរយកបានទេ ក៏គេចចៀសបុរសនុ៎ះ ដោយជុំវិញ ដូចជាបុគ្គលអ្នកឆ្លង ទៅដល់ត្រើយស្ទឹងហើយ ក៏វៀរបង់នូវក្បូនដូច្នោះ ។

(៤០៥) ស្ត្រីទាំងនោះ មានសេចក្តីប្រៀបធៀបដោយជ័រ ដូចជាភ្លើងដែលស៊ីនូវគ្រប់យ៉ាង មានមាយាដ៏ក្លៀវក្លា ដូចជាស្ទឹងមានខ្សែទឹកដ៏រហ័ស ព្រោះថា ស្ត្រីទាំងនុ៎ះ តែងសេពនូវបុរសជាទីស្រឡាញ់ ទាំងមិនជាទីស្រឡាញ់ ដូចជាទូកដែលតែងនូវប្រាំងទាំងខាងកាយ ទាំងប្រាំងខាងនាយដូច្នោះ ។

(៤០៦) ស្ត្រីទាំងនោះ មិនមែនរបស់បុរសម្នាក់ មិនមែនរបស់បុរសពីរនាក់ទេ ដូចជាកនផ្សារ ដែលគេរៀបហើយ បុរសណាសំគាល់នូវស្ត្រីទាំងនោះ ថាជារបស់អញ បុរសនោះ គប្បីចងនូវខ្យល់ ដោយសំណាញ់បាន ។

(៤០៧) យថា នទី ច បន្ថោ ច   បានាគារំ សភា បបា
ឯវំ លោកិត្ថិយោ នាម   វេលា តាសំ ន វិជ្ជតិ ។
(៤០៨) ឃតាសនសមា ឯតា   កណ្ហសប្បសិរូបមា
គាវោ ពហិ តិណស្សេវ   ឱមសន្តិ វរំ វរំ ។
(៤០៩) ឃតាសនំ កុញ្ជរំ កណ្ហសប្បំ
មុទ្ធាភិសិត្តំ បមទា ច សព្វា
ឯតេ នរោ និច្ចយតោ ភជេថ
តេសំ ហវេ ទុព្វិទុ សព្វភាវោ ។
(៤១០) នច្ចន្តវណ្ណា ន ពហូនំ កន្តា
ន ទក្ខិណា បមទា សេវិតព្វា
ន បរស្ស ភរិយា ន ធនស្ស ហេតុ
ឯតិត្ថិយោ បញ្ច ន សេវិតព្វា ។

ចុល្លកុណាលជាតកំ បឋមំ ។

## ភទ្ទសាលជាតកំ

(៤១១) កា ត្វំ សុទ្ធេហិ វត្ថេហិ   អឃេ វេហាយសណ្ឋិតា
កេន ត្យស្សូនិ វត្តន្តិ   កុតោ តំ ភយមាគតំ ។



(៤០៧) ស្ទឹង ផ្លូវ គៀមស្រា រោងសម្រាប់ប្រជុំ ទីអណ្តូង យ៉ាងណា មនុស្សស្រីទាំងឡាយ ក្នុងលោក ក៏យ៉ាងនោះដែរ ឯវេលារបស់ស្រីទាំងនោះ មិនមានឡើយ ។

(៤០៨) ស្រីទាំងនោះ ស្មើដោយភ្លើងដែលឆេះខ្លាញ់ ឧបមាដោយក្បាលពស់វែក ដូចជាពួកគោស៊ីរើសតែចុងស្មៅដ៏ប្រសើរ ៗ ខាងក្រៅ ។

(៤០៩) នរជនគប្បីសង្រួមជានិច្ច ហើយគប់រកនូវជនទាំង៥នេះ គឺភ្លើង ១ ដំរី ១ ពស់វែក ១ ស្តេចដែលបានមុទ្ធាភិសេកហើយ ១ ពួកស្រីទាំងអស់ ១ ភាវៈទៀងទាត់ របស់ជនទាំងនោះ គេស្គាល់បានដោយក្រ ។

(៤១០) ស្រីមានសម្បុរល្អពេក បុរសមិនគួរសេពទេ ស្រីជាទីស្រឡាញ់នៃបុរសច្រើនគ្នា បុរសមិនគួរសេពទេ ស្រីប្រសប់ប៉ិនប្រៀន បុរសមិនគួរសេពទេ ស្រីជាប្រពន្ធរបស់បុគ្គលដទៃ បុរសមិនគួរសេពទេ ស្រី (គប់រកបុរស) ព្រោះហេតុតែទ្រព្យ បុរសមិនគួរសេពទេ ស្រីទាំង៥ពួកនេះ បុរសមិនគួរសេពឡើយ ។

ចប់ ចុល្លកុណាលជាតក ទី ១ ។

## ភទ្ទសាលជាតក

(៤១១) (ព្រះរាជាទ្រង់ត្រាស់ថា) អ្នកជាអ្វី ដែលមានសំពត់ទាំងឡាយដ៏ស្អាត បានឋិតនៅលើអាកាសវេហាស៍ ទឹកភ្នែកទាំងឡាយរបស់អ្នកហូរចេញ តើដោយហេតុអ្វី ភ័យមកចំពោះអ្នកព្រោះអ្វី ។

(៩១២) តវេវ ទេវ វិជិតេ   ភទ្ទសាលោតិ មំ វិទូ
សដ្ឋិវស្សសហស្សានិ   តិដ្ឋតោ បូជិតស្ស មេ ។

(៩១៣) ការយន្តា នគរានិ   អគារេ ច និវេសនេ
វិវិធេ ចាបិ បាសាទេ   ន មំ តេ អច្ចមញ្ញិសុំ
យថេវ មំ តេ បូជេសុំ   តថេវ ត្វម្បិ បូជយ ។

(៩១៤) តញ្ច អហំ(១)ន បស្សាមិ   ថូលំ កាយេន តេ ទុមំ
អារោហបរិណាហេន   អភិរូបោសិ ជាតិយា ។

(៩១៥) បាសាទំ ការយិស្សាមិ   ឯកត្ថម្ភំ មនោរមំ
តត្ថ តំ ឧបនេស្សាមិ   ចិរំ តេ យក្ខ ជីវិតំ ។

(៩១៦) ឯវំ ចិត្តំ ឧទបាទិ   សរីរេន វិនាភាវំ
បុថុសោ មំ វិកន្តិត្វា   ខណ្ឌសោ អវកន្តថ ។

---
១ ម. តំ តហំ ។



(៩១២) (ទេវតាក្រាបទូលថា) បពិត្រព្រះសម្មតិទេព ជនទាំងឡាយគ្រប់ដែន របស់ព្រះអង្គ ស្គាល់ច្បាស់នូវខ្ញុំថា ជាភទ្ទសាលព្រឹក្ស កាលខ្ញុំឋិតនៅ (ក្នុងទីនោះ) អស់ ៦ ម៉ឺនឆ្នាំ ជនទាំងឡាយបានបូជាហើយ ។

(៩១៣) បពិត្រព្រះអង្គជាម្ចាស់ទិស (ព្រះរាជាទាំងឡាយ ពីដើមគ្រប់អង្គនោះ) កាលឲ្យគេសាងនូវក្រុងទាំងឡាយផង ដំណាក់ទាំងឡាយផង ប្រាសាទផ្សេងៗ ផង មិនដែលបៀតបៀនខ្ញុំឡើយ ព្រះរាជាទាំងនោះបូជាខ្ញុំ យ៉ាងណា សូមព្រះអង្គបូជាខ្ញុំ យ៉ាងនោះដែរ ។

(៩១៤) (ព្រះរាជា...) ខ្ញុំមិនបានឃើញអ្នក ជាដើមឈើធំ ដោយកាយរបស់អ្នកទេ អ្នកជាឈើមានទ្រង់ទ្រាយដ៏ល្អ ដោយកំពស់ ទំហំ និងកំណើត ។

(៩១៥) ខ្ញុំនឹងឲ្យគេធ្វើប្រាសាទ មានសសរតែមួយ ជាទីរីករាយនៃចិត្ត ខ្ញុំនឹងនាំយកអ្នកចូលទៅកាន់ប្រាសាទនោះ ជីវិតរបស់អ្នក (នឹងមាន) អស់កាលយូរ ។

(៩១៦) (ទេវតា...) (បើ) ព្រះទ័យ (របស់ទ្រង់) កើតឡើងយ៉ាងនេះ សេចក្តីព្រាត់ប្រាស (ចាកភទ្ទសាលព្រឹក្ស) ជាសរីរៈ (របស់ខ្ញុំ នឹងមានប្រាកដ) (កាលបើយ៉ាងនេះ) សូមព្រះអង្គកាត់ខ្ញុំ ជាច្រើនកំណាត់ កាត់ជាកំណាត់តូចៗចុះ ។

(៤៥៧)អគ្គំ ឆេត្វាន មជ្ឈេ ច បច្ឆា មូលម្ហិ ឆិន្ទថ
ឯវំ មេ ឆិជ្ជមានស្ស ន ទុក្ខំ មរណំ សិយា ។

(៤៥៨)ហត្ថបាទំ យថា ឆិន្ទេ កណ្ណនាសញ្ច ជីវតោ
តតោ បច្ឆា សីសេ ឆិន្ទេ តំ ទុក្ខំ មរណំ សិយា ។

(៤៥៩)សុខំ នុ ខណ្ឌសោ ឆិន្នំ ភទ្ទសាល វនប្បតិ
កឹ ហេតុ កឹ ឧបាទាយ ខណ្ឌសោ ឆិន្នមិច្ឆសិ ។

(៤៦០)យញ្ច ហេតុំ ឧបាទាយ ហេតុធម្មូបសំហិតំ
ខណ្ឌសោ ឆិន្នមិច្ឆាមិ មហារាជ សុណោហិ មេ ។

(៤៦១)ញាតី មេ សុខសំវឌ្ឍា មម បស្សេ និវាតជា
តេបិហំ ឧបហឹសេយ្យំ បរេសំ អសុខោចិតំ ។

(៤៦២)ចេតេយ្យរូបំ ចេតេសិ ភទ្ទសាល វនប្បតិ
ហិតកាមោសិ ញាតីនំ អភយំ សម្ម ទម្មិ តេ ។

ភទ្ទសាលជាតកំ ទុតិយំ ។



(៤៥៧) តែសូមព្រះអង្គកាត់ត្រង់ចុងនឹងកណ្តាល (មុន) រួចកាត់ត្រង់គល់ក្នុងកាលជាខាងក្រោយ កាលបើខ្ញុំត្រូវព្រះអង្គ កាត់យ៉ាងនេះ សេចក្តីស្លាប់ មិនគប្បីជាទុក្ខទេ ។

(៤៥៨) (ព្រោះថា...) ដូចយ៉ាង បុគ្គលកាត់ដៃនឹងជើងផង ត្រចៀកនឹងច្រមុះផង ឲ្យស្លាប់បាត់ជីវិត តពីនោះ គេកាត់ក្បាលក្នុងកាលខាងក្រោយ សេចក្តីស្លាប់នោះ ក៏ជាទុក្ខដែរ ។

(៤៥៩) ម្នាលភទ្ទសាលព្រឹក្ស ជាម្ចាស់នៃព្រៃ ការកាត់ជាកំណាត់ស្រួលឬ ព្រោះហេតុអ្វី ព្រោះអាស្រ័យហេតុអ្វី បានជាអ្នកចង់ឲ្យគេកាត់ជាកំណាត់ៗ ។

(៤៦០) (ទេវតាថា...) បពិត្រមហារាជ ខ្ញុំចង់ឲ្យគេកាត់ជាកំណាត់ ព្រោះអាស្រ័យហេតុ ដែលប្រកបដោយហេតុណា សូមព្រះអង្គទ្រង់ស្តាប់នូវហេតុនោះ របស់ខ្ញុំ ។

(៤៦១) ពួកឈើជាញាតិរបស់ខ្ញុំ ចំរើនដុះដាលដោយសេចក្តីសុខ កើតក្នុងទីមិនមានខ្យល់ នៅជិតខាងខ្ញុំ (កាលបើទ្រង់កាប់រំលំខ្ញុំ) ខ្ញុំមុខជានឹងរលំ សង្កត់ពួកឈើជាញាតិនោះ សេចក្តីទុក្ខនឹងកើតមានដល់ពួកឈើជាញាតិដទៃទៀត ។

(៤៦២) (ព្រះរាជា...) ម្នាលភទ្ទសាលព្រឹក្ស ជាម្ចាស់នៃព្រៃ អ្នកគិតនូវហេតុ ដែលមានសភាពគួរគិត អ្នកជាឈើប្រាថ្នានូវប្រយោជន៍ ដល់ពួកឈើជាញាតិ ម្នាលសំឡាញ់ ខ្ញុំឲ្យអភ័យដល់អ្នក ។

ចប់ ភទ្ទសាលជាតក ទី ២ ។

## សមុទ្ទវាណិជជាតកំ

(៩២៣) កសន្តិ វបន្តិ តេ ជនា
មនុជា កម្មផលូបជីវិនោ
នយិមស្ស ទីបកស្ស ភាគិនោ
ជម្ពុទីបា ឥទមេវ នោ វរំ ។

(៩២៤) តិបញ្ចរត្តូបគតម្ហិ ចន្ទេ
វេគោ មហា ហេហិតិ សាគរស្ស
ឧប្លវិស្សំ[១] ទីបមិមំ ឧឡារំ
មា វោ វធី គច្ឆថ លេណមញ្ញំ ។

(៩២៥) ន ជាតយំ សាគរវារិវេគោ
ឧប្លវិស្សំ ទីបមិមំ ឧឡារំ
តំ មេ និមិត្តេហិ ពហូហិ ទិដ្ឋំ
មា ភេថ កឹ សោចថ មោទថវ្ហោ[២] ។

១ ម. ឧប្លាវយំ ។ ម. ឧប្លវិស្សំ ។ ២ ម. មោទថាតិ ។



## សមុទ្ទវាណិជជាតក

(៩២៣) (ព្រះសាស្តាទ្រង់សំដែងនូវគាថា របស់បុរសម្នាក់ថា) ពួកមនុស្សជន (ក្នុងជម្ពូទ្វីប) ទាំងនោះ អាស្រ័យចិញ្ចឹមជីវិត ដោយផលនៃការងារ រមែងសាបព្រោះ ក៏មិនបានមួយចំណែកនៃកោះនេះឡើយ ឯកោះរបស់យើងនេះ ប្រសើរជាងជម្ពូទ្វីប ។

(៩២៤) (ធម្មិកទេវបុត្រ បានពោលថា) កាលបើព្រះចន្ទ្រដើរដល់រាត្រី ១៥ កើត សន្ទុះនៃសាគរធំ នឹងជោរលិចកោះដ៏ថ្កុំថ្កើងនេះ សន្ទុះនៃសាគរនោះ កុំសម្លាប់អ្នកទាំងឡាយឡើយ អ្នកទាំងឡាយចូររកទីជ្រកកោនដទៃចុះ ។

(៩២៥) (អធម្មិកទេវបុត្រ បានពោលថា) សន្ទុះនៃទឹក ក្នុងសាគរនេះ មិនមែនជោរលិចកោះដ៏ថ្កុំថ្កើងនេះទេ ដំណើរនោះយើងឃើញ ដោយនិមិត្តដ៏ច្រើន អ្នកទាំងឡាយកុំខ្លាច សោយសោកព្រោះហេតុអ្វី ចូររីករាយចុះ ។

(៤៦៦) បហូតភក្ខំ ពហុអន្នបានំ
បត្តត្ថ អាវាសមិមំ ឧឡារំ
ន វោ ភយំ បដិបស្សាមិ កិញ្ចិ
អាបុត្តបុត្តេហិ បមោទថវ្ហោ ។

(៤៦៧) យោ ទេវោយំ[១] ទក្ខិណាយំ ទិសាយំ
ខេមំ បដិក្កោសតិ តស្ស សច្ចំ
ន ឧត្តរោ វេទិ ភយាភយស្ស
មា ភេថ កឹ សោចថ មោទថវ្ហោ ។

(៤៦៨) យថា ឥមេ វិប្បវទន្តិ យក្ខា
ឯកោ ភយំ សំសតិ ខេមមេកោ
តទិង្ឃ មយ្ហំ វចនំ សុណាថ
ខិប្បំ លហុំ មា វិនស្សិម្ហ សព្វេ ។

(៤៦៩) សព្វេ សមាគម្ម ករោម នាវំ
ទោណឹ ទឡ្ហំ សព្វយន្តូបបន្នំ
សចេ អយំ ទក្ខិណោ សច្ចមាហ
មោឃំ បដិក្កោសតិ ឧត្តរោយំ ។

១. យោទេវ្យំ ។





(៤៦៦) អ្នកទាំងឡាយបានដល់លំនៅដ៏ថ្កុំថ្កើងនេះ ជាកន្លែងមានចំណីដ៏ច្រើន មានបាយនឹងទឹកដ៏ច្រើន យើងមិនឃើញភ័យបន្តិចបន្តួចនៃអ្នកទាំងឡាយឡើយ អ្នកទាំងឡាយ ចូររីករាយជាមួយនឹងកូននឹងចៅទាំងឡាយចុះ ។

(៤៦៧) ជាងឈើជាមនុស្សពាល បានពោលថា ទេវតាណា បំភ្លឺទិសខាងត្បូង និយាយប្រាប់សេចក្តីក្សេម ពាក្យរបស់ទេវតានោះពិត ទេវតាដែលបំភ្លឺទិសខាងជើង មិនដឹងនូវហេតុដែលគួរខ្លាចនឹងមិនគួរខ្លាច អ្នកទាំងឡាយកុំខ្លាចឡើយ សោយសោកធ្វើអ្វី ចូរនាំគ្នារីករាយចុះ ។

(៤៦៨) (ជាងឈើជាបណ្ឌិត បានពោលថា) យក្ខទាំងនេះពោលខុសគ្នា យក្ខម្នាក់ប្រាប់នូវភ័យ យក្ខម្នាក់ប្រាប់នូវសេចក្តីក្សេម ណ្ហើយចុះ អ្នកទាំងឡាយ ចូរស្តាប់នូវពាក្យ របស់យើងចុះ យើងទាំងអស់គ្នា កុំវិនាសឆាប់រហ័សឡើយ ។

(៤៦៩) យើងទាំងអស់គ្នា ចូរប្រជុំគ្នាធ្វើទូក គឺទូកកំពង់មាំ ប្រកបដោយយន្ត គ្រប់យ៉ាង បើទេវតា ដែលបំភ្លឺទិសខាងត្បូងនេះ និយាយពិត ទេវតា ដែលបំភ្លឺទិសខាងជើង និយាយប្រាប់នេះ មិនពិតឡើយ ។

(៤៣០) សា វេ នោ ហោហិតិ អាបទត្ថា
ឥមញ្ច ទីបំ ន បរិច្ចជេម
សចេ ច សោ ឧត្តរកេ(១) សច្ចមាហ
មោឃំ បដិក្កោសតិ ទក្ខិណោយំ ។

(៤៣១) ឥមេវ នាវំ អភិរុយ្ហ សព្វេ
ឃរំ មយំ សោត្ថិ គមេមុ តាវំ
ន វេ សុគណ្ហំ បឋមេន សេដ្ឋំ
កនិដ្ឋមាបាថគតំ គហេត្វា
យោ ចីធ មជ្ឈំ បរិយេយ្យ គណ្ហាតិ(២)
ស វេ នរោ សេដ្ឋមុបេតិ ឋានំ ។

(៤៣២) យថាបិ តេ សាគរវារិមជ្ឈេ
សកម្មុនា សោត្ថិ វហឹសុ វាណិជា
អនាគតត្ថំ បដិវិជ្ឈិយាន
អប្បម្បិ នាច្ចេតិ ស ភូរិបញ្ញោ ។

---

១ ម. ឧត្តរោ ។ ២ ម. អត្ថ បរិយេយ្យ គណ្ហតំ ។



(៤៣០) ទូករបស់យើងនោះ នឹងមានប្រយោជន៍ ដល់សេចក្តីអន្តរាយ (ដែលកើតមានក្រោយ) ព្រោះយើងមិនលះបង់ នូវកោះនេះ ។ បើទេវតា ដែលឋិតក្នុងទិសខាងជើង និយាយពិត ទេវតា ដែលឋិតក្នុងទិសខាងត្បូងនេះ និយាយមិនពិតទេ ។

(៤៣១) យើងទាំងអស់គ្នា ឡើងជិះទូកនោះឯង ហើយគប្បីឆ្លងទៅកាន់ត្រើយខាងណាយ ដោយសួស្តីយ៉ាងនេះ ។ បុគ្គលមិនគប្បីជឿ ដោយគិតថា ពាក្យដែលបុគ្គលទី ១ ពោលហើយ ជាពាក្យប្រសើរ ដូច្នេះទេ នរជនណា ក្នុងលោកនេះ កាន់យកនូវពាក្យនៃបុគ្គលទី ២ ដែលដល់នូវគន្លងនៃត្រចៀក ហើយពិចារណា (នូវពាក្យខាងដើម និងពាក្យខាងចុង) ហើយជឿនូវពាក្យជាកណ្តាល នរជននោះ រមែងដល់នូវទីដ៏ប្រសើរ ។

(៤៣២) (អភិសម្ពុទ្ធគាថា) ពាណិជទាំងនោះបានទៅ ដោយសួស្តី ក្នុងកណ្តាលនៃទឹកសមុទ្រ ដោយកម្មរបស់ខ្លួន យ៉ាងណាមិញ កុលបុត្រមានប្រាជ្ញាដូចផែនដី បានដឹងច្បាស់នូវប្រយោជន៍ ជាអនាគត ហើយមិនប្រព្រឹត្តកន្លង នូវប្រយោជន៍ (របស់ខ្លួន) សូម្បីតិច ក៏យ៉ាងនោះដែរ ។

(៤៣៣) ពាលា ច មោហេន រសានុគិទ្ធា
អនាគតំ អប្បដិវិជ្ឈិយត្ថំ
បច្ចុប្បន្នេ សីទន្តិ អត្ថជាតេ
សមុទ្ទមជ្ឈេ យថា តេ មនុស្សា ។
(៤៣៤) អនាគតំ បដិកយិរាថ កិច្ចំ
មា មំ កិច្ចំ កិច្ចកាលេ ព្យធេសិ
តំ តាទិសំ បដិកតកិច្ចការឹ
ន តំ កិច្ចំ កិច្ចកាលេ ព្យធេតីតិ ។

សមុទ្ទវាណិជជាតកំ តតិយំ ។

## កាមជាតកំ

(៤៣៥) កាមំ កាមយមានស្ស តស្ស ចេ តំ សមិជ្ឈតិ
អទ្ធា បីតិមនោ ហោតិ លទ្ធា មច្ចោ(*) យទិច្ឆតិ ។
(៤៣៦) កាមំ កាមយមានស្ស តស្ស ចេ តំ សមិជ្ឈតិ
តតោ នំ អបរំ កាមេ ឃម្មេ តណ្ហំវ វិន្ទតិ ។

* ម. មច្ចុ ។



(៤៣៣) ពួកជនពាល ដែលជាប់ចំពោះរស ព្រោះមោហៈ មិនបានដឹងច្បាស់នូវប្រយោជន៍ជាអនាគត ក៏លិចចុះក្នុងប្រយោជន៍ជាបច្ចុប្បន្ន ដូចជាមនុស្សទាំងនោះ(ដល់នូវសេចក្ដីវិនាស)ក្នុងកណ្ដាលសមុទ្រ ។

(៤៣៤) បុគ្គលគប្បីគ្រោងទុកនូវកិច្ចជាអនាគត (ដោយចំណាំថា) កិច្ចកុំបៀតបៀនអញ ក្នុងកាលដែលមានកិច្ចឡើយ ឯកិច្ចនោះមិនបានបៀតបៀន នូវបុគ្គលនោះ ជាអ្នកធ្វើកិច្ច ដែលខ្លួនបានគ្រោងទុកហើយប្រាកដដូច្នោះ ក្នុងកាលជាទីធ្វើកិច្ច ។

ចប់ សមុទ្ទវាណិជជាតក ទី ៣ ។

## កាមជាតក

(៤៣៥) (ព្រះមហាសត្វ បានពោលថា) កាលបុគ្គលប្រាថ្នានូវកាម បើកាមនោះសម្រេចដល់បុគ្គលនោះ សត្វប្រាថ្នាកាមណា បាន ហើយ រមែងជាអ្នកមានចិត្តរីករាយ ក្នុងវត្ថុនោះដោយពិត ។

(៤៣៦) កាលបុគ្គលប្រាថ្នាកាម បើកាមនោះសម្រេច ដល់បុគ្គលនោះ បុគ្គលនោះ រមែងបាននូវចំណង់ផ្សេង ជាងនោះទៅទៀត ដូចជា (បុគ្គលហត់នឿយ) បាននូវចំណង់ (ស្រេក) ក្នុងថ្ងៃក្ដៅ ។

(៤៣៧) កឹវ សិង្គិណោ សិង្គិ    វល្លមានស្ស វល្លតិ

ឃរំ មនុស្ស ភោសស្ស    ពាលស្ស អវិជានតោ

កិយ្យោ តណ្ហា បិបាសា ច    វល្លមានស្ស វល្លតិ ។

(៤៣៨) បវព្យា សាលិយវកំ    គកស្សំ ធាសគោរិសំ

ឧត្វាបិ ធាលមេកស្ស    វត្តិ វិត្វា សមំ ចរេ ។

(៤៣៩) រាជា បសយ្ហ បឋវឹ វិជិត្វា

សសាគរន្តំ មហិមាវសន្តោ

ឱរំ សមុទ្ទស្ស អតិត្តរូបោ

បារំ សមុទ្ទស្សបិ បត្ថយេថ[១] ។

(៤៤០) យាវ អនុស្សរំ[២] កាមេ មនសា តិត្តិ នាជ្ឈគា

តតោ និវត្តា បដិក្កម្ម ទិស្វា

តេ វេ តិត្តា យេ បញ្ញាយ តិត្តា ។

---

១ ឱ. ម. បត្ថយេធ ។ ២ ឱ. យោ ប អនុស្សរំ ។



(៤៣៧) កាលគោជាសត្វមានស្នែង កំពុងចំរើន ស្នែងរមែងចំរើនផង យ៉ាងណា កាលសត្វអ្នកមានបញ្ញាខ្ទន់ ល្ងង់ខ្លៅ មិនដឹងអ្វី កំពុងចំរើន តណ្ហានិងសេចក្ដីស្រេកឃ្លាន រមែងរីកចំរើនឡើង យ៉ាងនោះផង ។

(៤៣៨) ប្រសិនបើ (មាណពនោះ) ឲ្យស្រូវស្រូវខ្សាយ ឲ្យស្រូវដំណើប ឲ្យគោ សេះ និងបុរសជាខ្ញុំប្រុស លើផែនដី (ដល់បុគ្គលណាមួយ ទុកតែប៉ុណ្ណេះ) ក៏មិនល្មមដល់បុគ្គលម្នាក់ឡើយ បុរសដឹងយ៉ាងនេះហើយ គប្បីប្រព្រឹត្តឲ្យស្មើ ។

(៤៣៩) ស្ដេចកាលបានច្បាំងឈ្នះនូវផែនដី ហើយគ្រប់គ្រងផែនដី មានសាគរជាទីបំផុត មានសភាពជាអ្នកមិនឆ្អែត នឹងត្រើយសមុទ្រខាងអាយ ក៏ចង់បាននូវត្រើយសមុទ្រខាងនាយទៀត ។

(៤៤០) បុរសកាលនឹកស្រណោះនូវកាមទាំងឡាយ ដោយចិត្ត (ដរាបណា) ក៏មិនដល់នូវសេចក្ដីឆ្អែត ដរាបនោះ ពួកសត្វណាត្រឡប់ចិត្តចេញ គេចខ្លួនថយអំពីកាមនោះ ហើយឃើញ (ទោសកាមដោយញាណ) ជាអ្នកឆ្អែតដោយប្រាជ្ញា ពួកសត្វនោះ ទើបឈ្មោះថាឆ្អែតពិតមែន ។

(៨៦១) បញ្ញាយ តិត្តិនំ សេដ្ឋំ ន សោ កាមេហិ តប្បតិ
បញ្ញាយ តិត្តំ បុរិសំ តណ្ហា ន កុរុតេ វសំ ។

(៨៦២) អបចិនេថេវ កាមានិ(១) អប្បិច្ឆស្ស អលោលុបោ
សមុទ្ទមត្តោ បុរិសោ ន សោ កាមេហិ តប្បតិ ។

(៨៦៣) រថការោវ ចម្មស្ស បរិកន្តំ ឧបាហនំ
យំ យំ ជហតិ(២) កាមានំ តំ តំ សម្បជ្ជតេ សុខំ
សព្វញ្ចេ សុខមិច្ឆេយ្យ សព្វេ កាមេ បរិច្ចជេ ។

(៨៦៤) អដ្ឋតេ ភាសិតា គាថា សព្វា ហោន្តិ សហស្សិយោ
បដិគណ្ហ មហាព្រហ្មេ សាធេតំ តវ ភាសិតំ ។

(៨៦៥) ន មេ អត្ថោ សហស្សេហិ សតេហិ នហុតេហិ វា
បច្ឆិមំ ភាសតោ គាថំ កាមេ មេ ន រតោ(៣) មនោ ។

---

១ ម. កាមានំ ។ ២ ម. ចជតិ ។ ៣ ឱ. ន រតោ ។ ម. និរតោ ។





(៨៦១) បុរសនោះមិនក្តៅក្រហាយ ដោយកាមទាំងឡាយ (នេះ) ជាអំពើដ៏ប្រសើរ របស់ពួកជនអ្នកឆ្អែត ដោយប្រាជ្ញា តណ្ហាមិនធ្វើបុរសដែលឆ្អែតដោយប្រាជ្ញា ឲ្យលុះក្នុងអំណាចបានឡើយ ។

(៨៦២) សូមព្រះអង្គកាត់បង់នូវកាមទាំងឡាយចេញ បុរសអ្នកមានប្រាជ្ញាប៉ុនសមុទ្រ អ្នកមានសេចក្តីប្រាថ្នាតិច អ្នកមិនលោភលន់ បុរសនោះ រមែងមិនក្តៅក្រហាយ ដោយកាមទាំងឡាយ ។

(៨៦៣) បុគ្គលលះបង់នូវចំណែក នៃកាមទាំងឡាយណា ៗ សេចក្តីសុខក៏សម្រេច (ដល់បុគ្គលនោះ) ព្រោះចំណែកនៃកាមទាំងឡាយនោះ ៗ ដូចជាងស្បែកកាត់ស្បែកជើង (កែងចៀរខ្ចៅចំហៀរ) នៃស្បែកគោល (ក៏បាននូវថ្លៃស្បែកជើង ឈ្មោះថាជាអ្នកបានសេចក្តីសុខ) បើបុគ្គលប្រាថ្នានូវសេចក្តីសុខគ្រប់យ៉ាង គួរលះកាមទាំងអស់ចេញ ។

(៨៦៤) (ព្រាហ្មណ៍ក្រាបទូលថា) គាថាទាំងអស់ ៨ ដែលអ្នកពោលហើយ គួរដល់ថ្លៃ ១.០០០ កហាបណៈ ម្នាលមហាព្រហ្ម អ្នកចូរទទួលយក (នូវកហាបណៈទាំងនេះ) ចុះ ភាសិតរបស់អ្នកនេះ ប្រពៃណាស់ ។

(៨៦៥) (ព្រះមហាសត្វ...) ខ្ញុំព្រះអង្គ មិនត្រូវការ ដោយកហាបណៈ ទាំងរយ ទាំងពាន់ ទាំងម៉ឺនទេ កាលដែលខ្ញុំព្រះអង្គកំពុងពោលគាថាខាងចុង ចិត្តរបស់ខ្ញុំព្រះអង្គ មិនត្រេកអរក្នុងកាមឡើយ ។

(៤៦៦)អក្រោការតាយំ មាណវកោ សព្វលោកវិទូ មុនិ
យោ តណ្ហំ ទុក្ខជននិំ(១) បរិជានាតិ បណ្ឌិតោ ។

កាមជាតកំ អដ្ឋមំ ។

## ជនសន្ធជាតកំ

(៤៦៧)ទស ខលុមានិ ឋានានិ យានិ បុព្វេ អការិត្វា
ស បច្ឆា អនុតប្បតិ ឥច្ចាហ រាជា ជនសន្ធោ ។
(៤៦៨)អលទ្ធា វិត្តំ(២) តបតិ បុព្វេ អសមុទានិតំ
ន បុព្វេ ធនមេសិស្សំ ឥតិ បច្ឆានុតប្បតិ ។
(៤៦៩)សក្យរូបំ បុរេ សន្តំ មយា សិប្បំ ន សិក្ខិតំ
កិច្ឆា វុត្តិ អសិប្បស្ស ឥតិ បច្ឆានុតប្បតិ ។
(៤៧០)កូដវេទី បុរេ អាសឹ បិសុណោ បិដ្ឋិមំសិកោ
ចណ្ឌោ ច ផរុសោ ចាសឹ(៣) ឥតិ បច្ឆានុតប្បតិ ។

១ ម. យោ ធម្មំ តណ្ហំ ទុក្ខជននិំ ។ ឱ. យោ ធម្មំ តណ្ហំ ទុក្ខជននំ ។ ២ ម. វិត្តំ ។ ឱ. វិទ្ធំ ។ ៣ ម. ចាបិ ។



(៤៦៦) (ព្រះពោធិ...) អ្នកប្រាជ្ញណា កំណត់ដឹងនូវតណ្ហា ដែលញុំាងសេចក្ដីទុក្ខឲ្យកើតឡើង អ្នកប្រាជ្ញនោះ គឺមាណពដ៏ប្រសើរ ដែលជាអ្នកដឹងនូវលោកទាំងមូលនេះទេតើ ។

ចប់ កាមជាតក ទី ៨ ។

## ជនសន្ធជាតក

(៤៦៧) (ព្រះសាស្ដាទ្រង់ត្រាស់ថា) ព្រះបាទជនសន្ធៈ ទ្រង់មានព្រះឱក្ដីថា បុគ្គលណាមិនបានធ្វើហេតុទាំង ១០ នេះ ទុកជាមុនទេ បុគ្គលនោះ តែងក្ដៅក្រហាយ ក្នុងកាលជាខាងក្រោយ ។
(៤៦៨) បុគ្គលមិនបានទ្រព្យ ដែលខ្លួនមិនបានឲ្យកើតឡើង ក្នុងកាលមុន រមែងក្ដៅក្រហាយ តែងក្ដៅក្រហាយរឿយ ៗ ក្នុងកាលជាខាងក្រោយថា អាត្មាអញមិនបានស្វែងរកទ្រព្យទុក ក្នុងកាលមុន ។
(៤៦៩) បុគ្គលតែងក្ដៅក្រហាយរឿយ ៗ ក្នុងកាលជាខាងក្រោយថា សិល្បៈជាគុណមានសភាពអង់អាច អាត្មាអញមិនបានរៀនទុក ក្នុងកាលមុន ការចិញ្ចឹមជីវិតនៃបុគ្គល អ្នកមិនមានសិល្បៈ លំបាក ។
(៤៧០) បុគ្គលតែងក្ដៅក្រហាយរឿយៗ ក្នុងកាលជាខាងក្រោយថា កាលពីដើម អាត្មាអញជាអ្នកចុះប្រែប្រួលក្នុងអំពើកោងផង ជាអ្នកញុះញង់ផង ស៊ីសាច់ខ្នងគេ គឺស៊ីសំណូកផង ជាអ្នកកាចផង អាក្រក់ផង ។

(៤៨១) បាណាតិបាតី បុរេ អាសី លុទ្ទោ ចាបិ(១) អនារិយោ
ភូតានំ នាបចាយិស្សំ(២) ឥតិ បច្ឆានុតប្បតិ ។
(៤៨២) ពហូសុ វត សន្តីសុ(៣) អនាបាទាសុ ឥត្ថីសុ
បរទារំ អាសេវិស្សំ ឥតិ បច្ឆានុតប្បតិ ។
(៤៨៣) ពហុម្ហិ វត សន្តម្ហិ អន្នបានេ ឧបដ្ឋិតេ
ន បុព្វេ អទទិំ ទានំ ឥតិ បច្ឆានុតប្បតិ
(៤៨៤) មាតរំ បិតរំ ចាបិ ជិណ្ណកេ គតយោព្វនេ(៤)
បហុ សន្តោ ន បោសិស្សំ ឥតិ បច្ឆានុតប្បតិ ។
(៤៨៥) អាចរិយមនុសត្ថារំ សព្វកាមរសាហរំ
បិតរំ អតិមញ្ញិស្សំ ឥតិ បច្ឆានុតប្បតិ ។
(៤៨៦) សមណេ ព្រាហ្មណេ ចាបិ សីលវន្តេ ពហុស្សុតេ
ន បុព្វេ បយិរុបាសិស្សំ ឥតិ បច្ឆានុតប្បតិ ។

---

១ ម. ចាសិ ។ ២ ម. នាបចាយិស្សំ ។ ម. ន បចាយិស្សំ ។ ៣ ម. សន្តាសុ ។
៤ ម. ជិណ្ណកំ គតយោព្វនំ ។



(៤៨១) បុគ្គលតែងក្តៅក្រហាយក្រោយ ។ គឺកាលជាខាងក្រោយថា កាលពីដើម អាត្មាអញ ជាអ្នកសំឡាប់សត្វផង កាចសាហាវផង ជាអ្នកមិនប្រសើរផង មិនកោតក្រែងចំពោះពួកសត្វផង ។

(៤៨២) បុគ្គលតែងក្តៅក្រហាយក្រោយ ។ គឺកាលជាខាងក្រោយថា អើហ្ន៎ កាលដែលពួកស្ត្រីមានច្រើនឥតគណនា ជាស្ត្រីមិនមានអត្ត-កយ (មិនមានគេកាន់កាប់សោះ) អាត្មាអញសេពនឹងប្រពន្ធគេ ។

(៤៨៣) បុគ្គលតែងក្តៅក្រហាយក្រោយ ។ គឺកាលជាខាងក្រោយថា អើហ្ន៎ កាលពីដើមអាត្មាអញមានបាយនិងទឹកច្រើនឥតគណនា តែមិនបានឲ្យទានសោះ ។

(៤៨៤) បុគ្គលតែងក្តៅក្រហាយក្រោយ ។ គឺកាលជាខាងក្រោយថា កាលអាត្មាអញ មានទ្រព្យច្រើន មិនបានចិញ្ចឹមមាតា និងបិតា ដែលចាស់ មានវ័យកន្លងហើយ ។

(៤៨៥) បុគ្គលតែងក្តៅក្រហាយក្រោយ ។ គឺកាលជាខាងក្រោយថា អាត្មាអញ បានមើលងាយបិតា ដែលជាអាចារ្យ អ្នកប្រៀនប្រដៅ ជាអ្នកនាំមកនូវរសគ្រប់យ៉ាង ។

(៤៨៦) បុគ្គលតែងក្តៅក្រហាយក្រោយ ។ គឺកាលជាខាងក្រោយថា គឺកាលមុន អាត្មាអញ មិនបានចូលទៅជិតពួកសមណៈនិងព្រាហ្មណ៍ អ្នកមានសីល ជាពហុស្សូតឡើយ ។

(៤៥៧) សាធុ ហោតិ តបោ ចិណ្ណោ សន្តោ ច បយិរុបាសិតោ
ន ច បុព្វេ តបោ ចិណ្ណោ ឥតិ បច្ឆានុតប្បតិ ។
(៤៥៨) យោ ច ញត្វាន ហិតានិ យោនិសោ បដិបជ្ជតិ
ករំ បុរិសកិច្ចានិ ស បច្ឆា នានុតប្បតីតិ ។

ជនសន្ធជាតកំ បញ្ចមំ ។

## មហាកណ្ហជាតកំ

(៤៥៩) កណ្ហោ កណ្ហោ ច ឃោរោ ច សុក្កទាឋោ បភា-
សក[១]
ពន្ធោ[២] បញ្ចហិ រជ្ជូហិ កឹ រវិ[៣] សុនខោ តវ ។
(៤៦០) នាយំ មិគានមត្ថាយ ឧសិន្នរ[៤] កវិស្សតិ
មនុស្សានំ អនយោ ហុត្វា តទា កណ្ហោ បមោក្ខតិ ។
(៤៦១) បត្តហត្ថា សមណកា មុណ្ឌា សង្ឃាដិបារុតា
នង្គលេហិ កសិស្សន្តិ តទា កណ្ហោ បមោក្ខតិ ។

១ ម. បភាសវា ។ ២ ម. ពទ្ធោ ។ ៣ ម. ធំ ។ ៤ ម. ឧសីនក ។ ៥ ម. ឧសីនកោ ។



(៤៥៧) បុគ្គលតែងក្ដៅក្រហាយរឿយៗ ក្នុងកាលជាខាងក្រោយថា តបៈ គឺសុចរិតធម៌ ដែលគេសន្សំហើយផង បុគ្គលអ្នកស្ងប់ដែលគេចូលទៅអង្គុយជិតផង ជាការប្រពៃ តបៈ (មានសភាពយ៉ាងនេះ) អាត្មាអញ មិនបានសន្សំហើយ ក្នុងកាលពីដើម ។
(៤៥៨) ចំណែកខាងបុគ្គលណា កាលធ្វើកិច្ច របស់បុរសទាំងឡាយ ហើយប្រតិបត្តិនូវហេតុទាំងនេះ ដោយឧបាយ បុគ្គលនោះ រមែងមិនក្ដៅក្រហាយរឿយៗ ក្នុងកាលជាខាងក្រោយឡើយ ។

ចប់ ជនសន្ធជាតក ទី ៥

## មហាកណ្ហជាតក

(៤៥៩ (ព្រះរាជា ត្រាស់សួរថា) ម្នាលអ្នកមានព្យាយាម ឆ្កែរបស់អ្នក ខ្មៅណាស់ គួរស្ញើម មានចង្កូមសល្អ អ្នកចងដោយខ្សែ ៥ កើតមានប្រយោជន៍អ្វីដល់អ្នក ។
(៤៦០) (សក្កទេវរាជពោលថា) បពិត្រព្រះបាទឧសិន្នរៈ ឆ្កែនេះ មិនមក ដើម្បីប្រយោជន៍ដល់ពួកម្រឹគទេ ឆ្កែខ្មៅនឹងបំផ្លាញ នូវពួកមនុស្ស ក្នុងកាលណា នឹងរួចទៅ (អំពីដៃខ្ញុំ) ក្នុងកាលនោះ ។
(៤៦១) ពួកសមណៈត្រងោល មានបាត្រក្នុងដៃ ឃ្លុំសង្ឃាដិ នឹងភ្ជួររាស់ ដោយនង្គ័លទាំងឡាយ (ក្នុងកាលណា) ឆ្កែខ្មៅ នឹងរួច (ស្ទុះទៅស៊ីនូវសមណៈទាំងនោះ) ក្នុងកាលនោះ ។

(៤៦២)តបស្សិនិយោ បព្វជិតា មុណ្ឌា សង្ឃាដិបារុតា
យទា លោកេ គមិស្សន្តិ តទា កណ្ហោ បមោក្ខតិ។

(៤៦៣)ទីឃុត្តរោដ្ឋា ជដិលា បង្កទន្តា រជស្សិរា
ឥណំ ចោទយ គច្ឆន្តិ តទា កណ្ហោ បមោក្ខតិ។

(៤៦៤)អធិច្ច វេទេ សាវិត្តឹ យញ្ញតន្តញ្ច ព្រាហ្មណា
ភតិកាយ យជិស្សន្តិ តទា កណ្ហោ បមោក្ខតិ។

(៤៦៥)មាតរំ បិតរំ ចាបិ ជិណ្ណកេ គតយោព្វនេ
បហុ សន្តា ន ភរន្តិ តទា កណ្ហោ បមោក្ខតិ។

(៤៦៦)មាតរំ បិតរំ ចាបិ ជិណ្ណកេ គតយោព្វនេ
ពាលា តុម្ហេតិ វក្ខន្តិ តទា កណ្ហោ បមោក្ខតិ។



(៤៦២) ពួកភិក្ខុនី មានតបៈ ជាអ្នកបួសកោរសក់ ឃ្លុំសង្ឃាដិ នឹងទៅ (បរិភោគកាម) ក្នុងលោក ក្នុងកាលណា ឆ្កែខ្មៅ នឹងរួច (សួរទៅស៊ីនូវនាងភិក្ខុនីទាំងនោះ) ក្នុងកាលនោះ ។

(៤៦៣) ពួកជដិល មានបបូរមាត់ខាងលើវែង មានធ្មេញប្រកបដោយមន្ទិល មានធូលីលើក្បាល នឹងទៅទារបំណុល (ក្នុងកាលណា) ឆ្កែខ្មៅ នឹងរួច(សួរទៅស៊ីនូវជដិលទាំងនោះ) ក្នុងកាលនោះ ។

(៤៦៤) ពួកព្រាហ្មណ៍ បានរៀនវេទទាំងឡាយផង សាវិត្តិសាស្ត្រផង យញ្ញសូត្រក្នុងសាវិត្តិសាស្ត្រនោះផង នឹងបូជាដើម្បីថ្លៃឈ្នួល (ក្នុងកាលណា) ឆ្កែខ្មៅ នឹងរួច (សួរទៅស៊ីនូវព្រាហ្មណ៍ទាំងនោះ) ក្នុងកាលនោះ ។

(៤៦៥) ពួកជន អ្នកមានទ្រព្យច្រើន នឹងមិនចិញ្ចឹមមាតាបិតា ដែលជរាមានវ័យកន្លងហើយ (ក្នុងកាលណា) ឆ្កែខ្មៅ នឹងរួច (សួរទៅស៊ីនូវជនអ្នកមានទ្រព្យទាំងនោះ) ក្នុងកាលនោះ ។

(៤៦៦) ពួកជន នឹងនិយាយទៅកាន់មាតាបិតា ដែលជរា មានវ័យកន្លងហើយថា អ្នកទាំងឡាយ ជាមនុស្សពាលផ្តេះ (ក្នុងកាលណា) ឆ្កែខ្មៅ នឹងរួច(សួរទៅស៊ីនូវជនទាំងនោះ)ក្នុងកាលនោះ ។

(៤៦៧)អាចរិយភរិយំ(១) សខឹ មាតុលានឹ បិតុច្ឆកឹ

យទា លោកេ គមិស្សន្តិ តទា កណ្ហោ បមោក្ខតិ ។

(៤៦៨)អសិចម្មំ គហេត្វាន ខគ្គំ បគ្គយ្ហ ព្រាហ្មណា

បន្ថឃាតំ ករិស្សន្តិ តទា កណ្ហោ បមោក្ខតិ ។

(៤៦៩)សុក្កច្ឆវី វេធវេរា ថូលពាហូ អបាតុភា

មិត្តភេទំ ករិស្សន្តិ តទា កណ្ហោ បមោក្ខតិ ។

(៤៧០)មាយាវិនោ នេកតិកា អសប្បុរិសចិន្តកា

យទា លោកេ ភវិស្សន្តិ តទា កណ្ហោ បមោក្ខតីតិ ។

មហាកណ្ហជាតកំ ឆដ្ឋំ ។

---

១ អាចរិយភរិយំ សខា – ភរិយំ មាតុលានីតិ អដ្ឋកថាយំ ទិស្សតិ ។



(៤៦៧) ពួកជនប្រព្រឹត្ត (សេវនកិច្ច) នឹងភរិយារបស់អាចារ្យ ភរិយារបស់សំឡាញ់ ម្ដាយធំ ម្ដាយមីងខាងម្ដាយ ម្ដាយធំ ម្ដាយមីងខាងឪពុក ក្នុងលោក ក្នុងកាលណា ខ្មៅនឹងរួច (ស្ទុះទៅស៊ីនូវជនទាំងនោះ) ក្នុងកាលនោះ ។

(៤៦៨) ពួកព្រាហ្មណ៍កាន់ដាវនឹងខែល ដកព្រះខាន់ ធ្វើនូវការសំឡាប់នូវអ្នកដំណើរ ក្នុងកាលណា ខ្មៅនឹងរួច (ស្ទុះទៅស៊ីនូវពួកព្រាហ្មណ៍ទាំងនោះ) ក្នុងកាលនោះ ។

(៤៦៩) ពួកបុរស មានស្បែកសម្បុរសស្អាត មានដើមដៃធំ មានកាយវិការមិនប្រាកដ មានគំនៀរនឹងស្ត្រីមេម៉ាយ នឹងធ្វើនូវការបំបែកមិត្រ(១) (ក្នុងកាលណា) ខ្មៅនឹងរួច (ស្ទុះទៅស៊ីនូវបុរសនោះ) ក្នុងកាលនោះ ។

(៤៧០) ពួកជនអ្នកមានមាយា ជាអ្នកបោកប្រាស មានគំនិតជាអសប្បុរស នឹងមានក្នុងលោក (ក្នុងកាលណា) ខ្មៅនឹងរួច (ស្ទុះទៅស៊ីនូវជនមានមាយាទាំងនោះ) ក្នុងកាលនោះ ។

ចប់ មហាកណ្ហជាតក ទី ៦ ។

---

១ ពួកអ្នកលេងតែងនាំទៅលេងស៊ីផឹក យកស្ត្រីមេម៉ាយអ្នកមានទ្រព្យ ចាយទ្រព្យអស់ ហើយ ក៏រឿងបំបែកលែងស្ត្រីនោះចោល ទៅរកស្ត្រីមេម៉ាយស្ដុកស្ដម្ភទៀត ។ តាមន័យក្នុងអដ្ឋកថា ។

# កោសិយជាតកំ

(៤៧១) នេវ កិណាមិ ន វិក្កិណាមិ
ន ចាបិ មេ សន្និចយោ ឥធត្ថិ(១)
សុកិច្ឆរូបំ វតិទំ បរិត្តំ
បត្ថោទនោ នាលមយំ ទុវិន្នំ ។

(៤៧២) អប្បម្ហា អប្បកំ ទជ្ជា(២) អនុមជ្ឈតោ មជ្ឈកំ
ពហុម្ហា ពហុកំ ទជ្ជា អទានំ នុបបជ្ជតិ ។
តំ តំ វទាមិ កោសិយ ទេហិ ទានានិ ភុញ្ជ ច
អរិយមគ្គំ សមារុហ នេកាសី(៣) លភតេ សុខំ ។

(៤៧៣) មោឃញ្ចស្ស ហុតំ ហោតិ មោឃញ្ចាបិ សមីហិតំ
អតិថិស្មឹ យោ និសិន្នស្មឹ ឯកោ ភុញ្ជតិ ភោជនំ ។
តំ តំ វទាមិ កោសិយ ទេហិ ទានានិ ភុញ្ជ ច
អរិយមគ្គំ សមារុហ នេកាសី លភតេ សុខំ ។

---

១ ម. ចត្ថិ ។ ២ ម. ទជ្ជំ ។ ៣ ម. នេកាសិ ។



# កោសិយជាតក

(៤៧១) (កោសិយសេដ្ឋី ពោលថា) ខ្ញុំមិនទិញ មិនលក់ទេ មួយទៀត ការសន្សំ (ទ្រព្យ) របស់ខ្ញុំ ក៏មិនមានក្នុងទីនេះដែរ ព្រោះនេះតិច មានសភាពក្រក្រៃពេក ព្រោះអង្ករ ១ កំបង់នេះ មិនល្មមដល់ជនពីរនាក់ទេ ។

(៤៧២) (សក្កទេវរាជពោលថា) បុគ្គលគប្បីឲ្យវត្ថុតិច អំពីវត្ថុតិច គប្បីឲ្យវត្ថុពាក់កណ្ដាល អំពីវត្ថុពាក់កណ្ដាល គប្បីឲ្យវត្ថុច្រើន អំពីវត្ថុច្រើន ការមិនឲ្យ មិនកើតទេ ។ ម្នាលកោសិយសេដ្ឋី ហេតុនោះ ខ្ញុំសូមនិយាយនឹងអ្នក អ្នកចូរឲ្យទានផង ចូរបរិភោគផង ចូរឡើងកាន់អរិយមគ្គផង បុគ្គលស៊ីម្នាក់ឯង មិនបានសេចក្ដីសុខទេ ។

(៤៧៣) (ចន្ទទេវបុត្រ ពោលថា) បុគ្គលណា កាលដែលភ្ញៀវអង្គុយហើយ បរិភោគភោជនតែម្នាក់ឯង ការបូជារបស់បុគ្គលនោះឈ្មោះថា ឥតអំពើផង ការព្យាយាមញុំាងទ្រព្យឲ្យកើតរបស់បុគ្គលនោះឈ្មោះថា ឥតអំពើផង ។ ម្នាលកោសិយសេដ្ឋី ហេតុនោះ ខ្ញុំសូមនិយាយនឹងអ្នក អ្នកចូរឲ្យទានផង ចូរបរិភោគផង ចូរឡើងកាន់អរិយមគ្គផង បុគ្គលស៊ីម្នាក់ឯង មិនបានសេចក្ដីសុខទេ ។

(៤៧៦)សច្ចញ្ចស្ស ហុតំ ហោតិ សច្ចញ្ចាបិ សមីហិតំ

អតិថិស្មឹ យោ និសិន្នស្មឹ នេកោ ភុញ្ជតិ ភោជនំ។

តំ តំ វទាមិ កោសិយ ទេហិ ទានានិ ភុញ្ជ ច

អរិយមគ្គំ សមារុហ នេកាសី លភតេ សុខំ។

(៤៧៧)សតញ្ច ជុហតិ ហោមោ ពហុកាយ គយាយ ច

ទោណេ តិម្ពរុតិត្ថស្មឹ សីឃសោតេ មហាវហេ។

អត្រ ចស្ស ហុតំ ហោតិ អត្រ ចស្ស សមីហិតំ

អតិថិស្មឹ យោ និសិន្នស្មឹ នេកោ ភុញ្ជតិ ភោជនំ។

តំ តំ វទាមិ កោសិយ ទេហិ ទានានិ ភុញ្ជ ច

អរិយមគ្គំ សមារុហ នេកាសី លភតេ សុខំ។



(៤៧៦) (សុរិយទេវបុត្រ ពោលថា) បុគ្គលណា កាលដែលភ្ញៀវអង្គុយហើយ មិនបរិភោគភោជនតែម្នាក់ឯង ការបូជារបស់បុគ្គលនោះ ឈ្មោះថា សច្ចៈផង ការព្យាយាមញ៉ាំងទ្រព្យឲ្យកើត របស់បុគ្គលនោះ ឈ្មោះថា សច្ចៈផង ។ ម្នាលកោសិយសេដ្ឋី ហេតុនោះ ខ្ញុំសូមនិយាយនឹងអ្នក អ្នកចូរឲ្យទានទាំងឡាយផង ចូរបរិភោគផង ចូរឡើងកាន់អរិយមគ្គផង បុគ្គលស៊ីម្នាក់ឯង មិនបានសេចក្តីសុខទេ ។

(៤៧៧) (មាតលិទេវបុត្រ ពោលថា) បុរស(ក្នុងលោក) ស្រះហើយបូជា ក្នុងទន្លេផង ក្នុងស្រះបោក្ខរណីផង ក្នុងកំពង់ឈ្មោះទោណៈផង ក្នុងកំពង់ ឈ្មោះតិម្ពរុផង ក្នុងស្ទឹងដ៏មានខ្សែទឹក ដ៏រហ័សផង ។ បុគ្គលណា កាលដែលភ្ញៀវអង្គុយហើយ មិនបរិភោគភោជនតែម្នាក់ឯង ការបូជារបស់បុគ្គលនោះ ឈ្មោះថា មានក្នុងទីនោះផង ការព្យាយាមញ៉ាំងទ្រព្យឲ្យកើតរបស់បុគ្គលនោះ ឈ្មោះថា មានក្នុងទីនោះផង ។ ម្នាលកោសិយសេដ្ឋី ហេតុនោះ ខ្ញុំសូមនិយាយនឹងអ្នក អ្នកចូរឲ្យទានទាំងឡាយផង ចូរបរិភោគផង ចូរឡើងកាន់អរិយមគ្គផង បុគ្គលស៊ីម្នាក់ឯង មិនបានសេចក្តីសុខទេ ។

(៤៣៦)ពឡិសំ ហិ សោ និគិលតិ ទីឃសុត្តំ សបច្ចគំ
អតិថិស្មឹ យោ និសិន្នស្មឹ ឯកោ ភុញ្ជតិ ភោជនំ។
តំ តំ វទាមិ កោសិយ ទេហិ ទានានិ ភុញ្ជ ច
អរិយមគ្គំ សមារុហ នេកាសី លភតេ សុខំ។

(៤៣៧) ឧឡារវណ្ណា វត ព្រាហ្មណា ឥមេ
អយញ្ច វោ សុនខោ កិស្ស ហេតុ
ឧច្ចាវចំ វណ្ណនិភំ វិកុព្វតិ
អក្ខាថ នោ ព្រាហ្មណា កេ នុ តុម្ហេ ។

(៤៣៨) ចន្ទោ ច សុរិយោ ច ឧភោ ឥធាគតា
អយំ បន មាតលិ ទេវសារថិ
សក្កោហមស្មិ តិទសានមិន្ទោ
ឯសោ ច ខោ បញ្ចសិខោតិ វុច្ចតិ ។

(៤៣៩)បាណិស្សរា មុទិង្គា ច មុរជាលម្ពរានិ ច
សុត្តមេនំ បពោធេន្តិ បដិពុទ្ធោ ច នន្ទតិ ។



(៤៣៦) (បញ្ចសិខទេវបុត្រ ពោលថា) បុគ្គលណា កាលដែលភ្ញៀវអង្គុយហើយ បរិភោគភោជនតែម្នាក់ឯង បុគ្គលនោះឈ្មោះថា លេបនូវសន្ទូចមានខ្សែវែង ព្រមទាំងនុយផង ។ ម្នាលកោសិយសេដ្ឋី ហេតុនោះ ខ្ញុំសូមនិយាយនឹងអ្នក អ្នកចូរឲ្យទានទាំងឡាយផង ចូរបរិភោគផង ចូរឡើងកាន់អរិយមគ្គផង បុគ្គលស៊ីម្នាក់ឯង មិនបានសេចក្ដីសុខទេ ។

(៤៣៧) (កោសិយសេដ្ឋី...) ឧហ៎ ព្រាហ្មណ៍ទាំងនេះ មានវណ្ណៈដ៏លើសលុប ទាំងឆ្កែរបស់អ្នកទាំងនេះ ក៏បញ្ចេញនូវពន្លឺនៃវណ្ណៈផ្សេងៗ តើព្រោះហេតុអ្វី ម្នាលព្រាហ្មណ៍ទាំងឡាយ អ្នកទាំងឡាយ ចូរប្រាប់ដល់យើងចុះ តើអ្នកជាអ្វី ។

(៤៣៨) (សក្កទេវរាជ...) ទេវបុត្រទាំងពីរគឺ ចន្ទទេវបុត្រ ១ សុរិយទេវបុត្រ ១ មកក្នុងទីនេះ ឯទេវបុត្រនេះ ឈ្មោះមាតលិ ជាសារថីរបស់ទេវតា យើងឈ្មោះសក្កៈ ជាធំជាងពួកទេវតាជាន់ត្រៃត្រិង្ស ឯទេវបុត្រនេះ គេហៅថា បញ្ចសិខៈ ។

(៤៣៩) សំឡេងទះដៃទាំងឡាយផង សម្ភោរតូចទាំងឡាយផង សម្ភោរធំនិងស្គរធំទាំងឡាយផង រមែងញុំាងបញ្ចសិខទេវបុត្រនេះ ដែលដេកលក់ឲ្យភ្ញាក់ឡើង ឯបញ្ចសិខទេវបុត្រនេះ លុះភ្ញាក់ហើយក៏ត្រេកអរ ។

(៤៨០) យេ កេចិមេ មច្ឆរិនោ(១) កទរិយា
បរិភាសកា សមណព្រាហ្មណានំ
ឥធេវ និក្ខិប្ប សរីរទេហំ
កាយស្ស ភេទា និរយំ វជន្តិ ។

(៤៨១) យេ កេចិមេ សុគតិមាសមានា
ធម្មេ ឋិតា សំយមេ សំវិភាគេ
ឥធេវ និក្ខិប្ប សរីរទេហំ
កាយស្ស ភេទា សុគតឹ វជន្តិ ។

(៤៨២) ត្វំ នោ ញាតិ បុរិមាសុ ជាតិសុ
សោ មច្ឆរី កោសិយោ បាបធម្មោ
តវេវ អត្ថាយ ឥធាគតម្ហា
មា បាបធម្មោ និរយំ អបត្ថ(២) ។

(៣)

(៤៨៣) អទ្ធា ហិ មេ តេ ហិតកាមា យំ មំ សមនុសាសថ
សោហំ តថា ករិស្សាមិ សព្វំ វុត្តំ ហិតេសិភិ ។

---

១ ម. មច្ឆរិយោ ។ ២ ម. គមិត្ថ ។ ៣ ម. ទំ ពេ ។



(៤៨០) ពួកជនណានីមួយ ជាអ្នកកំណាញ់ស្វិតស្វាញ ប្រទេចផ្ដាសានូវសមណៈនិងព្រាហ្មណ៍ទាំងឡាយ លុះទំលាក់ចោលនូវកាយ គឺសរីរៈ ក្នុងលោកនេះ បែកធ្លាយនៃកាយហើយ ក៏ទៅកាន់នរក ។

(៤៨១) ពួកជនណានីមួយ កាលប្រាថ្នានូវសុគតិ ឋិតនៅក្នុងធម៌ ក្នុងសេចក្ដីសង្រួម ក្នុងការចែករំលែក លុះទំលាក់ចោលនូវកាយ គឺសរីរៈ ក្នុងលោកនេះ បែកធ្លាយនៃកាយហើយ ក៏ទៅកាន់សុគតិ ។

(៤៨២) អ្នកជាញាតិ របស់ពួកយើង ក្នុងជាតិមុន អ្នកនោះឈ្មោះកោសិយៈ ជាអ្នកមានសេចក្ដីកំណាញ់ មានធម៌ដ៏លាមក ពួកយើងមកក្នុងទីនេះ ដើម្បីប្រយោជន៍ដល់អ្នក (ដោយគិតថា) កុំឲ្យអ្នកមានធម៌ដ៏លាមក ទៅកាន់នរកឡើយ ។

(៤៨៣) (កោសិយសេដ្ឋី...) ពួកលោកឈ្មោះថា ប្រាថ្នានូវប្រយោជន៍ដល់ខ្ញុំដោយពិត ព្រោះពួកលោក ពុនប្រៀនប្រដៅខ្ញុំ ខ្ញុំនោះ នឹងធ្វើតាមពាក្យ ទាំងអស់ ដែលពួកលោកជាអ្នកប្រាថ្នា នូវប្រយោជន៍ បានពោល (លើក)ហើយ ដោយបការៈដូច្នោះ ។

ឯសាហមជ្ជ ឧបរមាមិ
ន ចាបាហំ កិញ្ចិ ករេយ្យ បាបំ
ន ចាបិ មេ កិញ្ចិ អទេយ្យមត្ថិ
ន ចាបិទត្វា ឧទកំ បិវាមិ ។
ឯវញ្ច មេ ទទតោ សព្វកាលំ
ភោគា ឥមេ វាសវ ខីយិស្សន្តិ
តតោ អហំ បព្វជិស្សាមិ សក្ក
ហិត្វាន កាមានិ យថោធិកានិ ។

កោសិយជាតកំ សត្តមំ ។

## មេណ្ឌកបញ្ហជាតកំ

(៩៨៦) យេសំ ន កទាចិ ភូតបុព្វំ
សខ្យំ សត្តបទម្បិ ឥមស្មឹ លោកេ
ជាតា អមិត្តា ទុវេ សហាយា
បដិសន្ធាយ ចរន្តិ កិស្ស ហេតុ ។



ខ្ញុំនេះទើបនឹងវៀរលែង (ចាកសេចក្តីកំណាញ់) នេះឯង ខ្ញុំនឹងឈប់ធ្វើបាបកម្មបន្តិចហើយ ទាំងវត្ថុតិចតួចដែលខ្ញុំមិនគប្បីឲ្យមិនមាន ខ្ញុំបើមិនបានឲ្យទានទឹក នឹងមិនផឹកឡើយ ។ បពិត្រសក្កៈ កាលបើខ្ញុំឲ្យទាន អស់កាលទាំងពួងយ៉ាងនេះ ភោគៈទាំងឡាយគង់តែនឹងអស់ទៅ បពិត្រសក្កៈ តពីនោះទៅ ខ្ញុំនឹងលះបង់កាមទាំងឡាយ តាមសមគួរ ដល់ចំណែកហើយនឹងបួស ។

ចប់ កោសិយជាតក ទី ៧ ។

## មេណ្ឌកបញ្ហជាតក

(៩៨៦) (ព្រះបាទវិទេហរាជ ទ្រង់ត្រាស់សួរពួកអ្នកប្រាជ្ញថា) តាំងពីកាលណាមកក្នុងលោកនេះ មិនធ្លាប់មានពួកសត្វណាមានជើង ៧(១) យកគ្នាជាសំឡាញ់ឡើយ សត្វទាំងពីរនោះជាសត្រូវនឹងគ្នា (ឥឡូវ) ត្រឡប់ជាយកគ្នាធ្វើជាសំឡាញ់ ប្រព្រឹត្តកប់គាត់គ្នា តើព្រោះហេតុដូចម្តេច ។

---

(១) ពាក្យនិទ្ទេស សត្វទាំងពីរនេះមានជើងបួន ៗ តែផ្ទួនជើងមួយ ។

(៤៨៥) យទិ មេ អជ្ជ បាតរាសកាលេ
បញ្ហំ ន សក្កុណាថ(១) វត្តុមេតំ
រដ្ឋា បព្វាជយិស្សាមិ វោ សព្វេ
ន ហិ មមត្ថោ ទុប្បញ្ញជាតិកេហិ ។

(៤៨៦) មហាជនសមាគមម្ហិ ឃោរេ
ជនកោលាហលសង្គមម្ហិ ជាតេ
វិក្ខិត្តមនា អនេកចិត្តា
បញ្ហំ ន សក្កុណោម វត្តុមេតំ ។

(៤៨៧) ឯកគ្គចិត្តាវ ឯកតោ
រហសិ គតា អត្ថំ និចិន្តយិត្វា
បវិវេកេ សម្មសិត្វាន ធីរា
អថ វក្ខន្តិ ជនិន្ទ ឯតមត្ថំ ។

(៤៨៨) ឧគ្គបុត្តរាជបុត្តិយានំ
ឧរត្តម្មំសំ(២) បិយំ មនាបំ
ន តេ សុនខស្ស អទេន្តិ មំសំ
អថ មេណ្ឌស្ស សុណេន សខ្យមស្ស ។

១ ឱ. សក្កុណេយ្យាថ ។ ២ ឱ. ឧរត្តស្ស មំសំ ។



(៤៨៥) ប្រសិនបើអ្នកទាំងឡាយ មិនអាចដោះប្រស្នារបស់យើងនុះ ក្នុងពេលបាយព្រឹក ក្នុងថ្ងៃនេះបានទេ យើងនឹងបំបរបង់អ្នកទាំងអស់គ្នាអំពីដែន ព្រោះយើងមិនត្រូវការនឹងពួកមនុស្សឥតប្រាជ្ញាឡើយ ។

(៤៨៦) (អាចារ្យសេនកៈ ថែរមើលទៅពោធិសត្វ ហើយក្រាបទូលព្រះបាទវិទេហក្សត្រ) កាលបើមានការប្រជុំនៃមហាជន គគ្រឹកគគ្រេង កាលបើមានការជួបជុំដើម្បីជួលនៃជន កើតឡើងហើយ (យ៉ាងនេះ) យើងខ្ញុំមានចិត្តរវើរវាយ មានចិត្តមិននឹងនៅ ក្នុងអារម្មណ៍តែមួយ មិនអាចឆ្លើយប្រស្នានុះបានទេ ។

(៤៨៧) បពិត្រព្រះបាទជនិន្ទ្រាធិរាជ អ្នកប្រាជ្ញទាំងឡាយ ម្នាក់ៗ មានចិត្តតាំងនៅ ក្នុងអារម្មណ៍តែមួយ នៅក្នុងទីស្ងាត់ហើយ គិតនូវសេចក្តីទាំងឡាយ ពិចារណានូវកាយវិវេក នឹងចិត្តវិវេក ទើបក្រាបទូលសេចក្តីនុះ ក្នុងកាលជាខាងក្រោយបាន ។

(៤៨៨) (អាចារ្យសេនកៈ ក្រាបទូលថា) សាច់ពពែ ជាទីពេញចិត្ត ជាទីគាប់ចិត្ត របស់ពួកអាមាត្យ នឹងព្រះរាជបុត្រទាំងឡាយ ពួកអាមាត្យ នឹងព្រះរាជបុត្រទាំងនោះ មិនបរិភោគសាច់ឆ្កែទេ បានជាពពែនឹងឆ្កែយកគ្នាជាសំឡាញ់ ។

(៤៨៩) ចម្មំ វិហនន្តិ ឯឡកស្ស
អស្សបិដ្ឋត្ថរណំ សុខស្ស[១] ហេតុ
ន ច តេ សុនខស្ស អត្ថរន្តិ
អថ មេណ្ឌស្ស សុណេន សខ្យមស្ស ។

(៤៩០) អាវេល្លិតសិង្គិកោ ហិ មេណ្ឌោ
ន ច សុនខស្ស វិសាណកានិ អត្ថិ
តិណភក្ខោ មំសភោជនោ ច
អថ មេណ្ឌស្ស សុណេន សខ្យមស្ស ។

(៤៩១) តិណមាសិ បលាសមាសិ មេណ្ឌោ
ន ច សុណោ តិណមាសិ នោ បលាសំ
គណ្ហេយ្យ សុណោ សសំ ពិឡារំ
អថ មេណ្ឌស្ស សុណេន សខ្យមស្ស ។

(៤៩២) អឌ្ឍបលោ ចតុប្បទស្ស
មេណ្ឌោ អដ្ឋនខោ អទិស្សមានោ
ឆាទិយំ អាហរតិ អយំ ឥមស្ស
មំសំ អាហរតិ អយំ អមុស្ស ។

---

១ ម. អស្សបិដ្ឋត្ថរស្សុខស្ស ។



(៤៨៩) (អាចារ្យបុក្កុសៈ ទូលថា) ពួកជនតែងពន្លះ ស្បែកពពែសម្រាប់ក្រាលលើខ្នងសេះ ព្រោះហេតុចង់ឲ្យស្រួល តែពួកជនទាំងនោះ មិនក្រាលស្បែកឆ្កែទេ បានជាពពែនិងឆ្កែ យកគ្នាជាសម្លាញ់ ។

(៤៩០) (អាចារ្យកាមិន្ទ ទូលថា) ពពែមានស្នែងជាវង្វង់ ឯឆ្កែគ្មានស្នែងទេ ពពែស៊ីស្មៅ ឆ្កែស៊ីសាច់ បានជាពពែនិងឆ្កែយកគ្នាជាសម្លាញ់ ។

(៤៩១) (អាចារ្យទេវិន្ទ ទូលថា) ពពែស៊ីស្មៅ ស៊ីស្លឹកឈើ ឯឆ្កែមិនស៊ីស្មៅ មិនស៊ីស្លឹកឈើទេ ឆ្កែចាំតែចាប់ទន្សាយនឹងសំពោច បានជាពពែនិងឆ្កែ យកគ្នាជាសម្លាញ់ ។

(៤៩២) (ព្រះមហោសថទូលថា) សត្វជើង ៣ កន្លះ គឺឆ្កែមានជើងបីកន្លះ ពពែមានជើង ៤ មានក្រចក ៨ បន្ទំលួចសាច់ ឯឆ្កែនេះលួច (ស្មៅ) ឲ្យពពែនេះ ពពែនេះលួចសាច់ឲ្យឆ្កែឯនោះ ។

(៤៤៣) បាសាទវរគតោ វិទេហសេដ្ឋោ
វីតិហារំ អញ្ញោញ្ញភោជនានំ
អទ្ទស កិរ សក្ខិតំ ជនិន្ទោ
ពុភុក្ខស្ស បុណ្ណមុខស្ស ចេតំ ។

(៤៤៤) លាភា វត មេ អនប្បរូបា
យស្ស មេ ឯទិសា បណ្ឌិតា កុលម្ហិ
បញ្ហស្ស គម្ភីរគតំ និបុណមត្ថំ
បដិវិជ្ឈន្តិ សុភាសិតេន ធីរា ។

(៤៤៥) អស្សតរីរថញ្ច ឯកមេកំ
ផីតំ គាមវរញ្ច ឯកមេកំ
សព្វេសំ វោ ទម្មិ បណ្ឌិតានំ
បរមប្បតីតមនោ សុភាសិតេនាតិ ។

មេណ្ឌកបញ្ហជាតកំ អដ្ឋមំ ។

## មហាបទុមជាតកំ

(៤៤៦) នាទិដ្ឋា បរតោ ទោសំ អណុំថូលានិ សព្វសោ
ឥស្សរោ បណយេ ទណ្ឌំ សាមំ អប្បដិវេក្ខិយ ។



(៤៤៣) ឮថា ព្រះបាទវិទេហរាជ ជាស្តេចដ៏ប្រសើរ ជាធំជាងជន ស្តេចគង់នៅលើប្រាសាទដ៏ប្រសើរ ទ្រង់ទតឃើញជាក់ច្បាស់នូវការផ្លាស់ប្តូរភោជនដល់គ្នានឹងគ្នា របស់ឆ្កែនឹងពពែដែលដើរទៅលួចអាហារពេញមាត់មកឲ្យគ្នាបរិភោគ ។

(៤៤៤) (ព្រះបាទវិទេហរាជ ទ្រង់មានព្រះរាជឱង្ការថា) យើងបានពេញជាមានលាភ មានសភាពមិនតិចទេ ព្រោះអ្នកប្រាជ្ញទាំងឡាយបែបនេះ មាននៅក្នុងត្រកូលរបស់យើង អ្នកប្រាជ្ញទាំងនេះយល់នូវប្រស្នា ដ៏ជ្រាលជ្រៅល្អិត ដោយសុភាសិតបាន ។

(៤៤៥) យើងមានចិត្តត្រេកអរ ដ៏ក្រៃលែង យើងឲ្យរទេះអស្សតរ នឹងរថមួយ ៗ ម្នាក់ ឲ្យស្រុកល្អដែលបរិបូណ៌មួយ ៗ ម្នាក់ ដល់អ្នកទាំងអស់គ្នា ជាអ្នកប្រាជ្ញ ព្រោះសុភាសិត ។

ចប់ មេណ្ឌកបញ្ហាជាតក ទី ៨ ។

## មហាបទុមជាតក

(៤៤៦) (ពួកជនក្រាបទូលថា) ព្រះរាជាជាឥស្សរៈ បើមិនទាន់ឃើញទោសតូចធំ ដោយសព្វគ្រប់ អំពីសំណាក់បុគ្គលដទៃ ទាំងមិនទាន់ពិចារណាឲ្យឃើញច្បាស់ដោយខ្លួនឯងទេ មិនគប្បីដាក់អាជ្ញាឡើយ ។

(៩៩៧) យោ ច អប្បដិវេក្ខិត្វា ទណ្ឌំ កុព្វតិ ខត្តិយោ
សកណ្ដកំ សោ គិលតិ ជច្ចន្ធោវ សមក្ខិកំ ។

(៩៩៨) អទណ្ឌិយំ ទណ្ឌយតិ ទណ្ឌិយញ្ច អទណ្ឌិយំ
អន្ធោវ វិសមំ មគ្គំ ន ជានាតិ សមាសមំ ។

(៩៩៩) យោ ច ឯតានិ ឋានានិ អណុំថូលានិ សព្វសោ
សុទិដ្ឋមនុសាសេយ្យ ស វេ វោហរិតុមរហតិ ។

(១០០០) នេកន្តមុទុនា សក្កា ឯកន្តតិខិណេន វា
អត្តំ មហន្តេ ឋបេតុំ តស្មា ឧភយមាចរេ ។

(១០០១) បរិភូតោ មុទុ ហោតិ អតិតិក្ខោ ច វេរវា
ឯតញ្ច ឧភយំ ញត្វា អនុមជ្ឈំ សមាចរេ ។



(៩៩៧) បើក្សត្រិយ៍ណា មិនពិចារណា ហើយធ្វើអាជ្ញា ក្សត្រិយ៍នោះ ឈ្មោះថា លេបភោជន ប្រកបដោយបន្លា ប្រកបដោយរុយ ដូចជាមនុស្សខ្វាក់ ។

(៩៩៨) ព្រះរាជាណា ដាក់អាជ្ញាដល់បុគ្គល ដែលមិនគួរដាក់អាជ្ញា មិនដាក់អាជ្ញាដល់បុគ្គល ដែលគួរដាក់អាជ្ញា ព្រះរាជានោះឈ្មោះថា មិនដឹងការស្មើនឹងមិនស្មើ ដូចជាមនុស្សខ្វាក់ ដើរតាមផ្លូវមិនរាបស្មើ ។

(៩៩៩) ព្រះរាជាណា ឃើញនូវហេតុទាំងឡាយតូចនិងធំនុ៎ះ ដោយសព្វគ្រប់ ជាហេតុដែលឃើញត្រឹមត្រូវហើយ សឹមប្រៀនប្រដៅ ព្រះរាជានោះ ទើបគួរហៅថា ព្រះរាជាបាន ។

(១០០០) ព្រះរាជា ដែលមានព្រះទ័យទន់ពេក មានព្រះទ័យរឹងពេក ក៏មិនអាចតាំងខ្លួន ក្នុងភាពជាធំបានទេ ហេតុនោះ ព្រះរាជាគួរប្រព្រឹត្តនូវហេតុទាំងពីរ ។

(១០០១) (ព្រោះ) ព្រះរាជា ដែលមានព្រះទ័យទន់ ត្រូវពួកគេមើលងាយ ឯព្រះរាជាមានព្រះទ័យរឹងពេក រមែងមានពៀរ ព្រះរាជា ជ្រាបហេតុទាំងពីរនោះហើយ គួរប្រព្រឹត្តជាកណ្តាល ។

(១០០២) ពហុម្បិ រត្តា ភាសេយ្យ ទុដ្ឋាបិ ពហុ ភាសតិ

ន ឥត្ថីការណា រាជ បុត្តំ ឃាតេតុមរហសិ ។

(១០០៣) សព្វោវ លោកោ ឯកតោ ឥត្ថី ច អយមេកិកា

តេនាហំ បដិបជ្ជិស្សំ គច្ឆ បក្ខិបថេវ តំ ។

(១០០៤) អនេកតាលេ នរកេ គម្ភីរេ ច សុទុត្តរេ

បាតិតោ គិរិទុគ្គស្មឹ កេន ត្វំ តត្ថ នាមរិ ។

(១០០៥) នាគោ ជាតផណោ តត្ថ ថាមវា គិរិសានុជោ

បច្ចគ្គហិ មំ ភោគេហិ តេនាហំ តត្ថ នាមរឹ ។

(១០០៦) ឯហិ តំ បដិនេស្សាមិ រាជបុត្ត សកំ ឃរំ

រជ្ជំ ការេហិ ភទ្ទន្តេ កឹ អរញ្ញេ ករិស្សសិ ។



(១០០២) បុគ្គលត្រេកអរហើយ និយាយច្រើនក៏មាន បុគ្គលខឹងហើយ និយាយច្រើនក៏មាន បពិត្រមហារាជ ព្រះអង្គមិនគួរសម្លាប់ព្រះរាជបុត្រ ព្រោះហេតុតែស្ត្រីទេ ។

(១០០៣) (ព្រះរាជា...) មនុស្សលោកទាំងអស់ (ជាបក្សពួកនៃកុមារ) ឯស្ត្រីនេះតែម្នាក់ឯងទេ ព្រោះហេតុនោះ យើងនឹងប្រតិបត្តិ (តាមពាក្យនាងនេះវិញ) អ្នកឯងចូរទៅទម្លាក់ (កូនប្រុសនេះទៅ) ។

(១០០៤) យើងជាបិតា បានឲ្យគេយកកូនឯង ទៅបោះក្នុងជ្រោះភ្នំ ដ៏ជ្រៅ ច្រើនជួរត្នោត មិនងាយនឹងឡើងមកបានទេ ហេតុអ្វីបានជាកូនឯង មិនស្លាប់ក្នុងជ្រោះនោះ ។

(១០០៥) (មហាបទុមតាបសថា...) ក្នុងវេលានោះ នាគរាជ មានកំឡាំង ដ៏ខ្លាំងក្លៃ អាស្រ័យនៅទីជិតភ្នំ បានទទួលទ្រអាត្មាភាព ដោយភេន ពាំនខ្លួន ហេតុនោះបានជាអាត្មាភាពមិនស្លាប់ ក្នុងជ្រោះនោះ ។

(១០០៦) (ព្រះរាជា...) ម្នាលរាជបុត្រ សូមលោកនិមន្តមក យើងនឹងនាំលោកទៅកាន់ផ្ទះរបស់ខ្លួនវិញ ម្នាលលោកដ៏ចំរើន សូមលោកគ្រប់គ្រងរាជសម្បត្តិចុះ លោកនៅធ្វើអ្វី ក្នុងព្រៃ ។

(១០០៧) យថា គិលិត្វា ពលិសំ ឧទ្ធរេយ្យ សលោហិតំ
ឧទ្ធរិត្វា សុខី អស្ស ឯវំ បស្សាមិ អត្តនា(១) ។

(១០០៨) កោ នុ ត្វំ ពលិសំ ព្រូសិ កោ ត្វំ ព្រូសិ សលោហិតំ
កោ នុ ត្វំ ឧទ្ធដំ ព្រូសិ តំ មេ អក្ខាហិ បុច្ឆិតោ ។

(១០០៩) កាមាហំ ពលិសំ ព្រូមិ ហត្ថិអស្សំ សលោហិតំ
ចត្តាហំ ឧទ្ធដំ ព្រូមិ ឯវំ ជានាហិ ខត្តិយ ។

(១០១០) ចិញ្ចមាណវិកា មាតា ទេវទត្តោ ច មេ បិតា
អានន្ទោ បណ្ឌិតោ នាគោ សារីបុត្តោ ច ទេវតា
អហំ តទា រាជបុត្តោ ឯវំ ធារេថ ជាតកន្តិ ។

មហាបទុមជាតកំ នវមំ ។

---

(១) ម. ឆ. សុខំ បស្សាមិ អត្តនំ ។



(១០០៧) (មហាបទុមកុមារ...) បុគ្គលលេបផ្លែសន្ទូច ហើយទាញចេញមក លុះទាញចេញមក ព្រមទាំងឈាម គប្បីជាសុខយ៉ាងណា អាត្មាភាពឃើញច្បាស់ ដោយខ្លួនឯង ក៏យ៉ាងនោះដែរ ។

(១០០៨) (ព្រះរាជា...) លោកពោលថា អ្វីជាផ្លែសន្ទូច លោកពោលថា អ្វីជាឈាម លោកពោលថា អ្វីទាញចេញមក កាលបើយើងសួរហើយ លោកចូរប្រាប់រឿងនោះ ។

(១០០៩) (មហាបទុមកុមារ...) អាត្មាភាព ពោលនូវកាមថា ជាផ្លែសន្ទូច ពោលនូវដំរីនិងសេះថា ជាឈាម ពោលនូវការលះ ពោលថា ជាគ្រឿងទាញចេញមក បពិត្រក្សត្រិយ៍ សូមព្រះអង្គជ្រាបយ៉ាងនេះចុះ ។

(១០១០) (ប្រជុំជាតក) មាតាចុងនៃតថាគត គឺនាងចិញ្ចមាណវិកា បិតានៃតថាគត គឺទេវទត្ត នាគរាជ គឺអានន្ទជាអ្នកប្រាជ្ញ ទេវតា គឺសារីបុត្រ រាជបុត្រ ក្នុងកាលនោះ គឺតថាគត អ្នកទាំងឡាយចូរចាំទុកនូវជាតក ដោយប្រការយ៉ាងនេះចុះ ។

ចប់ មហាបទុមជាតក ទី ៩ ។

# មិត្តាមិត្តជាតកំ

(១០១១)កានិ កម្មានិ កុព្វានំ កថំ វិញ្ញូ បរក្កមេ
អមិត្តំ ជានេយ្យ មេធាវី ទិស្វា សុត្វា ច បណ្ឌិតោ។
(១០១២)ន នំ ឧម្ហយតេ ទិស្វា ន ច នំ បដិនន្ទតិ
ចក្ខូនិ ចស្ស ន ទទាតិ បដិលោមញ្ច វត្តតិ ។
(១០១៣)អមិត្តេ តស្ស ភជតិ មិត្តេ តស្ស ន សេវតិ
វណ្ណកាមេ និវារេតិ អក្កោសន្តេ បសំសតិ។
(១០១៤)គុយ្ហញ្ច តស្ស នក្ខាតិ តស្ស គុយ្ហំ ន គូហតិ
កម្មំ តស្ស ន វណ្ណេតិ បញ្ញស្ស នប្បសំសតិ ។
(១០១៥)អភវេ នន្ទតិ តស្ស ភវេ តស្ស ន នន្ទតិ
អច្ឆរិយំ ភោជនំ លទ្ធា តស្ស នុប្បជ្ជតេ សតិ
តតោ នំ នានុកម្បតិ អហោ សោបិ លភេយ្យិតោ។



# មិត្តាមិត្តជាតក

(១០១១) (ព្រះបាទព្រហ្មទត្ត សួរមហាសត្វថា) បណ្ឌិតអ្នកមានប្រាជ្ញា ឃើញ ឬ ឮនូវជន កំពុងធ្វើនូវអំពើអ្វីៗ ទើបដឹងថាជាអមិត្រ បាន តើវិញ្ញូជន ទើបព្យាយាម ដូចម្តេច ។

(១០១២) (ព្រះមហាសត្វសំដែងនូវលក្ខណៈ នៃបុគ្គលជាសត្រូវនោះថា) បុគ្គលជាសត្រូវ ឃើញបុគ្គលនោះហើយ មិនញញឹម ១ មិនទទួល ត្រេកអរនឹងសំដីបុគ្គលនោះ ១ មិនឲ្យភ្នែកដល់បុគ្គលនោះ ១ ប្រព្រឹត្ត ទទឹងទាស់ ១ ។

(១០១៣) បុគ្គលតែងសេពគប់នឹងពួកសត្រូវ របស់បុគ្គលនោះ ១ មិនសេពគប់ នឹងពួកមិត្ររបស់បុគ្គលនោះ ១ ឃាត់នូវពួកជនអ្នកនិយាយសរសើរ ១ សរសើរពួកជនអ្នកជេរ ១ ។

(១០១៤) មិនប្រាប់សេចក្តីកំបាំង ដល់បុគ្គលនោះ ១ មិនលាក់សេចក្តី កំបាំងរបស់បុគ្គលនោះ ១ មិនសរសើរការងារ របស់បុគ្គលនោះ ១ មិនសរសើរប្រាជ្ញា របស់បុគ្គលនោះ ១ ។

(១០១៥) ត្រេកអរនឹងសេចក្តីវិនាស របស់បុគ្គលនោះ ១ មិនត្រេកអរ នឹងសេចក្តីចំរើន របស់បុគ្គលនោះ ១ បានភោជនចំឡែក មិននឹកនា ដល់បុគ្គលនោះ ១ មិនអនុគ្រោះបុគ្គលនោះ គិតរបស់នោះថា ឲ្យមិត្រនោះ ទើបបានរបស់នេះ ១ ។

(១០១៦) ឥច្ចេតេ សោឡសាការា អមិត្តស្មឹ បតិដ្ឋិតា
យេហិ អមិត្តំ ជានេយ្យ ទិស្វា សុត្វា ច បណ្ឌិតោ ។

(១០១៧) កានិ កម្មានិ កុព្វានំ កថំ វិញ្ញូ បរក្កមេ
មិត្តំ ជានេយ្យ មេធាវី ទិស្វា សុត្វា ច បណ្ឌិតោ ។

(១០១៨) បវុត្ថញ្ចស្ស(១) សរតិ អាគតំ អភិនន្ទតិ
តតោ កេលាយិតោ ហោតិ វាចាយ បដិនន្ទតិ ។

(១០១៩) មិត្តេ តស្ស ភជតិ អមិត្តេ តស្ស ន សេវតិ
អក្កោសន្តេ និវារេតិ វណ្ណកាមេ បសំសតិ ។

(១០២០) គុយ្ហញ្ច តស្ស អក្ខាតិ តស្ស គុយ្ហញ្ច គូហតិ
កម្មញ្ច តស្ស វណ្ណេតិ បញ្ញមស្ស បសំសតិ ។

(១០២១) ភវេ ច នន្ទតិ តស្ស អភវេ តស្ស ន នន្ទតិ
អច្ឆរិយំ ភោជនំ លទ្ធា តស្ស ឧប្បជ្ជតេ សតិ
តតោ នំ អនុកម្បតិ អហោ សោបិ លភេយ្យិតោ ។

---

១ ម. បវុត្ថំ តំ ។ ឧ. បវុត្ថំ តស្ស ។



(១០១៦) បណ្ឌិត ឃើញឬឮ ហើយស្គាល់ថាជាអមិត្របាន ដោយអាការទាំង ១៦ នេះ ដែលតាំងនៅ ក្នុងអមិត្តដោយប្រការដូច្នេះៗ

(១០១៧) (ព្រះបាទព្រហ្មទត្ត...) បណ្ឌិតអ្នកមានប្រាជ្ញា ឃើញឬឮក្តីផង កំពុងធ្វើការដ៏អ្វីៗ គប្បីដឹងថាជាមិត្របាន តើបណ្ឌិតគប្បីព្យាយាម ដូចម្តេច ។

(១០១៨) (មហោសធ...) បុគ្គលជាមិត្រ តែងនឹករលឹកដល់មិត្រ ដែលនៅបែកគ្នា ១ ត្រេកអរនឹងមិត្រ ដែលមកដល់ ១ ជាអ្នករាប់អានចំពោះមិត្រនោះ ១ ទទួលរាក់ទាក់ ដោយវាចា ១ ។

(១០១៩) គប់រកនឹងពួកមិត្រ របស់មិត្រនោះ ១ មិនសេពគប់នឹងពួកអមិត្រ របស់មិត្រនោះ ១ ហាមឃាត់នូវពួកអ្នកជេរ ១ សរសើរពួកជន ដែលនិយាយសរសើរ ១ ។

(១០២០) ប្រាប់សេចក្តីកំបាំង ដល់មិត្រនោះ ១ បិទបាំងសេចក្តីកំបាំង របស់មិត្រនោះ ១ សរសើរការងារ របស់មិត្រនោះ ១ សរសើរប្រាជ្ញា របស់មិត្រនោះ ១ ។

(១០២១) ត្រេកអរនឹងសេចក្តីចំរើន របស់មិត្រនោះ ១ មិនត្រេកអរនឹងសេចក្តីវិនាស របស់មិត្រនោះ ១ បានភោជនដ៏ប្លែក តែងនឹកនា ដល់មិត្រនោះ ១ អនុគ្រោះមិត្រនោះ អំពីរបស់នោះថា ៖ មិត្រនោះ គប្បីបានរបស់នេះ ១ ។

[១០៦៦] ឯតេ ច សោឡសាការា មិត្តស្មឹ សុប្បតិដ្ឋិតា
យេហិ មិត្តញ្ច ជានេយ្យ ទិស្វា សុត្វា ច បណ្ឌិតោ ។

មិត្តាមិត្តជាតកំ ទសមំ ។

## តស្សុទ្ទានំ

លហុចិត្ត សសាល ភាសន្តិ បុន
អថ កាម ជនសន្ធលុទ្ធានកោ
អថ កណ្ហ សុកោសិយ មេណ្ឌកោ
បទុមោ បុន មិត្តវរេន ទស ។

ទ្វាទសនិបាតំ និដ្ឋិតំ ។

---



[១០៦៦] បណ្ឌិត ឃើញ ឬ ឮហើយ ស្គាល់ជាមិត្រ ដោយអាការ ទាំង ១៦ នេះ ដែលដំកល់នៅ ក្នុងមិត្រ ដោយប្រការដូច្នេះ ។

ចប់ មិត្តាមិត្តជាតក ទី ១០ ។

## ឧទ្ទាននៃទ្វាទសនិបាតនោះគឺ

និយាយអំពីស្ត្រីចិត្តស្រាល ១ រុក្ខទេវតាឈ្មោះភទ្ទសាល ១ ពួកជនក្តុរកស់ ១ កាម ១ ហេតុ ១០ យ៉ាង ១ ឆ្កែខ្មៅ ១ កោសិយសេដ្ឋី ១ ពពែដ៏ប្រសើរ ១ មហាបទុមកុមារ ១ មិត្រដ៏ប្រសើរ ១ រួមត្រូវជា ១០ ។

ចប់ ទ្វាទសនិបាត ។

---

# តេរសនិបាតជាតកំ

## អម្ពជាតកំ

(១០៦៣) អហាសិ មេ អម្ពផលានិ បុព្វេ
អណូនិ ថូលានិ ច ព្រហ្មចារី
តេហេវ មន្តេហិ ន ទានិ តុយ្ហំ
ទុមប្ផលានិ បាតុភវន្តិ ព្រហ្មេ ។

(១០៦៤) នក្ខត្តយោគំ បដិមានយាមិ
ខណំ មុហុត្តញ្ច មន្តេន បស្សំ
នក្ខត្តយោគញ្ច ខណញ្ច លទ្ធា
អទ្ធា ហរិស្សម្ពផលំ ពហុតំ ។

(១០៦៥) នក្ខត្តយោគំ ន បុរេ អភាណិ
ខណំ មុហុត្តំ ន បុរេ អសំសិ
អជាហរិ អម្ពផលំ បហុតំ
វណ្ណេន គន្ធេន រសេនុបេតំ ។

# តេរសនិបាតជាតក

## អម្ពជាតក

(១០៦៣) (ព្រះបាទពារាណសី ត្រាស់សួរថា) នែអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ កាលពីដើម អ្នកបានយកផ្លែស្វាយទាំងឡាយ តូចក៏មាន ធំក៏មាន មកឲ្យយើង នែព្រាហ្មណ៍ ឥឡូវនេះ ផ្លែឈើទាំងឡាយ មិនកើតប្រាកដ ដោយមន្តទាំងឡាយរបស់អ្នកនោះ ។

(១០៦៤) (ព្រាហ្មណ៍មាណព ក្រាបទូលថា) ខ្ញុំព្រះអង្គរង់ចាំ នូវការប្រកបនូវនក្ខត្តឫក្ស ខ្ញុំព្រះអង្គមើលឃើញ ដោយមន្ត នែមួយពេល មួយស្របក់ ខ្ញុំព្រះអង្គបាននូវការប្រកបនូវនក្ខត្តឫក្ស នឹងពេល ហើយ សឹមខ្ញុំព្រះអង្គ នាំយកផ្លែស្វាយឲ្យបានច្រើន មកថ្វាយព្រះអង្គ ពុំខានឡើយ ។

(១០៦៥) (ព្រះរាជា...) កាលពីដើម អ្នកមិនបាននិយាយអាងនូវការប្រកបនូវនក្ខត្តឫក្ស ពីដើមមិនឃើញរកពេល រកស្របក់ នែអ្នក បានយកផ្លែស្វាយដ៏ច្រើន ដែលបរិបូណ៌ ដោយពណ៌ ដោយក្លិន ដោយរស (មកឲ្យយើង) ។

(១០៦៦) មន្តាភិជប្បេន បុរេវ តុយ្ហំ
ទុមប្ផលា បាតុភវន្តិ ព្រហ្មេ
ស្វាជ្ជ ន ភាតេសិ(១) ជប្បម្បិ មន្តំ(២)
អយំ សោ កោ នាម តវជ្ជ ធម្មោ ។

(១០៦៧) ចណ្ឌាលបុត្តោ មម សម្បទាសិ
ធម្មេន មន្តេ បកតិញ្ច សំសិ
មា ចស្សុ មេ បុច្ឆិតោ នាមគោត្តំ
គុយ្ហិត្ថោ មា តំ វិជហេយ្យ មន្តោ(៣) ។

(១០៦៨) សោហំ ជនិន្ទេន ជនម្ហិ បុដ្ឋោ
មក្ខាភិភូតោ អលិកំ អភាណិ
មន្តា ឥមេ ព្រាហ្មណស្សាតិ មិច្ឆា
បហីនមន្តោ កបណោ រុទាមិ ។

(១០៦៩) ឯរណ្ឌា បុចិមន្ទា វា អថ វា ផាលិភទ្ទកា
មធុំ មធុត្ថិកោ វិន្ទេ សោ ហិ តស្ស ទុមុត្តមោ ។

---

១ ម. ជាតេសិ ។ ឱ. ជាតេសិ ។ ២ ម. មន្តេ ។ ៣ ម. មន្តំ វិជហេយ្យមន្តោ ។



(១០៦៦) នែព្រាហ្មណ៍ កាលពីដើម ផ្លែឈើទាំងឡាយ តែងកើត ប្រាកដ ដោយការសូត្រសែកមន្តរបស់អ្នក ថ្ងៃនេះ អ្នកមិនសូត្រ សែកមន្ត តើធម្មតា របស់អ្នក ក្នុងថ្ងៃនេះ ដូចម្តេច ។

(១០៦៧) (មាណព...) កូនចណ្ឌាលបានឲ្យមន្តទាំងឡាយ ដល់ខ្ញុំព្រះ អង្គ ដោយធម៌ ទាំងបាននិយាយប្រាប់ នូវប្រក្រតី និងសេចក្តីទោស នៃមន្តទាំងឡាយថា បើមានគេសួរអ្នកកុំលាក់នាម និងគោត្ររបស់ ខ្ញុំ កុំឲ្យមន្តលះបង់អ្នកបាន ។

(១០៦៨) ខ្ញុំព្រះអង្គដែលព្រះជនិន្ទ្រត្រាស់សួរក្នុងប្រជុំជននោះ មានសេចក្តី លុបគុណគេគ្របសង្កត់ បានក្រាបទូលពាក្យកុហក ថាពាក្យខុសថា មន្តទាំងឡាយនេះ ជារបស់ព្រាហ្មណ៍ ខ្ញុំព្រះអង្គមានមន្តសាប សូន្យ ជាបុគ្គលកំព្រាយំទួញ ។

(១០៦៩) (ព្រះរាជា...) បុរសអ្នកត្រូវការដោយទឹកឃ្មុំ គេរកបានទឹកឃ្មុំ អំពីដើមល្ហុងខ្វងក្តី អំពីដើមស្តៅក្តី ឬក៏អំពីដើមរលួសបាយក្តី ឯដើម ឈើនោះ ឈ្មោះថាជាឈើដ៏ប្រសើរ របស់បុរសនោះ ។

(១០៣០) ខត្តិយា ព្រាហ្មណា វេស្សា សុទ្ទា ចណ្ឌាលបុក្កុសា
យម្ហា ធម្មំ វិជានេយ្យ សោ ហិ តស្ស នរុត្តមោ ។

(១០៣១) ឥមស្ស ទណ្ឌញ្ច វធញ្ច ទត្វា
គលេ គហេត្វា ខលយាថ ជម្មំ
យោ ឧត្តមត្ថំ កសិរេន លទ្ធំ
មានាតិមានេន វិនាសយិត្ថ ។

(១០៣២) យថា សមំ មញ្ញមានោ បតេយ្យ
សោព្ភំ គុហំ នរកំ បូតិបាទំ
រជ្ជូតិ(១) វា អក្កមេ កណ្ហសប្បំ
អន្ធោ យថា ជោតិមធិដ្ឋហេយ្យ
ឯវម្បិ ត្វំ មំ ខលិតំ សបញ្ញ
បហីនមន្តស្ស បុន សម្ភវាហំ ។

(១០៣៣) ធម្មេន មន្តេ តវ សម្បទាសិំ
តុម្បិ ធម្មេន បរិគ្គហេសិ
បកាតិម្បិ តេ អត្តមនោ អសំសិ
ធម្មេ ឋិតំ តំ ន ជហេយ្យ មន្តោ ។

១ ម. រជ្ជំ ។



(១០៣០) បុគ្គលបានដឹងធម៌ អំពីជនណា ទោះក្សត្រិយ៍ក្តី ព្រាហ្មណ៍ក្តី អ្នកជំនួញក្តី អ្នកស្រែក្តី ចណ្ឌាលក្តី អ្នកពោលសម្រាមក្តី ជននោះ ឈ្មោះថាជាជនដ៏ប្រសើរ របស់បុគ្គលនោះ ។

(១០៣១) បុរសណា ញុំាងប្រយោជន៍ដ៏ឧត្តម ដែលខ្លួនបានមកហើយ ដោយលំបាក ឲ្យវិនាសទៅ ដោយមានះ និងអតិមានះ អ្នកទាំងឡាយ ចូរឲ្យខ្ញុំគេវាយផង ចូរឲ្យការសម្លាប់ផង ដល់ជនអាក្រក់នេះ ហើយចាប់បុរសនេះលាកមកនេះច្រកក ហើយញាំញី ។

(១០៣២) (មាណព...) បុរសស្មានថា (ទីនេះ) រាបស្មើ គប្បីធ្លាក់ ទៅកាន់ត្រពាំង គុហា ជ្រោះ និងរណ្តៅមានលាមកស្អុយក្តី ដើរជាន់លើពស់វែក ដោយស្មានថា ខ្សែក្តី បុគ្គលខ្វាក់ដើរជាន់ភ្លើងក្តី យ៉ាងណា ។ បពិត្រលោក ប្រកបដោយប្រាជ្ញា សូមលោក (អត់ទោស)ចំពោះខ្ញុំ ដែលជាអ្នកភ្លាំងភ្លាត់ យ៉ាងនោះៗដែរ ហើយឲ្យមន្តឲ្យខ្ញុំ ដែលជាអ្នកមានមន្តសាបរលាបអស់ហើយ ម្តងទៀត ។

(១០៣៣) (កោសិយ...) យើងបានឲ្យមន្តទាំងឡាយ ដល់អ្នក ដោយធម៌ហើយ នឹងមិនយកភ្នាក់ផ្សេងឡើយ ចំណែកអ្នក ក៏បានទទួលរៀនយកមន្ត ដោយធម៌ហើយដែរ យើងមានចិត្តត្រេកអរ បានទាំងប្រាប់នូវប្រក្រតី (នៃមន្ត) ដល់អ្នកហើយ បើអ្នកតាំងនៅក្នុងធម៌ មន្តមិនលះបង់អ្នកបានទេ ។

(១០៣៤) សោ ពាល មន្តំ(១) កសិរេន លទ្ធំ
យំ ទុល្លភំ អជ្ជ មនុស្សលោកេ
កិញ្ចាបិ លទ្ធំ ជីវិតំ អប្បបញ្ញោ(២)
វិនាសយី អលិកំ ភាសមានោ ។

(១០៣៥) ពាលស្ស មូឡ្ហស្ស អកតញ្ញុនោ ច
មុសា ភណន្តស្ស អសញ្ញតស្ស
មន្តំ មយំ តាទិសកេ ន ទេម
កុតោ មន្តា គច្ឆ ន មយ្ហំ រុច្ចសីតិ ។

អម្ពជាតកំ បឋមំ ។

## ផន្ទនជាតកំ

(១០៣៦) កុឋារិហត្ថោ បុរិសោ វនមោគយ្ហ តិដ្ឋសិ
បុដ្ឋោ មេ សម្ម អក្ខាហិ កឹ ទារុំ ឆេតុមិច្ឆសិ ។

(១០៣៧) ឥស្សរោ វនានិ ចរសិ សមានិ វិសមានិ ច
បុដ្ឋោ មេ សម្ម អក្ខាហិ កឹ ទារុំ នេមិយា ទឡ្ហំ ។

---

១ ម. យោ ពាលមន្តំ ។ ឱ. យោ ពលមន្តំ ។ ២ ម. កិញ្ចាបិ លទ្ធា ជីវិតុ អប្បបញ្ញោ ។ ឱ. កិញ្ចាបិ លទ្ធា ជីវិតុំ អប្បបញ្ញោ ។



(១០៣៤) ម្នាលបុគ្គលពាល អ្នកនោះ ធ្វើមន្តដែលខ្ញុំបានហើយដោយលំបាក បានមកដោយកម្រ ក្នុងមនុស្សលោក ឲ្យវិនាសទៅ ក្នុងថ្ងៃនេះ អ្នកនោះជាអ្នកឥតប្រាជ្ញា ពោលពាក្យកុហក ឈ្មោះថា ញុំាងជីវិត ដែលខ្ញុំបានដោយកម្រឲ្យវិនាស ។

(១០៣៥) យើងមិនឲ្យមន្តទាំងឡាយបែបនោះ ដល់មនុស្សល្ងង់ខ្លៅ វង្វេង ជាអកតញ្ញូ ពោលពាក្យកុហក មិនសង្រួម ឯមន្តទាំងឡាយនឹងមានមកពីណាទៀត អ្នកឯងចូរចេញទៅ អ្នកឯងមិនគាប់ចិត្តយើងទេ ។

ចប់ អម្ពជាតក ទី ១ ។

## ផន្ទនជាតក

(១០៣៦) (កាឡសីហៈសួរថា) អ្នកជាបុរសមានដៃកាន់ពូថៅ ចូលមកឈរនៅក្នុងព្រៃ នែសំឡាញ់ ខ្ញុំសួរហើយ ចូរអ្នកប្រាប់ តើអ្នកចង់កាប់ឈើអ្វី ។

(១០៣៧) (វឌ្ឍកីព្រាហ្មណ៍ តបថា) អ្នកជាកាឡសីហៈ ត្រាច់ទៅកាន់ព្រៃស្មើ និងមិនស្មើ ម្នាលសំឡាញ់ ខ្ញុំសួរហើយ អ្នកចូរប្រាប់ ឈើអ្វី ធ្វើខ្នងកង់ជាប់មាំ ។

(១០៣៨) នេវ សាលោ ន ខទិរោ នាស្សកណ្ណោ កុតោ ធវោ

រុក្ខោ ច ជន្តុនោ នាម តំ ទារុំ នេមិយា ទឡ្ហំ។

(១០៣៩) កីទិសាទិស្ស បត្តានិ ខន្ធោ វាបន កីទិសោ

បុដ្ឋោ មេ សម្ម អក្ខាហិ យថា ជានេមុ ជន្តុនំ។

(១០៤០) យស្ស សាខា បលម្ពន្តិ នមន្តិ ន ច ភញ្ជរេ

សោ រុក្ខោ ជន្តុនោ នាម យស្ស មូលេ អហំ ឋិតោ។

(១០៤១) អរានំ ចក្កនាភីនំ ឦសានេមិរថស្ស ច

សព្វស្ស តេ កម្មនិយោ អយំ ហេស្សតិ ជន្តុនោ។

(១០៤២) ឥតិ ជន្តុនរុក្ខោបិ តាវទេ អជ្ឈភាសថ

មយ្ហម្បិ វចនំ អត្ថិ ភារទ្វាជ សុណោហិ មេ។

(១០៤៣) ឧមស្ស ឧបក្ខន្ធម្ហា ឧក្កច្ច ចតុរង្គុលំ

តេន នេមឹ បសារេសិ(១) ឯវំ ទឡ្ហតរំ សិយា។

១ ម. បសារយំ ។



(១០៣៨) (ការសួរថា:...) ដើមរាំងក៏មិនជាប់ ដើមខ្ទីរក៏មិនជាប់ ដើមត្រចៀកក្រៀលក៏មិនជាប់ ដើមត្រែងក៏មិនជាប់ មានតែដើមពង្រ ឈើនោះឯងគង់នេះជាប់មាំ ។

(១០៣៩) (រុក្ខ...) ស្លឹកពង្រនោះ ដែលដូចម្ដេច ដើមពង្រនោះ ដែលដូចម្ដេច សម្លាញ់ យើងសួរហើយ អ្នកចូរប្រាប់ យើងឲ្យស្គាល់ដើមពង្រ យ៉ាងណា ។

(១០៤០) (ការសួរថា:...) មែកឈើណា សំយុងចុះផង មិនទន់ ទោរផង មិនបាក់ផង ខ្ញុំឈរក្បែរគល់ឈើណា ឈើនោះ ហើយ ជាដើមពង្រ ។

(១០៤១) ដើមពង្រនេះ គួរដល់ការធ្វើរបស់អ្នក ដើម្បីកាំនៃកង់ ឡាយ ដើម្បីកន្លែងនីដុំនៃកង់ឡាយ ដើម្បីបង្គោលនៃ ធ្នឹម កង់នេះ នឹងរបស់សព្វគ្រប់ ក្រៅពីនេះទាំងអស់ ។

(១០៤២) (អភិសម្ពុទ្ធគាថា) ព្រោះហេតុនោះ ទេវតាក្រស៊ីយនៅលើ ដើមពង្រ បាននិយាយថា ពាក្យរបស់ខ្ញុំក៏មានដែរ ម្នាលភារ- ទ្វាជព្រាហ្មណ៍ អ្នកឯងចូរស្តាប់ពាក្យខ្ញុំសិន ។

(១០៤៣) អ្នកចូរកាយយកស្បែកខ្លាឃ្មុំនេះត្រឹម ចំនួន ៤ ធ្នាប់ហើយយក ស្បែកនោះមកព្រាប់ខ្នងកង់នេះ ធ្វើយ៉ាងនេះ ទើបជាប់មាំមួន ។

[១០៤៤] ឥតិ ជន្តុទុក្ខោចំ    ភេរិ ការយេសិ តេវតា
ជាតានញ្ច អជាតានំ    ក្លៀសានំ ទុក្ខមាវហំ(១) ។

[១០៤៥] ឥច្ចេវំ ជន្តុនោ ក្លៀសំ    ក្លៀសោ ច បន ជន្តុនំ
អញ្ញមញ្ញំ វិភេទេន    អញ្ញមញ្ញមឃាតយុំ ។

[១០៤៦] ឯវមេវ មនុស្សេសុ    វិភេទោ យត្ថ ជាយតិ
មយូរនច្ចំ នច្ចន្តិ    យថា តេ ក្លៀសជន្តុតា ។

[១០៤៧] តំ វោ វទាមិ ភទ្ទំ វោ    យាវន្តេត្ថ សមាគតា
សម្មោទថ មា វិវទិត្ថ    មា ហោថ ក្លៀសជន្តុតា ។

១ ម. រុក្ខមាវហំ ។



(១០៤៤) ទៅកាន់ផលអាស្រ័យនៅលើដើមព្រីង បានសម្រេចហើយ ហើយ បាននាំយកសេចក្ដីទុក្ខមកឲ្យដល់ត្បាយ៉ូតាំងពីឡូយ ដែលកើតហើយផង ដែលមិនទាន់កើតហើយផង ដោយប្រការដូច្នេះ ។

(១០៤៥) ដើមព្រីងចង់ទៀតទាំងត្បាយ៉ូ ឯត្បាយ៉ូចង់ទៀតទាំងដើមព្រីង ហើយបានសម្លាប់គ្នា ទៅវិញទៅមក ដោយការពាល់ទាំងគ្នា ទៅវិញទៅមក ដោយប្រការដូច្នេះឯង ។

(១០៤៦) ត្បាយ៉ូទាំងដើមព្រីងនោះ ចង់ទៀតទៅយ៉ាងណា ការពាល់ទាំងរបស់មនុស្សទាំងឡាយ កើតមានក្នុងទីណា មនុស្សទាំងនោះ ឈ្មោះថា ក៏ដូចជាក្ដាកកត់(១) ក្នុងទីនោះ ក៏យ៉ាងនោះដែរ ។

(១០៤៧) គឺជាគតទាំងសំដែងនូវហេតុនោះថ្វាយមហារាជ ពួកមនុស្ស ដែលមកប្រជុំក្នុងទីនេះ មានចំនួនប៉ុន្មាន សូមសេចក្ដីចំរើនមាន ដល់មហាបពិត្រ មានចំនួនប៉ុណ្ណោះ សូមមហាបពិត្រ ព្រមព្រៀងគ្នា កុំពាល់ទាំងគ្នា កុំឲ្យដូចត្បាយ៉ូទាំងដើមព្រីងឡើយ ។

១ ពន្លាព្រៃការទាំងឡាយ ដែលកើតនូវទៀតកាលណា ក៏ទាញញៀញ្ញិចូល របស់ក ឲ្យឃើញប្រាកដ យ៉ាងណាមិញ ពួកមនុស្ស កាលបើកើតវិវាទឈ្លោះពាល់ទាំងគ្នា ហើយ ក៏ក្រោកសកោសដល់គ្នានឹងគ្នា តែងតែប្រែទៅរំលើកបើកកាយញ្ញិចូលទៅ វិញទៅមក នឹងមានទោសច្រើន ក៏យ៉ាងនោះដែរ ។ អដ្ឋកថា ។

(១០៦៨)សាមគ្យ មវ សំគ្គេច គុណ្ណហោតិ បសំសិតំ

សាមគ្យតោ ធម្មដ្ឋោ យោគក្ខេមា ន ធំសតីតិ ។

ជុណ្ហជាតកំ ទុតិយំ ។

## ជវនហំសជាតកំ

(១០៦៩) ឥធេវ ហំស និបត បិយំ មេ តវ ទស្សនំ

ឥស្សរោសិ អនុប្បត្តោ យំ ឥធត្ថិ បវេទយ ។

(១០៧០) សវនេន ឯកស្ស បិយា ភវន្តិ

ទិស្វា បនេកស្ស វិគេតិ ឆន្ទោ

ទិស្វា ច សុត្វា ច បិយា ភវន្តិ

កច្ចិន្នុ មេ បិយសិ ទស្សនេន ។

(១០៧១)សវនេន បិយោ មេសិ ភិយ្យោ ចាគម្ម ទស្សនំ

ឯវំ បិយទស្សនោ សមានោ វស ហំស មម សន្តិកេ ។



(១០៦៨) សូមមហាបពិត្រ សំគាល់ថាសេចក្តីព្រមព្រៀងគ្នាតែម្យ៉ាង ព្រោះសេចក្តីព្រមព្រៀងគ្នានោះ ព្រះពុទ្ធទាំងឡាយ សរសើរហើយ បុគ្គលអ្នកត្រេកអរ ក្នុងសេចក្តីព្រមព្រៀងគ្នា អ្នកតាំងនៅក្នុងធម៌ រមែងមិនសាបសូន្យ ចាកព្រះនិព្វានជាទីក្សេម ចាកយោគៈទាំងឡាយឡើយ ។

ចប់ ជុណ្ហជាតក ទី ២ ។

## ជវនហំសជាតក

(១០៦៩) (ព្រះបាទពារាណសី មានព្រះរាជបន្ទូលថា) នែហង្ស ឯងចូរចុះលើតាំងមាសនេះចុះ ការឃើញឯង ជាទីពេញចិត្តរបស់អញ ឯងសមគួរជាធំហើយ របស់ណាមានក្នុងទីនេះ ឯងចូរប្រាប់មកចុះ ។

(១០៧០) (ជវនហង្ស...) បុគ្គលខ្លះគ្រាន់តែឮហើយស្រឡាញ់ក៏មាន ខ្លះគ្រាន់តែឃើញគ្នាហើយ អស់សេចក្តីស្រឡាញ់ក៏មាន ខ្លះឃើញផងឮផង ទើបស្រឡាញ់ក៏មាន ចុះព្រះអង្គគ្រាន់តែឃើញ តើស្រឡាញ់ខ្ញុំដែរឬទេ ។

(១០៧១) (ព្រះរាជា..) អញគ្រាន់តែបានឮ ស្រឡាញ់ឯងនៅហើយ លុះបានឃើញ អញក៏តែស្រឡាញ់ឡើង នែហង្ស ឯង អញឃើញហើយស្រឡាញ់យ៉ាងនេះ ឯងចូរនៅក្នុងសំណាក់អញចុះ ។

(១០៨២) សេយ្យាម តកការេ បិដ្ឋិ សក្កតបូជិតា
មញ្ញោ ច ឯកតា មជ្ជំ ហិសរកជំ បចន្តុ មេ ។

(១០៨៣) ធិរត្ថុ តំ មជ្ជបានំ យំ មេ បិយតរំ តយា
ន ចាបិ មជ្ជំ បិវិស្សាមិ យាវ មេ វច្ឆសី ឃរេ ។

(១០៨៤) សុវិជានំ សិគាលានំ សកុណានញ្ច វស្សិតំ
មនុស្សវស្សិតំ រាជ ទុព្វិជានតរំ តតោ ។

(១០៨៥) អបិ ចេ មញ្ញតី បោសោ ញាតិ មិត្តោ សខាតិ វា
យោ បុព្វេ សុមនោ ហុត្វា បច្ឆា សម្បជ្ជតេ ទិសោ ។

(១០៨៦) យស្មឹ មនោ និវិសតិ អវិទូរេ សហាបិ សោ
សន្តិកេបិ ហិ សោ ទូរេ យស្មា វិវសតេ[១] មនោ ។

---
១ ម. យស្មឹ និវិសតេ ។



(១០៨២) (កវេហស្ស...) ទឹកនៅក្នុងដំណាក់របស់ព្រះឥន្ទ្រ ព្រះឥន្ទ្រធ្វើសក្ការបូជា អស់កាលជានិច្ចហើយ តែក្រែងពេលណាមួយ ព្រះឥន្ទ្រស្រវឹងដោយទឹកស្រវឹងហើយ ទ្រង់ត្រាស់បង្គាប់ថា នាយពិសេស ចូរចំអិនសាច់ស្ដេចហង្ស យកមកឲ្យយើង ។

(១០៨៣) (ព្រះរាជា...) ថ្វីយ! ន្ថើម ការផឹកទឹកស្រវឹង ដែលជាទីស្រឡាញ់របស់អញ ជាងឯង បើឯងនៅក្នុងដំណាក់អញដរាបណា អញនឹងមិនផឹកទឹកស្រវឹងដរាបនោះ ។

(១០៨៤) (កវេហស្ស...) សំដីរបស់ពួកចចកនឹងពួកបក្សី យល់បានងាយ បពិត្រមហារាជ សំដីរបស់ពួកមនុស្ស កម្រដឹងបាន ជាងសំដីសត្វនោះទៅទៀត ។

(១០៨៥) មួយទៀត បើបុរសណា កាលពីដើម មានចិត្តល្អ គេសំគាល់ថា ជាញាតិ ជាមិត្រ ឬជាសម្លាញ់ តែលុះដល់ពេលខាងក្រោយមក បុរសនោះ ត្រឡប់ជាសត្រូវនឹងគ្នាទៅវិញ ក៏មាន ។

(១០៨៦) បុគ្គលណាមានចិត្តស្មោះស្មើ ដោយសារសេចក្ដីស្រឡាញ់ បុគ្គលនោះ ឈ្មោះថានៅជិតជាមួយគ្នា បុគ្គលណាមានចិត្តមិនស្មោះស្មើ បុគ្គលនោះទោះនៅក្នុងទីជិត ក៏ហាក់ដូចជានៅក្នុងទីឆ្ងាយ ។

[១០៥៧] អន្តោបិ ចេ ហោតិ បសន្នចិត្តោ

បារំ សមុទ្ទស្ស បសន្នចិត្តោ

អន្តោបិ សោ ហោតិ បទុដ្ឋចិត្តោ

បារំ សមុទ្ទស្ស បទុដ្ឋចិត្តោ ។

[១០៥៨] សំវសន្តា វិវសន្តិ យេ ទិសា តេ រវេសក

អារកា សន្តោ(១) សំវសន្តិ មនសា រដ្ឋវឌ្ឍន ។

[១០៥៩] អតិចិរំ និវាសេន បិយោ ភវតិ អប្បិយោ

អាមន្ត ខោ តំ គច្ឆាម បុរា តេ ហោម អប្បិយោ ។

[១០៦០] ឯវំ ចេ យាចមានានំ អញ្ជលឹ នាវពុជ្ឈសិ

បរិចារកានំ សន្តានំ វចនំ ន ករោសិ នោ

ឯវំ តំ អភិយាចាម បុន កយិរាសិ បរិយាយំ ។

១ ម. អារកិតា ។



[១០៥៧] សំឡាញ់ណា ជាអ្នកមានចិត្តជ្រះថ្លានឹងគ្នា បើទុកជានៅឯត្រើយសមុទ្រខាងនាយ សំឡាញ់ដែលមានចិត្តជ្រះថ្លានឹងគ្នានោះ ក៏ឈ្មោះថា នៅក្នុងសមុទ្រជាមួយគ្នា សំឡាញ់ណាមានចិត្តប្រទូស្តគ្នា បើទុកជានៅក្នុងសមុទ្រជាមួយគ្នា សំឡាញ់ដែលមានចិត្តប្រទូស្តគ្នានោះ ក៏ឈ្មោះថា នៅត្រើយសមុទ្រខាងនាយវិញ ។

[១០៥៨] បពិត្រព្រះអង្គជាបុគ្គលប្រសើរលើរថ បុគ្គលទាំងឡាយណា ជាសត្រូវនឹងគ្នា បើទុកជានៅជាមួយគ្នា បុគ្គលទាំងនោះ ក៏ឈ្មោះថា នៅឆ្ងាយគ្នា បពិត្រព្រះអង្គជាបុគ្គលចំរើនក្នុងដែន ពួកសប្បុរស ទោះបីនៅក្នុងទីឆ្ងាយ ក៏ឈ្មោះថា នៅក្នុងទីជាមួយ ដោយចិត្ត ។

[១០៥៩] បុគ្គលជាទីស្រឡាញ់ រមែងមិនស្រឡាញ់វិញ ព្រោះតែនៅជាមួយគ្នាយូរពេក ខ្ញុំសូមថ្វាយបង្គំលាព្រះអង្គទៅវិញ មុនពេលដែលខ្ញុំមិនជាទីស្រឡាញ់របស់ព្រះអង្គ ។

[១០៦០] (ព្រះរាជា...) កាលបើយើងអង្វរយ៉ាងនេះ អ្នកមិនទទួលដឹងនូវអញ្ជលី មិនធ្វើតាមពាក្យយើង ជាអ្នកបម្រើទេ យើងសូមអង្វរអ្នកយ៉ាងនេះថា អ្នកគប្បីធ្វើនូវការត្រឡប់មកទៀត ។

(១០៦១)ឯវំ ចេ នោ វិហរតំ អន្តរាយោ ន ហេស្សតិ
តុម្ហំ ចាបិ មហារាជ មយ្ហំ ច រដ្ឋវឌ្ឍន
អប្បេវនាម បស្សេម អហោរត្តានមច្ចយេ ។

ជវនហំសជាតកំ តតិយំ ។

## ចុល្លនារទកស្សបជាតកំ[1]

(១០៦២)ន តេ កដ្ឋានិ ភិន្នានិ ន តេ ឧទកមាភតំ
អគ្គីបិ តេ ន ហាបិតោ កិន្នុ មន្ទោវ ឈាយសិ ។

(១០៦៣)ន ឧស្សហេ វនេ វត្ថុំ កស្សបាមន្តយាមិ តំ
ទុក្ខោ វាសោ អរញ្ញស្មឹ រដ្ឋំ ឥច្ឆាមិ គន្តវេ ។

(១០៦៤)យថា អហំ ឥតោ គន្ត្វា យស្មឹ ជនបទេ វសំ
អាចារំ ព្រហ្មេ សិក្ខេយ្យំ តំ ធម្មំ អនុសាស មំ ។

(១០៦៥)សចេ អរញ្ញំ ហិត្វាន វនមូលផលានិ ច
រដ្ឋេ រោចយសេ វាសំ តំ ធម្មំ និសាមេហិ មេ ។

[1] ឱ. ម. ចុល្លនារទជាតកំ ។



(១០៦១) (កដហំស...) បពិត្រមហារាជ ជាអ្នកមានសេចក្តីចម្រើន ក្នុងដែន កាលបើយើងនៅយ៉ាងនេះ សេចក្តីអន្តរាយនឹងមិនមាន ដល់ព្រះអង្គ ទាំងដល់ខ្លួនព្រះបង្គំជាខ្ញុំ សូមឲ្យយើងបានជួបគ្នា ក្នុងកាលកន្លងទៅនៃថ្ងៃនិងយប់ ។

ចប់ ជវនហំសជាតក ទី ៣ ។

## ចុល្លនារទកស្សបជាតក

(១០៦២) (តាបសពោធិសត្វ សួរថា) អុសកូនឯងមិនពុះ ទឹកកូនឯង មិនដង ភ្លើងក៏កូនឯងមិនបង្កាត់ កូនឯងជាមនុស្សល្ងង់ទៅឬ បាន ជាទៅសញ្ជប់សញ្ជឹង ។

(១០៦៣) (តាបសកុមារ តបថា) ខ្ញុំមិនអាចនៅក្នុងព្រៃបានទេ បពិត្រ កស្សបៈ ខ្ញុំសូមលាលោក ការនៅក្នុងព្រៃពិបាក ខ្ញុំចង់ទៅដែនវិញ ។

(១០៦៤) ខ្ញុំចេញទៅពីព្រៃនេះ ហើយនៅក្នុងជនបទណា បពិត្រតាបស ដ៏ប្រសើរ បុគ្គលគប្បីសិក្សាឫកពាយ៉ាងណា សូមព្រះបិតាប្រៀន ប្រដៅទំនៀមទម្លាប់នោះដល់ខ្ញុំ ។

(១០៦៥) (តាបស...) បើបាឯងលះបង់ព្រៃ និងមើមឈើផ្លែឈើ ហើយពេញចិត្តនឹងការនៅ ក្នុងដែនវិញ បាឯងចូរស្តាប់ទំនៀម ទម្លាប់នោះ របស់អញ ។

(១០៦៦)វិសំ មា បដិសេវិត្ថ បបាតំ បរិវជ្ជយ
បង្កេ ច មា វិសីទិត្ថ យត្តោ អាសីវិសេ ចរេ ។
(១០៦៧)កិន្នុ វិសំ បបាតោ វា បង្កោ វា ព្រហ្មចារិនំ
កំ ត្វំ អាសីវិសំ ព្រូសិ តំ មេ អក្ខាហិ បុច្ឆិតោ ។
(១០៦៨)អាសវោ តាត លោកស្មឹ សុរា នាម បវុច្ចតិ
មនុញ្ញា សុរភី វគ្គូ មធុខុទ្ទរសូបមា
វិសំ តទាហុ អរិយា ព្រហ្មចរិយស្ស នារទ ។
(១០៦៩)ឥត្ថិយោ តាត លោកស្មឹ បមត្តំ បមថេន្តិ តា
ជវន្តិ មុនិនោ[១] ចិត្តំ តូលំ ភដ្ឋំ មាលុតោ
បបាតោ ឯស អក្ខាតោ ព្រហ្មចរិយស្ស នារទ ។
(១០៧០) លាភោ សិលោកោ សក្ការោ
បូជា បរកុលេសុ ច
បង្កោ ឯសោវ អក្ខាតោ ព្រហ្មចរិយស្ស នារទ ។

១ ម. ហរន្តិ យុវិនោ ។ ឱ. ហរន្តិ យុវិនោ ។



(១០៦៦) ម្នាលឯងចូរកុំសេពថ្នាំពិស ចូរវៀរចាកនូវអណ្តូង កុំឲ្យលិចទៅក្នុងភក់ឡើយ ចូរប្រព្រឹត្តប្រយ័ត្ននឹងពួកអាសិរពិស ។

(១០៦៧) (តាបសកុមារ...) អ្វីជាថ្នាំពិស ជាអណ្តូង ជាភក់ របស់អ្នកប្រព្រឹត្តព្រហ្មចរិយធម៌ លោកពោលនូវអ្វីថាជាអាសិរពិស ខ្ញុំសួរហើយ សូមលោកប្រាប់រឿងនោះដល់ខ្ញុំ ។

(១០៦៨) (តាបសពោធិសត្វ...) នែបា គ្រឿងក្រវឹកក្នុងលោក គេហៅថា ស្រា ជារបស់ពេញចិត្ត ជារបស់ឈ្ងុយឈ្ងប់ ឆ្ងាញ់ពិសា មានឧបមាដូចរសផ្អែមតូចមួយ ម្នាលនារទៈ ព្រះអរិយៈទាំងឡាយ បានពោលថា ស្រានោះ ជាថ្នាំពិស របស់បុគ្គលអ្នកប្រព្រឹត្តព្រហ្មចារ្យ ។

(១០៦៩) នែបា ស្ត្រីទាំងឡាយក្នុងលោក រមែងញាំញីនូវបុរស ដែលស្រវឹងហើយ ពួកស្ត្រីទាំងនោះ តែងផ្សាយចិត្តនៃប្រុសកំលោះ ដូចជាខ្យល់ផាត់នូវប៉ុយគរ ដែលជ្រុះអំពីដើម ម្នាលនារទៈ នោះហើយ ដែលលោកហៅថា អណ្តូង របស់អ្នកប្រព្រឹត្តព្រហ្មចារ្យ ។

(១០៧០) លាភ សេចក្តីសរសើរ សក្ការៈ និង ការបូជា ក្នុងត្រកូលអ្នកដទៃ ម្នាលនារទៈ នោះឯងដែលលោកហៅថា ភក់ល្បាប់ របស់អ្នកប្រព្រឹត្តព្រហ្មចារ្យ ។

(១០៧១) មហន្តា តាត ភជាលោ អាវសន្តិ មហឹ ឥមំ
តេ តាធិសេ មនុស្សិន្ទេ មហន្តេ តាត យាវធ ។
(១០៧២) ឥស្សរានំ អធិបតីនំ ន តេសំ បាទតោ ចរេ
អាសីវិសោតិ អក្ខាតោ ព្រហ្មចារិស្ស តាវធ ។
(១០៧៣) កត្តុត្តោ កត្តុកាលេន យំ តេហិ ឧបសង្កមេ
យទេត្ថ កុសលំ ញត្វា តត្ថ យាសេសមំ ករេ ។
បវិសិត្វា បរកុលំ បានត្ថោ (១) ភោជនាយ វា
មិតំ ខាទេ មិតំ ភុញ្ជេ ន ច រូបេ មនំ ករេ ។
(១០៧៤) កុដ្ឋិ មជ្ជំ កិរាសញ្ញ (២) សភា និករណានិ ច
អារកា បរិវជ្ជេហិ យានីវ វិសមំ បថត្ថំ ។

ចុល្លនារទកស្សបជាតកំ និដ្ឋិតំ ។

---

១ ឱ. បានត្ថំ ។ ២ ឱ. កិរាសំ ក ។ ឱ. កិរាសិញ្ញ ។



(១០៧១) នែពុក ពួកស្តេចធំៗ គ្រប់គ្រងផែនដីនេះ នែនារទៈកូន ពុកឯង (ចូរគោរព) ពួកស្តេចទាំងនោះ ដែលជាធំជាងមនុស្ស ដ៏ប្រសើរក្រោកផ្ទួរនោះ ។
(១០៧២) ចូរពុកកុំប្រព្រឹត្តនៅផ្ទាល់ព្រះបាទា នៃពួកស្តេចជាឥស្សរៈ ជាអធិបតីទាំងនោះឡើយ នែនារទៈ (កោនឯង) ដែលគេហៅថា អាសីពិស របស់អ្នកប្រព្រឹត្តព្រហ្មចារ្យ ។
(១០៧៣) បើពុក ត្រូវការភត្ត ក្នុងពេលភត្ត គប្បីចូលទៅកាន់ផ្ទះ ណាដែលពុកដឹងថា ត្រកូលណាមិនមានទោស ក្នុងស្រុកនោះ គប្បីប្រព្រឹត្តស្វែងរកអាហារ ក្នុងផ្ទះនោះចុះ ។ លុះចូលទៅកាន់ ត្រកូលដទៃ ដើម្បីទឹកក្តី ដើម្បីភោជនក្តី គប្បីទំពាស៊ីឲ្យល្មម ប្រមាណ គប្បីបរិភោគឲ្យល្មមប្រមាណ តែពុកកុំគប្បីពេញ ចិត្តនឹងរូប (ស្ត្រី) ទាំងឡាយឡើយ ។
(១០៧៤) ពុកចូរចៀសវាង ចេញឲ្យឆ្ងាយ នូវទីគោឈរ តៀមស្រា មនុស្សអ្នកលេង មនុស្សអ្នកឆបោក កន្លែងប្រជុំមនុស្សច្រើន នឹងកន្លែងដែលគេចុកដាក់ប្រាក់មាស ឲ្យដូចជាបុគ្គល ទៅដោយ យាន (ដែលផ្ទុកដោយសប្បិ ទឹកប្រេង) វៀរផ្លូវមិនរាបស្មើ ។

ចប់ ចុល្លនារទកស្សបជាតក ទី ៤ ។

# ទូតជាតកំ

(១០៧៥) ទូតេ តេ ព្រហ្មេ បាហេសឹ គង្គាតីរស្មិ ឈាយតោ[១]
តេសំ បុដ្ឋោ ន ព្យាកាសិ ទុក្ខំ គុយ្ហមតំ នុ តេ ។

(១០៧៦) សចេ តេ ទុក្ខមុប្បជ្ជេ កាសីនំ រដ្ឋវឌ្ឍន
មា ខោ នំ តស្ស អក្ខាហិ យោ តំ ទុក្ខា ន មោចយេ ។

(១០៧៧) យោ តស្ស ទុក្ខជាតស្ស ឯកង្គមបិ ភាគសោ[២]
វិប្បមោចេយ្យ ធម្មេន កាមំ តស្ស បវេទយេ ។

(១០៧៨) សុវិជានំ សិគាលានំ សកុន្តានញ្ច វស្សិតំ
មនុស្សវស្សិតំ រាជ ទុព្វិជានតរំ តតោ ។

(១០៧៩) អបិ ចេ មញ្ញតី បោសោ ញាតិ មិត្តោ សខាតិ វា
យោ បុព្វេ សុមនោ ហុត្វា បច្ឆា សម្បជ្ជតេ ទិសោ ។

---

១ ម. ឈាយតោ ។ ២ ម. យោ ច តតោ ទុក្ខជាតស្ស ឯកង្គមបិ ភាគសោ ។



# ទូតជាតក

(១០៧៥) (ព្រះរាជាត្រាស់សួរថា) ម្នាលព្រាហ្មណ៍ យើងបានបញ្ជូនពួកទូតមក ក្នុងសំណាក់អ្នក ដែលកំពុងសម្ងំនៅ ក្បែរច្រាំងគង្គា ពួកទូតទាំងនោះបានសួរហើយ តែអ្នកមិនឆ្លើយប្រាប់សោះ សេចក្តីទុក្ខ (ណា) ដែលកើតឡើងដល់អ្នក សេចក្តីទុក្ខនោះ មិនបានតែអ្នកទេឬ ។

(១០៧៦) (មហាសត្វ ទូលថា) បពិត្រព្រះអង្គជាបុគ្គលចំរើន ក្នុងដែនរបស់អ្នកកាសី បើសេចក្តីទុក្ខ គប្បីកើតឡើងដល់ព្រះអង្គ បុគ្គលណា ដោះទុក្ខនោះមិនបានទេ សូមព្រះអង្គកុំប្រាប់សេចក្តីទុក្ខនោះ ដល់បុគ្គលនោះឡើយ ។

(១០៧៧) បុគ្គលណា គប្បីដោះទុក្ខព្រះអង្គនោះបានដោយធម៌ ជាចំណែក នៃសេចក្តីសុខតែមួយក៏ដី សូមព្រះអង្គប្រាប់ដល់បុគ្គលនោះ ដោយពិត ។

(១០៧៨) សម្លេងពួកចចកក្តី ពួកសត្វស្លាបក្តី ដឹងបានដោយងាយ បពិត្រមហារាជ សំដីរបស់មនុស្ស ដឹងបានដោយក្រ ជាងសម្លេងនោះទៅទៀត ។

(១០៧៩) មួយទៀត កាលពីមុន បុរសណា មានចិត្តល្អ គេសំគាល់ថា ជាញាតិសន្តាន ឬមិត្រសំឡាញ់ តែដល់មកខាងក្រោយ បុរសនោះ ត្រឡប់ទៅជាសត្រូវនឹងគ្នាវិញក៏មាន ។

(១០៨០) យោ អត្តនោ ទុក្ខមនានុបុដ្ឋោ
បវេទយេ ជន្តុ អកាលរូបេ
អានន្ទិនោ តស្ស ភវន្តិ មិត្តា
ហិតេសិនោ តស្ស ទុខី ភវន្តិ ។

(១០៨១) កាលញ្ច ញត្វាន តថាវិធស្ស
មេធាវិនំ ឯកមនំ វិទិត្វា
អក្ខេយ្យ តិព្វានិ(១) បរស្ស ធីរោ
សណ្ហំ គិរំ អត្ថវតី បមុញ្ចេ ។

(១០៨២) សចេ ច ជញ្ញា អវិសយ្ហមត្តនោ
ន តេហិ មយ្ហំ សុខាគមាយ(២)
ឯកោវ តិព្វានិ សហេយ្យ ធីរោ
សច្ចំ ហិរោត្តប្បមបេក្ខមានោ ។

(១០៨៣) អហំ រដ្ឋានិ វិចរន្តោ និគមេ រាជធានិយោ
ភិក្ខមានោ មហារាជ អាចរិយស្ស ធនត្ថិកោ ។

១ ម. អាចិក្ខេយ្យ តិព្វានិ ។ ២ ម. តាយ ន-តិ មយ្ហំ សុខាគមាយ ។ ឱ. តាយ តេហិ មយ្ហំ សុខាគមាយ ។



(១០៨០) ជនណា មានគេសាកសួរសេចក្តីទុក្ខរបស់ខ្លួន ហើយនិយាយប្រាប់ (នូវសេចក្តីកង្វល់របស់ខ្លួន) ក្នុងកាលមិនគួរ មិត្រទាំងឡាយ ជាអ្នកមិនត្រេកអរចំពោះជននោះក៏មាន ជាអ្នកស្វែងរកនូវប្រយោជន៍ មានសេចក្តីទុក្ខចំពោះជននោះ ក៏មាន ។

(១០៨១) អ្នកប្រាជ្ញដឹង នូវកាលគួរ (នឹងនិយាយប្រាប់) ផង ដឹងនូវមេធាវីជនជា មានចិត្តតែមួយជាមួយនឹងខ្លួនផង ទើបគួរប្រាប់នូវសេចក្តីទុក្ខទាំងឡាយ ដល់ជនឯទៀត មានប្រការដូច្នោះ ហើយគប្បីបញ្ចេញនូវពាក្យផ្អែមពីរោះ ជាពាក្យមានប្រយោជន៍ ។

(១០៨២) អ្នកប្រាជ្ញកាលបើសំឡឹងពិនិត្យឃើញនូវហិរិនិងឱត្តប្បៈជាក់ច្បាស់ ហើយ បើមិនដឹងនូវទុក្ខដែលខ្លួនគិតថាទ្រាំបានថា សេចក្តីសុខដែលនឹងមានដល់គ្នាឯង មិនមែនមាន (ព្រោះការលើកទុក្ខៈដាក់ទម្ងន់ទៅលើអ្នកដទៃ) ហើយក៏អត់ទ្រាំទុក្ខធំទាំងនោះតែម្នាក់ឯង ។

(១០៨៣) បពិត្រមហារាជ ខ្ញុំព្រះអង្គជាអ្នកត្រូវការដោយទ្រព្យ (យកទៅជូន) ដល់អាចារ្យ ទើបដើរសូមគេក្នុងដែន និគមនិងរាជធានី ។

[១០៨៤] គហបតី រាជបុរិសេ មហាសាលេ ច ព្រាហ្មណេ
អលត្ថំ សត្ត និក្ខានិ   សុវណ្ណស្ស ជាតរូប
តេ មេ នដ្ឋា មហារាជ   តស្មា សោចាមហំ ភុសំ ។

[១០៨៥] បុរិសា តេ មហារាជ   មនសានុវិចិន្តិតា
នាលំ ទុក្ខា បមោចេតុំ   តស្មា តេសំ ន ព្យាហរឹ ។

[១០៨៦] ត្វញ្ច ខោ មេ មហារាជ   មនសានុវិចិន្តិតោ
អលំ ទុក្ខា បមោចេតុំ   តស្មា តុយ្ហំ បវេទយឹ ។

[១០៨៧] តស្សាទាសិ បសន្នចិត្តោ   កាសីនំ រដ្ឋវឌ្ឍនោ
ជាតរូបមយេ និក្ខេ   សុវណ្ណស្ស ចតុទ្ទសាតិ ។

ទូតជាតកំ បញ្ចមំ ។

## កាលិង្គពោធិជាតកំ

[១០៨៨] រាជា កាលិង្គោ ចក្កវត្តិ
ធម្មេន បថវិមនុសាសិ
អគមាសិ(១) ពោធិសមីបំ
នាគេន មហានុភាវេន ។

---

១ ម. អគមា ។



[១០៨៤] បពិត្រព្រះអង្គជាធំជាងជន ខ្ញុំព្រះអង្គ (សូមទ្យ) ពួកគហបតី ពួករាជបុរស ពួកព្រាហ្មណមហាសាល បានក្ដារមាស ៧ បពិត្រមហារាជ ក្ដារមាសរបស់ខ្ញុំព្រះអង្គនោះបាត់ ហេតុនោះបានជាខ្ញុំព្រះអង្គសោកដ៏ក្រៃលែង ។

[១០៨៥] បពិត្រមហារាជ ពួករាជបុរសរបស់ព្រះអង្គ ខ្ញុំព្រះអង្គបានត្រិះរិះដោយចិត្តថា មិនអាចដើម្បីជួយដោះខ្ញុំព្រះអង្គឲ្យរួចចាកទុក្ខបានទេ ហេតុនោះ ខ្ញុំព្រះអង្គ មិនប្រាប់ដល់រាជបុរសទាំងនោះឡើយ ។

[១០៨៦] បពិត្រមហារាជ ចំណែកព្រះអង្គ ខ្ញុំព្រះអង្គបានត្រិះរិះដោយចិត្តថា ព្រះអង្គអាចជួយដោះទុក្ខបាន ហេតុនោះ ខ្ញុំព្រះអង្គ ទើបក្រាបទូលដល់ព្រះអង្គ ។

[១០៨៧] (អភិសម្ពុទ្ធគាថា) ព្រះបាទកាសី ជាអ្នកចំរើនដែនរបស់អ្នកកាសី មានព្រះហឫទ័យជ្រះថ្លា បានប្រទានក្ដារមាសសុទ្ធ ចំនួន ១៤ ដុំ ដល់មហាសត្វនោះ ។

ចប់ ទូតជាតក ទី ៥ ។

## កាលិង្គពោធិជាតក

[១០៨៨] (អភិសម្ពុទ្ធគាថា) ព្រះបាទកាលិង្គជាស្ដេចចក្រពត្តិ គ្រប់គ្រងមនុស្សលើផែនដី ដោយធម៌ ស្ដេចបានមកដល់ទីជិតពោធិព្រឹក្ស ដោយដំរីមានអានុភាពធំ ។

[១០៨៩] កាលិង្គោ ភារទ្វាជោ ច
រាជានំ កាលិង្គំ សមណកោលញ្ញំ
ចក្កំ វត្តយតោ បរិគ្គហេត្វា
បញ្ជលី ឥទមព្រវិ ។

[១០៩០] បច្ចោរោហ មហារាជ
ភូមិភាគោ យថា សមណុគ្គិតោ(១)
ឥធ អនធិវរា ពុទ្ធា
អភិសម្ពុទ្ធា វិរោចន្តិ ។

[១០៩១] បទក្ខិណតោ អាវដ្ដា
តិណលតា អស្មឹ ភូមិភាគស្មឹ
បថវិយា អយំ មណ្ឌោ
ឥតិ នោ សុតំ មហារាជ ។

[១០៩២] សាគរបរិយន្តាយ (មេទនិយា)
សព្វភូតធរណិយា
បថវិយា អយំ(២) មណ្ឌោ
ឱរោហិត្វា នមោ ករោហិ ។

១ ម. សមណុគ្គតោ ។ ២ ឱ ម. បឋវិយាយំ ។



(១០៨៩) ភារទ្វាជព្រាហ្មណ៍បុរោហិត នៅក្នុងដែនកាលិង្គ លើកអញ្ជលី ចំពោះព្រះរាជា ចក្រពត្តិ ដែលទ្រង់ប្រសូតចាកត្រកូលសមណៈព្រះនាមចុល្លកាលិង្គ ក្រាបទូលពាក្យនេះថា

(១០៩០) បពិត្រមហារាជ សូមព្រះអង្គស្តេចចុះមក ចំណែកនៃផែនដីនេះ ជាប្រទេសដែលសមណៈសរសើរហើយ ព្រះពុទ្ធទាំងឡាយមានគុណថ្លឹងមិនបាន កើតត្រាស់ដឹងហើយ រុងរឿងក្នុងទីនេះ ។

(១០៩១) បពិត្រមហារាជ តាមដែលខ្ញុំព្រះអង្គឮមកថា ស្មៅនិងវល្លិ៍ទាំងឡាយ ក្នុងចំណែកនៃផែនដីនេះ វិលក្តោងទៅខាងស្តាំ នេះជាផ្ចិតនៃផែនដី ។

(១០៩២) ផ្ចិតនៃផែនដីនេះ ដែលមានសមុទ្រសាគរជាទីបំផុត ជាទីទ្រទ្រង់នូវសត្វទាំងពួង សូមព្រះអង្គស្តេចចុះមក ធ្វើនមស្ការ ។

(១០៨៣) យេ តេ ភវន្តិ នាគា ច
អភិជាតា ច កុញ្ជរា
ឯត្តាវតា បទេសំ តេ
នាគា នេវុបយន្តិ ។

(១០៨៤) អភិជាតោ នាគោ កាមំ
បេសេហិ កុញ្ជរំ ទន្តិ
ឯត្តាវតា បទេសោ ច
ន សក្កា នាគេន ឧបគន្តុំ ។

(១០៨៥) តំ សុត្វា រាជា កាលិង្គោ
វេយ្យញ្ជនិកវចោ និសាមេត្វា
សម្បេសេសិ នាគំ ឧយ្យាម(១)
មយំ យថា ឥមំ វចនំ ។

(១០៨៦) សម្បេសិតោ ច រញ្ញា នាគោ
កោញ្ចោ អភិនទិត្វាន
បដិសក្កិត្វា(២) និសីទិ
គរុភារំ អសហមានោ ។

---

១ ឱ. ញស្សាម ។ ម. ទស្សាម ។ ២ ម. បដិសេក្កិត្វា ។





(១០៨៣) ពួកដំរីណា ដែលកើត ក្នុងឧបោសថត្រកូល ជាដំរីដ៏ប្រសើរ ដំរីទាំងនោះ រមែងមិនហ៊ានចូលទៅកាន់ប្រទេស មានប្រមាណប៉ុណ្ណេះទេ ។

(១០៨៤) ដំរី កើតក្នុងឧបោសថត្រកូល ក៏ពិតហើយ តែថា ប្រទេសប៉ុណ្ណោះនេះ ដំរីនុ៎ះមិនហ៊ានចូលទៅជិតទេ សូមព្រះអង្គយកកង្វេរ (កាប់) បញ្ជូនដំរីដ៏ប្រសើរ ដែលគេបានបង្ហឹកហើយ (ឲ្យចូលទៅមើល) ។

(១០៨៥) ព្រះបាទកាលិង្គ ទ្រង់ព្រះសណ្ដាប់ពាក្យព្រាហ្មណ៍បុរោហិតនោះហើយ ទ្រង់ពិចារណា តាមពាក្យបុរោហិតជាអ្នកមើលលក្ខណៈ ទើបបញ្ជូនដំរីដ៏ប្រសើរ ដែលកើតក្នុងឧបោសថត្រកូល ដោយគិតថា យើងនឹងដឹង (ដំរី) ចូលទៅ តាមពាក្យរបស់បុរោហិតនេះលើមើល ។

(១០៨៦) ឯដំរីដែលស្ដេចបញ្ជូនទៅ ក៏មិនអាចទទួលភារៈ ដ៏ធ្ងន់បាន ហើយស្រែកដូចជាសត្វក្រៀល ថយក្រោយ អង្គុយ (លើអាកាស) ។

(១០៩៧) កាលិង្គោ ភារទ្វាជោ នាគំ ខីណាយុកំ
វិទិត្វាន រាជានំ កាលិង្គំ តរមានោ
អជ្ឈភាសិត្ថ អញ្ញំ សង្កម នាគំ
នាគោ ខីណាយុកោ មហារាជ ។

(១០៩៨) តំ សុត្វា កាលិង្គោ តរមានោ
សង្កមិ នាគំ សង្កន្តេ រញ្ញេ
នាគោ តត្ថេវ បតិ ភុម្យា
វេយ្យញ្ជនិកវចោ[១] យថា តថា អហុ នាគោ ។

(១០៩៩) កាលិង្គោ ភារទ្វាជំ កាលិង្គោ ព្រាហ្មណំ ឥទមវោច[២]
ត្វមេវាសិ សម្ពុទ្ធោ សព្វញ្ញូ សព្វទស្សាវី ។

(១១០០) តំ អនធិវាសេន្តោ កាលិង្គំ[៣]
ព្រាហ្មណោ ឥទមវោច
វេយ្យញ្ជនិកា ហិ មយំ
ពុទ្ធា សព្វញ្ញុនោ មហារាជ ។

---

១ ឱ. ....និយាកោ ។ ២ ម. កលិង្គោ រាជា កលិង្គំ ព្រាហ្មណំ ឥទមវោច ។
៣ ឱ. តំ រាជំ អនធិវាសេន្តោ កាលិង្គោ ។ ម. តំ អនធិវាសេន្តោ កលិង្គំ ។



(១០៩៧) ភារទ្វាជព្រាហ្មណ៍ ក្នុងដែនកាលិង្គដឹងថា ដំរីនោះអស់អាយុហើយ ក៏ប្រញាប់ក្រាបទូលព្រះបាទកាលិង្គថា បពិត្រមហារាជ សូមព្រះអង្គឆ្លងដំរីដទៃវិញ ព្រោះដំរីនេះអស់អាយុហើយ ។

(១០៩៨) ព្រះបាទកាលិង្គបានឮពាក្យនោះហើយ ក៏ទ្រង់ប្រញាប់ទៅកាន់ដំរី (ដទៃ) កាលបើស្ដេចទ្រង់ឈានឆ្លងទៅហើយ ដំរីក៏ដួលធ្លាក់មកលើផែនដី ក្នុងទីនោះឯង ពាក្យព្រាហ្មណ៍បុរោហិត អ្នកទាយលក្ខណៈយ៉ាងណា ដំរីក៏យ៉ាងនោះ ។

(១០៩៩) ព្រះបាទកាលិង្គ មានព្រះរាជឱង្ការនេះ នឹងកាលិង្គភារទ្វាជ-ព្រាហ្មណ៍ថា អ្នកឯង ជាមនុស្សត្រាស់ដឹងដោយប្រពៃ ជាសព្វញ្ញូ ឃើញការសព្វគ្រប់ ។

(១១០០) កាលិង្គភារទ្វាជព្រាហ្មណ៍ មិនទទួលការសរសើរនោះ ក៏ក្រាបបង្គំទូលស្ដេចថា បពិត្រមហារាជ ទូលព្រះបង្គំជាខ្ញុំ ត្រាន់តែជាអ្នកទាយលក្ខណៈ ព្រះពុទ្ធទាំងឡាយ ទើបព្រះអង្គជាសព្វញ្ញូ ។

(១១០១) សព្វញ្ញូ សព្វវិទូ ច
ពុទ្ធា លក្ខណេន ជានន្តិ
អាគមពលសា ហិ មយំ
ពុទ្ធា សព្វំ បជានន្តិ ។

(១១០២) បហំសិត្វាន(១) សត្តាហំ
នានាតុរិយេហិ វជ្ជមានេហិ
មាលាវិលេបនំ អភិហរិត្វា
បាការបរិក្ខេបំ ការេសិ អថ រាជា បាយាសិ ។

(១១០៣) សដ្ឋិវាហសហស្សានិ បុប្ផានិ សន្និបាតយិ
បូជេសិ រាជា កាលិង្គោ ពោធិមណ្ឌមនុត្តរន្តិ ។

កាលិង្គពោធិជាតកំ ឆដ្ឋំ ។

## អកិត្តិជាតកំ

(១១០៤) អកិត្តិំ ទិស្វាន សម្មន្តំ(២) សក្កោ ភូតបតី ព្រវិ
កោ បព្ពយំ មហាព្រហ្មេ ឯកោ សម្មសិ ឃម្មនិ ។

១ ម. បហោយិត្វាន ។ ម. មហយិត្វាន ។ ២ ម. ម. សម្មន្តំ ។



(១១០១) ព្រះពុទ្ធទាំងឡាយព្រះអង្គដឹងនូវសព្វ ជ្រាបសព្វ តែងដឹងដោយលក្ខណៈ ចំណែកយើងទាំង (ទេវតា) ដោយសារកំឡាំងសិល្ប-សាស្ត្រ ព្រះពុទ្ធទាំងឡាយ ទើបព្រះអង្គទ្រង់ជ្រាបសព្វ ។

(១១០២) ព្រះបាទកាលិង្គ ទ្រង់ចាត់ចែងពោធិមណ្ឌល ហើយនាំយកផ្កា កម្រងនឹងគ្រឿងក្រអូប គ្រឿងលាប ព្រមទាំងតូរ្យតន្ត្រីទាំងឡាយ ផ្សេងៗ ទ្រង់ឲ្យធ្វើកំពែងព័ទ្ធជុំវិញ ហើយទើបទ្រង់យាងចេញទៅ ។

(១១០៣) ព្រះបាទកាលិង្គ បានឲ្យគេប្រមូល ផ្កាឈើទាំងឡាយ ចំនួនប្រាំមួយហ៊ឺនរទេះ មកបូជាកន្លែងពោធិព្រឹក្ស ដ៏ប្រសើរបំផុត (នោះ) ។

ចប់ កាលិង្គពោធិជាតក ទី ៦ ។

## អកិត្តិជាតក

(១១០៤) (អភិសម្ពុទ្ធគាថា) សក្កទេវរាជ ជាម្ចាស់នៃសត្វ លុះឃើញអកិត្តិបណ្ឌិត កំពុងគិតនៅ ទើបសួរថា បពិត្រមហាព្រហ្ម លោកព្រោះទុក្ខដូចម្ដេច បានជាមកគិតនៅ គង់ទីក្ដៅម្នាក់ឯង ។

(១១០៥)ទុក្ខោ បុនព្ភវោ សក្ក សរីរស្ស ច ភេទនំ
សម្មោហមរណំ ទុក្ខំ តស្មា សម្មាមិ កោសិយ ។

(១១០៦)ឯតស្មឹ តេ សុលបិតេ បតិរូបេ សុភាសិតេ
វរំ កស្សប តេ ទម្មិ យំ កិញ្ចិ មនសិច្ឆសិ ។

(១១០៧)វរញ្ចេ មេ អទោ សក្ក សព្វភូតានមិស្សរ
យេន បុត្តេ ច ទារេ ច ធនធញ្ញំ បិយានិ ច
លទ្ធា នរា ន តប្បន្តិ(១) សោ លោភោ ន មយិ វសេ ។

(១១០៨)ឯតស្មឹ តេ សុលបិតេ បតិរូបេ សុភាសិតេ
វរំ កស្សប តេ ទម្មិ យំ កិញ្ចិ មនសិច្ឆសិ ។

(១១០៩)វរញ្ចេ មេ អទោ សក្ក សព្វភូតានមិស្សរ
ខេត្តំ វត្ថុំ ហិរញ្ញញ្ច គវាស្សំ ទាសពោរិសំ
យេន ជាតេន ជីយន្តិ សោ ទោសោ ន មយិ វសេ ។

---

១ ម. នាភិតប្បន្តិ ។



(១១០៥) (អកិត្តិតាបស ឆ្លើយថា) បពិត្រសក្កៈ ការកើតក្នុងភពថ្មីទៀត នាំមកនូវសេចក្តីទុក្ខ ការបែកធ្លាយនៃសរីរៈ នាំមកនូវសេចក្តីទុក្ខ ការស្លាប់ព្រោះតែវង្វេង ក៏នាំមកនូវសេចក្តីទុក្ខ បពិត្រកោសិយៈ ហេតុនោះ បានជាអាត្មា (អត្ថយស្រាប់ព្រះនិព្វាន) ។

(១១០៦) (សក្កៈ...) សុភាសិតពីសមគួរនេះ លោកបានពោលល្អ ហើយ បពិត្រកស្សបៈ លោកមានចិត្តប្រាថ្នា ចង់បានពរណា ខ្ញុំប្រគេនពរនោះ ដល់លោក ។

(១១០៧) (អកិត្តិ...) បពិត្រសក្កៈ ជាធំជាងសត្វទាំងពួង បើព្រះអង្គ ប្រទានពរដល់អាត្មា នរជនបានកូន ប្រពន្ធ ទ្រព្យស្រូវនិងវត្ថុដែល ជាទីស្រឡាញ់ ហើយនិងមិនឆ្អែតស្កប់ស្កល់ ដោយលោភៈណា សូម កុំឲ្យលោភៈនោះ នៅក្នុងសន្តានរបស់អាត្មាបានឡើយ ។

(១១០៨) (សក្កៈ...) សុភាសិតពីសមគួរនេះ លោកបានពោលល្អហើយ បពិត្រកស្សបៈ លោកមានចិត្តប្រាថ្នាពរណា ខ្ញុំប្រគេនពរនោះ ដល់លោក ។

(១១០៩) (អកិត្តិ...) បពិត្រសក្កៈជាធំជាងសត្វទាំងពួង បើព្រះអង្គប្រទានពរដល់អាត្មា ពួកជន រមែងញាំញីស្រែចំការ ប្រាក់មាស គោ សេះ និងទាសបុរស ដោយទោសៈណា ដែលកើតហើយ សូមកុំ ឲ្យទោសៈនោះ នៅក្នុងសន្តានអាត្មាបានឡើយ ។

(១១១០) ឯតស្មឹ តេ សុលបិតេ   បដិរូបេ សុភាសិតេ
វរំ កស្សប តេ ទម្មិ   យំ កិញ្ចិ មនសិច្ឆសិ។

(១១១១) វរញ្ចេ មេ អទោ សក្ក   សព្វភូតានមិស្សរ
ពាលំ ន បស្សេ ន សុណេ   ន ច ពាលេន សំវសេ
ពាលេនល្លាបសល្លាបំ   ន ករេ ន ច រោចយេ។

(១១១២) កិន្នុ តេ អករំ ពាលោ   វទ កស្សប ការណំ
កេន កស្សប ពាលស្ស   ទស្សនំ នាភិកង្ខសិ។

(១១១៣) អនយំ នយតិ ទុម្មេធោ   អធុរាយំ និយុញ្ជតិ
ទុន្នយោ សេយ្យសោ ហោតិ   សម្មា វុត្តោ បកុប្បតិ
វិនយំ សោ ន ជានាតិ   សាធុ តស្ស អទស្សនំ។

(១១១៤) ឯតស្មឹ តេ សុលបិតេ   បដិរូបេ សុភាសិតេ
វរំ កស្សប តេ ទម្មិ   យំ កិញ្ចិ មនសិច្ឆសិ។



(១១១០) (សក្កៈ...) សុភាសិតដ៏សមគួរនេះ លោកបាននិយាយល្អហើយ បពិត្រកស្សបៈ លោកមានចិត្តប្រាថ្នាពរណា ខ្ញុំប្រគេនពរនោះ ដល់លោក ។

(១១១១) (អកិត្តិ...) បពិត្រសក្កៈជាធំជាងសត្វទាំងពួង បើព្រះអង្គប្រទានពរដល់អាត្មា អាត្មាសូមកុំឲ្យជួបនឹងមនុស្សពាល សូមកុំឲ្យឮដំណឹងមនុស្សពាល សូមកុំឲ្យនៅរួមនឹងមនុស្សពាល សូមកុំឲ្យបានធ្វើទាំងកុំឲ្យពេញចិត្តនឹងការចរចា ទៅមកនឹងមនុស្សពាល ។

(១១១២) (សក្ក...) មនុស្សពាលបានធ្វើអ្វីដល់លោក បពិត្រកស្សបៈ សូមលោកប្រាប់ហេតុ បពិត្រកស្សបៈ ហេតុអ្វី បានជាលោកមិនប្រាថ្នាជួបមនុស្សពាល ។

(១១១៣) (អកិត្តិ...) បុគ្គលពាល រមែងនាំទៅនូវអំពើមិនគួរនាំ រមែងប្រកបនូវកិច្ចមិនមែនជាធុរៈ ការណែនាំទៅរកអាក្រក់ ជាការប្រសើរ (របស់បុគ្គលពាលនោះ) បុគ្គលពាលបើគេនិយាយត្រូវ ក៏ទៅជាខឹង បុគ្គលពាល រមែងមិនដឹងច្បាប់ទម្លាប់ ការមិនជួបប្រទះនឹងបុគ្គលពាលនោះ ជាការប្រពៃ ។

(១១១៤) (សក្កៈ..) សុភាសិតដ៏សមគួរនេះ លោកបាននិយាយល្អហើយ បពិត្រកស្សបៈ លោកមានចិត្តប្រាថ្នាពរណា ខ្ញុំប្រគេនពរនោះ ដល់លោក ។

[១១១៥] វរញ្ចេ មេ អទោ សក្ក សព្វភូតានមិស្សរ
ធីរំ បស្សេ សុណេ ធីរំ ធីរេន សហ សំវសេ
ធីរេនល្លាបសល្លាបំ តំ ករេ តញ្ច រោចយេ ។

[១១១៦] កិន្នុ តេ អការំ ធីរោ វទ កស្សប ការណំ
កេន កស្សប ធីរស្ស ទស្សនំ អភិកង្ខសិ ។

[១១១៧] នយំ នយតិ មេធាវី អធុរាយំ ន យុញ្ជតិ
សុនយោ សេយ្យសោ ហោតិ សម្មាវុត្តោ ន កុប្បតិ
វិនយំ សោ បជានាតិ សាធុ តេន សមាគមោ ។

[១១១៨] ឯតស្មឹ តេ សុលបិតេ បដិរូប សុភាសិតេ
វរំ កស្សប តេ ទម្មិ យង្កិញ្ចិ មនសិច្ឆសិ ។



(១១១៥) (អកិត្តិ...) បពិត្រសក្កៈ ជាធំជាងសព្វសត្វទាំងពួង បើព្រះអង្គនឹងប្រទានពរដល់អាត្មា អាត្មាសូមឲ្យជួបប្រទះអ្នកប្រាជ្ញ សូមឲ្យស្តាប់អ្នកប្រាជ្ញ សូមឲ្យនៅរួមជាមួយនឹងអ្នកប្រាជ្ញ សូមឲ្យបានធ្វើ ទាំងសូមឲ្យបានចូលចិត្តនឹងការចរចារទៅមក ជាមួយនឹងអ្នកប្រាជ្ញនោះ ។

(១១១៦) (សក្កៈ...) អ្នកប្រាជ្ញបានធ្វើប្រយោជន៍អ្វីដល់លោក បពិត្រកស្សបៈ សូមលោកប្រាប់ហេតុ បពិត្រកស្សបៈ ហេតុអ្វីបានជាលោកចង់ជួបប្រទះអ្នកប្រាជ្ញ ។

(១១១៧) (អកិត្តិ...) អ្នកប្រាជ្ញ រមែងណែនាំនូវហេតុ ដែលគួរដឹកនាំ រមែងមិនប្រកបនូវកិច្ចដែលមិនមែនជាធុរៈ ការដឹកនាំល្អ ជាការប្រសើរ (របស់អ្នកប្រាជ្ញនោះ) អ្នកប្រាជ្ញ បើគេនិយាយត្រូវហើយ រមែងមិនក្រោធ អ្នកប្រាជ្ញនោះ រមែងដឹងច្បាប់ ការសេពគប់ជាមួយនឹងអ្នកប្រាជ្ញនោះ ជាការប្រពៃ ។

(១១១៨) (សក្កៈ...) សុភាសិតដ៏សមគួរនេះ លោកបានពោលល្អហើយ បពិត្រកស្សបៈ លោកមានចិត្តប្រាថ្នាពរណា ខ្ញុំនឹងប្រគេនពរនោះដល់លោក ។

(១១៥៩)វរញ្ចេ មេ អទោ សក្ក  សព្វភូតានមិស្សរ
តតោ រត្យា វិវសនេ  សុរិយស្សុគ្គមនំ បតិ
ទិព្វា ភក្ខា បាតុភវេយ្យុំ  សីលវន្តោ ច យាចកា
ទទតោ មេ ន ខីយេថ  ទត្វា នានុតបេយ្យហំ
ទទំ ចិត្តំ បសាទេយ្យំ  ឯតំ សក្ក វរំ វរេ ។
(១១៦០)ឯតស្មឹ តេ សុលបិតេ  បតិរូបេ សុភាសិតេ
វរំ កស្សប តេ ទម្មិ  យំ កិញ្ចិ មនសិច្ឆសិ ។
(១១៦១)វរញ្ចេ មេ អទោ សក្ក  សព្វភូតានមិស្សរ
ន មំ បុន ឧបេយ្យាសិ  ឯតំ សក្ក វរំ វរេ ។
(១១៦២)ពហូហិ វត្តចរិយាហិ  នរា ច អថ នារិយោ
ទស្សនំ អភិកង្ខន្តិ  កិន្នុ មេ ទស្សនេ ភយំ ។
(១១៦៣)តំ តាទិសំ ទេវវណ្ណំ  សព្វកាមសមិទ្ធិនំ
ទិស្វា តបោ បមជ្ជេយ្យំ[១] ឯតំ តេ ទស្សនេ ភយន្តិ ។

អកិត្តិជាតកំ សត្តមំ ។

១ ម. បមជ្ជេយ្យ ។



(១១៥៩) (អកិត្តិ ..) បពិត្រសក្កៈ ជាធំជាងសត្វទាំងពួង បើព្រះអង្គប្រទានពរដល់អាត្មា លុះកាលរាត្រីនោះអស់ហើយ ព្រះអាទិត្យកំពុងរះឡើង សូមឲ្យទិព្វភោជនកើតប្រាកដ ទាំងពួកយាចកអ្នកមានសីល (គប្បីមក) កាលបើអាត្មាឲ្យ សូមទិព្វភោជនកុំឲ្យអស់ លុះឲ្យហើយ សូមកុំឲ្យក្តៅក្រហាយក្រោយ កាលបើកំពុងឲ្យ គប្បីឲ្យមានចិត្តជ្រះថ្លា បពិត្រសក្កៈ សូមព្រះអង្គប្រទានពរនុ៎ះចុះ ។

(១១៦០) (សក្កៈ...) សុភាសិតដ៏សមគួរនេះ លោកបានពោលល្អហើយ បពិត្រកស្សបៈ លោកមានចិត្តប្រាថ្នាពរណា ខ្ញុំនឹងប្រគេនពរនោះដល់លោក ។

(១១៦១) (អកិត្តិ...) បពិត្រសក្កៈ ជាធំជាងសត្វទាំងពួង បើព្រះអង្គប្រទានពរដល់អាត្មា ព្រះអង្គកុំចូលមកកាន់អាត្មាទៀតឡើយ បពិត្រសក្កៈ សូមព្រះអង្គប្រទានពរនុ៎ះចុះ ។

(១១៦២) (សក្កៈ...) ពួកជនប្រុសស្រី តែងចង់ឃើញ (ខ្ញុំ) ដោយការប្រព្រឹត្តវត្តដ៏ច្រើនចុះ ភ័យក្នុងការឃើញខ្ញុំ (មានដល់លោក) ។

(១១៦៣) (អកិត្តិ...) អាត្មា ឃើញព្រះអង្គ មានភេទជាទេវតាប្រាកដដូច្នោះ មានសេចក្តីប្រាថ្នាទាំងពួងសម្រេចហើយ គប្បីប្រហែសក្នុងតបធម៌ ភ័យក្នុងការឃើញព្រះអង្គនុ៎ះ មានដល់(អាត្មា) ។

ចប់ អកិត្តិជាតក ទី ៧ ។

## តក្ការិយជាតកំ

(១១៦៤) អហមេវ ទុព្ភាសិតំ ភាសិ ពាលោ
ភេកោវរញ្ញេ អភិវស្សមានោ
តក្ការិយេ សោព្ភមិមំ បតាមិ(១)
ន កិរេវ សាធុ អតិវេលភាណី ។

(១១៦៥) បប្បោតិ មច្ចោ អតិវេលភាណី
ពន្ធំ(២) វធំ សោកបរិទ្ទវញ្ច
អត្តានមេវ គរហាសិ ឯត្ថ
អាចេរិយ តំ និខណន្តិ សោព្ភេ ។

(១១៦៦) កិមេវហំ តុណ្ឌិលំ អនុបុច្ឆឹ
ករេយ្យាសំ ភាតរំ កាលិកាយ(៣)
នគ្គោវហំ វត្ថយុគញ្ច ជិនោ
អយម្បិ អត្ថោ ពហុ តាទិសោវ ។

---

១ ម. សោព្ភម្ហិ អហំ បតាមិ ។ ២ ម. ពន្ធំ ។ ៣ ម. ករេយ្យ សំភាតរំ កាលិ-កាយំ ។ ម. ករេយ្យ សភាតរំ កាឡិកាយ ។



## តក្ការិយជាតក

(១១៦៤) (ព្រាហ្មណ៍បុរោហិត និយាយថា) ខ្ញុំឯង ជាមនុស្សល្ងង់ និយាយសំដីអាក្រក់ ដូចជាកង្កែបហៅពស់ក្នុងព្រៃ ម្នាលតក្ការិយៈ ខ្ញុំធ្លាក់ក្នុងរណ្តៅនេះ ព្រោះថា បុគ្គលនិយាយហួសប្រមាណ មិនប្រពៃឡើយ ។

(១១៦៥) (តក្ការិយមាណពតបថា) បុគ្គលអ្នកនិយាយហួសប្រមាណ តែងដល់នូវការចង ការសម្លាប់ សោកនិងខ្សឹកខ្សួល លោកតិះដៀលខ្លួនលោក ព្រោះតែហេតុនោះ បពិត្រលោកអាចារ្យ ពួកជនកប់លោកក្នុងរណ្តៅ ឥឡូវនេះ ។

(១១៦៦) (មហាសត្វដំណាលពីសេដ្ឋីបុត្រ និយាយថា) ថ្វីបានជាអញសួរ អញយកការទៅតុណ្ឌិលៈជាបងនាងកាលី បានជាអញត្រូវតែដណ្ដើមយកសំពត់ទាំងគូ ហើយជាមនុស្សអាក្រាត ដំណើរនេះឯង ប្រហែលគ្នានឹងលោក ច្រើនប្រការ ។

(១១៦៧) យោ យុជ្ឈមានានំ(១) អយុជ្ឈមានោ
មេណ្ឌន្តរំ អច្ចុបតី កុលិង្គោ
សោ បិសិតោ មេណ្ឌសិរេហិ តត្ថ
អយម្បិ អត្ថោ ពហុ តាទិសោវ ។

(១១៦៨) ចតុរោ ជនា បោត្ថកមគ្គហេសុំ
ឯកញ្ច បោសំ អនុរក្ខមានា
សព្វេវ តេ ភិន្នសិរា សយឹសុ
អយម្បិ អត្ថោ ពហុ តាទិសោវ ។

(១១៦៩) អជា យថា វេឡុគុម្ពស្មឹ ពទ្ធា(២)
អវេក្ខិបន្តី អសិមជ្ឈគច្ឆិ(៣)
តេនេវ តស្សា គលកា វិកន្តា(៤)
អយម្បិ អត្ថោ ពហុ តាទិសោវ ។

១ ម. យុជ្ឈមានេន ។ ២ ឱ. ពទ្ធា ។ ម. ពន្ធំ ។ ៣ ឱ. អជ្ឈគញ្ឆិ ។ ម. អសិំ មជ្ឈគច្ឆិ ។ ៤ ឱ. គលស្សា គលកា វិកន្តំ ។ ម. គលស្ស គលយោ វិកន្តុំ ។



(១១៦៧) (ដំណាលរឿងកុកសត្វថា) កាលពពែទាំងពីរ កំពុងតែជល់គ្នា កុកសត្វណា ចូលទៅត្រង់ចន្លោះពពែ កុកសត្វនោះ ត្រូវក្បាលពពែទាំងពីរ ចង្កិចខ្ទេចក្នុងទីនោះ ដំណើរនេះ ប្រហែលគ្នានឹងលោក ច្រើនយ៉ាង ។

(១១៦៨) (ដំណាលរឿងជន ៤ នាក់ថា) ជន ៤ នាក់ កាន់ជាយក្រណាត់ត្រងបុរសម្នាក់ (ដែលលោតពីចុងត្នោត) ជនទាំង ៤ នាក់ នោះ បែកក្បាលដួលស្លាប់ ដំណើរនេះប្រហែលគ្នានឹងលោក ច្រើនយ៉ាង ។

(១១៦៩) (ដំណាលរឿងពពែថា) ដូចជាមេពពែ ដែលគេចងទុក ក្បែរគុម្ពឫស្សី ទាត់ជើងក្រោយលេង បានជាន់កាំបិត ហេតុនោះ បានជាទោរ កាំបិតកាត់កមេពពែនោះ ដំណើរនេះឯងប្រហែលគ្នានឹងលោក ច្រើនយ៉ាង ។

(១១៣០) នយិមេ ទេវា(១) នាបិ គន្ធព្វបុត្តា
មិគា ឥមេ អត្ថវសំ គតា ឥមេ(២)
ឯកញ្ច នំ សាយមាសេ បចន្តុ
ឯកំ បុនប្បាតរាសេ(៣) បចន្តុ ។

(១១៣១) សតំ សហស្សាន ទុព្ភាសិតានំ
កលម្បិ នាគ្ឃតិ សុភាសិតស្ស
ទុព្ភាសិតំ សង្កមានោ កិលេសោ
តស្មា តុណ្ហី កិំបុរិសោ ន ពាល្យា ។

(១១៣២) យា មេសា ព្យាកាសិ បមុញ្ចថេតំ
គិរិញ្ច នំ(៤) ហិមវន្តំ នយន្តុ
ឥមញ្ច ខោ ទេន្តុ មហានសាយ
បាតោវ នំ បាតរាសេ បចន្តុ ។

(១១៣៣) បជ្ជុន្នាថា បសវោ  បសុនាថា អយំ បជា
ត្វំ នាថោសិ(៥) មហារាជ  អម្ហនាថា មម ភរិយា(៦)
ទ្វិន្នមញ្ញតរំ ញត្វា  មុត្តោ គច្ឆេយ្យ បព្វតំ ។

---

១ ម. ឥមេ ន ទេវា ។ ២ ម. អត្ថវសំ គតាមេ ។ ៣ ម. ឯកញ្ច នំ បាតរាសេ ។ ៤ ម. គិរិំ ។ ៥ ម. នាថោសិ ។ ៦ ឱ. នាថេហំ ភរិយាយ ច ។ ម. នាថោហំ ភរិយាយ មេ ។



(១១៣០) (ដំណាលរឿងព្រះរាជាពារាណសីត្រាស់ថា) កិន្នរទាំងពីរនេះ មិនមែនជាទេវតា មិនមែនជាគន្ធព្វបុត្រទេ កិន្នរទាំងនេះជាម្រឹគទេ កិន្នរទាំងនេះ ព្រានព្រៃបាននាំមក ដោយអំណាចប្រយោជន៍ ពួកអ្នកធ្វើក្រយាស្ងោយ ចូរចំអិនកិន្នរមួយនោះ ក្នុងពេលបាយល្ងាច ចូរចំអិនកិន្នរមួយទៀត ក្នុងពេលបាយព្រឹក ។

(១១៣១) (រឿងកិន្នរីទូលព្រះរាជាថា) ពាក្យជាទុព្ភាសិត មួយសែនម៉ាត់ ក៏មិនដល់មួយចំណិត នៃពាក្យជាសុភាសិតឡើយ បុគ្គលកាលខ្លាចនូវពាក្យជាទុព្ភាសិត រមែងលំបាក ព្រោះហេតុនោះ កិន្នរនៅស្ងៀម មិនមែនព្រោះល្ងង់ទេ ។

(១១៣២) (ព្រះរាជាត្រាស់ថា) កិន្នរីណាបាននិយាយនឹងអញ អ្នកទាំងឡាយ ចូរលែងកិន្នរីនុ៎ះចេញ ចូរនាំកិន្នរនោះទៅកាន់ហិមពាន្ត អ្នកទាំងឡាយ ចូរប្រគល់កិន្នរនេះ ដើម្បីរោងគ្រួ ចូរចំអិនវា ក្នុងពេលបាយព្រឹក អំពីព្រលឹម ។

(១១៣៣) (កិន្នរក្រាបទូលថា) ពួកសត្វចិញ្ចឹម មានមេឃជាទីពឹង ពួកមនុស្សមានសត្វចិញ្ចឹមជាទីពឹង បពិត្រមហារាជ ទ្រង់មានព្រះអង្គជាទីពឹង ឯភរិយារបស់ខ្ញុំ មានខ្ញុំជាទីពឹង គប្បីដឹងយើងខ្ញុំទាំងពីរនាក់ សូមឲ្យអ្នកដែលរួច (អំពីសេចក្ដីស្លាប់) ដឹងថា អ្នកណាមួយ (ស្លាប់) ហើយសឹមទៅភ្នំ ។

(១១៣៤) ន វេ និទ្ធា សុបរិវជ្ជយាថ[1]
នានាជនា សេវិតព្វា ជនិន្ទ
យេនេវ ឯកោ លភតេ បសំសំ
តេនេវ អញ្ញោ លភតេ និន្ទិតារំ ។

(១១៣៥) សព្វោ លោកោ បរចិត្តេន អតិចិត្តោ[2]
សព្វោ លោកោ ចិត្តវា សម្ហិ ចិត្តេ
បច្ចេកចិត្តា បុថុ សព្វសត្តា
កស្សីធ ចិត្តស្ស វសេ ន វត្តេ ។

(១១៣៦) តុណ្ហី អហុ កិម្បុរិសោ សភរិយោ[3]
យោ ទានិ ព្យាកាសិ ភយស្ស ភីតោ
សោ ទានិ មុត្តោ សុខិតោ អរោគោ
វាចា កិរេវត្ថវតី[4] នរានំ ។

កក្ការិយជាតកំ អដ្ឋមំ ។

---

១ ឱ. សុបរិវជ្ជយា ខេ ។ ម. សុបរិវជ្ជយេថ ។ ២ ឱ. សព្វោ លោកោ បរ-ចិត្តោ អតិចិត្តោ ។ ម. សព្វោ លោកោ បរិចិត្តោ ។ ៣ អដ្ឋកថាយំ សកាណិសោ ។ ៤ គិរេវត្ថវតី ។



(១១៣៤) បុគ្គលមិនងាយនឹងវៀរនិន្ទាទេ បពិត្រព្រះជនិន្ទ ព្រោះអធ្យាស្រ័យ សេពគប់ របស់ពួកជន អ្នកមានសេចក្តីប្រាថ្នាផ្សេង ៗ គ្នា (លះម័ល) បុគ្គលពួកមួយ បាននូវសេចក្តីសរសើរ ដោយគុណ មានសីលគុណជាដើមណា បុគ្គលឯទៀត បាននូវពាក្យនិន្ទា ដោយគុណមានសីលគុណជាដើមនោះ ទៅវិញ ។

(១១៣៥) សត្វលោកទាំងអស់ មានចិត្តក្រៀវក្រា ដោយចិត្តផ្សេងគ្នា សត្វលោកទាំងអស់ មានចិត្តប្រព្រឹត្តទៅ ក្នុងចិត្តរបស់ខ្លួន ពួកសត្វទាំងអស់ មានចិត្តផ្សេង ៗ គ្នា មានប្រភេទដ៏ច្រើន ក្នុងលោកនេះ បុគ្គលមិនលុះអំណាចចិត្ត របស់បុគ្គលណា បានឡើយ ។

(១១៣៦) (ព្រះរាជា...) កិន្នរណា ព្រមទាំងភរិយានៅស្ងៀម ឥឡូវនេះ ភ័យហើយ បានដោះសា កិន្នរនោះ រួចអំពីភ័យ ដល់នូវសេចក្តីសុខ មិនមានរោគក្នុងកាលឥឡូវនេះចុះ វាចារបស់ជនទាំងឡាយ ជាវាចាមានប្រយោជន៍ ។

ចប់ កក្ការិយជាតក ទី ៨ ។

# រុរុមិគជាតកំ[១]

(១១៣៧) តស្ស[២] គាមវរំ ទម្មិ   នារិយោ ច អលង្កតា
យោ[៣] មេ តំ មិគមក្ខាសិ   មិគានំ មិគមុត្តមំ ។
(១១៣៨) មយ្ហំ គាមវរំ ទេហិ   នារិយោ ច អលង្កតា
អហំ តេ មិគមក្ខិស្សំ   មិគានំ មិគមុត្តមំ ។
(១១៣៩) ឯតស្មឹ វនសណ្ឌស្មឹ   អម្ពា សាលា ច បុប្ផិតា
ឥន្ទគោបកសញ្ឆន្នា   ឯត្ថេសោ តិដ្ឋតិ មិគោ ។
(១១៤០) ធនុំ អទេឡ្ហំ[៤] កត្វាន   ឧសុំ សន្នយ្ហុបាគមិ
មិគោ ច ទិស្វា រាជានំ   ទូរតោ អជ្ឈភាសថ
អាគមេហិ មហារាជ   មា មំ វិជ្ឈិ រថេសភ
កោ នុ តេ ឥទមក្ខាសិ   ឯត្ថេសោ តិដ្ឋតិ មិគោ ។

១ ឱ. រុរុជាតកំ ។ ម. រុរុមិគរាជជាតកំ ។ ២ ម. តស្ស ។ ៣ ម. យោ ។
៤ ម.សជ្ជំ ។



# រុរុមិគជាតក

(១១៣៧) (ព្រះបាទព្រហ្មទត្ត ប្រកាសថា) នរណា ប្រាប់ម្រឹគនោះ ជាម្រឹគដ៏ឧត្តមជាងម្រឹគទាំងឡាយ ដល់យើង យើងនឹងឲ្យស្រុកសួយនឹងនាងនារី ដែលស្អិតស្អាងហើយ ដល់អ្នកនោះ ។

(១១៣៨) (សេដ្ឋិបុត្ត ក្រាបទូលថា) សូមព្រះអង្គប្រទានស្រុកសួយ នឹងពួកនាងនារី ដែលស្អិតស្អាង ដល់ខ្ញុំព្រះបង្គំជាខ្ញុំចុះ ខ្ញុំព្រះបង្គំជាខ្ញុំនឹងក្រាបទូលម្រឹគនោះ ជាម្រឹគដ៏ឧត្តម ជាងម្រឹគទាំងឡាយ ដល់ព្រះអង្គ ។

(១១៣៩) ដើមស្វាយនឹងដើមសាលព្រឹក្ស ក្នុងដងព្រៃនុ៎ះ មានផ្ការីក (ផែនដី) ដ៏ដេរដាស ដោយស្មៅ មានសម្ផស្សស្រួល មានពណ៌ក្រហមដូចជាសម្បុរនៃសត្វមេភ្លៀង ម្រឹគនុ៎ះ ឋិតនៅក្នុងដងព្រៃនុ៎ះ ។

(១១៤០) (អភិសម្ពុទ្ធគាថា) ព្រះបាទព្រហ្មទត្ត ទ្រង់យកព្រះខ្សែកៅទណ្ឌ ផ្គាប់កាំសរ ហើយស្តេចចូលគម្រង់ទៅ ឯម្រឹគក្រលេកឃើញព្រះរាជាហើយ ក៏ទូលអង្វរពីចម្ងាយថា បពិត្រមហារាជ សូមព្រះអង្គឈប់សិន បពិត្រព្រះអង្គប្រសើរក្នុងរថ សូមព្រះអង្គកុំបាញ់ខ្ញុំព្រះបង្គំជាខ្ញុំឡើយ នរណាគេ បានក្រាបទូលដំណើរនេះដល់ព្រះអង្គថា ម្រឹគនុ៎ះ ឋិតនៅក្នុងដងព្រៃនុ៎ះ ។

(១០៦១) ឯស តាយតេ ហោតោ សោ សព្ទ តិដ្ឋតិ អាវកោ
សោ ហិ មេ វនមក្ខាសិ ឯត្ថេសោ តិដ្ឋតិ មិគោ ។

(១០៦២) សច្ចំ កិរេវមាហំសុ នរា ឯកច្ចិយា ឥធ
កដ្ឋំ និប្លវិតំ(១) សេយ្យោ ន ត្វេវេកច្ចិយោ នរោ ។

(១០៦៣) កិន្នុ រុរុ គរហាសិ មិគានំ
កឹ បក្ខីនំ កឹ បន មានុសានំ
ភយំ ហិ មំ វិន្ទតិនប្បរូបំ
សុត្វាន តំ មានុសិំ(២) ភាសមានំ ។

(១០៦៤) យមុទ្ធរឹ វាហនេ វុយ្ហមានំ
មហោទកេ សលិលេ សីឃសោតេ
តតោនិទានំ ភយមាគតំ មម
ទុក្ខោ ហវេ រាជ អសព្ភិ សង្គមោ ។

---

១ ឱ. និប្លវិតំ ។ ម. និប្លវិតំ ។ ២ ។ តំ មានុសំ ។ ម. តេ មានុសិំ ។



(១០៦១) (ព្រះរាជា...) នែសំឡាញ់ បុរសជាអ្នកប្រព្រឹត្តអាក្រក់លាមកនុ៎ះ ឋិតនៅអំពីចម្ងាយ បុរសនោះ បានប្រាប់ដំណើរនេះ ដល់យើងថា ម្រឹគនុ៎ះ ឋិតនៅក្នុងទីនុ៎ះ ។

(១០៦២) (ម្រឹគមាសពោធិសត្វ...) បានឮមកថា នរជនពួកខ្លះក្នុងលោកនេះ បានពោលពាក្យពិតយ៉ាងនេះថា កំណាត់ឈើដែលគេស្រង់ឡើង ប្រសើរជាង ឯនរជនពួកខ្លះ ដែលគេស្រង់ឡើង មិនប្រសើរទេ ។

(១០៦៣) (ព្រះរាជា...) ម្នាលម្រឹគ អ្នកតិះដៀលម្រឹគទាំងឡាយ ឬបក្សីទាំងឡាយ ឬក៏មនុស្សទាំងឡាយ យើងមានភ័យច្រើន ព្រោះតែឮអ្នកនិយាយ ជាភាសាមនុស្ស ។

(១០៦៤) (ម្រឹគមាស...) ខ្ញុំបានស្រង់មនុស្សណា ដែលរសាត់ទៅក្នុងទឹក មានទឹកច្រើន ទឹកជ្រៅ មានខ្សែទឹក ហូរហាស់ (ខ្លាំង) ភ័យមានមកដល់ខ្លួនព្រះបង្គំជាខ្ញុំហើយ ព្រោះហេតុតែស្រង់មនុស្សនោះ បពិត្រមហារាជ ការប្រជុំនឹងអសប្បុរស តែនាំមកនូវសេចក្តីទុក្ខ ។

(១១៦៥) សោហំ ចតុប្បត្តមិមំ វិហង្គមំ
តន្តុច្ឆិទំ ហាលយេ ឱស្សជ្ជាមិ
ហនាមិ តំ មិត្តទុព្ភិំ អកិច្ចការឹ
យោ តាទិសំ កម្មកតំ ន ជានេ ។

(១១៦៦) ធីរស្ស ពាលស្ស ហវេ ជនិន្ទ
សន្តោ វធំ នប្បសំសន្តិ ជាតុ
កាមំ ឃរំ គច្ឆតុ បាបធម្មោ
យញ្ញស្ស កត្តំ ករេតស្ស ទេហិ
អហញ្ច តេ កាមការោ ភវាមិ ។

(១១៦៧) អទ្ធា ហុ អញ្ញតរោ សតំ សោ
យោ ទុព្ភតោ មានុសស្ស ន ទុព្ភិ
កាមំ ឃរំ គច្ឆតុ បាបធម្មោ
យញ្ញស្ស កត្តំ ករេតស្ស ទម្មិ
អហញ្ច តេ កាមវរំ ទទាមិ ។



(១១៦៥) (ព្រះរាជា...) យើងនឹងបាញ់ព្រួញនេះទៅតាមអាកាស ជាព្រួញមានស្លាបកន្ទុយ ៤ ផ្តាច់ខ្សែសរៈ (ឬសរនោះ) ចំណើមខ្សែ យើងនឹងសម្លាប់មនុស្សនោះ ជាមនុស្សប្រទូស្តមិត្ត ជាអ្នកធ្វើកិច្ចដែលមិនគួរធ្វើ មិនដឹងនូវឧបការគុណ ដែលធ្វើហើយព្រោះដល់ខ្លួននោះ ។

(១១៦៦) (ប្រើសមាស...) បពិត្រព្រះជនិន្ទ សប្បុរសទាំងឡាយ រមែងមិនសរសើរនូវការសម្លាប់របស់អ្នកប្រាជ្ញ ឬមនុស្សពាល ដោយពិត សូមឲ្យមនុស្សអ្នកមានបាបធម៌ទៅផ្ទះ តាមសេចក្តីប្រាថ្នាចុះ កត្តណា (ដែលព្រះអង្គត្រូវប្រទាន) ដល់បុរសនុ៎ះ សូមព្រះអង្គប្រទានកត្តនោះ ដល់បុរសនុ៎ះចុះ ចំណែកខ្ញុំសូមធ្វើ តាមសេចក្តីប្រាថ្នារបស់ព្រះអង្គចុះ ។

(១១៦៧) (ព្រះរាជា...) ម្នាលប្រើសមាស បណ្តាសប្បុរសទាំងឡាយ អ្នកដែលមិនប្រទូស្ត ចំពោះមនុស្ស ដែលប្រទូស្តនោះ គឺជាក់ជាជាសប្បុរសមួយ ដោយពិត មនុស្សមានបាបធម៌ ចូរទៅផ្ទះរបស់ខ្លួន តាមសេចក្តីប្រាថ្នាចុះ កត្តណា (ដែលយើងត្រូវឲ្យ) ដល់បុរសនុ៎ះ យើងនឹងឲ្យកត្តនោះ ដល់បុរសនុ៎ះ មួយទៀត យើងនឹងឲ្យស្រុកសួយដល់អ្នក ។

(១១៦៨) សុវិជានំ សិគាលានំ    សកុណានញ្ច វស្សិតំ
មនុស្សវស្សិតំ រាជ    ទុព្វិជានតរំ តតោ
អបិ ចេ មញ្ញតី បោសោ    ញាតិ មិត្តោ សខាតិ វា
យោ បុព្វេ សុមនោ ហុត្វា    បច្ឆា សម្បជ្ជតេ ទិសោ ។

(១១៦៩) សមាគតា ជានបទា    នេគមា ច សមាគតា
មិគា ធញ្ញំ ខាទន្តិ    តំ ទេវ បដិសេធតុ ។

(១១៧០) កាមំ ជនបទោ មាសិ    រដ្ឋញ្ចាបិ វិនស្សតុ
ន ត្វេវាហំ រុរុំ ទុព្ភេ    ទត្វា អភយ ទក្ខិណំ ។

(១១៧១) មា មេ ជនបទោ អាសិ    មា មំ ជនបទោ អហុ(១)
ន ត្វេវាហំ មិគរាជស្ស    វរំ ទត្វា មុសា ភណេតិ ។

រុរុមិគជាតកំ នវមំ ។

---

១ ម. ច. រដ្ឋញ្ចាបិ វិនស្សតុ ។



(១១៦៨) (ប្រើសមាស...) បពិត្រមហារាជ សំឡេងរបស់ចចក នឹងក្រៀល គេដឹងបានដោយងាយ ឯសំដីរបស់មនុស្ស គេដឹងបានដោយក្រ ជាងសំដីសត្វទាំងនោះទៅទៀត បុរសណាមានចិត្តល្អ គេសំគាល់ថា ជាញាតិ ជាមិត្រ ជាសំឡាញ់ ក្នុងកាលមុន បុរសនោះ វិលមកជាសត្រូវវិញ ក្នុងកាលជាខាងក្រោយ ។

(១១៦៩) (អភិសម្ពុទ្ធគាថា) ពួកអ្នកជនបទ ក៏មកប្រជុំគ្នា ពួកអ្នកនិគមក៏មកប្រជុំគ្នា (ហើយក្រាបទូលស្តេច) ថា ពួកម្រឹគស៊ីស្រូវអស់ហើយ សូមព្រះសម្មតិទេព កំចាត់ពួកម្រឹគនោះចេញ ។

(១១៧០) (ព្រះរាជា...) ចូរកុំឲ្យមានជនបទ ទាំងដែនក៏ចូរវិនាសទៅដោយពិតចុះ យើងឲ្យអភ័យ ដល់ពួកបក្សីហើយ មិនប្រទូស្តប្រើសមាសទេ ។

(១១៧១) យើងមិនមានជនបទក្តី ជនបទមិនមានដល់យើងក្តី យើងឲ្យពរដល់មិគរាជហើយ មិននិយាយពាក្យកុហកទេ ។

ចប់ រុរុមិគជាតក ទី ៩ ។

# សរភជាតកំ

(១១៨២)អាសីសេថេវ បុរិសោ ន និព្វិន្ទេយ្យ បណ្ឌិតោ
បស្សាមិ វោហំ អត្តានំ យថា ឥច្ឆឹ តថា អហុ ។
(១១៨៣)អាសីសេថេវ បុរិសោ ន និព្វិន្ទេយ្យ បណ្ឌិតោ
បស្សាមិ វោហំ អត្តានំ ឧទកា ថលមុព្ភតំ ។
(១១៨៤)វាយមេថេវ បុរិសោ ន និព្វិន្ទេយ្យ បណ្ឌិតោ
បស្សាមិ វោហំ អត្តានំ យថា ឥច្ឆឹ តថា អហុ ។
(១១៨៥)វាយមេថេវ បុរិសោ ន និព្វិន្ទេយ្យ បណ្ឌិតោ
បស្សាមិ វោហំ អត្តានំ ឧទកា ថលមុព្ភតំ ។
(១១៨៦) ទុក្ខូបនីតោបិ នរោ សបញ្ញោ
អាសំ ន ឆិន្ទេយ្យ សុខាគមាយ
ពហូ ហិ ផស្សា អហិតា ហិតា ច
អវិតក្កិតា មច្ចុមុបព្វជន្តិ ។



# សរភជាតក

(១១៨២) (ព្រះបាទព្រហ្មទត្ត បន្លឺឧទានថា) បុរសជាបណ្ឌិត ត្រូវតែប្រាថ្នា មិនគប្បីនឿយណាយទេ តថាគតឃើញខ្លួនសម្រេច ដូចសេចក្តីប្រាថ្នា ។

(១១៨៣) បុរសជាបណ្ឌិត ត្រូវតែប្រាថ្នា មិនគប្បីនឿយណាយទេ តថាគតឃើញខ្លួន ដែលគេស្រង់អំពីទឹក មកលើគោក ។

(១១៨៤) បុរសជាបណ្ឌិត ត្រូវតែព្យាយាម មិនគប្បីនឿយណាយទេ តថាគតឃើញខ្លួន សម្រេចដូចសេចក្តីប្រាថ្នា ។

(១១៨៥) បុរសជាបណ្ឌិត ត្រូវតែព្យាយាម មិនគប្បីនឿយណាយទេ តថាគតឃើញខ្លួន ដែលសរភម្រឹគស្រង់អំពីទឹក មកលើគោក ។

(១១៨៦) នរជនដែលប្រកបដោយប្រាជ្ញា សូម្បីដល់សេចក្តីទុក្ខ ក៏មិនកាត់បង់សេចក្តីប្រាថ្នា ដើម្បីឲ្យបានសុខ ព្រោះថាផស្សៈ(១)ទាំងឡាយ មានច្រើន មិនជាប្រយោជន៍ក៏មាន ជាប្រយោជន៍ក៏មាន ពួកជនអ្នកមិនត្រិះរិះ រមែងចូលទៅរកសេចក្តីស្លាប់ ។

---

១ ផស្សៈ ប្រែថា ការប៉ះពាល់មាន ៤ គឺការប៉ះពាល់នឹងទុក្ខ, សុខ, មរណៈ និងជីវិត ។ ការប៉ះពាល់ទុក្ខនិងមរណៈ មិនជាប្រយោជន៍របស់សត្វ ។ ការប៉ះពាល់សុខ និងជីវិត ជាប្រយោជន៍ ។ អដ្ឋកថាន័យ ។

(១១៥៧) អចិន្តិតម្បិ ភវតិ ចិន្តិតម្បិ វិនស្សតិ
ន ហិ ចិន្តាមយា ភោគា ឥត្ថិយា បុរិសស្ស វា ។

(១១៥៨) សរភំ គិរិទុគ្គស្មិំ យំ ត្វំ អនុសរី បុរេ
អលីនចិត្តស្ស តុវំ(១) វិក្កន្តមនុជីវសិ ។

(១១៥៩) យោ តំ វិទុគ្គា នរកា សមុទ្ធរិ
សិលាយ យោគ្គំ សរភោ ករិត្វា
ទុក្ខូបនីតំ មច្ចុមុខា បមោចយិ
អលីនចិត្តំ តមេវ វទេសិ ។

(១១៦០) កឹ ត្វំ នុ តត្ថេវ តទា អហោសិ
ឧទាហុ តេ កោចិ នំ ឯតទក្ខា
វិវដច្ឆទោ នុសិ សព្វទស្សី
ញាណំ នុ តេ ព្រាហ្មណ ភឹសរូបំ ។

(១១៦១) ន ចេវហំ តត្ថ តទា អហោសឹ
ន ចាបិ មេ កោចិ នំ ឯតទក្ខា
គាថាបទានញ្ច សុភាសិតានំ
អត្ថំ តទានេន្តិ ជនិន្ទ ធីរា ។

១ ម. តំ ។



(១១៥៧) ហេតុដែលយើងមិនបានគិត ក៏ប្រែជាមាន ហេតុដែលយើងបានគិតហើយ ក៏ប្រែជាវិនាសទៅវិញ ភោគៈទាំងឡាយរបស់ស្ត្រីក្តី របស់បុរសក្តី មិនមែនសម្រេចមកពីការគិតឡើយ ។

(១១៥៨) (បុរោហិត ក្រាបបង្គំទូលថា) ពីដើម ព្រះអង្គ ជាប់តាមសរភម្រឹគក្នុងដីដែនភ្នំ ព្រះអង្គបានរស់រវព្រោះផល ដោយសារសេចក្តីក្លាហាន របស់សរភម្រឹគ ដែលមានចិត្តមិនរួញរា ។

(១១៥៩) សរភម្រឹគណា ធ្វើនូវការប្រកាន់ថ្ម បានស្រង់ព្រះអង្គឡើងអំពីរណ្តៅ ដែលមិនងាយឡើងរួច ហើយបានដោះព្រះអង្គ ដែលដល់នូវសេចក្តីទុក្ខ ឲ្យរួចអំពីមាត់សេចក្តីស្លាប់ ព្រះអង្គពណ៌នាសរសើរសរភម្រឹគ ដែលជាសត្វមានចិត្តមិនរួញរានោះឯង ។

(១១៦០) (ព្រះរាជា...) ក្នុងពេលនោះ អ្នកឯងបាននៅក្នុងទីនោះដែរឬ ឬមួយអ្នកណាមួយប្រាប់ដំណើរនោះ ដល់អ្នក ឬក៏អ្នកជាបុគ្គលមានដំបូលគឺកិលេសបើកហើយ ជាអ្នកឃើញហេតុសព្វ ម្នាលព្រាហ្មណ៍ អ្នកមានញាណ ដ៏មានកំឡាំងក្លៀវក្លាឬ ។

(១១៦១) (បុរោហិត...) ក្នុងពេលនោះ ទូលព្រះបង្គំជាខ្ញុំ មិនបាននៅក្នុងទីនោះទេ ទាំងគ្មាននរណាមួយប្រាប់ដំណើរនោះ ដល់ទូលបង្គំជាខ្ញុំឡើយ បពិត្រព្រះជនិន្ទ អ្នកប្រាជ្ញទាំងឡាយ តែងពិចារណាសេចក្តីនៃបទនៃគាថា ទាំងសុភាសិតទាំងឡាយនោះ ។

(១១៦២) អាទាយ បត្តិំ បរវីរិយឃាតិំ
ចាបេ សរំ កឹ វិចិកិច្ឆសេ តុវំ
នុណ្ណោ សរោ(១) សរភំ ហន្តុ ខិប្បំ
អន្នំ ហិ ឯតំ វរបញ្ញ រញ្ញោ ។

(១១៦៣) អទ្ធា បជានាមិ អហំបិ ឯតំ
អន្នំ មិគោ ព្រាហ្មណ ខត្តិយស្ស
បុព្វេ កតញ្ច អបចាយមានោ
តស្មា មិគំ សរភំ នោ ហនាមិ ។

(១១៦៤) នេសោ មិគោ មហារាជ អសុរេសោ និសម្បតិ
ឯតំ ហន្ត្វា មនុស្សិន្ទ ភវស្សុ អមរាធិបោ ។

(១១៦៥) សចេ ច រាជ វិចិកិច្ឆសេ តុវំ
ហន្តុំ មិគំ សរភំ សហាយកំ
សបុត្តទារោ នរវីរសេដ្ឋ
គន្ត្វា(២) តុវំ វេតរណិំ យមស្ស ។

១ ម. នុណ្ណោ សរភោ ។ ២ គន្តា តេ ចេតិ អត្ថោ ចាយំ ទិស្សតិ ។



(១១៦២)(ព្រះឥន្ទ្រជ្រែកចូលក្នុងសរីរៈបុរោហិត ហើយទូលថា) ព្រះអង្គភ្ជាប់ព្រះខម្រង់កាំសរ មានស្លាបតន្ទុយ ជាគ្រឿងសម្លាប់បុគ្គលដទៃដោយសេចក្ដីព្យាយាម ភ្ជាប់ព្រះខម្រង់ទៅធ្នូហើយ នៅតែលំអែកអ្វីទៀត ចូរឲ្យព្រះខម្រង់កាំសរ ដែលព្រះអង្គបាញ់ទៅហើយ សំឡាប់សារកម្រឹគឲ្យឆាប់ទៅ បពិត្រមហារាជ មានប្រាជ្ញាដ៏ប្រសើរ ព្រោះសារកម្រឹគនុ៎ះ នឹងបានជាក្រយាស្ងោយ របស់ព្រះរាជា ។

(១១៦៣) ព្រះរាជា...) ម្នាលព្រាហ្មណ៍ យើងដឹងថា សារកម្រឹគនោះ ជាក្រយាស្ងោយរបស់ក្សត្រិយ៍ ពិតមែនហើយ តែយើងគោរពគុណ ដែលសារកម្រឹគ ធ្វើហើយក្នុងកាលមុន ហេតុនោះ យើងមិនសម្លាប់សារកម្រឹគទេ ។

(១១៦៤) (សក្ក...) បពិត្រមហារាជ នុ៎ះមិនមែនជាសារកម្រឹគទេ នុ៎ះជាព្រះឥន្ទ្រជាធំជាងអសុរ បពិត្រព្រះអង្គជាធំជាងមនុស្ស ព្រះអង្គសម្លាប់ព្រះឥន្ទ្រនោះហើយ ចូរបានជាស្ដេចទេវតា ។

(១១៦៥) បពិត្រមហារាជ បើព្រះអង្គ នៅតែលំអែកចិត្តការសម្លាប់សារកម្រឹគ ដែលជាសំឡាញ់ហើយ បពិត្រព្រះអង្គប្រសើរជាងការព្យាយាមជាទីនរជន ព្រះអង្គព្រមទាំងព្រះរាជបុត្រ ព្រះរាជទេវី នឹងធ្លាក់ទៅ ក្នុងវេតរណីនរក នៃព្រះយមរាជ ។

(១១៦៦) កាមំ អហំ ជានបទា ច សព្វេ
បុត្តា ច ទារា ច សហាយសង្ឃា
គច្ឆេមុ តំ បេតរណឹ យមស្ស
ន ត្វេវ ហញ្ញេ មម បាណហេតុ(១) ។

(១១៦៧) អយំ មេ កោ កិច្ឆគតស្ស មយ្ហំ
ឯកស្ស កត្តា វិវនស្មិំ ឃោរេ
តំ តាទិសំ បុព្វកិច្ចំ សរន្តោ
ជានំ មហាព្រហ្មេ កថំ ហនេយ្យំ ។

(១១៦៨) មិត្តាភិរាធី ចិរមេវ ជីវ
រជ្ជំ ឥមំ ធម្មគុណេ បសាស
នារីគណេហិ បរិចារយន្តោ
មោទស្សុ រដ្ឋេ តិទិវេវ វាសវោ ។

(១១៦៩) អក្កោធនោ និច្ចបសន្នចិត្តោ
សព្វាតិថី យាចយោគោ ភវិត្វា(២)
ទត្វា ច ភុត្វា ច យថានុភាវំ
អនិន្ទិតោ សគ្គមុបេហិ ឋានន្តិ ។

សរភជាតកំ ទសមំ ។

---

១ ម. ន ត្វេវ ហញ្ញេ យោ មម បាណទស្សុ ។ ឱ. ន ត្វេវ ហញ្ញេ មម បាណហេតុ យោ ។
២ ម. សព្វាតិថី យាចយោគោ ច ភវិត្វា ។ ឱ. សព្វាតិថី យាចយោគោ វិទិត្វា ។



(១១៦៦) (ព្រះរាជា...) យើងផង ពួកអ្នកជនបទទាំងអស់ផង បុត្រ បុត្រីផង អគ្គមហេសីផង ពួកសំឡាញ់ផង គួរគ្រាន់តែទៅកាន់វេត-រណីនរក នៃព្រះយមរាជ ដោយពិតចុះ យើងមិនត្រូវសម្លាប់សត្វ ដែលឲ្យជីវិតយើងឡើយ ។

(១១៦៧) សរភម្រឹគនេះ ជាអ្នកឲ្យជីវិតដល់យើង ដែលដល់នូវសេចក្តី លំបាកម្នាក់ឯង ក្នុងព្រៃ ដ៏តក់ស្លុត បពិត្រមហាព្រហ្ម យើងរលឹក ដឹងនូវកិច្ចការខាងដើម ដែលបានធ្វើហើយ គប្បីសម្លាប់ដូចម្តេចបាន ។

(១១៦៨) (សក្កៈ...) សូមព្រះអង្គ ជាអ្នកញុំាងមិត្រឲ្យត្រេកអរ គង់ ព្រះជន្មរស់កាលយូរអង្វែង សូមព្រះអង្គសោយរាជសម្បត្តិនេះ ក្នុងធម្មគុណ សូមឲ្យមានពួកនាងនារីហែហមរោម ហើយត្រេកអរ ក្នុងដែនរបស់ព្រះអង្គចុះ ដូចជាវាសវៈត្រេកអរ ក្នុងឋានត្រៃត្រឹង្ស ។

(១១៦៩) ព្រះអង្គជាបុគ្គលមិនក្រោធ មានព្រះទ័យជ្រះថ្លាជានិច្ច យក សមណព្រាហ្មណ៍ ប្រកបដោយធម៌ទាំងអស់ ជាភ្ញៀវ ព្រះអង្គគួរ តែសូមបាន ឲ្យទាននឹងប្រើប្រាស់ខ្លួនឯង តាមសមគួរ សត្វ លោកមិនតិះដៀលបាន សូមព្រះអង្គទៅកើត ក្នុងឋានសួគ៌ចុះ ។

ចប់ សរភជាតក ទី ១០ ។

## តស្សុទ្ទានំ

វរមម្ពុ ផន្ទុហរិ សហំសវរោ
អថវញ្ញស្មិំ ទូតកបញ្ចមកោ
អថ ពោធិ អកិត្តិ សុតក្ការិយា
អថ រុរុមិគេន បរេ សរភោ ៗ

វីសតិនិបាតំ និដ្ឋិតំ ។

---



## ឧទ្ទាននៃវីសតិនិបាតនោះគឺ

និយាយអំពីស្វាយដ៏ប្រសើរ ១ ដីទ ១ ហង្សដ៏ប្រសើរ ១ ការនៅក្នុងព្រៃ ១ ទូតជាគំរប់ ៥ កាលិង្គពោធិព្រឹក្ស ១ អកិត្តិតាបស ១ តក្ការិយបុរោហិត ១ ម្រឹគមាស ១ សរភម្រឹគ ១ ៗ

ចប់ វីសតិនិបាត ។

---